ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

# ក្រមច្បាប់និងបទប្បញ្ញត្តិអនុវត្ត
# ចំពោះ
# គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ



បច្ចុប្បន្នកម្ម ឆ្នាំ ២០១១

ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

# ក្រមបទប្បញ្ញត្តិអនុវត្តចំពោះ
# គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

បច្ចុប្បន្នកម្ម ឆ្នាំ ២០១១



## អារម្ភកថា

វិស័យធនាគារ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ព្រោះវិស័យនេះ អាចគៀងគរធនធានហិរញ្ញវត្ថុ ដែលទំនេរសម្រាប់បម្រើឱ្យតម្រូវការក្នុងផលិតកម្ម និងអាជីវកម្ម ។ ដើម្បីផ្សារភ្ជាប់ការសន្សំជាមួយការវិនិយោគ និងកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យធនាគារត្រូវតែដើរទន្ទឹមគ្នាជាមួយការអភិវឌ្ឍវិស័យឯកជន សម្រាប់ទ្រទ្រង់ដល់ការបង្កើនល្បឿនកំណើនសេដ្ឋកិច្ចដែលត្រូវបានចាត់ទុកថា ជាមធ្យោបាយចម្បងសម្រាប់ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ចាប់តាំងពីទស្សវត្តឆ្នាំ១៩៩០ ក្របខ័ណ្ឌបទប្បញ្ញត្តិចំពោះវិស័យធនាគារត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ។ ក្នុងរយៈពេលនោះ ប្រកាស បទបញ្ជា សារាចរណែនាំផ្សេងៗត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារអនុវត្ត ដើម្បីសម្រួលឱ្យដំណើរការវិស័យនេះ ប្រព្រឹត្តទៅដោយរលូន ។ ជាលទ្ធផល ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យធនាគារ និងហិរញ្ញវត្ថុមានការរីកចំរើនយ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងតាមរយៈអន្តរការិយកម្មធនាគារ ដែលបានគៀងគរធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រវិស័យផលិតកម្ម និងសេវាកម្ម ។ នេះបញ្ជាក់ឱ្យឃើញថា ជំនឿទុកចិត្តរបស់សាធារណជនចំពោះវិស័យធនាគារនៅកម្ពុជា មានការកើនឡើងជាបន្តបន្ទាប់ ។

ធនាគារជាតិនៃកម្ពុជា យល់ឃើញថា ការរៀបចំចងក្រងឯកសារច្បាប់នេះឡើង មានសារៈសំខាន់ណាស់សំរាប់ធនាគារិក សវនករ និស្សិត និងអ្នកវិនិយោគដែលមានបំណងចង់ស្វែងយល់ពីក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៃវិស័យធនាគារនៅកម្ពុជាដែលមានលក្ខណៈប្រមូលផ្តុំ និងគ្រប់ជ្រុងជ្រោយ ។ សៀវភៅកម្រងឯកសារច្បាប់សំរាប់គ្រប់គ្រងវិស័យធនាគារនៅកម្ពុជា ត្រូវបានប្រមូលផ្តុំទៅតាមផ្នែកនូវរាល់ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តកន្លងមក ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ដើម្បីឱ្យស្របទៅតាមការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា សៀវភៅកម្រងឯកសារច្បាប់សំរាប់គ្រប់គ្រងវិស័យធនាគារនៅកម្ពុជា ពិតជាផ្តល់នូវផលប្រយោជន៍ជាអតិបរមា ចំពោះធនាគារិក សវនករ និស្សិត និងវិនិយោគិន ក្នុងការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះក្រុមការងារដែលបានខិតខំរៀបចំចងក្រងឯកសារនេះឡើង ។

**ទេសាភិបាល**

ជា ចាន់តូ

# Foreword

The banking sector in Cambodia is playing an important role in contributing to economic development through the mobilization and allocation of previously unproductive financial resources to fulfill the financial needs of the manufactureing and services sectors.

Matching savings to investment and economic growth, the banking sector must develop in line with private sector development in order to sustain the economic growth, pace, a measure regarded by Royal Government of Cambodia as essential for poverty reduction.

Since the 1990s, a legal framwork for the banking sector has been established. At that time Prakas, directives, cuculars and regulations were issued to facilitate the smooth functioning of this sector. As a result, in recent years the banking and financial sectors have developed rapidly, reflected through the banking intermediation of mobilizing financial resources to support the manufacturing and services sectors. This is clear evidence of the subsequent increase of public confidence in Cambodia's banking and financial sectors.

We at the National Bank of Cambodia understand that a compilation of these regulations is essential for bankers, auditors, students and investors who are willing to get a better understanding of the comprehensive and centralized legal framework and regulations for Cambodia's banking sector. As for the evolution of the banking sector, all laws and regulations have been issued and updated by the National Bank of Cambodia into the textbook of Laws and Regulations Applicable to banks and Financial Institutions.

I hope and believe that the Laws and Regulations Applicable to banks and Financial Institutions textbook truly provides considerable benefits to bankers, auditors, students, and investors in their research studies aimed at a better understanding of legal framework and regulations of the banking sector in Cambodia

I would like to thank the working team for their hard work in compiling this textbook.

**The Governor**
**Chea Chanto**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "កម្រងច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ត្រូវបានរៀបចំឡើងតាមគំនិតផ្តួចផ្តើមរបស់លោក Michel DABADIE អតីតជំនាញការប្រចាំនៅធនាគារជាតិនៃកម្ពុជា ដោយមានការគាំទ្រដោយ លោកស្រី **ជា សិរី** អគ្គនាយករងនៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី **ជា សិរី** អគ្គនាយករងនៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលបានផ្តល់ការណែនាំជាប្រចាំដល់ក្រុមការងារនៃនាយកដ្ឋាននីតិកម្ម និងសូមថ្លែងអំណរគុណចំពោះមន្ត្រីបុគ្គលិកនៃនាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការរៀបចំសៀវភៅនេះសម្រេចបានជាស្ថាពរ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

**នាយកដ្ឋាននីតិកម្ម**

# កំណត់សំគាល់

អត្ថបទដែលភ្ជាប់មកនេះមានគោលបំណងបង្ហាញពីបច្ចុប្បន្នកម្មកម្រងខ្លឹមសារនៃច្បាប់ និងបទប្បញ្ញត្តិ ដែលនៅជាធរមានទាំងឡាយទាក់ទងនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គិតត្រឹមឆ្នាំ២០១១។ ក្នុងករណីមានភាពមិនស្របគ្នាណាមួយកើតឡើង ខ្លឹមសារនៅក្នុងអត្ថបទដើមមានអាទិភាពលើខ្លឹមសារ ដែលមាននៅក្នុងសៀវភៅនេះ។

រាល់ការបកប្រែនៅក្នុងសៀវភៅនេះមិនមានលក្ខណៈជាផ្លូវការទេ។

ប្រសិនបើលោកអ្នករកឃើញកំហុសណាមួយនៅក្នុងសៀវភៅនេះ សូមលោកអ្នកទំនាក់ទំនងមកយើងខ្ញុំ តាមរយៈ៖

នាយកដ្ឋាននីតិកម្ម: banlim@nbc.org.kh

# មាតិកា

**អារម្ភកថា**

## ក. ច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ


| | ទំព័រ |
|---|---|
| - ច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា(១៩៩៦) | ១ |
| - ច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា(២០០៦) | ២៨ |
| - ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់(១៩៩៧) | ៣៣ |
| - ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ(១៩៩៩) | ៤២ |
| - ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់(២០០៥) | ៧៧ |
| - ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម(២០០៥) | ២០៤ |
| - ច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម(២០០៧) | ៣១៩ |
| - ច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ(២០០៩) | ៣៤២ |


## ខ- បទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌផ្តល់អាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ


| | | |
|---|---|---|
| • ធ៧-៩៧-១៤៧ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ | ប្រកាសស្តីពី លក្ខខណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ៣៥៨ |
| • ធ៧-០៨-១៩៣ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ | ប្រកាសស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារ | ៣៦២ |
| • ធ៩-០៩-២៣០ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ | ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់ | ៣៦៤ |
| • ធ៩-០៩-២៦២ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ | ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ | ៣៧៤ |

- ធ៧-០០-០៤ ថ្ងៃទី១០ ខែកមរា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ — ៣៧៦
- ធ៧-០០-០៥ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ — ៣៩៥
- ធ៧-០០-០៦ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ — ៤១០
- ធ៧-០២-៤៩ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ — ប្រកាសស្តីពី កាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុនិងការសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ — ៤២៦
- ធ៧-០៦-២០៩ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ — ប្រកាសស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ — ៤២៨
- ធ៧-០៧-១៦៣ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ — ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ — ៤២៩
- ធ៧-០១-១៣៦ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ — ប្រកាសស្តីពី ប្រាក់តំកល់ធានាលើដើមទុន — ៤៣១
- ធ៧-០៤-២០៥ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ — ប្រកាសស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ — ៤៣៣
- ធ៧-០៩-០១២ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ — ប្រកាសស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ — ៤៣៥
- ធ៧-០១-១៨៧ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ — ប្រកាសស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ — ៤៣៦
- ធ៧-០១០-០០១ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ — សារាចរណែនាំស្តីពី ការកំណត់ចំណាត់ថ្នាក់វិនិយោគ — ៤៣៨

- ធ៩-០១០-១៥១ ប្រកាសស្តីពី អ្នកដំណើរការគតិយភាគី ៤៤១
ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០


## គ- បទប្បញ្ញត្តិអនុវត្តចំពោះធនាគារពាណិជ្ជ និង ធនាគារឯកទេស

### បទប្បញ្ញត្តិប្រុងប្រយ័ត្ន


- ធ៧-០០-៤៦ ប្រកាសស្តីពី អនុបាតសាធនភាពរបស់ធនាគារ ៤៥២
ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០
- ធ៧-០១-១៣៧ ប្រកាសស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ ៤៥៦
ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១
- ធ៧-០៦-២២៦ ប្រកាសស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៤៥៨
ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦
- ធ៧-០៩-២១៦ ប្រកាសស្តីពី ការផ្តល់របាយការណ៍ឥណទានធំ និងពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ ៤៦១
ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩
- ធ៧-០១-១៨៦ ប្រកាសស្តីពី អចលនទ្រព្យរបស់ធនាគារ ៤៦៥
ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១
- ធ៧-០០-៣៨ ប្រកាសស្តីពី សាច់ប្រាក់ងាយស្រួលរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ៤៦៦
ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០
- ធ៩-៩៨-៤១៤ ប្រកាសស្តីពី ប្រភពទុនជាប្រាក់បញ្ញើសំរាប់ប្រើប្រាស់ក្នុងស្រុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៦៩
ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨
- ធ៧-០៩-០៧៤ ប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៧១
ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩
- ធ៧-០៩-០២០ ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ៤៨២
ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩

- ធ៧-០៩-០៧៥ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ — ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៨៣
- ធ៧-០១០-១៨២ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ — ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ ៥០១
- ធ៧-០១១-០០១ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ — សារាចរស្តីពីការអនុវត្តប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ៥០៥

**វិធានគណនេយ្យ និង របាយការណ៍**

- ធ៧-០២-២១៨ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២ — ប្រកាសស្តីពី ការដាក់អោយអនុវត្តប្លង់គណនីសំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៥០៩
- ធ៧-០៣-០១ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣ — សារាចរណែនាំស្តីពី ការធ្វើបង្គរ និងរំលស់ប្រចាំថ្ងៃសំរាប់ធនាគារពាណិជ្ជ និងធនាគារឯកទេស ៥១០
- ធ៧-០៤-២០៤ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ — ប្រកាសស្តីពី ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៥១១
- ធ៧-០៥-០៣ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥ — សារាចរណែនាំស្តីពី អនុវត្តន៍គណនេយ្យរូបិយវត្ថុចំរុះតាមប្លង់គណនីឯកភាព ៥២៩
- ធ៧-៩៥-០៤ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៥ — ការធ្វើរបាយការណ៍សរុបទ្រព្យសកម្មនិងទ្រព្យអកម្មនៅលើថាសទន់ ៥៣២
- ធ៦-០៣-០១២ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣ — ប្រកាសស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ ៥៣៣
- ធ៧-០៦-២១១ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ — ប្រកាសស្តីពី កាលបរិច្ឆេទធ្វើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស ៥៨៧

**បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត**


- ធ៥-០១-២០១ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១ ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់ជាគោលសំរាប់បុនហិរញ្ញប្បទាន ៥៨៩
- ធ៧-០៣-០០២ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ សារាចរណែនាំស្តីពី ការផ្តល់និងការថតចំលងឯកសារនៅពេលត្រួតពិនិត្យដល់ទីកន្លែង ៥៩០
- ធ៧-០៤-០៣៧ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ ប្រកាសស្តីពី ការទូទាត់សងជាមុននូវប្រាក់ថ្លៃជួលនិងភតិសន្យា ៥៩១
- ធ៧-០៤-០០៦ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤ ប្រកាសស្តីពី ការទូទាត់ភាគលាភជាមុន ៥៩៣
- ធ៧-០៩-០១៣ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ប្រកាសស្តីពី ការផ្តល់ឥណទានវិបារូបន៍ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ៥៩៤


**ឃ- បទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

**បទប្បញ្ញត្តិប្រុងប្រយ័ត្ន**


- ធ៧-០១-១១៥ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១ ប្រកាសស្តីពី ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ ៦០២
- ធ៧-០២-១៨៦ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើឥណទានអនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦០៣
- ធ៧-០២-៤៨ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ប្រកាសស្តីពី អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦០៥
- ធ៧-០២-៤៥ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ប្រកាសស្តីពី ការរក្សាប្រាក់បំរុងកាតព្វកិច្ចចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦០៦
- ធ៧-០៧-១៣៣ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ប្រកាសស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦០៨

• ធ៧-០៧-១៣២ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦១០

**វិធានគណនេយ្យ និង របាយការណ៍**

• ធ៧-០២-២១៩ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២ ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តប្លង់គណនីសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦១៣

• ធ៧-០២-៤៧ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ប្រកាសស្តីពី គំរូវការរបាយការណ៍សំរាប់ប្រតិបត្តិករគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ៦១៤

• ធ៧-០៦-២១២ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ប្រកាសស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦១៦

**ខ. បទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

**បទប្បញ្ញត្តិប្រុងប្រយ័ត្នអនុវត្ត**

• ធ៧-០២-២០៣ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២ ប្រកាសស្តីពី នីតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦១៨

• ធ៧-០៧-១៣៤ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ប្រកាសស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦២២

• ធ៧-០១១-២៤៣ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ប្រកាសស្តីពី តម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៦២៥

**អភិបាលកិច្ច ស្តងការគណនី ការត្រួតពិនិត្យផ្ទៃក្នុង និង ការប្រឆាំងការសំអាតប្រាក់**

• ធ៧-០៤-០៣៨ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ ប្រកាសស្តីពី កាតព្វកិច្ចអនុវត្តតាមខ្លឹមសារនិងការពិត ៦២៨

• ធ៧-០៥-០៥៤ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ប្រកាសស្តីពី គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន ៦៣០

• ធ៧-០៥-០២ សារាចរណែនាំស្តីពី ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាពនៅតាមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៦៣១
ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥

• ធ៧-០៨-២១១ ប្រកាសស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦៣៤
ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨

• ធ៧-០៨-២១២ ប្រកាសស្តីពី លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ៦៤៣
ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨

• ធ៧-០១០-១៧២ ប្រកាសស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦៥០
ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០

• ធ៧-០១០-០០២ សារាចរណែនាំស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៦៧៣
ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០

• ធ៧-០៨-០៨៩ ប្រកាសស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៦៧៤
ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨

## វិធានគណនេយ្យ និង ព័ត៌មានឥណទាន

• ធ៧-០០-៥០ ប្រកាសស្តីពី ដំណើរការគណនេយ្យកម្មសំរាប់ប្រតិបត្តិការរូបិយប័ណ្ណ ៦៩៨
ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០

• ធ៧-០៧-១៦៤ ប្រកាសស្តីពី ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សំរាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ៧០២
ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

• ធ៧-០១១-១៤៥ ប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន ៧០៣
ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១

## បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

• ធ៧-០២-២២០ ប្រកាសស្តីពី ប្រតិបត្តិការលើមូលប័ត្ររបស់ធនាគារដែលមានអាជ្ញាប័ណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៧២៣
ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

- ធ៧-០១១-០៨២ ប្រកាសស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ៧២៥
ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

- ធ៥-០៩-២២៩ ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ ៧២៨
ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

- ធ៥-០១០-១៨៣ ប្រកាសស្តីពី ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា ៧៣១
ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

- ធ៥-០៣-០០៧ ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ៧៣៧
ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣

- ធ៥-០៩-០១១ ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ប្រាក់បញ្ញើទុនបំរុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុន ជារូបិយប័ណ្ណដុល្លារអាមេរិក ៧៣៨
ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

- ធ៧-០៩-២១៣ ប្រកាសស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ៧៣៩
ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩


## ច- ប្រព័ន្ធទូទាត់ ផាត់ទាត់ និង ផ្ទេរប្រាក់


- ធ៩-៩៨-៤១១ ប្រកាសស្តីពី ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ តាមរយៈធនាគារជាតិនៃកម្ពុជា ៧៤០
ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨

- ធ៥-០០-១៥០ ប្រកាសស្តីពី សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិក ៧៤១
ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

- ធ៥-០០-១៧០ ប្រកាសស្តីពី សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ៧៦១
ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០

- ធ៥-០៣-០១៦ សេចក្តីជូនដំណឹងស្តីពី ការផ្ទេរទៅ-មក ខេត្ត-ក្រុង និងការកំណត់កំរៃសេវា ៧៨០
ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៣

| | | |
|---|---|---|
| • ធ៩-០៦-២៣៤<br>ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦ | ប្រកាសស្តីពី ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ | ៧៨៣ |
| • ធ៩-០៦-២៣៥<br>ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦ | ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ៧៩០ |
| • ធ៩-០៦-២៤០<br>ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ | ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ | ៨០២ |
| • ធ៩-០៨-១៨៦<br>ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ | ប្រកាសស្តីពី មូលប្បទានប័ត្រស្តង់ដារ | ៨០៨ |
| • ធ៩-០៨-១៨៧<br>ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ | ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ៨២០ |
| • ធ៥-០៩-២២៨<br>ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ | ប្រកាសស្តីពី ការដាក់ឲ្យប្រើប្រាស់មូលប័ត្រស្តង់ដារ របស់ធនាគារជាតិនៃកម្ពុជា | ៨២៤ |
| • ធ៩-០១០-១៥០<br>ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ | ប្រកាសស្តីពី ការដាក់ឲ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ៨២៦ |
| • ធ៥-០៩-៦៣៨<br>ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ | សេចក្តីជូនដំណឹងស្តីពី ការកំណត់កម្រៃសេវាផ្ទេរប្រាក់ទៅ-មកក្នុងប្រទេស តាមរយៈធនាគារជាតិនៃកម្ពុជា | ៨៣០ |
| • ធ៥-០៩-៨៦០<br>ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ | សេចក្តីជូនដំណឹងស្តីពី ការបង់កម្រៃសេវាផាត់ទាត់ប្រចាំឆ្នាំរបស់សមាជិកសភាផាត់ទាត់នៅធនាគារជាតិនៃកម្ពុជា | ៨៣១ |
| • ធ៥-០១០-៤៨៦<br>ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ | សេចក្តីជូនដំណឹងស្តីពី ការយកកម្រៃសេវាផាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត | ៨៣២ |
| • ធ៥-០១១-១៣៦<br>ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១ | សេចក្តីជូនដំណឹងស្តីពី ការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត | ៨៣៣ |
| • ធ៥-០១១-០២៨៩<br>ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ | សេចក្តីជូនដំណឹងបន្ថែមលើ ការស្នើសុំផ្ទេរប្រាក់ទៅក្រៅប្រទេស តាមរយៈធនាគារជាតិនៃកម្ពុជា | ៨៣៤ |

## ឆ. អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

- ធ៧-០១១-២៤១ អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ៨៣៥

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

- ធ៧-០១១-២៤២ ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ៨៣៧

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

## ឧបសម្ព័ន្ធ

- តារាងនៃបទប្បញ្ញត្តិត្រូវបាននិរាករណ៍
- តារាងនៃបទប្បញ្ញត្តិត្រូវបានធ្វើវិសោធនកម្មលើបញ្ញត្តិផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅ

# នៃ

# ធនាគារជាតិនៃកម្ពុជា

# ព្រះរាជក្រម

នស/រកម/០១៩៦/២៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

• • • • • • • • •

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងឯកឧត្តម ចៅ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ធនាគារជាតិនៃកម្ពុជាហៅថា "ធនាគារកណ្តាល" គឺជាស្ថាប័នស្វយ័តសាធារណៈមានលក្ខណៈជាពាណិជ្ជកម្មនិងឧស្សាហកម្ម ។

**មាត្រា ២.-**

ធនាគារកណ្តាលជានីតិបុគ្គលមានសមត្ថភាពគតិយុត្តិពេញលេញនិងជាអាទិ៍មានសមត្ថភាពក្នុងការ :

១-ឱ្យប្រាក់គេខ្ចី ខ្ចីប្រាក់ពីគេនិងចុះកិច្ចសន្យាផ្សេងៗទៀត ។

២-ប្តឹងនិងការពារនៅមុខតុលាការ ។

៣-ធ្វើលទ្ធកម្ម កាន់កាប់និងផ្ទេរចេញនូវចលនទ្រព្យនិងអចលនទ្រព្យ ក្នុងគោលដៅនៃការប្រកបអាជីវកម្មរបស់ខ្លួន ។

**មាត្រា ៣.-**

ធនាគារកណ្តាលមានបេសកកម្មចំបងគឺកំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថេរភាពសំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន ។

**មាត្រា ៤.-**

ធនាគារកណ្តាលមានសិទ្ធិចេញប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទៀត ដើម្បីបំពេញបេសកកម្មរបស់ខ្លួននិងដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ។

**មាត្រា ៥.-**

ធនាគារកណ្តាលត្រូវចេញផ្សាយជាប្រក្រតីនូវគោលដៅនយោបាយរូបិយវត្ថុ (រូបិយវត្ថុ ឥណទាន ការប្តូរប្រាក់ អត្រាការប្រាក់) និងស្ថិតិទាក់ទងជាអាទិ៍ដល់បរិមាណរូបិយវត្ថុ ថ្លៃ ឥណទាន ជញ្ជីងទូទាត់និងការប្តូរប្រាក់ ។

**មាត្រា ៦.-**

ទីស្នាក់ការដើមធនាគារកណ្តាលត្រូវតាំងនៅរាជធានីភ្នំពេញ ។ ធនាគារកណ្តាលអាចបើក សាខា ទីភ្នាក់ងារក្នុងប្រទេសនិងការិយាល័យតំណាងនៅឯបរទេស ក្រោយពីមានការយល់ព្រមពីក្រុម ប្រឹក្សាភិបាលនៃធនាគារកណ្តាល ។

## ជំពូកទី ២
## មុខងារនិងភារកិច្ចទូទៅ

**មាត្រា ៧.-**

ធនាគារកណ្តាលមានមុខងារនិងភារកិច្ចដូចតទៅ :

១-កំណត់គោលដៅនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។

២-ត្រិះរិះរក អនុវត្តនិងត្រួតពិនិត្យនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ឱ្យសំរេចទៅតាមគោលដៅដែល បានកំណត់ ។

៣-ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផល ហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាល ។

៤-ផ្តល់ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀត ដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបទបញ្ញានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ ។

៥-ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជានិងកែលំអប្រសិទ្ធិភាពនៃការទូទាត់អន្តរ-ធនាគារ ។

៦-ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ទទួលខុសត្រូវនិងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈ ក្នុងកិច្ចការធនាគារ គណនានរូបិយវត្ថុ ។

៨-តម្កើងតារាងជញ្ជីងទូទាត់ ។

៩-ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទានបរទេសជាមួយប្រទេសក្រៅ ។

១០-ចូលរួមក្នុងការបង្កើតនិងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុ ។

១១-ផ្តល់ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ហារឹមប័ណ្ណ ត្បូងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ។

១២-កំណត់អត្រាការប្រាក់ ។

**មាត្រា ៨.-**

ធនាគារកណ្តាលអាចបើកគណនីឱ្យ :

-ស្ថាប័នរដ្ឋឬអង្គភាពរដ្ឋបាលកណ្តាល ដូចជារតនាគារជាតិជាដើម

-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារកណ្តាលឱ្យធ្វើអាជីវកម្ម

-ធនាគារកណ្តាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ។

ធនាគារកណ្តាលមិនអាចបើកគណនីឱ្យសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ ។

# ជំពូកទី ៣

## ស្វ័យភាពនៃធនាគារកណ្តាល

**មាត្រា ៩.-**

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន ធនាគារកណ្តាលក្នុងឋានៈជាអ្នកទទួលនូវសិទ្ធិអចិន្ត្រៃយ៍ពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការគ្រប់គ្រង តែត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តភារកិច្ចនិងលទ្ធផលដែលសំរេចបាន ជូនរដ្ឋសភានិងរាជរដ្ឋាភិបាល ។

ទេសាភិបាលនៃធនាគារកណ្តាលអាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី តាមការអញ្ជើញរបស់រាជរដ្ឋាភិបាល ។ រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលនៃធនាគារកណ្តាល តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលនេះ។

តាមសំណើរបស់រដ្ឋសភា ទេសាភិបាលឬសមាជិកក្រុមប្រឹក្សាភិបាលត្រូវបំភ្លឺអំពីនយោបាយនៃធនាគារកណ្តាលឬអត្ថាធិប្បាយសេចក្តីព្រាងច្បាប់ជូនរដ្ឋសភា ឬគណៈកម្មការជំនាញនៃរដ្ឋសភា ។

**មាត្រា ១០.-**

នៅដំណាច់ឆមាសនីមួយៗ ធនាគារកណ្តាលត្រូវដាក់ជូនរដ្ឋសភានិងរាជរដ្ឋាភិបាលនូវរបាយការណ៍ដោយ :

-វាយតម្លៃនូវគោលធំៗនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងរៀបរាប់អំពីនយោបាយរូបិយវត្ថុនិងនយោបាយប្តូរប្រាក់ដែលធនាគារកណ្តាលត្រូវអនុវត្តក្នុងឆមាសបន្ទាប់ឬក្នុងរយៈពេលវែងជាងនេះ ។

-ពិនិត្យឡើងវិញនិងវាយតម្លៃការអនុវត្តនយោបាយរូបិយវត្ថុនិងនយោបាយប្តូរប្រាក់ដែលមានចែងក្នុងរបាយការណ៍ឆមាសមុន ។

**មាត្រា ១១.-**

ក្រៅពីរបាយការណ៍ខាងលើ ធនាគារកណ្តាលត្រូវធ្វើរបាយការណ៍តាមការចាំបាច់របស់រដ្ឋសភានិងរាជរដ្ឋាភិបាល ។

# ជំពូកទី ៤

## ការគ្រប់គ្រងធនាគារកណ្ដាល

**មាត្រា ១២.-**

១-អង្គការគ្រប់គ្រងរបស់ធនាគារកណ្ដាលគឺក្រុមប្រឹក្សាភិបាល ដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវបានដឹកនាំដោយទេសាភិបាល ។ ក្រុមប្រឹក្សានេះមានសមាជិក ៧រូប គឺ ទេសាភិបាល ទេសាភិបាលរង និងសមាជិក ៥រូបទៀត ដែល ១រូបតំណាងប្រមុខរដ្ឋាភិបាល ១រូប តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូបតំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឱ្យ មជ្ឈដ្ឋានឧត្ដមសិក្សា និង ១រូបទៀតតំណាងឱ្យបុគ្គលិកធនាគារកណ្ដាល ។

ក្នុងតំណែងរបស់ខ្លួន ទេសាភិបាលនិងទេសាភិបាលរង មិនអាចជាមន្ត្រីរាជការ មិនអាច ជាទីប្រឹក្សាអង្គភាពសាធារណៈ មិនអាចជាសមាជិករាជរដ្ឋាភិបាលនិងមិនអាចជាសមាជិករដ្ឋសភាទេ ។

លក្ខខណ្ឌខាងលើនេះក៏ត្រូវអនុវត្តចំពោះសមាជិកដទៃទៀតដែរលើកលែងតែតំណាងឱ្យ ប្រមុខរាជរដ្ឋាភិបាលនិងតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងតំណាងមជ្ឈដ្ឋានឧត្ដមសិក្សាដែល ម្នាក់ៗអាចរក្សាលក្ខណៈជាមន្ត្រីរាជការបាន ។

២-ក្រុមប្រឹក្សាមានភារកិច្ចជាអាទិ៍ :

-រៀបចំនយោបាយសំរាប់កិច្ចប្រតិបត្តិការរបស់ធនាគារកណ្ដាល

-ចេញប្រកាស បទបញ្ជា សារាចរ និងសេចក្ដីណែនាំផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការ ធនាគារកណ្ដាល

-ចងក្រងបទបញ្ជាផ្ទៃក្នុង

-តាក់តែងលក្ខន្តិកៈបុគ្គលិក

-បង្កើតនាយកដ្ឋាននានារបស់ធនាគារកណ្ដាល

-បង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យ

-បង្កើតគណៈកម្មការសំរាប់បណ្ដុះបណ្ដាលវិជ្ជាជីវៈនៃបុគ្គលិក ។

៣-ទេសាភិបាលមានតួនាទីជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាលនិងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា លើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន ។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការរបស់ធនាគារកណ្តាល និងមានសិទ្ធិអំណាចធ្វើកិច្ចការទាំងឡាយណាដែលមិនបានកំណត់សំរាប់ក្រុមប្រឹក្សានៅក្នុងច្បាប់នេះឬបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ទេសាភិបាលត្រូវតែងតាំងមន្ត្រី បុគ្គលិកនៃធនាគារកណ្តាលនិងលើកសំណើជូនក្រុមប្រឹក្សាក្នុងការកម្រិតប្រាក់បៀវត្ស ព្រមទាំងប្រាក់បំណាច់ផ្សេងៗចំពោះក្របខ័ណ្ឌជាន់ខ្ពស់ ។

៤-ទេសាភិបាលរងមានសិទ្ធិអំណាច និងបំពេញភារកិច្ចទាំងឡាយដែលទេសាភិបាលកំណត់ឱ្យ ។ ក្នុងករណីអវត្តមានរបស់ទេសាភិបាល ទេសាភិបាលរងជំនួសទេសាភិបាល ។

**មាត្រា ១៣.-**

ទេសាភិបាលនិងទេសាភិបាលរងត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

សមាជិកដទៃទៀតនៃក្រុមប្រឹក្សាត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ឈប់ពីតំណែងដោយអនុក្រឹត្យ ។ សមាជិកទាំងនេះត្រូវបានជ្រើសរើសតាមបញ្ជីរៀបចំដោយទេសាភិបាលដែលមានឈ្មោះ៣នាក់ក្នុងប្រភេទតំណាងនីមួយៗ ។

**មាត្រា ១៤.-**

១-សមាជិកនៃក្រុមប្រឹក្សាត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងមានអាយុមិនលើសពី ៦៥ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសំរាប់រយៈពេល ៤ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបានតែ ១ដងតក់ ។ ចំពោះក្រុមប្រឹក្សាលើកទី១ ដែលបង្កើតតាមច្បាប់នេះលើកលែងតែទេសាភិបាល ទេសាភិបាលរងនិងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២រូប ត្រូវចប់ក្នុងរយៈ ២ឆ្នាំក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២-សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក-ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាលឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬផ្នែកពាណិជ្ជកម្ម ។

ខ-មានសេចក្តីសំរេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ដែលចែងក្នុងមាត្រា ១៥និង១៦នៃច្បាប់នេះ ។

គ-អវត្តមានក្នុងការប្រជុំជាប់ៗគ្នា៤ដង លើកលែងតែមានជម្ងឺនិងក្នុងករណីប្រធានស័ក្តិដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ-លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង-មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានដោយបាត់បង់សមត្ថភាពពលកម្មនិងវិបត្តិស្មារតី ។

ច-ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣-ការប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើយ៉ាងហោចណាស់ ២ខែម្តង ។

៤-សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមានដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥-ទេសាភិបាលនិងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនឹងសមាជិកនៃរាជរដ្ឋាភិបាល ។

**មាត្រា ១៥.-**

១-មិនអនុញ្ញាតឱ្យអ្នកដឹកនាំ បុគ្គលិកឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សារបស់ធនាគារកណ្តាល:

-ទាញយកតាមរយៈធនាគារកណ្តាលនូវផលប្រយោជន៍ទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬផ្នែកផ្សេងៗទៀត

-ទទួលយក ដើម្បីផលប្រយោជន៍ទាំងនេះនូវការណែនាំដែលពាក់ព័ន្ធដល់ភារកិច្ចដែលខ្លួនត្រូវបំពេញដូចមានចែងក្នុងច្បាប់នេះ

-ទទួលធ្វើការងារណាដែលផ្ទុយពីភារកិច្ចរបស់ខ្លួន

-ទទួលអំណោយឬលាភសក្ការៈសំរាប់ខ្លួនឯងផ្ទាល់ឬសំរាប់បុគ្គលជិតស្និទ្ធិជាមួយខ្លួនដែលជាគ្រួសារផ្ទាល់ក្តី ពាណិជ្ជកម្មឬហិរញ្ញវត្ថុក្តីដោយលំអៀងនូវភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ច។

២-សមាជិកទាំងអស់នៃក្រុមប្រឹក្សាត្រូវរាយការណ៍ឱ្យបានសព្វគ្រប់ជូនទៅក្រុមប្រឹក្សាអំពីផលប្រយោជន៍សំខាន់ៗផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬរបរអាជីវកម្មផ្សេងទៀតដែលខ្លួនឬគ្រួសារផ្ទាល់មានដោយចំពោះឬដោយប្រយោល ហើយពុំមានសិទ្ធិបោះឆ្នោតលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ខ្លួនឡើយ ។ ប៉ុន្តែអាចចូលរួមដើម្បីបំពេញចំនួនកូរ៉ុមក្នុងអង្គប្រជុំ ដែលត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦.-**

អ្នកដឹកនាំ បុគ្គលិកនិងសមាជិកនៃក្រុមប្រឹក្សារបស់ធនាគារកណ្តាលមិនត្រូវផ្តល់ឱ្យអ្នកដទៃនូវព័ត៌មានដែលទាក់ទងនឹងការសម្ងាត់វិជ្ជាជីវៈដែលខ្លួនបានទទួលក្នុងពេលបំពេញភារកិច្ចឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលច្បាប់អនុញ្ញាតឬមានការបង្គាប់ពីតុលាការ ។

## ជំពូកទី ៥

## ដើមទុន ការប្រើប្រាស់ប្រាក់ចំណេញនិងទុនបំរុង

**មាត្រា ១៧.-**

១-ធនាគារកណ្តាលត្រូវបានអនុញ្ញាតឱ្យមានដើមទុនដែលកម្រិតដោយអនុក្រឹត្យ ។ ដើមទុននេះអាចកែប្រែបានតាមពេលវេលាចាំបាច់ ។ ដើមទុនទាំងមូលត្រូវបានចុះបញ្ជីនិងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាលនិងមិនអាចផ្ទេរឬដាក់ឱ្យជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

២-នៅពេលដែលទ្រព្យសកម្មពិតក្នុងតារាងតុល្យការរបស់ធនាគារកណ្តាលថយចុះក្រោមចំនួនទ្រព្យអកម្ម រាជរដ្ឋាភិបាលត្រូវប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដើម្បីបំពេញឱនភាពនោះក្នុងកំឡុង ៦០ថ្ងៃ ក្រោយពីពេលចេញផ្សាយតារាងតុល្យការរបស់ធនាគារកណ្តាល ។ មូលប័ត្ររដ្ឋជាប័ណ្ណអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន ។

**មាត្រា ១៨.-**

លទ្ធផលជាមូលដ្ឋាននៃការិយបរិច្ឆេទនីមួយៗរបស់ធនាគារកណ្តាលត្រូវបានគណនា ក្រោយពីបានដកចំណាយប្រតិបត្តិការប្រចាំការិយបរិច្ឆេទនោះនិងក្រោយពីបានដកទុកសំរាប់ .

១-ទាយជ្ជទានដល់គណនីសំវិធានធនសំរាប់ហានិភ័យនិងការស្រុតចុះតម្លៃនិងដល់គណនីរំលស់ទ្រព្យសកម្ម ។

២-សំវិធានធនដល់មូលនិធិសោធនដែលកំណត់ដោយក្រុមប្រឹក្សា ។

៣-ប្រាក់បំរុងទូទៅស្មើនឹង ២០% ( ម្ភៃភាគរយ ) លើលទ្ធផលក្រោយពីដកក្នុងចំណុច ១និង២នៃមាត្រានេះ ។

៤-ប្រាក់បំរុងសំរាប់សងថ្លៃមូលប័ត្រទាំងឡាយដែលធនាគារកណ្តាលបានទទួល ។

៥-មូលនិធិសំរាប់វិនិយោគសម្ភារភាពរបស់ធនាគារកណ្តាលដែលកំណត់ដោយក្រុមប្រឹក្សា។

**មាត្រា ១៩.-**

ប្រាក់ចំណេញសុទ្ធត្រូវបង់ចូលថវិកាជាតិក្រោយពីបានដកចេញ :

- ៥% ( ប្រាំភាគរយ ) សំរាប់រង្វាន់បុគ្គលិកដោយមិនគិតក្រុមប្រឹក្សា ។
- ០.៥% ( សូន្យក្បៀសប្រាំភាគរយ ) សំរាប់សមាជិកក្រុមប្រឹក្សា ។

**មាត្រា ២០.-**

គម្រោងចំណាយទាំងអស់របស់ធនាគារកណ្តាលត្រូវចងក្រងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាហើយផ្ញើជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាដើម្បីជាពត៌មាន ។

## ជំពូកទី ៦

## សមត្ថកិច្ចការផ្ទេរមូលនិធិជាមួយអង្គភាពសាធារណៈ

**មាត្រា ២១.-**

១-ធនាគារកណ្តាលទទួលប្រាក់បញ្ញើផ្ទាល់មុខជារូបិយវត្ថុជាតិពីរតនាគារជាតិ ។ ធនាគារកណ្តាលទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជូសនូវទឹកប្រាក់ដែលរតនាគារជាតិត្រូវចំណាយ ។

ធនាគារកណ្តាលត្រូវកំណត់ជាមួយនឹងគេនាគារជាតិនូវកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលត្រូវអនុវត្ត ។

២-ចំណូលជារូបិយប័ណ្ណរបស់រតនាគារជាតិត្រូវលក់ឱ្យធនាគារកណ្តាល ហើយធនាគារកណ្តាលត្រូវបញ្ចូលទឹកប្រាក់ជារៀលក្នុងគណនីតែមួយរបស់រតនាគារជាតិដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ ។

**មាត្រា ២២.-**

ធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ ។

ធនាគារកណ្តាលមានភារកិច្ចក្នុងការផ្តល់ពត៌មាននិងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយដែលមានអានុភាពក្នុងការធ្វើឱ្យសំរេចគោលដៅនយោបាយនៃហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

១-ធនាគារកណ្តាលត្រូវជួយគ្រប់គ្រងក្នុងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាលឬអង្គភាពសាធារណៈដោយធ្វើប្រតិបត្តិការលើមូលប័ត្រជាអាទិ៍ ជូនយោបល់លើកាលបរិច្ឆេទនៃការបោះផ្សាយមូលប័ត្រនិងជំរុញទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុឱ្យរីកចំរើន ។

២-ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិគាហករបស់រាជរដ្ឋាភិបាលឬរបស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការដូចខាងក្រោមនេះ :

-ការទិញ លក់មូលប័ត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈព្រមទាំងកិច្ចការជាភ្នាក់ងារគណនេយ្យដើម្បីចុះបញ្ជីនិងផ្ទេរនូវមូលប័ត្រនោះ

-ការទូទាត់សងដើមនិងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលប័ត្រទាំងនោះ ។

៣-ធនាគារកណ្តាលត្រូវកំណត់ជាមួយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈ អំពីកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

**មាត្រា ២៤.-**

ធនាគារកណ្តាលមិនត្រូវផ្តល់ឥណទានដោយផ្ទាល់ឬដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលប័ត្រដែលបោះផ្សាយដំបូងឬមូលប័ត្រដែលធានាដោយរាជរដ្ឋាភិបាលឬដោយអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ ។

**មាត្រា ២៥.-**

ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ខែជូនទៅរតនាគារជាតិដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន :

១-រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាលនិងអ្នកខ្ចីដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវសាននិងអត្រាការប្រាក់ ។

២-ប្រតិបត្តិការឥណទានត្រូវធ្វើឱ្យមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដែលអាចធ្វើអន្តរការបាន ។

៣-ចំនួនទឹកប្រាក់សរុបនៃឥណទាននិងមូលប័ត្រដែលមានស្របតាមមាត្រា ២៤នៃច្បាប់នេះក្នុងការិយបរិច្ឆេទនីមួយៗមិនត្រូវឱ្យលើសពី ១០% ( ដប់ភាគរយ ) នៃចំណូលធម្មតានៃថវិកាជាតិក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយ ដោយមិនគិតជំនួយនិងចំណូលពីការលក់ទ្រព្យសម្បត្តិ ។

**មាត្រា ២៦.-**

នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការផ្សារចំហឬកិច្ចប្រតិបត្តិការអប្បហារឬឥណទានជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារកណ្តាលអាចលក់ ទិញ ទទួលឬដាក់បញ្ចាំស្បងនៃមូលប័ត្ររដ្ឋដែលត្រូវបានគេបោះផ្សាយជាសាធារណៈពីមុនមក ហើយដែលត្រូវផុតកំណត់សងក្នុងកំឡុង ៩០ថ្ងៃ ។

**មាត្រា ២៧.-**

ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលត្រូវពិគ្រោះជាមួយធនាគារកណ្តាលសិន មុននិងសំរេចថវិកាជាតិជាស្ថាពរដើម្បីកំណត់នូវចំនួនទឹកប្រាក់ឥណទានសរុបដែលរាជរដ្ឋាភិបាលនិងអង្គភាពសាធារណៈនានាអាចត្រូវការពីធនាគារកណ្តាលក្នុងកម្រិតដូចមានចែងក្នុងមាត្រា ២៥នៃច្បាប់នេះ ។

**មាត្រា ២៨.-**

ធនាគារកណ្តាលចូលរួមក្នុងការគ្រប់គ្រងបំណុលសាធារណៈក្នុងនិងក្រៅប្រទេសដោយរាប់បញ្ចូលទាំងលិខិតធានារ៉ាប់រងចេញជូនឥណទាយកផង ។

# ជំពូកទី ៧
## របបនិងនយោបាយប្តូរប្រាក់

**មាត្រា ២៩.-**

ធនាគារកណ្តាលត្រូវកំណត់និងអនុវត្តរបបនិងនយោបាយប្តូរប្រាក់នៃព្រះរាជាណាចក្រកម្ពុជា ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣០.-**

១-ធនាគារកណ្តាលត្រូវរក្សានិងគ្រប់គ្រងទុនបំរុងផ្លូវការក្រៅប្រទេសដែលរួមមាន :

-មាសរូបិយវត្ថុ

-រូបិយប័ណ្ណដែលមានទ្រង់ទ្រាយជាក្រដាសឬជាកាសនិងសមតុល្យធនាគារនៅបរទេស

-ធនធានជាទុនបំរុងដែលអន្តរជាតិទទួលស្គាល់ជាអាទិ៍មាន :

.រូបិយប័ណ្ណដែលទិញពីមូលនិធិរូបិយវត្ថុអន្តរជាតិយកក្នុងផ្នែកបំរុង

.ធនធានជាសិទ្ធិដកពិសេស អេស.ឌី.អរ ( S.D.R ) របស់ព្រះរាជាណាចក្រកម្ពុជា

-រូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលមានកំណត់ជារូបិយប័ណ្ណហើយត្រូវសងនៅក្រៅប្រទេស

-ប័ណ្ណរតនាគារដែលបោះផ្សាយដោយរដ្ឋាភិបាលបរទេស

-មូលប័ត្រដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។

២-ធនាគារកណ្តាលត្រូវរក្សាទុនបំរុងក្រៅប្រទេសឱ្យនៅកម្រិតគ្រប់គ្រាន់ដើម្បីធានាដល់ប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

៣-កាលណាទុនបំរុងផ្លូវការក្រៅប្រទេសមានការថយចុះឬមានភាពដែលអាចថយចុះដល់កម្រិតខ្វះខាត ធនាគារកណ្តាលត្រូវដាក់ជូនដល់រាជរដ្ឋាភិបាលនូវរបាយការណ៍ស្តីពីមូលហេតុនៃបញ្ហានិងវិធានការដើម្បីកែសម្រួល ។ របាយការណ៍នេះត្រូវធ្វើជាប្រចាំរហូតដល់ស្ថានភាពថយចុះខាងលើត្រូវបានដោះស្រាយរួចជាស្រេច ។

៤-ធនាគារកណ្តាលជាអ្នកទទួលបន្ទុកថែរក្សាធនធានផ្លូវការក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា ហើយមានសិទ្ធិជ្រើសរើសអាណត្តិគាហកដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលឬធនាគារពាណិជ្ជកម្មបរទេសដើម្បីកាន់កាប់ជំនួស ។

**មាត្រា ៣១.-**

១-ធនាគារកណ្តាលត្រូវកំណត់អត្រាប្តូរប្រាក់នៃរូបិយវត្ថុជាតិឱ្យមាននិយតភាព ។ ដូច្នេះធនាគារកណ្តាលមានសិទ្ធិជាអាទិ៍ :

-ធ្វើអាជីវកម្មលើមាសជាកាសឬជាដុំនិងលើលោហៈធាតុឬត្បូងថ្មមានតម្លៃផ្សេងទៀត

-ធ្វើអាជីវកម្មលើរូបិយប័ណ្ណដោយប្រើឧបករណ៍នានាដែលធនាគារិកធ្លាប់ប្រើជាទូទៅ

-ធ្វើអាជីវកម្មលើប័ណ្ណធនាគារឬលើមូលប័ត្រផ្សេងទៀត ដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ

-បើកនិងកាន់កាប់គណនីធនាគារពាណិជ្ជឬស្ថាប័នហិរញ្ញវត្ថុ សាធារណៈអន្តរជាតិនៅឯបរទេស

-បើកនិងកាន់កាប់គណនី និងធ្វើសកម្មភាពជាភ្នាក់ងារឬជាអ្នកទាក់ទងជំនួសមុខធនាគារកណ្តាលបរទេស រដ្ឋាភិបាលបរទេស ទីភ្នាក់ងាររដ្ឋាភិបាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិនានា

-កំណត់អត្រាទិញ លក់រូបិយប័ណ្ណនានា

-កម្រិតស្ថានភាពរូបិយប័ណ្ណនៃធនាគារពាណិជ្ជនិងទីកន្លែងប្តូរប្រាក់ដែលមិនមែនជាធនាគារ

-ចេញបទបញ្ជាដែលពាក់ព័ន្ធលើការប្តូរប្រាក់និងអាជីវកម្មលើមាស លោហៈធាតុនិងត្បូងថ្មមានតម្លៃ

-ប្រកាសអត្រាប្តូររវាងប្រាក់រៀលនិងរូបិយប័ណ្ណផ្សេងៗ

-ចូលរួមក្នុងកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិជំនួសមុខឱ្យរដ្ឋ

២-ធនាគារកណ្តាលមិនអាចផ្តល់ឱ្យអ្នកដទៃនូវលិខិតធានាអត្រាប្តូរប្រាក់ទៅអនាគត ហើយមិនអាចអនុញ្ញាតឬមិនត្រូវប្រើពហុអត្រាឡើយ ។

**មាត្រា ៣២.-**

១-ប្រាក់តម្លៃលើសសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលតម្លៃទ្រព្យសកម្មនិងទ្រព្យអកម្មនៃធនាគារកណ្តាលដែលកត់ត្រាជារូបបិយប័ណ្ណឬឯកតាគណនីឯទៀតក្រៅពីរូបិយវត្ថុជាតិ ត្រូវចុះជាឥណទាននៅក្នុងគណនីទុនបំរុងពិសេស ។

២-ប្រាក់តម្លៃខ្វះសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលដូចខាងលើនេះ ត្រូវកត់ត្រាបញ្ចូលពីសមតុល្យឥណទាយីនៃគណនីទុនបំរុងពិសេស ហើយបើសមតុល្យនោះមានបរិមាណមិនគ្រប់គ្រាន់ដើម្បីទូទាត់ប្រាក់ខ្វះទាំងនោះទេ រតនាគារជាតិត្រូវចេញមូលប័ត្រដែលអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានទៅឱ្យធនាគារកណ្តាលដើម្បីបង្គ្រប់ឱនភាព ។

៣-ទាំងប្រាក់តម្លៃលើសសុទ្ធ ទាំងប្រាក់តម្លៃខ្វះសុទ្ធដែលចែងក្នុងមាត្រានេះមិនត្រូវគិតចូលក្នុងតារាងប្រតិលាភប្រចាំឆ្នាំរបស់ធនាគារកណ្តាលឡើយ ។

៤-រាល់សមតុល្យឥណទាយីក្នុងគណនីទុនបំរុងពិសេស នៅចុងការិយបរិច្ឆេទនៃធនាគារកណ្តាល ត្រូវប្រើសំរាប់សងមូលប័ត្រដែលត្រូវបានបោះផ្សាយដូចមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

៥-សមតុល្យគណនីទុនបំរុងពិសេសនេះមិនត្រូវមានការគ្រមើមតម្រង់ឡើយ លើកលែងតែអនុលោមតាមមាត្រានេះ ។

## ជំពូកទី ៨

## សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**មាត្រា ៣៣.-**

ធនាគារកណ្តាលត្រូវទទួលខុសត្រូវផ្តាច់មុខក្នុងការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀតដូចមានចែងក្នុងមាត្រា ៧នៃច្បាប់នេះដោយ :

១-ចេញប្រកាស បទបញ្ជានិងការណែនាំផ្សេងៗព្រមទាំងចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យសំរេចមុខងារដែលមានចែងក្នុងជំពូកទី២នៃច្បាប់នេះដោយអនុវត្តបទដ្ឋាននៃការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងត្រួតពិនិត្យព្រមទាំងមធ្យោបាយសមស្រប ។

២-ចាត់តាំងបុគ្គលិករបស់ខ្លួនឬបុគ្គលដទៃទៀតដែលមានសមត្ថភាពឱ្យត្រួតពិនិត្យជានិច្ចកាលលើលិខិតស្នាមនិងចុះធ្វើអធិការកិច្ចដល់កន្លែង ព្រមទាំងពិនិត្យបញ្ជី ការចុះបញ្ជីនិងឯកសារផ្សេងៗរបស់គ្រឹះស្ថានទាំងនេះ ។

៣-តម្រូវឱ្យអភិបាលឬបុគ្គលិកគ្រឹះស្ថានទាំងនោះផ្តល់ដល់ធនាគារកណ្តាលនូវពត៌មាននានាសំរាប់ធ្វើការត្រួតពិនិត្យនិងកែតំរូវ ។

៤-ប្តឹងទៅតុលាការឬដាក់កម្មវិបាកតាមច្បាប់ជាធរមាន ប្រសិនបើមានការប្រព្រឹត្តល្មើសដោយគ្រឹះស្ថាន ឬដោយអភិបាលបុគ្គលិករបស់គ្រឹះស្ថាននោះ :

-បំពានបទបញ្ញត្តិនៃច្បាប់ជាធរមាន ឬបទបញ្ជារបស់ធនាគារកណ្តាល

-ការខ្វះខាតក្នុងការបំពេញកាតព្វកិច្ចផ្សេងៗ

-មិនគោរពវិធានការនយោបាយរូបិយវត្ថុឬវិធានការប្រុងប្រយ័ត្ននានាដែលបានកំណត់ ។

**មាត្រា ៣៤.-**

ធនាគារកណ្តាលមានសិទ្ធិបើកគណនីនិងទទួលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្តល់ការប្រាក់និងយកកម្រៃដែលធនាគារកណ្តាលជាអ្នកកំណត់ ។

**មាត្រា ៣៥.-**

១-ធនាគារកណ្តាលចេញបទបញ្ជាដោយផ្សព្វផ្សាយឬជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីតម្រូវឱ្យគ្រឹះស្ថានទាំងនោះតំកល់ទុនបំរុងកាតព្វកិច្ច ។ ទុនបំរុងនេះត្រូវរក្សាជាសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនឬជាប្រាក់បញ្ញើពិសេសក្នុងគណនីចរន្តនៅធនាគារកណ្តាល ។

២-ធនាគារកណ្តាលតម្រូវមេគុណទុនបំរុងដូចគ្នាចំពោះកិច្ចសន្យាសមិស ។ ចំនួនទឹកប្រាក់ទុនបំរុងតម្កល់ទុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយយោលទៅតាមប្រាក់បញ្ញើនិងកិច្ចសន្យាសមិសផ្សេងៗទៀតដែលគ្រឹះស្ថានធ្វើជាមួយអតិថិជន ។

រាល់ការកំណត់ឬការបង្កើនមេគុណទុនបំរុងកាតព្វកិច្ចនឹងចូលជាធរមាន១ខែចាប់ពីពេលដែលគ្រឹះស្ថាននោះបានទទួលដំណឹងជាលាយល័ក្ខណ៍អក្សរ ។

ធនាគារកណ្តាលអាចលើកលែងការតម្កល់ទុនបំរុងជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រភេទខ្លះ

៣-ធនាគារកណ្តាលដាក់ពិន័យដោយយកកម្រៃជើងសាក្នុងមួយថ្ងៃដែលស្មើសស្មើនឹង ១/១០ (មួយភាគដប់) នៃអត្រាបុនហិរញ្ញប្បទានចុងក្រោយរបស់ធនាគារកណ្តាលលើគ្រឹះស្ថានទាំងឡាយណាដែលមិនគោរពទុនបំរុងកាតព្វកិច្ច ។ កម្រៃជើងសាទាំងនេះអាចដកយកពីសមតុល្យនៃគណនីរបស់គ្រឹះស្ថាននោះដែលមានបើកនៅធនាគារកណ្តាល ។

**មាត្រា ៣៦.-**

១-ធនាគារកណ្តាលត្រូវកំណត់បែបបទហើយមិញ លក់ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬធ្វើអប្បហារ បុនប្បហារ កំដូចជាធ្វើកិច្ចប្រតិបត្តិការប៉ង់ស្យុងនូវ :

ក-រូបិយាណត្តិឬប័ណ្ណសងតាមបញ្ជាដែលបោះផ្សាយ ឬធ្វើឡើងសំរាប់ផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្មជាយថាភូតដោយមានហត្ថលេខាសាធនីយពីរយ៉ាងតិច ក្នុងនោះយ៉ាងហោចណាស់ត្រូវមានហត្ថលេខាមួយជារបស់ធនាគារពាណិជ្ជដែលមានកាលវសាន ៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួល កំប៉ុន្តែរូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលចេញឬធ្វើឡើងសំរាប់ហិរញ្ញប្បទាន ផលិតកម្មឬពាណិជ្ជកម្មធញ្ញជាតិ តាមរដូវកាលអាចមានកាលវសាន ២១០ថ្ងៃ គិតពីថ្ងៃចេញផ្សាយ ។

ខ-មូលប័ត្ររដ្ឋដែលបានចេញផ្សាយជាសាធារណៈនិងមានកាលវសាន ៩០ថ្ងៃ គិត គិតពីថ្ងៃដែលបានធ្វើលទ្ធកម្ម ។

គ-មូលប័ត្រឥណទេយ្យឯកជនដែលអាចជួញដូរបានលើទីផ្សាររូបិយវត្ថុព្រមទាំងឥណទេយ្យឯកជនរបស់ធនាគារ ដែលមានហត្ថលេខាសាធនីយនិងដែលមានចុះនៅក្នុងបញ្ជីដោយទទួលស្គាល់ដោយក្រុមប្រឹក្សា ។

ឃ-មូលប័ត្ររបស់ធនាគារកណ្តាលផ្ទាល់ ។

២-ធនាគារកណ្តាលត្រូវកំណត់និងចេញផ្សាយនូវអត្រាអប្បបរមាសំរាប់ធ្វើបុនអប្បហារ បុរេប្រទាន ទទួលប៉ង់ស្យុង ឬឱ្យខ្ចី ។ ធនាគារកណ្តាលអាចកំណត់អត្រានិងពិដានអតិបរមាខុសៗគ្នា សំរាប់ប្រតិបត្តិការ ឬកាលវសានផ្សេងៗគ្នា ។

**មាត្រា ៣៧.-**

ធនាគារកណ្តាលអាចផ្តល់បុរេប្រទានលើគណនីចរន្តដល់ធនាគារពាណិជ្ជដែលធានាដោយ មូលប័ត្ររដ្ឋឬមូលប័ត្រធានាដោយរដ្ឋ ។

**មាត្រា ៣៨.-**

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមការណែនាំជាលាយល័ក្ខណ៍អក្សររបស់ ធនាគារកណ្តាលដែលប្រកាសជារួមឬដោយឡែក ស្តីពីតារាងតុល្យការ ការសន្យាក្រៅតារាងតុល្យការនិង គណនីអាជីវកម្មដែលទាក់ទងទៅនឹង :

-ដើមទុនអប្បបរមា

-ចំនួនទឹកប្រាក់អប្បបរមានៃមូលនិធិសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ទាល់

-ការហាមឃាត់ ការដាក់កម្រិត ល័ក្ខខ័ណ្ឌ បញ្ញត្តិផ្សេងៗ

២-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើសកម្មភាពដូចគ្នានិងមានស្ថានភាពហិរញ្ញវត្ថុដូច គ្នាត្រូវស្ថិតនៅក្រោមបទបញ្ជាដូចគ្នា ។

**មាត្រា ៣៩.-**

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនទៅធនាគារកណ្តាលនូវពត៌មានឬទិន្នន័យ ដែលធនាគារកណ្តាលសុំស្នើដើម្បីបំពេញមុខងាររបស់ខ្លួន ។

២-ក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់វិជ្ជាជីវៈ ធនាគារកណ្តាលអាចបោះពុម្ពផ្សាយទាំងស្រុងឬ មួយផ្នែកនូវពត៌មានទាំងនោះឬទិន្នន័យរួមតាមប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬតាមប្រភេទសកម្ម ភាពរបស់គេ ។

៣-ធនាគារកណ្តាលទទួលរ៉ាប់រងលើកកំពស់សេវាអន្តរធនាគារដូចជាធ្វើមជ្ឈការនៃ ហានិភ័យ និងការមិនសងបំណុលជាដើម ។

មាត្រា ៤០.-

ក្នុងកិច្ចសហប្រតិបត្តិការជាមួយធនាគារពាណិជ្ជ ធនាគារកណ្តាលត្រូវបង្កើតសភាផាត់ទាត់មួយសំរាប់បំរើការទូទាត់អន្តរធនាគារឱ្យឆាប់រហ័សនិងមានប្រសិទ្ធិភាព ។

## ជំពូកទី ៩

## រូបិយវត្ថុ

មាត្រា ៤១.-

ឯកតារូបិយវត្ថុរបស់កម្ពុជាគឺរៀល។ មួយរៀលស្មើនឹងដប់កាក់ មួយកាក់ស្មើនឹងដប់សេន។ សញ្ញាសំគាល់ប្រាក់រៀលគឺអក្សរ (៛) ។

មាត្រា ៤២.-

ធនាគារកណ្តាលមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយក្រដាសប្រាក់និងកាសជារៀល កាក់និងសេន ។

មាត្រា ៤៣.-

១-ក្នុងពេលដែលមិនបានដកចេញពីចរាចរទេនោះ ក្រដាសប្រាក់និងកាសដែលបោះផ្សាយដោយធនាគារកណ្តាលគឺជារូបិយវត្ថុមានតម្លៃនីត្យានុកូលក្នុងព្រះរាជាណាចក្រកម្ពុជានិងមានតេជានុភាពផ្ទេរសេរីកាគ្មានព្រំដែនចំពោះក្រដាសប្រាក់ និងមានព្រំដែនចំពោះកាសក្នុងល័ក្ខខ័ណ្ឌកំណត់ដោយធនាគារកណ្តាល ។

២-ការទូទាត់ណាដែលមានចំនួនទឹកប្រាក់លើសពីការកំណត់របស់ធនាគារកណ្តាលអាចឬត្រូវតែធ្វើតាមលេខនា ។

មាត្រា ៤៤.-

១-ធនាគារកណ្តាលជាអ្នកទទួលបន្ទុកក្នុងការបោះពុម្ពក្រដាសប្រាក់ ចាក់ពុម្ពកាសនិងការងារពាក់ព័ន្ធឯទៀតដូចជាការធានាសន្តិសុខក្នុងការថែរក្សានិងចលនាក្រដាសប្រាក់និងកាសដែលមិនទាន់

បញ្ចេញផ្សាយ ការថានាថែរក្សានិងការបំផ្លាញចោលនៅពេលចាំបាច់នូវបណ្ដាពុម្ពក្រដាស់ប្រាក់និងកាស ដែលដកចេញពីចរាចរ ។

២-ធនាគារកណ្ដាលត្រូវកំណត់ដោយបទបញ្ជានូវលក្ខណៈផ្សេងៗ តម្លៃ ទំហំ ទម្ងន់ តំរូ និងលក្ខណៈរូបភាពផ្សេងៗទៀតរបស់ក្រដាសប្រាក់ដែលត្រូវបោះពុម្ពនិងកាសដែលត្រូវចាក់ពុម្ព ។

**មាត្រា ៤៥.-**

ធនាគារកណ្ដាលមានសិទ្ធិសំរេចប្រកាសប្ដូរ ក្រោយពីមានការយល់ព្រមពីរាជរដ្ឋាភិបាលដើម្បី ដកចេញពីចរាចរនូវក្រដាសប្រាក់និងកាសដែលបានបោះផ្សាយរួចហើយ ។ ធនាគារកណ្ដាលចំណាយសង តាមតម្លៃនៃក្រដាសប្រាក់ឬកាសទាំងនោះ ដោយប្ដូរនឹងក្រដាសប្រាក់ឬកាសផ្សេងទៀតដែលខ្លួនបានបោះ ផ្សាយ ។ សេចក្ដីសំរេចនេះត្រូវមានទម្រង់ជាបទបញ្ជារបស់ធនាគារកណ្ដាលហើយត្រូវបញ្ជាក់ច្បាស់អំពី រយៈពេលនិងទីតាំងដែលត្រូវប្ដូរក្រដាសប្រាក់និងកាសទាំងនោះ ។

**មាត្រា ៤៦.-**

នៅពេលចប់រយៈកាលប្ដូរក្រដាសប្រាក់និងកាសដែលបានចែងក្នុងមាត្រា ៤៥ :

១-ក្រដាសប្រាក់និងកាសប្រមូលចូលដែលបានមកពីការប្ដូរត្រូវតែលែងមានតម្លៃ នីត្យានុកូល ។

២-ចំនួនទឹកប្រាក់ជាក្រដាសនិងជាកាសសរុបដែលបានប្រកាសឱ្យមកប្ដូរតែមិនបាន យកមកប្ដូរ ត្រូវគិតដកចេញពីបរិមាណរូបិយវត្ថុនៅក្នុងចរាចរដែលចុះក្នុងបញ្ជីធនាគារកណ្ដាលហើយត្រូវ ចាត់ទុកជាប្រាក់ចំណូលរបស់ធនាគារកណ្ដាល ។

**មាត្រា ៤៧.-**

បើមានជនណាស្នើសុំប្ដូរក្រដាសប្រាក់ឬកាសដែលធនាគារកណ្ដាលបោះផ្សាយនោះ ធនាគារ កណ្ដាលត្រូវតែប្ដូរឱ្យតាមតម្លៃស្មើដោយគ្មានគិតសោហ៊ុយអ្វីទាំងអស់ ។

**មាត្រា ៤៨.-**

ហាមមិនឱ្យផលិតជាថ្មីឡើងវិញនូវក្រដាសប្រាក់ កាស មូលប្បទានប័ត្រ មូលប័ត្រឬប័ណ្ណ ទូទាត់ផ្សេងៗទោះជារៀល ជាកាក់ ជាសេនក្ដីឬជារូបិយវត្ថុបរទេសក្ដីនិងមិនឱ្យបង្កើតវត្ថុទាំងឡាយណា

ដែលក្រាប់តាមក្រដាសប្រាក់ កាស មូលប្បទានប័ត្រ ប័ណ្ណទូទាត់ផ្សេងៗដោយពុំបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីធនាគារកណ្តាលជាមុននោះទេ ។

**មាត្រា ៤៩.-**

ធនាគារកណ្តាលត្រូវតែគ្រប់គ្រងដោយផ្ទាល់នូវសន្និធិរូបិយវត្ថុបំរុងធ្វើផែនការបោះផ្សាយ និងធានាការផ្តល់ជាទៀងទាត់នូវក្រដាសប្រាក់និងកាស ដើម្បីបំពេញតម្រូវការរូបិយវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាទាំងបរិមាណនិងគុណភាព ។

**មាត្រា ៥០.-**

ធនាគារកណ្តាលត្រូវដកចេញពីចរាចរនូវរូបិយវត្ថុមិនគ្រប់លក្ខណៈប្រើប្រាស់ដើម្បីបំផ្លាញចោលហើយប្តូរថ្មីជំនួសវិញ ។

**មាត្រា ៥១.-**

ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និងកាស បើសិនជារូបភាពវាលែងមានភាពច្បាស់លាស់ បាត់បង់រូបភាពដើមឬធ្លុះធ្លាយឬដែលបាត់បង់ទំហំ ៣០% ( សាមសិបភាគរយ ) ឬលើសពីនេះ ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរហើយបំផ្លាញចោលដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារកណ្តាលអាចយល់ព្រមសងមួយចំណែកឬទាំងអស់ ។

**មាត្រា ៥២.-**

ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនពត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៥៣.-**

ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលឱ្យសង ចំពោះក្រដាសប្រាក់ឬកាសណាដែលខ្លួនធ្វើឱ្យបាត់បង់ឬធ្វើឱ្យអន្តរាយឡើយ ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្លៃនូវក្រដាសប្រាក់ដែលមានការខូចខាតរូបភាពក្រៅ ជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ បោះពុម្ព បោះត្រាឬបិទវត្ថុស្អិតពីលើឬធ្លុះធ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ ។

**មាត្រា ៥៤.-**

បរិមាណក្រដាសប្រាក់និងកាសកំពុងធ្វើចរាចរ ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យអកម្មរបស់ធនាគារកណ្តាលដោយមិនគិតបញ្ចូលនូវបរិមាណក្រដាសប្រាក់និងកាសនៅក្នុងសន្និធិរូបិយវត្ថុបំរុងទេ ។

## ជំពូកទី ១០

## គណនីនិងការពិនិត្យគណនី

**មាត្រា ៥៥.-**

ការិយបរិច្ឆេទគណនេយ្យនៃធនាគារកណ្តាល ចាប់ផ្តើមពីថ្ងៃទី០១ខែមករាដល់ថ្ងៃទី៣១ខែធ្នូ ជារៀងរាល់ឆ្នាំ ។

**មាត្រា ៥៦.-**

ធនាគារកណ្តាលត្រូវ :

១-កាន់កាប់បញ្ជីគណនេយ្យនិងបញ្ជីផ្សេងៗទៀតហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែលឆ្លុះបញ្ចាំងដោយប្រាកដប្រជានូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ស្របទៅតាមគោលការណ៍និងបែបបទគណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅសំរាប់ធនាគារកណ្តាល ។

២-រៀបចំនិងចេញផ្សាយរបាយការណ៍សង្ខេបប្រចាំខែស្តីពីស្ថានភាពនៃសកម្មភាពរបស់ខ្លួន។

៣-ដាក់ជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាក្នុងអំឡុង ៦ខែ បន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនីមួយៗនូវច្បាប់ចម្លងនៃគណនីប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍ដែលអាចចេញផ្សាយបាន ស្តីពីប្រតិបត្តិការរបស់ខ្លួននិងស្តីពីស្ថានភាពសេដ្ឋកិច្ចរូបិយវត្ថុក្នុងការិយបរិច្ឆេទកន្លងមក ។

**មាត្រា ៥៧.-**

ការពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល ។

# ជំពូកទី ១១

## បទបញ្ញត្តិផ្សេងៗ

**មាត្រា ៥៨.-**

ធនធាន ទ្រព្យសម្បត្តិ ប្រតិលាភ ប្រតិបត្តិការនិងអាជីវកម្មរបស់ធនាគារកណ្តាលត្រូវបានលើកលែងមិនយកពន្ធនិងអាករឡើយ ។

**មាត្រា ៥៩.-**

ធនាគារកណ្តាលមិនត្រូវចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងសហគ្រាសដែលមានលក្ខណៈឧស្សាហកម្មឬពាណិជ្ជកម្មឡើយ លើកលែងតែគ្រឹះស្ថានដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយសកម្មភាពរបស់ធនាគារកណ្តាល ដូចជាការវាយតម្លៃនិងការពិនិត្យកិច្ចសន្យាធានា ប្រព្រឹត្តកម្មនិងការបញ្ជូនទិន្នន័យ ការបោះពុម្ពឯកសារហិរញ្ញវត្ថុ ការផាត់ទាត់សងគ្នា ការបញ្ជូនសារលិខិតឬការជម្រះបញ្ជីទ្រព្យសម្បត្តិក្នុងលក្ខខ័ណ្ឌដែលទឹកប្រាក់ចូលហ៊ុនទាំងអស់នោះមិនលើសពី ៥% ( ប្រាំភាគរយ ) នៃមូលនិធិរបស់ខ្លួនផ្ទាល់ ។

**មាត្រា ៦០.-**

ធនាគារកណ្តាលមិនត្រូវធ្វើលទ្ធកម្មដោយទិញឬដោយភតិសន្យានូវសិទ្ធិពិតប្រាកដលើអចលនទ្រព្យ លើកលែងតែទ្រព្យសម្បត្តិណាដែលចាំបាច់សំរាប់ធ្វើសកម្មភាពនិងមុខងាររបស់ខ្លួនឬសំរាប់ការងារសង្គមកិច្ចចំពោះបុគ្គលិករបស់ខ្លួន ។

បទបញ្ញត្តិនៃមាត្រានេះពុំឃាត់ធនាគារកណ្តាលមិនឱ្យធ្វើលទ្ធកម្មក្នុងក្របខ័ណ្ឌនៃការទូទាត់សងឥណទេយ្យរបស់ខ្លួននូវសិទ្ធិដែលមានចែងក្នុងមាត្រា ៥៩ឬមាត្រានេះទេ ។

**មាត្រា ៦១.-**

រាល់ប្រកាស បទបញ្ជា សារាចរនិងបណ្តាសេចក្តីណែនាំផ្សេងៗដែលចេញដោយធនាគារកណ្តាលសំរាប់អនុវត្តជាទូទៅចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការផ្សព្វផ្សាយក្នុងរាជកិច្ចហើយចូលជាធរមានបញ្ញត្តិចាប់តាំងពីថ្ងៃចេញផ្សាយនោះឬតាមកាលកំណត់ដែលមានចែងក្នុង ប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទាំងនោះ ។

**មាត្រា ៦២.-**

ដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ធនាគារកណ្តាលអាចធ្វើបណ្តឹងខាងផ្នែករដ្ឋប្បវេណីភ្ជាប់ជាមួយផ្នែកព្រហ្មទណ្ឌនូវគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៦៣.-**

ការកម្រិតឥណទាននៅក្នុងចំណុច ៣ មាត្រា ២៥ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះឥណទានណាដែលត្រូវផ្តល់ឱ្យក្រោយថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណាពុំព្រមទទួលយករូបិយវត្ថុដែលមានតម្លៃនីត្យានុកូលនិងមានភេជានុភាពធ្វើសេរីការលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់ដែលពុំព្រមទទួលយកនោះ ។

**មាត្រា ៦៥.-**

អ្នកក្លែងក្រដាសប្រាក់ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើដែនដីនៃរដ្ឋដទៃទៀតនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់អស់មួយជីវិត ។

វត្ថុតាងដែលរឹបអូសបានត្រូវទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

**មាត្រា ៦៦.-**

ជនណាប្រព្រឹត្តដោយចេតនាដោយបញ្ចូលក្នុងចរាចរឬរក្សាទុកសំរាប់ចរាចរនូវក្រដាសប្រាក់ឬកាសក្លែងក្លាយ ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

**មាត្រា ៦៧.-**

ជនណាប្រើប្រាស់ឬរក្សាទុកដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលនូវបណ្តាសម្ភារៈ ឧបករណ៍ គ្រឿងយន្តនិងប្រដាប់សំរាប់ផលិតក្រដាសប្រាក់ឬកាស ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ឯវត្ថុតាងនឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

**មាត្រា ៦៨.-**

ជនណាទទួលក្រដាសប្រាក់ឬកាសដែលក្រោយមកបានដឹងថាជាក្រដាសប្រាក់ឬកាសក្លែងក្លាយហើយនៅតែយកទៅដាក់ឱ្យធ្វើចរាចរវិញ ជននោះត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់នោះ ។

**មាត្រា ៦៩.-**

ដើម្បីអនុវត្តនិងបំពេញមុខងារឱ្យបានល្អតាមច្បាប់នេះ ធនាគារកណ្តាលអាចស្នើសុំពត៌មានដែលខ្លួនត្រូវការពីរូបវន្តបុគ្គលឬនីតិបុគ្គលដែលពាក់ព័ន្ធ រួមទាំងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអង្គភាពក្រោមឱវាទទៀតផង ។

ជនណាដែលមិនព្រមផ្តល់ពត៌មានដែលធនាគារកណ្តាលបានស្នើសុំស្របតាមមាត្រានេះឬដែលមានចេតនាផ្តល់ពត៌មានខុសឬបំភាន់ ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រ ( មួយលានរៀល ) ដល់ ១០.០០០.០០០ រ ( ដប់លានរៀល ) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

**មាត្រា ៧០.-**

ជនណាគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើសកម្មភាពមានលក្ខណៈជាធនាគារដូចជាឥណទាន ជំនួញដើងសារូបិយប័ណ្ណ ការប្តូររូបិយប័ណ្ណ ការទទួលប្រាក់ពីសាធារណជន ការគ្រប់គ្រងមធ្យោបាយទូទាត់ ប្រតិបត្តិការលើមូលប័ត្រ អាជីវកម្មមាស លោហធាតុនិងត្បូងថ្មមានតម្លៃដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលត្រូវបញ្ឈប់សកម្មភាពភ្លាមតាមអធិបញ្ញារបស់ធនាគារកណ្តាល ។ ជនដែលប្រព្រឹត្តល្មើសនឹងអធិបញ្ញានេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រ (មួយលានរៀល)ដល់ ១០.០០០.០០០ រ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧១.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៥ ចំណុច ១ និងមាត្រា ១៦ នឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ ៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

មាត្រា ៧២.-

បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ៣៦ ច.ល.

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃ កម្ពុជា

# ព្រះរាជក្រម

## យើង

នស/រកម/១២០៦/០៣៦

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧
# នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

**មាត្រាមួយ.-**

មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា១៤ .- ថ្មី**

១-សមាជិកនៃក្រុមប្រឹក្សា ត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍ និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានអាយុមិនលើសពី ៦៥ ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសម្រាប់រយៈពេល ៤ ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបាន ។ ចំពោះក្រុមប្រឹក្សាលើកទី ១ ដែលបង្កើតតាមច្បាប់នេះ លើកលែងតែទេសាភិបាល ទេសាភិបាលរង និងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២ រូប ត្រូវចប់ក្នុងរយៈពេល ២ ឆ្នាំ ក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២_សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក_ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាល ឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬ ផ្នែកពាណិជ្ជកម្ម ។

ខ_មានសេចក្តីសម្រេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ ដែលចែងក្នុងមាត្រា ១៥ និង១៦ នៃច្បាប់នេះ ។

គ_អវត្តមានក្នុងការប្រជុំជាប់ៗគ្នា ៤ ដង លើកលែងតែមានជំងឺ និងក្នុងករណីប្រធានស័ក្តិ ដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ_លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង_មិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន ដោយបាត់បង់សមត្ថភាពពលកម្ម និងវិបត្តិស្មារតី ។

ច_ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣_ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើយ៉ាងហោចណាស់ ២ ខែ ម្តង ។

៤_សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃស្យាច់វត្តមាន ដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥_ទេសាភិបាល និងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនឹងសមាជិកនៃរាជរដ្ឋាភិបាល ។

**មាត្រា ៥៧ -- ថ្មី**

ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា-ភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល.០៦១២.៥៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ១៦. ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មករា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងការប្តូរប្រាក់

ជស/រកម/០៨៩៧/០៣

# ព្រះរាជក្រម

យើង

ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំង ឯកឧត្ដម ថៅ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ និងសម្ដេចនាយករដ្ឋមន្ត្រីទី២ និង អំពី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**

ច្បាប់នេះអនុវត្តចំពោះរាល់ប្រតិបត្តិការរូបិយប័ណ្ណនិងជាទូទៅគឺ រាល់ប្រតិបត្តិការដែលប្រព្រឹត្តឡើងរវាងនិវេសជននិងអនិវេសជនទាក់ទងទៅនឹង :

- ការទូទាត់ពាណិជ្ជកម្ម
- ការផ្ទេរប្រាក់ ឬ
- ចលនានៃដើមទុន ដោយរាប់បញ្ចូលទាំងការវិនិយោគផង ។

**មាត្រា ២.**

ត្រូវចាត់ទុកជារូបិយប័ណ្ណ សំរាប់ការអនុវត្តច្បាប់នេះ :

- មធ្យោបាយទូទាត់ឬមូលប័ត្រ ជារូបិយវត្ថុបរទេស
- មាសមិនទាន់កែច្នៃឬលោហធាតុមានតំលៃដទៃទៀតមិនទាន់កែច្នៃនិងត្បូងថ្មមានតំលៃមិនទាន់កែច្នៃ ។

**មាត្រា ៣.**

ត្រូវចាត់ទុកជានិវេសជន :

- រូបវន្តបុគ្គលទាំងឡាយដោយពុំគិតពីសញ្ជាតិ ដែលមានសកម្មភាពចំបងឬមានលំនៅឋានចំបងនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ) ឡើងទៅ វៀរលែងតែមន្ត្រីបរទេស ដែលបំពេញបេសកកម្មការទូតឬបេសកជនប្រហាក់ប្រហែល
- នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសនិងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នីតិបុគ្គលនៃច្បាប់ក្រៅប្រទេស
- គ្រប់មន្ត្រីរាជការខ្មែរបំពេញភារកិច្ចនៅបរទេស ដោយឥតគិតពីរយៈពេលនៃការស្នាក់នៅ ។

**មាត្រា ៤.**

ត្រូវចាត់ទុកជាអនិវេសជន :

- រូបវន្តបុគ្គលសញ្ជាតិខ្មែរ ដែលមានសកម្មភាពចំបងឬលំនៅឋានចំបង

នៅបរទេសចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ ( ១៨២ថ្ងៃ ) ឡើងទៅ

- រូបវន្តបុគ្គលបរទេសដែលមានសកម្មភាពចំបងឬលំនៅឋានចំបងនៅព្រះរាជាណាចក្រកម្ពុជា តិចជាងមួយរយប៉ែតសិបពីរថ្ងៃ ( ១៨២ថ្ងៃ )

- នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសដែលមានទីតាំងនៅបរទេសនិងសាខានៅបរទេសរបស់នីតិបុគ្គលនៃច្បាប់ក្នុងប្រទេស

- មន្ត្រីបរទេសដែលបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ឬបេសកជនប្រហាក់ប្រហែល ។

# ជំពូកទី ២

## អន្តរការិយកម្មធនាគារ

**មាត្រា ៥.**

១- រាល់ប្រតិបត្តិការប្តូរប្រាក់តាមរបៀបលេខនាដោយមានរាប់បញ្ចូលការទិញនិងការលក់រូបិយប័ណ្ណលើផ្សារប្តូរប្រាក់ផង ការផ្ទេរប្រាក់ ការទូទាត់ក្រៅប្រទេសគ្រប់ប្រភេទក៏ដូចជាចលនានៃដើមទុនជារូបិយប័ណ្ណ ឬជារូបិយវត្ថុជាតិរវាងកម្ពុជានិងប្រទេសក្រៅ ឬរវាងនិវេសជននិងអនិវេសជន អាចប្រព្រឹត្តទៅដោយសេរី ប៉ុន្តែប្រតិបត្តិការទាំងនោះ ត្រូវតែអនុវត្តដោយឆ្លងតាមអន្តរការីប្រតិស្រុតិ ។

២- មានតែធនាគារដែលមានទីតាំងជាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេដែលត្រូវបានចាត់ទុកជាអន្តរការីប្រតិស្រុតិ ។

៣- អន្តរការីប្រតិស្រុតិ ក្រោមល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងបទបញ្ជា ត្រូវបង្ខំឲ្យផ្តល់ជូនធនាគារកណ្តាលជាទៀងទាត់ នូវរបាយការណ៍តាមកាលកំណត់តាមប្រភេទនៃប្រតិបត្តិការផ្ទេរប្រាក់ឬការទូទាត់និងចលនានៃដើមទុនចេញ និងចូលដែលបានអនុវត្តរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសក្រៅទៅតាមរយៈពេលដែលនឹងកំណត់ដោយធនាគារកណ្តាល ។

៤- អន្តរការីប្រតិស្រុតិដែលធ្វើការនាំចេញសាច់ប្រាក់ជារូបិយប័ណ្ណ ត្រូវធ្វើប្រតិវេទន៍ជាមុនជូនធនាគារកណ្តាល ។

៥- អាជីវករប្តូរប្រាក់ដល់ដៃដែលមានទីតាំងអចល័តឬចល័តអាចធ្វើសកម្មភាពប្តូរប្រាក់បានលុះត្រាតែបានទទួលការអនុញ្ញាតជាមុនពីធនាគារកណ្តាល ។

**មាត្រា៦.**

ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសំរាប់រយៈពេលយ៉ាងយូរ៣ខែ ដើម្បីកំណត់ល័ក្ខខ័ណ្ឌបណ្តោះអាសន្នខ្លះចំពោះសកម្មភាពរបស់អន្តរការីប្រតិស្រុតិ ជាអាទិ៍ចំពោះប្រតិបត្តិការដែលមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ ឬស្ថានភាពរូបិយប័ណ្ណរបស់ខ្លួនឬការឲ្យខ្ចីជារូបិយវត្ថុជាតិទៅអនិវេសជន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៧.**

និវេសជនអាចកាន់រក្សាទុកនូវរូបិយប័ណ្ណដោយសេរីទាំងទម្រង់ ទាំងទីកន្លែងនៅក្នុងប្រទេស ។ ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសម្រាប់រយៈពេលយ៉ាងយូរ ៣ខែ ដើម្បីផ្អាកមិនឲ្យអនុវត្តបទប្បញ្ញត្តិនេះជាបណ្តោះអាសន្ន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

# ជំពូកទី ៣

# ប្រតិបត្តិការចរន្ត

**មាត្រា ៨.**

អ្នកនាំចេញឬអ្នកនាំចូលទំនិញឬសេវា ត្រូវធ្វើការទូទាត់តាមរយៈអន្តរការីប្រតិស្រុតិនូវប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនជាមួយប្រទេសក្រៅ ។

**មាត្រា ៩.**

ធនាគារកណ្តាលអាចទាមទារឲ្យអន្តរការីប្រតិស្រុតិបង្ហាញនូវសក្ខីប័ត្រធនាគារវិកប្ប នៅពេលដែលដាក់ពាក្យសុំទិញរូបិយប័ណ្ណដើម្បីទូទាត់ការនាំចូល និងនៅពេលក្រោយមកទៀតនូវសក្ខីប័ត្ររដ្ឋបាលផ្សេងៗទៀតដែលបញ្ជាក់ថា ទំនិញបាននាំចូលមកក្នុងប្រទេសរួចហើយ ។

**មាត្រា ១០.**

ចាប់តាំងពីពេលធ្វើបេឡានិច័យ ប្រាក់ចំណូលដែលបានមកពីការនាំចេញទំនិញឬសេវា ត្រូវបញ្ចូលក្នុងខ្ទង់ឥណទាននៃគណនីរបស់អ្នកនាំចេញ ដែលមានបើកនៅធនាគារវិកប្បស្រប តាមមាត្រា៨ នៃច្បាប់នេះ ។

**មាត្រា ១១.**

មូលនិធិបដិភាគជារូបិយវត្ថុជាតិ ដែលបានមកពីការធ្វើពាណិជ្ជកម្មក្នុងប្រទេសនូវទំនិញនាំចូលក្នុងក្របខ័ណ្ឌការខ្ចីប្រាក់ពីក្រៅឬជាអំណោយ ត្រូវបង់ចូលខ្ទង់ឥណទាននៃគណនីរបស់រតនាគារជាតិ ដែលបើកនៅធនាគារកណ្តាល ទៅតាមបែបបទដែលនឹងត្រូវកំណត់តាមកិច្ចព្រមព្រៀងរួមរវាងរតនាគារជាតិនិងធនាគារកណ្តាល ។

**មាត្រា ១២.**

រាល់ការនាំចេញឬការនាំចូលមាសមិនទាន់កែច្នៃ ត្បូងថ្មមានតំលៃមិនទាន់កែច្នៃឬលោហធាតុមានតំលៃមិនទាន់កែច្នៃដទៃទៀត អាចដំណើរការដោយសេរី ស្របតាមចំណុច ១ មាត្រា ៥ នៃច្បាប់នេះ ប៉ុន្តែត្រូវធ្វើប្រតិវេទន៍ជាមុននៅធនាគារកណ្តាល បើចំនួនទំនិញនៃប្រតិបត្តិការនីមួយៗមានតំលៃស្មើឬលើសពីមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិក ។

**មាត្រា ១៣.**

ការនាំចេញឬការនាំចូលដោយអ្នកដំណើរនូវមធ្យោបាយទូទាត់ជារូបិយប័ណ្ណដែលមានទឹកប្រាក់ស្មើឬលើសពីមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិក ឬជារូបិយវត្ថុជាតិដែលមានតំលៃសមមូលនឹងមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិកឬច្រើនជាងនេះ ត្រូវតែធ្វើប្រតិវេទន៍ចំពោះមន្ត្រីគយនៅពេលឆ្លងកាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ។

សាច់ប្រាក់ចាប់តាំងពីកំរិតមួយដែលកំណត់ដោយបទបញ្ជារបស់ធនាគារកណ្តាល អ្នកនាំចេញត្រូវដាក់ជូនធនាគារកណ្តាលពិនិត្យជាមុន មុននឹងធ្វើការនាំចេញ ។

ជារៀងរាល់ខែ ទីចាត់ការគយនិងរដ្ឋាករត្រូវបញ្ជូនបញ្ជីនៃប្រតិវេទន៍ដូចបានកំណត់ខាងលើទៅធនាគារកណ្តាល ។

# ជំពូកទី៤

## ការវិនិយោគ ចលនានៃដើមទុន

**មាត្រា ១៤.**

ចលនានៃដើមទុនទាក់ទងនឹងការវិនិយោគបរទេសនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥**

ក្នុងករណីដែលការជំរះបញ្ជីនៃការវិនិយោគបរទេសបានប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ផលដែលបានមកពីការជំរះបញ្ជីនោះនឹងត្រូវផ្ទេរបានដោយសេរី ។

**មាត្រា ១៦**

ការធ្វើវិនិយោគនៃនិវេសជននៅបរទេស ត្រូវធ្វើប្រតិវេទន៍ជាមុនដល់ធនាគារកណ្តាល បើទឹកប្រាក់មានចំនួនស្មើឬលើសពីមួយសែន ( ១០០.០០០ ) ដុល្លារអាមេរិក ។

**មាត្រា ១៧**

ការផ្ទេរប្រាក់ទាក់ទងនឹងការធ្វើវិនិយោគឬការជំរះបញ្ជីនៃការធ្វើវិនិយោគ ត្រូវធ្វើតាមរយៈអន្តរការីប្រតិស្រុតិដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។ អន្តរការីប្រតិស្រុតិត្រូវធ្វើរបាយការណ៍ជូនធនាគារកណ្តាលជាក្រោយលើទឹកប្រាក់ធ្វើប្រតិបត្តិការម្តងៗមានចំនួនស្មើ ឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

## ជំពូកទី ៥
## ចលនានៃដើមទុនផ្សេងៗ

**មាត្រា ១៨**

ការឲ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ ដោយរាប់បញ្ចូលទាំងឥណទានពាណិជ្ជកម្មផងរវាងនិវេសជននិងអនិវេសជនអាចប្រព្រឹត្តទៅដោយសេរី ឲ្យតែការខ្ចីនិងការសងវិញ ធ្វើតាមរយៈអន្តរការីប្រតិស្រុតិ ។

**មាត្រា ១៩**

ចលនានៃដើមទុនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ (ការទូទាត់ថ្លៃទំនិញឬសេវានាំចូលនិងនាំចេញ ការផ្ទេរប្រាក់ ការវិនិយោគ ការឲ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ) ត្រូវបញ្ចូលក្នុងរបាយការណ៍ធនាគារជាប្រចាំតាមការកំណត់ដែលមានចែងក្នុងចំណុច ៣ មាត្រា ៥ នៃច្បាប់នេះ ។ ចលនានៃដើមទុនទាំងនោះត្រូវកត់ត្រាតាមប្រភេទប្រតិបត្តិការនិមួយៗ ហើយត្រូវគោរពដល់ការសម្ងាត់វិជ្ជាជីវៈ ។

# ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា ២០**

អន្តរការីប្រតិស្រុតិមានភារៈ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយប្រុងប្រយ័ត្ននូវការគោរពបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ឬដែលមានចែងក្នុបទបញ្ជាទាំងឡាយនៃធនាគារកណ្តាលដើម្បីអនុវត្តប្រតិបត្តិការដែលខ្លួនបានធ្វើដោយផ្ទាល់ឬដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

អន្តរការីប្រតិស្រុតិណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ២១**

ជនណាប្រព្រឹត្តល្មើសនឹងចំណុច៣ ឬ ចំណុច៤ ឬ ចំណុច៥ នៃមាត្រា៥ ឬប្រព្រឹត្តល្មើសនឹងមាត្រា១៧ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ ដប់លានរៀល(១០.០០០.០០០រៀល) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

**មាត្រា ២២**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា១១ឬវាក្យខ័ណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ស្មើនឹងដប់ភាគរយ(១០ភាគរយ) នៃទឹកប្រាក់ល្មើស ។

**មាត្រា ២៣**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១២ ឬមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងម្ភៃភាគរយ(២០ភាគរយ)នៃទឹកប្រាក់ល្មើស ។

**មាត្រា ២៤**

ជនណាប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ដប់លានរៀល(១០.០០០.០០០រៀល) ។ រីឯវត្ថុតាងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

**មាត្រា ២៥**

ជនណាប្រព្រឹត្តល្មើសនឹងចំណុច ១ មាត្រា ៥ ឬមាត្រា ៨ ឬមាត្រា ១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងហាសិបភាគរយ ( ៥០ភាគរយ ) នៃទឹក ប្រាក់ល្មើស ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៦**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ សីហា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**ហត្ថលេខា** **ហត្ថលេខា**

បានជំរាបជូន **អ៊ុង ហួត** **ហ៊ុន សែន**

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ចៅ ច័ន្ទលាភ**

លេខ: ១៥២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ [illegible] ឆ្នាំ១៩៩៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ិន ឆាន់

រាជកិច្ចឆ្នាំទី ៥ លេខ៣១ ស្ងួន ថ្ងៃទី២៣ ខែសីហា ឆ្នាំ ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# គ្រឹះស្ថានធនាគារ

# និង

# ហិរញ្ញវត្ថុ

# ព្រះរាជក្រម

នស/រកម/១១៩៩/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របតាមរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## អន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុ

**មាត្រា ១.-**

ធនាគារគឺជានីតិបុគ្គល ដែលមាននីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី ។

**មាត្រា ២.-**

ប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន :

១- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកំរៃ រាប់បញ្ចូលទាំងឥណទានកតិសន្យានិងការសន្យាតាមហត្ថលេខា ។

២- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន ។

៣- ប្រព្រឹត្តិកម្មនិងការដាក់អោយអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយប័ណ្ណ ។

អង្គភាពណាក៏ដោយ អោយតែអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំង៣ប្រភេទខាងលើនេះ ត្រូវបានចាត់ទុកជាបានធ្វើអាជីវកម្មធនាគារ តាមការជាក់ស្តែង ។

អង្គភាពណា ដែលអនុវត្តតែសកម្មភាពមួយក្នុងចំណោមសកម្មភាពជាមូលដ្ឋានទាំង៣នេះ ឬអនុវត្តតែផ្នែកមួយនៃសកម្មភាពនីមួយៗនោះ ត្រូវបានអោយឈ្មោះថាជាធនាគារឯកទេស ។

**មាត្រា ៣.-**

ចំពោះសាធារណជនឬសំរាប់ខ្លួនឯងផ្ទាល់ ធនាគារអាចធ្វើបាននូវ :

១- រាល់ប្រតិបត្តិការហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ វៀរលែងតែ ប្រតិបត្តិការធានារ៉ាប់រងដែលត្រូវកំណត់ដោយច្បាប់ធានារ៉ាប់រងដោយឡែក ។

២- រាល់ប្រតិបត្តិការប្តូរប្រាក់ ។

៣- អន្តរការិយកម្មនិងការអនុវត្តន៍រាល់ប្រតិបត្តិការលើមូលប័ត្រឥណទេយ្យជូញដូរបាននៅ

លើទីផ្សារ ។

៤- រាល់ប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ។

៥- សេដ្ឋពាណិជ្ជកម្មដល់ដៃឬមានកាលកំណត់ លើលោហធាតុនិងត្បូងថ្មមានតម្លៃ និងវត្ថុធាតុដើមឬទំនិញ ។

៦- ប្រតិបត្តិការលើសេវាកម្មដទៃទៀត ដែលផ្សារភ្ជាប់នឹងសកម្មភាពចំបងរបស់ខ្លួន ដោយមានការយល់ព្រមពីអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារ ។

**មាត្រា ៤.-**

ធនាគារ ដូចដែលបានកំណត់និយមន័យមកហើយ អាចអនុវត្ត សំរាប់ខ្លួនឯងផ្ទាល់ឬសំរាប់អតិថិជនរបស់ខ្លួន ដោយផ្ទាល់ឬតាមរយៈការចូលហ៊ុនទៅក្នុងក្រុមហ៊ុនឯកទេសណាមួយឬច្រើន នូវប្រតិបត្តិការផ្សេងៗលើមូលប័ត្រ ដែលបង្កបង្កើតនូវអន្តរការិយកម្មហិរញ្ញវត្ថុ ជាអាទិ៍រួមមាន :

១- ការប្រមូលមូលនិធិសំរាប់បរិវិសកម្ម ឬសំរាប់ទិញមូលប័ត្រ តាមបញ្ជារបស់អតិថិជនជាឯកត្តជនឬជាក្រុមប្រមូលផ្តុំជាអង្គភាពបណ្តាក់ទុនសមូហភាព ។

២- បរិវិសកម្មនិងការជួញដូរមូលប័ត្រ ។

៣- ការរក្សាទុកមូលប័ត្រ ។

៤- ការគ្រប់គ្រងមូលប័ត្រ ជាឯកត្តជនឬជាសមូហភាព ។

៥- ការទិញផ្តាច់មូលប័ត្រនៅពេលផ្សាយចេញ ។

៦- វិស្វកម្មហិរញ្ញវត្ថុ ។

៧- ការជួញដូរឧបករណ៍និស្សន្ទទាក់ទងនឹងសកម្មភាពរបស់ខ្លួន ។

៨- ប្រតិបត្តិការគ្រប់ប្រភេទលើមូលប័ត្រធ្វើឡើងសំរាប់ខ្លួនផ្ទាល់ក្នុងនាទីជាក្រុមហ៊ុនពាណិជ្ជកម្មចំណុះច្បាប់ទូទៅនិងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៥.-**

សំរាប់តតិយជន ក្រុមហ៊ុនហិរញ្ញវត្ថុឯកទេសឯទៀតក៏អាចធ្វើប្រតិបត្តិការលើមូលប័ត្រដូចធនាគារដែរ ។

## មាត្រា ៦._

ពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ក្រុមហ៊ុនហិរញ្ញវត្ថុត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជាស្របតាមបទប្បញ្ញត្តិនៃមាត្រា ៧ ចំណុច ៤ និងចំណុច ១១ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ។

ប៉ុន្តែរាល់ប្រតិបត្តិការលើមូលប័ត្រដែលអនុវត្តដោយធនាគារនិងដោយក្រុមហ៊ុនហិរញ្ញវត្ថុក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើលរបស់គណៈកម្មការពិសេសមួយដោយឡែក ចំពោះការចេញផ្សាយ តម្លាភាពនៃការជួញដូរ និងកិច្ចការពារប្រាក់សន្សំវិនិយោគក្នុងសង្ហារឹមប័ណ្ណ ។

សមាសភាពនិងតួនាទីរបស់គណៈកម្មការនេះត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ជាដែលគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ ។

## មាត្រា ៧._

អាជ្ញាធរអាណាព្យាបាលនៃប្រពន្ធ័ធនាគារនិងអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធហិរញ្ញវត្ថុត្រូវសហការក្នុងការកំណត់បែបបទ លើសកម្មភាពមូលប័ត្រ ឬ ក្នុងឱកាសដែលចេញអាជ្ញាប័ណ្ណ ឬ តាមការចេញបទបញ្ជា ដើម្បីជៀសវាងការភ័ន្តច្រឡំ ដែលអាចកើតមានឡើងពីសកម្មភាពជាន់គ្នាមួយចំនួន នៅក្នុងវង្វង់ធនាគារ ឬ នៅក្នុងវង្វង់ក្រុមហ៊ុនហិរញ្ញវត្ថុឯកទេស ដូចជាការប្រមូលប្រាក់បញ្ញើមានមុខសញ្ញា ការរក្សាទុកឬការគ្រប់គ្រងមូលប័ត្រ ។

## មាត្រា ៨._

រាល់ប្រតិបត្តិការដែលប្រទាក់គ្នានឹងសកម្មភាពធនាគារ ដូចមានចែងនៅក្នុងមាត្រា ៣ កថាខ័ណ្ឌ ២-៣-៤-និង ៥ នៃច្បាប់នេះ អាចធ្វើឡើងបានដោយអង្គភាពមិនមែនធនាគារតែក្នុងលក្ខខណ្ឌដែលមានកំណត់ដោយអាជ្ញាធរអាណាព្យាបាល ប្រសិនបើប្រតិបត្តិការទាំងនោះធ្វើសំរាប់សាធារណជន ។

## ជំពូកទី ២
## ដែននៃការអនុវត្តន៍

**មាត្រា ៩.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចដែលបានកំណត់ន័យក្នុងជំពូកទី១ខាងលើ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ និងត្រូវបានហៅថា "គ្រឹះស្ថានចំណុះច្បាប់នេះ" ក្នុងមាត្រាបន្តបន្ទាប់ទៅនេះ ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយត្រូវបានហាមឃាត់មិនអោយយកប្រតិបត្តិការធនាគារធ្វើជាអាជីវកម្មប្រក្រតី ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយ មិនត្រូវប្រើប្រាស់នូវនាមករណ៍ឬឃីហោ ឬពាណិជ្ជសញ្ញា ឬសេវាសញ្ញា ការផ្សាយដំណឹងពាណិជ្ជកម្មឬរាល់សំនួនពាក្យដទៃទៀត ដែលនាំអោយមានការយល់ច្រឡំថាខ្លួនត្រូវបានប្រតិស្រុតអោយធ្វើសកម្មភាពណាមួយក្រោមការអនុញ្ញាតនៃច្បាប់នេះ ។

**មាត្រា ១០.-**

បណ្តាគ្រឹះស្ថានចំណុះច្បាប់នេះ ក្រៅពីត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្មឬក្រោមលក្ខន្តិកៈនីត្យានុកូលពិសេសនៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះថែមទៀត ។

ក្នុងករណីមានខ្វឹមសារខ្វែងគ្នារវាងអត្ថបទច្បាប់ទាំងនេះ គឺបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវយកជាបានការ ។

## ជំពូកទី ៣
## រូបភាពគតិយុត្តរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

**មាត្រា ១១.-**

គ្រឹះស្ថានចំណុះច្បាប់នេះត្រូវតែបានបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនភាគហ៊ុននៃច្បាប់

ពាណិជ្ជកម្មឬក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គហសមាគមឬសហករណ៍ដែលស្ថិតនៅក្រោម លក្ខន្តិកៈនីត្យានុកូលដោយឡែក ។

ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គហសមាគមឬសហករណ៍ ត្រូវតែបានប្រមូលផ្តុំគ្នាជាសហពន្ធ័ ដែលហៅថាអង្គការកណ្តាល ។

អង្គការកណ្តាលទាំងនេះ ត្រូវទទួលបន្ទុកក្នុងការជម្រុញអោយមានសិទ្ធិពលរវាងបណ្តាញនៃ គ្រឹះស្ថានដែលចូលជាសមាជិក ហើយធានាដំណើរការអោយបានត្រឹមត្រូវ ។

ដើម្បីសំរេចតាមបំណងខាងលើ អង្គការកណ្តាលទាំងនេះត្រូវចាត់វិធានការចាំបាច់ជាអាទិ៍ ដើម្បី ធានាអោយមានសាច់ប្រាក់ងាយស្រួលនិងសាធនភាពនៃគ្រឹះស្ថានទីមួយៗនៃបណ្តាញទាំងមូល ។

អង្គការកណ្តាលខ្លួនឯងទាំងនេះក៏ត្រូវបានចាត់ទុកជាគ្រឹះស្ថានចំណុះច្បាប់នេះដែរ ។

**មាត្រា ១២.-**

គ្រឹះស្ថានចំណុះច្បាប់នេះ ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចជាក្រុមហ៊ុនក្រោម ច្បាប់ក្នុងស្រុកឬជាសាខារបស់ធនាគារបរទេស ។

**មាត្រា ១៣.-**

ធនាគារបរទេសអាចបើក នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន នូវការិយាល័យដែលមាន សកម្មភាព ខាងពត៌មាន សម្ព័ន្ធការ ឬជាតំណាង បន្ទាប់ពីបានទទួលការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែ ការិយាល័យទាំងនេះមិនអាចធ្វើប្រតិបត្តិការអន្តរការិយកម្មធនាគារឬហិរញ្ញវត្ថុនិងការស្វែងរកអតិថិជនបាន ឡើយ ។

ការបោះទីតាំងទាំងនោះ អាចប្រកាន់យកទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុកឬជាគ្រឹះស្ថានសាមញ្ញ ឬជាអ្នកទទួលសិទ្ធិប្រទានសាមញ្ញ ហើយត្រូវតែមានការចុះក្នុងបញ្ជីពាណិជ្ជកម្មតាមរូបភាពដែលប្រកាន់យក ។

ការិយាល័យតំណាងទាំងនេះអាចរក្សាទុកនូវនាមករណ៍ឬយីហោនៃធនាគារបរទេសដែលខ្លួន តំណាងអោយ ។

ការអនុញ្ញាតអោយបើកការិយាល័យតំណាងមានថេរវេលាពីរឆ្នាំ (២ឆ្នាំ) ហើយអាចត្រូវបន្តអោយបានតែមួយដងគត់ ។

## ជំពូកទី ៤
## អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

**មាត្រា ១៤.-**

មុននឹងធ្វើសកម្មភាព គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរអាណាព្យាបាលសិន ។ មុននឹងផ្តល់អាជ្ញាប័ណ្ណអោយ អាជ្ញាធរអាណាព្យាបាលត្រូវពិនិត្យអោយបានច្បាស់លាស់ ជាពិសេសនូវ :

១- គុណភាពនៃអ្នកចូលហ៊ុននិងស្ថានភាពពិតប្រាកដខាងហិរញ្ញវត្ថុរបស់អ្នកទាំងនោះ ។

២- សម្បទានៃអ្នកចូលហ៊ុនសំខាន់ៗ ដើម្បីគោរពរួមគ្នានូវកាតព្វកិច្ចដែលតម្រូវដល់អ្នកទាំងនោះក្នុងករណីចាំបាច់ត្រូវបង្កើនបង្គ្រប់ តាមវិធីណាមួយ នូវមូលនិធិផ្ទាល់របស់ធនាគារតាមស្មារតីមាត្រា ២៧ នៃច្បាប់នេះ ។

៣- ភាពសមស្របនៃមធ្យោបាយធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដោយមានកម្មវិធីសកម្មភាពភ្ជាប់ជាមួយ ។

អាជ្ញាធរអាណាព្យាបាលត្រូវស្វែងយល់ពីពតិមានលើលក្ខខណ្ឌបដិការដែលប្រទេសក្រៅផ្តល់អោយកាលបើភាគទុនិកៈរបស់ក្រុមហ៊ុនក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឬទីស្នាក់ការនៃសាខាជាអាណិកជននៃប្រទេសទាំងនោះ ។

**មាត្រា ១៥.-**

អាជ្ញាធរអាណាព្យាបាលនឹងសំរេចផ្តល់អាជ្ញាប័ណ្ណក្នុងរយៈពេលប្រាំមួយខែ (៦ខែ) គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់ ។ រាល់ការបដិសេធមិនផ្តល់អាជ្ញាប័ណ្ណត្រូវតែមានធ្វើប្រវេសន៍ដល់ម្ចាស់សំណើ ។ បញ្ជីសមមិននៃគ្រឹះស្ថានប្រតិស្រុតត្រូវចុះផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជា និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជានិងក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរអាណាព្យាបាល ។

# ជំពូកទី ៥

## ដើមទុនអប្បបរមា សាធនភាព

**មាត្រា ១៦.-**

គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមរូបភាពក្រុមហ៊ុនពាណិជ្ជកម្មឬមិនមែនពាណិជ្ជកម្ម នៃច្បាប់ក្នុងស្រុក ទោះក្រោមរូបភាពគតិយុត្តបែបណាក៏ដោយ មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានដើមទុនដំបូងដែល ត្រូវបង់គ្រប់ចំនួនទាំងស្រុង យ៉ាងតិចស្មើនឹងចំនួនដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាល ។

សាខាទាំងឡាយនៃធនាគារបរទេស មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានទាយជ្ជទានដើមទុនដែល ត្រូវបង់គ្រប់ចំនួនទាំងស្រុងស្មើនឹងដើមទុនអប្បបរមារបស់គ្រឹះស្ថានចំណុះច្បាប់នេះ បង្កើតឡើងក្រោមទំរង់ជា ក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ។

ដើមទុនអប្បបរមានិងប្រាក់ដកល់ធានាជាអចិន្ត្រៃយ៍នៅក្នុងបញ្ជីធនាគារជាតិនៃកម្ពុជា របស់ គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់អាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែចំពោះធនាគារពាណិជ្ជ ចំនួនទឹកប្រាក់នៃដើមទុនអប្បបរមា មិនត្រូវស្ថិតនៅក្រោមកំរិតហាសិបពាន់លានរៀល (៥០.០០០.០០០.០០០រ) ទេ ។

ចំនួនទឹកប្រាក់ខាងលើនេះ ត្រូវគិតតាមអត្រាអន្តរជាតិ មួយ អេស.ឌី.អរ៍ (SDR) ស្មើនឹងប្រាំពាន់ ប្រាំមួយរយដប់ប្រាំមួយរៀល (៥.៦១៦រ) ។

ចំពោះប្រាក់ដែលត្រូវតំកល់នៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់យ៉ាងតិចចំនួនប្រាំភាគរយ (៥%) នៃចំនួនដើមទុនអប្បបរមាខាងលើ ។

គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុកនិងក្រោមទំរង់ ជាសាខាធនាគារបរទេស ត្រូវបង្ហាញជាអចិន្ត្រៃយ៍ថា បន្ទាប់ពីការដកចេញនូវទ្រព្យសកម្មគ្មានតម្លៃ ទ្រព្យសកម្ម របស់ខ្លួនមានតំលៃលើសពីទ្រព្យអកម្មដែលខ្លួនជំពាក់គតិយជនក្នុងទឹកប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមាឬ ទាយជ្ជទានដើមទុនអប្បបរមា ។

**មាត្រា ១៧.-**

គ្រឹះស្ថានចំណុះច្បាប់នេះត្រូវគោរពអនុបាតនៃសាធនភាពដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាលតាមវិបរិណាមនៃបទដ្ឋានអន្តរជាតិ ។ យោលទៅតាមទំហំហានិភ័យ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវកែតំរូវបរិមាណមូលនិធិផ្ទាល់សុទ្ធអោយបានសមស្របតាមសមាមាត្រ ។

# ជំពូកទី ៦

## សមត្ថភាពនៃអ្នកដឹកនាំ

**មាត្រា ១៨.-**

គ្មានជនណាម្នាក់អាច :

- ធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានប្រតិស្រុត
- គ្រប់គ្រង កាន់កាប់ ឬ ដឹកនាំ ដោយផ្ទាល់ឬតាមរយៈសន្ធានការី ទោះជាក្នុងតួនាទីណាក៏ដោយ
- ចុះហត្ថលេខាក្នុងនាមគ្រឹះស្ថាននោះ ។

ប្រសិនបើជននោះ :

១- ត្រូវបានផ្តន្ទាទោសជាស្ថាពរ ពីបទ :

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬ រំលោភលើការទុកចិត្ត
- លួចដកហូតយកទ្រព្យសាធារណៈ ក្នុងតួនាទីខ្លួនជាអ្នកទទួលរក្សាបញ្ញើ
- ជំរិតយកមូលនិធិ ឬ វត្ថុមានតម្លៃ ធ្វើនិទ្ទនភាព អោយខូចកេរ្តិ៍ឈ្មោះប្រទេសជាតិ ឬ ល្មើសនឹងច្បាប់ប្តូរប្រាក់
- ធ្វើព្រឹទ្ធិកម្ម
- ការសំអាតប្រាក់
- ក្លែង ឬ/ និងប្រើលិខិតក្លែងក្លាយ ឯកជនឬសាធារណៈ ។

២- ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញផ្សាយមូលប្បទានប័ត្រគ្មានសវិធានវត្ថុ ។

៣- ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេស ពីបទឧក្រិដ្ឋឬមជ្ឈិម ដែលចែងនៅចំណុច ១ និង ២ នៃមាត្រានេះ ។

៤- ត្រូវបានផ្តន្ទាទោស នៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ពីបទចនក្ស័យផ្ទាល់ខ្លួន ឬការជំរះបំណុលតាមផ្លូវតុលាការ ឬការជំរះទ្រព្យសម្បត្តិ ។

៥- ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ ។

៦- ត្រូវបានជាប់រឿងជាឯកត្តជន ក្នុងការគ្រប់គ្រងនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាប័ណ្ណត្រូវបានដកហូតវិញដោយមូលហេតុរងទណ្ឌកម្មខាងវិន័យ ។

# ជំពូកទី ៧

## សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគីរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម

**មាត្រា ១៩.-**

លក្ខខណ្ឌទាំងឡាយនៃការផ្សំបង្កើតដើមទុន ទោះជាប្រែប្រួលក្តីមិនប្រែប្រួលក្តី នៃគ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមរូបភាពក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម រួមទាំងអត្តសញ្ញាណកម្មអចិន្ត្រៃយ៍នៃសង្គមិកៈឬអ្នកកាន់ភាគហ៊ុននៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្មទាំងនេះ ត្រូវបានកំណត់តាក់តែងនៅក្នុងលក្ខន្តិកៈនិត្យានុកូលពិសេសមួយ សំរាប់អនុវត្តលើក្រុមហ៊ុនដែលមានលក្ខណៈសហករណ៍ឬសង្គហសមាគម ។

អនុលោមតាមមាត្រា ១១ និងចំណុច ២ នៃមាត្រា ១៤ នៃច្បាប់នេះ អង្គការកណ្តាលនៃបណ្តាញនីមួយៗគឺជាអ្នកទទួលធានាសាធនភាពនិងសាច់ប្រាក់ងាយស្រួលនៃបណ្តាញនេះ ចំពោះតតិយជន អ្នកផ្ញើប្រាក់ឬឥណទាយក ។

# ជំពូកទី ៨
## សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគទុនិកភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្ម

**មាត្រា ២០.-**

ភាគទុនិកៈនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្ម អាចជារូបវន្តបុគ្គល ឬតាមលក្ខខណ្ឌកំណត់ដោយអាជ្ញាធរអាណាព្យាបាល អាចជានីតិបុគ្គលដែលភាគទុនិកៈត្រូវមាន អត្តសញ្ញាណច្បាស់លាស់ ។

អាជ្ញាធរអាណាព្យាបាលត្រូវចៀសវាងជាអាទិ៍ នូវក្រុមហ៊ុនដែលជាភាគទុនិកៈបណ្តាក់បន្តគ្នាពីមួយ ទៅមួយ ។

**មាត្រា ២១.-**

ក្រុមហ៊ុនហូលឌិងដែលមានគ្រឹះស្ថានចំណុះច្បាប់នេះជាបុត្តសម្ព័ន្ធ ដោយផ្ទាល់មុខឬជាចំបង ចំនួន តិចឬច្រើនក៏ដោយ ក៏ត្រូវចាត់ទុកជាគ្រឹះស្ថានចំណុះច្បាប់នេះដែរ ជាអាទិ៍ចំពោះការទាក់ទងទៅនឹងអាជ្ញាប័ណ្ណ និង ភាពចំណុះក្រោមអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ២២.-**

គ្រឹះស្ថានចំណុះច្បាប់នេះត្រូវបញ្ជូនអោយអាជ្ញាធរអាណាព្យាបាល នៅពេលដាក់ពាក្យស្នើសុំ អាជ្ញាប័ណ្ណ នូវអត្តសញ្ញាណនៃភាគទុនិកៈរបស់ខ្លួន ដែលមានភាគទុនស្មើឬលើសចំនួនប្រាំភាគរយ (៥%) នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតដោយផ្ទាល់ឬដោយប្រយោល ។

មាត្រា ២៣.-

រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវធ្វើប្រតិវេទន៍ ជូនទៅអាជ្ញាធរអាណាព្យាបាលដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានចំណុះច្បាប់នេះ ដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មឬអនុប្បទានភាគទុន ដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលអោយភាគទុនិកៈឬក្រុមភាគទុនិកៈនេះទទួលបានឬបាត់បង់ទៅវិញចំនួនប្រាំភាគរយ (៥%) នៃដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះឬចំនួនប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោត ។

មាត្រា ២៤.-

១- រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវទទួល ដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានពាក់ព័ន្ធចំណុះច្បាប់នេះ នូវការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាលដើម្បីធ្វើលទ្ធកម្មឬអនុប្បទានភាគទុនដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលអោយភាគទុនិកៈឬក្រុមភាគទុនិកៈនេះ :

ក- ទទួលបានឬបាត់បង់ទៅវិញ ពាក់កណ្ដាល មួយភាគបី មួយភាគប្រាំ ឬ មួយភាគដប់ នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត

ខ- ទទួលបានឬបាត់បង់ទៅវិញ នូវសិទ្ធិអំណាចនៃការត្រួតពិនិត្យលើការគ្រប់គ្រងរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលខុសត្រូវក្នុងការបំពេញទំរង់បែបបទនៃប្រតិវេទន៍ឬនៃការអនុញ្ញាត ។

ក្នុងករណីដែលទំរង់បែបបទទាំងនេះបំពេញមិនបានត្រឹមត្រូវ ការបោះឆ្នោតរបស់ភាគទុនិកៈពាក់ព័ន្ធនៅក្នុងមហាសន្និបាតនឹងត្រូវចាត់ទុកជាមោឃៈជាស្វ័យប្រវត្តិដោយមិនទាន់និយាយដល់ទណ្ឌកម្មនីត្យានុកូលឯទៀតដែលត្រូវអនុវត្តផង ។

មាត្រា ២៥.-

ក្រោមបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្មស្តីពីចំនួនអប្បបរមានៃភាគទុនិកៈរបស់ក្រុមហ៊ុនមូលធន ទំហំបរិមាណនៃការដាក់ទុននីមួយៗចូលក្នុងដើមទុននៃគ្រឹះស្ថានចំណុះច្បាប់នេះមិនត្រូវមានកំរិតទេ ។ ប៉ុន្តែនៅក្នុងពេលពិនិត្យពាក្យសុំអាជ្ញាប័ណ្ណ ហើយក្រោយមក នៅពេលធ្វើប្រតិវេទន៍ឬសុំការអនុញ្ញាតឆ្លងកំរិតភាគរយដែលបានចែងខាងលើ អាជ្ញាធរអាណាព្យាបាលត្រូវ :

- យកចិត្តទុកដាក់អោយមានវត្តមាននៃភាគទុនិកៈដែលមានឥទ្ធិពល

- ចៀសវាងនូវការប្រមូលផ្តុំ ក៏ដូចជាការបំបែកហួសប្រមាណនៃដើមទុន ។

ប៉ុន្តែការប្រមូលផ្តុំធំធេងអាចត្រូវទទួលយកបានក្នុងករណីដែលភាគទុនិកៈពាក់ព័ន្ធគឺជាធនាគារបរទេសដែលមានស្តង់ឌិងខ្ពស់ ។

## មាត្រា ២៦.-

នៅក្នុងន័យនៃច្បាប់នេះ ភាគទុនិកៈត្រូវបានចាត់ទុកថាមានឥទ្ធិពល ចាប់តាំងពីពេលដែលខ្លួនគេមាន ដោយផ្ទាល់ឬដោយប្រយោល នូវភាគទុនយ៉ាងតិចស្មើនឹងម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ឬចាប់តាំងពីពេលដែលខ្លួនគេមាននូវសិទ្ធិអំណាចក្នុងការសំរេចពិតប្រាកដ ដោយមូលហេតុជាអាទិ៍នៃការបំបែកហួសប្រមាណនៃដើមទុន ។

## មាត្រា ២៧.-

កាលបើស្ថានភាពហិរញ្ញវត្ថុនៃគ្រឹះស្ថានចំណុះច្បាប់នេះមានបញ្ហាខ្វះខាត អាជ្ញាធរអាណាព្យាបាលត្រូវបង្គាប់ដោយដាច់ខាតដល់ភាគទុនិកៈមានឥទ្ធិពលអោយពួតដៃគ្នាក្នុងការបង្កើនមូលនិធិផ្ទាល់ ធ្វើយ៉ាងណាអោយបទដ្ឋានបទបញ្ជានៃសាធនភាពត្រូវបានគោរព ។

ក្នុងករណីមិនព្រមអនុវត្តតាម ភាគទុនិកៈមានឥទ្ធិពលទាំងនោះត្រូវទទួលទណ្ឌកម្មនានាដែលបានគ្រោងទុកក្នុងចំណុច ២ នៃមាត្រា ៥៥ នៃច្បាប់នេះ ។ បើមានការដកលំតារាងតុល្យការ ឥណទាយកឬអ្នកផ្ញើប្រាក់អាចប្តឹងទៅតុលាការទាមទារអោយភាគទុនិកៈមានឥទ្ធិពលបំពេញទ្រព្យអកម្ម ។

# ជំពូកទី ៩

## សមាសភាព អគ្គសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគទុនិកភាពរបស់ទីស្នាក់ការគ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង ក្រោមរូបភាពជាសាខាធនាគារបរទេស

**មាត្រា ២៨.-**

សាខានៃគ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុបរទេស ដែលត្រូវបានប្រតិស្រុតអោយធ្វើសកម្មភាពធនាគារឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងជាបន្ទាន់ដល់អាជ្ញាធរអាណាព្យាបាល ក្រោមការទទួលខុសត្រូវរបស់ខ្លួន នូវពត៌មានអំពីការកែប្រែសមាសភាពនៃភាគទុនិកៈមានឥទ្ធិពលនៃទីស្នាក់ការរបស់ខ្លួន ។

**មាត្រា ២៩.-**

អាជ្ញាធរអាណាព្យាបាលអាចពិនិត្យឡើងវិញ នូវអាជ្ញាប័ណ្ណដែលបានចេញអោយសាខា បើសិនជាការផ្លាស់ប្តូរដែលលើកឡើងនៅមាត្រា ២៨ នៃច្បាប់នេះ មានលក្ខណៈបន្ថយការធានាខាងហិរញ្ញវត្ថុឬការទទួលខុសត្រូវរបស់ទីស្នាក់ការនៅបរទេស ។

**មាត្រា ៣០.-**

កាលបើស្ថានភាពហិរញ្ញវត្ថុតម្រូវអោយធ្វើ សាខាធនាគារមានកាតព្វកិច្ចស្នើទៅទីស្នាក់ការនៅបរទេសអោយបង្កើនឡើងវិញនូវទាយជ្ជទានដើមទុនដែលមានបញ្ជាក់នៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ១៦ នៃច្បាប់នេះឬកែប្រែការប្រើប្រាស់ទ្រព្យសកម្មឡើងវិញ ។

**មាត្រា ៣១.-**

ក្នុងករណីជំកល់តារាងតុល្យការនៅបរទេសនៃទីស្នាក់ការរបស់សាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ទ្រព្យសកម្មទាំងអស់នៃសាខានេះត្រូវបានឃាត់ទុក ជាអាទិភាពសំរាប់សងអោយអតិថិជនជានិវេសជនដែលបានយកមកផ្ញើទុកនូវមូលប័ត្រ មាស ឬប្រាក់ និងសំរាប់សងអោយឥណទាយក ក្នុងករណីអ្នកជំរះបញ្ជីរបស់សាខាទទួលស្គាល់ថាជាសិទ្ធិរបស់ពួកគេនៅក្នុងទ្រព្យសកម្ម នៅពេលជំកល់តារាងតុល្យការនៃទីស្នាក់ការ ។

# ជំពូកទី ១០
## ភាគកម្មរបស់គ្រឹះស្ថានចំណុះច្បាប់នេះក្នុងដើមទុន
## នៃក្រុមហ៊ុនពាណិជ្ជកម្មដទៃទៀត

**មាត្រា ៣២.-**

ត្រូវបានចាត់ទុកជាភាគកម្ម ក្នុងការអនុវត្តន៍ច្បាប់នេះ គឺភាគកម្ម ដែលអនុញ្ញាតអោយគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់ ដោយផ្ទាល់ឬដោយប្រយោល នូវចំនួនដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនដែលគ្រឹះស្ថាននោះបានចូលរួម ។

**មាត្រា ៣៣.-**

គ្រឹះស្ថានចំណុះច្បាប់នេះមិនអាចមានភាគកម្មលើសពីដប់ប្រាំភាគរយ (១៥%) នៅក្នុងក្រុមហ៊ុនមួយ ហើយសរុបភាគកម្មក្នុងក្រុមហ៊ុននានាមិនអាចលើសពីហុកសិបភាគរយ (៦០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ ។

**មាត្រា ៣៤.-**

ភាគកម្មនៅក្នុងដើមទុននៃសហគ្រាសនិងក្រុមហ៊ុនដូចខាងក្រោមនេះ មិនត្រូវវាងករិតភាគរយនីមួយៗ ឬរួមគ្នាដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះឡើយ :

១- សហគ្រាសមានចរិតឧស្សាហកម្ម អចលនទ្រព្យ ឬ ពាណិជ្ជកម្មដែលជាសកម្មភាពជាប់ជាមួយអាជីវកម្មនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ ក្រោយពីមានប្រតិវេទន៍ឬការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល តាមបទប្បញ្ញត្តិនៃជំពូកទី ៨ នៃច្បាប់នេះ ។

៣- ក្រុមហ៊ុនអាជីវកម្មកសិកម្ម ។

មាត្រា ៣៥.-

ត្រូវបានចាត់ទុកថាជាក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ សំរាប់ការអនុវត្តន៍ក្នុងចំណុច ២ នៃមាត្រា ៣៤ នៃច្បាប់នេះគឺ :

១- គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនហិរញ្ញវត្ថុ រួមបញ្ចូលទាំងក្រុមហ៊ុនដែលធ្វើសកម្មភាពដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

៣- សហគ្រាសដែលប្រកបរបរជាប្រក្រតី នូវប្រតិបត្តិការធនាគារនិងប្រតិបត្តិការហិរញ្ញវត្ថុនៅបរទេស ។

៤- ក្រុមហ៊ុនធានារ៉ាប់រង ។

មាត្រា ៣៦.-

កាលបើភាគទុនិកៈគ្រឹះស្ថានចំណុះច្បាប់នេះជាក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ ឬកាលបើគ្រឹះស្ថានចំណុះច្បាប់នេះខ្លួនឯងកាន់កាប់នូវភាគកម្មក្នុងក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ អាជ្ញាធរអាណាព្យាបាលត្រូវទាមទារ សំរាប់ការគណនាមូលនិធិផ្ទាល់សុទ្ធដើម្បីជាមូលដ្ឋានអោយអនុបាតប្រុងប្រយ័ត្ននៃគ្រឹះស្ថានចំណុះច្បាប់នេះ នូវ :

- ការដកចេញនៃភាគកម្មដែលគ្រឹះស្ថានក្រោយនេះកាន់កាប់ក្នុងក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ

- ការប្រមាចបញ្ចូលគ្នាជាមុននៃតារាងតុល្យការរបស់ចង្កោមក្រុមហ៊ុន នៅពេលដែលភាគកម្មទៅវិញទៅមកនេះមានចំនួនស្មើឬលើសពីម្ភៃភាគរយ (២០%) នៃដើមទុនក្រុមហ៊ុនពាក់ព័ន្ធ ។

មាត្រា ៣៧.-

ការចូលភាគកម្មដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុននីតិបុគ្គលមានចរិតឧស្សាហកម្មឬពាណិជ្ជកម្មដែលមានទីស្នាក់ការនៅបរទេស ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

# ជំពូកទី ១១

## ការបោះទីតាំងនៃគ្រឹះស្ថានចំណុះច្បាប់នេះ នៅបរទេសឬនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៣៨.-**

ការចូលភាគកម្មនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុនធនាគារឬក្រុមហ៊ុនហិរញ្ញវត្ថុ ព្រមទាំងការបើកសាខាឬការិយាល័យតំណាងនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៣៩.-**

ការបើកសាខាដោយគ្រឹះស្ថានចំណុះច្បាប់នេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

ការចូលភាគកម្មដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះមួយទៀត ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ ដល់មាត្រា ២៧ ព្រមទាំងមាត្រា ៣៣ ដល់មាត្រា ៣៥ នៃច្បាប់នេះ ។

# ជំពូកទី ១២

## អាជ្ញាធរអាណាព្យាបាលនិងអំណាចចេញបទបញ្ជា

**មាត្រា ៤០.-**

ធនាគារកណ្តាលបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារនិងលើសកម្មភាពប្រទាក់គ្នាដូចជាផ្សាររូបិយវត្ថុ ប្រព័ន្ធទូទាត់អន្តរធនាគារនិងអន្តរការិយកម្មហិរញ្ញវត្ថុ ។

ក្នុងតួនាទីនេះ ធនាគារកណ្តាល :

១- ចេញអាជ្ញាប័ណ្ណនិងកំណត់បែបបទនានាអំពីការចេញអាជ្ញាប័ណ្ណនេះ ។

២- រៀបចំ កាន់កាប់យ៉ាងទៀងទាត់ជាប្រចាំនិងចាត់ចែងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជានិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបញ្ជីរាយនាមធនាគារ ។

៣- ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតអោយកំណត់អោយច្បាស់ជាអាទិ៍នូវ :

ក- កំពស់ដើមទុនអប្បបរមានិងការយកទៅប្រើក្នុងប្រភេទទ្រព្យសកម្ម ។

ខ- អនុបាតឬមេគុណប្រុងប្រយ័ត្នផ្សេង១ ដែលពាក់ព័ន្ធជាពិសេសដល់សាច់ប្រាក់ងាយស្រួល សាធនភាព ការបំបែងហានិភ័យ និងការប្រឈមមុខទល់នឹងហានិភ័យនៃការប្តូរប្រាក់ឬនៃទីផ្សារ ។

គ- វិធីវាយតម្លៃសមតុល្យនៃគណនី ។

ឃ- លក្ខខណ្ឌនានាដែលគេអាចចូលភាគកម្មក្នុងដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះឬក្រុមហ៊ុនហិរញ្ញវត្ថុ ។

ង- លក្ខខណ្ឌនានាដែលគ្រឹះស្ថានចំណុះច្បាប់នេះអាចចូលភាគកម្មក្នុងដើមទុននៃក្រុមហ៊ុនដទៃទៀតដែលមានចរិតធនាគារឬហិរញ្ញវត្ថុ ។

ច- ចំណាត់ថ្នាក់ប្រភេទឥណទាននិងការធ្វើសំវិធានធនចំពោះបំណុលពិបាកទារ ។

ឆ- ប្រព័ន្ធគណនេយ្យធនាគារនិងបទដ្ឋានដែលពាក់ព័ន្ធ ។

ជ- លក្ខខណ្ឌនានា ដែលប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុត្រូវបានអនុវត្តចំពោះអតិថិជន ។

ឈ- ការរៀបចំសេវាកម្មអន្តរធនាគារជាអាទិ៍ ការបង្កើតមជ្ឈការនៃពត៌មាន នៃហានិភ័យ ឬនៃបំណុលពិបាកទារ ។

ញ- លក្ខខណ្ឌនៃការផ្តល់បដិប្បញ្ញត្តិ តាមករណីនីមួយ១ ក្នុងលក្ខណៈពិសេសនិងបណ្តោះអាសន្ន ។

ដ- លក្ខខណ្ឌនានា ដែលត្រូវធ្វើប្រតិវេទន៍ជូនឬសុំការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល អំពីការប្រែប្រួលឬការផ្លាស់ប្តូរដែលពាក់ពន្ធ័ជាមួយ នាមករណ៍ ទំរង់នីត្យានុកូល ដើមទុន ការដឹកនាំ ការបោះទីតាំង និងសកម្មភាពនៃគ្រឹះស្ថានចំណុះច្បាប់នេះឬនៃទីស្នាក់ការ ប្រសិនបើជាករណីសាខាធនាគារបរទេស ។

ឋ- ការប្រកបមុខរបរស្វែងរកអតិថិជនក្នុងវិស័យធនាគារឬហិរញ្ញវត្ថុ ។

ឌ- ការកំណត់ដោយពិគ្រោះជាមួយសមាគមវិជ្ជាជីវៈនៃគ្រឹះស្ថានចំណុះច្បាប់នេះនូវវិធាននៃការប្រព្រឹត្តិទៅនៃប្រព័ន្ធធានាប្រាក់បញ្ញើ ។

៣- បែបបទអនុវត្តនៃច្បាប់នេះ ដែលទាក់ទងដល់ភាពខុសគ្នាស្តីពី លក្ខន្តិកៈគតិយុត្ត វិសាលភាពនៃបណ្តាញ ឬ ប្រភេទនៃសកម្មភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

៤- ចាត់ចែងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបទបញ្ជាដែលតាក់តែងឡើងដោយសំអាងលើសិទ្ធិអំណាចរបស់ខ្លួន ។

៥- រាប់រង តាមដាន ត្រួតពិនិត្យប្រព័ន្ធធនាគារ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ជាអចិន្ត្រៃយ៍លើឯកសារនិងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ដល់ទីកន្លែងនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។ បើយល់ឃើញថាចាំបាច់ អាចពង្រាតការត្រួតពិនិត្យដល់ទីកន្លែង នៅក្នុងក្រុមហ៊ុនជាបុគ្គលសម្ព័ន្ធរាល់អង្គភាពដែលជាសម្ព័ន្ធញាតិដទៃទៀតជាអាទិ៍ ក្រុមហ៊ុនដែលជាភាគទុនិកៈ ។

៦- រៀបចំឬត្រួតពិនិត្យគ្រប់ប្រព័ន្ធទូទាត់អន្តរធនាគារ ។

៧- អាចទាមទារការផ្តល់ពត៌មានដែលខ្លួនវិនិច្ឆ័យថាមានប្រយោជន៍ដល់បេសកកម្មរបស់ខ្លួនពីគ្រឹះស្ថានចំណុះច្បាប់នេះ ពីរដ្ឋបាលនានា ពីស្នងការគណនី ឬ ពីគ្រប់នីតិបុគ្គលឬរូបវន្តបុគ្គលដទៃទៀត ។

៨- អាចសំរេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៥៤ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

បេសកកម្មរបស់អាជ្ញាធរអាណាព្យាបាល គឺ :

១- ចេញអោយគ្រឹះស្ថានចំណុះច្បាប់នេះនូវអាជ្ញាប័ណ្ណសំរាប់ធ្វើសកម្មភាពធនាគារឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានពិនិត្យគ្រប់ជ្រុងជ្រោយនូវហេតុផលគ្រប់យ៉ាង ។

២- ប្រកាសអោយប្រើនិងចាត់អនុវត្តវិធានប្រុងប្រយត្ន័នៃរចនាសម្ព័ន្ធនៃការគ្រប់គ្រង ដែលគ្រឹះស្ថានចំណុះច្បាប់នេះត្រូវប្រតិបត្តិតាម ។

៣- ត្រួតពិនិត្យជាអចិន្ត្រៃយ៍ជាក្រោយ នូវស្ថានភាពនិងដំណើរការរបស់គ្រឹះស្ថានចំណុះច្បាប់នេះ នៅលើឯកសារនិងទៅដល់ទីកន្លែង ។

៤- សំរេចដាក់ទណ្ឌកម្មដល់គ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងករណីមិនប្រតិបត្តិតាមច្បាប់ ។

៥- ប្តឹងទៅតុលាការ ប្រសិនបើគ្រឹះស្ថានចំណុះច្បាប់នេះមិនប្រតិបត្តិតាមច្បាប់និងបទបញ្ជាធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់សាធារណជន ។

អ្នកដឹកនាំនិងភាគទុនិកៈនៃគ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលខុសត្រូវក្នុងការភន្លំច្រឡំខាងយុទ្ធសាស្ត្រ កំហុសឬការភ័ន្តច្រឡំក្នុងកិច្ចគ្រប់គ្រង កង្វះការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១៤. ១៩. ២៧ និងមាត្រា ៣០ នៃច្បាប់នេះ ។

# ជំពូកទី ១៣
## វិធានការប្រុងប្រយ័ត្ន ការត្រួតពិនិត្យផ្ទៃក្នុង

**មាត្រា ៤២.-**

នៅក្នុងលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល គ្រឹះស្ថានចំណុះច្បាប់នេះមានកាតព្វកិច្ចគោរព មិនត្រឹមតែវិធានការនយោបាយរូបិយវត្ថុ ដែលមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគោរពបទដ្ឋានគ្រប់គ្រងទាំងឡាយ សំរាប់ធានាសាច់ប្រាក់ងាយស្រួលនិងសាធនភាព ចំពោះអ្នកផ្ញើប្រាក់ និងជាទូទៅ ចំពោះតតិយជន ក៏ដូចចំពោះសមតានៃរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនទៀតផង ។

ដើម្បីគណនាមូលនិធិផ្ទាល់សុទ្ធ ដែលជាមូលដ្ឋានក្នុងការកំណត់បទដ្ឋានប្រុងប្រយ័ត្នរបស់គ្រឹះស្ថានចំណុះច្បាប់នេះនីមួយៗ អាជ្ញាធរអាណាព្យាបាលត្រូវដកចេញនូវ :

១- ទ្រព្យគ្មានតម្លៃខាងទ្រព្យសកម្ម នៃតារាងតុល្យការរបស់គ្រឹះស្ថាននេះ ។

២- ភាគកម្មទាំងឡាយដែលមានចូលក្នុងក្រុមហ៊ុនមានចរិតជាធនាគារឬហិរញ្ញវត្ថុ ព្រមទាំងក្នុងលក្ខខណ្ឌដែលកំណត់តាមបទបញ្ជា នូវការអោយខ្ចីគ្រប់ប្រភេទនិងគ្រប់រយៈកាលដល់ភាគទុនិកៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ឬមូលប័ត្រដែលគេបានចុះហត្ថលេខា ។

**មាត្រា ៤៣.-**

នៅក្នុងលក្ខខណ្ឌកំណត់ដោយអាជ្ញាធរអាណាព្យាបាល គ្រឹះស្ថានចំណុះច្បាប់នេះត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលមានវត្ថុបំណងជាអាទិ៍ :

១- ពិនិត្យបញ្ជាក់ថាប្រតិបត្តិការ ដែលអនុវត្តដោយគ្រឹះស្ថានចំណុះច្បាប់នេះនិងការរៀបចំនីតិវិធី មានលក្ខណៈត្រឹមត្រូវតាមបទប្បញ្ញត្តិនិងបទបញ្ជា តាមបទដ្ឋាននិងរបៀបប្រើវិជ្ជាជីវៈ និងករណីយកិច្ចសាស្ត្រ ក៏ដូច តាមការតម្រង់ទិសនៃការដឹកនាំទូទៅរបស់គ្រឹះស្ថាន ។

២- ពិនិត្យបញ្ជាក់ថា ការិតកំណត់អំពីហានិភ័យជាអាទិ៍ នៃបដិភាគ ការប្តូរប្រាក់ អត្រាការប្រាក់ និងទីផ្សារ ត្រូវបានគោរពតាមយ៉ាងហ្មត់ចត់ ។

៣- ប្រុងប្រយ័ត្នចំពោះសច្ចភាពនៃពត៌មានគណនេយ្យ ថវិកា និងហិរញ្ញវត្ថុ ដែលផ្សព្វផ្សាយទៅ ផ្ទៃក្នុងនិងទៅខាងក្រៅ ជាពិសេស ចំពោះលក្ខខណ្ឌនៃកិច្ចបញ្ជិកា នៃការរក្សាទុក និងលទ្ធភាពប្រើប្រាស់នូវពត៌មាន នេះ ។

## ជំពូកទី ១៤

## កាតព្វកិច្ចគណនេយ្យ ការត្រួតពិនិត្យពីខាងក្រៅ ដោយស្នងការគណនី

**មាត្រា ៤៤.-**

បទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្មឬនៃលក្ខន្តិកៈនីត្យានុកូលរបស់ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ដែល ពាក់ព័ន្ធនិងការបញ្ឈប់បញ្ជី ការត្រួតពិនិត្យគណនី ព្រមទាំងការបញ្ជាក់អះអាងលើគណនី ដោយស្នងការគណនី ត្រូវអនុវត្តលើគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៤៥.-**

គ្រឹះស្ថានចំណុះច្បាប់នេះមានកាតព្វកិច្ចតាក់តែងនិងផ្សព្វផ្សាយ ហើយក្នុងករណីចាំបាច់ ច្របាច់ ចូលគ្នានូវគណនីរបស់ក្រុមខ្លួន តាមលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

ទន្ទឹមនេះ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវបង្ហាញជូន អាជ្ញាធរអាណាព្យាបាលដោយទៀងពេលនូវ ស្ថានភាពគណនេយ្យ អំពីការអនុវត្តនីតិវិធានការប្រុងប្រយ័ត្ននីត្យានុកូលឬនៃបទបញ្ជា ។

**មាត្រា ៤៦.-**

ស្នងការគណនីអាចធ្វើប្រតិបត្តិការនៅក្នុងគ្រឹះស្ថានចំណុះច្បាប់នេះបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

មុននឹងធ្វើការបញ្ជាក់អះអាងលើគណនី ស្នងការគណនីពិនិត្យសច្ចភាពនៃពត៌មានគណនេយ្យដែលមាននៅឯណាច់ការិយបរិច្ឆេទ ក្នុងតារាងតុល្យការ ក្រៅតារាងតុល្យការ ក្នុងគណនីអាជីវកម្ម និងក្នុងតារាងឧបសម្ព័ន្ធ ដែលសំរាប់ផ្សព្វផ្សាយឬផ្ញើជូនអាជ្ញាធរអាណាព្យាបាល ។

ស្នងការគណនីត្រូវប្តឹងទៅតុលាការ បើសំគាល់ឃើញថាគ្រឹះស្ថានចំណុះច្បាប់នេះបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ឬនៃបទបញ្ជា ធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍សាធារណជន ។

បន្ទាប់ពីការពិនិត្យ ស្នងការគណនីត្រូវតាក់តែងនិងផ្ញើជូនអាជ្ញាធរអាណាព្យាបាលនូវរបាយការណ៍ដែលបរិយាយពីការកត់សំគាល់របស់ខ្លួន ជាអាទិ៍អំពី :

១- ការបង់ដើមទុន ។

២- វិធីវាយតម្លៃសមតុល្យ ។

៣- វិធីប្រចាច់ចូលគ្នានូវតុល្យការ ។

៤- ស្ថានភាពហិរញ្ញវត្ថុនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

៥- កិច្ចព្រមព្រៀងដែលអាចមានដោយផ្ទាល់ឬដោយប្រយោល ក្នុងការិយបរិច្ឆេទនីមួយៗ រវាងគ្រឹះស្ថានចំណុះច្បាប់នេះជាភាគីម្ខាងនិងភាគទុនិកៈឬអ្នកដឹកនាំរបស់ខ្លួនជាភាគីម្ខាងទៀត ។

អាជ្ញាធរអាណាព្យាបាលអាចស្នើសុំពីស្នងការគណនីនូវគ្រប់ពត៌មានលើសកម្មភាពនិងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចបញ្ជូនអោយស្នងការគណនី នូវសេចក្តីកត់សំគាល់របស់ខ្លួនឬនូវសំណើសុំអោយពន្យល់ ដែលស្នងការគណនីត្រូវតែឆ្លើយតបជាលាយល័ក្ខណអក្សរ ។

# ជំពូកទី ១៥
## ការសម្ងាត់វិជ្ជាជីវៈ

**មាត្រា ៤៧.-**

ចំពោះបុគ្គលដែលចូលរួម ទោះក្នុងឋានៈណាក៏ដោយ នៅក្នុងការអភិបាល ការដឹកនាំ ការកាន់ការត្រួតពិនិត្យផ្ទៃក្នុងឬពីខាងក្រៅនៃគ្រឹះស្ថានចំណុះច្បាប់នេះ ឬ ចំពោះបុគ្គលឯទៀតដែលធ្វើការងារអោយគ្រឹះស្ថានចំណុះច្បាប់នេះ មិនត្រូវបរិហារបញ្ចេញប្រាប់ដល់ជនណាក៏ដោយ នូវពត៌មានដែលមានចរិតសម្ងាត់លើសេចក្ដីប្រកាស ហេតុការណ៍ សារលិខិត តួលេខ ឬ អត្ថន័យនៃឯកសារគណនេយ្យឬរដ្ឋបាលដែលខ្លួនបានដឹងតាមរយៈមុខងាររបស់ខ្លួន ។

បុគ្គលទាំងឡាយណាដែលមិនគោរពតាមកាតព្វកិច្ចទាក់ទងនឹងការរក្សាការសម្ងាត់វិជ្ជាជីវៈនេះត្រូវទទួលទោសដែលចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះ ។

ប៉ុន្តែកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈនេះ មិនអាចជំទាស់នឹងអាជ្ញាធរអាណាព្យាបាល ស្នងការ-គណនី អភិបាលបណ្ដោះអាសន្ន អ្នកជំរះបញ្ជី ក៏ដូចជាអាជ្ញាធរតុលាការដែលចាត់ការក្នុងក្របខ័ណ្ឌនៃនីតិព្រហ្មទណ្ឌ ។

# ជំពូកទី ១៦
## សម្ព័ន្ធញាតិរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

**មាត្រា ៤៨.-**

បន្ថែមលើបទប្បញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់នេះ ស្ដីពីការគណនាមូលនិធិផ្ទាល់សុទ្ធ ការសហការខាងហិរញ្ញវត្ថុគ្រប់ប្រភេទ ដែលផ្ដល់ដោយគ្រឹះស្ថានចំណុះច្បាប់នេះ ទោះតាមរូបភាពណាក៏ដោយ ត្រូវតែស្ថិតនៅក្រោមបទបញ្ជារបស់អាជ្ញាធរអាណាព្យាបាលដែលសំដៅ ម្យ៉ាងត្រូវតែដឹងជាអចិន្ត្រៃយ៍អំពីការសហការនេះ និងម្យ៉ាងទៀតត្រូវស្ថិតនៅក្នុងកំរិតកំណត់ កាលបើហត្ថគាហកៈត្រូវបានចាត់ទុកជាភាគីក្នុងសម្ព័ន្ធញាតិ ។

មាត្រា ៤៩.-

ក្នុងន័យនៃច្បាប់នេះ ត្រូវបានចាត់ទុកជាភាគីក្នុងសម្ព័ន្ធញាតិជាមួយគ្រឹះស្ថានចំណុះច្បាប់នេះ គឺ :

១- បុគ្គលទាំងឡាយដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ។

២- ក្រុមហ៊ុនណាដែលគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ឬដោយប្រយោល នូវភាគកម្មយ៉ាងតិចស្មើនឹងដប់ភាគរយ (១០%) នៃដើមទុនឬតំណាងយ៉ាងតិចដប់ភាគរយ (១០%) នៃសិទ្ធិបោះឆ្នោត ។

៣- បុគ្គលណាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ឬ ការត្រួតពិនិត្យផ្ទៃក្នុង ។

៤- រាល់សវនករគណនី ។

មាត្រា ៥០.-

អាជ្ញាធរអាណាព្យាបាលមានសិទ្ធិសុំអោយគ្រឹះស្ថានចំណុះច្បាប់នេះអនុវត្តការសហការខាងហិរញ្ញវត្ថុ តាមទីតាំងដូចគ្នា ចំពោះហត្ថលាភកៈ ដែលអាជ្ញាធរអាណាព្យាបាលចាត់ទុកជាភាគីសម្ព័ន្ធជិតស្និទ្ធ ជាអាទិ៍ខាងពង្សឬហិរញ្ញវត្ថុជាមួយបុគ្គលទាំងឡាយដែលមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ឬចំពោះហត្ថលាភកៈមានភាគកម្មតិចជាងកំរិតដែលមានចែងកំណត់ក្នុងមាត្រា ៤៩ នៃច្បាប់នេះក៏ពិតមែន តែមានឥទ្ធិពលក្នុងការគ្រប់គ្រងដោយហេតុមានការបំបែកដើមទុនហួសប្រមាណ ។

# ជំពូកទី ១៧

## ការសំអាតប្រាក់

មាត្រា ៥១.-

យោងតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០១៩៧-០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៧ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវតែអនុវត្តក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយត្រូវចាត់គ្រប់វិធានការសំដៅ ម្យ៉ាងកត់អត្តសញ្ញាណច្បាស់លាស់របស់អតិថិជនទាំងអស់និង

របស់ប្រតិបត្តិការទាំងឡាយដែលធ្វើតាមរយៈខ្លួន បើសិនជាលើសពីកំរិតមួយដែលអាជ្ញាធរអាណាព្យាបាលបានកំណត់ ហើយសំដៅម្យ៉ាងទៀត រក្សានូវឯកសារពាក់ព័ន្ធទាំងអស់យ៉ាងតិចអោយបានដប់ឆ្នាំ (១០ឆ្នាំ) ។

# ជំពូកទី ១៨

## ទណ្ឌកម្មខាងវិន័យ

**មាត្រា ៥២.-**

ប្រសិនបើគ្រឹះស្ថានប្រតិស្រុតបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ឬនៃបទបញ្ជាស្តីពីសកម្មភាពរបស់ខ្លួន ឬប្រសិនមិនបានធ្វើតាមការដាស់តឿន ឬប្រសិនមិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាលអាចសំរេចដាក់ តាមនីតិវិធីដែលធ្វើចំពោះមុខសាមីខ្លួន នូវទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមធ្វើប្រតិបត្តិការមួយចំនួននិងការកំណត់ព្រំដែនដទៃទៀត ក្នុងការធ្វើសកម្មភាព
- ការព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ឬច្រើននាក់ ដោយមានឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការអោយលាឈប់ពីការងារជាស្វ័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ឬច្រើននាក់ ដោយមានឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការដាក់អោយស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់
- ការដកហូតអាជ្ញាប័ណ្ណជាស្ថាពរនិងការដាក់អោយជំរះបញ្ជីជាបន្ទាប់ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចសំរេច ឬ ដោយជំនួស ឬ ដោយបន្ថែមលើទណ្ឌកម្មទាំងនេះ នូវការពិន័យជាប្រាក់យ៉ាងច្រើនបំផុតត្រឹមស្មើនឹងដើមទុនអប្បបរមាដែលតំរូវអោយគ្រឹះស្ថាននោះអនុវត្ត ។

**មាត្រា ៥៣.-**

ការតែងតាំងអភិបាលបណ្ដោះអាសន្នឬអ្នកជំរះបញ្ជីគឺជាវិធានការប្រញាប់បន្ទាន់ ដែលមានចរិត អភិបាលនិងអភិរក្ស ។ ការតែងតាំងនេះត្រូវបានជូនដំណឹងជាផ្លូវការដល់គ្រឹះស្ថានសាមី ហើយមានប្រសិទ្ធិភាព អនុវត្តជាបន្ទាន់ ។

**មាត្រា ៥៤.-**

ទណ្ឌកម្មឯទៀតខាងវិន័យ ដែលមានចរិតជាសីលធម៌ឬជាប្រាក់កាស គឺជាការសំរេចយុត្តាធិការ ធ្វើឡើងដោយអាជ្ញាធរអាណាព្យាបាលដែលជាអ្នកមានសិទ្ធិសំរេចចុងក្រោយបំផុតជាស្ថាពរ ។ ទណ្ឌកម្មទាំងនេះ ត្រូវបានអនុវត្តជាបន្ទាន់ ប៉ុន្តែអាចជាកម្មវត្ថុប្ដឹងសាទុក្ខបានដើម្បីវិនិច្ឆ័យដោយមូលហេតុខុសខាងទំរង់ឬខាងនីតិវិធី នៅចំពោះមុខយុត្តាធិការរដ្ឋបាលខ្ពស់បំផុត ។

## ជំពូកទី ១៩

## ទណ្ឌកម្មខាងព្រហ្មទណ្ឌ

**មាត្រា ៥៥.-**

ក្រៅពីទណ្ឌកម្មដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នានា ឬលើលក្ខន្តិកៈនីត្យានុកូលនៃក្រុមហ៊ុន មិនមែនពាណិជ្ជកម្ម ទណ្ឌកម្មខាងក្រោមនេះអាចត្រូវបានអនុវត្តនៅក្នុងន័យនៃច្បាប់នេះគឺ :

១- បុគ្គលណា ជាឯកត្តជនក្ដីឬក្នុងនាមអង្គភាពក្ដី ដែលយកប្រតិបត្តិការធនាគារជាវិជ្ជាជីវៈជា ប្រក្រតីនិងសំរាប់សាធារណជនដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ដល់ប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០៛) ដល់ពីររយហាសិបលានរៀល (២៥០.០០០.០០០៛) ឬទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ដោយមិនទាន់គិតដល់ការបិទគ្រឹះស្ថានផង ។

២- បុគ្គលណាឬអង្គភាពណា ដែលបំពានលើបទប្បញ្ញត្តិនៃមាត្រា ៩, ១១, ១៨, ១៥, ២៧, ៣០ និងមាត្រា ៤៧ នៃច្បាប់នេះ ត្រូវរងទណ្ឌកម្មខាងព្រហ្មទណ្ឌដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៥ នៃច្បាប់នេះ ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០៛) ដល់ដប់លានរៀល (១០.០០០.០០០៛) ឬមួយក៏ទទួលទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ចំពោះបុគ្គលណា ទោះជាឯកត្តជនក្តីឬក្នុងនាមអង្គភាពក្តីដែល :

- បំពានលើបទប្បញ្ញត្តិនៃមាត្រា ៨. ១៣. ២៣. ២៤. ២៨. ៣៨. ៣៩. ៤៤. ៤៥. ៤៦ និងមាត្រា ៥១ នៃច្បាប់នេះ

- ឬ មិនឆ្លើយតបនឹងការសុំព័ត៌មានដូចមានចែងក្នុងចំណុច ៧ នៃមាត្រា ៤០នៃច្បាប់នេះ ពីសំណាក់អាជ្ញាធរអាណាព្យាបាល បន្ទាប់ពីការដាក់កំហិត

- ឬ ជូនដំណឹងដោយចេតនា នូវព័ត៌មានខុសដល់អាជ្ញាធរអាណាព្យាបាល

- ឬ បង្កឧបសគ្គ ដល់ការត្រួតពិនិត្យដោយអាជ្ញាធរអាណាព្យាបាលឬដោយស្នងការគណនីរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ព្រមទាំងដល់ការបំពេញបេសកកម្មរបស់អភិបាលបណ្តោះអាសន្នឬអ្នកជំរះបញ្ជីដែលតែងតាំងឡើងដោយអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៥៦.-**

ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះត្រូវសំរេចដោយតុលាការ ផ្អែកលើពាក្យបណ្តឹងឬការប្តឹងទាមទារដម្ងឺចិត្តពីបទអាជ្ញា ពីសំណាក់អាជ្ញាធរអាណាព្យាបាលឬពីសំណាក់សមាគមវិជ្ជាជីវៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ដែលចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ ។

## ជំពូកទី ២០

## ការអភិបាលបណ្តោះអាសន្ន ការជំរះបញ្ជី

**មាត្រា ៥៧.-**

ប្រសិនបើមានគ្រោះភ័យធ្ងន់ធ្ងរនិងជាក់ស្តែងលើសាធនភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ និងប្រសិនបើការបំពេញបង្គ្រប់មូលនិធិផ្ទាល់ដែលចែងក្នុងចំណុច ២ នៃមាត្រា ១៤. មាត្រា ១៥. ២៧ និង មាត្រា ៣០ នៃច្បាប់នេះនៅតែគ្មានប្រសិទ្ធភាព អាជ្ញាធរអាណាព្យាបាលអាច ជាស្វ័យប្រវត្តិ ឬតាមសំណើរបស់អ្នកដឹកនាំ

ឬរបស់ភាគទុនិកៈ តែងតាំងអភិបាលបណ្តោះអាសន្ន សំរាប់រយៈពេលដំបូងដែលមិនអាចលើសពីបីខែ (៣ខែ) ។ ប្រសិនបើកាលៈទេសៈតម្រូវ បេសកកម្មរបស់អភិបាលបណ្តោះអាសន្នអាចត្រូវបានពន្យារពេលបីខែ (៣ខែ) ទៀត ។ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលបន្ទុកក្នុងការចេញសោហ៊ុយទាំងអស់ ។

**មាត្រា ៥៨.-**

ក្រោយពេលតែងតាំង អភិបាលបណ្តោះអាសន្នមានសិទ្ធិអំណាចផ្តាច់មុខក្នុងការដឹកនាំ ការគ្រប់គ្រង និងជាតំណាងអោយគ្រឹះស្ថានចំណុះច្បាប់នេះ ។

**មាត្រា ៥៩.-**

បេសកកម្មចំបងរបស់អភិបាលបណ្តោះអាសន្ន គឺ :

- រៀបចំជាបន្ទាន់នូវការវាយតម្លៃថា គ្រឹះស្ថានចំណុះច្បាប់នេះអាចឬមិនអាចមានសាធនភាព
- គ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ដោយការពារអោយបានជាអតិបរមានូវសាធនភាពរបស់គ្រឹះស្ថាន និងសមភាពរវាងអ្នកផ្ញើប្រាក់ឬឥណទាយក ។

**មាត្រា ៦០.-**

អភិបាលបណ្តោះអាសន្នត្រូវធ្វើរបាយការណ៍ពីបេសកកម្មរបស់ខ្លួនទៅអាជ្ញាធរអាណាព្យាបាល ដើម្បីដកចេញនូវវិធានការអភិរក្ស បន្ទាប់ពីការវាយតម្លៃ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានសាធនភាព ហើយគ្រឹះស្ថាននេះអាចគោរពតាមរាល់វិធានការប្រុងប្រយ័ត្នតាមច្បាប់និងតាមបទបញ្ជា ។

**មាត្រា ៦១.-**

ប្រសិនបើបន្ទាប់ពីការវាយតម្លៃ គ្រឹះស្ថានអាចមានសាធនភាព ប៉ុន្តែប្រសិនបើគ្រឹះស្ថាននេះ ក្នុងរយៈពេលបីខែ (៣ខែ) គ្មានលទ្ធភាពអនុវត្តវិធានការតាមបទដ្ឋានប្រុងប្រយ័ត្នទាក់ទងដល់មូលនិធិផ្ទាល់សុទ្ធ និងទាក់ទងដល់សាច់ប្រាក់ងាយស្រួល អាជ្ញាប័ណ្ណអាចត្រូវដកហូតវិញ ហើយការអភិបាលបណ្តោះអាសន្នត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីក្រៅផ្លូវតុលាការ ដោយគ្រឹះស្ថានចំណុះច្បាប់នេះជាអ្នកទទួលចេញសោហ៊ុយ ។

អ្នកជំរះបញ្ជី ដែលអាចជាអភិបាលបណ្ដោះអាសន្ន ត្រូវជំរះទ្រព្យសកម្មនិងសងបំណុលនៃគ្រឹះស្ថាន ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៦២.-**

ប្រសិនបើបន្ទាប់ពីការវាយតម្លៃ គ្រឹះស្ថានគ្មានសាធនភាព អាជ្ញាប័ណ្ណត្រូវបានដកហូតភ្លាម ហើយការអភិបាលបណ្ដោះអាសន្នត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីតាមផ្លូវតុលាការ ហើយសោហ៊ុយចំណាយជាបន្ទុករបស់គ្រឹះស្ថាន ។

អភិបាលបណ្ដោះអាសន្នត្រូវធ្វើប្រតិវេទន៍នូវការឈប់សងប្រាក់ហើយប្ដឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីតែងតាំងអ្នកជំរះបញ្ជីតាមផ្លូវតុលាការ ។ អភិបាលបណ្ដោះអាសន្នអាចបំពេញតួនាទីជាអ្នកជំរះបញ្ជីបានដែរ ។

អ្នកជំរះបញ្ជីតាមផ្លូវតុលាការ ជំរះទ្រព្យសកម្ម ហើយដោះស្រាយរាល់កិច្ចសន្យា ក្រោមការត្រួតពិនិត្យរបស់តុលាការនិងតាមនីតិវិធីនៃច្បាប់ទូទៅ ។ ប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុដែលប្រព្រឹត្តឡើងនៅពេលជំរះបញ្ជី ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៦៣.-**

ការជំរះបញ្ជី តាមផ្លូវតុលាការឬមិនតាមផ្លូវតុលាការ អាស្រ័យដោយគ្រឹះស្ថានចំណុះច្បាប់នេះ គ្មានឬមានសាធនភាព នឹងត្រូវធ្វើឡើងបន្ទាប់ពីការប្រកាសដកអាជ្ញាប័ណ្ណ ដោយការដាក់ទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

**មាត្រា ៦៤.-**

ផ្អែកលើលក្ខណៈពិសេសនៃសកម្មភាពធនាគារឬហិរញ្ញវត្ថុ កិច្ចសន្យាក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ បន្ទាប់ពីបានប្រកាសទុកជាបានការ ត្រូវជំរះស្រឡះតាមលំដាប់ដូចខាងក្រោម :

១- សោហ៊ុយនិងតម្លៃការដែលពាក់ព័ន្ធដល់ការអភិបាលបណ្ដោះអាសន្ននិងការជំរះបញ្ជីតាមផ្លូវតុលាការឬមិនតាមផ្លូវតុលាការ ។

២- ពន្ធនិងអាករ ដែលត្រូវបង់ជូនរតនាគារជាតិ ។

៣- បៀវត្សបុគ្គលិករបស់គ្រឹះស្ថានចំណុះច្បាប់នេះសំរាប់រយៈពេលបីខែ (៣ខែ) មុនថ្ងៃកំណត់តែងតាំងអ្នកជំរះបញ្ជី ។

៤- ឥណទេយ្យធានាដោយឯកសិទ្ធិដទៃទៀតឬដោយប្រាតិភោគ ក្នុងករណីដែលការធានាទាំងនេះត្រូវបានព្រមព្រៀងនៅក្រៅរយៈពេលមន្ទិលសង្ស័យ ។

៥- ប្រាក់បញ្ញើជាសាច់ប្រាក់ ជាមាស និងជាមូលប័ត្រ ឬ ឥណទេយ្យគ្រប់ប្រភេទដែលកាន់កាប់ដោយសាមីជន ក្រៅពីស្ថាប័នធនាគារឬហិរញ្ញវត្ថុ ដោយចាប់ផ្តើមសងអតិថិជនម្នាក់ៗ ដែលជាម្ចាស់គណនីប្រាក់បញ្ញើជារៀលនូវទឹកប្រាក់ដូចគ្នាខ្ពស់បំផុតចំនួនពីរលានរៀល (២.០០០.០០០រ) ។

៦- ប្រាក់បញ្ញើដទៃទៀតជាសាច់ប្រាក់ ជាមាស និងជាមូលប័ត្រ ឬ ឥណទេយ្យផ្សេងទៀតដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុ ។

៧- ឥណទេយ្យជាប់លក្ខខណ្ឌនិងការអោយខ្ចីជាប់ភាគភាព ។

**មាត្រា ៦៥.-**

អាជ្ញាធរអាណាព្យាបាល អភិបាលបណ្តោះអាសន្ន ឬអ្នកជំរះបញ្ជី ត្រូវតែប្តឹងទៅតុលាការប្រសិនបើសំគាល់ឃើញមានបទល្មើសធ្ងន់ធ្ងរខាងព្រហ្មទណ្ឌដែលជំទាស់នឹងបទប្បញ្ញត្តិច្បាប់ឬបទបញ្ជា ។

**មាត្រា ៦៦.-**

អភិបាលបណ្តោះអាសន្នឬអ្នកជំរះបញ្ជី ត្រូវបានជ្រើសរើសដោយអាជ្ញាធរអាណាព្យាបាលនៅក្នុងបញ្ជីអ្នកមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិ ដែលអាជ្ញាធរអាណាព្យាបាលបានរៀបចំជាមួយក្រសួងយុត្តិធម៌ ។

**មាត្រា ៦៧.-**

ប្រសិនបើបេសកកម្មខាងលើត្រូវរាំងស្ទះតាមបែបណាក្តីដោយគ្រឹះស្ថានចំណុះច្បាប់នេះ អភិបាលបណ្តោះអាសន្ននិងអ្នកជំរះបញ្ជី ត្រូវប្រើប្រាស់សិទ្ធិប្តឹងតវ៉ាចំពោះមុខតុលាការពីបទល្មើសមិនអោយបំពេញមុខងារ ។

**មាត្រា ៦៨.-**

ភាគទុនិកៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលមានសាធនភាព អាចសំរេចក្នុងមហាសន្និបាតវិសាមញ្ញ នូវការជំរះបញ្ជីគ្រឹះស្ថានរបស់ខ្លួនបានតាមនីតិវិធីនៃច្បាប់ទូទៅ ។

ផ្តើមចេញពីសេចក្តីសំរេចនេះ អាជ្ញាធរអាណាព្យាបាលតែងតាំងអ្នកជំរះបញ្ជីដើម្បីអោយធ្វើប្រតិបត្តិការជំរះបញ្ជី ក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

**មាត្រា ៦៩.-**

តម្លៃការនិងសោហ៊ុយផ្សេងៗទៀត ដែលកើតមកពីការអភិបាលបណ្តោះអាសន្នឬដោយការជំរះបញ្ជីត្រូវគិតគូរលើមូលដ្ឋាននៃអត្រាតំលៃវិជ្ជាជីវៈប្រចាំតំបន់ជាធរមាននិងជាបន្ទុកស្វ័យប្រវត្តិរបស់គ្រឹះស្ថានចំណុះច្បាប់នេះ តាមការអនុវត្តន៍មាត្រា ៥៧, ៦១, ៦២, ៦៣ និងមាត្រា ៦៤ នៃច្បាប់នេះ ។

## ជំពូកទី ២១
## កិច្ចការពារអតិថិជន

**មាត្រា ៧០.-**

អាជ្ញាធរអាណាព្យាបាលមានបន្ទុកកំណត់នូវតំរូវវិធាននៃការដឹកនាំល្អ ក្រោយពីការពិគ្រោះយោបល់ពីវិជ្ជាជីវៈ សំដៅការពារអតិថិជន ជាអាទិ៍ចំពោះកិច្ចការដែលពាក់ពន្ធ័ទៅនឹង :

១- តម្លាភាព និងការកំរិតលក្ខខណ្ឌនៃបរិយាទាននិងតម្លៃការនៃប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុ ។

២- ការអនុវត្តន៍ឬការបញ្ឈប់ឥណទាន ។

៣- ការចរចាឡើងវិញលើការអោយខ្ចី ។

**មាត្រា ៧១.-**

សមតុល្យឥណទាយី នៃគណនីរបស់អតិថិជន ឬរបស់គ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុ ដែលនៅសល់

គ្មានចលនាពីសំណាក់ម្ចាស់គណនី ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ជាប់គ្នា ត្រូវតែផ្ទេរ ក្រោយពីរយៈពេលនេះ ជូនទៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងប្រាក់បញ្ញើធនាគារ ដែលត្រូវឯងអាជ្ញាយុកាលលទ្ធកម្ម ។

# ជំពូកទី ២២
# ការរៀបចំវិជ្ជាជីវៈ

**មាត្រា ៧២.-**

នៅក្រោមរូបភាពគតិយុត្តឬឯកទេសកម្មណាក៏ដោយ គ្រឹះស្ថានចំណុះច្បាប់នេះទាំងអស់មានកាតព្វកិច្ចចូលជាសមាជិកដោយផ្ទាល់ទៅក្នុងសមាគមវិជ្ជាជីវៈតែមួយគត់ ដែលលក្ខន្តិកៈត្រូវតែដាក់សុំទិដ្ឋាការជាមុនពីសំណាក់អាជ្ញាធរអាណាព្យាបាល ។ ដោយឡែកចំពោះក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ការចូលជាសមាជិកក្នុងសមាគមវិជ្ជាជីវៈត្រូវធ្វើតាមរយៈអង្គការសហពន្ធ័រួមដូចមានកំណត់ក្នុងមាត្រា ១១ នៃច្បាប់នេះ ។

សមាគមនេះត្រូវស្ថិតនៅក្រោមអំណាចប្រធានតែម្នាក់ ដែលសមាជិកទាំងអស់ត្រូវបោះឆ្នោតជ្រើសរើសតាមនីតិវិធីច្បាស់លាស់ក្នុងលក្ខន្តិកៈរបស់សមាគម ។ ប៉ុន្តែនៅក្នុងផ្ទៃក្នុងនៃសមាគម សមាជិកអាចប្រមូលផ្តុំគ្នា ជាផ្នែករងដាច់ៗគ្នាទៅតាមឯកទេសកម្មវិជ្ជាជីវៈរបស់ខ្លួន ។

**មាត្រា ៧៣.-**

សមាគមវិជ្ជាជីវៈនេះមានកម្មវត្ថុដូចតទៅ :

១- តំណាងផលប្រយោជន៍សមូហភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ជាពិសេសចំពោះអំណាចសាធារណៈនិងអាជ្ញាធរអាណាព្យាបាល ។

២- ផ្តល់ពត៌មានដល់សមាជិកនិងសាធារណជន ស្តីពីវិជ្ជភាពនៃប្រតិបត្តិការធនាគារនិងហិរញ្ញវត្ថុ ។

៣- សិក្សារាល់បញ្ហាដែលជាប្រយោជន៍រួម ។

៤- លើកកំពស់ការបណ្តុះបណ្តាលអន្តរធនាគារខាងវិជ្ជាជីវៈ ។

៥- រៀបចំនិងគ្រប់គ្រងរាល់សេវាអន្តរធនាគារ ដោយមានការយល់ព្រមឬក្រោមការត្រួតពិនិត្យពីអាជ្ញាធរអាណាព្យាបាល ។

៦- ប្ដឹងទៅតុលាការ យោងតាមមាត្រា ៥៦ នៃច្បាប់នេះ ។

# ជំពូកទី ២៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៧៥.-**

១- គ្រឹះស្ថានដែលបានទទួលប្រតិស្រុតពីមុនមក ត្រូវកែតំរូវលក្ខន្តិកៈសកម្មភាពនិងរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនអោយបានសមស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ក្រោយពីច្បាប់នេះចូលជាធរមាន និងត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មីនៅក្នុងរយៈពេលដូចគ្នានេះ ។

ក្រោយពីការពិនិត្យពាក្យសុំ ធនាគារជាតិនៃកម្ពុជានឹងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវឈ្មោះគ្រឹះស្ថានដែលបានទទួលប្រតិស្រុតតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្រោយរយៈពេលប្រាំមួយខែ (៦ខែ) គ្រឹះស្ថានណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទដ្ឋានទាំងឡាយសំរាប់អនុវត្ត ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួននិងត្រូវធ្វើការជំរះបញ្ជី ។

២- គ្រឹះស្ថានណាយកប្រតិបត្តិការមានចរិតជាធនាគារឬហិរញ្ញវត្ថុធ្វើអាជីវកម្មដែលចែងក្នុងមាត្រា ២ មាត្រា៣ និងមាត្រា ៤ នៃច្បាប់នេះ ដោយគ្មាននីតិសម្បទា ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់ខ្លួន ហើយត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទៅអាជ្ញាធរអាណាព្យាបាលពាក់ព័ន្ធក្នុងរយៈពេលបីខែ (៣ខែ) ចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។

៣- អង្គភាពទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងអនុវត្តប្រតិបត្តិការធនាគារសំដៅជំរុញអន្តរការិយកម្មធនាគារ នៅក្នុងវិស័យកសិកម្ម សិប្បកម្ម ជំនួញតូចតាចនិងសេវាចំពោះឯកត្តជន អាចបន្តសកម្មភាពរបស់ខ្លួននៅក្នុងលក្ខខណ្ឌបដិប្បញ្ញត្តិនៃច្បាប់នេះ ដែលត្រូវបានកំណត់ដោយបទបញ្ជាពិសេសរបស់ធនាគារជាតិនៃកម្ពុជា ជាអាទិ៍អំពី :

- ដើមទុនអប្បបរមា

- អាជ្ញាប័ណ្ណនិងបែបបទអនុវត្ត
- វិធានការប្រុងប្រយ័ត្នដែលត្រូវប្រតិបត្តិតាម
- លក្ខខណ្ឌនៃការបោះទីតាំង ។

## ជំពូកទី ២៤
## អវសានប្បញ្ញត្តិ

**មាត្រា ៧៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ២១៨ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**អគ្គនាយកសារគ្រឹះជាតិកម្ពុជា**

**ហត្ថលេខា**

**ជា ចាន់តូ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ឧបករណ៍អាចជួញដូរបាន

# និង

# ប្រតិបត្តិការទូទាត់សងប្រាក់

ព្រះរាជក្រម

នស/រកម/១០០៥/០៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់អគ្គទេសាភិបាលធានាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

/៤៩

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះគ្រប់គ្រងលើឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ រួមបញ្ចូលទាំងគណនីធនាគារ និងប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់ ។

១-ឧបករណ៍អាចជួញដូរបានសំដៅដល់បញ្ជា ឬ ការសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីទូទាត់សងចំនួនប្រាក់ជាកំណត់មួយ ដែលអាចផ្ទេរបានតាមរយៈការប្រគល់ ហើយកាលបើចាំបាច់ក៏មានបិដ្ឋិលេខផងដែរ ។ ឧបករណ៍អាចជួញដូរបានដែលគ្រប់គ្រងដោយច្បាប់នេះ រួមមានមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា ។

២-ប្រតិបត្តិការទូទាត់សងប្រាក់ ដែលគ្រប់គ្រងនិងកំណត់ដោយច្បាប់នេះ ជាការផ្ទេរមូលនិធិរវាង ឬ ពីគណនីធនាគារ ។ ប្រតិបត្តិការទូទាត់សងប្រាក់អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ ។ ប្រតិបត្តិការនេះ ត្រូវបានផ្តួចផ្តើមឡើងតាមរយៈបញ្ជាទូទាត់ ដែលអាចត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ តាមអេឡិចត្រូនិក និងដោយផ្ទាល់មាត់នៅក្រោមល័ក្ខខ័ណ្ឌខ្លះ ។

៣-ប្រព័ន្ធទូទាត់សងប្រាក់ រួមមានស្ថាប័ន ឬ យន្តការ ដែលសម្រួលដល់ការទូទាត់សងប្រាក់ជារូបិយវត្ថុ និងជាការផ្ទេរតម្លៃជារូបិយវត្ថុតាមរយៈប្រតិបត្តិការទូទាត់សងប្រាក់ ។

**មាត្រា ២.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

១-**ករណីប្រធានស័ក្តិ** សំដៅដល់ព្រឹត្តិការណ៍ ដែលជាឧបសគ្គមិនអាចចៀសផុតបាន មិនអាចគ្រប់គ្រងបាន និងហួសពីលទ្ធភាពត្រួតត្រារបស់បុគ្គល ដែលត្រូវអនុវត្តកាតព្វកិច្ច ។

២-**ការចេញផ្សាយ** សំដៅដល់ការសរសេរ ចុះហត្ថលេខា និងប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជាឱ្យទៅអ្នកកាន់ទីមួយ ។

៣-**ការចេញមូលប្បទានបត្រ ឬ រូបិយាណត្តិ** សំដៅដល់ការសរសេរ និងចុះហត្ថលេខាលើមូលប្បទានប័ត្រ ឬ រូបិយាណត្តិ ។

៤-**ការទូទាត់** សំដៅដល់ការសងប្រាក់ ដើម្បីជម្រះកាតព្វកិច្ចលើបញ្ជាទូទាត់អន្តរធនាគារ ។

៥-**ការបង្ហាញ** សំដៅដល់ការប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ដើម្បីសុំឱ្យធ្វើស្វីការចំពោះរូបិយាណត្តិ ឬ ទូទាត់សងប្រាក់ពីបហាវិត ឬ អ្នកចេញប័ណ្ណ ។

៦-**ការប្រតិបត្តិ** នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់ការអនុវត្តបញ្ជាដែលមាននៅក្នុងបញ្ជាទូទាត់ តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ។

៧-**ការផាត់ទាត់** សំដៅដល់ការប្តូរគ្នា និងដំណើរការជាអន្តរធនាគារលើបញ្ជាទូទាត់ក្នុងគោលដៅគណនាចំនួនប្រាក់សុទ្ធ ជាទ្វេភាគីឬពហុភាគី ដែលធនាគារនីមួយៗជំពាក់គ្នាទៅវិញទៅមកក្នុងការទូទាត់រាល់បញ្ជាទូទាត់ដែលត្រូវបានបញ្ចូលមកក្នុងគ្រាផាត់ទាត់នីមួយៗ ។

៨-**ការផ្ទេរផ្ទៃក្នុង** សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងធនាគារជាមួយគ្នា ដោយមានបញ្ជាទូទាត់តែមួយ ។ អ្នកចូលរួមនៅក្នុងការផ្ទេរផ្ទៃក្នុង រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារដែលដើរតួជាអ្នកផ្តើមប្រតិបត្តិការផង និងជាធនាគារគោលដៅផង ហើយនិងអ្នកទទួល ។

៩-**ការផ្ទេរអន្តរធនាគារ** សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់នៅធនាគារពីរផ្សេងគ្នា ដោយមានបញ្ជាទូទាត់យ៉ាងតិចចំនួនពីរ ។ នៅក្នុងការផ្ទេរអន្តរធនាគារ :

ក-ធនាគារទទួលនីមួយៗ ដែលពុំមែនជាធនាគារគោលដៅប្រតិបត្តិតាមបញ្ជាទូទាត់នៃអ្នកផ្ញើរបស់ខ្លួន តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ហើយបញ្ជាទូទាត់ចុងក្រោយត្រូវបានផ្ញើទៅធនាគារគោលដៅ

ខ-អ្នកចូលរួមនៅក្នុងការផ្ទេរអន្តរធនាគារ រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារផ្តើមប្រតិបត្តិការ ធនាគារគោលដៅ និងអ្នកទទួល ព្រមទាំងអាចមាន

ធនាគារអន្តរការីមួយ ឬ ច្រើនផងដែរ

គ-នៅពេលណាដែលធនាគារផ្តើមប្រតិបត្តិការ ពុំបានទូទាត់ដោយផ្ទាល់ជាមួយធនាគារគោលដៅទេ យ៉ាងហោចណាស់ក៏ចាំបាច់ត្រូវមានធនាគារអន្តរ-ការីមួយ ឬ ច្រើនផងដែរ

ឃ-សម្រាប់បញ្ជាទូទាត់អន្តរធនាគារនីមួយៗ ធនាគារផ្ញើទូទាត់ជាមួយធនាគារទទួល ដូចមានចែងក្នុងមាត្រា ២០២ នៃច្បាប់នេះ ។

១០-**ការផ្ទេរឥណពន្ធ** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅធនាគាររបស់ខ្លួន ដោយផ្អែកលើការអនុញ្ញាតពីអ្នកសងប្រាក់ឱ្យធ្វើការទារប្រាក់ពីគណនីអ្នកសងប្រាក់ ។

១១-**ការផ្ទេរឥណទាន** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកសងប្រាក់ដែលបានចេញបញ្ជាទូទាត់ឱ្យធនាគារផ្ទេរមូលនិធិចេញពីគណនីរបស់ខ្លួនឱ្យទៅអ្នកទទួលប្រាក់ ឬទៅក្នុងគណនីអ្នកទទួលប្រាក់ ។

១២-**កិច្ចព្រមព្រៀង** ក្នុងផ្នែកទី ៧ ជំពូកទី ៥ នៃច្បាប់នេះសំដៅដល់កិច្ចសន្យារវាងធនាគារ និងអតិថិជន ដែលអនុវត្តចំពោះប្រតិបត្តិការគណនី រួមទាំងបញ្ហានានា ដូចជារយៈពេលនៃប្រតិបត្តិការនោះ ការកែប្រែ និងបញ្ជាទូទាត់ ។

១៣-**គណនី** សំដៅដល់គណនីទាំងឡាយ ដែលបានបើកនៅក្រោមកិច្ចសន្យារវាងអតិថិជន និងធនាគារ ទោះបីជាគណនីចរន្ត គណនីផ្ទេរប្រាក់ ឬ គណនីផ្សេងទៀតក្តី និងរួមទាំងគណនីនៅក្រោមទំនាក់ទំនងពិសេស ដែលបង្កើតឡើងក្នុងគោលបំណងអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់តែមួយប៉ុណ្ណោះ ។

១៤-**គណនីទូទាត់** សំដៅដល់គណនីដែលធនាគារមួយ បានបើកនៅក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ចូលនិងចេញ ។

១៥-**គណនីប្រាក់បញ្ញើមានសៀវភៅ** សំដៅដល់គណនីដែលត្រូវបានចុះឥណពន្ធ និងឥណទានដោយធនាគារ ដើម្បីកត់ត្រាប្រតិបត្តិការក្នុងសៀវភៅប្រាក់បញ្ញើដែលធនាគារបានចេញឱ្យអតិថិជនតាំងពីដំបូង ហើយត្រូវបានយកមកឱ្យធនាគារកត់ត្រារាល់ប្រតិបត្តិការ ។

១៦-**តាមការប្រគល់សិទ្ធិ** សំដៅដល់ការប្រគល់សិទ្ធិ ដែលមានកម្រិត

ꫝ/12४

ដើម្បីទារប្រាក់ក្នុងនាមអ្នកផ្ញើរ ។

១៧-**តាមអេឡិចត្រូនិក** សំដៅដល់មធ្យោបាយទូរគមនាគមន៍ភ្ជាប់ដោយប្រព័ន្ធកុំព្យូទ័រ ឬការបញ្ជូនជារូបវ័ន្ត ពុំមានការភ្ជាប់ប្រព័ន្ធកុំព្យូទ័រ មានខ្សែអាត់ ហ្វូណូក្រាម ឬឧបករណ៍ប្រហាក់ប្រហែលនេះ ។

១៨-**តម្លៃសម្រាប់ទារបំណុល** សំដៅដល់តម្លៃដែលត្រូវបានទទួលដោយអ្នកផ្ញើរនៅពេលធ្វើបេឡានិច័យ ឬតម្លៃដែលទារមកវិញដោយអ្នកទទួលការផ្ញើរ នៅលើឧបករណ៍អាចជួញដូរបាន ។

១៩-**តម្លៃសម្រាប់ធានា ឬតម្លៃសម្រាប់ដាក់បញ្ចាំ** សំដៅដល់ការផ្ញើរដោយមានការធានា ឬ ការផ្ញើរក្នុងគោលបំណងបង្កើតអត្ថប្រយោជន៍នៃការធានា និងដែលមិនមែនជាការផ្ញើរកម្មសិទ្ធិ ។

២០-**ថ្ងៃធ្វើការរបស់ធនាគារ** សំដៅដល់ពេលវេលាមួយផ្នែកនៃថ្ងៃដែលក្នុងអំឡុងពេលនោះ ធនាគារបានបើកទ្វារដើម្បីទទួលដំណើរការបញ្ជូនបញ្ជាទូទាត់ និងសារផ្សេងៗដែលទាក់ទងទៅនឹងប្រតិបត្តិការទូទាត់សងប្រាក់ ។

២១-**ថ្ងៃប្រសិទ្ធភាព** សំដៅដល់ថ្ងៃធ្វើការរបស់ធនាគារ ដែលនៅក្នុងថ្ងៃនោះ បញ្ជាទូទាត់ត្រូវបានអនុវត្តតាមបញ្ជារបស់អ្នកផ្ញើ ។

២២-**ធនាគារ** សំដៅដល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការធនាគារក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថាន ឬ អង្គភាពណាមួយដែលច្បាប់អនុញ្ញាតឱ្យទទួលប្រាក់បញ្ញើ ឬ ចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់លើគណនីរបស់អតិថិ-ជន ។

សាខា ឬ ការិយាល័យដោយឡែករបស់ធនាគារ ត្រូវបានចាត់ទុកជាធនា-គារដាច់ដោយឡែក សម្រាប់គោលបំណងនៃ (ក) ភារកិច្ចក្នុងការអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់ និង (ខ) ការគណនាពេលវេលាដែលក្នុងពេលនោះ ឬ កំណត់កន្លែងដែលនៅទីនោះសកម្មភាព ឬ សេចក្តីជូនដំណឹង ឬ បញ្ជាត្រូវបានធ្វើ ។

២៣-**ធនាគារគោលដៅ** សំដៅដល់ធនាគារ ដែលត្រូវបានបញ្ជាក់នៅក្នុងបញ្ជាទូទាត់ ដែលក្នុងនេះ ការទូទាត់ឱ្យទៅអ្នកទទួលប្រាក់ក្នុងការផ្ញើរឥណទាន ត្រូវ

បានធ្វើឡើង ឬ ដែលមានគណនីរបស់អ្នកសងប្រាក់ក្នុងការផ្ទេរឥណពន្ធ ។ ធនាគារគោលដៅ ជាធនាគារដែលទទួលបញ្ជាទូទាត់ក្រោយគេបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារគោលដៅ ជាធនាគាររបស់អ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារគោលដៅ ជាធនាគាររបស់អ្នកសងប្រាក់ ។

២៤-**ធនាគារផ្តើមប្រតិបត្តិការ** សំដៅដល់ធនាគារដែលទទួលបញ្ជាទូទាត់ដែលផ្តើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារផ្តើមប្រតិបត្តិការជាធនាគាររបស់អ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្តើមប្រតិបត្តិការជាធនាគាររបស់អ្នកទទួលប្រាក់ ។

២៥-**ធនាគារទទួល** សំដៅដល់ធនាគារ ដែលបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវបានបញ្ជូនឱ្យទៅ ។

២៦-**ធនាគារអន្តរការី** សំដៅដល់ធនាគារទទួល ដែលស្ថិតនៅកណ្តាលធនាគារផ្តើមប្រតិបត្តិការ និងធនាគារគោលដៅ ។

២៧-**នីតិវិធីសុវត្ថិភាព** សំដៅដល់នីតិវិធីបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអតិថិជន និងធនាគារទទួល ក្នុងគោលបំណង :

-ផ្ទៀងផ្ទាត់ថា បញ្ជាទូទាត់ ឬ ការបញ្ជាបញ្ឈប់ពិតជាបញ្ជារបស់អតិថិជន ឬ

-រាវរកការភ័ន្តច្រឡំក្នុងការបញ្ជូន ឬ ក្នុងខ្លឹមសារនៃបញ្ជាសងប្រាក់ ឬបញ្ជាបញ្ឈប់ ។

នីតិវិធីសុវត្ថិភាព អាចទាមទារឱ្យមានការប្រើប្រាស់វិធាន លេខកូដ ឬ លេខសម្ងាត់ ដែលបញ្ជាក់ពាក្យ ឬ ចំនួនប្រាក់ពាក្យមានន័យសម្ងាត់ នីតិវិធីសួរបញ្ជាក់ទៅវិញ ឬ វិធីប្រហាក់ប្រហែលផ្សេងទៀត ។ ការប្រៀបធៀបហត្ថលេខានៅលើបញ្ជាទូទាត់ ឬ ទំនាក់ទំនងជាមួយអតិថិជន ដែលមានគំរូហត្ថលេខាប្រតិស្រុតពុំមែនជានីតិវិធីសុវត្ថិភាពឡើយ ។

២៨-**បច្ចិលទិញដោយគ្មានសោហ៊ុយ** សំដៅដល់ការសន្យា ដែលអនុញ្ញាតឱ្យធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធ ដោយមិនតម្រូវឱ្យអ្នកកាន់ធ្វើវិរុទ្ធវាទ ។

8/128

២៩-**បញ្ជាទូទាត់** សំដៅដល់បញ្ជាទៅធនាគារឱ្យធ្វើការសងប្រាក់ ឬទារប្រាក់មួយចំនួនចេញពីគណនី ដែលបានចង្អុលបង្ហាញឱ្យទៅ ឬ សម្រាប់អ្នកទទួលប្រាក់ ឬ ឱ្យទៅ ឬ សម្រាប់គណនីរបស់អ្នកទទួលប្រាក់ និងរួមទាំងការកែប្រែណាមួយ នៅលើបញ្ជាទូទាត់ផងដែរ ។ បញ្ជានោះអាចមានកំណត់ថ្ងៃប្រសិទ្ធភាព ប៉ុន្តែមិនត្រូវស្ថិតនៅក្រោមលក្ខខណ្ឌណាមួយ ក្រៅពីអ្វីដែលធនាគារផ្តើមប្រតិបត្តិការបានព្រមព្រៀងអនុវត្តឡើយ ។ ភាគីនៃបញ្ជាទូទាត់ រួមមានអ្នកផ្ញើ និងធនាគារទទួល ។ នៅពេលណាដែលអ្នកផ្ញើជាធនាគារ នៅពេលនោះបញ្ជាទូទាត់ គឺជាបញ្ជាទូទាត់អន្តរធនាគារ ។

៣០-**បញ្ជាករ** សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬ រូបិយាណត្តិ ។

៣១-**បញ្ជារិត** សំដៅដល់បុគ្គលដែលទទួលបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬ រូបិយាណត្តិ ។

៣២-**ប្រតិបត្តិការទូទាត់សងប្រាក់** សំដៅដល់ការផ្ទេរមូលនិធិពីគណនីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ ឬ ឱ្យទៅគណនីអ្នកទទួលប្រាក់ ។ ប្រតិបត្តិការទូទាត់សងប្រាក់ :

(ក)អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ

(ខ)ត្រូវបានផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទៅកាន់ធនាគារផ្តើមប្រតិបត្តិការ ឱ្យអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់នោះ

(គ)ត្រូវបានអនុវត្តដោយធនាគារអ្នកសងប្រាក់ ដោយការកត់ត្រាឥណពន្ធលើគណនីរបស់អ្នកសងប្រាក់ ចំពោះធនាគាររបស់អ្នកទទួលប្រាក់វិញ ធ្វើការកត់ត្រាឥណទានលើគណនីរបស់អ្នកទទួលប្រាក់ ឬ ដាក់មូលនិធិឱ្យស្ថិតនៅក្នុងការគ្រប់គ្រង និងសម្រាប់តម្រូវការប្រើប្រាស់របស់អ្នកទទួលប្រាក់ ដូចដែលបានបញ្ជាដោយអ្នកផ្តើមប្រតិបត្តិការ

(ឃ)អាចជាការផ្ទេរមូលនិធិពីអ្នកសងប្រាក់ទៅអ្នកទទួលប្រាក់ដែលអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬ ពីរផ្សេងគ្នា និង

(ង)អាចជាការផ្ទេរមូលនិធិ ដែលនៅក្នុងនោះអ្នកសងប្រាក់ត្រូវតែមានគណនី ហើយការទូទាត់ឱ្យទៅអ្នកទទួលប្រាក់អាចនឹងធ្វើឡើងនៅក្នុងធនាគារតែមួយជាមួយគ្នា ឬ ពីរផ្សេងគ្នា ។

៣៣-**បិដ្ឋិលេខ** សំដៅដល់ហត្ថលេខាលើខ្នងនៃឧបករណ៍អាចជួញដូរបានដោយមាន ឬ គ្មានពាក្យបញ្ជាក់ ។ ដើម្បីមានប្រសិទ្ធភាព បិដ្ឋិលេខត្រូវតែបានបំពេញបង្គ្រប់ដោយការប្រគល់ ។

៣៤-**បុគ្គល** សំដៅដល់នីតិបុគ្គល និងរូបវ័ន្តបុគ្គល ។

៣៥-**ភាពគ្រប់គ្រាន់នៃសមតុល្យ** ចំពោះបញ្ជាទូទាត់ សំដៅដល់ការមានមូលនិធិគ្រប់គ្រាន់ពោលគឺ អត្ថិភាពនៃសមតុល្យគណនី ដែលមិនតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់ រួមមានសមតុល្យនៅពេលបិទបញ្ជីនាថ្ងៃធ្វើការរបស់ធនាគារថ្ងៃម្សិល **បូក** ខ្ទង់ឥណទាននៃការផ្ទេរប្រាក់ចូលក្នុងគណនីអ្នកសងប្រាក់នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ ប្រាក់បញ្ញើនិងប្រាក់ផ្ទេរចូល **ដក** ការសងប្រាក់ចេញ ការដកប្រាក់ដែលកើតមានរួចហើយ នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ និង សោហ៊ុយទាំងឡាយរបស់ធនាគារ ដែលអាចមាន ។ មូលនិធិដែលឆ្លុះបញ្ចាំងជាខ្ទង់ឥណទានបណ្តោះអាសន្ន នៅក្នុងគណនីរបស់អ្នកសងប្រាក់មិនត្រូវបានបូកបញ្ចូលជាផ្នែកមួយនៃចំនួនប្រាក់ ដែលតម្រូវសម្រាប់ការទូទាត់នោះទេ ។

៣៦-**មូលនិធិ** សំដៅដល់សាច់ប្រាក់ និងប្រាក់បញ្ញើ ដែលបានដាក់ផ្ញើនៅក្នុងគណនីធនាគារ ។

៣៧-**រូបិយបដិភោគ** សំដៅដល់ការធានាទូទាត់សងប្រាក់លើមូលប្បទានប័ត្ររូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ។

៣៨-**រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុណាមួយ ក្រៅពីរូបិយវត្ថុក្នុងស្រុក ។

៣៩-**រូបិយវត្ថុក្នុងស្រុក** សំដៅដល់ប្រាក់រៀល ដែលជារូបិយវត្ថុផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ។

៤០-**វិវរុទ្ធទាន** សំដៅដល់ប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងជាផ្លូវការនៅក្នុងកាលៈទេសៈទាំងឡាយដូចជា ការខកខាន ឬ ការបដិសេធមិនធ្វើសឹការ ការមិនទូទាត់សងប្រាក់ ឬ មិនផ្តល់ទិដ្ឋាការ ដែលផ្តល់សិទ្ធិដល់អ្នកកាន់ឱ្យធ្វើឧបាស្រ័យលើ

10/128

ឧបករណ៍អាចជូញដូរបាន ។ វិវាទត្រូវតែបានធ្វើដូច និងនៅពេលដែលតម្រូវដោយបទប្បញ្ញត្តិដោយឡែកនៃច្បាប់នេះ ។

៤១-**ស្វ៊ីភារ** សំដៅដល់ការយល់ព្រមរបស់បហារិតនៃរូបិយាណត្តិដើម្បីអនុវត្តតាមបញ្ជារបស់បហារ៉ក ។ ដើម្បីមានប្រសិទ្ធភាព ស្វ៊ីការត្រូវតែបានបំពេញបង្គ្រប់ ដោយការប្រគល់និងការជូនដំណឹង ។

៤២-**សម្រាប់បេឡានិច័យ** សំដៅដល់បិដ្ឋិលេខមួយដែលបង្ហាញថាបិដ្ឋិ-លេខនោះមិនមែនជាការផ្ទេរកម្មសិទ្ធិ ប៉ុន្តែសម្រាប់គោលបំណងសម្រួលបេឡានិច័យ ឬ ទារមកវិញនូវចំនួនប្រាក់លើឧបករណ៍អាចជួញដូរបាន ដោយអ្នកទទួលការផ្ទេរក្នុងនាមអ្នកផ្ទេរ ។

៤៣-**អន្តគាហក** នៅក្នុងជំពូកទី ២ ទី ៣ និងទី ៤ នៃច្បាប់នេះ សំដៅដល់បុគ្គលដែលទទួលផលពីការទូទាត់សងមូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា នៅពេលត្រូវបានចេញផ្សាយ ។

៤៤-**អតិថិជន** សំដៅដល់ឯកត្តជន ទោះបីជាមានប្រកបមុខរបរក្ដី ឬ ពុំមានក្ដី ឬនីតិបុគ្គលរួមទាំងធនាគារផង ដែលមានគណនីនៅធនាគារមួយ ។

៤៥-**អន្តរាគមន៍ដើម្បីទូទាត់សងប្រាក់** សំដៅដល់នីតិវិធីដែលភាគីមិនពាក់ព័ន្ធនឹងឧបករណ៍អាចជួញដូរបានចូលធ្វើអន្តរាគមន៍ ដើម្បីធ្វើស្វ៊ីការ ឬ ទូទាត់សងប្រាក់ជូនភាគីដែលពាក់ព័ន្ធ ។

៤៦-**អ្នកចេញប័ណ្ណសងតាមបញ្ជា ឬ អ្នកចេញប័ណ្ណ** សំដៅដល់បុគ្គលដែលធ្វើការសន្យាទូទាត់សងប្រាក់ នៅលើប័ណ្ណសងតាមបញ្ជា ។

៤៧-**អ្នកផ្ញើ** សំដៅដល់បុគ្គល ដែលបញ្ជូនបញ្ជាទូទាត់ទៅធនាគារទទួល ។

៤៨-**អ្នកផ្ដើមប្រតិបត្តិការ** សំដៅដល់អ្នកធ្វើបញ្ជាទូទាត់ដំបូង ដែលផ្ដើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកផ្ដើមប្រតិបត្តិការជាអ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកផ្ដើមប្រតិបត្តិការ ជាអ្នកទទួលប្រាក់ ។

៤៩-**អ្នកទទួល** សំដៅដល់អ្នកចូលរួម ដែលធនាគាររបស់ខ្លួន ជាអ្នកទទួលបញ្ជាទូទាត់ចុងក្រោយបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលជាអ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលជាអ្នក

សងប្រាក់ ។

៥០-**អ្នកទទួលប្រាក់** នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់អ្នកចូលរួម ដែលនឹងត្រូវទទួលប្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ និងនៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលប្រាក់រាប់បញ្ចូលផងដែរ នូវអ្នកដែលត្រូវទទួលប្រាក់ដោយការផ្ទេរដែលមានការប្រគល់សិទ្ធិ បើសិនជាមាន ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលប្រាក់ជាអ្នកទទួល ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលប្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។

៥១-**អ្នកសងប្រាក់** សំដៅដល់អ្នកចូលរួម ដែលត្រូវសងប្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកសងប្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកសងប្រាក់ជាអ្នកទទួល ។

៥២-**ឥណទានវិបារូបន៍** សំដៅដល់ពិតាននៃឥណទាន ដែលអនុញ្ញាតឱ្យខ្ចីមូលនិធិ ហើយការដក ឬ ការផ្ទេរមូលនិធិនោះត្រូវប្រើមូលប្បទានប័ត្រ ឬ បញ្ជាទូទាត់ ។

៥៣-**ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទ ដែលរូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ត្រូវដល់កាលកំណត់សង ។

៥៤-**ឧបាស្រ័យ** សំដៅដល់សិទ្ធិប្តឹងទារសំណងមកវិញនូវការខូចប្រយោជន៍ពីបុគ្គលដែលពាក់ព័ន្ធ លើឧបករណ៍អាចជួញដូរបាន ។

## ជំពូកទី ២
## មូលប្បទានប័ត្រ

### ផ្នែកទី ១
### ការចេញនិងទម្រង់នៃមូលប្បទានប័ត្រ

**មាត្រា ៣.-**

មូលប្បទានប័ត្រ ជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌឱ្យទៅធនាគារ និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ មូលប្បទានប័ត្រ

ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងជំពូកនេះ ។

**មាត្រា ៤.–**

មូលប្បទានប័ត្រ អាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ ជាអក្សរបរទេស និងត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **មូលប្បទានប័ត្រ** ដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតល័ក្ខខ័ណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែង ដែលមូលប្បទានប័ត្រត្រូវបានចេញ

-ហត្ថលេខារបស់បហារីក ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានប័ត្រ ។

**មាត្រា ៥.–**

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ពុំមានសុពលភាពជាមូលប្បទានប័ត្រឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌខាងក្រោម :

១-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថា ជាកន្លែងត្រូវទូទាត់សងប្រាក់ ។ បើមានកន្លែងច្រើនបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិត មូលប្បទានប័ត្រនោះអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបញ្ជាក់មុនបង្អស់ ។

២-បើគ្មានសេចក្តីបញ្ជាក់ទាំងនេះ និងសេចក្តីបញ្ជាក់ណាមួយផ្សេងទៀតទេ មូលប្បទានប័ត្រអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបហារិតមានទីស្នាក់ការកណ្តាលរបស់ខ្លួន ។

៣-មូលប្បទានប័ត្រដែលមិនបានបញ្ជាក់ច្បាស់លាស់នូវកន្លែងនៃការចេញ ត្រូវបានចាត់ទុកថាចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារីក ។

13/124

មាត្រា ៦.–

មូលប្បទានប័ត្រត្រូវតែបានចេញឱ្យទូទាត់សងប្រាក់ដោយធនាគារ ដែលបានទទួលរក្សាប្រាក់សម្រាប់ទុកសងក្នុងនាមបហារិក និងដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ដែលមានចែង ឬ បញ្ជាក់ឱ្យបហារិកមានសិទ្ធិប្រើប្រាស់ប្រាក់នោះ តាមមូលប្បទានប័ត្រ ។ ទោះបីបដិញ្ញាខាងលើនេះ មិនបានប្រតិបត្តិតាមក្តី ក៏ឧបករណ៍នេះនៅតែមានសុពលភាពជាមូលប្បទានប័ត្រដដែល ។

មាត្រា ៧.–

មូលប្បទានប័ត្រ មិនត្រូវបានធ្វើស្វីការទេ ។ សេចក្តីបញ្ជាក់ពីស្វីការនៅលើមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ មិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិ ក្នុងដៃរបស់បហារិត ដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហារិតនៃមូលប្បទានប័ត្រក៏មិនទទួលខុសត្រូវចំពោះអ្នកកាន់ឡើយ ។

មាត្រា ៨.–

មូលប្បទានប័ត្រអាចត្រូវបានចេញផ្សាយ ដើម្បីទូទាត់សងប្រាក់ឱ្យទៅ :

-បុគ្គលដែលមានការបញ្ជាក់ដោយមាន ឬ ដោយគ្មានពាក្យថា **សងតាមបញ្ជា**

-បុគ្គលដែលមានការបញ្ជាក់ដោយពាក្យថា **មិនសងតាមបញ្ជា** ឬ ដោយពាក្យផ្សេងៗទៀតដែលមានន័យដូចគ្នា ឬ

-អ្នកកាន់ ។

មូលប្បទានប័ត្រ ដែលអាចទូទាត់សងប្រាក់ឱ្យទៅបុគ្គល ដែលមានបញ្ជាក់ដោយពាក្យថា ឬ **អ្នកកាន់** ឬ ពាក្យទាំងឡាយដែលមានន័យដូចគ្នានេះ ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រ ដែលចេញឱ្យទៅអ្នកកាន់ ។

មូលប្បទានប័ត្រ ដែលមិនបានបញ្ជាក់ឈ្មោះរបស់អត្ថគាហក ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ ។

14/12

មាត្រា ៩.–

មូលប្បទានប័ត្រ អាចត្រូវចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារីកខ្លួនឯងផ្ទាល់ ។

មូលប្បទានប័ត្រ អាចត្រូវចេញជាប្រយោជន៍ឱ្យតតិយជន ។

មូលប្បទានប័ត្រ មិនអាចចេញដើម្បីទូទាត់សងប្រាក់ ដោយបហារីកខ្លួនឯងបានឡើយ លើកលែងតែការចេញនេះ ធ្វើឡើងដោយគ្រឹះស្ថានមួយទៅលើគ្រឹះស្ថានមួយទៀត ដែលជាកម្មសិទ្ធិរបស់បហារីកដដែលនេះ ។

មាត្រា ១០.–

បដិញ្ញាណាមួយពាក់ព័ន្ធទៅនឹងការតម្រូវឱ្យសងការប្រាក់ ដែលកំណត់នៅលើមូលប្បទានប័ត្រមិនត្រូវយកជាបានការឡើយ ។

មាត្រា ១១.–

មូលប្បទានប័ត្រ អាចត្រូវបានទូទាត់សងប្រាក់ នៅទីស្នាក់ការរបស់តតិយបុគ្គល នៅកន្លែងដែលបហារិតមានទីស្នាក់ការ ឬ នៅកន្លែងផ្សេងមួយទៀតឱ្យតែជានិច្ចកាលតតិយបុគ្គលនេះជាធនាគារ ។

មាត្រា ១២.–

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាង ជាចំនួនត្រូវយកជាបានការ ។

មាត្រា ១៣.–

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រនៅតែមានតម្លៃដដែល ទោះបីមូលប្បទានប័ត្រនោះ មានហត្ថលេខារបស់បុគ្គលអសម-

15/៤៤

ត្តភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬបានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

**មាត្រា ១៤.-**

បុគ្គលណាដែលបានចុះហត្ថលេខានៅលើមូលប្បទានប័ត្រក្នុងនាមបុគ្គលមួយទៀត ដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើមូលប្បទានប័ត្រនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលរ៉ាប់រងជួសឱ្យ ។ វិធានដូចគ្នានេះ ក៏អនុវត្តទៅលើអាណាព្យាបាលដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

**មាត្រា ១៥.-**

បហារីកទទួលខុសត្រូវក្នុងការទូទាត់សងប្រាក់ ។ បដិញ្ញាណាមួយ ដែលធ្វើឱ្យបហារីករួចផុតពីការទទួលខុសត្រូវនេះ មិនត្រូវយកជាបានការឡើយ ។

**មាត្រា ១៦.-**

បើមូលប្បទានប័ត្រ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្ដឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះ បានទទួលមូលប្បទានប័ត្រមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ២

## បិដ្ឋិលេខមូលប្បទានប័ត្រ

**មាត្រា ១៧.-**

មូលប្បទានប័ត្រ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ដោយមាន ឬ ដោយគ្មានពាក្យថា **សងតាមបញ្ជា** អាចត្រូវផ្ទេរបាន ដោយបិដ្ឋិលេខ ។

14/125

មូលប្បទានប័ត្រដែលចេញឱ្យទូទាត់សងប្រាក់ ចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមានពាក្យថា **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នាអាចត្រូវបានផ្ទេរ ស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

មូលប្បទានប័ត្រ អាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបហារីកក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃមូលប្បទានប័ត្រនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខមូលប្បទានប័ត្រនោះ បន្តទៀតបាន ។

**មាត្រា ១៨.–**

បិដ្ឋិលេខ ត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយ ដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងមូលប្បទានប័ត្រ ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឡើងដោយបហារិត ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ **អ្នកកាន់** មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

បិដ្ឋិលេខដែលធ្វើឱ្យបហារិត មានតម្លៃត្រឹមតែជាបង្កាន់ដៃទទួលប្រាក់ លើកលែងតែក្នុងករណីដែលបហារិតមានគ្រឹះស្ថានច្រើនកន្លែង ហើយបិដ្ឋិលេខនេះត្រូវបានធ្វើជាប្រយោជន៍ឱ្យគ្រឹះស្ថានមួយទៀត ក្រៅពីគ្រឹះស្ថានដែលមូលប្បទានប័ត្រនោះ ត្រូវបានចេញ ។

**មាត្រា ១៩.–**

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរនៅលើខ្នងមូលប្បទានប័ត្រ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុបំត្រ** និងត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខអាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

១/៤៩

**មាត្រា ២០.–**

បិដ្ឋិលេខផ្ទេរសិទ្ធិទាំងអស់ នៃមូលប្បទានប័ត្រឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តមូលប្បទានប័ត្រជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេរមូលប្បទានប័ត្រឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

**មាត្រា ២១.–**

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណាដែលមូលប្បទានប័ត្រត្រូវបានធ្វើបិដ្ឋិលេខបន្តឡើយ ។

**មាត្រា ២២.–**

ម្ចាស់មូលប្បទានប័ត្រ ដែលអាចធ្វើបិដ្ឋិលេខបានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់មូលប្បទានប័ត្រតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវចាត់ទុកថាបានទទួលមូលប្បទានប័ត្រ តាមរយៈបិដ្ឋិលេខចំហ ។

**មាត្រា ២៣.–**

បិដ្ឋិលេខនៅលើមូលប្បទានប័ត្រ ដែលចេញឱ្យទៅអ្នកកាន់នាំឱ្យអ្នកធ្វើបិដ្ឋិលេខនោះមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្ដីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែបិដ្ឋិលេខ

នេះ មិនប្រែក្លាយឧបករណ៍នោះទៅជាមូលប្បទានប័ត្រ**សងតាមបញ្ជា** ឡើយ ។

**មាត្រា ២៤.-**

នៅពេលដែលបុគ្គលណាមួយបានបាត់បង់សិទ្ធិកាន់កាប់មូលប្បទានប័ត្រដោយមូលហេតុណាក៏ដោយ ទោះបីជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិ-ដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងមាត្រា ២២ នៃច្បាប់នេះ អ្នកកាន់ដែលទទួលបានមូលប្បទានប័ត្រមកជាកម្មសិទ្ធិមិនត្រូវបានបង្ខំឱ្យបោះបង់ចោលមូលប្បទានប័ត្រឡើយ លើកលែងតែមូលប្បទានប័ត្រនោះបានមកដោយទុច្ច-រិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

**មាត្រា ២៥.-**

បុគ្គលទាំងឡាយដែលប្តឹងអំពីមូលប្បទានប័ត្រ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបហារីក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលមូលប្បទានប័ត្រ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះមិនអនុវត្តចំពោះមូលប្បទានប័ត្រ ដែលចេញដើម្បីទូទាត់សងប្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសងតាមបញ្ជា** ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

**មាត្រា ២៦.-**

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ការបំណុល** ឬ **សម្រាប់បេឡានិច័យ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃមូលប្បទានប័ត្រនោះ ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់ ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិឋិលេខ មិនអាចរលត់បានដោយហេតុផល នៃមរណភាពរបស់ភាគី ដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផល ដែលបុគ្គល នេះ បានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

**មាត្រា ២៧.-**

បិឋិលេខដែលធ្វើឡើងក្រោយពីវិរុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសម-ម្ងលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់បង្ហាញឱ្យទូទាត់សងប្រាក់ អាចនឹង ៖

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ២២ មាត្រា ២៤ និង មាត្រា ២៥ នៃច្បាប់នេះឡើយ ។

បើគ្មានភស្តុតាងផ្ទុយទេ បិឋិលេខដែលគ្មានចុះកាលបរិច្ឆេទត្រូវចាត់ទុកថាបាន ធ្វើនៅលើមូលប្បទានប័ត្រ មុនពេលធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមម្ងលគ្នា ឬ នៅ មុនផុតរយៈពេលកំណត់យោងតាមកថាខណ្ឌខាងលើនៃមាត្រានេះ ។

## ផ្នែកទី ៣
## វូបិយបដិភោគមូលប្បទានប័ត្រ

**មាត្រា ២៨.-**

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវបានធានាដោយវូបិយបដិភោគនៅលើ ចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃមូលប្បទានប័ត្រ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គលក្រៅពីបហារិត ឬ ដោយបុគ្គល ណាមួយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។

**មាត្រា ២៩.-**

វូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើមូលប្បទានប័ត្រផ្ទាល់ ឬ នៅលើ អនុប័ត្រ ។

វូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើវូបិយបដិភោគ** ឬ ដោយ រូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់

រូបិយបដិភោគហៅថា រូបិយបដិភោគី ។

ហត្ថលេខាធ្វើរូបិយបដិភោគ ត្រូវបានចុះនៅខាងមុខមូលប្បទានប័ត្រ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវបុគ្គលណាមួយ ដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្ដីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថាធ្វើឱ្យបហារិក ។

**មាត្រា ៣០.-**

រូបិយបដិភោគីមានកាតព្វកិច្ច ដូចបុគ្គលដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងមូលប្បទានប័ត្រ រូបិយបដិភោគីមានសិទ្ធិទាំងឡាយដែលផ្ដើមចេញពីមូលប្បទានប័ត្រនោះ ទល់នឹងបុគ្គលដែលត្រូវបានធានា និង បុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះ នៅលើមូលប្បទានប័ត្រ ។

## ផ្នែកទី ៤
## ការបង្ហាញមូលប្បទានប័ត្រនិងការទូទាត់សងប្រាក់

**មាត្រា ៣១.-**

មូលប្បទានប័ត្រ ត្រូវបានទូទាត់សងប្រាក់នៅពេលបង្ហាញ ។ បដិញ្ញាណាមួយដែលមានន័យផ្ទុយពីនេះ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ ដែលបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនកាលបរិច្ឆេទដែលជាថ្ងៃចេញផ្សាយត្រូវតែទូទាត់សងប្រាក់នៅថ្ងៃបង្ហាញ ។

**មាត្រា ៣២.-**

មូលប្បទានប័ត្រ ត្រូវតែបានបង្ហាញដើម្បីឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតពីថ្ងៃចេញផ្សាយ ។

**មាត្រា ៣៣.-**

នៅពេលដែលមូលប្បទានប័ត្រត្រូវបានចេញនៅកន្លែងមួយហើយ នឹងត្រូវទូទាត់សងប្រាក់នៅកន្លែងមួយផ្សេងទៀត ដែលមានប្រតិទិនខុសគ្នាថ្ងៃចេញផ្សាយនឹងត្រូវបានប្រកាន់យកតាមថ្ងៃដែលត្រូវគ្នាក្នុងប្រតិទិនប្រចាំកន្លែងដែលត្រូវទូទាត់សងប្រាក់ ។

**មាត្រា ៣៤.-**

ការបង្ហាញមូលប្បទានប័ត្រនៅ ឬ តាមរយៈសភាផាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជា ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

**មាត្រា ៣៥.-**

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវជំទាស់ ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិអ្នកកាន់ ។

បើការទូទាត់សងមូលប្បទានប័ត្រមិនត្រូវបានជំទាស់ទេ បហារិតនៅតែអាចទូទាត់សងប្រាក់បាន ទោះបីផុតរយៈពេលកំណត់ត្រូវបង្ហាញក៏ដោយ ។

**មាត្រា ៣៦.-**

មរណភាព ឬ អសមត្ថភាពរបស់បហារីក ដែលកើតឡើងក្រោយការចេញផ្សាយមូលប្បទានប័ត្រ ពុំមានផលប៉ះពាល់ដល់មូលប្បទានប័ត្រឡើយ ។

**មាត្រា ៣៧.-**

បហារិតដែលទូទាត់សងមូលប្បទានប័ត្រអាចតម្រូវឱ្យប្រគល់មូលប្បទានប័ត្រនោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

បើមិនមានចំនួនប្រាក់គ្រប់គ្រាន់ ក្នុងគណនីរបស់បហារីកទេ អ្នកកាន់អាចមិនបដិសេធការទូទាត់សងចំនួនប្រាក់មួយផ្នែកនៃមូលប្បទានប័ត្រ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បហារិតអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើមូលប្បទានប័ត្រ និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ៣៨.–

បហារិតដែលទូទាត់សងមូលប្បទានប័ត្រមានបិដ្ឋិលេខ ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ៣៩.–

រូបិយប័ណ្ណដែលត្រូវប្រើប្រាស់ សម្រាប់ទូទាត់សងប្រាក់លើមូលប្បទានប័ត្រត្រូវបានកំណត់ដូចខាងក្រោម ៖

១-មូលប្បទានប័ត្រ ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យបហារិតដើម្បីទូទាត់សងជារូបិយប័ណ្ណនៃគណនី ដែលមូលប្បទានប័ត្រត្រូវបានចេញ ។

២-នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃគណនី ចំនួនប្រាក់អាចត្រូវសងជារូបិយប័ណ្ណនៃគណនីដោយបហារិតតាមតម្លៃនៃរូបិយប័ណ្ណនោះ នៅថ្ងៃទូទាត់សងប្រាក់ ។

៣-បើមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយមូលប្បទានប័ត្រនេះមិនត្រូវបានទូទាត់សងប្រាក់នៅពេលបង្ហាញ អ្នកកាន់អាចតម្រូវឱ្យភាគីពាក់ព័ន្ធធ្វើការទូទាត់សងចំនួនប្រាក់នៃមូលប្បទានប័ត្រជារូបិយប័ណ្ណនៃកន្លែងទូទាត់សងប្រាក់តាមអត្រាប្តូរប្រាក់ នៅថ្ងៃបង្ហាញ ឬនៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

៤-ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់ ត្រូវអនុវត្តក្នុងការកំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារីកអាចកំណត់ថាចំនួនប្រាក់ទូទាត់សង ត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ដែលបញ្ជាក់នៅលើមូលប្បទានប័ត្រ ។

៥-ទោះបីមានកថាខណ្ឌទី ៣ នៃមាត្រានេះក៏ដោយ មូលប្បទានប័ត្រចេញឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលត្រូវបានប្រើនៅព្រះរាជាណាចក្រកម្ពុជា ឬ បើនៅលើមូលប្បទានប័ត្រ បហារីកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើជារូបិយប័ណ្ណមួយច្បាស់លាស់ អ្នកកាន់អាចទាមទារពីភាគីពាក់ព័ន្ធណាមួយឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់នោះ ។

៦-បើចំនួនប្រាក់នៃមូលប្បទានប័ត្រ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែល

មាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់និងប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ នៅពេលដែលរូបិយប័ណ្ណ ដែលបានបញ្ជាក់មិនមែនជារូបិយប័ណ្ណនៃគណនីដែលត្រូវទូទាត់សងប្រាក់ ការទូទាត់សងមូលប្បទានប័ត្រត្រូវធ្វើឡើងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ពុំមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់នៃមូលប្បទានប័ត្រត្រូវបានធ្វើឡើងជារូបិយប័ណ្ណដែលត្រូវបានប្រើយ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

## ផ្នែកទី ៥

## មូលប្បទានប័ត្រឆូតបន្ទាត់និងមូលប្បទានប័ត្រទូទាត់សងចូលក្នុងគណនី

**មាត្រា ៤០.-**

បហារីក ឬ អ្នកកាន់អាចឆូតបន្ទាត់លើមូលប្បទានប័ត្រ ។

ការឆូតបន្ទាត់មានរូបភាពជាបន្ទាត់ស្របគ្នាពីរដែលគូសនៅខាងមុខមូលប្បទានប័ត្រ ។ បន្ទាត់ឆូតអាចមានពីរបែប គឺបន្ទាត់ឆូតទូទៅ ឬ បន្ទាត់ឆូតពិសេស ។

បន្ទាត់ឆូតទូទៅមានបន្ទាត់គូសតែពីរ ឬ នៅចន្លោះបន្ទាត់ទាំងពីរមានពាក្យថា ធនាគារ ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ។ បន្ទាត់ឆូតពិសេសមានឈ្មោះរបស់ធនាគារនៅចន្លោះបន្ទាត់ទាំងពីរ ។

បន្ទាត់ឆូតទូទៅ អាចត្រូវប្តូរបានទៅជាបន្ទាត់ឆូតពិសេស ប៉ុន្តែបន្ទាត់ឆូតពិសេសមិនអាចត្រូវប្តូរមកជាបន្ទាត់ឆូតទូទៅវិញបានឡើយ ។

ការកោសលុបកែបន្ទាត់ឆូត ឬ ឈ្មោះរបស់ធនាគារ មិនអាចធ្វើបានឡើយ ។

**មាត្រា ៤១.-**

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតទូទៅ បហារិតអាចទូទាត់សងឱ្យទៅធនាគារ ឬ ទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះ ។

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតពិសេស បហារិតអាចទូទាត់សងឱ្យទៅធនាគារដែលមានឈ្មោះនៅលើមូលប្បទានប័ត្រតែប៉ុណ្ណោះ ឬ បើធនាគារនេះជាបហា-

វិតអាចទូទាត់សងឱ្យទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះដែរ ។ ប៉ុន្តែធនាគារដែលមានឈ្មោះលើមូលប្បទានប័ត្រ អាចធ្វើបេឡានិច័យតាមរយៈធនាគារមួយទៀត ។

ធនាគារអាចទទួលយកមូលប្បទានប័ត្រឆូតបន្ទាត់ពីអតិថិជនរបស់ខ្លួន ឬ ពីធនាគារមួយផ្សេងទៀតតែប៉ុណ្ណោះ ។ ធនាគារមិនអាចធ្វើបេឡានិច័យមូលប្បទានប័ត្រឆូតបន្ទាត់ជាប្រយោជន៍ឱ្យបុគ្គលដទៃទៀត ក្រៅពីបុគ្គលដែលបានពោលខាងលើនេះឡើយ ។

ចំពោះមូលប្បទានប័ត្រដែលមានបន្ទាត់ឆូតពិសេសច្រើន បហារិតមិនអាចទូទាត់សងប្រាក់បានឡើយ លើកលែងតែក្នុងករណីដែលមានបន្ទាត់ឆូតតែពីរកន្លែងដែលក្នុងនោះបន្ទាត់ឆូតមួយកន្លែងសម្រាប់ធ្វើបេឡានិច័យតាមរយៈសភាផាត់ទាត់ ។

បហារិត ឬ ធនាគារ ដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាត ដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

**មាត្រា ៤២.-**

បហារីក ឬ អ្នកកាន់មូលប្បទានប័ត្រអាចហាមឃាត់ការទូទាត់សងជាសាច់ប្រាក់ដោយសរសេរអក្សរកាត់ទទឹងផ្ទៃមុខមូលប្បទានប័ត្រនោះថា **សម្រាប់ទូទាត់សងចូលក្នុងគណនី** ឬ តាមសំនួនសេចក្តីដែលមានន័យដូចគ្នា ។

ក្នុងករណីនេះ មូលប្បទានប័ត្រអាចត្រូវបានទូទាត់ដោយបហារិតតាមរយៈកិច្ចបញ្ជិកាគណនេយ្យតែប៉ុណ្ណោះ ដោយការចុះឥណទានចូលគណនី ការផ្ទេរប្រាក់ពីគណនីមួយចូលទៅគណនីមួយទៀត ការកាត់កង ឬ ការទូទាត់តាមរយៈសភាផាត់ទាត់ ។ ការទូទាត់តាមកិច្ចបញ្ជិកាគណនេយ្យមានន័យថា ជាការទូទាត់សងប្រាក់ ។

ការកោសលុបកែណាមួយចំពោះពាក្យថា **សម្រាប់ទូទាត់សងចូលក្នុងគណនី** មិនអាចធ្វើបានឡើយ ។

បហារិតដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាតដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

## ផ្នែកទី ៦
## ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់

### មាត្រា ៤៣.-

អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងអ្នកធ្វើបិដ្ឋិលេខបហារ័ក និងភាគីជាប់ពាក់ព័ន្ធដទៃទៀត បើមូលប្បទានប័ត្រដែលត្រូវបានបង្ហាញនៅក្នុងរយៈពេលកំណត់ត្រឹមត្រូវនោះមិនត្រូវបានទូទាត់សងប្រាក់ ហើយបើមានភស្តុតាងយ៉ាងហោចណាស់មួយ ដែលបង្ហាញពីការបដិសេធមិនទូទាត់សងប្រាក់ដូចខាងក្រោម ៖

-វិរុទ្ធវាទ ឬ ឧបករណ៍ផ្លូវការផ្សេងណាមួយ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទនិងបញ្ជាក់ដោយបហារិតអំពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទធ្វើឡើងដោយសភាជាត់ទាត់ដែលបញ្ជាក់ថាមូលប្បទានប័ត្រ ត្រូវបានប្រគល់នៅក្នុងរយៈពេលកំណត់ និងមិនត្រូវបានទូទាត់សងប្រាក់ ។

### មាត្រា ៤៤.-

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃមូលប្បទានប័ត្រភ្ជាប់ជាមួយ ហើយត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញបហារិត ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ មិនទទួលយក ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនទទួលយក ។

វិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា ត្រូវតែបានធ្វើឡើងនៅមុនពេលផុតកំណត់បង្ហាញឱ្យទូទាត់សងប្រាក់ ។

បើមូលប្បទានប័ត្រត្រូវបានបង្ហាញឱ្យទូទាត់សង នៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់វិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាអាចត្រូវបានធ្វើឡើងនៅថ្ងៃធ្វើការទីមួយបន្ទាប់ពីរយៈពេលផុតកំណត់ ។

ក្រោយផុតរយៈពេលកំណត់សម្រាប់ធ្វើវិរុទ្ធវាទស្តីពីការមិនទូទាត់សងប្រាក់ អ្នកកាន់ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធលើមូលប្បទានប័ត្រនោះ ប៉ុន្តែអាចប្តឹងបហារីកក្រោមបទប្បញ្ញត្តិដោយឡែកស្តីពីកិច្ចសន្យា ហើយសំណងដែលបានមកវិញ ត្រូវកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារីកដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

**មាត្រា ៤៥.-**

អ្នកកាន់ ត្រូវជូនដំណឹងពីការមិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងទៅបហារីកនៅក្នុងរយៈពេលបួន(០៤)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលវិរុទ្ធវាទ ឬ ប្រតិ-វេទន៍ដែលសមមូលគ្នាត្រូវបានធ្វើ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិ-លេខរបស់ខ្លួនអំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះនិងអាសយ-ដ្ឋានរបស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់បហារីកបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ សេចក្តីជូនដំណឹងដូចគ្នានេះក៏ត្រូវបានផ្តល់ទៅឱ្យបិយបដិភោគីនៅក្នុងរយៈពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខមិនបានបញ្ជាក់អំពីអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង អាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនមូលប្បទានប័ត្រត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹងត្រូវបង្ហាញភស្តុតាងថា ខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះ នឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួនបើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃមូលប្បទានប័ត្រឡើយ ។

**មាត្រា ៤៦.-**

តាមរយៈបដិញ្ញាថា **បង្វិលវិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលវិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើមូលប្បទានប័ត្រ បហារ៉ក អ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះ មិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញមូលប្បទានប័ត្រនៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងបានឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ជាបន្ទុករបស់បុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់នោះ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហារ៉ក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខឬរូបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែ

អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីនោះតែប៉ុណ្ណោះ ។ ទោះបីជាបដិញ្ញាសរសេរដោយបហារ៉ែកក្តី បើអ្នកកាន់ធ្វើវិវុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា អ្នកកាន់នេះត្រូវទទួលរ៉ាប់រងលើសោហ៊ុយទាំងអស់ដែលកើតមាន ។ កាលបើបដិញ្ញាកើតចេញអំពីអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី សោហ៊ុយនៃវិវុទ្ធវាទ ឬ នៃប្រតិវេទន៍ ដែលសមមូលគ្នា បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។

## មាត្រា ៤៧.–

រាល់បុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានប័ត្រមានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះមុខអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្តឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានប័ត្រជាឯកត្តជន ឬ រួមគ្នាដោយមិនគិតផលលំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ហើយបានទទួលយកមូលប្បទានប័ត្ររក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្តឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្តឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្តឹងទីមួយនោះក៏ដោយ ។

## មាត្រា ៤៨.–

អ្នកកាន់អាចទាមទារពីភាគីដែលខ្លួនបានអនុវត្តសិទ្ធិធ្វើឧបាស្រ័យនូវចំនួនប្រាក់ដែលមិនត្រូវបានទូទាត់សង ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

## មាត្រា ៤៩.–

ភាគីដែលទទួលនិងទូទាត់សងមូលប្បទានប័ត្រ អាចទាមទារមកវិញពីភាគីទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សង ការប្រាក់លើ

១.១/៤៩ ទ

ចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃដែលបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

**មាត្រា ៥០.-**

ភាគីពាក់ព័ន្ធនីមួយៗដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ឱ្យប្រគល់មកខ្លួននូវមូលប្បទានប័ត្ររួមជាមួយវិរុទ្ធ-វាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នា និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលនិងបានទូទាត់សងមូលប្បទានប័ត្រអាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយបាន ។

**មាត្រា ៥១.-**

កាលបើការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬ វិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាក្នុងរយៈពេលកំណត់ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវធ្វើប្រតិវេទន៍អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើមូលប្បទានប័ត្រ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ៤៥ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញមូលប្បទានប័ត្រភ្លាមដើម្បីឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ឬ ធ្វើប្រតិវេទន៍ដែលសមមូលគ្នា ។

បើករណីប្រធានស័ក្តិនៅតែបន្តកើតមានលើសពីដប់ប្រាំ(១៥)ថ្ងៃ ក្រោយកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងអំពីករណីប្រធានស័ក្តិនោះទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ក្តី ឧបា-ស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាមិនចាំបាច់ធ្វើឡើយ ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គល ដែលបានទទួលសិទ្ធិក្នុងការបង្ហាញមូលប្បទានប័ត្រ ឬ ធ្វើវិរុទ្ធវាទ ឬ ធ្វើប្រតិវេទន៍ដែលសមមូលគ្នា មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើមូលប្បទានប័ត្រដែលត្រូវបានបាត់បង់ ឬ បំផ្លាញ អាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តមូលប្បទានប័ត្រដែលសងការខូចខាតទៅភាគីពាក់ព័ន្ធចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើមូលប្បទានប័ត្រ តាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលមូលប្បទានប័ត្រមកដោយសុចរិត ។

## ផ្នែកទី ៧

## បេឡានិច័យមូលប្បទានប័ត្រ

**មាត្រា ៥២.-**

បេឡានិច័យមូលប្បទានប័ត្រ ត្រូវបានប្រព្រឹត្តទៅដូចខាងក្រោមនេះ :

១-កាលបើមូលប្បទានប័ត្រ ត្រូវបានប្រគល់ឱ្យធនាគារដើម្បីចុះឥណទានគណនីអតិថិជនតាមចំនួនប្រាក់នៃមូលប្បទានប័ត្រ ធនាគារទទួលបានសិទ្ធិនិងអំណាចទាំងអស់របស់អ្នកកាន់មូលប្បទានប័ត្រ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការចុះឥណទានគណនីនេះមានលក្ខណៈបណ្តោះអាសន្ន ហើយធនាគារអាចចុះឥណពន្ធគណនី ឬ ម្យ៉ាងទៀតអាចធ្វើឧបាស្រ័យទាមទារពីអតិថិជនវិញបាន បើមូលប្បទានប័ត្រមិនត្រូវបានទូទាត់សងប្រាក់ទេនោះ ។ លើកលែងតែបានព្រមព្រៀងផ្សេងពីនេះ ការដកប្រាក់ចេញពីគណនីឥណទានបណ្តោះអាសន្នអាចធ្វើបាន លុះណាតែមានការសម្រេចរបស់ធនាគារតែប៉ុណ្ណោះ និងជាកម្មវត្ថុនៃការសងវិញ ឬ ការធ្វើឧបាស្រ័យពីអតិថិជន បើមូលប្បទានប័ត្រមិនត្រូវបានទូទាត់សងប្រាក់ទេ ។

៣-ដោយមិនគិតដល់ការខ្វះខាត ការខុសឆ្គង ការរឹតត្បិតឬការកម្រិត ឬ ទម្រង់ ឬ ប្រភេទនៃបិដ្ឋិលេខរបស់អតិថិជន សិទ្ធិរបស់ធនាគារក្រោមកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាម្ចាស់នៃមូលប្បទានប័ត្រដែលអាចធ្វើបិដ្ឋិលេខបានអនុលោមតាម មាត្រា ២២ ទោះបីមានមាត្រា ២៦ នៃច្បាប់នេះ ដែលអនុវត្តផ្សេងពីនេះក៏ដោយ ។

**មាត្រា ៥៣.–**

នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ មូលប្បទានប័ត្រនោះជាបញ្ហាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្តីពីប្រតិបត្តិការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីមូលប្បទានប័ត្ររវាងបទប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

## ផ្នែកទី ៨
## ការកែលើមូលប្បទានប័ត្រ

**មាត្រា ៥៤.–**

ក្នុងករណីមានការកែលើខ្លឹមសារនៃមូលប្បទានប័ត្រ រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែនោះ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃមូលប្បទានប័ត្រ ។

## ផ្នែកទី ៩
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

**មាត្រា ៥៥.–**

រាល់ការធ្វើឧបាស្រ័យ ដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារីក និងភាគីពាក់ព័ន្ធដទៃៗទៀត មានរយៈពេលប្រាំមួយ(០៦)ខែ បន្ទាប់ពីការផុតកំណត់រយៈពេលបង្ហាញឱ្យទូទាត់សងប្រាក់ ។

រាល់ការធ្វើឧបាស្រ័យដោយភាគីពាក់ព័ន្ធដទៃៗទៀតអំពីការទូទាត់សងមូលប្បទានប័ត្រទល់នឹងភាគីជាប់ពាក់ព័ន្ធផងគ្នា មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលភាគីពាក់ព័ន្ធបានទូទាត់សងមូលប្បទានប័ត្រ ឬ បានទទួលរងការប្តឹង ។

**មាត្រា ៥៦.-**

ការកំណត់រយៈពេលធ្វើឱ្យបាត់ស្រ័យដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

## ផ្នែកទី ១០
## ការគណនារយៈពេលកំណត់

**មាត្រា ៥៧.-**

ការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទអាចប្រព្រឹត្តទៅបានទៅក្នុងថ្ងៃធ្វើការតែប៉ុណ្ណោះ ។

កាលបើថ្ងៃចុងក្រោយនៃរយៈពេលដែលបានកំណត់ ដើម្បីអនុវត្តសកម្មភាពណាមួយទាក់ទងទៅនឹងមូលប្បទានប័ត្រ ជាពិសេសចំពោះការបង្ហាញឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាត្រូវចំថ្ងៃឈប់សម្រាកជាផ្លូវការ រយៈពេលកំណត់នេះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ពីផុតរយៈពេលកំណត់ ។ ថ្ងៃឈប់សម្រាកក៏ត្រូវបានរាប់បញ្ចូលទៅក្នុងការគណនារយៈពេលកំណត់ទាំងនោះផងដែរ ។

**មាត្រា ៥៨.-**

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលផងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

**មាត្រា ៥៩.-**

ទោះបីតាមផ្លូវច្បាប់ក្តី ឬ តាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

## ជំពូកទី ៣

## រូបិយាណត្តិ

### ផ្នែកទី ១

### ការចេញផ្សាយនិងទម្រង់នៃរូបិយាណត្តិ

**មាត្រា ៦០.-**

រូបិយាណត្តិជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌ ចេញដោយបុគ្គលមួយឱ្យទៅបុគ្គលដទៃ ចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យបុគ្គលជាអ្នកទទួលបញ្ជាទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ រូបិយាណត្តិត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងក្នុងជំពូកនេះ ។

**មាត្រា ៦១.-**

រូបិយាណត្តិជាឧបករណ៍ឥណទាន ។ រូបិយាណត្តិអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ អក្សរបរទេស ហើយត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **រូបិយាណត្តិ** ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតល័ក្ខខ័ណ្ឌឱ្យទូទាត់សងនូវចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិតដែលជាបុគ្គលត្រូវទូទាត់សងប្រាក់

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន

-កាលបរិច្ឆេទ និងកន្លែង ដែលរូបិយាណត្តិត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់បហារីកដែលជាបុគ្គលចេញបញ្ជាលើរូបិយាណត្តិ ។

### មាត្រា ៦២.–

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយដូចមានចែងនៅក្នុងមាត្រា ៦១ នៃច្បាប់នេះ ពុំមានសុពលភាពជារូបិយាណត្តិឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌដូចខាងក្រោម :

១-រូបិយាណត្តិ ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់បហារិតផងដែរ ។

៣-រូបិយាណត្តិ ដែលមិនបានបញ្ជាក់ច្បាស់នូវកន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថាចេញ នៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារីក ។

៤-រូបិយាណត្តិ អាចត្រូវចេញឱ្យទូទាត់សងប្រាក់ទៅអ្នកកាន់បាន ។ រូបិយាណត្តិដែលគ្មានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន ត្រូវបានចាត់ទុកថាជារូបិយាណត្តិទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

### មាត្រា ៦៣.–

រូបិយាណត្តិ អាចត្រូវបានចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារីក ។ រូបិយាណត្តិ អាចត្រូវបានចេញទៅលើបហារីកខ្លួនឯងផ្ទាល់ ឬ ជាប្រយោជន៍ដល់តតិយបុគ្គល ។

### មាត្រា ៦៤.–

រូបិយាណត្តិ អាចត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់បហារិត ឬ នៅកន្លែងផ្សេងទៀត ។

### មាត្រា ៦៥.–

ចំពោះប្រភេទរូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ បហារីកអាចចែងល័ក្ខ-

ន័យថាចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃរូបិយាណត្តិផ្សេងពីខាងលើ បដិញ្ញានេះមិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ ត្រូវតែបានបញ្ជាក់នៅលើរូបិយាណត្តិ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញផ្សាយរូបិយាណត្តិ លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

**មាត្រា ៦៦.–**

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរ ជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរច្រើនផងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នាចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

**មាត្រា ៦៧.–**

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើរូបិយាណត្តិនៅតែមានតម្លៃដដែល ទោះបីរូបិយាណត្តិនោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬ បានចុះហត្ថ-លេខាជំនួសមានការទទួលខុសត្រូវ ។

**មាត្រា ៦៨.–**

បុគ្គលណា ដែលបានចុះហត្ថលេខានៅលើរូបិយាណត្តិក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើរូបិយាណត្តិនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលរ៉ាប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជនដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

៦៦/១២១

**មាត្រា ៦៩.–**

បហារីកធានាលើស៊ីការនិងការទូទាត់សងប្រាក់ ។

បហារីកអាចរួចផុតពីការទទួលខុសត្រូវលើស៊ីការ ប៉ុន្តែមិនអាចរួចផុតពីការទទួលខុសត្រូវលើការទូទាត់សងប្រាក់ឡើយ ។

**មាត្រា ៧០.–**

បើរូបិយាណត្តិ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលរូបិយាណត្តិមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ២
## បិដ្ឋិលេខរូបិយាណត្តិ

**មាត្រា ៧១.–**

រូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា **សងតាមបញ្ជា** អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលបហារីកបានបញ្ចូលក្នុងរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នា រូបិយាណត្តិនោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

រូបិយាណត្តិអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបហារិតក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃរូបិយាណត្តិនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខរូបិយាណត្តិនោះបន្តទៀតបាន ។

**មាត្រា ៧២.-**

ប័ណ្ណលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើប័ណ្ណលេខរូបិយាណត្តិ មិនត្រូវយកជាបានការឡើយ ។

ប័ណ្ណលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងរូបិយាណត្តិ ត្រូវចាត់ទុកជាមោឃៈ ។

ប័ណ្ណលេខដែលធ្វើឱ្យអ្នកកាន់ មានតម្លៃស្មើនឹងប័ណ្ណលេខចំហ ។

**មាត្រា ៧៣.-**

ប័ណ្ណលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងរូបិយាណត្តិ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុប័ត្រ** ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើប័ណ្ណលេខ ។

ប័ណ្ណលេខអាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើប័ណ្ណ-លេខប៉ុណ្ណោះ ហៅថា **ប័ណ្ណលេខចំហ** ។

**មាត្រា ៧៤.-**

ប័ណ្ណលេខផ្ទេរសិទ្ធិទាំងអស់នៃរូបិយាណត្តិឱ្យទៅអ្នកកាន់ ។

បើជាប័ណ្ណលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើប័ណ្ណលេខបន្តរូបិយាណត្តិជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេររូបិយាណត្តិឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើប័ណ្ណលេខ ។

**មាត្រា ៧៥.-**

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើប័ណ្ណលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខ អាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀតបាន ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលរូបិយាណត្តិត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើរូបិយាណត្តិចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឱ្យបាស្រ័យ ប៉ុន្តែរូបិយាណត្តិនោះមិនអាចប្រែក្លាយទៅជារូបិយាណត្តិ **សងតាមបញ្ជា** បានឡើយ ។

**មាត្រា ៧៦.-**

ម្ចាស់រូបិយាណត្តិដែលអាចធ្វើបិដ្ឋិលេខបានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់រូបិយាណត្តិតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលរូបិយាណត្តិតាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយ បានបាត់បង់សិទ្ធិកាន់កាប់រូបិយាណត្តិដោយមូលហេតុណាក៏ដោយ ទោះបីជារូបិយាណត្តិចេញផ្សាយឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានរូបិយាណត្តិមកជាកម្មសិទ្ធិ មិនត្រូវបានបង្ខំឱ្យបោះបង់ចោលរូបិយាណត្តិឡើយ លើកលែងតែរូបិយាណត្តិនោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

**មាត្រា ៧៧.-**

បុគ្គលទាំងឡាយដែលប្តឹងអំពីរូបិយាណត្តិ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបចាហ៍ក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

31/114

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះរូបិយាណត្តិដែលចេញផ្សាយដើម្បីទូទាត់សងប្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសងតាមបញ្ជា** ឬ ប្រយោគណាមួយ ដែលមានន័យដូចគ្នាបានឡើយ ។

**មាត្រា ៧៨.–**

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ការបំណុល** ឬ **សម្រាប់បេឡានិច័យ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តបានក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់បាន ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខបានផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

នៅពេលដែលរូបិយាណត្តិត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ រូបិយា-ណត្តិនោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៩ ស្តីពីប្រតិបត្តិការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីរូបិយាណត្តិរវាងបទប្បញ្ញត្តិនៃជំពូកនេះនិងជំពូកទី ៩ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

**មាត្រា ៧៩.–**

កាលបើបិដ្ឋិលេខមួយមានសេចក្តីបញ្ជាក់ថា **តម្លៃសម្រាប់ធានា** ឬ **តម្លៃសម្រាប់ដាក់បញ្ចាំ** ឬ សេចក្តីបញ្ជាក់ណាផ្សេងទៀត ដែលមានន័យថាសម្រាប់ដាក់បញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្តាភាគីដែលពាក់ព័ន្ធមិនអាចប្តឹងអ្នកកាន់ ដោយសំអាងលើទំនាក់ទំនងផ្ទាល់ជាមួយអ្នកធ្វើបិដ្ឋិលេខបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

៥០/១២៥

**មាត្រា ៨០.–**

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីវិរុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមម្មូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់នេះឡើយ ។

បើគ្មានភស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបានធ្វើនៅលើរូបិយាណត្តិមុនពេលធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមម្មូលគ្នា ឬ មុនផុតរយៈពេលកំណត់ដែលបានយោងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។

## ផ្នែកទី ៣
## ស្ទីការរូបិយាណត្តិ

**មាត្រា ៨១.–**

រហូតដល់ពេលឥណប្រតិទាន អ្នកកាន់ ឬ បុគ្គលដែលមានរូបិយាណត្តិ អាចបង្ហាញរូបិយាណត្តិបាននៅលំនៅរបស់បហារិតដើម្បីឱ្យធ្វើស្ទីការ ។

**មាត្រា ៨២.–**

ចំពោះប្រភេទរូបិយាណត្តិណាក៏ដោយ បហារ៉កអាចចែងល័ក្ខខ័ណ្ឌថា រូបិយាណត្តិនោះ ត្រូវបានបង្ហាញឱ្យធ្វើស្ទីការដោយមាន ឬ ដោយគ្មានកំណត់ពេល ។

បហារ៉កអាចហាមឃាត់ការបង្ហាញឱ្យធ្វើស្ទីការបាន លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវទូទាត់សងប្រាក់ នៅអាសយដ្ឋានរបស់តតិយភាគី ឬ នៅកន្លែងផ្សេងទៀត ក្រៅពីលំនៅរបស់បហារិត ឬ លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវបានចេញឱ្យទូទាត់សងប្រាក់នៅពេលកំណត់មួយក្រោយការបង្ហាញ ។

បហារ៉កក៏អាចចែងល័ក្ខខ័ណ្ឌថា ការបង្ហាញឱ្យធ្វើស្ទីការនេះមិនប្រព្រឹត្តទៅនៅមុនកាលបរិច្ឆេទដែលបានកំណត់នោះឡើយ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗអាចចែងល័ក្ខខ័ណ្ឌថា រូបិយាណត្តិត្រូវបានបង្ហាញឱ្យធ្វើស្ទីការដោយមាន ឬ ដោយគ្មានរយៈពេលកំណត់ លើកលែងតែបហារីកបានហាមឃាត់ការធ្វើស្ទីការនោះរួចហើយ ។

**មាត្រា ៨៣.–**

រូបិយាណត្តិទាំងឡាយដែលត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើស្ទីការនៅក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។

បហារីកអាចបង្រួញ ឬ ពន្យាររយៈពេលកំណត់នេះ ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខទាំងឡាយផងដែរ ។

**មាត្រា ៨៤.–**

បហារិតអាចស្នើសុំឱ្យធ្វើការបង្ហាញរូបិយាណត្តិបានជាលើកទីពីរនៅថ្ងៃបន្ទាប់ពីការបង្ហាញលើកទីមួយ ។ ភាគីទាំងឡាយដែលពាក់ព័ន្ធមិនអាចតវ៉ាថា ការស្នើសុំនេះមិនត្រូវអនុវត្តតាមនោះបានឡើយ លើកលែងតែការស្នើសុំនេះត្រូវបានចែងនៅក្នុងវិរុទ្ធវាទ ។

អ្នកកាន់មិនត្រូវប្រគល់ឱ្យទៅបហារិតនូវរូបិយាណត្តិដែលបង្ហាញឱ្យធ្វើស្ទីការឡើយ ។

**មាត្រា ៨៥.–**

ស្ទីការត្រូវបានសរសេរនៅលើរូបិយាណត្តិដោយប្រើពាក្យថា **បានធ្វើស្ទីការ** ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយបហារិត ។ ហត្ថលេខាសាមញ្ញរបស់បហារិតនៅខាងមុខនៃរូបិយាណត្តិបង្កើតបានជាស្ទីការ ។

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងប្រាក់ក្នុងរយៈពេលណាមួយក្រោយការបង្ហាញ ឬ ត្រូវតែបានបង្ហាញឱ្យធ្វើស្ទីការនៅក្នុងរយៈពេលកំណត់ណាមួយដោយអនុលោមតាមបដិញ្ញាពិសេស ស្ទីការនោះត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ។ បើស្ទីការនោះគ្មាន

ចុះកាលបរិច្ឆេទទេ អ្នកកាន់ ដើម្បីរក្សាសិទ្ធិឧបាស្រ័យទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងទល់នឹងបហារីកត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្លេចភ្លាំងនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

**មាត្រា ៨៦.–**

ស្ទីការពុំមានល័ក្ខខ័ណ្ឌទេ ប៉ុន្តែបហាវិតអាចទាមទារការធ្វើស្ទីការទៅលើតែមួយផ្នែកនៃចំនួនប្រាក់ដែលត្រូវទូទាត់សង ។

រាល់ការកែប្រែផ្សេងទៀត ដែលអ្នកធ្វើស្ទីការបានធ្វើលើខ្លឹមសារនៃរូបិយាណត្តិ គឺជាការបដិសេធមិនធ្វើស្ទីការ ។ ប៉ុន្តែអ្នកធ្វើស្ទីការត្រូវទទួលខុសត្រូវស្របតាមខ្លឹមសារនៃស្ទីការដែលខ្លួនបានកែប្រែ ។

**មាត្រា ៨៧.–**

កាលបើបហារីកនៃរូបិយាណត្តិបានបញ្ជាក់កន្លែងទូទាត់សងប្រាក់ក្រៅពីលំនៅរបស់បហាវិត ដោយគ្មានបញ្ជាក់ពីអាសយដ្ឋានរបស់តតិយភាគីដែលជាកន្លែងត្រូវទូទាត់សងប្រាក់ បហាវិតអាចបញ្ជាក់ឈ្មោះតតិយភាគីនេះនៅក្នុងពេលធ្វើស្ទីការតែម្តង ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ អ្នកធ្វើស្ទីការត្រូវបានចាត់ទុកថាបានយល់ព្រមទូទាត់សងរូបិយាណត្តិនោះដោយខ្លួនឯងនៅកន្លែងទូទាត់សងប្រាក់ ។

បើរូបិយាណត្តិត្រូវបានទូទាត់សងនៅលំនៅរបស់បហាវិត អាសយដ្ឋានដែលជាកន្លែងជាមួយគ្នានឹងកន្លែងដែលធ្វើការទូទាត់សងប្រាក់ ត្រូវបានបញ្ជាក់នៅពេលបហាវិតធ្វើស្ទីការ ។

**មាត្រា ៨៨.–**

រូបិយាណត្តិមិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិក្នុងដៃរបស់បហាវិតដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហាវិតនៃរូបិយាណត្តិដែលមិនព្រមធ្វើស្ទីការមិនទទួលខុសត្រូវលើរូបិយាណត្តិឡើយ ។

តាមរយៈស្ទីការ បហាវិតទទួលទូទាត់សងរូបិយាណត្តិនៅពេលដល់ឥណប្រតិទាន ។

បើពុំមានការទូទាត់សងប្រាក់ទេ អ្នកកាន់ ទោះបីខ្លួនជាបហារីកក្តី មានសិទ្ធិធ្វើឧបាស្រ័យផ្ទាល់អំពីរូបិយាណត្តិទល់នឹងអ្នកធ្វើស្ទីការ ចំពោះអ្វីៗដែលអាចត្រូវបានទាមទារអនុលោមតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃច្បាប់នេះ ។

**មាត្រា ៨៩.-**

កាលបើបហារិតដែលបានធ្វើស្ទីការនៅលើរូបិយាណត្តិបានលុបស្ទីការនោះនៅមុនពេលមានបដិទានរូបិយាណត្តិមកវិញ ស្ទីការនេះត្រូវបានចាត់ទុកថាបានបដិសេធចោល ។ ក្នុងករណីដែលគ្មានភស្តុតាងផ្ទុយពីនេះ ការលុបចោលត្រូវបានចាត់ទុកថាធ្វើឡើងនៅមុនពេលរូបិយាណត្តិត្រូវបានធ្វើបដិទាន ។

បើបហារិតបានជូនដំណឹងពីស្ទីការរបស់ខ្លួនជាលាយលក្ខណ៍អក្សរឱ្យទៅអ្នកកាន់ ឬ ឱ្យទៅភាគីណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ទោះបីយ៉ាងណាក៏ដោយ ក៏បហារិតត្រូវទទួលខុសត្រូវចំពោះភាគីទាំងនេះ ស្របតាមខ្លឹមសារនៃស្ទីការរបស់ខ្លួន ។

## ផ្នែកទី ៤
## រូបិយបដិភោគរូបិយាណត្តិ

**មាត្រា ៩០.-**

ការទូទាត់សងរូបិយាណត្តិ អាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃរូបិយាណត្តិ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។

**មាត្រា ៩១.-**

រូបិយបដិភោគអាចត្រូវបានធ្វើឡើង នៅលើរូបិយាណត្តិផ្ទាល់ ឬ នៅលើអនុប័ត្រ ។

៥១/១២៦

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថា **រូបិយបដិភោគី** ។

រាល់ហត្ថលេខា ដែលបានចុះនៅខាងមុខរូបិយាណត្តិក្រៅពីហត្ថលេខារបស់បហារិត ឬ របស់បហារ៉ក ត្រូវបានចាត់ទុកថាជាហត្ថលេខាធ្វើរូបិយបដិភោគ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវបុគ្គលណាមួយដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថា ធ្វើឱ្យបហារ៉ក ។

**មាត្រា ៩២.-**

រូបិយបដិភោគីមានកាតព្វកិច្ចដូចបុគ្គល ដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងរូបិយាណត្តិ រូបិយបដិភោគីមានសិទ្ធិទាំងឡាយនៃរូបិយាណត្តិនោះទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះនៅលើរូបិយាណត្តិ ។

## ផ្នែកទី ៥
## កាលប្បវត្តិនៃរូបិយាណត្តិ

**មាត្រា ៩៣.-**

រូបិយាណត្តិអាចត្រូវបានចេញដើម្បី :

-ទូទាត់សងប្រាក់នៅពេលបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ

-ទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

រូបិយាណត្តិអាចត្រូវបានចេញឱ្យទូទាត់សងប្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមានល័ក្ខខ័ណ្ឌថាក្នុងករណីខកខានទូទាត់សងប្រាក់នៅដំណាក់កាលណាមួយ ចំនួនប្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

រូបិយាណត្តិទាំងឡាយដែលមានឥណប្រតិទានផ្សេងពីនេះ ត្រូវបានចាត់ទុកជាមោឃៈ ។

**មាត្រា ៩៤.-**

រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ។ រូបិយាណត្តិនេះត្រូវតែបានបង្ហាញនៅពេលណាមួយ ក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។ បហារិកអាចបង្រួញ ឬ ពន្យាររយៈពេលនេះ ។ រយៈពេលកំណត់នេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខផងដែរ ។

បហារិកអាចបញ្ជាក់ថា រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញ ត្រូវចាប់ផ្តើមពីថ្ងៃកំណត់នោះ ។

**មាត្រា ៩៥.-**

ឥណប្រតិទាននៃរូបិយាណត្តិទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើស្វីការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទទេ ស្វីការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកធ្វើស្វីការ ត្រូវបានចាត់ទុកថា បានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើស្វីការ ។

**មាត្រា ៩៦.-**

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែ ឬ ច្រើនខែ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញរូបិយាណត្តិ

48/125

មានឥណប្រតិទាននៅកាលបរិច្ឆេទ ដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ រូបិយាណត្តិមានឥណប្រតិទាននៅថ្ងៃចុងក្រោយនៃខែនោះ ។

កាលបើរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញរយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្តាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា **ប្រាំបីថ្ងៃ** ឬ **ដប់ប្រាំថ្ងៃ** មិនមានន័យថា មួយសប្តាហ៍ ឬ ពីរសប្តាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថា **កន្លះខែ** មានន័យថាដប់ប្រាំថ្ងៃ ។

**មាត្រា ៩៧.-**

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

កាលបើរូបិយាណត្តិចេញរវាងកន្លែងពីរ ដែលមានប្រតិទិនខុសគ្នាត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ថ្ងៃចេញផ្សាយត្រូវបានគិតតាមថ្ងៃដែលត្រូវគ្នានឹងប្រតិទិននៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយឥណ-ប្រតិទានក៏ត្រូវកំណត់ស្របទៅតាមនោះដែរ ។ រយៈពេលសម្រាប់បង្ហាញរូបិយាណត្តិ-ត្រូវបានគណនាទៅតាមវិធាននេះ ។

**វិធានទាំងនេះមិនត្រូវបានអនុវត្តទេ បើមានបដិញ្ញា ឬ ខ្លឹមសារថែងអំពីវិធានផ្សេងពីនេះ ។**

## ផ្នែកទី ៦
## ការទូទាត់សងប្រាក់

### មាត្រា ៩៨.-

អ្នកកាន់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២)ថ្ងៃ ធ្វើការបន្ទាប់ ។

ការបង្ហាញរូបិយាណត្តិតាមរយៈសភាជាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

### មាត្រា ៩៩.-

បហាវិតដែលទូទាត់សងរូបិយាណត្តិ អាចតម្រូវឱ្យប្រគល់រូបិយាណត្តិនោះឱ្យខ្លួនក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់រូបិយាណត្តិ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បហាវិតអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើរូបិយាណត្តិ និងទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

### មាត្រា ១០០.-

នៅពេលដែលរូបិយាណត្តិមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ៩៨ នៃច្បាប់នេះ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

### មាត្រា ១០១.-

អ្នកកាន់រូបិយាណត្តិ មិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់នៅមុនពេលដល់ឥណប្រតិទានឡើយ ។

45/124

បហារិតដែលទូទាត់សងប្រាក់មុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិ-ភ័យ ដោយខ្លួនឯងផ្ទាល់ ។

បហារិតដែលទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ បហារិត ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិ-លេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

**មាត្រា ១០២.-**

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញជារូបិយប័ណ្ណដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើរូបិយាណត្តិនោះធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារកអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើរូបិយាណត្តិ ។

វិធានទាំងឡាយខាងលើនេះមិនត្រូវបានអនុវត្តចំពោះរូបិយាណត្តិ :

-ដែលចេញជារូបិយប័ណ្ណដែលមានការទទួលយក នៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ បហារកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ រូបិយាណត្តិនឹងត្រូវទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃរូបិយាណត្តិ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែលមាននាមបារីកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និងប្រទេសចេញផ្សាយ ឬប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុង

៎ ៧/៤

រូបិយាណត្តិត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ មិនមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

នៅពេលដែលរូបិយាណត្តិត្រូវបានទូទាត់សងនៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវបុះឥណពន្ធតាមចំនួនប្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

## ផ្នែកទី ៧
## ឧបាស្រ័យចំពោះការមិនធ្វើស៊ីការឬការមិនទូទាត់សងប្រាក់

**មាត្រា ១០៣.-**

អ្នកកាន់រូបិយាណត្តិ អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បរហារិក និងភាគីពាក់ព័ន្ធដទៃៗទៀត :

១-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើ ឬ

២-ទោះបីនៅមុនពេលដល់ឥណប្រតិទានក្តី :

-បើមានករណីមិនព្រមធ្វើស៊ីការចំពោះចំនួនប្រាក់ទាំងស្រុង ឬមួយផ្នែកនៃរូបិយាណត្តិ

-ក្នុងករណីធនក្ស័យរបស់បហារិត ទោះបីជាមាន ឬ គ្មានធ្វើស៊ីការក្តី ឬ ក្នុងករណីបញ្ឈប់បហារិតមិនឱ្យទូទាត់សងប្រាក់ដោយគ្មានសេចក្តីសម្រេចពីតុលាការ ឬ នៅពេលណាដែលការអនុវត្តរឹបអូសទ្រព្យសម្បត្តិរបស់បហារិតពុំបានសម្រេច

-ក្នុងករណីធនក្ស័យរបស់បហារិកនៃរូបិយាណត្តិ ដែលមិនធ្វើស៊ីការ ។

**មាត្រា ១០៤.-**

វិវុទ្ធវាទអាចត្រូវបានធ្វើឡើងក្រោមល័ក្ខខ័ណ្ឌដូចតទៅ :

១-ការខកខានមិនបានធ្វើស៊ីការ ឬ មិនបានទូទាត់សងប្រាក់ត្រូវតែបានបង្ហាញភស្តុតាងដោយវិវុទ្ធវាទតាមច្បាប់ ។

50/ករ

២-វិរុទ្ធវាទចំពោះការមិនធ្វើស្ទីការ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់បង្ហាញឱ្យធ្វើស្ទីការ ។ ដូចមានចែងនៅក្នុងមាត្រា ៨៤ នៃច្បាប់នេះ បើការបង្ហាញលើកទីមួយ ត្រូវបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់នោះ វិរុទ្ធវាទអាចធ្វើឡើងនៅថ្ងៃបន្ទាប់ ។

៣-វិរុទ្ធវាទចំពោះការមិនទូទាត់សងរូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់ នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលរូបិយាណត្តិនោះត្រូវទូទាត់សងប្រាក់ ។ នៅក្នុងករណីនៃរូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញវិរុទ្ធវាទត្រូវតែបានធ្វើក្រោមល័ក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើស្តីពីវិរុទ្ធវាទចំពោះការមិនធ្វើស្ទីការ ។

៤-វិរុទ្ធវាទចំពោះការមិនធ្វើស្ទីការ អាចធ្វើបានដោយមិនបាច់បង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ និងបង្ហាញវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ ។

៥-បើបហារិតត្រូវបានបញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ទោះបីមាន ឬ គ្មានស្ទីការក្តី ឬ បើការអនុវត្តរឹបអូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន តែនៅក្រោយការបង្ហាញរូបិយាណត្តិឱ្យទៅបហារិតធ្វើការទូទាត់សងប្រាក់ និងនៅក្រោយពេលដែលវិរុទ្ធវាទត្រូវបានធ្វើ ។

៦-បើបហារិតត្រូវបានប្រកាសថាធនក្ស័យ ទោះបីបាន ឬ មិនបានធ្វើស្ទី-ការក្តី ឬ បើបហារីកនៃរូបិយាណត្តិ ដែលមិនធ្វើស្ទីការត្រូវបានប្រកាសថាធនក្ស័យ ការបង្ហាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្ស័យនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន ។

៧-វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រី ដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃរូបិយាណត្តិភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិរុទ្ធវាទនោះ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ

សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញបហារិត ឬ អ្នកធ្វើស្ទីការ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស្ទីការ ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស្ទីការ ។

៨-វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់បហារិតបញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ នៃមាត្រានេះ ។

## មាត្រា ១០៥.-

អ្នកកាន់ត្រូវជូនដំណឹងពីការមិនធ្វើស្ទីការ ឬ មិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន បហារ៉ក និងរូបិយបដិភោគីណាមួយនៃអ្នកធ្វើស្ទីការនៅក្នុងរយៈពេលបួន(០៤)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ(០២)ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួល ដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់បហារ៉កបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹង ត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើរូបិយាណត្តិ សេចក្តីជូនដំណឹងដូចគ្នានេះ ក៏ត្រូវបានផ្តល់ទៅរូបិយបដិភោគីនៅក្នុងពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខ មិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

52/128

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹងអាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនរូបិយាណត្តិត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួន បើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃរូបិយាណត្តិឡើយ ។

**មាត្រា ១០៦.-**

តាមរយៈបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរ និងមានចុះហត្ថលេខានៅលើរូបិយាណត្តិ បហារីក អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី អាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិវាទ ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញរូបិយាណត្តិ នៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ជាបន្ទុករបស់បុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហារីក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីប៉ុណ្ណោះ ។ ទោះបីបដិញ្ញាសរសេរដោយបហារីកក៏ដោយ បើអ្នកកាន់ធ្វើវិវាទ អ្នកកាន់នេះត្រូវទទួលរ៉ាប់រងលើសោហ៊ុយទាំងអស់ដែលកើតមាន ។ កាលបើបដិញ្ញាកើតចេញអំពីអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី សោហ៊ុយនៃ

វិវាទ បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។

## មាត្រា ១០៧.-

រាល់បហារ៉ក អ្នកធ្វើស៊ីការ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលធានាដោយការធ្វើរូបិយបដិភោគនៃរូបិយាណត្តិ មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្ដឹងទល់នឹងបុគ្គលជាប់ពាក់ព័ន្ធទៅនឹងរូបិយាណត្តិជាឯកត្តជន ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះ ចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះ ត្រូវមានចំពោះបុគ្គលណាដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ហើយបានទទួលយករូបិយាណត្តិរក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្ដឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្ដឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ ពីបុគ្គលដែលបានទទួលរងការប្ដឹងទីមួយនោះក៏ដោយ ។

## មាត្រា ១០៨.-

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្លួនអនុវត្តសិទ្ធិឧបាស្រ័យនូវចំនួនប្រាក់នៃរូបិយាណត្តិដែលមិនបានធ្វើស៊ីការ ឬ មិនបានទូទាត់សងដោយមានការប្រាក់ បើការប្រាក់នោះមានចែងលើរូបិយាណត្តិ ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហ៊ុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃរូបិយាណត្តិត្រូវជាកម្មវត្ថុនៃការធ្វើអប្បហារ ។ អប្បហារនេះត្រូវបានគណនាទៅតាមអត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបាស្រ័យ នៅកន្លែងស្នាក់នៅរបស់អ្នកកាន់ ។

## មាត្រា ១០៩.-

ភាគីដែលបានទទួលយក និងទូទាត់សងរូបិយាណត្តិ អាចទាមទារមកវិញពីភាគីទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សងការប្រាក់

54/124

លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

**មាត្រា ១១០.–**

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ឱ្យប្រគល់មកខ្លួន នូវរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធវាទ និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយក និងបានទូទាត់សងរូបិយាណត្តិ អាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយ ។

**មាត្រា ១១១.–**

នៅក្នុងករណីដែលការអនុវត្តសិទ្ធិធ្វើឧបាស្រ័យ បន្ទាប់ពីការធ្វើស្ទីការតែលើមួយផ្នែកនៃចំនួនប្រាក់ ភាគីដែលទូទាត់សងចំនួនប្រាក់លើរូបិយាណត្តិដែលមិនត្រូវបានធ្វើស្ទីការនោះ អាចទាមទារឱ្យបញ្ជាក់ការទូទាត់សងប្រាក់មួយផ្នែកនេះនៅលើរូបិយាណត្តិ និងទាមទារយកបង្កាន់ដៃក្នុងការទូទាត់សងប្រាក់នេះផង ។ អ្នកកាន់ក៏ត្រូវតែប្រគល់ឱ្យអ្នកទូទាត់សងប្រាក់នេះ នូវច្បាប់ចម្លងមានវិញ្ញាបនកម្មនៃរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធវាទ ដើម្បីអាចអនុវត្តសិទ្ធិឧបាស្រ័យជាបន្តទៀត ។

**មាត្រា ១១២.–**

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើឧបាស្រ័យអាចទូទាត់សងប្រាក់ដោយខ្លួនឯង តាមមធ្យោបាយនៃរូបិយាណត្តិថ្មីមួយទៀត ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញឱ្យទៅភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់សងនៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានា ដែលចែងនៅក្នុងមាត្រា ១០៨ និង មាត្រា ១០៩ នៃច្បាប់នេះ រូបិយាណត្តិថ្មីមានបញ្ចូលនូវកម្រៃជើងសា និងថ្លៃតែមប្រើផងដែរ ។

បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សង ត្រូវបានកំណត់ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញនៅកន្លែងដែលរូបិយាណត្តិដំបូង ត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់ភាគីពាក់

ព័ន្ធ ។ បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិទូទាត់សងនៅពេលបង្ហាញ នៅកន្លែងដែលបហារិកនៃរូបិយាណត្តិថ្មីនោះ មានលំនៅនៅកន្លែងជាមួយភាគីមួយដែលពាក់ព័ន្ធ ។

**មាត្រា ១១៣.-**

អ្នកកាន់បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារិក និងភាគីពាក់ព័ន្ធដទៃទៀត លើកលែងតែសិទ្ធិធ្វើឧបាស្រ័យទល់នឹងអ្នកធ្វើស្វី-ការ ក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ការធ្វើវិរុទ្ធវាទចំពោះការមិនធ្វើស្វីការ ឬ ការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលវិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលវិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

បើគ្មានការបង្ហាញឱ្យធ្វើស្វីការក្នុងរយៈពេលដែលកំណត់ដោយបហារិកទេ អ្នកកាន់បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនចំពោះការមិនទូទាត់សងប្រាក់ក៏ដូចជាការមិនធ្វើស្វីការ លើកលែងតែខ្លឹមសារនៃបដិញ្ញាបានបង្ហាញថា បហារិកមានចេតនាធ្វើឱ្យខ្លួនរួចផុតពីការធានាលើស្វីការតែប៉ុណ្ណោះ ។

បើបដិញ្ញាស្តីពីរយៈពេលកំណត់ឱ្យបង្ហាញ មានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខនោះតែប៉ុណ្ណោះ ។

អ្នកកាន់ដែលបាត់បង់សិទ្ធិធ្វើឧបាស្រ័យក្រោមមាត្រានេះ អាចប្តឹងបហារិកក្រោមបទប្បញ្ញត្តិដោយឡែកស្តីពីកិច្ចសន្យា ។ សំណងបានមកវិញដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវបានកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារិក ដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

56/118

មាត្រា ១១៤.-

កាលបើការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទក្នុងរយៈពេលកំណត់ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបានដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើរូបិយាណត្តិ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១០៥ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិភ្លាមដើម្បីឱ្យធ្វើស៊ីការ ឬ ឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ។

បើករណីប្រធានស័ក្តិ នៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលដល់ឥណប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទមិនចាំបាច់ធ្វើឡើយ ។

ចំពោះរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះ ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះរូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញដែលមានបញ្ជាក់ច្បាស់នៅលើរូបិយាណត្តិ ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិរុទ្ធវាទ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើរូបិយាណត្តិដែលត្រូវបានបាត់បង់ ឬ ត្រូវបំផ្លាញអាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តរូបិយាណត្តិដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើរូបិយាណត្តិតាមសេចក្តី

៩៧/២៥ .

សម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលរូបិយាណត្តិមកដោយសុចរិត ឬ ដោយគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ៨
## ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

**មាត្រា ១១៥.-**

បហារីក អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវធ្វើស្វីការ ឬ ទូទាត់សងប្រាក់បានក្នុងករណីចាំបាច់ ។

រូបិយាណត្តិអាចត្រូវបានធ្វើស្វីការ ឬ ទូទាត់សងដោយបុគ្គលដែលធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ជូសកូនបំណុលណាមួយ ដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីបហារិត ឬ ភាគីដែលបានពាក់ព័ន្ធលើរូបិយាណត្តិរួចហើយ លើកលែងតែអ្នកធ្វើស្វីការ ។

នៅក្នុងរយៈពេលពីរ(០២)ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគី ដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនប្រាក់នៃរូបិយាណត្តិឡើយ ។

**មាត្រា ១១៦.-**

ស្វីការដោយអន្តរាគមន៍អាចកើតមាននៅក្នុងគ្រប់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់ឥណប្រតិទានលើរូបិយាណត្តិដែលមិនទាន់ត្រូវបានធ្វើស្វីការ ។

កាលបើរូបិយាណត្តិមានបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវបានចាត់តាំងឱ្យធ្វើស្វី-ការ ឬ ឱ្យទូទាត់សងប្រាក់ ក្នុងករណីចាំបាច់នៅកន្លែងដែលទូទាត់សងប្រាក់ អ្នកកាន់មិនអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួន នៅមុនពេលដល់ឥណប្រតិទានទល់នឹងបុគ្គលដែលត្រូវបានចាត់តាំង និងហត្ថលេខីបន្តបន្ទាប់ឡើយ លើកលែងតែអ្នកកាន់បានបង្ហាញ

៩៨/១២៥

រូបិយាណត្តិឱ្យទៅបុគ្គលនោះ និងមានសំអាងដោយវិវុទ្ធវាទអំពីការបដិសេធមិនព្រមធ្វើស្ទីការរបស់បុគ្គលដដែលនេះ ។

ក្នុងករណីអន្តរាគមន៍ផ្សេងៗទៀត អ្នកកាន់អាចបដិសេធការធ្វើស្ទីការដោយអន្តរាគមន៍ ។ ផ្ទុយទៅវិញ បើព្រមទទួលយកស្ទីការបែបនេះ អ្នកកាន់បាត់បង់សិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់ឥណប្រតិទានទល់នឹងបុគ្គលដែលបានធ្វើស្ទីការនេះនិងហត្ថលេខីបន្តបន្ទាប់ ។

## មាត្រា ១១៧.-

ស្ទីការដោយអន្តរាគមន៍ត្រូវធ្វើនៅលើរូបិយាណត្តិ និងចុះហត្ថលេខាដោយបុគ្គលដែលធ្វើអន្តរាគមន៍ ។ ស្ទីការនេះបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវទទួលការទូទាត់សងប្រាក់ ហើយក្នុងករណីគ្មានការបញ្ជាក់នេះទេ ស្ទីការត្រូវបានចាត់ទុកថាបានធ្វើឱ្យបហារីក ។

## មាត្រា ១១៨.-

អ្នកធ្វើស្ទីការដោយអន្តរាគមន៍ មានការទទួលខុសត្រូវដូចគ្នានឹងភាគីទទួលអន្តរាគមន៍ចំពោះអ្នកកាន់ និងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បន្ទាប់ក្រោយភាគីដែលបានទទួលអន្តរាគមន៍នោះ ។

ថ្វីបើមានការធ្វើស្ទីការដោយអន្តរាគមន៍ក្តី ក៏ភាគីទទួលអន្តរាគមន៍ និងភាគីទាំងឡាយដែលពាក់ព័ន្ធអាចទាមទារឱ្យអ្នកកាន់ប្រគល់រូបិយាណត្តិវិវុទ្ធវាទ និង ទាមទារបង្កាន់ដៃទទួលប្រាក់បានបើមាន ដើម្បីប្តូរនឹងការទូទាត់សងចំនួនប្រាក់ដូចមានចែងក្នុងមាត្រា ១០៨ នៃច្បាប់នេះ ។

## មាត្រា ១១៩.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ អាចធ្វើបាននៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះរូបិយាណត្តិ នៅពេលដល់ឥណប្រតិទាន ឬ នៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងប្រាក់ ត្រូវរាប់បញ្ចូលនូវចំនួនប្រាក់ទាំងអស់ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងប្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ ។

**មាត្រា ១២០.-**

បើរូបិយាណត្តិត្រូវបានធ្វើស៊ីការដោយអន្តរាគមន៍ពីបុគ្គលដែលមានលំនៅនៅកន្លែងត្រូវទូទាត់សងប្រាក់ ឬ បើបុគ្គលទាំងឡាយដែលមានលំនៅនៅទីនោះដែរត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ ត្រូវធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់យ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ ឬ ភាគីដែលរូបិយាណត្តិត្រូវបានធ្វើស៊ីការជាប្រយោជន៍ឱ្យ និងអ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

**មាត្រា ១២១.-**

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍ បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

**មាត្រា ១២២.-**

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាព អំពីការទទួលប្រាក់នៅលើរូបិយាណត្តិដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជួស ។ ក្នុងករណីគ្មានសេចក្ដីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យបហារីក ។

រូបិយាណត្តិ និងវិរុទ្ធវាទ បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

**មាត្រា ១២៣.-**

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃរូបិយាណត្តិទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជួស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើរូបិយាណត្តិ ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខរូបិយាណត្តិបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគី ដែលទទួលការទូទាត់សងប្រាក់ជួសត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ ការទូទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេ ត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

## ផ្នែកទី ៩
## ផ្នែកទាំងឡាយនៃរូបិយាណត្តិមួយច្បាប់និងច្បាប់ចម្លង

**មាត្រា ១២៤.-**

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញមួយច្បាប់មានពីរ ឬ ច្រើនផ្នែកដូចគ្នា ផ្នែកនីមួយៗត្រូវចុះលេខ និងមានសេចក្តីយោងទៅផ្នែកផ្សេងទៀត ផ្នែកទាំងអស់បង្កើតបានជារូបិយាណត្តិមួយច្បាប់ ។

ស្ទីការ និងបិដ្ឋិលេខនីមួយៗ នៅលើរូបិយាណត្តិដែលបានចេញក្នុងមួយច្បាប់ អាចត្រូវបានសរសេរនៅលើផ្នែកណាមួយ ប៉ុន្តែត្រូវបានពាក់ព័ន្ធទៅលើរូបិយាណត្តិទាំងមូល ហើយមិនមែនទៅលើតែផ្នែកណាមួយដាច់គ្នានោះទេ ។ ស្ទីការ ឬ បិដ្ឋិលេខនីមួយៗទាំងនោះ ត្រូវបានសរសេរនៅលើតែផ្នែកមួយប៉ុណ្ណោះ ។

បហារីកដែលចុះហត្ថលេខាលើផ្នែកនីមួយៗ មានការទទួលខុសត្រូវនៅលើរូបិយាណត្តិទាំងមូល ហើយមិនមែនលើផ្នែកនីមួយៗនោះទេ ។

ភាគីដែលបានធ្វើផ្នែកមួយដើម្បីធ្វើស្វីការ ត្រូវតែចង្អុលបង្ហាញនៅលើផ្នែកផ្សេងទៀត នូវឈ្មោះរបស់បុគ្គលដែលមានផ្នែកនោះនៅក្នុងដៃ ។ បុគ្គលនោះត្រូវតែប្រគល់ផ្នែកនោះឱ្យទៅអ្នកកាន់ស្របច្បាប់នៃផ្នែកមួយទៀត ។ បើបុគ្គលនោះបដិសេធ អ្នកកាន់អាចអនុវត្តសិទ្ធិឧបាស្រ័យបាន លុះត្រាតែខ្លួនបានធ្វើវិរុទ្ធវាទដោយបញ្ជាក់អំពី ៈ

-ផ្នែកដែលបានធ្វើដើម្បីធ្វើស្វីការ មិនត្រូវបានប្រគល់ឱ្យខ្លួនតាមការស្នើសុំ

-ស្វីការ ឬការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅលើផ្នែកផ្សេងទៀត ។

**មាត្រា ១២៥.-**

នៅពេលដែលអ្នកកាន់រូបិយាណត្តិមួយច្បាប់ធ្វើបិដ្ឋិលេខលើផ្នែកពីរ ឬ ច្រើនឱ្យទៅបុគ្គលផ្សេងគ្នា ៖

-អ្នកកាន់ត្រូវទទួលខុសត្រូវ នៅលើរាល់ផ្នែកទាំងនោះ ហើយអ្នកធ្វើបិដ្ឋិលេខនីមួយៗបន្ទាប់ពីអ្នកកាន់ ត្រូវទទួលខុសត្រូវលើផ្នែកដែលខ្លួនបានធ្វើបិដ្ឋិលេខដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា

-អ្នកកាន់ស្របច្បាប់នៃផ្នែកដែលមានកម្មសិទ្ធិទីមួយ មានសិទ្ធិទាមទារប្រាក់ដែលបហារីកបានសងឱ្យទៅបុគ្គលណាមួយ ឬ បហារិត ដែលមិនបានធ្វើស្វីការលើរូបិយាណត្តិ ។

នៅពេលដែលបហារិតធ្វើស្វីការច្រើនជាងមួយផ្នែក ហើយផ្នែកដែលបានធ្វើស្វីការនោះធ្លាក់ទៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ផ្សេងគ្នា បហារិតត្រូវទទួលខុសត្រូវលើរាល់ផ្នែកទាំងនោះ ដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា ។

**មាត្រា ១២៦.-**

នៅពេលដែលអ្នកធ្វើស្វីការលើរូបិយាណត្តិ ដែលបានចេញមួយច្បាប់ ធ្វើការទូទាត់សងប្រាក់ ដោយពុំបានទាមទារឱ្យប្រគល់មកវិញនូវផ្នែកដែលមានស្វីការរបស់ខ្លួន ហើយផ្នែកនោះនៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ នៅពេលដល់ឥណប្រតិទាន អ្នកធ្វើស្វីការនោះ ត្រូវទទួលខុសត្រូវចំពោះអ្នកកាន់នេះ ។

បហារីកនៃរូបិយាណត្តិមួយច្បាប់ ត្រូវរួចផុតពីការទទួលខុសត្រូវ នៅពេលដែលខ្លួនបានសងប្រាក់ នៅលើផ្នែកណាមួយដែលបានយកមកបង្ហាញ ។

ℱ

64/128

ក្រោមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១២៥ និងមាត្រា ១២៦ នៃច្បាប់នេះ នៅពេលដែលផ្នែកណាមួយនៃរូបិយាណត្តិ ត្រូវបានរួចបំណុលដោយការទូទាត់សង ប្រាក់ ឬ តាមរបៀបផ្សេងទៀត រូបិយាណត្តិទាំងមូលត្រូវបានរួចបំណុល ។

**មាត្រា ១២៧.-**

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងរូបិយាណត្តិ ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យបានត្រឹមត្រូវតាមច្បាប់ដើមជាមួយនិងបិដ្ឋិលេខ និង សេចក្តីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់ លាស់នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខ និងធ្វើរូបិយបដិភោគនៅក្នុងលក្ខណៈដូច គ្នា ហើយមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

**មាត្រា ១២៨.-**

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើម ត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើមដែលមានចែងខាងលើ ឱ្យទៅអ្នកកាន់ស្រប ច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើរូបិយបដិភោគច្បាប់ចម្លង លុះ ត្រាតែបានបញ្ជាក់នៅលើវិរុទ្ធវាទថា ច្បាប់ដើមមិនទាន់ត្រូវប្រគល់មកវិញតាមសំណើ របស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ ដើមមានបដិញ្ញាថា **ចាប់ផ្តើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិ-លេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ** ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខ បន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ១០
## ការកែលើរូបិយាណត្តិ

**មាត្រា ១២៩.-**

ក្នុងករណីមានការកែលើខ្លឹមសារនៃរូបិយាណត្តិ រាល់ភាគីដែលបានចុះហត្ថ-លេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃរូបិយា-ណត្តិ ។

## ផ្នែកទី ១១
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

**មាត្រា ១៣០.-**

រាល់ឧបាស្រ័យដែលកើតឡើងពីរូបិយាណត្តិ ទល់នឹងអ្នកធ្វើស្វីការ មានរយៈពេលបី(០៣)ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រ័យដែលធ្វើឡើងដោយអ្នកកាន់ ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងបហារីក មានរយៈពេលមួយឆ្នាំ គិតពីថ្ងៃធ្វើវិរុទ្ធវាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទាន កាលបើមានបដិញ្ញាថា **បង្វិលវិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលវិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រ័យរបស់អ្នកធ្វើបិដ្ឋិលេខ ទល់នឹងអ្នកធ្វើបិដ្ឋិលេខផងគ្នា និងបហា-រីក មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និងបានទូទាត់សងរូបិយាណត្តិ ឬ គិតពីថ្ងៃដែលបានទទួលរងការប្តឹង ។

**មាត្រា ១៣១.-**

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

64/128

## ផ្នែកទី ១២
## ការគណនារយៈពេលកំណត់

**មាត្រា ១៣២.–**

រូបិយាណត្តិដែលដល់រយៈពេលកំណត់ទូទាត់សងប្រាក់ នៅថ្ងៃឈប់សម្រាកផ្លូវការ នឹងត្រូវទូទាត់សងនៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងរូបិយាណត្តិ ជាពិសេសការបង្ហាញឱ្យធ្វើស៊ីការ និងវិរុទ្ធវាទអាចត្រូវធ្វើឡើងបានតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយ ដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

**មាត្រា ១៣៣.–**

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះ នឹងមិនរាប់បញ្ចូលជាមួយផងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

**មាត្រា ១៣៤.–**

ទោះបីតាមផ្លូវច្បាប់ក្តីឬតាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

## ជំពូកទី ៤
## ប័ណ្ណសងតាមបញ្ជា

## ផ្នែកទី ១
## ការចេញផ្សាយនិងទម្រង់នៃប័ណ្ណសងតាមបញ្ជា

**មាត្រា ១៣៥.–**

ប័ណ្ណសងតាមបញ្ជា ជាការសន្យាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌដែលធ្វើឡើងនិងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញប័ណ្ណដែលសន្យាសងចំនួនប្រាក់

ជាកំណត់មួយ ឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជាត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងជំពូកនេះ ។

**មាត្រា ១៣៦.-**

ប័ណ្ណសងតាមបញ្ជាជាឧបករណ៍ឥណទាន ។ ប័ណ្ណសងតាមបញ្ជាអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ អក្សរបរទេស ហើយត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **ប័ណ្ណសងតាមបញ្ជា** ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញប័ណ្ណ

-ការសន្យាទូទាត់សងដោយឥតល័ក្ខខ័ណ្ឌនូវចំនួនប្រាក់ជាកំណត់មួយ

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែងដែលប័ណ្ណសងតាមបញ្ជានោះត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់អ្នកចេញប័ណ្ណ ដែលជាបុគ្គលធ្វើការសន្យាលើប័ណ្ណសងតាមបញ្ជា ។

**មាត្រា ១៣៧.-**

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ១៣៦ នៃច្បាប់នេះពុំមានសុពលភាពជាប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌដូចខាងក្រោម :

១-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

64/128

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់អ្នកចេញប័ណ្ណផងដែរ ។

៣-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់កន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថា ចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ។

៤-ប័ណ្ណសងតាមបញ្ជា អាចត្រូវចេញដើម្បីទូទាត់សងប្រាក់ទៅអ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជាដែលគ្មានឈ្មោះបុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាជាប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

**មាត្រា ១៣៨.-**

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងប្រាក់ នៅកន្លែងក្រៅពីលំនៅរបស់អ្នកចេញប័ណ្ណ រួមទាំងនៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់អ្នកចេញប័ណ្ណ ឬ នៅកន្លែងផ្សេងទៀត ។

**មាត្រា ១៣៩.-**

ចំពោះប្រភេទប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ អ្នកចេញប័ណ្ណអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃប័ណ្ណសងតាមបញ្ជាផ្សេងពីខាងលើ បដិញ្ញានេះ មិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ត្រូវតែបានបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញប័ណ្ណសងតាមបញ្ជា លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

**មាត្រា ១៤០.-**

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជា

តួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ និងកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

**មាត្រា ១៤១.-**

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា នៅតែមានតម្លៃដដែល ទោះបីប័ណ្ណសងតាមបញ្ជានោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬ បានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

**មាត្រា ១៤២.-**

បុគ្គលណាដែលបានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា ក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើប័ណ្ណសងតាមបញ្ជានោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលរ៉ាប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជន ដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

**មាត្រា ១៤៣.-**

បើប័ណ្ណសងតាមបញ្ជាមានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្ដឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលប័ណ្ណសងតាមបញ្ជាមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ២
## បិដ្ឋិលេខប័ណ្ណសងតាមបញ្ជា

**មាត្រា ១៤៤.–**

ប័ណ្ណសងតាមបញ្ជា ដែលចេញឱ្យទូទាត់សងចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា **សងតាមបញ្ជា** អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលអ្នកចេញប័ណ្ណបានបញ្ចូលក្នុងប័ណ្ណសងតាមបញ្ជា ដែលចេញដើម្បីទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នា ប័ណ្ណសងតាមបញ្ជានោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាព ជាការផ្ទេរជាធម្មតាតែប៉ុណ្ណោះ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅអ្នកចេញប័ណ្ណក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃប័ណ្ណសងតាមបញ្ជានោះក្តី ។ បុគ្គលទាំងនេះអាចធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជានោះបន្តទៀតបាន ។

ឧបករណ៍ដែលមានទម្រង់ជាប័ណ្ណសងតាមបញ្ជា ដែលអាចទូទាត់សងបានតាមបញ្ជាអ្នកចេញប័ណ្ណ មិនមែនជាប័ណ្ណសងតាមបញ្ជាក្រោមជំពូកនេះឡើយ លើកលែងតែប័ណ្ណនេះត្រូវបានធ្វើបិដ្ឋិលេខដោយអ្នកចេញប័ណ្ណ។

**មាត្រា ១៤៥.–**

បិដ្ឋិលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជា មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ **អ្នកកាន់** មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

៤៧/១៤៤-

## មាត្រា ១៤៦.-

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងប័ណ្ណសងតាមបញ្ជា ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុបំត្រ** ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខ អាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

## មាត្រា ១៤៧.-

បិដ្ឋិលេខ ផ្ទេរសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តប័ណ្ណសងតាមបញ្ជាជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេរប័ណ្ណសងតាមបញ្ជាឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

## មាត្រា ១៤៨.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើប័ណ្ណសងតាមបញ្ជាចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែប័ណ្ណសងតាមបញ្ជានោះមិនអាចប្រែក្លាយទៅជាប័ណ្ណសងតាមបញ្ជា ដើម្បី **សងតាមបញ្ជា** ឡើយ ។

## មាត្រា ១៤៩.-

ម្ចាស់ប័ណ្ណសងតាមបញ្ជាដែលអាចធ្វើបិដ្ឋិលេខបាន ជាអ្នកកាន់ស្របច្បាប់

បើបុគ្គលនេះបានក្លាយជាម្ចាស់ប័ណ្ណសងតាមបញ្ជា តាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលប័ណ្ណសងតាមបញ្ជា តាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយបានបាត់បង់សិទ្ធិកាន់កាប់ប័ណ្ណសងតាមបញ្ជា ដោយមូលហេតុណាក៏ដោយ ទោះបីជាប័ណ្ណសងតាមបញ្ជាចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានប័ណ្ណសងតាមបញ្ជាមកជាកម្មសិទ្ធិ មិនត្រូវបានបង្ខំឱ្យបោះបង់ចោលប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែប័ណ្ណសងតាមបញ្ជានោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## មាត្រា ១៥០.-

បុគ្គលទាំងឡាយដែលប្តឹងអំពីប័ណ្ណសងតាមបញ្ជា មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកចេញប័ណ្ណ ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះប័ណ្ណសងតាមបញ្ជាដែលចេញដើម្បីទូទាត់សងទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសងតាមបញ្ជា** ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

## មាត្រា ១៥១.-

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ទារបំណុល** ឬ **សម្រាប់បេឡានិច័យ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀតដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជា ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្ដឹងអ្នកកាន់បាន ហើយអ្នកកាន់នេះក៏អាចប្ដឹងអ្នកធ្វើបិដ្ឋិលេខបានផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្ដល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជា ត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ ប័ណ្ណសងតាមបញ្ជានោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្ដីពីប្រតិបត្តិ-ការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីប័ណ្ណសងតាមបញ្ជារវាងបទប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

**មាត្រា ១៥២.-**

កាលបើបិដ្ឋិលេខមួយមានសេចក្ដីបញ្ជាក់ថា **តម្លៃសម្រាប់ធានា** ឬ **តម្លៃសម្រាប់ដាក់បញ្ចាំ** ឬ សេចក្ដីបញ្ជាក់ណាផ្សេងទៀតដែលមានន័យថាសម្រាប់ដាក់បញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជានោះ ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្ដាភាគីដែលពាក់ព័ន្ធមិនអាចប្ដឹងអ្នកកាន់បាន ដោយសំអាងលើទំនាក់ទំនងផ្ទាល់របស់ខ្លួនជាមួយអ្នកធ្វើបិដ្ឋិលេខឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

**មាត្រា ១៥៣.-**

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីការធ្វើវិរុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមមូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្ដល់សិទ្ធិក្រោមមាត្រា ១៤៩ និងមាត្រា ១៥០ នៃច្បាប់នេះ ។

បើគ្មានភស្តុតាងផ្ទុយទេ បិឋិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបានធ្វើនៅលើប័ណ្ណសងតាមបញ្ជាមុនធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នា ឬ មុនផុតរយៈពេលកំណត់ ដែលបានយោងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥៣ នេះ ។

## ផ្នែកទី ៣

## ការទទួលខុសត្រូវរបស់អ្នកចេញប័ណ្ណសងតាមបញ្ជា

**មាត្រា ១៥៤.-**

ក្នុងការចេញប័ណ្ណសងតាមបញ្ជា អ្នកចេញប័ណ្ណសន្យាទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ។

បើមិនបានទូទាត់សងប្រាក់ អ្នកកាន់អាចធ្វើឧបាស្រ័យដោយផ្ទាល់លើប័ណ្ណសងតាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណ ដើម្បីទាមទារនូវអ្វីដែលអាចធ្វើបានស្របតាមមាត្រា ១៧៥ និងមាត្រា ១៧៦ នៃច្បាប់នេះ ។

**មាត្រា ១៥៥.-**

ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើទិដ្ឋាការនៅក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទចេញប័ណ្ណ ។

អ្នកចេញប័ណ្ណអាចបង្រួញ ឬ ពន្យាររយៈពេលកំណត់នេះបាន ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិឋិលេខទាំងឡាយផងដែរ ។

**មាត្រា ១៥៦.-**

ទិដ្ឋាការត្រូវបានសរសេរនៅលើប័ណ្ណសងតាមបញ្ជា ដោយប្រើពាក្យថា **បានធ្វើទិដ្ឋាការ** ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយអ្នកចេញប័ណ្ណ ។

ទិដ្ឋាការត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃដែលបង្ហាញឱ្យទូទាត់សងប្រាក់ ។ បើទិដ្ឋាការនោះគ្មានចុះកាលបរិច្ឆេទទេ អ្នកកាន់ដើម្បីរក្សាសិទ្ធិឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងអ្នកចេញប័ណ្ណ ត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្លេចភ្លាំងនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

រយៈពេលកំណត់ក្រោយការបង្ហាញដែលប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់ ត្រូវគិតពីថ្ងៃធ្វើទិដ្ឋាការដែលបានចុះហត្ថលេខាដោយអ្នកចេញប័ណ្ណ នៅលើប័ណ្ណសងតាមបញ្ជា ។ ការបដិសេធរបស់អ្នកចេញប័ណ្ណក្នុងការផ្តល់ទិដ្ឋាការដោយមានចុះកាលបរិច្ឆេទ ត្រូវតែបញ្ជាក់ដោយការធ្វើវិរុទ្ធវាទ ដែលជាកាលបរិច្ឆេទកំណត់ថ្ងៃចាប់ផ្តើមនៃរយៈពេលកំណត់ បន្ទាប់ពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ។

## ផ្នែកទី ៤
## វូបិយបដិភោគប័ណ្ណសងតាមបញ្ជា

**មាត្រា ១៥៧.-**

ការទូទាត់សងប័ណ្ណសងតាមបញ្ជាអាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃប័ណ្ណសងតាមបញ្ជា ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

**មាត្រា ១៥៨.-**

រូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើប័ណ្ណសងតាមបញ្ជាផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀត ដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថារូបិយបដិភោគី ។

74/128

រាល់ហត្ថលេខាដែលបានចុះនៅខាងមុខប័ណ្ណសងតាមបញ្ជា ក្រៅពីហត្ថលេខារបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាហត្ថលេខាផ្ញើរូបិយបដិភោគ ។

រូបិយបដិភោគត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ នូវបុគ្គលណាមួយដែលជាបុគ្គលទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្ដីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថាផ្ញើឱ្យអ្នកចេញប័ណ្ណ ។

**មាត្រា ១៥៩.-**

រូបិយបដិភោគីមានកាតព្វកិច្ចដូចបុគ្គលដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធាននោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងប័ណ្ណសងតាមបញ្ជា រូបិយបដិភោគីមានសិទ្ធិទាំងឡាយនៃប័ណ្ណសងតាមបញ្ជានេះ ទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានោះ នៅលើប័ណ្ណសងតាមបញ្ជា ។

## ផ្នែកទី ៥
## ឥណប្រតិទានប័ណ្ណសងតាមបញ្ជា

**មាត្រា ១៦០.-**

ប័ណ្ណសងតាមបញ្ជា អាចត្រូវបានចេញដើម្បី :

-ទូទាត់សងប្រាក់នៅពេលបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញប័ណ្ណ

-ទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានចេញដើម្បីឱ្យទូទាត់សងប្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមាន

ល័ក្ខខ័ណ្ឌថា ក្នុងករណីខកខានទូទាត់សងប្រាក់នៅដំណាក់កាលណាមួយ ចំនួនប្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

ប័ណ្ណសងតាមបញ្ជាទាំងឡាយ ដែលមានឥណប្រតិទានផ្សេងពីនេះត្រូវបានចាត់ទុកជាមោឃៈ ។

**មាត្រា ១៦១.-**

ប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយត្រូវតែបានបង្ហាញនៅពេលណាមួយក្នុងរយៈពេលមួយ(០១) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញផ្សាយ ។ អ្នកចេញប័ណ្ណអាចបង្រួញ ឬ ពន្យាររយៈពេលនេះបាន ។ រយៈពេលកំណត់នេះក៏អាចត្រូវបានបង្រួញ ដោយអ្នកធ្វើបិដ្ឋិលេខផងដែរ ។

អ្នកចេញប័ណ្ណអាចបញ្ជាក់ថា ប័ណ្ណសងតាមបញ្ជាដែលអាចទូទាត់សងប្រាក់នៅពេលបង្ហាញ មិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញត្រូវចាប់ផ្ដើមពីថ្ងៃកំណត់នោះ ។

**មាត្រា ១៦២.-**

ឥណប្រតិទាននៃប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើទិដ្ឋាការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទទេ ទិដ្ឋាការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើទិដ្ឋាការ ។

**មាត្រា ១៦៣.-**

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានចេញ ដើម្បីឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែ ឬ ច្រើនខែក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាន នៅកាលបរិច្ឆេទដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាននៅថ្ងៃចុងក្រោយនៃខែនោះ ។

79/128

កាលបើប័ណ្ណសងតាមបញ្ជាត្រូវបានចេញដើម្បីឱ្យទូទាត់សងប្រាក់ ក្នុងរយៈពេល មួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ រយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្ដាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា **ប្រាំបីថ្ងៃ** ឬ **ដប់ប្រាំថ្ងៃ** មិនមានន័យថាមួយសប្ដាហ៍ ឬ ពីរសប្ដាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថា **កន្លះខែ** មានន័យថាដប់ប្រាំថ្ងៃ ។

**មាត្រា ១៦៤.-**

កាលបើប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់នៅថ្ងៃកំណត់មួយ ឬ នៅរយៈពេលកំណត់មួយ បន្ទាប់ពីថ្ងៃកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ លើកលែងតែមានបដិញ្ញានៅក្នុងប័ណ្ណសងតាមបញ្ជា ឬ មានល័ក្ខខ័ណ្ឌសាមញ្ញ ដែលប័ណ្ណសងតាមបញ្ជាចង្អុលបង្ហាញអំពីបំណងក្នុងការជ្រើសរើសយកវិធានផ្សេងពីនេះ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

## ផ្នែកទី ៦
## ការទូទាត់សងប្រាក់

**មាត្រា ១៦៥.-**

អ្នកកាន់ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២) ថ្ងៃធ្វើការបន្ទាប់ ។

ការបង្ហាញប័ណ្ណសងតាមបញ្ជាតាមរយៈសភាផាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជា គឺជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

**មាត្រា ១៦៦.-**

អ្នកចេញប័ណ្ណដែលទូទាត់សងប័ណ្ណសងតាមបញ្ជា អាចតម្រូវឱ្យប្រគល់ប័ណ្ណសងតាមបញ្ជានោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់ប្រាក់មួយផ្នែកនៃចំនួនប្រាក់ប័ណ្ណសងតាមបញ្ជា ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ អ្នកចេញប័ណ្ណអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះនៅលើប័ណ្ណសងតាមបញ្ជា និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

**មាត្រា ១៦៧.-**

នៅពេលដែលប័ណ្ណសងតាមបញ្ជាមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ១៦៥ នៃច្បាប់នេះ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

**មាត្រា ១៦៨.-**

អ្នកកាន់ប័ណ្ណសងតាមបញ្ជាមិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទានឡើយ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិភ័យដោយខ្លួនឯងផ្ទាល់ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ អ្នកចេញប័ណ្ណត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

**មាត្រា ១៦៩.-**

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើជារូបិយប័ណ្ណ ដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេស

ជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើប័ណ្ណសងតាមបញ្ជានោះ ធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃដែលទូទាត់សងប្រាក់ តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែអ្នកចេញប័ណ្ណអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។

វិធានទាំងឡាយខាងលើនេះ មិនត្រូវបានអនុវត្តចំពោះប័ណ្ណសងតាមបញ្ជា :

-ដែលធ្វើជារូបិយប័ណ្ណដែលមានការទទួលយកនៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ អ្នកចេញប័ណ្ណបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ ប័ណ្ណសងតាមបញ្ជានឹងត្រូវទូទាត់សងជារូបិយប័ណ្ណដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវបានបញ្ជាក់ជារូបិយប័ណ្ណ ដែលមាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និង ប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់មិនមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានទូទាត់សងប្រាក់នៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវចុះឥណពន្ធតាមចំនួនប្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

# ផ្នែកទី ៧
## ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់

### មាត្រា ១៧០.-

អ្នកកាន់ប័ណ្ណសងតាមបញ្ជា អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ អ្នកចេញប័ណ្ណ និងភាគីពាក់ព័ន្ធដទៃៗទៀត :

-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើ

-នៅមុនពេលដល់ឥណប្រតិទាន ក្នុងករណីធនក្ស័យរបស់អ្នកចេញប័ណ្ណ ឬ ក្នុងករណីអ្នកចេញប័ណ្ណបញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ទោះបីគ្មានសេចក្ដីសម្រេចពីតុលាការក្ដី ឬ នៅពេលណាដែលការអនុវត្តរឹបអូសទ្រព្យសម្បត្តិរបស់អ្នកចេញប័ណ្ណពុំបានសម្រេចក្ដី ។

### មាត្រា ១៧១.-

ការខកខានមិនបានទូទាត់សងប្រាក់ ត្រូវតែបានបង្ហាញភស្តុតាងដោយវិរុទ្ធវាទតាមច្បាប់ ។

វិរុទ្ធវាទចំពោះការមិនទូទាត់សងប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណឬក្រោយការបង្ហាញ ត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលប័ណ្ណសងតាមបញ្ជានោះត្រូវទូទាត់សងប្រាក់ ។ នៅក្នុងករណីនៃប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ វិរុទ្ធវាទត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។ វិរុទ្ធវាទចំពោះការបដិសេធមិនផ្ដល់ទិដ្ឋាការ អាចធ្វើបានដោយមិនចាំបាច់បង្ហាញឱ្យទូទាត់សងប្រាក់ ហើយត្រូវតែធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។

បើអ្នកចេញប័ណ្ណ បញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ឬ បើការអនុវត្តរឹបអូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន តែនៅក្រោយការ

បង្ហាញប័ណ្ណសងតាមបញ្ជា ឱ្យទៅអ្នកចេញប័ណ្ណធ្វើការទូទាត់សងប្រាក់ និងនៅក្រោយពេលដែលវិរុទ្ធវាទត្រូវបានធ្វើ ។

បើអ្នកចេញប័ណ្ណត្រូវបានប្រកាសថាធនក្ស័យ ការបង្ហាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្ស័យនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន ។

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ឱ្យបញ្ជាក់យថាភាពនៃឯកសារ ។ ដរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃប័ណ្ណសងតាមបញ្ជាភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់ឈ្មោះបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញអ្នកចេញប័ណ្ណ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសពីដប់ (១០) គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ។

វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់អ្នកចេញប័ណ្ណ បញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

**មាត្រា ១៧២.-**

អ្នកកាន់ត្រូវជូនដំណឹងពីការមិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងរូបិយបដិភោគីណាមួយនៃអ្នកចេញប័ណ្ណ នៅក្នុងរយៈពេលបួន (០៤) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលវិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលវិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋាន

៨១/៤៨

របស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់អ្នកចេញប័ណ្ណបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា សេចក្តីជូនដំណឹងដូចគ្នានេះក៏ត្រូវបានផ្តល់ទៅរូបិយបដិភោគី នៅក្នុងពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខមិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង អាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនប័ណ្ណសងតាមបញ្ជាត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវបានចាត់ទុកថា បានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើង ដោយការធ្វេសប្រហែសរបស់ខ្លួន បើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

**មាត្រា ១៧៣.-**

តាមរយៈបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានទិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា អ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធវាទ ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញប័ណ្ណសងតាមបញ្ជានៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងឡើយ ។ សោហ៊ុយ

84/128

ដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ត្រូវធ្លាក់ទៅលើបុគ្គលដែលបានប្ដឹងទល់នឹងអ្នកកាន់ ។

បដិញ្ញាដែលត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីត្រូវអនុវត្តបានចំពោះអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីតែប៉ុណ្ណោះ ។ ទោះបីជាមាន ឬ គ្មានបដិញ្ញាក្ដី បើអ្នកកាន់ធ្វើវិរុទ្ធវាទ សោហ៊ុយនៃការធ្វើវិរុទ្ធវាទអាចត្រូវបានទារពីបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

**មាត្រា ១៧៤.-**

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលធានា ដោយការធ្វើរូបិយបដិភោគនៃប័ណ្ណសងតាមបញ្ជា មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្ដឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងប័ណ្ណសងតាមបញ្ជាជាឯកត្តជន ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ហើយបានទទួលយកប័ណ្ណសងតាមបញ្ជារក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្ដឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្ដឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្ដឹងទីមួយនោះក៏ដោយ ។

**មាត្រា ១៧៥.-**

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្លួនអនុវត្តសិទ្ធិធ្វើឧបាស្រ័យ នូវចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជា ដែលមិនបានទូទាត់សងដោយមានការប្រាក់ បើការប្រាក់នោះមានចែងលើប័ណ្ណសងតាមបញ្ជា ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហ៊ុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវជាកម្មវត្ថុនៃការធ្វើអប្បហារ ។ អប្បហារនេះត្រូវបានគណនា

៨៣/៤៨-

ទៅតាមអត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបាស្រ័យនៅកន្លែងស្នាក់នៅរបស់អ្នកកាន់ ។

## មាត្រា ១៧៦.-

ភាគីដែលបានទទួលយកនិងទូទាត់សងប័ណ្ណសងតាមបញ្ជា អាចទាមទារមកវិញពីភាគីទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សង ការប្រាក់លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ ដោយធនាគារជាតិនៃកម្ពុជាគិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

## មាត្រា ១៧៧.-

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ ឱ្យប្រគល់មកខ្លួននូវប័ណ្ណសងតាមបញ្ជារួមជាមួយនឹងវិរុទ្ធវាទ និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយកនិងបានទូទាត់សងប័ណ្ណសងតាមបញ្ជា អាចលុបចោលបិដ្ឋិលេខរបស់ខ្លួនផ្ទាល់ និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់បានតាមក្រោយ ។

## មាត្រា ១៧៨.-

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើឧបាស្រ័យអាចទូទាត់សងខ្លួនឯង តាមមធ្យោបាយនៃការចេញរូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញទៅលើភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់សងបាននៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានាដែលចែងនៅក្នុងមាត្រា ១៧៥ និងមាត្រា ១៧៦ នៃច្បាប់នេះ រូបិយាណត្តិមានបញ្ចូលនូវកម្រៃជើងសានិងថ្លៃតែមប្រិ៍ផងដែរ ។

បើរូបិយាណត្តិត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញនៅពេលដែលប័ណ្ណសងតាមបញ្ជាដំបូងត្រូវបានទូទាត់សងនៅលំនៅរបស់ភាគីពាក់ព័ន្ធ ។ បើរូបិយាណត្តិត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវ

បានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ នៅពេលដែលអ្នកចេញរូបិយាណត្តិនោះ មានលំនៅនៅកន្លែងជាមួយភាគីដែលពាក់ព័ន្ធ ។

**មាត្រា ១៧៩.-**

អ្នកកាន់បាត់បង់សិទ្ធិធ្វើឱបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងភាគីពាក់ព័ន្ធដទៃៗទៀត លើកលែងតែអ្នកចេញប័ណ្ណក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញប័ណ្ណសងតាមបញ្ជា ដែលចេញដើម្បីឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្ដីផ្សេងណាមួយ ដែលមានន័យដូចគ្នា ។

បើបដិញ្ញាស្ដីពីរយៈពេលកំណត់ឱ្យបង្ហាញមានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខតែប៉ុណ្ណោះ ។

**មាត្រា ១៨០.-**

កាលបើការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទក្នុងរយៈពេលកំណត់ ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នឹងត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្ដល់សេចក្ដីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្ដីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១៧២ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាភ្លាម ដើម្បីឱ្យធ្វើការទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ។

បើករណីប្រធានស័ក្តិនៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលដល់ឥណប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទ មិនចាំបាច់ធ្វើឡើយ ។

ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញ ដែលមានបញ្ជាក់ច្បាស់នៅលើប័ណ្ណសងតាមបញ្ជា ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិរុទ្ធវាទ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើប័ណ្ណសងតាមបញ្ជាដែលត្រូវបានបាត់បង់ ឬ ត្រូវបំផ្លាញអាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តប័ណ្ណសងតាមបញ្ជាដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើប័ណ្ណសងតាមបញ្ជាតាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលប័ណ្ណសងតាមបញ្ជាមកដោយសុចរិត ឬ ដោយគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ៨
## ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

**មាត្រា ១៨១.-**

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវទូទាត់សងប្រាក់ ក្នុងករណីចាំបាច់ ។

៩៤/១២៤

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងប្រាក់ ដោយបុគ្គលដែលធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ជួសកូនបំណុលណាមួយដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីដែលបានពាក់ព័ន្ធលើប័ណ្ណសងតាមបញ្ជា ។

នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគីដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

**មាត្រា ១៨២.-**

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍អាចធ្វើបាន នៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះប័ណ្ណសងតាមបញ្ជានៅពេលដល់ឥណប្រតិទាន ឬនៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងប្រាក់ត្រូវរាប់បញ្ចូលនូវចំនួនប្រាក់ទាំងអស់ ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងប្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ ។

**មាត្រា ១៨៣.-**

បើបុគ្គលទាំងឡាយដែលមានលំនៅនៅកន្លែងទូទាត់សងប្រាក់ ត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ យ៉ាងយឺតបំផុតនៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ និងអ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

**មាត្រា ១៨៤.-**

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

**មាត្រា ១៨៥.-**

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាពអំពីការទទួលប្រាក់នៅលើប័ណ្ណសងតាមបញ្ជា ដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជួស ។ ក្នុងករណីគ្មានសេចក្តីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យអ្នកចេញប័ណ្ណ ។

ប័ណ្ណសងតាមបញ្ជា និងវិរុទ្ធវាទ បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

**មាត្រា ១៨៦.-**

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជួស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើប័ណ្ណសងតាមបញ្ជា ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជាបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគីដែលទទួលការទូទាត់សងប្រាក់ជួស ត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ការទូទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

# ផ្នែកទី ៩
# ច្បាប់ចម្លង

**មាត្រា ១៨៧.-**

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងប័ណ្ណសងតាមបញ្ជា ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យបានត្រឹមត្រូវតាមច្បាប់ដើមជាមួយនឹងបិដ្ឋិលេខ និងសេចក្ដីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់លាស់នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខនិងធ្វើវូបិយបដិភោគ នៅក្នុងលក្ខណៈដូចគ្នា និងមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

**មាត្រា ១៨៨.-**

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើមត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើម ដែលមានចែងខាងលើឱ្យទៅអ្នកកាន់ស្របច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើវូបិយបដិភោគច្បាប់ចម្លង លុះត្រាតែបានបញ្ជាក់នៅលើវិរុទ្ធវាទថា ច្បាប់ដើមមិនទាន់ត្រូវបានប្រគល់មកវិញតាមសំណើរបស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ដើមមានបដិញ្ញាថា **ចាប់ផ្ដើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិលេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ** ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខបន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ១០
## ការកែលើប័ណ្ណសងតាមបញ្ជា

**មាត្រា ១៨៩.-**

ក្នុងករណីមានការកែលើខ្លឹមសារនៃប័ណ្ណសងតាមបញ្ជា រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃប័ណ្ណសងតាមបញ្ជា ។

## ផ្នែកទី ១១
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

**មាត្រា ១៩០.-**

រាល់ឧបាស្រ័យដែលកើតឡើងពីប័ណ្ណសងតាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណមានរយៈពេលបី (០៣) ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រ័យដែលធ្វើឡើងដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយមានរយៈពេលមួយ (០១) ឆ្នាំ គិតពីថ្ងៃធ្វើវិរុទ្ធវាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទានកាលបើមានបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្ដីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រ័យរបស់អ្នកធ្វើបិដ្ឋិលេខទល់នឹងអ្នកធ្វើបិដ្ឋិលេខផងគ្នាមានរយៈពេលប្រាំមួយ (០៦) ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និងបានទូទាត់សងប័ណ្ណសងតាមបញ្ជា ឬ គិតពីថ្ងៃដែលបានទទួលរងការប្ដឹង ។

**មាត្រា ១៩១.-**

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ១៩០ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

90/12 8.

## ផ្នែកទី ១២
## ការគណនារយៈពេលកំណត់

**មាត្រា ១៩២.-**

បំណុលសងតាមបញ្ជាដែលដល់រយៈពេលកំណត់ទូទាត់សងប្រាក់នៅថ្ងៃឈប់សម្រាកផ្លូវការនឹងត្រូវទូទាត់សងប្រាក់នៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងបំណុលសងតាមបញ្ជា ជាពិសេសការបង្ហាញឱ្យទូទាត់សងប្រាក់ និងវិរុទ្ធ-វាទអាចត្រូវធ្វើឡើងតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

**មាត្រា ១៩៣.-**

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលជាមួយផងទេ នូវថ្ងៃដែលរយៈពេលនោះចាប់ផ្ដើម ។

**មាត្រា ១៩៤.-**

ទោះបីតាមផ្លូវច្បាប់ក្ដី ឬ តាមផ្លូវតុលាការក្ដីពុំអនុញ្ញាតឱ្យមានរយៈពេលអនុ-គ្រោះឡើយ ។

## ជំពូកទី ៥
## ប្រតិបត្តិការទូទាត់សងប្រាក់
## ផ្នែកទី ១
## កម្មវត្ថុនៃការអនុវត្ត

**មាត្រា ១៩៥.-**

ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ជារូបិយវត្ថុក្នុងស្រុក ឬ រូ-បិយប័ណ្ណណាមួយ ។ ជំពូកនេះកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកចូលរួមនិងអនុវត្ត

ចំពោះការរៀបចំប្រតិបត្តិការ ការត្រួតពិនិត្យ និងការគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៩៦.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចបើកគណនីជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ និងអាចធ្វើប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈគណនីទាំងនេះ នៅក្រោមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងទៅតាមបទប្បញ្ញត្តិទាំងឡាយក្នុងផ្នែកទី ៧ នៃជំពូកនេះ ។ រូបវន្តបុគ្គលឬនីតិបុគ្គលអាចមានគណនីមួយ ឬ ច្រើនក្នុងធនាគារមួយ ឬ ច្រើនបាន ។

កថាខណ្ឌខាងលើនៃមាត្រានេះពុំបានបដិសេធចោល និងត្រូវអនុលោមតាមកាតព្វកិច្ចណាមួយដែលតម្រូវដោយច្បាប់ទាក់ទងទៅនឹងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកក៏ដូចជាការរឹតត្បិត ឬ ការដាក់កំហិតដោយច្បាប់ដែលពាក់ពន្ធ័ទៅនឹងប្រភេទ ឬ ថ្នាក់ជាក់លាក់របស់គណនី ឬរូបិយប័ណ្ណ ។

**មាត្រា ១៩៧.-**

បញ្ជាទូទាត់អាចត្រូវផ្ញើដោយអតិថិជនណាមួយពីក្នុង ឬ ពីក្រៅព្រះរាជាណាចក្រកម្ពុជា និងទទួលដោយធនាគារណាមួយដែលមានទីតាំងនៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃជំពូកនេះ ហើយបទប្បញ្ញត្តិណាដែលពុំមានចែងទេ ត្រូវស្ថិតនៅក្រោមច្បាប់ដទៃទៀតដែលអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ។ កថាខណ្ឌនេះត្រូវអនុវត្តចំពោះការផ្ញើពីក្នុង ឬ ពីក្រៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកផ្ញើ និងធនាគារទទួល ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារដែលមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលសាខា ឬ ការិយាល័យដោយឡែកនោះបានបោះទីតាំង លើកលែងតែមាន

កិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកផ្ញើ និងធនាគារទទួល ។

សិទ្ធិនិងកាតព្វកិច្ចរវាងធនាគារនិងអតិថិជនរបស់ខ្លួន ដែលទាក់ទងនឹងគណនី និងបញ្ជាទូទាត់ចូល ឬ ចេញ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែកដែលបានរក្សាគណនីទាំងនោះ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងធនាគារនិងអតិថិជនរបស់ខ្លួន ។

បញ្ហាពេលវេលានៃការទូទាត់សងប្រាក់ធ្វើឡើងដោយអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់មួយ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុ-វត្តនៅកន្លែងជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែករបស់ធនាគារគោលដៅ ។

បញ្ជាទូទាត់អាចត្រូវបញ្ជូនទៅធនាគារជាតិនៃកម្ពុជាឱ្យអនុវត្តការសងប្រាក់ចេញពី ឬ ចូលទៅក្នុងគណនីដែលបានបើកនៅទីនោះ ។ ក្នុងករណីនេះ ជំពូកនេះនឹងត្រូវអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាក្នុងនាមជាធនាគារមួយដែរ ។

នៅពេលណាដែលធនាគារទទួលយល់ព្រមអនុវត្តបញ្ជាដែលពុំមែនជាបញ្ជាទូទាត់ ដោយហេតុថាបញ្ជានោះជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌណាមួយ បញ្ជាបែបនេះក៏ត្រូវបានចាត់ទុកថាជាបញ្ជាទូទាត់ដែរ ។ ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនត្រូវអនុវត្តចំពោះភារកិច្ច :

-របស់ធនាគារទទួលក្នុងការបញ្ជូនបន្តនូវល័ក្ខខ័ណ្ឌណាមួយទៅកាន់ធនាគារគោលដៅ និង

-របស់ធនាគារគោលដៅ ដើម្បីអនុវត្តល័ក្ខខ័ណ្ឌនោះឡើយ ។

**មាត្រា ១៩៨.-**

សិទ្ធិអំណាចរបស់អ្នកទទួលក្នុងការផ្ទេរឥណពន្ធ មានដូចខាងក្រោម :

១-នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលអាចដកហូតសិទ្ធិអំណាចដែលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការដោយធ្វើសេចក្តីជូនដំណឹងដល់ធនាគារគោលដៅអំពីការដកហូតសិទ្ធិអំណាចនោះជាលាយលក្ខណ៍អក្សរ តាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់ក៏បាន បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនឱ្យធ្វើបែបនេះ ។ សេច-ក្តីជូនដំណឹងត្រូវតែធ្វើឡើងមុនពេលដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ និងក្នុងរយៈពេលនិងតាមវិធីគ្រប់គ្រាន់ ដែលអាចឱ្យធនាគារគោលដៅមានឱកាស

សមស្របក្នុងការអនុវត្តតាម ។ ធនាគារគោលដៅត្រូវបដិសេធបញ្ជាទូទាត់ទាំងឡាយណារបស់អ្នកផ្ញើ ដែលមានសេចក្តីជូនដំណឹងឱ្យដកហូតសិទ្ធិអំណាច ។

២-នៅក្នុងការផ្ទេរឥណពន្ធ សេចក្តីជូនដំណឹងបញ្ជាក់ពីមរណភាព ឬ សេចក្តីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីត្យានុកូលនៃអ្នកទទួលដែលធនាគារគោលដៅទទួលបាន មានប្រសិទ្ធភាពដូចគ្នានឹងសេចក្តីជូនដំណឹងរបស់អ្នកទទួលអំពីការដកហូតសិទ្ធិអំណាច ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះដែរ ។

៣-អតិថិជនដែល :

-គណនីត្រូវបានកត់ត្រាឥណពន្ធតាមចំនួនប្រាក់ក្នុងបញ្ជាទូទាត់នៃការផ្ទេរឥណពន្ធ

-ឥវ៉ាពីសិទ្ធិអំណាចរបស់អ្នកផ្តើមប្រតិបត្តិការ និង

-ជំទាស់ជាលាយលក្ខណ៍អក្សរនឹងការចុះឥណពន្ធក្នុងរយៈពេលបួន (០៤) ថ្ងៃបន្ទាប់ពីបានដឹងដំណឹងអំពីការចុះឥណពន្ធនេះ នៅក្នុងគណនីរបស់ខ្លួន អាចមានសិទ្ធិចុះបញ្ច្រាសការចុះឥណពន្ធនោះវិញ លើកលែងតែធនាគារគោលដៅបានផ្តល់ភស្តុតាងអំពីសិទ្ធិអំណាចដែលផ្តល់ដោយអតិថិជនទៅកាន់អ្នកផ្តើមប្រតិបត្តិ-ការនោះ ។

៤-តាមរយៈការអនុញ្ញាតឱ្យធ្វើការផ្ទេរឥណពន្ធ អ្នកទទួលជានាការទូទាត់សងប្រាក់ទៅអ្នកផ្តើមប្រតិបត្តិការ ។

៥-មាត្រានេះមិនអនុវត្តចំពោះសិទ្ធិអំណាចដែលអ្នកទទួលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការ តាមការចេញផ្សាយមូលប្បទានប័ត្រនោះទេ ។

## ផ្នែកទី ២

## បញ្ជាទូទាត់

**មាត្រា ១៩៩.-**

បញ្ជាទូទាត់ជាបញ្ជារបស់អ្នកផ្ញើទៅធនាគារទទួល និងមិនប្រើជាការផ្ទេរមូលនិធិឱ្យអ្នកចូលរួមណាមួយ ក្នុងប្រតិបត្តិការទូទាត់សងប្រាក់ឡើយ ។

បញ្ជាទូទាត់អាចធ្វើឡើងជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ អាចធ្វើ

96/128

ឡើងដោយផ្ទាល់មាត់ បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរវាងភាគីនៃបញ្ជាទូទាត់ ។ បើមានការព្រមព្រៀងដូច្នេះពីមុន និងជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌក្នុងកិច្ចព្រមព្រៀង ទំនាក់ទំនងជាបន្តបន្ទាប់មកទៀតរួមទាំងបញ្ជាបញ្ឈប់ផង ក៏អាចត្រូវធ្វើឡើងដោយផ្ទាល់មាត់បានដែរ ។

បញ្ជាទូទាត់ត្រូវកំណត់អត្តសញ្ញាណ អ្នកទទួលនិងធនាគារគោលដៅឱ្យបានត្រឹមត្រូវ ។ នៅពេលណាដែលបញ្ជាទូទាត់កំណត់អត្តសញ្ញាណអ្នកចូលរួមណាមួយនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់តាមប្រព័ន្ធស្វ័យប្រវត្តិដោយបញ្ជាក់ឈ្មោះ និង លេខកូដ ធនាគារទទួលពុំចាំបាច់បញ្ជាក់នូវសង្គតិភាពរវាងឈ្មោះ និង លេខកូដនោះឡើយ ហើយអាចសងប្រាក់ដោយផ្អែកតែលើលេខកូដប៉ុណ្ណោះ ។ នៅពេលណាដែលនិយោជិតណាម្នាក់ជាអ្នកអនុវត្តបញ្ជាទូទាត់កត់សម្គាល់ឃើញថាឈ្មោះ និងលេខកូដពុំមានសង្គតិភាព ធនាគារទទួលត្រូវបដិសេធបញ្ជាទូទាត់នោះ ។

ធនាគារជាតិនៃកម្ពុជាអាចចេញបទបញ្ជាចែងអំពីល័ក្ខខ័ណ្ឌនានា ដែលនៅក្នុងនោះបញ្ជាទូទាត់ និងទំនាក់ទំនងផ្សេងៗទៀតរួមទាំងបញ្ជាបញ្ឈប់ផងដែរ អាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ។

**មាត្រា ២០០.-**

នៅក្នុងការផ្ទេរឥណទាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារទទួលមានកាតព្វកិច្ចអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ញើ តែក្នុងករណីដែលគណនីអ្នកផ្ញើមានសមតុល្យគ្រប់គ្រាន់ប៉ុណ្ណោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្ដើមប្រតិបត្តិការត្រូវអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ដើមប្រតិបត្តិការ បន្ទាប់ពីមានភស្តុតាងសមស្របអំពីសិទ្ធិអំណាចដែលអ្នកទទួលប្រគល់ឱ្យ និងមានការធានាសងការខូចខាតវិញពីអ្នកផ្ដើមប្រតិបត្តិការ ។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារផ្ដើមប្រតិបត្តិការពុំមានកាតព្វកិច្ចផ្ដល់មូលនិធិដល់អ្នកផ្ដើមប្រតិបត្តិការ ឬ សូម្បីធ្វើការចុះឥណទានបណ្ដោះអាសន្នក្តី នៅមុនពេលបញ្ចប់ការផ្ទេរឥណពន្ធ ។ បើគណនីរបស់អ្នកផ្ដើមប្រតិបត្តិការត្រូវបានចុះឥណទានដោយធនាគារផ្ដើមប្រតិបត្តិការ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ការចុះ

ឥណទាននោះត្រូវមានលក្ខណៈបណ្ដោះអាសន្ន ហើយគណនីអ្នកផ្ដើមប្រតិបត្តិការអាចនឹងត្រូវចុះឥណពន្ធវិញក្នុងចំនួនប្រាក់ស្មើនឹងការចុះឥណទាន បើការផ្ទេរឥណពន្ធពុំត្រូវបានបញ្ចប់ដូចដែលបានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះទេ ។

ធនាគារទទួល ត្រូវអនុវត្តតែបញ្ជាទូទាត់ណាដែល :

- បានបំពេញសេចក្ដីត្រឹមត្រូវ និងបានការអនុញ្ញាត ឬ មានយថាភាព
- បានកំណត់អត្តសញ្ញាណធនាគារគោលដៅត្រឹមត្រូវ
- បានពណ៌នាអំពីអ្នកទទួលដោយប្រាកដប្រជា ។

ធនាគារទទួលដែលមិនអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវជូនដំណឹងដល់អ្នកផ្ញើជាបន្ទាន់អំពីការបដិសេធ ឬ ការមិនទទួលរបស់ខ្លួន ។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ និងមិនគិតដល់ការយកសោហ៊ុយដូចដែលបានព្រមព្រៀង ឬ ដែលជាទម្លាប់ក្ដី ធនាគារទទួលត្រូវអនុវត្តបញ្ជាទូទាត់តាមចំនួនប្រាក់ដែលបានបញ្ជាដោយអ្នកផ្ញើ ។

ធនាគារទទួលត្រូវអនុវត្តបញ្ជាទាំងឡាយ ដែលមាននៅក្នុងបញ្ជាទូទាត់នៅថ្ងៃធ្វើការដែលធនាគារទទួលបានបញ្ជានោះ ឬ នៅថ្ងៃប្រសិទ្ធភាពរបស់បញ្ជាទូទាត់នោះ បើមាន ដែលជាទូទៅគឺនៅពេលក្រោយមកទៀត ។ ធនាគារទទួលអាចកំណត់ពេលម៉ោងកំណត់សម្រាប់អនុវត្តបញ្ជាទូទាត់ ។ រាល់បញ្ជាទូទាត់ណាដែលបានទទួលក្រោយពេលកំណត់នេះ ត្រូវបានចាត់ទុកថាបានទទួលនៅថ្ងៃធ្វើការបន្ទាប់របស់ធនាគារ ។

ធនាគារផ្ដើមប្រតិបត្តិការនៅក្នុងការផ្ទេរឥណទាន នឹងធនាគារគោលដៅ នៅក្នុងការផ្ទេរឥណពន្ធដែលបានទទួលបញ្ជាទូទាត់លើសពីមួយក្នុងអំឡុងថ្ងៃធ្វើការរបស់ធនាគារ ឬ បញ្ជាស្របច្បាប់ផ្សេងទៀត ដើម្បីដកមូលនិធិចេញពីគណនី អាចនឹងអនុ-វត្តបញ្ជាទាំងនោះតាមលំដាប់លំដោយណាក៏បាន លើកលែងតែមានការចែងផ្សេងពីនេះ នៅក្នុងច្បាប់ផ្សេងទៀត ។

ធនាគារទទួលត្រូវមានការប្រុងប្រយ័ត្នជានិច្ចក្នុងការអនុវត្តបញ្ជាទូទាត់ ។ ធនា-គារទទួលត្រូវប្រុងប្រយ័ត្នក្នុងការបកស្រាយបញ្ជាទូទាត់ដែលមិនច្បាស់លាស់ ហើយធ្វើសកម្មភាពដោយស្មោះត្រង់ និងត្រូវអនុវត្តបញ្ជាទូទាត់ទៅតាមអត្ថន័យសមស្របដោយមិនចាំបាច់ស្វែងយល់ថាការបកស្រាយនោះជាការផ្ទុយពីបំណងរបស់អ្នកផ្ញើឡើយ ។

ក្នុងការទទួលបញ្ជាទូទាត់ និងធ្វើសកម្មភាពនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ និងទោះបីជាមានកិច្ចព្រមព្រៀងផ្ទុយពីនេះក៏ដោយ ធនាគារទទួលត្រូវតែគោរពតាមច្បាប់នេះ ព្រមទាំងបទបញ្ជា ឬ សេចក្តីណែនាំទាំងឡាយដែលពាក់ព័ន្ធក៏ដូចជាច្បាប់ដទៃទៀតដែរ ។ ធនាគារត្រូវធ្វើសកម្មភាពដោយយកចិត្តទុកដាក់ និងសុចរិតស្របតាមស្តង់ដាររួមរបស់ធនាគារ និងត្រូវជួយដល់អ្នកចូលរួមនានាក្នុងការបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ដោយត្រឹមត្រូវ ។ នៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ធនាគារត្រូវរក្សាការសម្ងាត់ និងធ្វើសកម្មភាពជាប្រយោជន៍ខ្ពស់បំផុតរបស់អ្នកផ្ញើ ។

ជាកម្មវត្ថុនៃកាតព្វកិច្ចរក្សាការសម្ងាត់ នៅក្រោមច្បាប់នានាដែលកំពុងអនុវត្ត ធនាគារទទួល ដែលបានបញ្ជាឱ្យបញ្ជូនប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈធនាគារអន្តរការី ឬ ទៅកាន់ធនាគារគោលដៅដែលខ្លួនវិនិច្ឆ័យថាពុំអាចទុកចិត្តបានក្នុងកាលៈទេសៈនោះ ត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកផ្ញើអំពីការបារម្ភរបស់ខ្លួន ។ ប៉ុន្តែនៅពេលណាដែលធនាគារទទួលនៅតែបានទទួលបញ្ជាឱ្យបញ្ជូនប្រតិបត្តិការផ្ទុយពីការជូនដំណឹងរបស់ខ្លួន ធនាគារទទួលអាចបដិសេធមិនទទួលបញ្ជាទូទាត់នោះ ឬ ដោយមិនគិតដល់បទប្បញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់នេះ អាចប្រតិបត្តិបញ្ជានោះដោយអ្នកផ្ញើត្រូវទទួលរ៉ាប់រងហានិភ័យ ។

**មាត្រា ២០១.-**

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ រវាងអ្នកផ្ញើ និង ធនាគារទទួល បញ្ជាទូទាត់អាចត្រូវបដិសេធឬបញ្ឈប់បាន ។ បញ្ជាទូទាត់នឹងត្រូវបានបញ្ឈប់ដោយអ្នកផ្ញើ នៅពេលណាដែលបញ្ជាបញ្ឈប់មានការអនុញ្ញាត ឬ មានការបញ្ជាក់ត្រឹមត្រូវដោយអ្នកផ្ញើឬក្នុងនាមអ្នកផ្ញើ ត្រូវបានទទួលដោយធនាគារទទួលនៅក្នុងពេល និងតាមវិធីដែលធនាគារអាចធ្វើការបញ្ឈប់បញ្ជាទូទាត់នៅមុនពេលអនុវត្ត ។

ទោះបីជាបន្ទាប់ពីបានប្រតិបត្តិបញ្ជាទូទាត់របស់អ្នកផ្ញើរួចហើយក្តី តាមការស្នើសុំរបស់អ្នកផ្ញើ ធនាគារដែលបានទទួលនិងប្រតិបត្តិបញ្ជានេះអាចចេញបញ្ជាបញ្ឈប់ឱ្យទៅធនាគារទទួលរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។ បញ្ជា

១៧/៧. ✓

បញ្ឈប់ដែលចេញដោយអ្នកផ្ញើទៅកាន់ធនាគារគោលដៅនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់នឹងមានប្រសិទ្ធភាពតែនៅពេលណាដែលបញ្ជាបញ្ឈប់នោះបានទៅដល់ធនាគារគោលដៅ នៅមុនពេលដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ប៉ុណ្ណោះ ។

បញ្ជាបញ្ឈប់ត្រូវតែកត់សម្គាល់បញ្ជាទូទាត់ ដែលត្រូវបញ្ឈប់នោះឱ្យបានច្បាស់លាស់ និងត្រូវបានបញ្ជូនទៅធនាគារទទួលជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីមុនរវាងភាគីនៃបញ្ជាទូទាត់ ។

បញ្ជាទូទាត់ដែលពុំទាន់បានអនុវត្តដោយធនាគារទទួលត្រូវបានដកមកវិញនៅក្នុងករណីដូចតទៅ :

-នៅពេលបញ្ចប់ថ្ងៃធ្វើការទីប្រាំរបស់ធនាគារទទួល ឬ ក្នុងរយៈពេលខ្លីជាងនេះតាមការព្រមព្រៀងគ្នា បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ឬ នៅថ្ងៃប្រសិទ្ធភាពនៃបញ្ជាទូទាត់ ដែលជាទូទៅនៅពេលក្រោយមកទៀត

-នៅពេលណាដែលធនាគារទទួលបានដឹងអំពីមរណភាព ឬ សេចក្ដីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីត្យានុកូលនៃអ្នកផ្ញើ ឬ

-នៅពេលណាដែលធនាគារទទួលត្រូវបានបិទដោយអាជ្ញាធរត្រួតពិនិត្យ ។

ការបញ្ឈប់ឬការដកមកវិញនូវបញ្ជាទូទាត់នឹងមិនមានប្រសិទ្ធភាពទេ បន្ទាប់ពីប្រតិបត្តិការទូទាត់សងប្រាក់នោះ ត្រូវបានបញ្ចប់ជាស្ថាពរ ។

**មាត្រា ២០២.-**

ការទូទាត់បញ្ជាទូទាត់អន្តរធនាគារ និងពេលវេលាសម្រាប់ការទូទាត់ត្រូវបានកំណត់ដូចតទៅ :

១-ការទូទាត់ចំពោះបញ្ជាទូទាត់អន្តរធនាគារ អាចធ្វើឡើង :

ក-នៅលើគណនីទូទាត់របស់បណ្ដាធនាគារនៅធនាគារជាតិនៃកម្ពុជា ដែលនៅក្នុងករណីនេះ ត្រូវស្ថិតក្រោមបទបញ្ជាទាក់ទងនឹងសភាផាត់ទាត់ដែល

៩៩/១២៥

ចេញដោយធនាគារជាតិនៃកម្ពុជា

ខ-តាមរយៈការកត់ត្រាឥណពន្ធ ឬ ឥណទានទៅក្នុងគណនីផ្សេង ពីគណនីទូទាត់ ដែលធនាគារមួយមាននៅធនាគារមួយទៀត ឬ នៅធនាគារទីបី ។ ការចុះឥណពន្ធ ឬ ឥណទានបែបនេះអាចធ្វើឡើងសម្រាប់បញ្ជាទូទាត់នីមួយៗដោយឡែកពីគ្នា ឬ សម្រាប់បញ្ជាទូទាត់ជាសំណុំ ដែលក្នុងករណីណាក៏ដោយ ក៏ត្រូវធ្វើឡើងនៅចុងគ្រានៃការផាត់ទាត់ដែរ

គ-តាមមធ្យោបាយផ្សេងទៀត ដែលអាចសម្រេចកាតព្វកិច្ចបាន ។

២-ពេលវេលាសម្រាប់ការទូទាត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះមានដូចតទៅ :

ក-នៅក្រោមកថាខណ្ឌទី ១-ក នៅពេលណាដែលការទូទាត់ត្រូវបានបញ្ចប់ក្រោមបទបញ្ញាទាក់ទងនឹងសភាផាត់ទាត់ដែលចេញដោយធនាគារជាតិនៃកម្ពុជា

ខ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណពន្ធគណនីមួយ នៅពេលណាដែលខ្ទង់ឥណពន្ធត្រូវបានកត់ត្រាទៅក្នុងគណនី

គ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណទានគណនីមួយ នៅពេលណាខ្ទង់ឥណទានដែលបានកត់ត្រាក្នុងគណនីត្រូវបានប្រើប្រាស់ ឬ បើមិនបានប្រើប្រាស់ គឺនៅពេលចាប់ផ្តើមថ្ងៃធ្វើការបន្ទាប់ដែលមានខ្ទង់ឥណទានសម្រាប់ប្រើប្រាស់ ហើយធនាគារ បានដឹងអំពីការចុះឥណទានក្នុងគណនីរបស់ខ្លួន

ឃ-នៅក្នុងកថាខណ្ឌទី ១-គ អនុលោមតាមច្បាប់ដែលបានកំណត់អំពីពេលសម្រេចកាតព្វកិច្ច ។

៣-កថាខណ្ឌនេះត្រូវអនុវត្តកាលបើការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ នៃមាត្រានេះកើតមានឡើងដោយអនុលោមតាមកិច្ចព្រមព្រៀង ឬ វិធានដែលអនុវត្តចំពោះការបញ្ចប់ការទូទាត់អន្តរធនាគារក្រៅធនាគារជាតិនៃកម្ពុជា និង សម្រាប់បញ្ជាទូទាត់សងប្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគី ។ ទោះបីជាមានកថាខណ្ឌទី ២-ខ នៃមាត្រានេះក៏ដោយ ការទូទាត់បែបនេះកើតមានឡើងនៅពេលដែលការទូទាត់សងនេះ ត្រូវបានបញ្ចប់តាមកិច្ចព្រមព្រៀង ឬ វិធាន ។

៤-បទបញ្ញាដែលចេញដោយធនាគារជាតិនៃកម្ពុជាអាចរឹតត្បិត ឬ គ្រប់គ្រងលើកាលៈទេសៈ ដែលក្នុងនេះការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ ឬ គ នៃមាត្រានេះអាចកើតមានឡើង ក៏ដូចជាអាចកែប្រែពេលវេលាសម្រាប់ការទូទាត់ ។

៥-ដោយមិនគិតដល់អ្វីដែលមានចែងនៅក្នុងច្បាប់ណាមួយ ដែលទោះជាទាក់ទងឬមិនទាក់ទងដល់បណ្តឹងអំពីអសាធនភាពទល់នឹងធនាគារ មិនត្រូវ :

-មានឥទ្ធិពលប្រតិសកម្មលើសិទ្ធិ និងកាតព្វកិច្ចដែលកើតឡើងពី ឬ ដែលពាក់ព័ន្ធជាមួយការជាត់ទាត់ និងការទូទាត់បញ្ញាទូទាត់ឡើយ ក្រៅពីនៅពេលវេលាដែលបណ្តឹងអំពីអសាធនភាពនោះ ត្រូវបានធ្វើ ឬ

-មានផលប៉ះពាល់ទៅលើប្រសិទ្ធភាព និងការអនុវត្តបាននៃបញ្ញាទូទាត់ដែលទទួលបានដោយធនាគារទទួល នៅមុនពេលមានបណ្តឹងអំពីអសាធនភាពនេះ និងមុនពេលការទូទាត់សងប្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគីព្រមទាំងមុនពេលមានការផ្តល់ការធានាណាមួយ ។

៦-ដើម្បីគោលបំណងនៃកថាខណ្ឌទី ៥ នៃមាត្រានេះ និងកថាខណ្ឌទី ២ នៃមាត្រាទី ២២៧ នៃច្បាប់នេះ **បណ្តឹងអំពីអសាធនភាព** គឺជាវិធានការរួមដែលកំណត់ដោយច្បាប់ដើម្បីជំរះបញ្ជី បញ្ចប់សកម្មភាព ឬ ដើម្បីរៀបចំធនាគារឡើងវិញ ទោះដោយស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្តក្តី ហើយពេលវេលានៃការបើកបណ្តឹងអំពីអសាធនភាព ជាពេលវេលាដែលអាជ្ញាធរតុលាការ ឬ រដ្ឋបាលពាក់ព័ន្ធប្រកាសអំពីសេចក្តីសម្រេចរបស់ខ្លួន ។

## ផ្នែកទី ៣
## អ្នកដំណើរការតតិយភាគី

**មាត្រា ២០៣.-**

ក្នុងការអនុវត្តផ្នែកណាមួយនៃប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារអាចប្រើប្រាស់អ្នកដំណើរការតតិយភាគី ។ ដូចដែលបានអនុញ្ញាតដោយធនាគារ អ្នកដំណើរការតតិយភាគីអាចធ្វើការក្នុងនាមធនាគារដែលបានផ្តល់សិទ្ធិជា :

190/128

-អ្នកទំនាក់ទំនង

-អ្នកផាត់ទាត់អន្តរធនាគារ ដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅកាន់ធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

-ភ្នាក់ងារគ្រប់គ្រងនិងប្រតិបត្តិការ សម្រាប់ធនាគារដែលមានគណនីអតិថិជន និង/ឬ

-កន្លែងផ្ញើនិងទទួលបញ្ជាទូទាត់ដែលត្រូវបានផ្ញើឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការផ្ញើ និងទទួលបញ្ជាទូទាត់ ។

**មាត្រា ២០៤.-**

អ្នកដំណើរការតតិយភាគីត្រូវគោរពតាមរាល់កាតព្វកិច្ច ល័ក្ខខ័ណ្ឌ និងការរឹតត្បិតទាំងឡាយដែលកំណត់ដោយបទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ។ បទបញ្ជាទាំងនោះអាចចែងអំពីការផ្តល់អាជ្ញាប័ណ្ណ បញ្ញត្តិកម្ម ការត្រួតពិនិត្យ និងអាចអនុវត្តចំពោះអ្នកដំណើរការតតិយភាគីគ្រប់ប្រភេទទាំងអស់ ។ ប្រភេទផ្សេងគ្នានៃអ្នកដំណើរការតតិយភាគី តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា អាចស្ថិតក្រោមកាតព្វកិច្ចខុសៗគ្នា ។

ធនាគារមួយអាចធ្វើជាអ្នកដំណើរការតតិយភាគីក្នុងនាមធនាគារមួយទៀត ។

**មាត្រា ២០៥.-**

ក្រៅពីការទទួលខុសត្រូវរវាងធនាគារនិងអ្នកដំណើរការតតិយភាគី ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកដំណើរការតតិយភាគីធ្វើសកម្មភាពជួសមុខឱ្យ ត្រូវទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬ កំហុសរបស់អ្នកដំណើរការតតិយភាគីនោះ ។

ដើម្បីធានាការគោរពតាមច្បាប់នេះនិងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀត ធនាគារត្រូវធានាថា អ្នកដំណើរការតតិយភាគីត្រូវធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួន ចំពោះហេតុការណ៍ទាំងឡាយដែលបុគ្គលនេះបានធ្វើសកម្មភាពជួសមុខឱ្យ ហើយធនាគារមិនអាចបដិសេធការគ្រប់គ្រង និងការ

១០/២៥ .

ត្រួតពិនិត្យនេះទេ ។

**មាត្រា ២០៦.-**

អ្នកដំណើរការតតិយភាគីត្រូវបដិសេធបញ្ជាទូទាត់ដែលអតិថិជនរបស់ធនាគារផ្ញើមកខ្លួនដោយផ្ទាល់ លើកលែងតែ :

ក-បញ្ជាទូទាត់នោះត្រូវបានផ្ញើមក ដោយការប្រគល់សិទ្ធិរបស់ធនាគារ

ខ-នៅក្នុងករណីនៃការផ្ទេរឥណទាន

-អ្នកដំណើរការតតិយភាគីធ្វើសកម្មភាពក្នុងនាមធនាគារ ជាភ្នាក់ងារគ្រប់គ្រង ឬ ប្រតិបត្តិការលើគណនីអតិថិជន ហើយគណនីអតិថិជននោះមានសមតុល្យគ្រប់គ្រាន់

-អ្នកដំណើរការតតិយភាគី បានទទួលការអនុញ្ញាតពីធនាគារ ។

បញ្ជាទូទាត់របស់អតិថិជនដែលអនុវត្តដោយអ្នកដំណើរការតតិយភាគី ត្រូវបានចាត់ទុកថា ជាបញ្ជាពីអតិថិជនទៅកាន់ធនាគាររបស់ខ្លួន អនុវត្តតាមបញ្ជាទូទាត់នេះធនាគារធ្វើបញ្ជាទូទាត់ផ្ញើទៅអ្នកដំណើរការតតិយភាគី ដើម្បីបញ្ជូនបន្តទៅកាន់ធនា-គារទទួល ។

នៅពេលណាដែលធនាគារមួយផ្តល់សិទ្ធិដល់អ្នកដំណើរការតតិយភាគីឱ្យធ្វើជាកន្លែងទទួលបញ្ជាទូទាត់ទាំងឡាយដែលផ្ញើមកធនាគារ បញ្ជាទូទាត់ដែលបានទទួលដោយអ្នកដំណើរការតតិយភាគី ត្រូវបានចាត់ទុកថាបានទទួលដោយធនាគារទទួល ។

## ផ្នែកទី ៤

## ការបញ្ចប់ការផ្ទេរឥណទាននិងការសងបំណុល

**មាត្រា ២០៧.-**

ការផ្ទេរឥណទានត្រូវបានបញ្ចប់ក្នុងករណីដូចខាងក្រោម :

១-ការផ្ទេរឥណទាននឹងត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅបានទទួលប្រាក់ ។ ចំពោះការផ្ទេរផ្ទៃក្នុង ធនាគារបានទទួលការសងប្រាក់នៅពេលណាដែលខ្លួនបានកត់ត្រាឥណពន្ធក្នុងគណនីរបស់អ្នកផ្តើមប្រតិបត្តិការនូវចំនួនប្រាក់

102/128

នៃបញ្ជាទូទាត់ ។ ចំពោះការផ្ទេរឥណទានអន្តរធនាគារ ធនាគារគោលដៅបានទទួលប្រាក់នៅពេលណាដែលការទូទាត់អន្តរធនាគាររួមទាំងបញ្ជាទូទាត់របស់ធនាគារផ្ញើផងនោះ ត្រូវបានបញ្ចប់ ។

២-ការផ្ទេរឥណទានត្រូវបានបញ្ចប់ នៅពេលចាប់ផ្តើមថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃដែលធនាគារគោលដៅបានទទួលបញ្ជាទូទាត់ ឬ បន្ទាប់ពីថ្ងៃប្រសិទ្ធភាពដែលជាថ្ងៃក្រោយមកទៀត បើនៅពេលនោះ អ្នកផ្ញើមានចំនួនប្រាក់គ្រប់គ្រាន់សម្រាប់ចុះឥណទាននៅធនាគារគោលដៅ និងលើកលែងតែធនាគារគោលដៅបដិសេធបញ្ជាទូទាត់មិនយឺតជាងមួយម៉ោងក្រោយមក ។

៣-នៅពេលណាដែលអ្នកទទួលពុំមានគណនីជាមួយនិងធនាគារគោលដៅពីមុនមកទេ ឬ នៅពេលណាដែលគណនីនោះ ត្រូវបិទ ឬ រាំងខ្ទប់ចំពោះការសងប្រាក់ចូល ការផ្ទេរឥណទានត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅសងប្រាក់ឱ្យទៅអ្នកទទួល ។

**មាត្រា ២០៨.-**

នៅពេលបញ្ចប់ការផ្ទេរឥណទាន ធនាគារគោលដៅនឹងក្លាយទៅជាអ្នកជំពាក់បំណុលចំពោះអ្នកទទួលតាម ចំនួនប្រាក់នៃបញ្ជាទូទាត់ដែលខ្លួនបានទទួល ហើយក្រោយពីការដកចេញកម្រៃសេវាសមស្រប ធនាគារនោះត្រូវសងប្រាក់ឱ្យទៅអ្នកទទួលភ្លាម ។

ការសងប្រាក់ឱ្យទៅអ្នកទទួលដោយធនាគារគោលដៅ ត្រូវធ្វើឡើងតាមរយៈការចុះឥណទានគណនីអ្នកទទួលមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីការផ្ទេរឥណទានត្រូវបានបញ្ចប់ ។ នៅពេលណាដែលពុំមានគណនីរបស់អ្នកទទួលប្រាក់ ឬ ពុំអាចសម្គាល់គណនីឱ្យបានច្បាស់លាស់គ្រប់គ្រាន់ទេ ឬ នៅពេលណាដែលមានការបញ្ជាបែបនេះ ធនាគារគោលដៅត្រូវផ្តល់ដំណឹងភ្លាមដល់អ្នកទទួលអំពីការដែលខ្លួនមានមូលនិធិនៅក្នុងដៃ និងត្រូវសងឱ្យទៅអ្នកទទួល ។

នៅពេលណាដែលអ្នកទទួល ឬ គណនីអ្នកទទួលពុំត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ដែលធនាគារគោលដៅបានទទួល ជាហេតុនាំឱ្យមានការសង្ស័យ

អំពីអត្តសញ្ញាណអ្នកទទួល ធនាគារគោលដៅមិនត្រូវទទួលបញ្ជាទូទាត់នោះឡើយ ហើយត្រូវផ្តល់ដំណឹងដល់អ្នកផ្ញើពីការមិនទទួលនេះ ។

នៅពេលណាដែលធនាគារគោលដៅបានសងប្រាក់ឱ្យទៅអ្នកទទួល ឬ បានសន្យាថាសងប្រាក់ឱ្យទៅអ្នកទទួលជាមុន ការសងប្រាក់ ឬ ការសន្យានេះត្រូវមានលក្ខណៈស្ថាពរនិងមិនអាចកែប្រែបាន ហើយការផ្ទេរឥណទានត្រូវចាត់ទុកថាបានបញ្ចប់ ប៉ុន្តែអ្នកផ្ញើអាចនៅជំពាក់ធនាគារទទួលរបស់ខ្លួន ។ ការសន្យាសងប្រាក់របស់ធនាគារគោលដៅអាចត្រូវធ្វើដោយផ្ទាល់ជាមួយអ្នកទទួល ឬ តាមកិច្ចព្រមព្រៀងអន្តរធនាគារ ។

មាត្រា ២០៩.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានធ្វើឡើងដើម្បីសងបំណុល ដែលអ្នកផ្តើមប្រតិបត្តិការបានជំពាក់អ្នកទទួល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ ។ ការទូទាត់សងមានកម្រិតត្រឹមចំនួនប្រាក់ដែលបានសងនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់តែប៉ុណ្ណោះ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ បន្ទាប់ពីអ្នកទទួលយល់ព្រមធ្វើការធានាលើការទូទាត់សងប្រាក់ ឬ ការធានាលើការទូទាត់សងប្រាក់នោះ ត្រូវបានបញ្ជាក់ដោយធនាគារគោលដៅទៅអ្នកទទួល លើកលែងតែក្នុងកាលៈទេសៈដូចមានចែងក្នុងកថាខណ្ឌទី ៣ មាត្រា ២០៧ នៃច្បាប់នេះ ។

អ្នកធានាឬធនាគារគោលដៅដែលបានធានាឬបញ្ជាក់អំពីការទូទាត់សងប្រាក់ក្រោមកថាខណ្ឌខាងលើត្រូវទទួលរ៉ាប់រងទូទាត់សងប្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកទទួលនូវចំនួនប្រាក់ដែលបានធានាឬបញ្ជាក់នោះ ។

## ផ្នែកទី ៥
## ការបញ្ចប់ការផ្ទេរឥណពន្ធនិងការសងបំណុល

មាត្រា ២១០.-

ការផ្ទេរឥណពន្ធត្រូវបានបញ្ចប់ក្នុងករណីដូចខាងក្រោម :

១-ការផ្ទេរឥណពន្ធនឹងត្រូវបានបញ្ចប់ នៅពេលណាដែលធនាគារគោលដៅកត់ត្រាឥណពន្ធគណនីរបស់អ្នកទទួល ដូចដែលបានបញ្ជានៅក្នុងបញ្ជាទូទាត់ដែលខ្លួនបានទទួលហើយពុំបានចុះបញ្ច្រាសឥណពន្ធ និងពុំបានបដិសេធបញ្ជាទូទាត់រហូតដល់ចុងថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។ នៅពេលណាដែលបញ្ជាទូទាត់បញ្ជាទៅធនាគារគោលដៅ ឱ្យចុះឥណពន្ធលើគណនីណាមួយដែលបើកនៅធនាគារនោះ ការផ្ទេរឥណពន្ធនឹងត្រូវបញ្ចប់នៅពេលចប់ថ្ងៃធ្វើការរបស់ធនាគារបន្ទាប់ពីបានទទួលបញ្ជាទូទាត់ ទោះបីជាមុនការកត់ត្រាឥណពន្ធលើគណនីអ្នកទទួលក៏ដោយ និងបើរហូតមកទល់ពេលនោះពុំមានការបដិសេធសមស្របចំពោះបញ្ជាទូទាត់នោះទេ ។

២-រហូតដល់ពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ធនាគារគោលដៅអាចបដិសេធបញ្ជាទូទាត់នោះបាន ។ ធនាគារគោលដៅមានសិទ្ធិដែលទទួលបានពីអ្នកផ្ញើរបស់ខ្លួន ដើម្បីទូទាត់ចំនួនប្រាក់ឱ្យទៅអ្នកផ្ញើនោះវិញដោយជូនដំណឹងអំពីការបដិសេធរបស់ខ្លួនដល់អ្នកផ្ញើ និងធនាគារផ្តើមប្រតិបត្តិ-ការ បើអ្នកទាំងពីរនេះជាធនាគារពីរផ្សេងគ្នា ។ ការបដិសេធ និង ការទទួលសិទ្ធិពីអ្នកផ្ញើមានលក្ខណៈស្វ័យប្រវត្តិតាមច្បាប់ នៅពេលណាដែលធនាគារទទួលត្រូវបានបិទទ្វារដោយអាជ្ញាធរត្រួតពិនិត្យមុនពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។

៣-នៅពេលបានទទួលសេចក្តីជូនដំណឹងពីការបដិសេធ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្តើមប្រតិបត្តិការត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួន និងមានសិទ្ធិដូចគ្នានេះ ក្នុងការទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើនោះ ។ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្តើមប្រតិបត្តិការ ត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួនអំពីការបដិសេធនោះមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីការបដិសេធ ។

៤-នៅពេលបានទទួលដំណឹងពីការបដិសេធ ធនាគារផ្តើមប្រតិបត្តិការត្រូវផ្តល់ដំណឹងភ្លាមដល់អ្នកផ្តើមប្រតិបត្តិការអំពីការបដិសេធនោះ ដោយមិនឱ្យហួសពីមួយថ្ងៃធ្វើការបន្ទាប់របស់ធនាគារ និងអាចចុះបញ្ច្រាសឥណទានដែលបានកត់ត្រា

ជាបណ្តោះអាសន្ននៅគ្រាមុនទៅក្នុងគណនីអ្នកផ្តើមប្រតិបត្តិការ ឬ ម៉្យាងទៀតអាច ប្រមូលពីអ្នកផ្តើមប្រតិបត្តិការមកវិញនូវការទូទាត់សងប្រាក់ដែលបានផ្ញើនៅពេល មុន ចំពោះបញ្ជាទូទាត់នោះ ។

៥-ថ្វីបើមានកថាខណ្ឌទី២នៃមាត្រានេះក្តី ធនាគារគោលដៅត្រូវទទួល ខុសត្រូវចំពោះមុខអ្នកទទួល ក្នុងការមិនទូទាត់សងប្រាក់ដោយខុសឆ្គង នៅពេលណា ដែលខ្លួនបានបដិសេធបញ្ជាទូទាត់នោះ ដោយមិនត្រឹមត្រូវតាមច្បាប់ ឬ ដោយគ្មាន មូលហេតុស្របច្បាប់ :

-ទោះបីជាមានការយល់ដឹងអំពីសិទ្ធិរបស់អ្នកទទួលចំពោះការ ផ្ទេរឥណពន្ធក្តី

-ទោះបីជាមានអត្តសញ្ញាណច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ទទួល ដោយធនាគារ ដែលមានគណនីអ្នកទទួលហើយក្តី និង

-ទោះបីមានសមតុល្យគ្រប់គ្រាន់ក្នុងគណនីក្តី ។

៦-រយៈពេលដែលបានកំណត់តាមមាត្រា ២១០ និងមាត្រា ២១១ នៃ ច្បាប់នេះអាចត្រូវបានបង្រួញដោយកិច្ចព្រមព្រៀង ឬ បទបញ្ជា ។

**មាត្រា ២១១.-**

នៅពេលបញ្ចប់ការផ្ទេរឥណពន្ធ ធនាគារគោលដៅ និង ធនាគារទទួលនីមួយៗ ដែលបានទទួលការសងប្រាក់ពីធនាគារទទួលរបស់ខ្លួន ត្រូវទទួលខុសត្រូវចំពោះអ្នក ផ្ញើរបស់ខ្លួននូវចំនួនប្រាក់ដែលខ្លួនបានទទួលនោះ ។ ការសងប្រាក់ដោយធនាគារ គោលដៅឱ្យទៅអ្នកផ្ញើរបស់ខ្លួនត្រូវមានចំនួនស្មើនឹងខ្ទង់ឥណពន្ធដែលបានចុះនៅលើ គណនីអ្នកទទួល និងត្រូវធ្វើឡើងមិនហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានបញ្ចប់ ការផ្ទេរឥណពន្ធនោះ ។ ការសងប្រាក់ដោយធនាគារទទួលដទៃទៀតត្រូវធ្វើឡើងមិន ហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលការទូទាត់សងរបស់ខ្លួន ។

នៅពេលបានទទួលប្រាក់រួច និងជាកម្មវត្ថុនៃការចុះបញ្ជោសនៅក្នុងកថាខណ្ឌ ទី ៣ មាត្រា ១៩៨ នៃច្បាប់នេះ ធនាគារផ្តើមប្រតិបត្តិការត្រូវជំពាក់អ្នកផ្តើមប្រតិ- បត្តិការនូវចំនួនប្រាក់ដែលខ្លួនបានទទួល ។ ក្នុងករណីនេះ ខ្ទង់ឥណទានបណ្តោះអា-

105/125

សន្ទទាំងឡាយ ដែលបានផ្តល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការត្រូវចូលជាស្ថាពរ ។ មុនពេលដែលឥណទានចូលជាស្ថាពរ ពុំត្រូវមានការទាមទារឱ្យធនាគារផ្តើមប្រតិបត្តិការផ្តល់មូលនិធិឱ្យទៅអ្នកផ្តើមប្រតិបត្តិការទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការផ្តល់មូលនិធិណាមួយ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ត្រូវមានលក្ខណៈបណ្តោះអាសន្នរហូតដល់ពេលបញ្ចប់តែម្តង ។

**មាត្រា ២១២.-**

នៅពេលណាដែលការផ្ទេរឥណពន្ធតាមការប្រគល់សិទ្ធិត្រូវបានធ្វើឡើង ដើម្បីសងបំណុលដែលអ្នកទទួលបានជំពាក់អ្នកផ្តើមប្រតិបត្តិការ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ ។ ការរួចផុតពីបំណុលមានកម្រិតត្រឹមចំនួនប្រាក់ដែលបានទូទាត់សងនៅពេលបញ្ចប់ប្រតិបត្តិការ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ ប្រសិនបើ និងនៅពេលណាដែលការធានាលើការទូទាត់សងប្រាក់ត្រូវបានយល់ព្រមដោយអ្នកផ្តើមប្រតិបត្តិការ ឬ ត្រូវបានបញ្ជាក់ដោយធនាគារផ្តើមប្រតិបត្តិការទៅអ្នកផ្តើមប្រតិបត្តិការ ។

អ្នកធានា ឬ ធនាគារផ្តើមប្រតិបត្តិការដែលបានធានាឬបញ្ជាក់អំពីការទូទាត់សងប្រាក់ក្រោមកថាខណ្ឌខាងលើ ត្រូវទទួលរ៉ាប់រងទូទាត់សងប្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកផ្តើមប្រតិបត្តិការនូវចំនួនប្រាក់ដែលបានធានា ឬ បញ្ជាក់នោះ ។

## ផ្នែកទី ៦
## ការទទួលខុសត្រូវ ការខូចខាត និងសំណង

**មាត្រា ២១៣.-**

ការទទួលខុសត្រូវរបស់អ្នកផ្ញើ ត្រូវបានកំណត់ដូចខាងក្រោម :

១-បុគ្គលជាអ្នកផ្ញើត្រូវទទួលខុសត្រូវលើបញ្ជាសងប្រាក់ ឬ លើបញ្ជាបញ្ឈប់ដែលយល់ព្រមដោយធនាគារទទួល នៅពេលណាដែលបញ្ជាសងប្រាក់ ឬបញ្ជា

១០៣/១២៥

បញ្ឈប់នោះត្រូវបាន ៖

ក-ចេញដោយបុគ្គលនោះឱ្យទៅធនាគារទទួល

ខ-ចេញដោយអ្នកទទួលសិទ្ធិពីបុគ្គលនោះ ឱ្យទៅធនាគារទទួល

គ-យល់ព្រមដោយធនាគារទទួល អនុលោមតាមនីតិវិធីសុវត្ថិភាពសមស្របដែលមានលក្ខណៈពាណិជ្ជកម្ម ដែលបានព្រមព្រៀងរវាងធនាគារនិងបុគ្គលនោះ ដើម្បីពិនិត្យបញ្ជាក់ពីយថាភាពនៃបញ្ជាទូទាត់ដែលបញ្ជាដោយបុគ្គលនោះទៅកាន់ធនាគារ ឬ

ឃ-បញ្ជាក់យល់ព្រមដោយបុគ្គលនោះ ។

២-កថាខណ្ឌទី ១-គ នៃមាត្រានេះពុំត្រូវបានអនុវត្តទេ ហើយបុគ្គលជាអ្នកផ្ញើបញ្ជាទូទាត់ក៏ពុំត្រូវទទួលខុសត្រូវដែរ នៅពេលណាដែលបុគ្គលនោះបង្ហាញភស្តុតាងថាខ្លួនមិនបានទទួលផលប្រយោជន៍ពីបញ្ជាសងប្រាក់ ឬ ពីបញ្ជាបញ្ឈប់ ហើយការចេញបញ្ជាសងប្រាក់ឬបញ្ជាបញ្ឈប់ដោយគ្មានការអនុញ្ញាតនោះ ពុំត្រូវបានបង្កឡើងដោយ ៖

-បុគ្គលជាអ្នកផ្ញើ ឬ ជនដទៃទៀតជាអ្នកទទួលសេចក្តីទុកចិត្តគ្រប់ពេលវេលាឱ្យធ្វើការងារសម្រាប់បុគ្គលនេះ ពាក់ព័ន្ធទៅនឹងប្រតិបត្តិការទូទាត់សងប្រាក់ ឬ នីតិវិធីសុវត្ថិភាព ឬ

-ជនណាដែលបានទទួលពីបុគ្គលជាអ្នកផ្ញើ ឬ ពីប្រភពនៅក្រោមការគ្រប់គ្រងរបស់បុគ្គលនេះនូវលទ្ធភាពប្រើប្រាស់មធ្យោបាយបញ្ជូនសារ ឬព័ត៌មានព្រមទាំងមធ្យោបាយប្រើប្រាស់កម្មវិធី សូហ្វវែរ កុំព្យូទ័រ ឬ មធ្យោបាយដូចគ្នានេះ ដែលងាយស្រួលក្នុងការល្មើសនឹងនីតិវិធីសុវត្ថិភាព ។

៣-សម្រាប់គោលបំណងនៃកថាខណ្ឌទី ១-គ នៃមាត្រានេះ នីតិវិធីសុវត្ថិភាពនឹងត្រូវបានចាត់ទុកថាសមស្របតាមលក្ខណៈពាណិជ្ជកម្ម បើនីតិវិធីនេះត្រូវបានជ្រើសរើសដោយអតិថិជនផ្ទុយពីការណែនាំរបស់ធនាគារដែលបានស្នើឡើងនូវនីតិវិធីសមស្រប ហើយត្រូវបានអតិថិជនបដិសេធ ។

108/128

មាត្រា ២១៤.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ អ្នកផ្ញើមិនត្រូវធ្វើឱ្យមានការខូចប្រយោជន៍ដល់ធនាគារទទួលទេ និងត្រូវសងទៅធនាគារនោះវិញចំពោះការខាតបង់ផ្សេងៗ រហូតដល់ចំនួនប្រាក់នៃបញ្ជាទូទាត់ចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយព្រមទាំងការប្រាក់ ។

នៅក្នុងការផ្ទេរឥណទាន ទោះបីជាធនាគារទទួលបានអនុវត្ត និងមានការបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់រួចហើយក្តី អ្នកផ្ញើពុំមានការទទួលខុសត្រូវឡើយ ចំពោះធនាគារទទួលលើបញ្ជាទូទាត់ដែលត្រូវបានបញ្ជូនទៅកាន់ធនាគារទទួល ដោយអនុលោមតាមនីតិវិធីសុវត្ថិភាពសម្រាប់រាវរកនូវការខុសឆ្គង ហើយផ្អែកលើកម្រិតអនុញ្ញាតដោយច្បាប់វឌ្ឍប្បវេណី ធនាគារទទួលត្រូវមានសិទ្ធិទារពីអ្នកទទួលមកវិញនូវចំនួនប្រាក់ដែលអ្នកផ្ញើសងដោយភ័ន្តច្រឡំ ក្នុងករណី :

-អ្នកផ្ញើគ្មានបំណងផ្ញើបញ្ជាទូទាត់ អ្នកផ្ញើមានបំណងបញ្ជាឱ្យសងប្រាក់ទៅអ្នកទទួលផ្សេងក្រៅពីអ្នកដែលមាននៅក្នុងបញ្ជាទូទាត់ ឬ បញ្ជាទូទាត់មានចំនួនប្រាក់ធំជាងចំនួនដែលអ្នកផ្ញើមានបំណងសង និង

-អ្នកផ្ញើបង្ហាញភស្តុតាងថាខ្លួនបានគោរពតាមនីតិវិធីសុវត្ថិភាព ហើយការភ័ន្តច្រឡំអាចនឹងត្រូវបានរាវរកឃើញ បើធនាគារទទួលបានគោរពតាមនីតិវិធីសុវត្ថិភាពផងដែរ ។

នៅក្នុងការផ្ទេរឥណពន្ធ អ្នកផ្ញើនីមួយៗធានាចំពោះធនាគារទទួលថាបញ្ជាទូទាត់របស់ខ្លួនមានការអនុញ្ញាតត្រឹមត្រូវ និងស្របតាមការប្រគល់សិទ្ធិដែលមានប្រសិទ្ធភាព និងសុពលភាពរបស់អ្នកផ្តើមប្រតិបត្តិការនិងអ្នកទទួល ។

អ្នកផ្ញើបញ្ជាទូទាត់ និង អ្នកទទួលដែលអនុញ្ញាតឱ្យអ្នកផ្តើមប្រតិបត្តិការធ្វើការផ្ទេរឥណពន្ធរួមទាំងការចេញផ្សាយមូលប្បទានប័ត្រ ត្រូវមានការប្រុងប្រយ័ត្នជានិច្ច ដើម្បីទប់ស្កាត់ការក្លែងបន្លំ និងការចេញផ្សាយ ឬ ការកែប្រែបញ្ជាទូទាត់ ដោយគ្មានការអនុញ្ញាតឬដោយគ្មានសិទ្ធិចេញផ្សាយ និងដើម្បីធានាថាបញ្ជាទូទាត់នោះមានលក្ខណៈច្បាស់លាស់និងមានអត្ថន័យប្រាកដប្រជា ។

## មាត្រា ២១៥.-

នៅពេលណាដែលការផ្ទេរឥណទានមិនត្រូវបានបញ្ចប់ទេ ដោយមិនគិតដល់កំហុសដែលបណ្តាលមកពីផ្នែកណាមួយនៃអ្នកចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់ :

១-អ្នកផ្តើមប្រតិបត្តិការពុំមានការទទួលខុសត្រូវចំពោះមុខធនាគារផ្តើមប្រតិបត្តិការទេ និងមានសិទ្ធិឱ្យចុះឥណទានឡើងវិញលើគណនីរបស់ខ្លួនតាមចំនួនប្រាក់ដែលបានចុះឥណពន្ធ ដើម្បីសងចំនួនប្រាក់ក្នុងបញ្ជាទូទាត់ ។ លើសពីនេះទៀត អ្នកផ្តើមប្រតិបត្តិការត្រូវមានសិទ្ធិទាមទារពីធនាគារផ្តើមប្រតិបត្តិការនូវចំណាយដែលសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយព្រមទាំងការប្រាក់លើចំនួនប្រាក់ដែលបានចុះឥណទានឡើងវិញនោះ ។

២-ធនាគារផ្តើមប្រតិបត្តិការនិងធនាគារអន្តរការីណាមួយ ដែលអនុវត្តបញ្ជាពីអ្នកផ្ញើរបស់ខ្លួន ត្រូវបានរួចផុតដូចគ្នានេះដែរពីការទទួលខុសត្រូវចំពោះមុខធនាគារទទួលរបស់ខ្លួន និងមានសិទ្ធិទទួលសំណងរៀងៗខ្លួនពីធនាគារនោះ លើកលែងតែចំណាយ និងសោហ៊ុយផ្សេងៗ ។

## មាត្រា ២១៦.-

ធនាគារទទួល ត្រូវទទួលខុសត្រូវចំពោះចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយ ការប្រាក់ ការខូចប្រយោជន៍នានារួមទាំងការខាតបង់ពីអត្រាប្តូរប្រាក់ផងដែរបើមាន ដែលបណ្តាលមកពីការយឺតយ៉ាវ ឬ កំហុសរបស់ខ្លួន ក្នុងការអនុវត្តបញ្ជាទូទាត់ ។ អ្នកផ្តើមប្រតិបត្តិការអាចទាមទារការខាតបង់នេះ ឬ មួយពីធនាគារផ្តើមប្រតិបត្តិការ ឬ ពីធនាគារទទួល ដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ អ្នកទទួលប្រាក់អាចទាមទារការខាតបង់ ឬ មួយពីធនាគារគោលដៅ ឬ ពីធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ ធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ត្រូវទទួលខុសត្រូវសងឱ្យធនាគារផ្តើមប្រតិបត្តិការ ឬ ធនាគារគោលដៅ នូវចំនួនប្រាក់ដែលពួកគេសងការខូចខាត ។

លើសពីនេះទៀត ធនាគារទទួលដែល :

-ពុំបានផ្តល់ដំណឹងភ្លាមដល់អ្នកផ្ញើ អំពីការបដិសេធរបស់ខ្លួនចំពោះបញ្ជាទូទាត់ ឬ

2/0/128

មានការធ្វេសប្រហែសធ្ងន់ធ្ងរក្នុងការអនុវត្ត ឬ ពុំបានអនុវត្តនូវបញ្ជាទូទាត់

ត្រូវទទួលខុសត្រូវចំពោះអ្នកផ្ដើមប្រតិបត្តិការលើការខូចខាតជាក់ស្ដែងដែលអាចដឹងមុន ដែលពុំលើសពីចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្ដើមប្រតិបត្តិការ ទោះបីអ្នកផ្ដើមប្រតិបត្តិការជាអ្នកផ្ញើ ឬ មិនមែនអ្នកផ្ញើរបស់ខ្លួនក្ដី ប៉ុន្តែអាស្រ័យដោយអ្នកផ្ដើមប្រតិបត្តិការពុំមានការធ្វេសប្រហែសដែរ ។ នៅពេលដែលអាចអនុវត្តបាន អ្នកផ្ញើក៏អាចមានសិទ្ធិទទួលចំនួនប្រាក់នៃបញ្ជាទូទាត់ដែលបានសងមកវិញ អនុលោមតាមមាត្រា ២១៥ នៃច្បាប់នេះ ។

អ្នកផ្ដើមប្រតិបត្តិការមានសិទ្ធិទទួលមកវិញ នៅក្រោមកថាខណ្ឌទី ១ នៃមាត្រានេះ នូវចំនួនប្រាក់ទាំងស្រុងពីធនាគារផ្ដើមប្រតិបត្តិការ ឬ ពីធនាគារដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ។ អាស្រ័យដោយកិច្ចព្រមព្រៀងអន្តរធនាគារ ធនាគារដែលទទួលខុសត្រូវនៅក្រោមមាត្រានេះ មានសិទ្ធិទាមទារការចូលរួមចំណែកទទួលខុសត្រូវពីភាគីផ្សេងទៀត យោងតាមកម្រិតនៃការបង្កឱ្យមានការខូចខាតរបស់ភាគីទាំងនោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ការទទួលខុសត្រូវនៅក្រោមមាត្រានេះ និងកំរិតកំណត់ណាមួយដែលពាក់ព័ន្ធ មិនគិតដល់ការទទួលខុសត្រូវរបស់ធនាគារគោលដៅលើការខុសឆ្គងក្នុងការមិនព្រមទូទាត់សងប្រាក់នៅក្រោមមាត្រា ២១០(៥) ទេ ។

**មាត្រា ២១៧._**

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ ដោយមានការភ័ន្តច្រឡំរបស់ធនាគារទទួល ដែលជាធនាគារមានកំហុស ដូចជាការសងប្រាក់ទៅអ្នកទទួលពុំបានធ្វើឡើង ដូចដែលបានបញ្ជានៅក្នុងបញ្ជាទូទាត់របស់អ្នកផ្ដើមប្រតិបត្តិការ ជាបន្ថែមទៅលើសំណងមកវិញនៅក្រោមមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវអនុវត្តវិធានដូចតទៅ :

១-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលច្រើនហួស ឬ តិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្ដើមប្រតិបត្តិការ ការផ្ទេរឥណទានត្រូវចាត់

ទុកថាបានបញ្ចប់ក្នុងចំនួនប្រាក់ដែលបានសងឱ្យទៅអ្នកទទួល ។ នៅលើបញ្ជាទូទាត់នីមួយៗ អ្នកផ្ញើនីមួយៗត្រូវទទួលខុសត្រូវចំពោះមុខធនាគារទទួលក្នុងចំនួនប្រាក់នៃបញ្ជាទូទាត់របស់ខ្លួន ដែលនាំឱ្យ :

ក-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលច្រើនលើសពីចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសមានសិទ្ធិទទួលបានមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលសងលើសនោះ តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៅកន្លែងជាទីតាំងរបស់ធនាគារគោលដៅ និង

ខ-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសត្រូវសងប្រាក់ដែលខ្វះឱ្យទៅអ្នកទទួល និងមានសិទ្ធិរក្សាទុក ឬ ទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើរបស់ខ្លួននូវចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការសងប្រាក់ត្រូវបានធ្វើឱ្យទៅអ្នកទទួល ដែលពុំមែនជាអ្នកមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ហើយធនាគារមានកំហុសពុំមែនជាធនាគារគោលដៅនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទេនោះ អ្នកផ្តើមប្រតិបត្តិការនិងអ្នកផ្ញើឯទៀតមុនធនាគារមានកំហុស និងអ្នកទទួលបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ អាចចាត់ទុកថាការផ្ទេរឥណទានពុំទាន់បានបញ្ចប់ទេ ។ ធនាគារមានកំហុសមានសិទ្ធិប្រមូលមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលបានទូទាត់សង តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៃកន្លែងជាទីតាំងរបស់ធនាគារគោលដៅ ។

៣-ធនាគារមានកំហុសត្រូវទទួលខុសត្រូវ ចំពោះអ្នកចូលរួមលើប្រាក់ដើម ការប្រាក់ ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហ៊ុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មាន ដែលកើតឡើងអំពីការភ័ន្តច្រឡំនោះ ។

៤-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

115/128

**មាត្រា ២១៨.-**

នៅពេលដែលការផ្ទេរឥណពន្ធត្រូវបានបញ្ចប់ ដោយពុំស្របតាមការបញ្ជានៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ដោយសារតែការភ័ន្តច្រឡំរបស់ធនាគារទទួល ដែលជាធនាគារមានកំហុស ជាបន្ថែមទៅលើសំណងមកវិញ នៅក្រោមកថាខណ្ឌទី ៥ នៃមាត្រា ២១០ និងមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវអនុវត្តវិធាន ដូចតទៅ :

១-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់តិចជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារមានកំហុសត្រូវទាមទារចំនួនប្រាក់ដែលខ្វះពីអ្នកទទួល ហើយប្រគល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់ច្រើនជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនូវចំនួនប្រាក់ដែលលើសនោះ ។ ធនាគារមានកំហុសត្រូវសងចំនួនប្រាក់ដែលលើស ឱ្យទៅធនាគារគោលដៅ និងទារចំនួនប្រាក់លើសពីអ្នកផ្តើមប្រតិបត្តិការ ឬ អ្នកចូលរួមដទៃទៀត ទៅតាមចំនួនប្រាក់លើសដែលបានរក្សាទុក ។

៣-នៅពេលណាមានការកត់ត្រាឥណពន្ធ នៅលើគណនីអ្នកទទួលមួយផ្សេង ក្រៅពីអ្នកដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនេះនូវចំនួនប្រាក់ដែលបានចុះឥណពន្ធ និងត្រូវចុះឥណពន្ធគណនីអ្នកទទួលដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការតាមចំនួនប្រាក់នៃបញ្ជាទូទាត់ ។

៤-នៅពេលណាដែលមានការកត់ត្រាឥណពន្ធ គណនីអ្នកទទួលនៅក្នុងធនាគារគោលដៅមួយផ្សេង ក្រៅពីធនាគារនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅនោះត្រូវចុះឥណទានគណនីអ្នកទទួលនោះវិញតាមចំនួនប្រាក់ដដែល និងទារប្រាក់នេះពីធនាគារមានកំហុស ។ ធនាគារមានកំហុសត្រូវទារចំនួនប្រាក់ក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការពីអ្នកទទួលបញ្ជាទូទាត់របស់អ្នក

ផ្ដើមប្រតិបត្តិការ ។

៥-នៅក្រោមមាត្រានេះ ការទារប្រាក់ត្រូវធ្វើតាមរយៈការផ្ទេរឥណពន្ធ ហើយការសងប្រាក់តាមរយៈការផ្ទេរឥណទាន ។

៦-ធនាគារមានកំហុសត្រូវទទួលខុសត្រូវចំពោះអ្នកចូលរួមណាមួយលើប្រាក់ដើម ការប្រាក់ ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហ៊ុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មានដែលកើតឡើងពីការភ័ន្តច្រឡំនោះ ។

៧-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

## ផ្នែកទី ៧
## គណនីធនាគារ

**មាត្រា ២១៩.-**

យោងតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង និងលើកលែងតែក្នុងកាលៈទេសៈដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ សមតុល្យឥណទាយីដែលមានគ្រប់គ្រាន់អាចនឹងត្រូវអតិថិជនដកប្រាក់ចេញ ឬ ធនាគារធ្វើការសងប្រាក់តាមបញ្ជាទូទាត់ ។ ធនាគារពុំត្រូវបានបង្ខំឱ្យយល់ព្រម លើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើលើសកម្រិតសមតុល្យឥណទាយីឱ្យអតិថិជនឡើយ ។

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

2/24

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណងដាក់ចេញនូវវិធានការ ដើម្បីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងការរៀបចំ ចាត់ចែង និងត្រួតពិនិត្យ ការប្រតិបត្តិវិធានការទាំងនោះ ។

### មាត្រា ២.- ដែនអនុវត្ត

ច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀតសម្រាប់ប្រតិបត្តិច្បាប់នេះ ត្រូវអនុវត្តសម្រាប់ទប់ស្កាត់ និងត្រួតពិនិត្យការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

### មាត្រា ៣.- និយមន័យនៃពាក្យបច្ចេកទេស

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ពាក្យថា :

ក-**ការសំអាតប្រាក់** គឺជា :

១-ការបំប្លែង ឬ ការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬ ក្លែងប្រភពដើម មិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬ ជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់ នូវសកម្មភាពរបស់ខ្លួន ។

២-ការបិទបាំង ឬ ការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬ កម្មសិទ្ធិ ឬ សិទ្ធិ លើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៣-ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៤-ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយ និង ជម្រុញឱ្យប្រព្រឹត្តសកម្មភាពណាមួយ ដែលបានកំណត់ស្របតាមមាត្រា ៣ នៃច្បាប់នេះ ។

ខ-**ផលនៃបទល្មើស** គឺជាទ្រព្យសម្បត្តិណាដែលបាន ឬ ទទួលដោយផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិម ។

4/24

គ-**ទ្រព្យសម្បត្តិ** គឺជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យ ឬ អចលនទ្រព្យ រូបិយ ឬ អរូបិយ និងឯកសារ ឬ ឧបករណ៍គតិយុត្តិ ដែលជាភស្តុតាងនៃកម្មសិទ្ធិ ឬ អត្ថប្រយោជន៍លើទ្រព្យទាំងនេះ ។

ឃ-**ស្ថាប័នត្រួតពិនិត្យ** គឺជាធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រ និងស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍ ។

ង-**សំអាងនៃបទល្មើស** គឺជាបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិម ទោះជាបានប្រព្រឹត្តនៅក្រៅប្រទេស ដែលផលទទួលបានពីបទល្មើសទាំងនេះ អាចក្លាយជាកម្មវត្ថុនៃការសំអាតប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ក នៃមាត្រា ៣ នៃច្បាប់នេះ ។

ដើម្បីអាចយកមកប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ប្តឹងអំពីការសំអាតប្រាក់ សំអាងនៃបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្រៅប្រទេស ត្រូវមានចរិតជាបទល្មើសនៅក្នុងប្រទេស ដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត និងស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងពិសេសផ្សេងពីនេះ ។

ច-**ហិរញ្ញប្បទានភេរវកម្ម** គឺជាការផ្តល់ដោយចេតនានូវសេវាហិរញ្ញវត្ថុ ឬសេវាផ្សេងទៀត ក្នុងបំណងប្រើប្រាស់សេវានេះ ឬ ដោយដឹងថាមូលនិធិនេះនឹងត្រូវបាន ឬ អាចប្រើទាំងមូល ឬ មួយផ្នែកសម្រាប់គាំទ្រ ភេរវកម្ម សកម្មភាពរបស់ភេរវករ ឬ អង្គការចាត់តាំងរបស់ភេរវកម្ម ។

ឆ-**ប្រតិបត្តិការសង្ស័យ** គឺជាប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិ ដែលត្រូវបានសង្ស័យថាបានមកពីការប្រព្រឹត្តបទល្មើស ឬ ជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម ។

ជ-**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** គឺជាអង្គការកណ្តាលដែលទទួលខុសត្រូវក្នុងការទទួលវិភាគ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យ ដូចបានកំណត់នៅក្នុងកថាខណ្ឌ ឆ នៃមាត្រា ៣ នៃច្បាប់នេះ ប្រតិបត្តិការសាច់ប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១ នៃមាត្រា ១២ នៃច្បាប់នេះ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ។

ឈ-**អត្ថគាហកចុងក្រោយ** គឺជាបុគ្គលដែលកាន់កាប់ ឬ ត្រួតត្រាចុងក្រោយបង្គួស់លើអតិថិជន និង/ ឬ បុគ្គលដែលធ្វើប្រតិបត្តិការជំនួស រាប់បញ្ចូលទាំងបុគ្គលទាំងឡាយដែលកំពុងធ្វើប្រតិបត្តិការជាចុងក្រោយលើនីតិបុគ្គល ឬ កិច្ចសម្របសម្រួលណាមួយ ។

ញ-**បុគ្គលពាក់ព័ន្ធនយោបាយ** គឺជាឯកត្តជនដែលជា ឬ ដែលត្រូវបានប្រគល់មុខងារសាធារណៈ ខ្ពង់ខ្ពស់នៅក្រៅប្រទេស ដូចជាប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល អ្នកនយោ-បាយជាន់ខ្ពស់ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធា ឬ មន្ត្រីយុត្តិធម៌ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋ ឬ មន្ត្រីគណបក្សសំខាន់ៗ ។

ដ-**ក្រុមហ៊ុនអាណត្តិព្យាបាល** គឺជានីតិបុគ្គល ដែលត្រូវបានបង្កើតឡើងដោយបុគ្គលម្នាក់ដែលជាអ្នកប្រគល់អាណត្តិព្យាបាល ។ អ្នកប្រគល់អាណត្តិព្យាបាលផ្ទេរកម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិទៅឱ្យអ្នកទទួលអាណត្តិព្យាបាល ដែលធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះ សំរាប់ជាផលប្រយោជន៍ដល់អត្ថគាហកណាម្នាក់ច្បាស់លាស់ ។

ឋ-**ទុព្វលកម្ម** គឺការធ្វើឱ្យទៅជាមោឃៈ ។

## ជំពូកទី ២

## បុគ្គលរាយការណ៍

### មាត្រា ៤._ បុគ្គល និងវិជ្ជាជីវៈចំណុះច្បាប់នេះ

ច្បាប់នេះត្រូវអនុវត្តចំពោះបុគ្គល និង វិជ្ជាជីវៈដូចខាងក្រោម តទៅនេះហៅថាបុគ្គលរាយការណ៍ ។

ក-ធនាគារ រួមទាំងសាខារបស់ធនាគារបរទេស

ខ-គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនជើងសារមូលបត្រនិងក្រុមហ៊ុនធានារ៉ាប់រង

គ-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឃ-សហករណ៍ឥណទាន

ង-ក្រុមហ៊ុនភតិសន្យា មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ

ច-អាជីវកម្មប្តូរប្រាក់

ឆ-សេវាផ្ទេរប្រាក់

ជ-ភ្នាក់ងារអចលនទ្រព្យ អគារ និង ដីធ្លី

ឈ-ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ

ញ-ការិយាល័យប្រៃសណីយ៍ ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់

ដ-មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះរៀបចំ ឬ ធ្វើប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួនដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ

ឋ-កាស៊ីណូ និង គ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ

ឌ-អង្គការក្រៅរដ្ឋាភិបាល និង អង្គការមូលនិធិ ធ្វើសកម្មភាពអាជីវកម្មនិងរៃ-អង្គាសមូលនិធិ

ឍ-បុគ្គល ឬវិជ្ជាជីវៈផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដែលត្រូវស្ថិតក្នុងដែនអនុវត្តនៃច្បាប់នេះ ។

**មាត្រា ៥.- សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍**

សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍ ដូចមាននៅក្នុងមាត្រា ៤-ដ នៃច្បាប់នេះ រួមមាន :

១-ការទិញ និង លក់អចលនទ្រព្យ អគារនិងដីធ្លី

២-ការគ្រប់គ្រងប្រាក់ មូលបត្រ ឬ ទ្រព្យសកម្មផ្សេងទៀតរបស់អតិថិជនដូចជា :

ក-ការគ្រប់គ្រងគណនីធនាគារ ឬ គណនីមូលបត្រ

ខ-ការចូលរួមចំណែកក្នុងការបង្កើតប្រតិបត្តិការ ឬ គ្រប់គ្រងក្រុមហ៊ុន

៣-ការបង្កើតប្រតិបត្តិការ ឬ គ្រប់គ្រងនីតិបុគ្គលឬកិច្ចសម្របសម្រួល និងការទិញនិងលក់អង្គភាពអាជីវកម្ម

៤-ក្រុមហ៊ុនអាណត្តិព្យាបាល ឬ ក្រុមហ៊ុនដែលផ្ដល់សេវានៅពេលដែលក្រុមហ៊ុនទាំងនោះត្រៀមអនុវត្ត ឬ អនុវត្តសម្រាប់អតិថិជនទាក់ទងនឹងសកម្មភាពទាំងឡាយដូចខាងក្រោម :

-ធ្វើសកម្មភាពជាភ្នាក់ងារបង្កើតនីតិបុគ្គលនោះ

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជានាយក ឬ ជាលេខាធិការរបស់ក្រុមហ៊ុន ជាអ្នកចូលហ៊ុននៃក្រុមហ៊ុនសហកម្មសិទ្ធិ ឬ តួនាទីប្រហាក់ប្រហែលទាក់ទងជាមួយនីតិបុគ្គលផ្សេងទៀត

-ផ្ដល់ទីស្នាក់ការផ្លូវការ អាសយដ្ឋាន ឬ ទីតាំងអាជីវកម្ម អាសយដ្ឋានទំនាក់ទំនង ឬ រដ្ឋបាល សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ដទៃទៀត ឬ ការសម្របសម្រួលដទៃទៀត

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអាណត្តិព្យាបាល

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជាភាគទុនិកដែលត្រូវបានតែងតាំងជំនួសឱ្យបុគ្គលដទៃ ។

## ជំពូកទី ៣

## វិធានការត្រួតប្រកាន់យកដោយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ មុខរបរហិរញ្ញវត្ថុមិនមែនធនាគារ និង វិជ្ជាជីវៈដើម្បីទប់ស្កាត់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម

**មាត្រា ៦.- ការសម្ងាត់ធនាគារនិងវិជ្ជាជីវៈ**

ការសម្ងាត់ធនាគារ ឬ វិជ្ជាជីវៈ មិនត្រូវរារាំងការអនុវត្តច្បាប់នេះ និង មិនអាចយកមកប្រើជាលេសអាង ដើម្បីបដិសេធការផ្ដល់ព័ត៌មាន ដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័ន

8/24

ត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេស ឬ អន្តរជាតិ ឬ ក៏ដូច ដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធដល់ការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានបញ្ជាដោយ ឬ អនុវត្តក្រោមការត្រួតពិនិត្យរបស់តុលាការ ។

**មាត្រា ៧.– ការហាមឃាត់គណនីអនាមិក ឬ ផលិតផលសម្ងាត់**

បុគ្គលរាយការណ៍មិនត្រូវ :

ក-បើក ឬ រក្សាទុកគណនីអនាមិក ឬ គណនីដែលមានតែលេខ ឬ គណនីដែលដាក់ឈ្មោះបតិរូបកម្ម

ខ-ចេញផ្សាយ រក្សាទុក ឬ ទទួលយកផលិតផលហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែបានអនុវត្តវិធានការយកចិត្តទុកដាក់ចំពោះអតិថិជនស្របតាមមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ៨.– វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន**

១-បុគ្គលរាយការណ៍នៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវប្រកាន់យកវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនឱ្យបានច្បាស់លាស់រួមមានការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណជាដើមដូចជា :

ក-មុនពេលបង្កើតទំនាក់ទំនងអាជីវកម្ម ដូចជាការបើកគណនី ការទទួលថែ-រក្សាភាគហ៊ុន សញ្ញាប័ណ្ណ ឬ មូលបត្រផ្សេងៗក្នុងទូសុវត្ថិភាព ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចូលរួមប្រកបអាជីវកម្មផ្សេងទៀតជាមួយគ្នា

ខ-មុនពេលអនុវត្តប្រតិបត្តិការមួយដងមួយកាល ឬ តែមួយដង រួមមានការផ្ទេរប្រាក់តាមអេឡិចត្រូនិក ដែលមានចំនួនលើសពីចំនួនកំណត់ដោយស្ថាប័នត្រួតពិនិត្យ ព័ត៌-មានដែលភ្ជាប់មកជាមួយត្រូវមានបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់អ្នកផ្តើមប្រតិបត្តិការ និងទីកន្លែងដែលគណនីត្រូវបានបើក និងលេខគណនី ។ ក្នុងករណីគ្មានគណនី ត្រូវដាក់តែលេខយោង ។

គ-បើបុគ្គលរាយការណ៍មានការសង្ស័យពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយមិនគិតពីបរិមាណប្រាក់នៃប្រតិបត្តិការ

ឃ-បើបុគ្គលរាយការណ៍មានការសង្ស័យអំពីភាពស្មោះត្រង់ ឬ ភាពគ្រប់គ្រាន់

លើទិន្នន័យនៃអត្តសញ្ញាណរបស់អតិថិជន ដែលបានទទួលពីមុនមកហើយ ។

២-បុគ្គលរាយការណ៍ ត្រូវចាត់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដូចខាងក្រោម :

ក-សម្គាល់អត្តសញ្ញាណរបស់អតិថិជន ដោយទទួលបានជាអប្បបរមានូវនាម នាមត្រកូល ថ្ងៃ-ខែ-ឆ្នាំកំណើត និងអាសយដ្ឋាន សម្រាប់រូបវន្តបុគ្គល និងនាមករណ៍ លក្ខន្តិកៈ ឬ ការចុះបញ្ជី លេខសម្គាល់ ប័ណ្ណបង់ពន្ធ អាសយដ្ឋាន លេខទូរស័ព្ទជាដើម សម្រាប់នីតិបុគ្គលដូចបានកំណត់ដោយស្ថាប័នត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ថាអតិថិជនបានប្រើប្រាស់ឯកសារ ទិន្នន័យ ឬ ព័ត៌មាន ដែលមានប្រភពឯករាជ្យ គួរឱ្យជឿទុកចិត្តបានក្នុងការផ្តល់អត្តសញ្ញាណរបស់ខ្លួនដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងឯកសារ អត្តសញ្ញាណផ្លូវការមានរូបថត

ខ-សម្គាល់អត្តសញ្ញាណអ្នកទទួលប្រាក់ចុងក្រោយ និង ចាត់វិធានការសមស្រប ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណអត្ថគាហក តាមវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុបានប្រាកដក្នុងចិត្តថា អ្នកទទួលប្រាក់ចុងក្រោយ ត្រូវបានស្គាល់ច្បាស់លាស់ ។ សម្រាប់នីតិបុគ្គលឬកិច្ចសម្របសម្រួល បុគ្គលរាយការណ៍ ត្រូវចាត់វិធានការសមស្របដើម្បីស្វែងយល់ពីម្ចាស់ និង រចនាសម្ព័ន្ធអភិបាលរបស់អតិថិជន

គ-ទទួលព័ត៌មានពីគោលបំណង និង ប្រភេទនៃទំនាក់ទំនងអាជីវកម្ម

ឃ-បន្តយកចិត្តទុកដាក់ទៅលើទំនាក់ទំនងអាជីវកម្ម និង ពិនិត្យពិច័យប្រតិបត្តិការទាំងឡាយ ដែលបានប្រព្រឹត្តទៅក្នុងពេលទំនាក់ទំនងនេះ ដើម្បីធានាថាប្រតិបត្តិការទាំងនេះ ស្របទៅតាមគោលការណ៍ស្គាល់អតិថិជន មុខរបរនិងទ្រង់ទ្រាយហានិភ័យរបស់បុគ្គលរាយការណ៍ទាំងនោះ រួមទាំងប្រភពមូលនិធិផងបើចាំបាច់ ។

៣-នៅពេលណាបុគ្គលរាយការណ៍ មិនអាចអនុវត្តតាមកថាខណ្ឌ ២-ក ដល់ គ នៃមាត្រានេះ បុគ្គលនោះមិនត្រូវបើកគណនី មិនត្រូវចាប់ផ្តើមទំនាក់ទំនងអាជីវកម្ម ឬអនុវត្តប្រតិបត្តិការ ឬ ក្នុងករណីមានទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនរួចហើយ ត្រូវបញ្ឈប់ទំនាក់ទំនងអាជីវកម្មនោះ លើកលែងតែមានការណែនាំផ្ទុយពីនេះ ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ ក្នុងករណីដូចនេះ បុគ្គលរាយការណ៍ត្រូវពិចារណាពីការធ្វើរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យទាក់ទងជាមួយអតិថិជននោះ ។

10/24

៤-កាតព្វកិច្ចដែលមានចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះអតិថិជនថ្មីទាំងអស់ ក៏ដូចជាអតិថិជនដែលមានស្រាប់ ផ្អែកលើមូលដ្ឋាននៃការពិត និង ហានិភ័យ ។ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ពិនិត្យឡើងវិញ ចំពោះទំនាក់ទំនងដែលមានស្រាប់ ។

**មាត្រា ៩.- ការសម្គាល់អត្តសញ្ញាណអតិថិជន ដែលធ្វើប្រតិបត្តិការក្រោមកម្រិតកំណត់**

ការសម្គាល់អត្តសញ្ញាណ ក៏ត្រូវអនុវត្តផងដែរ ក្នុងករណីប្រតិបត្តិការដាច់ៗពីគ្នាត្រូវបានធ្វើជាច្រើនដង ដោយប្រតិបត្តិការនីមួយៗមានចំនួនប្រាក់តិចជាងចំនួនដែលបានកំណត់ដោយស្ថាប័នត្រួតពិនិត្យ ប៉ុន្តែបុគ្គលរាយការណ៍មានហេតុផលដែលអាចជឿបានថា ប្រតិបត្តិការទាំងនោះ ត្រូវបានធ្វើឡើងក្នុងគោលបំណងចៀសវាងការសម្គាល់អត្តសញ្ញាណ ។

**មាត្រា ១០.- ការតាមដានត្រួតពិនិត្យពិសេសទៅលើប្រតិបត្តិការមួយចំនួន**

១-បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ ជាពិសេសលើ :

ក-ប្រតិបត្តិការណាដែលស្មុគស្មាញ មិនប្រក្រតី ឬ មានចំនួនប្រាក់ច្រើន

ខ-ប្រភេទប្រតិបត្តិការមិនប្រក្រតី ដែលមិនបង្ហាញពីគោលបំណងសេដ្ឋកិច្ច ឬ ស្របច្បាប់ច្បាស់លាស់ណាមួយ

គ-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយគ្រឹះស្ថាន ឬ បុគ្គលក្នុងយុត្តាធិការដែលមិនមានប្រព័ន្ធគ្រប់គ្រាន់ សម្រាប់បង្ការ ឬ រារាំងសកម្មភាពសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម

ឃ-ការផ្ទេរប្រាក់តាមអេឡិចត្រូនិក ដែលពុំមានព័ត៌មានរបស់អ្នកផ្តើមប្រតិបត្តិការគ្រប់គ្រាន់

ង-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយបុគ្គលណា ដែលបុគ្គលរាយការណ៍មិនបានជួបប្រាស្រ័យផ្ទាល់នៅពេលអនុវត្តនីតិវិធីសម្គាល់អត្តសញ្ញាណ

ច-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយ

ឆ-ទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការដែលធ្វើតាមរយៈធនាគារទំនាក់ទំនងឆ្លងដែន ឬ ទំនាក់ទំនងដូចនេះផ្សេងទៀត ។

២-ក្នុងករណីយោងទៅកថាខណ្ឌទី ១ នៃមាត្រានេះ បុគ្គលរាយការណ៍ត្រូវស្វែងរកព័ត៌-មានបន្ថែមអំពីប្រភពដើម និងគោលដៅរបស់ប្រាក់ គោលបំណងនៃប្រតិបត្តិការ និង អត្ត-សញ្ញាណរបស់ភាគីចូលរួមប្រតិបត្តិការ ។

**មាត្រា ១១.- ការរក្សាទុកឯកសារកត់ត្រារបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវរក្សាទុកឯកសារកត់-ត្រាអត្តសញ្ញាណ និង ប្រតិបត្តិការរបស់អតិថិជនឱ្យបានគ្រប់គ្រាន់យ៉ាងតិចបំផុតប្រាំ (០៥)ឆ្នាំក្រោយគណនីត្រូវបានបិទ ឬ ទំនាក់ទំនងអាជីវកម្ម ជាមួយអតិថិជនត្រូវបានបញ្ចប់ និងត្រូវរក្សាទុកសម្រាប់តម្រូវការរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអាចមើលឡើងវិញនូវប្រតិបត្តិ-ការនីមួយៗ រួមមានចំនួនប្រាក់ និង ប្រភេទរូបិយប័ណ្ណ បើមាន ដើម្បីផ្តល់ភស្តុតាងសមស្របសម្រាប់កាត់ទោសជនល្មើស ។

**មាត្រា ១២.- របាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុ**

១-បុគ្គលរាយការណ៍ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនូវប្រតិបត្តិការសាច់ប្រាក់ ដែលលើសពីចំនួនកំណត់ដោយស្ថា-ប័នត្រួតពិនិត្យ ក៏ដូចជាប្រតិបត្តិការណាដែលពាក់ព័ន្ធប្រតិបត្តិការសាច់ប្រាក់ច្រើនផង ហើយចំនួនប្រាក់សរុបលើសពីចំនួនដែលបានកំណត់នេះ ។

២-ដោយពុំគិតដល់កាតព្វកិច្ចរាយការណ៍ ដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រានេះ បើបុគ្គលរាយការណ៍សង្ស័យ ឬ មានមូលដ្ឋានសមស្រប ដើម្បីសង្ស័យថាមូលនិធិជាផលបានមកពីការប្រព្រឹត្តបទល្មើស ឬ ជាប់ទាក់ទងដល់ហិរញ្ញប្បទានភេរវកម្ម បុគ្គលរាយការណ៍ត្រូវរាយការណ៍ជាបន្ទាន់ក្នុងរយៈពេល ២៤ ម៉ោង ពីការសង្ស័យរបស់ខ្លួនទៅអង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុ ។

៣-របាយការណ៍ពីការសង្ស័យ ត្រូវបញ្ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ តាមមធ្យោ-បាយទំនាក់ទំនងឆាប់រហ័សណាមួយ ដូចជាទូរសារ ឬ ប្រសិនបើគ្មាន តាមរយៈលិខិតជាលាយ-លក្ខណ៍អក្សរ ។ របាយការណ៍តាមទូរស័ព្ទ ត្រូវបញ្ជាក់បន្ថែមតាមទូរសារ ឬ លិខិតជាលាយ-



12/24.

លក្ខណ៍អក្សរក្នុងរយៈពេលមួយខ្លីបំផុតដែលអាចធ្វើបាន ។ នៅពេលទទួលបានរបាយការណ៍ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវបញ្ជាក់ថាបានទទួល ។

៤-បុគ្គលរាយការណ៍ ដែលបានផ្ញើរបាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក៏ដូចជាស្ថាប័នផ្សេងទៀត ដែលមានព័ត៌មានទាក់ទងដល់ប្រតិបត្តិការ ឬ ដល់អតិថិជនដែលជាប់ពាក់ព័ន្ធនៅក្នុងរបាយការណ៍ ត្រូវផ្តល់ឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ឬ ស្ថាប័នអនុវត្តច្បាប់ដែលកំពុងស៊ើបអង្កេត ដោយផ្តើមចេញពី ឬ ទាក់ទងដល់ព័ត៌មាននៅក្នុងរបាយការណ៍ និងព័ត៌មានផ្សេងទៀត ដែលមានអំពីប្រតិបត្តិការ ឬ ប្រតិបត្តិការដែលត្រូវបានប៉ុនប៉ងធ្វើ ឬ ភាគីចូលរួមក្នុងប្រតិបត្តិការ បើមានការស្នើសុំពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ឬ ស្ថាប័នអនុវត្តច្បាប់ ។

៥-បើអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ មានមូលដ្ឋានសមហេតុផលក្នុងការសង្ស័យថា ប្រតិបត្តិការ ឬ សំណើប្រតិបត្តិការមួយ អាចជាប់ពាក់ព័ន្ធបទល្មើសសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ឬ សម្រាប់ករណីប្រាកដប្រជា ឬ បន្ទាន់ បើយល់ថាចាំបាច់ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ អាចណែនាំបុគ្គលរាយការណ៍ជាលាយលក្ខណ៍អក្សរ ឬ តាមទូរស័ព្ទ បន្ទាប់មកជាលាយលក្ខណ៍អក្សរមិនឱ្យបន្តដំណើរការប្រតិបត្តិការនោះ ឬ ប្រតិបត្តិការដែលបានធ្វើ ឬប្រតិបត្តិការផ្សេងណា ដែលមានមូលនិធិទាក់ទងដល់ប្រតិបត្តិការនោះ ឬ ប្រតិបត្តិការដែលបានស្នើក្នុងរយៈពេលមួយដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបានកំណត់មិនឱ្យលើសពី ៤៨ ម៉ោង ដើម្បីឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាច :

-ធ្វើការស៊ើបអង្កេតចាំបាច់អំពីប្រតិបត្តិការ

-ផ្តល់ព័ត៌មាន និង ផ្តល់យោបល់ទៅស្ថាប័នអនុវត្តច្បាប់ បើយល់ថា សមស្រប ។

**មាត្រា ១៣.- ខ្លឹមសារនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ**

របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលត្រូវបានផ្ញើទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានភ្ជាប់មកជាមួយជាអប្បបរមានូវ :

ក-អត្តសញ្ញាណ និង សញ្ញាណសម្គាល់របស់បុគ្គលរាយការណ៍ រួមទាំងឈ្មោះ និងព័ត៌មានលំអិតសម្រាប់ទាក់ទងនៃមន្ត្រីរាយការណ៍



13/24

ខ-អត្តសញ្ញាណ និង សញ្ញាណសម្គាល់របស់អតិថិជននិងអត្ថគាហក ដែលពាក់-ព័ន្ធក្នុងប្រតិបត្តិការនោះ

គ-ប្រភេទ និង ព័ត៌មានលំអិតនៃប្រតិបត្តិការ ដូចជាចំនួនប្រាក់រូបិយប័ណ្ណ កាល-បរិច្ឆេទ ភាគីពាក់ព័ន្ធដែលត្រូវបានរាយការណ៍ថាសង្ស័យរួមមានលេខគណនី សញ្ញាណសម្គាល់របស់ម្ចាស់គណនីនោះ

ឃ-ពិពណ៌នាដោយសង្ខេបពីកាលៈទេសៈ និង ហេតុផលផ្សេងៗ ដែលបង្ហាញឱ្យឃើញថាជាប្រតិបត្តិការសង្ស័យ ។

**មាត្រា ១៤.- ការរួចផុតពីការទទួលខុសត្រូវចំពោះការរាយការណ៍ដោយសុចរិតនូវប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យ**

បុគ្គល នាយក ឬ និយោជិតរបស់បុគ្គលរាយការណ៍ :

១-ដែលបានបញ្ជូនព័ត៌មាន ឬ ផ្ញើរបាយការណ៍ ទៅអង្គភាពស៊ើបការណ៍ហិរ-ញ្ញវត្ថុដោយសុចរិត ស្របតាមច្បាប់នេះ មិនត្រូវបានប្តឹងចោទប្រកាន់ណាមួយពីបទរំលោភលើការហាមឃាត់ ក្នុងការបើកចំហព័ត៌មាន ឬ ការសម្ងាត់ធនាគារ ឬ ការសម្ងាត់វិជ្ជាជីវៈឡើយ ។

២-ដែលបានបញ្ជូនព័ត៌មាន ឬ ផ្ញើរបាយការណ៍ដោយសុចរិតស្របតាមបទប្ប-ញ្ញត្តិនៃច្បាប់នេះ មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌក៏ដូចជាមិនត្រូវទទួលទណ្ឌកម្មខាងវិជ្ជាជីវៈណាមួយឡើយ ទោះបីជាមានការស៊ើបអង្កេត ក៏មិនអាចនាំទៅដល់ការផ្តន្ទាទោសដែរ ។

៣-មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ដោយហេតុផលថា បានបង្កការខាតបង់ណាមួយខាងសម្ភារៈ និង/ឬ មិនមែនសម្ភារៈ កើតឡើងដោយសារការព្យួរប្រតិបត្តិការដូចមានចែងនៅកថាខណ្ឌ ៥ មាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៥.- ការហាមឃាត់ការផ្តល់ព័ត៌មាន**

ក្នុងកាលៈទេសៈណាក៏ដោយ បុគ្គលដែលមានកាតព្វកិច្ចផ្តល់ព័ត៌មាន ឬ បញ្ជូនរបាយ-ការណ៍ដូចមានចែងនៅក្នុងមាត្រា ១៣ ឬ បុគ្គលណាដែលបានដឹងរឿង មិនត្រូវផ្តល់ព័ត៌មាន



14/24

ឬ របាយការណ៍ទាំងនោះទៅបុគ្គលផ្សេង ក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុទេ លើកលែងតែមានការអនុញ្ញាតពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**មាត្រា ១៦.- ការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមរបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវបង្កើតកម្មវិធីសម្រាប់ទប់ស្កាត់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម តាមការណែនាំរបស់ស្ថាប័នត្រួតពិនិត្យដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។ កម្មវិធីទាំងនេះរួមមាន :

ក-ការបង្កើតគោលនយោបាយ នីតិវិធី និង ការត្រួតពិនិត្យផ្ទៃក្នុង រួមមានការរៀបចំការប្រតិបត្តិឱ្យ បានសមស្រប និង នីតិវិធីតាមដានគ្រប់គ្រាន់ ដើម្បីធានាឱ្យ មានលក្ខណសម្បត្តិខ្ពស់នៅពេលជ្រើសរើសនិយោជិត

ខ-ការតែងតាំងមន្ត្រីប្រតិបត្តិជាមន្ត្រីថ្នាក់គ្រប់គ្រង

គ-ការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកជាប្រចាំ

ឃ-មុខងារត្រួតពិនិត្យផ្ទៃក្នុង ដើម្បីផ្ទៀងផ្ទាត់ការប្រតិបត្តិ និង ប្រសិទ្ធភាពនៃរាល់វិធានការណ៍ ដែលត្រូវប្រកាន់យកដើម្បីអនុវត្តច្បាប់នេះ ។

**មាត្រា ១៧.- មន្ត្រីប្រតិបត្តិ**

មន្ត្រីប្រតិបត្តិដែលត្រូវបានតែងតាំងស្របតាមកថាខណ្ឌ ខ មាត្រា ១៦ នៃច្បាប់នេះ ជាមន្ត្រីជាន់ខ្ពស់មាន គុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ ដែលអាចមានលទ្ធភាពឆ្លើយតបបានល្អត្រឹមត្រូវទៅនឹងសំណួរទាក់ទងជាមួយបុគ្គលរាយការណ៍ និង ដំណើរការអាជីវកម្មរបស់បុគ្គលនោះ ព្រមទាំងអាចទទួលខុសត្រូវជាអប្បបរមា :

ក-ដើម្បីបង្កើត និង ថែរក្សាគោលនយោបាយផ្ទៃក្នុង នីតិវិធី និង សៀវភៅណែនាំពីការប្រតិបត្តិ

ខ-ដើម្បីធានាឱ្យ បុគ្គលិករបស់បុគ្គលរាយការណ៍ប្រតិបត្តិបានត្រឹមត្រូវតាមបទ-

បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតដែលទាក់ទងដល់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិនៃគោលនយោបាយ នីតិវិធី និង សៀវភៅណែនាំពីការប្រតិបត្តិដែលបានបង្កើតឡើងស្របតាមមាត្រានេះ

គ-ដើរតួជាអ្នកទំនាក់ទំនងរវាងបុគ្គលរាយការណ៍ និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងការងារ ដែលទាក់ទងដល់ការប្រតិបត្តិបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ផ្សេងទៀត ដែលចែងអំពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**មាត្រា ១៨.- ភាពពូកែច្ប់សមស្របនិងត្រឹមត្រូវ**

ស្ថាប័នត្រួតពិនិត្យត្រូវធានាថា គណៈគ្រប់គ្រង និង ភាគទុនិករបស់បុគ្គលរាយការណ៍ មានលក្ខណៈសមស្រប និងត្រឹមត្រូវ ដើម្បីអាចទប់ស្កាត់ឧក្រិដ្ឋជន និងសមាគតមិនឱ្យកាន់កាប់ ឬ ក្លាយជាអត្ថគាហក ឬ ជាអ្នកកាន់កាប់ផលប្រយោជន៍សំខាន់ៗ ឬ មុខងារគ្រប់គ្រងនៅក្នុងអង្គភាពទាំងនោះ ។

## ជំពូកទី ៤
## អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

**មាត្រា ១៩.- ការរៀបចំ**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវតែបានបង្កើតឡើងជាអង្គភាព ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

២-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងអំណាចធ្វើការសម្រេចចិត្តដោយឯករាជ្យក្នុងការងារដែលស្ថិតក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន ។

**មាត្រា ២០.- បុគ្គលិកនិងក្រុមប្រឹក្សាភិបាល**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូបតែងតាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវធ្វើការដោយស្ថិតនៅក្រោមឱវាទរបស់ក្រុមប្រឹក្សាភិបាល ដែលរួមមានមន្ត្រីជាន់ខ្ពស់តំណាងឱ្យស្ថាប័នដូចខាងក្រោម ៖

16/24

ក-ទីស្ដីការគណៈរដ្ឋមន្ត្រី

ខ-ក្រសួងយុត្តិធម៌

គ-ក្រសួងមហាផ្ទៃ

ឃ-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ង-ធនាគារជាតិនៃកម្ពុជា

២-ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ដោយជ្រើសរើសចេញពីតំណាងស្ថាប័នដូចបានរៀបរាប់ខាងលើសម្រាប់រយៈពេលពីរ (០២) ឆ្នាំ ។ ប្រធានអាណត្តិទីមួយរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែជាតំណាងធនាគារជាតិនៃកម្ពុជា ។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ។

៣-លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានបុគ្គលិកគ្រប់គ្រាន់ដែលត្រូវជ្រើសរើសដោយប្រធាន និង ត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ បុគ្គលិកត្រូវមានលក្ខណសម្បត្តិសុចរិតកម្រិតខ្ពស់ និង ត្រូវបានពិនិត្យជ្រើសរើសដោយអាជ្ញាធរពាក់ព័ន្ធ មុននឹងត្រូវបានអនុញ្ញាតឱ្យបម្រើការនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**មាត្រា ២១.- មុខងារ**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវ :

ក-ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ ដែលធ្វើឡើងស្របតាមមាត្រា ១២ នៃច្បាប់នេះ និងព័ត៌មានស្ដីពីការសង្ស័យនៃការសំអាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានផ្ញើមក

ខ-ប្រមូលព័ត៌មានដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុយល់ថា ទាក់ទងដល់សកម្មភាពរបស់ខ្លួនស្ដីពីការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមានទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលចាំបាច់ សម្រាប់អនុវត្តមុខងាររបស់ខ្លួនដូចជាព័ត៌មានដែលបានប្រមូល និងរក្សាទុកក្នុងទិន្នន័យ ដោយបុគ្គលរាយការណ៍

គ-យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និងព័ត៌-មានសម្រាប់ការពង្រឹង ការអនុវត្តច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួនដូចមានចែងក្នុងមាត្រានេះ រួមទាំងព័ត៌មាន ដែលត្រូវបានប្រមូល និងថែរក្សាទុកក្នុងទិន្នន័យរបស់ស្ថាប័នសាធារណៈផ្សេងៗ

ឃ-វិភាគ និង វាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្របដែលនាំឱ្យជឿជាក់ថា បទល្មើសសំអាតប្រាក់ ឬបទល្មើសហិរញ្ញប្បទានភេរវកម្មបានកើតឡើង ហើយក្នុងករណីនេះ បញ្ជូនសំណុំរឿងទៅអា-ជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេតពីបទល្មើស

ង-ចងក្រងស្ថិតិ និង កត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យ និងសាច់ប្រាក់ដែលបានទទួល វិភាគ និង បញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច និងផ្តល់ព័ត៌មានទាំងនោះទៅស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ

ច-ផ្តល់មតិទៅបុគ្គលរាយការណ៍ និង ស្ថាប័នពាក់ព័ន្ធផ្សេងៗនូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ ឬ ព័ត៌មានផ្សេងៗដូចមានចែងនៅក្នុងច្បាប់នេះ

ឆ-ធានាថា រាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតនៅក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត

ជ-ចាត់វិធានការដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការងារទាក់ទងដល់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។

**មាត្រា ២២.- ការត្រួតពិនិត្យដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍ស្តីពីការសម្គាល់អត្តសញ្ញាណរបស់អតិថិជន ការរក្សាទុកឯកសារកត់ត្រា ការរាយការណ៍ ប្រតិបត្តិការសង្ស័យ និង កាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់នេះ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នត្រួតពិនិត្យមានសមត្ថកិច្ច ក្នុងករណីដែលការត្រួតពិនិត្យដូចនេះត្រូវបានធ្វើរួចហើយ ។

18/24

២-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវធានាពីការប្រតិបត្តិរបស់បុគ្គលរាយការណ៍ស្រប តាមកាតព្វកិច្ចនានាដែលចែងក្នុងច្បាប់នេះ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងស្របតាមច្បាប់ដែលពាក់ព័ន្ធ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវសម្របសម្រួលការងារត្រួតពិនិត្យការប្រតិបត្តិតាមច្បាប់នេះជាមួយស្ថាប័នត្រួតពិនិត្យដែលមានស្រាប់ ។

៣-ក្នុងពេលត្រួតពិនិត្យ បើរកឃើញការមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាច :

ក-ណែនាំបុគ្គលរាយការណ៍ឱ្យប្រកាន់យកសកម្មភាពកែតម្រូវ ដូចដែលបានកំណត់

ខ-ជូនព័ត៌មានទៅស្ថាប័នត្រួតពិនិត្យផ្សេងទៀត អំពីការមិនប្រតិបត្តិតាម និងលើកសំណើឱ្យស្ថាប័នទាំងនោះ អនុវត្តវិធានការត្រួតពិនិត្យរួមមានការដាក់ទណ្ឌកម្ម ឬ ការដកហូតអាជ្ញាប័ណ្ណតាមសមត្ថកិច្ចរៀងខ្លួន

គ-ដាក់ទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់នេះ ។

### មាត្រា ២៣.- ភាតព្វកិច្ចរក្សាការសម្ងាត់

ក្រុមប្រឹក្សាភិបាល និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់នៃរាល់ព័ត៌មានដែលទទួលបានក្នុងដែននៃភារកិច្ចរបស់ខ្លួន ទោះបីជាក្រោយពេលចប់ភារកិច្ច នៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក៏ដោយ ។ រាល់ព័ត៌មានមិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេង ក្រៅពីគោលបំណងដែលបានចែងក្នុងច្បាប់នេះ ។

### មាត្រា ២៤.- មូលដ្ឋានទិន្នន័យ

យោងតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការការពារសិទ្ធិឯកជន និង មូលដ្ឋានទិន្នន័យប្រព័ន្ធកុំព្យូទ័រ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវដំណើរការមូលដ្ឋានទិន្នន័យដែលមានព័ត៌មានស្តីពីរបាយការណ៍ប្រតិបត្តិការសង្ស័យ និង ប្រតិបត្តិការសាច់ប្រាក់ដូចដែលបានតម្រូវដោយច្បាប់នេះ ។ ព័ត៌មានទាំងនោះត្រូវតែបានធ្វើបច្ចុប្បន្នកម្ម និង រៀបចំក្នុងន័យដើម្បីធានាប្រសិទ្ធភាព

19/24

ជាអតិបរមានៃការវិភាគប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងជួយបញ្ជាក់ថាជាការពិត ឬ ធ្វើឱ្យពួលកម្មការសង្ស័យ ។

**មាត្រា ២៥.– ទំនាក់ទំនងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស**

១-យោងតាមការសម្របសម្រួលគ្នាទៅវិញទៅមក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាចផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសបាន លុះណាតែអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសមានកាតព្វកិច្ចរក្សាការសម្ងាត់ដូចគ្នា ដោយមិនគិតពីប្រភេទនៃអង្គភាពទាំងនោះ ។ សម្រាប់គោលបំណងនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គភាពទាំងនោះបាន ។

២-នៅពេលបានទទួលសំណើសុំព័ត៌មាន ឬ ការបញ្ជូនព័ត៌មានពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជាដៃគូនៅបរទេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវឆ្លើយតបតាមសំណើក្នុងដែនអំណាចនៃច្បាប់នេះ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២៦.– ការសម្របសម្រួលផ្ទៃក្នុង**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ស្ថាប័នអនុវត្តច្បាប់ ស្ថាប័នត្រួតពិនិត្យ ព្រមទាំងស្ថាប័នរាជរដ្ឋាភិបាលមាន សមត្ថកិច្ចផ្សេងទៀតដែលទទួលខុសត្រូវទប់ស្កាត់ ឬ ត្រួតពិនិត្យការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបង្កើតយន្តការអចិន្ត្រៃយ៍កម្រិតខ្ពស់រៀងៗខ្លួនសម្រាប់ :

ក-ធានាអំពីការផ្លាស់ប្តូរព័ត៌មាន និង ការសម្របសម្រួលរវាងអាជ្ញាធរទាំងនេះជាមួយសមាគមឯកជនដែលពាក់ព័ន្ធ

ខ-ផ្តល់ការណែនាំសម្រាប់ការអនុវត្តច្បាប់នេះ

គ-បង្កើតគោលនយោបាយសម្រាប់វិស័យផ្សេងៗ ដែលស្ថិតនៅក្នុងដែនកំណត់នៃការអនុវត្តច្បាប់នេះ ។

មុខងារនិងភារកិច្ចនៃយន្តការសម្របសម្រួលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

20/24

**មាត្រា ២៧.- ការកម្រិតការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលត្រូវមានវិធានការសមស្រប ដើម្បីកាត់បន្ថយចរាចរណ៍ និង ការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម និង លើកទឹកចិត្តឱ្យប្រើប្រាស់មធ្យោបាយទូទាត់មិនមែនសាច់ប្រាក់ ដែលជួយសម្រួលដល់ការសម្គាល់អត្តសញ្ញាណរបស់ភាគីដែលចូលរួម ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ២៨.- ទណ្ឌកម្មខាងវិន័យ**

ស្ថាប័នត្រួតពិនិត្យត្រូវដាក់ទណ្ឌកម្មខាងវិន័យ ទៅលើបុគ្គលរាយការណ៍ណាដែលមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃមាត្រា ៧ ដល់មាត្រា ១២ និងមាត្រា ១៦ នៃច្បាប់នេះ ។

ការប្រព្រឹត្តល្មើសដូចមានចែងនៅក្នុងកថាខណ្ឌខាងលើ ត្រូវរងទណ្ឌកម្មដូចខាងក្រោម :

-ការព្រមាន

-ការស្តីបន្ទោស

-ការហាមឃាត់ ឬ ដាក់កំហិតមិនឱ្យធ្វើប្រតិបត្តិការណាមួយ ឬ ក្នុងរយៈពេលមួយតាមការកំណត់របស់ស្ថាប័នត្រួតពិនិត្យ

-ការដកហូតអាជ្ញាប័ណ្ណប្រកបអាជីវកម្ម

-ការស្នើឱ្យដកហូតតំណែងមន្ត្រី ឬ នាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ទាំងនោះ

-ការផាកពិន័យ

-ការបញ្ជាឱ្យឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយ និង លទ្ធផលនៃការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម

-ប្តឹងទៅតុលាការ នៅពេលដែលការរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះ និង បទបញ្ជាទាំងឡាយមានភាពធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណជន និង ដល់សន្តិសុខជាតិ ។

**មាត្រា ២៩.– ទណ្ឌកម្មខាងព្រហ្មទណ្ឌ**

ដោយពុំទាន់គិតដល់បទល្មើសទាំងឡាយដែលមានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត :

-បុគ្គលណាដែលបដិសេធការផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័នត្រួតពិនិត្យ ដូចមានចែងក្នុងមាត្រា ៦ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ១ ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយសែនរៀល (១០០.០០០ រៀល) ដល់មួយលានរៀល (១.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលមិនបានធ្វើរបាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា ១២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល)ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ព័ត៌មាន ឬ បញ្ជូនរបាយការណ៍ដូចមានចែងនៅក្នុងមាត្រា ១៣ ឬ បុគ្គលណាដែលបានដឹងរឿង ហើយផ្តល់ព័ត៌មាន ឬ របាយការណ៍ល្មើសនឹងបទប្បញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មាន ដូចមានចែងក្នុងមាត្រា ១៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលបានរំលោភកាតព្វកិច្ចរក្សាការសម្ងាត់ ដូចមានចែងក្នុងមាត្រា ២៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៣០.– ការឃាត់ទុកនិងរឹបអូសទ្រព្យសម្បត្តិ**

ក្នុងករណីមានការចោទប្រកាន់អំពីបទល្មើសសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌនោះ ទ្រព្យសម្បត្តិទាំងឡាយដែលពាក់ព័ន្ធ ឬ សង្ស័យថាពាក់ព័ន្ធនឹងបទល្មើស អាចត្រូវបានឃាត់ទុកមិនឱ្យមានចលនាផ្ទេរប្តូរ រហូតដល់មានការសម្រេចជាស្ថាពរពីតុលាការ ។

ក្នុងករណីតុលាការបានសម្រេចផ្តន្ទាទោសអំពីបទល្មើសសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្មរួចហើយ ទ្រព្យសម្បត្តិទាំងនោះត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

ស្ថាប័នត្រួតពិនិត្យ ត្រូវដាក់ចេញនូវបទប្បញ្ញត្តិ បទបញ្ជា និង សេចក្តីណែនាំសម្រាប់ការអនុវត្តច្បាប់នេះ ជាពិសេសចំពោះ :

-ការសម្របសម្រួលព័ត៌មាន ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីស្រុះស្រួលគ្នាអំពីវិធានការទាំងឡាយ ដែលត្រូវប្រកាន់យកក្នុងការដាក់ទណ្ឌកម្មខាងវិន័យ ឬការបញ្ជូនទៅតុលាការចំពោះបទល្មើសទាំងឡាយដែលបានកើតឡើង

-ការសម្របសម្រួលរវាងស្ថាប័នត្រួតពិនិត្យផងគ្នា ដើម្បីដាក់ចេញបទប្បញ្ញត្តិ បទបញ្ជា និង សេចក្តីណែនាំដើម្បីអនុវត្តច្បាប់នេះ

-ការចេញបទបញ្ជា និង សេចក្តីណែនាំ ដើម្បីកំណត់តួនាទី និងភារកិច្ច និងសម្រាប់ការពារមន្ត្រី បុគ្គលិក ដែលបំពេញការងារដោយសុចរិតនៅក្នុងអង្គភាពស៊ើបការណ៍ហិរញ្ញ-វត្ថុ ការរក្សាការសម្ងាត់នៃព័ត៌មាន និងវិធាននៃការបើកចំហព័ត៌មាន ។

ស្ថាប័នត្រួតពិនិត្យ ត្រូវសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ណែនាំបុគ្គលរាយការណ៍ក្នុងការរៀបចំបង្កើតនូវកម្មវិធីទប់ស្កាត់ការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវ-កម្មស្របតាមមាត្រា ១៦ នៃច្បាប់នេះ និងរៀបចំដាក់ចេញនូវគំរូរបាយការណ៍នានាឱ្យស្របតាមរូបភាព និង ចរិតលក្ខណៈនៃបុគ្គលរាយការណ៍ទាំងនេះ ។

បទបញ្ជា និង សេចក្តីណែនាំដែលចេញដោយស្ថាប័នត្រួតពិនិត្យក្រោមច្បាប់នេះ អាចកែប្រែ ឬ ធ្វើវិសោធនកម្មក្នុងកាលៈទេសៈសមស្រប ឬ នៅពេលដែលមានការចាំបាច់ ។



23/24

**មាត្រា ៣២.–**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៣.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.០៧០៦.២៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខៈ ៧៥៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

4/24

# ច្បាប់

# ស្តីពី

# ភតិសន្យាហិរញ្ញវត្ថុ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៦០៩/០០៩

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនា-គារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីភតិសន្យាហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំ រដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់សិទ្ធិ និងកាតព្វកិច្ចដល់ភាគីពាក់ព័ន្ធនឹងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និងដាក់ចេញនូវវិធានការ ដើម្បីការពារសិទ្ធិទាំងនោះ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។

**មាត្រា ៤.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ភតិបតី** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិកៈ ។
- **ភតិកៈ** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។
- **ចលនវត្ថុ** : សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដី និងអគារ ។
- **រយៈពេល** : សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះភតិកៈត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។
- **ភតិសន្យា** : សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយ

ភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយ ដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យា ត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។

- **ភតិសន្យាបន្ត** : សំដៅដល់ប្រតិបត្តិការដែលចលនវត្ថុ ត្រូវបានជួលដោយភតិកៈដំបូង ត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូង នៅមានសុពលភាពដដែល ។

- **ភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬ ច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :

ក-ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ-ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីជួលឱ្យភតិកៈ ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :

ក- ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬ មិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬ ការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

ខ-ភតិកៈមាន ឬ ពុំមានជម្រើស ឬ ក្រោយមកទទួលយកជម្រើសថាទិញ ឬ បន្តជួលចលនវត្ថុ មួយរយៈពេលបន្ថែមទៀត ។

- **ការបង់ថ្លៃឈ្នួលជាមុន** : សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិកៈ នៅពេល ឬ មុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។

- **ប្រាក់ប្រាតិភោគ** : សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិកៈនិងត្រូវបានកាន់កាប់ដោយភតិបតី ដើម្បីធានាកាតព្វកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិ-សន្យាហិរញ្ញវត្ថុ ដោយពេញលេញ និងទៀងទាត់ ។

- **អ្នកផ្គត់ផ្គង់** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលភតិបតីទទួលចលន-

វត្ថុដែលត្រូវជួលឱ្យភតិកៈ ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬ ឱ្យជួល រួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្គត់ផ្គង់ ។

- **កិច្ចព្រមព្រៀងផ្គត់ផ្គង់** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ ។

- **កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់ ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

**មាត្រា ៥.-**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតីនិងភតិកៈ ហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសារការីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ ។

**មាត្រា ៦.-**

កិច្ចព្រមព្រៀងមួយដែលពេញលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែកិច្ចព្រមព្រៀងនោះ មានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម :

ក-ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ-ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ-កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ-ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

**មាត្រា ៧.-**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចមានចែងអំពីប្រាក់ប្រាតិភោគ ឬ ការបង់ថ្លៃឈ្នួលជាមុន ឬ ទាំងពីរ ។ សម្រាប់ភតិកៈ ប្រាក់ប្រាតិភោគ អាច ឬ មិនអាចទទួលបាននូវ

ចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬ អាចប្រើប្រាស់ ដោយភតិបតី ដូចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ក្នុងករណីដែលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនមានចែងអំពីការប្រើប្រាក់ប្រាតិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញនិងតាមពេលកំណត់ហើយ ។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលបានការប្រាក់ទេ ។ ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

**មាត្រា ៨.-**

បើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងថា ចលនវត្ថុត្រូវបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតី ឬ ជាកម្មវត្ថុនៃភតិសន្យាពីភតិបតី ស្លាកសម្គាល់ទាំងនោះមិនត្រូវដកចេញ ឬ ធ្វើឱ្យមើលមិនស្គាល់ ដោយជនណាម្នាក់ ក្រៅពីភតិបតី ឬ អ្នកតំណាងរបស់ភតិបតីនោះឡើយ ។

នៅពេលបានរកឃើញការខូចខាតណាមួយនៃស្លាកសម្គាល់ដែលបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬ បើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដូចដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត ។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រានេះឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្លាស់ប្តូរស្លាកសម្គាល់នោះ ក្រោយពីភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ ។

**មាត្រា ៩.-**

បើភតិបតី និងភតិកៈព្រមព្រៀងគ្នាសងតាមវិធីមិនមែនរូបិយវត្ថុ ដូចជាផលិតផលសេវាកម្ម ការដោះដូរជាវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទម្រង់មិនមែនរូបិយវត្ថុនោះ ត្រូវកំណត់តាមតម្លៃទីផ្សារ លើកលែងតែភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ឬយន្តការណាមួយផ្សេងពីនេះ ។

**មាត្រា ១០.-**

នៅក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈទទួលយកការប្រើប្រាស់ចលនវត្ថុ ក្នុងរយៈពេលយ៉ាងតិចបំផុត ០១ (មួយ) ឆ្នាំ ។ នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងនោះ ភតិកៈអាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុនោះ ។ ភតិបតីផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យភតិកៈប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ ។

## ជំពូកទី ៣
## សិទ្ធិ និងភារកិច្ចរបស់ភតិបតី

**មាត្រា ១១.-**

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានជួល លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬ ទៅឱ្យភាគីផ្សេងទៀត ។

**មាត្រា ១២.-**

ភតិបតីត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត តាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ១៣.-**

ភតិបតីត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុនោះ ដោយគ្មានលក្ខខណ្ឌ ។

**មាត្រា ១៤.-**

ភតិបតីត្រូវធានាយ៉ាងណាឱ្យភតិកៈបានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុ ដែលបានជួល ដោយគ្មានការរំខាន នៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណាភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៥.-**

ភតិបតីមិនទទួលខុសត្រូវចំពោះភតិកៈលើចលនវត្ថុឡើយ លើកលែងតែក្នុងករណីដែលភតិកៈបានទទួលរងការខាតបង់ ដោយសារការធ្វើអន្តរាគមន៍របស់ភតិបតី ក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ ។

**មាត្រា ១៦.-**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីមិនទទួលខុសត្រូវសងការខូចខាត ដែលបង្កដល់តតិយជន ដោយសារចលនវត្ថុដែលខ្លួនបានជួលឡើយ ។

**មាត្រា ១៧.-**

ក្នុងករណីដែលភតិកៈមិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីត្រូវមានសិទ្ធិបន្ថែមពីលើសិទ្ធិ ដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដូចតទៅ :

ក-ភតិបតីអាចទាមទារឱ្យភតិកៈបង់ថ្លៃឈ្នួលដែលមិនទាន់បានសង រួមទាំងការប្រាក់ និងការខូចខាត

ខ-ភតិបតីក៏អាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលនាអនាគតបាន អាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងអាចទាមទារយកចលនវត្ថុដែលបានជួលមកវិញ បើមានករណីណាមួយ ដូចខាងក្រោម :

-ភតិកៈមិនបានបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុក្នុងរយៈពេលពីរគ្រាជាបន្តបន្ទាប់

-ភតិកៈបំពានខណាមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងខកខានមិនបានដោះស្រាយបញ្ហា ក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីភតិបតី

-ភតិកៈមានអ្នកធានាដែលគ្មានសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយភតិកៈមិនបានរកអ្នកធានាជំនួសណាម្នាក់ ដែលភតិបតីអាចទទួលយកបាន ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ តាមការស្នើសុំឱ្យរកអ្នកធានាជំនួសជាលាយលក្ខណ៍អក្សរពីភតិបតី ។

-ភតិកៈគ្មានសាធនភាព ក្ស័យធន ត្រូវបានរំលាយ ឬ ទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

គ-ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបាន ឬ មិនត្រូវបានរំលាយ នៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច :

-ទាមទារយកចលនវត្ថុដែលបានផ្តល់មកកាន់កាប់វិញ ដោយមិនចាំបាច់ប្តឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើង ដោយគ្មានអំពើហិង្សា និង

-ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបានរាប់ទាំងចំណាយបន្ថែម បណ្តាលមកពីកំហុសរបស់ភតិកៈផង ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ អាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះ អាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះ បណ្តាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាត ដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរ-ញ្ញវត្ថុ ។

ឃ-បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការឱ្យភតិកៈ ប្រគល់ចលនវត្ថុផ្តល់នោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្តុតាងដែលបង្ហាញថា ភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែ ភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ បើនៅពេលក្រោយមកមានភស្តុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានផ្តល់មកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

**មាត្រា ១៨.-**

ភតិបតីមានសិទ្ធិតម្រូវឱ្យភតិកៈសងការខាតបង់ បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានផ្តល់ ។

**មាត្រា ១៩.-**

ភតិបតីអាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានផ្តល់ នៅគ្រប់អំឡុងពេលដែលភតិកៈកាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈ

ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរំលាយមុនពេលក៏ដោយ រហូតដល់ពេលដែលចលនវត្ថុនោះ ត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។

ប្រសិនបើភតិកៈត្រូវទិញ និងបង់ថ្លៃធានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញធានារ៉ាប់រងនេះទេ ហើយភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ ។

**មាត្រា ២០.-**

ចលនវត្ថុដែលបានជួល មិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិកៈទេ ក្នុងន័យនេះ នៅពេលដែលភតិកៈក្ស័យធន ម្ចាស់បំណុលទាំងឡាយរបស់ភតិកៈ រួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិកៈ តាមសេចក្តីសម្រេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ ។

**មាត្រា ២១.-**

ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម្យ៉ាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិកៈ ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈយល់ព្រមមិនទាមទារកាត់កងការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ ។

**មាត្រា ២២.-**

ក្នុងករណី ភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀត មិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមាន តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះ

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

11/1/6

Kol

## ជំពូកទី ៤

## សិទ្ធិ និងភារកិច្ចរបស់គតិករ

**មាត្រា ២៣.–**

គតិករមានកាតព្វកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានផ្គត់ បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ។ បើចលនវត្ថុដែលបានផ្គត់មិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ គតិករមានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារភ្នាមឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈនោះ ឬ រំលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុ ស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ តែមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាត ដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ ។

**មាត្រា ២៤.–**

ការយល់ព្រមទទួលចលនវត្ថុ អាចជាឯកសារឬអាចតាមរយៈមធ្យោបាយផ្សេងៗទៀត ដូចខាងក្រោម :

ក-ក្រោយពេលដែលគតិករបានពិនិត្យចលនវត្ថុ ដែលត្រូវផ្គត់នោះរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្រប តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ

ខ-គតិករមិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និងអ្នកផ្គត់ផ្គង់ ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលា ក្រោយពេលបានទទួលដំណឹងនោះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គ-កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា គតិករត្រូវបានចាត់ទុកថា

បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈ ដែលមានរាយលម្អិតពីមូលហេតុច្បាស់លាស់ក្នុងរយៈពេលកំណត់ដប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីភតិកៈបានទទួលចលនវត្ថុនោះ ។

**មាត្រា ២៥.-**

តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិកៈ បានយល់ព្រមទទួលចលនវត្ថុជាផ្លូវការហើយ ។

**មាត្រា ២៦.-**

ភតិកៈ ត្រូវប្រើប្រាស់ចលនវត្ថុឱ្យបានត្រឹមត្រូវ តាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់វិធាន និងបទបញ្ញាជាធរមាន និងតាមលក្ខណៈបច្ចេកទេស ។ ភតិកៈក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ២៧.-**

នៅដំណាក់កាលផុតរយៈពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិកៈត្រូវប្រគល់ចលនវត្ថុដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណៈដូចដើម លើកលែងតែការសឹករេចរឹលធម្មតា ។

**មាត្រា ២៨.-**

ភតិកៈ ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុ ដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ ។

**មាត្រា ២៩.-**

ភតិកៈមិនត្រូវដាក់ជាហ៊ីប៉ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុក ចលនវត្ថុដែលបានជួល ឬ ធ្វើឱ្យមានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ ។

**មាត្រា ៣០.-**

ភតិក: មានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ៣១.-**

កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិក: ផងដែរ ប្រៀបដូចជាភតិក:ជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួល ហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិក: ។ ប៉ុន្តែអ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការ:មួយចំពោះភតិក:ផង និងភតិបតីផងនោះទេ ។

សិទ្ធិរបស់ភតិក: នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិក:បានយល់ព្រម ហើយមិនត្រូវបានប៉ះពាល់ ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិក:បានយល់ព្រមលើការកែប្រែនោះ ។

**មាត្រា ៣២.-**

ភតិក:មិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុ ដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី ត្រូវចាត់ទុកជាមោឃ: និងត្រូវបានចាត់ទុកថា ល្មើសច្បាប់នេះ និងច្បាប់ផ្សេងទៀត ។

## ជំពូកទី ៥

## អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ជា

**មាត្រា ៣៣.-**

ធនាគារជាតិនៃកម្ពុជា បំពេញតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថាន ភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងតួនាទីនេះ ធនាគារជាតិនៃកម្ពុជា :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១-ចេញ ល្បូរ ឬ ដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និង កំណត់នីតិវិធីនិងបែបបទនានាអំពីការចេញអាជ្ញាបណ្ណនេះ ។

២-ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់ច្បាស់ជាអាទិ៍នូវ :

ក-កម្រិតដើមទុនអប្បបរមា

ខ-អនុបាតប្រុងប្រយ័ត្នផ្សេងៗ

គ-ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសំវិធានធន

ឃ-ប្រព័ន្ធគណនេយ្យ និងបទដ្ឋានដែលពាក់ព័ន្ធ ។

៣-ត្រួតពិនិត្យ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ ជាអចិន្ត្រៃយ៍លើឯកសារ និងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ ដល់ទីកន្លែងនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

៤-អាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៤.–**

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការទាំងនេះក៏អាចអនុវត្តបានផងដែរ ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ធនាគារ ក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

## ជំពូកទី ៦
## ទណ្ឌកម្ម

**មាត្រា ៣៥.-**

ប្រសិនបើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬ មិនបានធ្វើតាមការដាស់តឿន ឬ មិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចដាក់ទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

-ព្រមាន

-ស្តីបន្ទោស

-ហាមធ្វើប្រតិបត្តិការមួយចំនួន និងកំណត់ព្រំដែនសកម្មភាព

-ល្បូរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-តម្រូវឱ្យលាឈប់ពីការងារជាស្វ័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-ដាក់ឱ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់

-ដកហូតអាជ្ញាបណ្ណជាស្ថាពរ និងការដាក់ឱ្យជម្រះបញ្ជីជាបន្ទាន់ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦.-**

គ្រឹះស្ថានណាដែលកំពុងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានទីតិសម្បទា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ទៅអាជ្ញាធរអាណាព្យាបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៨

# អវសានប្បញ្ញត្តិ

**មាត្រា ៣៧.–**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៦.៦៤០ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ :៦៦៥ ច.ល

**ប្រជុំថតចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជំនកេន**

17/17

ធ៧-៩៧-១៤៧ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

*ធ្វើវិសោធនកម្មដោយច្បាប់ ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ធ៩-៩៨-៤១៤ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់ក្នុងស្រុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ៧-០១-១៣៧ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ ធ៧-០៥-៥៤ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥ ស្តីពី គោលនយោបាយ ឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន ប្រកាស ធ៧-០៦-២១០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាស ស្តីពី សោហ៊ុយបង្កើនដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ ធ៧-០៦-២២៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ៧-០១-១៨៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី អចលនទ្រព្យរបស់ធនាគារ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ ប្រកាសលេខ ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។*

## ជំពូក១
## អំពីដើមទុន

**ប្រការ ១**.-

ដើមទុនរបស់គ្រឹះស្ថានត្រូវបានកំរិតដូចខាងក្រោម

១.១ : (ផុតកំណត់)

១.២ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ជាពិសេសប្រការ ៧ និង ប្រការ ៨)

១.៣ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ប្រកាសលេខ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

១.៤ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

១.៥ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

**ប្រការ ២**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១។

**ប្រការ ៣**.-

ដើមទុនក្នុងលក្ខន្តិកៈរបស់គ្រឹះស្ថានអាចត្រូវសុំបង្កើន ឬបន្ថយបាននៅក្រោមលក្ខខណ្ឌដែលត្រូវ ៖

៣.១ ត្រូវបានជំនួសដោយប្រកាស លេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

៣.២ ករណីបង្កើន :

(ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៧-០៦-២១០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦)

រាល់ការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។

ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួន សូន្យក្បៀសសូន្យបីភាគរយ (0,0៣%) លើចំនួនប្រាក់ដែលសុំបង្កើន។

៣.៣ ករណីបន្ថយ : ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

**ប្រការ ៤**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ៥**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និងធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០។

## ជំពូក២
## អំពីអាជ្ញាប័ណ្ណប្រកបអាជីវកម្ម

**ប្រការ ៦**.- អ្នកបង្កើតគ្រឹះស្ថានត្រូវបំពេញបែបបទជា ៣ ដំណាក់កាល ៖

៦.១ ដំណាក់កាលទី១ : ការផ្តល់ព័ត៌មាន និងណែនាំលក្ខខណ្ឌនៃសំណុំបែបបទ ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០០០ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

៦.២ ដំណាក់កាលទី២ : ការចេញលិខិតអនុញ្ញាតជាគោលការណ៍

៦.២.១ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវបានធនាគារជាតិនៃកម្ពុជាចេញឱ្យបន្ទាប់ពីការសិក្សាសំណុំបែបបទឃើញមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីបង្កលក្ខណៈឱ្យផ្ទេរដើមទុនមកធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំទីស្នាក់ការ និងរៀបចំដំណើរការដោយអនុលោមទៅតាមរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងនោះ។

៦.២.២ ក្នុងករណីដែលសាមីគ្រឹះស្ថានកំពុងផ្តើមបង្កើតមិនអាចដំណើរការបាននៅក្នុងកាលកំណត់នៃលិខិតអនុញ្ញាតជាគោលការណ៍នោះទេ ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ៥.០០០.០០០.០០ (ប្រាំលាន)

រៀលក្នុងមួយថ្ងៃដែលយឺតយ៉ាវនៅក្នុងរយៈពេល ៣០ថ្ងៃ ហើយបើនៅតែអនុវត្តមិនបាន លិខិតអនុញ្ញាតជាគោលការណ៍នោះត្រូវទុកជាមោឃៈ។

៦.៣ ដំណាក់កាលទី៣ : ការចេញអាជ្ញាប័ណ្ណប្រកបអាជីវកម្ម ៖

៦.៣.១ អាជ្ញាប័ណ្ណនេះត្រូវបានចេញជាផ្លូវការឱ្យសាមីគ្រឹះស្ថាន បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថារាល់លក្ខខណ្ឌក្នុងលិខិតអនុញ្ញាតជាគោលការណ៍ និងសំណុំបែបបទត្រូវបានបំពេញសព្វគ្រប់ហើយ។

៦.៣.២ និង ៦.៣.៣ ត្រូវបានជំនួសដោយប្រកាស លេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

៦.៣.៤ អាជ្ញាប័ណ្ណប្រកបអាជីវកម្មអាចត្រូវបន្តឡើងវិញបានលុះណាតែសាមីគ្រឹះស្ថានបានដាក់មកនូវសំណុំបែបបទដែលនៅខ្វះ ឬដែលអស់តម្លៃប្រើការបាន ឬ/និងបានធ្វើនិយ័តកម្មលើភាពមិនប្រក្រតីទាំងអស់របស់ខ្លួន។ ក្នុងករណីបំពេញលក្ខខណ្ឌទាំងនេះមិនបាន ត្រូវរងការផាកពិន័យជាប្រាក់ ចំនួន ១.០០០.០០០.០០ (មួយលាន) រៀលក្នុងមួយថ្ងៃ ដែលយឺតយ៉ាវដោយគិតបន្ទាប់ពីថ្ងៃសុពលភាពចុងក្រោយនៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មដែលពាក់ព័ន្ធរហូតដល់ពេលណាអាចបន្តឱ្យបាន។

**ប្រការ ៧**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃ១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃ១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ និងប្រកាស ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤។

## ជំពូក៣
## អំពីអាជ្ញាប័ណ្ណប្រកបអាជីវកម្ម

**ប្រការ ៨**.-

៨.១ ជំនួសដោយប្រកាស ធ៧-០៦-២២៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៨.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនអាចផ្តល់ឥណទាន (រាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខាគ្រប់ប្រភេទ)ឱ្យទៅ:

៨.២.១: ភាគទុនិក-សមាជិកក្រុមប្រឹក្សាភិបាល និងនាយកចាត់ការរបស់ខ្លួន (ជំនួសដោយប្រកាស ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ត្រង់ប្រការ ៤៩ និង៥០ និង ធ៧-០១-១៣៧ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ

៨.២.២: មុខសញ្ញាប្រើប្រាស់ ដើម្បីបង់ជំរះភាគកម្មក្នុងការបង្កើតគ្រឹះស្ថានមួយ ឬច្រើនទៀត

៨.២.៣: មុខសញ្ញាប្រើប្រាស់ក្រៅប្រទេស

៨.២.៤: មុខសញ្ញាប្រើប្រាស់ក្នុងប្រទេស ប៉ុន្តែសំអាងលើទ្រព្យដាក់បញ្ចាំដែលនៅក្រៅប្រទេសឡើយ។

៨.៣ ជំនួសដោយប្រកាស ធ៧-០៥-៥៤ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ស្តីពី គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាច ផ្តល់ឥណទាន។

៨.៤ ជំនួសដោយ ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ត្រង់ជំពូក១០: ភាគកម្មរបស់គ្រឹះស្ថានចំណុះច្បាប់នេះក្នុងដើមទុននៃក្រុមហ៊ុនពាណិជ្ជកម្មដទៃទៀត។

## ជំពូក៤
## អំពីការកាន់កាប់អចលនទ្រព្យ

**ប្រការ៩, ១០ និង១១**.-

ត្រូវបានជំនួសដោយប្រកាស ធ៧-០១-១៨៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ១២**.-

អគ្គនាយកដ្ឋាន អធិការដ្ឋានផ្ទៃក្នុង ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា មានភារកិច្ចរៀងៗខ្លួនអនុវត្តយ៉ាងម៉ឺងម៉ាត់តាមប្រកាសនេះ។

**ប្រការ ១៣**.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ចៅ ម៉េងលាត**

ធ៧-០៨-១៩៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និង លក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីអប្បបរមា និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹស្ថាះធនាគារ។ ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីសមត្ថភាពធ្វើប្រតិបត្តិការ របស់បុគ្គលស្នើសុំ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យបានស្របតាមការងារដ៏រលូននៃប្រព័ន្ធធនាគារ ដើម្បីផ្តល់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់សាធារណជន។ ពាក្យស្នើសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ដែលមិនត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះ នឹងត្រូវបដិសេធជាលាយលក្ខអក្សរ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារត្រូវគ្រប់គ្រងដោយបុគ្គលយ៉ាងតិចចំនួនពីររូប ដែលមានភាពសុចរិត និងគុណវុឌ្ឍិ និងមានបទពិសោធន៍សមស្របលើប្រតិបត្តិការធនាគារ។

**ប្រការ ៣**.-

ភាគទុនិកមួយ ឬច្រើន ត្រូវមានភស្តុតាងបង្ហាញថាមានបទពិសោធន៍ក្នុងសកម្មភាពដែលគ្រឹះស្ថានធនាគារមានបំណងធ្វើប្រតិបត្តិការ។

**ប្រការ ៤**.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវមានបុគ្គលិកគ្រប់គ្រាន់ និងមានជំនាញសមស្រប។ ធនធានបច្ចេកទេសរួមទាំងប្រព័ន្ធព័ត៌មានត្រូវមានប្រសិទ្ធភាព និងអាចជឿជាក់បាន ជាពិសេសប្រព័ន្ធសុវត្ថិភាពនៃប្រតិបត្តិការជាមួយសាធារណជន។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអាចឱ្យគ្រឹះស្ថានធនាគារ ៖

- ធានាបានថាប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំង នីតិវិធី ប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងការអនុវត្តធុរកិច្ច និងស្តង់ដារជាទូទៅ
- ធានាការប្រតិបត្តិតាមកម្រិតកំណត់ដែលបានដាក់ចេញចំពោះហានិភ័យ ជាពិសេសហានិភ័យសមភាគី ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់
- ធានាគុណភាពរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ភាពឋិតថេរផ្នែកហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារក្នុងរយៈពេលច្រើនឆ្នាំខាងមុខ ត្រូវបង្កើតឱ្យបានគ្រប់គ្រាន់តាមរយៈផែនការអាជីវកម្ម ការសិក្សាទីផ្សារ និងការសាកល្បងហិរញ្ញវត្ថុ (financial simulations) រួមទាំង ការធ្វើសេណារីយ៉ូសាកល្បង (stress scenarios) បើចាំបាច់។ ការសាកល្បងហិរញ្ញវត្ថុ ត្រូវមានសូចនាករ ដែលទទួលស្គាល់ជាទូទៅប្រើប្រាស់ក្នុងការវិភាគហិរញ្ញវត្ថុ និង បទដ្ឋានប្រុងប្រយ័ត្ន។

**ប្រការ ៧**.-

មាត្រា ១ នៃប្រកាសលេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ ត្រូវជំនួសដោយប្រការដូចខាងក្រោម ៖

"ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពល យ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០ រៀល (ហាសិបពាន់លានរៀល)។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិនដែលជា ឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ រៀល (មួយរយ ហាសិបពាន់លានរៀល)។"

**ប្រការ ៨**.-

មាត្រា ៤ នៃប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ ត្រូវជំនួសដោយប្រការដូចខាងក្រោម ៖

"ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ រៀល (ដប់ពាន់លានរៀល)។ ចំពោះធនាគារឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជា ឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ រៀល (សាមសិបពាន់លានរៀល)។"

**ប្រការ ៩**.-

នីតិវិធី និងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

**ប្រការ ១០**.-

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬ ទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-០៩-២៣០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

# សម្រេច

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ ដែលកំពុងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២**.-

និយមន័យ៖

១- **រូបិយវត្ថុ** សំដៅដល់ប្រាក់រៀលដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

២- **រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុបរទេសឬមធ្យោបាយទូទាត់ជារូបិយវត្ថុបរទេស ។

៣-**អាជីវកម្មប្តូរប្រាក់** សំដៅដល់ការ ទិញ-លក់ ប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណនានា ឬការទិញ-លក់រូបិយប័ណ្ណមួយជាមួយនឹងរូបិយប័ណ្ណផ្សេងៗទៀត។

**ប្រការ ៣**.-

ប្រតិបត្តិការដែលជាសកម្មភាពប្តូរប្រាក់ រួមមាន៖

- ទិញ និងលក់ក្រដាសប្រាក់ជារូបិយប័ណ្ណ
- ទិញមូលប្បទានប័ត្រទេសចរណ៍ ។

**ប្រការ ៤**.-

១- បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្តូរប្រាក់ត្រូវតែសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

២- បុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ច និងសិទ្ធិ ដូចតទៅ៖

ក- ត្រូវមានដើមទុនអប្បបរមាចំនួន ៨០.០០០.០០០រៀល (ប៉ែតសិបលានរៀល) តម្កល់នៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ដោយទទួលកម្រៃការប្រាក់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា

ខ- មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា

គ-មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយប័ណ្ណក្លែងក្លាយ។

**ប្រការ ៥**.-

១- ពាក្យសុំអាជ្ញាប័ណ្ណត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- នាមករណ៍យីហោ និងអាសយដ្ឋានធ្វើអាជីវកម្ម

ខ- លិខិតបង់ប្រាក់តម្កល់ដើមទុន

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២- ពាក្យសុំលិខិតអនុញ្ញាតត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវៈ

ក- ឈ្មោះ និងទីលំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យសុំ

ខ- ទីតាំងធ្វើអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរខណ្ឌ ឬស្រុក និង

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

១-ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យលើពាក្យស្នើសុំក្នុងរយៈពេល៤៥ថ្ងៃគិតពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញហើយអាចចេញអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតឬបដិសេធពាក្យស្នើសុំនោះ។

២- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតមិនអាចផ្ទេរឬប្តូរឈ្មោះបានឡើយ។

៣- អាជ្ញាប័ណ្ណមានសុពលភាពរយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។

៤- លិខិតអនុញ្ញាតមានសុពលភាពរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។

**ប្រការ ៧**.-

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោមៈ

ក- សោហ៊ុយដាក់ពាក្យសុំអាជ្ញាប័ណ្ណចំនួន ១០០.០០០(មួយរយពាន់រៀល)។

ខ- សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ១.២០០.០០០រៀល (មួយលានពីររយពាន់រៀល) ដែលត្រូវបង់នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

គ- ក្នុងរយៈពេល៣០ថ្ងៃមុនអាជ្ញាប័ណ្ណអស់សុពលភាពអ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណជាថ្មី។

ឃ-ក្នុងករណីមិនបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទាន់ពេលវេលាអ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន២០.០០០រៀល (ម្ភៃពាន់រៀល)ក្នុងមួយថ្ងៃ។ ប្រសិនបើអាជ្ញាប័ណ្ណអស់សុពលភាពរយៈពេល៣០ថ្ងៃ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំជាថ្មីឡើយ។

២- អ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោមៈ

ក- សោហ៊ុយដាក់ពាក្យសុំលិខិតអនុញ្ញាតចំនួន ១០០.០០០រៀល (មួយរយពាន់រៀល)

ខ- សោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំចំនួន ២០០.០០០រៀល (ពីររយពាន់រៀល)

គ- ក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព អ្នកកាន់លិខិតអនុញ្ញាតត្រូវដាក់ពាក្យសុំបន្តជាថ្មី។

៣- ចំពោះបុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណ សោហ៊ុយនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដំណាច់ឆ្នាំ។

៤- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់។

៥- ក្នុងករណីមានទីតាំង ឬអាសយដ្ឋានធ្វើប្រតិបត្តិការច្រើនកន្លែង ទីតាំងធ្វើប្រតិបត្តិការនីមួយៗត្រូវតែមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ហើយមិនត្រូវប្រកបអាជីវកម្មប្តូរប្រាក់នៅទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋាន ឬទីតាំងដែលបានអនុញ្ញាតឡើយ។

៦- រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ទីតាំងធ្វើប្រតិបត្តិការ កម្មសិទ្ធិធ្វើអាជីវកម្ម ការបិទអាជីវកម្ម និងបើកទីតាំងថ្មី អាជីវករប្តូរប្រាក់ត្រូវតែជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃ

កម្ពុជា។ រាល់ការកែប្រែទាំងនេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការមុនពេលបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជាឡើយ។

**ប្រការ ៨**.-

១- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត៖

ក- ត្រូវលើកយីហោនៅកន្លែងអាជីវកម្មរបស់ខ្លួនដោយដាក់អក្សរ "ប្តូរប្រាក់" និងអាចដាក់បន្ថែមជាភាសាអង់គ្លេស "Authorized Money Changer"

ខ- ត្រូវដាក់បង្ហាញអាជ្ញាប័ណ្ណគ្រប់ពេលវេលាទាំងអស់នៅកន្លែងដែលងាយមើលឃើញនៅក្នុងបរិវេណដែលបានអនុញ្ញាត

គ- ត្រូវដាក់បង្ហាញឱ្យសាធារណជនឃើញច្បាស់ជាប្រចាំនូវតារាងអត្រា ទិញ-លក់ ប្រចាំថ្ងៃរវាងប្រាក់រៀលជាមួយប្រាក់ដុល្លារនិងរវាងប្រាក់ដុល្លារជាមួយនឹងរូបិយប័ណ្ណផ្សេងៗ

ឃ-ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាមុនពេលចាប់ផ្តើមធ្វើអាជីវកម្មប្តូរប្រាក់នៅទីតាំងថ្មី។

២- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតត្រូវគោរពតាមក្រមប្រតិបត្តិដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៩**.-

ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត បើអ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត៖

ក- ល្មើសនឹងខ្លឹមសារនៃប្រកាសនិងឧបសម្ព័ន្ធនៃប្រកាសនេះ

ខ- មិនសហការជាមួយធនាគារជាតិនៃកម្ពុជាឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យឬ អង្កេត

គ- បានប្រព្រឹត្តការក្លែងបន្លំនិងធ្វើការបំភ័ន្តដោយចេតនា

ឃ- ធ្វើវិច្ឆេទកម្មកេងយកចំណេញដោយការបំប៉ោងអត្រាប្តូរ

ង-ផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យសាធារណជនមានការយល់ច្រឡំ ឬបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល

ច-ល្មើសនឹងបទបញ្ញាពាក់ព័ន្ធនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ១០**.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះត្រូវទទួលរងទណ្ឌកម្មយោងតាមមាត្រា៧០ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ១១**.-

ប្រកាសលេខ ធ៩-៩៨-៣៩៣ ប្រក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវកម្មប្តូរប្រាក់ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងខ្លួន។

**ប្រការ ១៣**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

## ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០៩-២៣០ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

## ក្រមប្រតិបត្តិសម្រាប់អាជីវករប្តូរប្រាក់

### ១. ដែនអនុវត្ត

ក្រមប្រតិបត្តិនេះអនុវត្តចំពោះអាជីវករប្តូរប្រាក់ទាំងអស់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជីវករប្តូរប្រាក់ត្រូវគោរពតាមក្រមប្រតិបត្តិនេះជាអចិន្ត្រៃយ៍។

ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធរគ្រប់គ្រង និងត្រួតពិនិត្យដែលនៅក្រោមយុត្តាធិការនេះ អាជីវករប្តូរប្រាក់ត្រូវបានត្រួតពិនិត្យ និងត្រូវបានដាក់ពិន័យ ឬទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ បទប្បញ្ញត្តិនានា និងការមិនគោរពតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

បុគ្គលដែលធ្វើសកម្មភាពជាអាជីវករប្តូរប្រាក់ ត្រូវតែស្នើសុំការអនុញ្ញាត (អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត) ពីធនាគារជាតិនៃកម្ពុជាមុននឹងចាប់ផ្តើមធ្វើប្រតិបត្តិការប្តូររូបិយប័ណ្ណ។

### ២. ភារកិច្ចរបស់អាជីវករប្តូរប្រាក់

១- អាជីវករប្តូរប្រាក់ដែលបានទទួលអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ៖

ក- បោះពុម្ពសៀវភៅវិក័យប័ត្រឱ្យហើយជាស្រេច ដែលនៅលើវិក័យប័ត្រនោះត្រូវមានលេខរៀងឈ្មោះ នាមករណ៍ យីហោ អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង។ លេខរៀងនីមួយៗនៃវិក័យប័ត្រនេះត្រូវធ្វើជាពីរច្បាប់ដែលច្បាប់ដើមសម្រាប់អតិថិជន និងច្បាប់ចម្លងសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់។ អាជីវករប្តូរប្រាក់ត្រូវផ្តល់វិក័យប័ត្រឱ្យអតិថិជននូវរាល់ពេលធ្វើប្រតិបត្តិការ។

ខ- បោះពុម្ពសៀវភៅវិក័យប័ត្រពិសេសមួយទៀតសម្រាប់ការដកហូតប្រាក់ ឬមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ។ លេខរៀងនីមួយៗនៃវិក័យប័ត្រនេះត្រូវធ្វើជាបីច្បាប់ ដែលច្បាប់ដើមសម្រាប់អតិថិជនច្បាប់ចម្លងមួយសម្រាប់ផ្តល់ឱ្យធនាគារជាតិនៃកម្ពុជាដោយត្រូវភ្ជាប់ជាមួយក្រដាសប្រាក់ ឬមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ និងច្បាប់ចម្លងមួយទៀតសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់។

គ- មានបុគ្គលិកដែលមានសមត្ថភាពក្នុងការធ្វើវិក័យប័ត្រការកត់ត្រា និងធ្វើរបាយការណ៍ជូនធនាគារជាតិនៃកម្ពុជា។

២- ជាទូទៅ អាជីវករប្តូរប្រាក់ត្រូវតែប្រកាន់ខ្ជាប់នូវភាពសុចរិតផ្នែកវិជ្ជាជីវៈដោយមិនក្លែងបន្លំ ឬឆ្លៀតឱកាសពីការមិនយល់ដឹងរបស់អតិថិជនដើម្បីផ្តល់ប្រាក់ក្លែងក្លាយ ឬបន្លំក្នុងការគណនាចំនួនប្រាក់ដែលអតិថិជនត្រូវបានទទួលជាដើម។

### ៣.សកម្មភាពហាមឃាត់

ក្រៅពីសកម្មភាពប្តូរប្រាក់រូបិយប័ណ្ណ និងទិញមូលប្បទានប័ត្រទេសចរណ៍អាជីវករប្តូរប្រាក់មិនត្រូវធ្វើប្រតិបត្តិការដូចខាងក្រោម៖

- ផ្តល់សេវាផ្ទេរប្រាក់

- ជួញដូររូបិយប័ណ្ណដោយការទូទាត់មិនផ្ទាល់ដៃនៅក្នុងរយៈពេលជាក់លាក់នៅពេលអនាគត
- ជួញដូរមូលបត្រភាគហ៊ុន និងធ្វើជាជើងសាករដោយខ្លួនឯង ឬធ្វើក្នុងនាមអតិថិជន
- ទទួលប្រាក់បញ្ញើពីសាធារណជន
- ផ្តល់ឥណទានដល់សាធារណជន
- ផ្តល់មធ្យោបាយទូទាត់សងប្រាក់ដល់សាធារណជន
- ផ្សាយពាណិជ្ជកម្មណាមួយដែលធ្វើឱ្យសាធារណជនយល់ច្រឡំថាខ្លួនផ្តល់សេវាប្រតិបត្តិការខាងលើ
- ជួញដូរក្រដាសប្រាក់ក្លែងក្លាយ

រាល់សកម្មភាពដែលអនុវត្តដោយខុសច្បាប់ គឺជាបទឧក្រិដ្ឋ និងត្រូវបានហាមឃាត់មិនឱ្យធ្វើប្រតិបត្តិការហើយអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតជាផ្លូវការរបស់អាជីវករប្តូរប្រាក់នឹងត្រូវបានដកហូត។

## ៤.ការស្គាល់អតិថិជន

នៅពេលដំណើរការប្តូររូបិយប័ណ្ណអាជីវករប្តូរប្រាក់ត្រូវស្គាល់អតិថិជនឱ្យបានច្បាស់លាស់។ ការស្គាល់អតិថិជននេះត្រូវបានធ្វើឡើងតាមរយៈការតម្រូវឱ្យអតិថិជនផ្តល់លិខិតសម្គាល់ខ្លួនជាផ្លូវការដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅប្រទេស។ លិខិតសម្គាល់ខ្លួនទាំងនោះរួមមានអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងលិខិតសម្គាល់ខ្លួនជាផ្លូវការផ្សេងទៀតដែលមានបិទរូបថត។

ការសម្គាល់អត្តសញ្ញាណនេះនឹងត្រូវអនុវត្តចំពោះ ៖

- អតិថិជនដែលប្តូរប្រាក់លើសពី១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក)
- អតិថិជនដែលប្តូរប្រាក់មួយលើកៗមានចំនួនតិច ប៉ុន្តែញឹកញាប់ដោយគ្មានមូលហេតុច្បាស់លាស់។

ចំពោះអតិថិជនដែលធ្លាប់ធ្វើប្រតិបត្តិការជាធម្មតា និងមានកម្មវត្ថុប្តូរប្រាក់ច្បាស់លាស់ដូចជាសម្រាប់បង់ពន្ធ បើកប្រាក់បៀវត្ស ឬទិញកសិផល។ល។ ការសម្គាល់អត្តសញ្ញាណនេះអាចមានលក្ខណៈធូរស្រាលជាង។

ប្រសិនបើ អតិថិជនបដិសេធក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណណាមួយ អាជីវករប្តូរប្រាក់មានសិទ្ធិបដិសេធមិនធ្វើប្រតិបត្តិការបាន។

## ៥.ក្រដាសប្រាក់ក្លែងក្លាយ

ក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្មប្តូរប្រាក់ត្រូវពិនិត្យមើលក្រដាសប្រាក់ និងមូលប្បទានប័ត្រទេសចរណ៍ដែលបានបង្ហាញសម្រាប់ទិញដើម្បីកំណត់នូវអត្តសញ្ញាណក្លែងក្លាយ។ ប្រសិនបើអាជីវករប្តូរប្រាក់ពិនិត្យឃើញថាក្លែងក្លាយអាជីវករនោះត្រូវរក្សាទុករូបិយប័ណ្ណក្លែងក្លាយនោះ ហើយចេញជាវិក័យប័ត្រមួយឱ្យទៅអតិថិជនដោយបញ្ជាក់ប្រាប់អតិថិជនថាខ្លួននឹងបញ្ជូនក្រដាសប្រាក់/មូលប្បទានប័ត្រទេសចរណ៍មកធនាគារជាតិនៃកម្ពុជា។

អាជីវកម្មប្តូរប្រាក់ត្រូវពិនិត្យក្រដាសប្រាក់ដែលខ្លួនប្រគល់ទៅឱ្យអតិថិជនដើម្បីកំណត់អត្តសញ្ញាណ និងដកហូតក្រដាសប្រាក់ក្លែងក្លាយចេញពីក្នុងចរាចរណ៍។

ក្រដាសប្រាក់ក្លែងក្លាយត្រូវតែបញ្ជូនមកធនាគារជាតិនៃកម្ពុជាភ្លាមៗ ដោយភ្ជាប់ជាមួយវិក័យប័ត្រចម្លងមួយច្បាប់។ ច្បាប់ដើមត្រូវប្រគល់ឱ្យអតិថិជនច្បាប់ទីពីរត្រូវរក្សាទុកនៅក្នុងបញ្ជី និងច្បាប់ទី៣ត្រូវរក្សាទុកជាឯកសាររបស់អាជីវកម្មប្តូរប្រាក់។ វិក័យប័ត្រនេះត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់

អតិថិជន អាសយដ្ឋាន ប្រទេសកំពុងស្នាក់នៅ ប្រភេទអត្តសញ្ញាណប័ណ្ណ និងលេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទ និងទីកន្លែងដែលផ្តល់អត្តសញ្ញាណប័ណ្ណនោះ។

ប្រសិនបើ អតិថិជនព្យាយាមលក់ក្រដាសប្រាក់ក្លែងក្លាយជាច្រើន ឬបរិមាណតិចតួចតែច្រើនដង អាជីវករប្តូរប្រាក់ត្រូវរាយការណ៍ជាបន្ទាន់អំពីបុគ្គលនោះទៅអាជ្ញាធរមានសមត្ថកិច្ច និងទីស្នាក់ការកណ្តាល ឬសាខាធនាគារជាតិនៃកម្ពុជាដែលនៅជិតបំផុត។

កាបោះផ្សាយ ឬបោះផ្សាយឡើងវិញនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា និងការរួមគំនិតជួយសម្រួលការធ្វើចរាចរក្រដាសប្រាក់ក្លែងក្លាយគឺជាបទឧក្រិដ្ឋដែលនឹងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ និងត្រូវបានដកហូតអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មប្តូរប្រាក់។ ដូច្នេះ អាជីវករប្តូរប្រាក់ទាំងអស់ត្រូវធ្វើអាជីវកម្មរបស់ខ្លួនដោយប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវការពារការធ្វើចរាចរក្រដាសប្រាក់ និងមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ។

## ៦.ការប្រុងប្រយ័ត្ន និងកាតព្វកិច្ចរាយការណ៍: ការប្រឆាំងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អាជីវកម្មប្តូរប្រាក់ជាអ្នកចូលរួមយ៉ាងសកម្មក្នុងទីផ្សារប្តូរប្រាក់។ ដូច្នេះ អាជីវករប្តូរប្រាក់ត្រូវបានចាត់ទុកជាបុគ្គលរាយការណ៍នៅក្រោមច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងន័យនេះ អាជីវករប្តូរប្រាក់ត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តតាមបទប្បញ្ញត្តិ ដែលបានកំណត់នៅក្រោមច្បាប់នេះរួមមានកាតព្វកិច្ចសម្គាល់អត្តសញ្ញាណរបស់អតិថិជន រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការប្តូរប្រាក់ ដែលលើសពីកម្រិតដែលកំណត់ដោយអង្គភាពស៊ើបការហិរញ្ញវត្ថុ។

គោលបំណងនៃការតម្រូវឱ្យបំពេញកាតព្វកិច្ចទាំងនេះ គឺដើម្បីជួយឱ្យអាជីវករប្តូរប្រាក់ជៀសផុតពីការចូលរួមទាំងដោយចេតនា និងដោយអចេតនាក្នុងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលជាសកម្មភាពឧក្រិដ្ឋដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ។ ដូច្នេះ ដើម្បីប្រកបមុខរបរសុច្ចរិតជាពលរដ្ឋល្អ និងការពារខ្លួនផុតពីសកម្មភាពខុសច្បាប់ទាំងនេះ អាជីវករប្តូរប្រាក់ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមបញ្ញត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់។

នីតិវិធីក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនឹងត្រូវបានណែនាំបន្ថែមទៀតដោយអង្គភាពស៊ើបការហិរញ្ញវត្ថុ។

អាជីវករប្តូរប្រាក់ត្រូវផ្តល់របាយការណ៍ជារៀងរាល់ខែអំពីប្រតិបត្តិការ ទិញ-លក់ រូបិយប័ណ្ណតាមការកំណត់ដូចតទៅ៖

ក- ត្រូវធ្វើកំណត់ត្រាដោយបំពេញតាមតារាង១ នៃឧបសម្ព័ន្ធនេះនូវរាល់ប្រតិបត្តិការប្តូរប្រាក់

ខ- ត្រូវបំពេញតាមតារាង២ នៃឧបសម្ព័ន្ធនេះនូវរាល់ការប្តូរប្រាក់ដោយអតិថិជនណាម្នាក់ ដែលមានទឹកប្រាក់លើសពី ១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក) ឬការប្តូរប្រាក់ញឹកញាប់ដោយអតិថិជនណាម្នាក់ដែលមានទឹកប្រាក់សរុបលើសពី ១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក)។

របាយការណ៍អំពីប្រតិបត្តិការប្រចាំថ្ងៃរបស់អាជីវកម្មប្តូរប្រាក់ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងអង្គភាពស៊ើបការហិរញ្ញវត្ថុ) នៅក្នុងសប្តាហ៍ទីពីរ រៀងរាល់ខែបន្ទាប់។

## ៧.ការរក្សាទុកបញ្ជី និងកំណត់ត្រា

១- អាជីវកម្មប្តូរប្រាក់ត្រូវរក្សាទុកសៀវភៅចុះបញ្ជី និងកំណត់ត្រាឱ្យបានត្រឹមត្រូវស្របតាមកាតព្វកិច្ចគ្រប់គ្រងស្តង់ដារវិជ្ជាជីវៈ និងកាតព្វកិច្ចបទប្បញ្ញត្តិ និងគតិយុត្តិផ្សេងៗទៀត។

២- ការចុះបញ្ជី និងកំណត់ត្រាអំពីសកម្មភាពប្តូររូបិយប័ណ្ណគឺជាកាតព្វកិច្ច។

៣- អាជីវករប្តូរប្រាក់ដែលកាន់អាជ្ញាប័ណ្ណត្រូវមានសៀវភៅធំ (General Ledger) ដើម្បីកត់ត្រានូវរាល់សកម្មភាព ទិញ-លក់ រូបិយប័ណ្ណ។ សៀវភៅនេះត្រូវរក្សាទុកនៅកន្លែងប្រកបអាជីវកម្ម និងត្រូវអាចទៅរកបានដោយងាយក្នុងករណីមានការចុះត្រួតពិនិត្យដល់ទីកន្លែង។ កំណត់ត្រាដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជានៅពេលធ្វើការត្រួតពិនិត្យដល់ទីកន្លែងត្រូវមានដូចខាងក្រោម ៖

- ច្បាប់ចម្លងឯកសារជួញដូរប្រចាំថ្ងៃដែលរៀបតាមលំដាប់លេខរៀង និងកាលបរិច្ឆេទ
- ច្បាប់ចម្លងវិក័យប័ត្រដែលបានចេញឱ្យសម្រាប់ការដកហូតក្រដាសប្រាក់ និងមូលប្បទានប័ត្ររទេសចរណ៍ក្លែងក្លាយ
- ច្បាប់ចម្លងរបាយការណ៍ប្រតិបត្តិការសង្ស័យដែលបានផ្ញើជូនធនាគារជាតិនៃកម្ពុជា។

កំណត់ត្រាទាំងអស់ត្រូវរក្សាទុកជាឯកសារ សម្រាប់រយៈពេល ៥ឆ្នាំ។

## ៨.ការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

ក្រុមការងារត្រួតពិនិត្យធនាគារជាតិនៃកម្ពុជា អាចចុះទៅត្រួតពិនិត្យដល់ទីកន្លែងរបស់អាជីវករប្តូរប្រាក់ដោយពុំចាំបាច់ជូនដំណឹងជាមុន។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវសហការដើម្បីសម្រួលដល់ដំណើរការនៃការត្រួតពិនិត្យ និងផ្តល់សៀវភៅចុះបញ្ជីកំណត់ត្រា និងឯកសារជាភស្តុតាងនៃប្រតិបត្តិការផ្សេងៗតាមការស្នើសុំរបស់ក្រុមត្រួតពិនិត្យ។

ប្រសិនបើ អាជីវកម្មប្តូរប្រាក់បង្អាក់ដំណើរការត្រួតពិនិត្យ ឬបដិសេធមិនសហការតវិយាបថបែបនេះនឹងត្រូវទទួលរងការពិន័យពីធនាគារជាតិនៃកម្ពុជា។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិការនេះ។

## ៩.ការបញ្ជាក់អំពីការទទួលយកក្រមប្រតិបត្តិ និងការសន្យាគោរពតាម

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

**ធនាគារជាតិនៃកម្ពុជា** តារាង១

# ទម្រង់នៃការចុះបញ្ជី
# រាល់ប្រតិបត្តិការប្តូររូបិយប័ណ្ណ

ឈ្មោះអាជីវកម្មប្តូរប្រាក់:............................................................................................................

| ថ្ងៃទីខែប្រតិបត្តិការ | ប្រភេទ និងចំនួននៃរូបិយប័ណ្ណ | | អត្រាប្តូរប្រាក់ |
|---|---|---|---|
| | ទិញ | លក់ | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

តារាង២

# ទម្រង់នៃការចុះបញ្ជី
# រាល់ប្រតិបត្តិការរូបិយប័ណ្ណ
# ដែលមានចំនួន ១០.០០០ ដុល្លារអាមេរិក ឬលើស

ឈ្មោះអាជីវកម្មប្តូរប្រាក់:........................................................................................................

| ថ្ងៃខែប្រតិបត្តិការ | ឈ្មោះអតិថិជន | សញ្ជាតិ | លេខអត្តសញ្ញាណប័ណ្ណ[១] | ចំនួនប្រតិបត្តិការ (បញ្ជាក់ថាតើចំនួនទិញ ឬលក់រូបិយប័ណ្ណ) | | អត្រាប្តូរប្រាក់ |
|---|---|---|---|---|---|---|
| | | | | ជារូបិយវត្ថុ | ជារូបិយប័ណ្ណ | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

[១] ក្នុងករណីជាអង្គភាពអាជីវកម្ម ត្រូវកត់ត្រានូវឈ្មោះអង្គភាពអាជីវកម្មនោះ និងឈ្មោះ សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់បុគ្គលដែលធ្វើប្រតិបត្តិការសម្រាប់ ឬក្នុងនាមជាអង្គភាពអាជីវកម្ម

ធ៩-០៩-២៦២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ

**ប្រការ ១**.-

ផ្តល់អាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនធ្វើអាជីវកម្ម នាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ តាមលក្ខខណ្ឌដូចខាងក្រោមៈ

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណដើម្បីប្រកបអាជីវកម្ម នាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ ត្រូវចុះបញ្ជីជាក្រុមហ៊ុនពាណិជ្ជកម្ម។

២-ពាក្យស្នើសុំរបស់ក្រុមហ៊ុនត្រូវភ្ជាប់ជាមួយនូវ :

ក) លិខិតបញ្ជាក់ចុះបញ្ជីពាណិជ្ជកម្ម

ខ) ឈ្មោះផ្លូវការរបស់តំណាងក្រុមហ៊ុន

គ) អាសយដ្ឋានរស់នៅ និងអាសយដ្ឋានប្រកបអាជីវកម្ម

ឃ) សម្មតិនាម ឬឈ្មោះពាណិជ្ជកម្ម

ង) លក្ខន្តិកៈក្រុមហ៊ុន

ច) លិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចស្តីពីការអនុញ្ញាតទីតាំងប្រកបអាជីវកម្ម

ឆ) ឯកសារផ្សេងៗទៀតតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា

៣- អ្នកដាក់ពាក្យស្នើសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០រៀល (មួយលានរៀល) និងសោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន២.០០០.០០០ រៀល (ពីរលានរៀល)។

**ប្រការ ២**.-

១- ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មានសិទ្ធធ្វើតែអាជីវកម្មទិញ-លក់ និងនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ប៉ុណ្ណោះ។

២- ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ ត្រូវប្រកបអាជីវកម្មនៅទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ និងត្រូវដាក់បង្ហាញជាសាធារណៈនូវឈ្មោះក្រុមហ៊ុន ឬផ្លាកយីហោរបស់ក្រុមហ៊ុន។

៣- រាល់ការនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ ត្រូវតែស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជានិងត្រូវបង់សាហ៊ុយ ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ក្នុងមួយប្រតិបត្តិការ។

**ប្រការ ៣**.-

អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃអាចត្រូវបានដកហូតវិញក្នុងករណីដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ និង បទប្បញ្ញត្តិនានា។

**ប្រការ ៤**.-

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាព ឬប្តូរទីតាំងធ្វើអាជីវកម្ម ក្រុមហ៊ុនសាមីត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយភ្ជាប់នូវសំណុំឯកសារពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ថ្ងៃជាមុន ដើម្បីជូនដំណឹងនិងសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

បុគ្គលណា ដែលប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ ដោយគ្មានអាជ្ញាប័ណ្ណ ឬគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

ប្រកាសលេខ ធ៩-៩៤-០១ ប្រក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវអនុវត្តភារកិច្ចតាមប្រកាសនេះរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់ត្ូ**

ធ៧-០០-០៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ

ធ្វើវិសោធនកម្មដោយប្រកាសៈ ធ៧-០៦-២០៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ផ្ទេរភាគហ៊ុនរបស់ធនាគារ និង ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តំកល់ធានាលើដើមទុន. ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១** .-

ធនាគារពាណិជ្ជ តទៅនេះហៅថាធនាគារ ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ។

**ប្រការ ២** .-

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណធនាគារត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយ ក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៣** .-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៨-១៩៣ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨)

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០,០០០,០០០,០០០ រៀល (ហាសិបពាន់លានរៀល)។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជន ឬក្រុមហ៊ុន ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ រៀល (មួយរយហាសិបពាន់លានរៀល)។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៤ .-**

ពាក្យសុំអាជ្ញាប័ណ្ណ[១] ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬ ជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបទប្បញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក. នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ. អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាក្នុងករណីជាក្រុមហ៊ុនបរទេស

គ. រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ. ប្រភេទមូលបត្រតំណាងឱ្យដើមទុន និងចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះ និងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង. ចំនួនដើមទុនដែលមានស្រាប់ ឬដើមទុនដែលបានគ្រោង ឬចំនួនដើមទុនដែលត្រូវបង់ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស។ ចំនួននេះយ៉ាងតិចបំផុតត្រូវស្មើនឹងចំនួនដើមទុនដែលមានចែងក្នុងប្រការ៣ នៃប្រកាសនេះ

ច. ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ. ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះ ត្រូវផ្តល់ព័ត៌មានដូចមាន រៀបរាប់ក្នុងប្រការ ៥ នៃប្រកាសនេះ

ជ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារ។ អ្នកចាត់ការដែលបានទទួលការតែងតាំងហើយខាងលើនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់នៅប្រការ ៦ នៃប្រកាសនេះ ហើយផ្តល់នូវលិខិតថ្កោលទោសមួយច្បាប់។ ចំពោះអ្នកចាត់ការជាជនបរទេសដែលមានលំនៅដ្ឋាននៅកម្ពុជាតិចជាងបីឆ្នាំ(៣ឆ្នាំ) លិខិតថ្កោលទោសនេះត្រូវជំនួសដោយឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមរបស់ខ្លួនដោយមានបញ្ជាក់ថាជនដែលមានពាក់ព័ន្ធមិនត្រូវបានហាមឃាត់មិនឱ្យចាត់ចែងការងារក្នុងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយតាមខ្លឹមសារនៃបទប្បញ្ញត្តិរបស់ប្រទេសនោះទេ។ អ្នកចាត់ការសាខាធនាគារបរទេសនៅកម្ពុជា ត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចនៅទីស្នាក់ការកណ្តាល។

ឈ. អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើ ត្រូវមានជីវប្រវត្តិ និង ត្រូវឆ្លើយសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៤ ព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថាគ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ) ហើយមានបញ្ជាក់ក្នុងជីវប្រវត្តិរបស់សមាជិកនោះ។

---

កំណត់សំគាល់:

[១] ត្រូវផ្ញើជូននូវលិខិតស្នើសម្រាប់សុំអាជ្ញាប័ណ្ណ (មាត្រា ១៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) សម្រាប់ប្រតិវេទន៍ (មាត្រា២៣) ឬសម្រាប់អនុញ្ញាត(មាត្រា២៤) ស្របតាមគំរូលិខិតដែលមានក្នុងឧបសម្ព័ន្ធទី ១។

ញ. ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការ ដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ។

ដ. ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ÷

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក(ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និងល័ក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំនិងទឹកប្រាក់មិនទាន់សង)
- ប្រភេទនិងទំហំនៃសេវាផ្សេងទៀតដែលផ្តល់ឱ្យអតិថិជន (គណនីសន្សំ ការផ្តល់មធ្យោបាយទូទាត់ ការគ្រប់គ្រងទ្រព្យសកម្មជាដើម)
- ប្រភេទអតិថិជន (ឯកជន ឯកត្តជន ក្រុមហ៊ុន អង្គការអន្តរជាតិ វិនិយោគិនជាស្ថាប័ន)ដែលធនាគារមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ÷ មូលនិធិផ្ទាល់បុរេប្រទានរបស់ភាគទុនិកៈ មូលប័ត្រឥណទេយ្យដែលអាចជួញដូរបាន ប្រាក់បញ្ញើពីសាធារណជនទូទៅ ប្រាក់កម្ចីលើទីផ្សារអន្តរធនាគារជាដើម
- ចំនួនប៉ាន់ស្មាននៃនិយោជិតក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ខាងមុខ និងបញ្ជីបើកបៀវត្ស ដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះការទាក់ទងអតិថិជន (ការបង្កើតសាខា) និងចំពោះទម្រង់ការគណនេយ្យនិងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីចំណេញ-ខាតសម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ)ខាងមុខ។ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបងៗ (ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា)នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឋ. ការត្រួតពិនិត្យផ្ទៃក្នុង៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- របៀបកំណត់កំរិតផ្ទៃក្នុងទៅលើប្រភេទហានិភ័យ និងទម្រង់ការផ្សេងៗសម្រាប់ធានាការអនុវត្តន៍ឱ្យបានត្រឹមត្រូវ
- នីតិវិធីដែលបានគ្រោងទុកសម្រាប់ធានាការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមសីលធម៌វិជ្ជាជីវៈ ពិសេសចំពោះប្រតិបត្តិការហិរញ្ញវត្ថុជាមួយអតិថិជន និងសម្រាប់រួមចំណែកក្នុងការប្រយុទ្ធប្រឆាំងការសំអាតប្រាក់
- សមាសភាព និងភារកិច្ចរបស់គណកម្មការត្រួតពិនិត្យបញ្ជី

ឌ. ការត្រួតពិនិត្យពីខាងក្រៅ

- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលត្រូវបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ

ឍ. ការត្រួតពិនិត្យរបស់ទីស្នាក់ការកណ្តាលឬក្រុមហ៊ុនដើម (សម្រាប់សាខាធនាគារបរទេស ឬ

បុគ្គលសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស)

- ពិពណ៌នាពីទម្រង់ការសម្រាប់ការត្រួតពិនិត្យសាខាឬបុគ្គលសម្ព័ន្ធរបស់ក្រុមហ៊ុនដើម
- ពិពណ៌នាពីការត្រួតពិនិត្យសាខាឬបុគ្គលសម្ព័ន្ធបរទេសរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម។

**ប្រការ ៥** .-

ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ(៥%)ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យសុំត្រូវផ្តល់ព័ត៌មានដូចតទៅ ៖

ក. អត្តសញ្ញាណរបស់ភាគទុនិកៈ ៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាន ទីស្នាក់ការកណ្តាលនិងលក្ខន្តិកៈ។ ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវធានាថាសមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ។ សម្រាប់គោលបំណងទាំងអស់នេះ បុគ្គលពាក់ព័ន្ធម្នាក់ៗ ត្រូវបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៤

ខ. បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់ លំអិតពីការសំរបសំរួលខាងគតិយុត្តិនិងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលប័ត្រ។ បើភាគទុនិកៈជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់ពីប្រភពដើមនៃដើមទុនវិនិយោគ។ បង្ហាញថាតើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែក ដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ. បញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ។ បើចាំបាច់ ត្រូវរៀបរាប់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនដើមនិងរបស់ក្រុមហ៊ុនហូលឌីងជាកណ្តាល (Intermediation holding companies) បង្ហាញនូវសមាមាត្រភាគហ៊ុននិងសិទ្ធិបោះឆ្នោត។ ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចាត់ការធំៗនៃអ្នកចូលហ៊ុន

ឃ. រៀបរាប់ពីសកម្មភាពរបស់ភាគទុនិកៈ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះ រួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគទុនិកៈមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថាតើក្រុមណាដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកៈមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទាន ឬទេ។ បើមានត្រូវរៀរាប់ឱ្យអស់

ង. ប្រាប់ថាតើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ។ បើមាន ត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ញាណា ឬ អាជ្ញាធរណា

ច. បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ

ឆ. បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬតុលាការនៅកម្ពុជាឬ

នៅបរទេសឬទេ។ ត្រូវរៀបរាប់ថា តើមានបានទទួលទណ្ឌកម្មណាមួយ ដោយសារការស៊ើបអង្កេត ឬទម្រង់ការឬទេ។ បញ្ជាក់ដែរថា តើភាគទុនិកៈជាកម្មវត្ថុ ឬអាចជាកម្មវត្ថុនៃទម្រង់ការរដ្ឋបាល យុត្តិធម៌ ឬជាមិត្តភាព នៅកម្ពុជាឬនៅបរទេសដែលអាចមានឥទ្ធិពលខាងសំភារៈទៅលើស្ថានភាព ហិរញ្ញវត្ថុរបស់ភាគទុនិកៈ នេះឬទេ

ជ. ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារ ដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ឈ. បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកដាក់ពាក្យសុំឬទេ ហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ញ. បញ្ជាក់ថាតើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកៈនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត

ដ. ផ្តល់គណនីនានារបស់ភាគទុនិកៈឬក្រុមហ៊ុនដើមរបស់ខ្លួន សម្រាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ ព្រមទាំងធ្វើការព្យាករណ៍សម្រាប់ឆ្នាំនេះ (រួមមានទាំងព័ត៌មានប្រចាប់បញ្ចូលគ្នាផង បើចាំបាច់)។ បើភាគទុនិកៈជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

**ប្រការ ៦** .-

បុគ្គលម្នាក់ក្នុងចំណោមពីររូប (២រូប) ដែលត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រង ដូចជាការទទួលខុសត្រូវក្នុងការដឹកនាំអាជីវកម្មធនាគារឱ្យមានប្រសិទ្ធភាពត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះ:[២] ដោយបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៤

ក. អត្តសញ្ញាណរបស់នាយកចាត់ការៈ

- នាម និងគោត្តនាម
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ
- អាសយដ្ឋានផ្ទាល់ខ្លួន(ត្រូវមានទីកន្លែងស្នាក់នៅក្រោយពេលបានទទួលការតែងតាំង បើមានការផ្លាស់ប្តូរ។ នាយកចាត់ការត្រូវមានកន្លែងស្នាក់នៅជិតកន្លែងសំខាន់សម្រាប់ធ្វើអាជីវកម្ម ដូចជានៅក្នុងប្រទេសកម្ពុជា)

ខ. គុណវុឌ្ឍិ និងបទពិសោធន៍ ៖

- សញ្ញាប័ត្រ ក៏ដូចជាថ្ងៃខែឆ្នាំនិងកន្លែងទទួលសញ្ញាប័ត្រ
- មុខតំណែងដែលបានកាន់កាប់ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ)ចុងក្រោយ ដោយមានឈ្មោះ ទីកន្លែង និងសកម្មភាពរបស់និយោជក ប្រភេទបទពិសោធន៍ទទួលបាននិងកំរិតទទួលខុសត្រូវ។

[២] ចំពោះការតែងតាំងនាយកចាត់ការ ធនាគារជាតិនៃកម្ពុជាត្រូវមានរាល់ព័ត៌មានទាំងអស់ដើម្បីអាចវាយតម្លៃពីកិត្តិនាម ភាពត្រឹមត្រូវ និងភាពថ្លៃថ្នូររបស់បុគ្គលដែលពាក់ព័ន្ធ។

គ. បញ្ជាក់ថា តើក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន នាយកចាត់ការនឹងចូលរួមសហការ ឬមានការ ព្រមព្រៀងជាមួយគ្រឹះស្ថានជាឯកត្តជនឬជានីតិបុគ្គលមួយផ្សេងទៀតក្រៅពីអ្នកដាក់ពាក្យសុំឬទេ។ ក្នុងករណីណាមួយ ក៏ត្រូវផ្តល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ។

ឃ. រៀបរាប់ពីភារកិច្ចគ្រប់គ្រង ដែលនាយកចាត់ការទទួលខុសត្រូវដោយផ្ទាល់។

ង. បញ្ជាក់ថា តើនាយកចាត់ការនៅជាឬធ្លាប់បានធ្វើជាភាគទុនិកៈសំខាន់(ដូចជាបានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតដប់ភាគរយ (១០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត) នៃក្រុមហ៊ុនណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំឬទេ។ ប្រសិនបើមានត្រូវ ប្រាប់ឈ្មោះនិងសកម្មភាពរបស់ក្រុមហ៊ុនចំនួនប្រាក់ និងភាគហ៊ុនរបស់ខ្លួនឬផលប្រយោជន៍ក្នុងក្រុមហ៊ុននោះ។

ច. ប្រាប់តាមការយល់ដឹងរបស់ខ្លួនថា តើក្រុមហ៊ុនណាខ្លះដែលខ្លួនបានកាន់កាប់តំណែងជាអ្នកទទួលខុសត្រូវឬក្នុងក្រុមហ៊ុនណាដែលខ្លួនជាភាគទុនិកៈសំខាន់ ឬដែលខ្លួនមានទំនាក់ទំនងអាជីវកម្មសំខាន់ជាមួយអ្នកស្នើសុំ។

ឆ. បញ្ជាក់ថា តើនៅកម្ពុជា ឬនៅបរទេស ខ្លួនធ្លាប់បានទទួលរងនូវទណ្ឌកម្មតាមនីតិវិធីវិជ្ជាជីវៈរដ្ឋបាល ឬតុលាការឬទេ។ ត្រូវរាយលំអិតនូវព័ត៌មានទាំងអស់ឱ្យបានសមស្រប។

ជ. បញ្ជាក់ថា តើខ្លួនធ្លាប់បានទទួលរងនូវវិន័យ ឬការបណ្តេញពីនិយោជកណាមួយដែរឬទេ។ បើមាន ត្រូវរាយលំអិតនូវព័ត៌មាន ដែលពាក់ព័ន្ធទាំងអស់។

ឈ.បញ្ជាក់ថា តើខ្លួនជាអ្នកផ្តល់ដើមទុនទៅឱ្យអ្នកស្នើសុំឬទេ ហើយតើខ្លួនមានបំណងអនុវត្ត ដោយផ្ទាល់ឬតាមរយៈអន្តរការី នូវសកម្មភាពប្រតិបត្តិការឯកត្តជនឬវិជ្ជាជីវៈជាមួយអ្នកស្នើសុំឬទេ។

ញ. ផ្តល់ព័ត៌មានបន្ថែមទាំងអស់ដែលអាចជួយបំភ្លឺដល់ធនាគារជាតិនៃកម្ពុជា។

ដ. រាល់ចម្លើយទាំងអស់ដែលទាក់ទងទៅនឹងសំនួរខាងលើ ត្រូវផ្ញើជូនតាមរយៈជីវប្រវត្តិ និងសំនួរក្នុងឧបសម្ព័ន្ធទី ៤ និងលិខិតស្របតាមគំរូលិខិតដូចមានក្នុងឧបសម្ព័ន្ធទី ២។

**ប្រការ ៧ .-**

ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោល យ៉ាងតិចបំផុតម្ភៃភាគរយ(២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពល ស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវផ្ញើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធ ទី៣ ទៅទេសាភិបាលធនាគារជាតិ នៃកម្ពុជា។

បទបញ្ញានេះអាចត្រូវដកចេញវិញបានតែនៅពេលមានការបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា។

## ជំពូក ទី ៣
## ការអនុម័តផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

**ប្រការ ៨** .-

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសំរេចរបស់ខ្លួន ក្នុងរយៈពេលប្រាំមួយខែ(៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើលិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេល និងការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៩** .-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៦-២០៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦)

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារពាណិជ្ជដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០** .-

អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួនបីលានប្រាំសែនរៀល (៣.៥០០.០០០ រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ។

**ប្រការ ១១** .- (ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤)

<u>សូមអានប្រកាសលេខ ធ៧-០៤-២០៥ ប្រក ចំពោះខ្លឹមសារលំអិត</u>

ធនាគារ និងសាខាធនាគារត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំនៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណ ធនាគារដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណនេះបាន ធនាគារសាមី ត្រូវរងទណ្ឌកម្មធ្ងន់ ជាងនេះទៀតរហូតដល់ ត្រូវដកហូតអាជ្ញាប័ណ្ណ។

## ជំពូកទី ៤
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១២** .-

ត្រូវបានជំនួសដោយ ប្រកាសធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១។

**ប្រការ ១៣ និង ១៤** .-

ត្រូវបានជំនួសដោយ ប្រកាសធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ១៥**.-

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឱ្យមានប្រសិទ្ធភាព ) ត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះ ទៅធនាគារជាតិនៃកម្ពុជា ÷

- អ្នកចាត់ការថ្មីត្រូវផ្ញើលិខិតស្របតាមគំរូដូចមានក្នុងឧបសម្ព័ន្ធទី ២ ផ្តល់ព័ត៌មានជូនទេសាភិបាលធនាគារជាតិនៃកម្ពុជាពីការតែងតាំងខ្លួនជាអ្នកចាត់ការ ហើយដោយមានបញ្ជាក់ពីមុខដំណែងរបស់ខ្លួនផង
- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)
- ព័ត៌មានដូចមានចែងនៅក្នុងប្រការ ៦ នៃប្រកាសនេះ
- ឯកសារទាំងអស់នេះត្រូវតែផ្តល់ឱ្យយ៉ាងហោចណាស់មួយខែ មុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង។

**ប្រការ ១៦** .-

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្ត ឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនិមួយៗត្រូវមានភ្ជាប់នូវព័ត៌មានដូចតទៅ ៖

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព ÷ ត្រូវផ្តល់ព័ត៌មានដែលមានកំណត់ក្នុងកថាខណ្ឌ ដ ប្រការ ៤ នៃប្រកាសនេះ
- ការបន្ថយដើមទុន ÷ ពិពណ៌នាពីខ្លឹមសារនិងល័ក្ខខណ្ឌដូចជាការសំរបសំរួលខាងគតិយុត្តិ និងខាងគណនេយ្យ ព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្ម ទៅអនាគត និងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត ÷ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈនិងព័ត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីវកម្ម ÷ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈ
- រាល់ការផ្លាស់ប្តូរទាំងអស់ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងតិចបំផុតបីខែ (៣ខែ) មុនពេលអនុវត្តដើម្បីសុំការយល់ព្រម

ធនាគារត្រូវបង់សោហ៊ុយចំនួនមួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិកៈដែលរងវិសោធនកម្ម។

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួនមួយភាគរយ (១%) លើចំនួនដែលបន្ថយ។

**ប្រការ ១៧** .-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៨** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថាន ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៩** .-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ឧបសម្ព័ន្ធ ១

# គំរូលិខិតស្នើសុំអាជ្ញាប័ណ្ណ(១) ធ្វើប្រតិវេទន៍(២) សុំការអនុញ្ញាត(៣) ដែលត្រូវផ្ញើជូន ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

---

ឯកឧត្តមជាទីគោរព

ក្នុងនាមជា ...............................................................(៤)

ខ្ញុំសូមដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីៈ

- ទទួលបន្តអាជ្ញាប័ណ្ណរបស់(ឈ្មោះក្រុមហ៊ុន) ដូចមាននៅក្នុងជំពូកទី IV នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ធ្វើប្រតិវេទន៍ពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មអនុប្បទានភាគទុនដូចមានក្នុងមាត្រាទី២៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- សុំការអនុញ្ញាតធ្វើលទ្ធកម្ម ឬអនុប្បទានភាគទុន ដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជាទីបញ្ចប់ ខ្ញុំសូមភ្ជាប់មកជាមួយនូវពាក្យសុំស្របតាមបញ្ញត្តិនៃប្រកាសលេខ .....

សូមឯកឧត្តមទេសាភិបាលទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

**ហត្ថលេខា**

---

(១) ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណ ឬសុំបន្តអាជ្ញាប័ណ្ណ

(២ )ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

(៣) ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្តីពី គ្រឹស្ថាៈនធនាគារនិងហិរញ្ញវត្ថុ

(៤)ផ្តល់គំរូហត្ថលេខារបស់ប្រធាន (Chairman) នាយកចាត់ការ មន្ត្រីដទៃទៀតដែលជាភ្នាក់ងារបានទទួល សិទ្ធិអំណាច (ភ្ជាប់ឯកសារភស្តុតាងមកជាមួយផង)។

ឧបសម្ព័ន្ធ ២

# គំរូលិខិត
# ផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ឯកឧត្តមជាទីគោរព**

យោងតាមការតែងតាំងនាយកធនាគារ (ឈ្មោះធនាគារ) ដែលខ្ញុំនឹងចូលកាន់តំណែង ជា (..........) ខ្ញុំសូមភ្ជាប់មកជាមួយនូវព័ត៌មាន (រួមមានប្រវត្តិសង្ខេបនិងសំនួរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤) តាមប្រការទី៦ នៃ ប្រកាសលេខ.........តម្រូវឱ្យមាន។

ខ្ញុំសូមធានាថាព័ត៌មានទាំងនេះពិតជាត្រឹមត្រូវ និងពេញលេញឆ្លើយតបទៅនឹងតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេស ខ្ញុំសូមធានាអះអាងថា ខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងមាត្រា ១៨ នៃច្បាប់ស្តីអំពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ្ញុំសូមសន្យាថានឹងផ្តល់ព័ត៌មានស្តីពីការប្រែប្រួលណាមួយដែលទាក់ទងទៅនឹងព័ត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកគ្រឹះស្ថានធនាគារ ខ្ញុំសូមធានាថានឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មាន ដែលទាក់ទងទៅនឹងការចាត់តាំងរដ្ឋបាល និងគណនេយ្យ ស្ថានភាពហិរញ្ញវត្ថុ ជាពិសេស ចំពោះគុណភាពនៃឥណទាន និងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់។

សូមឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

**ហត្ថលេខា**

ឧបសម្ព័ន្ធ ៣

**គំរូលិខិត**
**របស់ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ**
**ចំនួន២០%ច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ**
**ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

ឯកឧត្តមទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមភ្ជាប់មកជាមួយនូវព័ត៌មានទាំងឡាយតាមសំណើររបស់ធនាគារជាតិ នៃកម្ពុជាសុំ (តាមប្រកាសលេខ........) ទាក់ទងទៅនឹងការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិកៈ) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ) ។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មានទាំងនេះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ហើយថា តាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ព័ត៌មានយ៉ាងឆាប់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលខុសប្លែក យ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនហើយ។

ខ្ញុំបានកត់សម្គាល់ទៅលើបទប្បញ្ញត្តិប្រការ ៧ នៃប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះធនាគារជាតិនៃកម្ពុជាអាចបង្គាប់ឱ្យភាគទុនិកៈ មានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

សូមឯកឧត្តមទេសាភិបាលមេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

**ហត្ថលេខា**

Photo

4×6

**ឧបសម្ព័ន្ធទី ៤**

**ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី**

**ឯកត្តជន ឬ ជនដែលបម្រុងក្លាយទៅជា: គណៈនាយក ភាគទុនិក**

**នាយកចាត់ការ របស់ធនាគារពាណិជ្ជ**

# CURRICULUM VITEA

**and**

**Questionnaire for individual who are, or are proposing to become,**

**<u>Directors, Shareholders of Commercial Banks</u>**

1. គោត្តនាម

Family name.

------------------------------------------------------------------------

2. នាមខ្លួន

Given name (s).

------------------------------------------------------------------------

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

------------------------------------------------------------------------

4-1. សូមរៀបរាប់បំពេញលើគំរូនេះនូវនិតិសម្បទារបស់លោក, ឧទាហរណ៍ដូចជា: គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក, ភាគទុនិក ឬនាយកចាត់ការ ឬបុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

Please state in what capacity you are completing this form, **i.e.** as a current or prospective director, shareholder or manager or any combination of these.

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

4-2. សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈ តួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

4-3. ក្នុងការអនុវត្តន៍ភារកិច្ចរបស់អ្នក តើអ្នក និងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាត់បង្ហាញ របស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

4-4. សូមរៀបរាប់បើសិនជាអ្នក ជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

**5.** អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

**6.** អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុនៈ

Your previous private address(es) during the last 5 years.

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

8. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

9. ឈ្មោះ និងអាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល ៥ឆ្នាំ កន្លងមក

Name(s) and address(es) of your bankers within the last 5 years.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

10. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំ កន្លងមកដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនិមួយៗ ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the position held and relevant dates.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

11-2. សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other

than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

**11-3** សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

**12.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ, បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបាន ដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------

**13.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធ ជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវ គេធ្វើការស៊ើបអង្កេតដែរឬទេ , បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

**14.** តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ, បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

**15.** តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

**16.** តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស, នៅប្រទេសណា, តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ, បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

**17.** បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធ នឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

-------------------------------------------------------------- ----------------

**18.** សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**19.** សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**20.** បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ - តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ ៤-១. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យ ពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិតឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម):

***ចូរកត់សម្គាល់ឱ្យបានច្បាស់ថា*** : រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសំងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4.1? The omission of material facts may represent the provision of misleading information (see declaration below).
**N.B. (note well)** the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

## សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។ ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយ ចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

**DECLARATION**

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ
Name:

មុខងារ និងឋានៈដែលទទួលបន្ទុក
Position held:

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ
Signed: Date:……. /…….. / …….

ធ៧-០០-០៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ

ធ្វើវិសោធនកម្មដោយប្រកាស ធ៧-០៦-២០៨ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស, ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៤ ស្តីពីសោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ, ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ធនាគារឯកទេសឥណទានជនបទ តទៅនេះហៅថាធនាគារឯកទេស ដូចមានកំណត់និយមន័យក្នុងជំពូកទី១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ អនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ។

**ប្រការ ២.-**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើតែប្រតិបត្តិការណាដែលមានបញ្ជាក់ច្បាស់តាមខ្លឹមសារនៃលិខិតអនុញ្ញាត។

**ប្រការ ៣.-**

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសម្រាប់ធនាគារឯកទេស ត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៤.-**

(ជំនួសដោយ ប្រកាស ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨)

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ រៀល (ដប់ពាន់លានរៀល)។ ចំពោះធនាគារ ឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ រៀល (សាមសិបពាន់លានរៀល)។

នីតិវិធី និងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃ ប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៥.-**

ពាក្យសុំអាជ្ញាប័ណ្ណ ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬនាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ-ប្រភេទមូលប័ត្រតំណាងឱ្យដើមទុន។ ចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនផ្ទាល់ដែលបានអនុញ្ញាតនិងដែលបានបង់

ច- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិង កិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្ដល់ព័ត៌មានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារឯកទេស។ អ្នកចាត់ការដែលត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចត្រូវបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី២ ហើយ ត្រូវផ្ដល់នូវលិខិតថ្កោលទោស

ឈ-អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល និងដោយបន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ)

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគឺជាអង្គភាពដែលបានបង្កើតរួចហើយត្រូវផ្ដល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ចុងក្រោយ

ដ - ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ(៣ឆ្នាំ)ទៅមុខ ÷

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀតដែលត្រូវផ្ដល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់

គោលបំណង ខ្លឹមសារ និងល័ក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំ និង ទឹកប្រាក់មិនទាន់សង)

- ប្រភេទអតិថិជនដែលធនាគារឯកទេសមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ÷ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុល-បន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចី ជាដើម ហើយបើចាំបាច់ ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើត និងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ(បំណុលបន្ទាប់បន្សំជាដើម)
- ចំនួនប្រហាក់ប្រហែលនៃនិយោជិកក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ខាងមុខ និងបញ្ជីបើកបៀវត្ស ដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ទីតាំងសាខាដែលមានស្រាប់ឬដែលគ្រោងឱ្យមាន
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះទម្រង់ការគណនេយ្យ និងឧបករណ៍ កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញសម្រាប់ការិយបរិច្ឆេទគណនេយ្យ បីឆ្នាំ (៣ឆ្នាំ) ខាងមុខៗ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបងៗ(ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ)ខាងមុខ

ឋ- ការត្រួតពិនិត្យផ្ទៃក្នុង ÷

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះៗ

**ប្រការ ៦.-**

ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ(៥%) ឬ លើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកស្នើសុំ ត្រូវផ្តល់ព័ត៌មានដូចតទៅ ÷

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ÷

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិកៈៗ

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋានៗ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេៗ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេៗ បើមែនត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោតៗ រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្តនិងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលប័ត្រៗ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះ

នីតិវិធីដោយឡែក ដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះ ត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគទុនិកមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិក មានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ។ បើមានត្រូវរៀបរាប់ឱ្យអស់

ឃ- ប្រាប់ថា តើភាគទុនិកនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុ ឬទេ។ បើមានត្រូវបញ្ជាក់ថា ក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណា ឬ អាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិក

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬតុលាការឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកនិងអ្នកស្នើសុំឬទេ ហើយ តើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ- បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត។

**ប្រការ ៧.-**

ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ(២០%)នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជា តម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវធ្វើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា។

បទបញ្ជានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា អាចលើកលែងជាលាយលក្ខណ៍អក្សរ អនុញ្ញាតឱ្យរួចផុតពីការអនុវត្តន៍មាត្រា ៧ នៅពេលអនុម័តលើអាជ្ញាប័ណ្ណ។

## ជំពូកទី ៣
## ការអនុម័តផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសំរេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេល ណាមាន ការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវល័ក្ខខណ្ឌនិងរយៈពេលនៃការអនុវត្តន៍លិខិតអនុញ្ញាត។ ប្រសិនបើ អនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតនេះត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំ ពន្យារពេលនិងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៩.-**

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៦-២០៨ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦។

**ប្រការ ១០.-**

ត្រូវបានជំនួសដោយប្រកាស ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤។

**ប្រការ ១១.-**

ធនាគារឯកទេសត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំឱ្យបានមុនថ្ងៃទី១៥ ខែមករា ចំនួន [ ខ្លឹមសារ បញ្ជាក់បន្ថែមដោយ ប្រកាស ធ៧-០៤-២០៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ ] ចំពោះធនាគារដែលបានបង្កើតឡើងក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណធនាគារ ដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យ ដោយបង់ការប្រាក់លើទឹកប្រាក់ ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណនេះបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀត រហូតដល់ត្រូវដកហូត អាជ្ញាប័ណ្ណ។

## ជំពូកទី ៤
## បទបញ្ញាប្រុងប្រយ័ត្ន

**ប្រការ ១២.-**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដែលពុំធ្លាប់ធ្វើប្រិតិបត្តិការ ត្រូវបង់បង្គ្រប់ឱ្យពេញមួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ។

**ប្រការ ១៣.-**

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៦-២០៨ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦)

ធនាគារឯកទេស ដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុន ស្មើនឹងប្រាំភាគរយ(៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកំរៃការប្រាក់ ដូចខាងក្រោម ÷

ក.ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀល ទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២) នៃអត្រាការប្រាក់បុនហិរញ្ញប្បទានដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយៈពេល៦ខែម្តង។

ខ.ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកំរៃការប្រាក់បីភាគប្រាំបី (៣,៨) នៃអត្រា SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយៈពេល ៦ ខែម្តង។ ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងទៅធនាគារទាំងអស់ពីអត្រាការប្រាក់ ដែលបានអនុវត្ត សម្រាប់កាលកំណត់នីមួយៗ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះ នៅពេលធនាគារឯកទេសនោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម។

**ប្រការ ១៤.-**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវតំកល់ទុនបម្រុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ ទុនបម្រុងកាតព្វកិច្ចនេះ ត្រូវបានរក្សាទុកតាមល័ក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញាដោយឡែកស្តីពីទុនបម្រុងកាតព្វកិច្ច។

**ប្រការ ១៥.-**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណរួចហើយត្រូវអនុវត្តឱ្យបានសមស្របតាមបញ្ញតិទាំងអស់ដែលធនាគារត្រូវអនុវត្ត ពិសេសតម្រូវការនៃការធ្វើរបាយការណ៍។

## ជំពូកទី ៥
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១៦ និង ១៧.-**

ត្រូវបានជំនួសដោយ ប្រកាស ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ១៨.-**

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឱ្យមានប្រសិទ្ធិភាព ) ត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះទៅធនាគារជាតិនៃកម្ពុជា ÷

- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុម-ប្រឹក្សាភិបាល)
- ជីវប្រវត្តិនិងការបំពេញសំនួរក្នុងឧបសម្ព័ន្ធទី ២

ឯកសារទាំងអស់នេះ ត្រូវតែផ្តល់ឱ្យយ៉ាងហោចណាស់មួយខែមុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង។

**ប្រការ ១៩.-**

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនីមួយៗ ត្រូវមានភ្ជាប់នូវព័ត៌មានដូចតទៅ៖

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព៖ ត្រូវផ្តល់ព័ត៌មានដែលមានកំណត់ក្នុងកថាខណ្ឌ ដ ប្រការ ៥ នៃប្រកាសនេះ
- ការបន្ថយដើមទុន៖ ការពិពណ៌នាពីខ្លឹមសារនិងល័ក្ខខណ្ឌដូចជា ការសំរបសំរួលខាងគតិយុត្ត និងខាងគណនេយ្យព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្មទៅអនាគតនិងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត ៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈនិងព័ត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីវកម្ម៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈរាល់ការផ្លាស់ប្តូរទាំងអស់ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលអនុវត្តដើម្បីសុំការយល់ព្រម។

ធនាគារត្រូវបង់សោហ៊ុយចំនួនមួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិកៈដែលរងវិសោធនកម្ម។

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួនមួយភាគរយ (១%) លើចំនួនដែលបន្ថយ។

**ប្រការ ២០.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២១.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារឯកទេសនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២២.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ឧបសម្ព័ន្ធទី ១

# គំរូលិខិត
# របស់ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ ចំនួន២០% ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ឯកឧត្តមអគ្គទេសាភិបាលជាទីគោរព**

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវព័ត៌មានទាំងឡាយតាមសំណើរបស់ធនាគារជាតិ នៃកម្ពុជា (តាមលិខិតលេខ...........) ទាក់ទងដល់ការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិក) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ )។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មាននេះគ្រប់គ្រាន់និងត្រឹមត្រូវ ហើយតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះ ទៀតដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាផ្តល់ព័ត៌មានយ៉ាងឆាប់រហ័សជូនធនាគារជាតិនៃកម្ពុជានូវរាល់ការប្រែប្រួលណា ដែលធ្វើឱ្យប្លែក យ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនរួចមកហើយ។

ខ្ញុំបានធ្វើការកត់សម្គាល់ទៅលើបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែង ថានៅពេលណាស្ថានភាពតម្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចស្នើឱ្យភាគទុនិកដែលមានឥទ្ធិពលរបស់គ្រឹះស្ថាន ផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

ដោយសេចក្តីគោរព

**ហត្ថលេខា**

**ឧបសម្ព័ន្ធទី ២**

| |
|---|
| **Photo**<br><br>**4×6** |

**ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី**
**ឯកត្តជន ឬជនដែលបម្រុងក្លាយទៅជា: គណៈនាយក ភាគទុនិក**
**នាយកចាត់ការ របស់ធនាគារឯកទេស**

# CURRICULUM VITEA

**and**

**Questionnaire for individual who are, or are proposing to become,**

## Directors, Shareholders of Specialized Banks

1. គោត្តនាម

Family name.

---------------------------------------------------------------------------------------------------------------

2. នាមខ្លួន

Given name (s).

---------------------------------------------------------------------------------------------------------------

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

---------------------------------------------------------------------------------------------------------------

4-1. សូមរៀបរាប់បំពេញលើគំរូនេះនូវនិតិសម្បទារបស់លោក, ឧទាហរណ៍ដូចជា: គណៈនាយកបច្ចុប្បន្ន ឬ ជាអនាគតគណៈនាយក, ភាគទុនិក ឬ នាយកចាត់ការ ឬ បុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

Please state in what capacity you are completing this form, **i.e.** as a current or prospective director, shareholder or manager or any combination of these.

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

4-2. សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈ តួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

4-3. ក្នុងការអនុវត្តន៍ភារកិច្ចរបស់អ្នក តើអ្នកនិងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាត់បង្ហាញរបស់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

4-4. សូមរៀបរាប់បើសិនជាអ្នកជា អ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

5. អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

6. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុនៈ

Your previous private address(es) during the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

8. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

--------------------------------------------------------------------------------

--------------------------------------------------------------------------------

9. ឈ្មោះ និង អាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

Name(s) and address(es) of your bankers within the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

10. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមកដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនិមួយៗ ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the position held and relevant dates.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

11-2. សូមរៀបរាប់កាលពី១០ឆ្នាំមុនបើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមាន សូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះនិងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other

than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

**11-3** សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមាន ទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

**12.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ, បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបាន ដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

**13.**តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធ ជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួនធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ , បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**14.** តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ, បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**15.** តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**16.** តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស, នៅប្រទេសណា, តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះ អង្គភាពណាមួយឬសមាជិកណាម្នាក់ដែរឬទេ, បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**17.** បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធ នឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

----------------------------------------------------------------------------------------------------- --------------------------

**18.** សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

**19.** សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------

**20.** បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ - តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុង សំណួរ ៤-១. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យពិចារណា ឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិត ឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តី ប្រកាសដូចខាងក្រោម):

***ចូរកត់សម្គាល់ឱ្យបានច្បាស់ថា*** : រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសំងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4.1? The omission of material facts may represent the provision of misleading information (see declaration below).

**N.B. (note well)** the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

## សេចក្ដីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្ដល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។ ខ្ញុំបាទសូម បញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយ ចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវនិងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬ ផ្ទុយពីសេចក្ដីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាប នោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្ដល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ដែលត្រូវផ្លាស់ប្ដូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

**DECLARATION**

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ:

Name: ______________________________

មុខងារ និងឋានៈដែលទទួលបន្ទុក

Position held: ______________________________

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

Signed: Date:……. /…….. / …….

ធ៧-០០-០៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ធ្វើវិសោធនកម្មដោយប្រកាសៈ ធ៧-០៧-១៣៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីអនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ៧-០៦-២០៩ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធ៧-០២-៤៩ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីកាតព្វកិច្ច ចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ត្រូវបានជំនួសដោយប្រកាស ធ៧-០២-៤៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២។

**ប្រការ ២.-**

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណត្រូវធ្វើតែប្រតិបត្តិការធនាគារ ដូចមានកំណត់ក្នុងមាត្រា២នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សេវាឥណទាននិងសញ្ញ័យត្រូវបានអនុញ្ញាតឱ្យធ្វើប្រសិនបើមិនមានការហាមឃាត់ដោយប្រកាសនេះ ឬ ដោយខ្លឹមសារនៃលិខិតអនុញ្ញាតឱ្យបង្កើតគ្រឹះស្ថាន។

រាល់គ្រឹះស្ថាន អង្គការក្រៅរដ្ឋាភិបាល សមាគម ទោះបានទទួលអាជ្ញាប័ណ្ណ ឬ បានចុះបញ្ជីហើយក្តីមិនត្រូវបានអនុញ្ញាតឱ្យ ÷

- ក- ផ្តល់ឥណទានភតិសន្យា ធ្វើប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុ និស្សន្ទ (derivatives) និងសេដ្ឋពាណិជ្ជដល់ដៃ ឬ មានកាលកំណត់លើលោហធាតុមានតម្លៃទំនិញត្បូងថ្ម មានតម្លៃវត្ថុធាតុដើម។
- ខ- ផ្តល់សេវាទូទាត់តាមរយៈគណនីមូលប្បទានប័ត្រ (Checking accounts) ឬធ្វើប្រតិបត្តិការ swap ឬ មានកាលកំណត់ជារូបិយប័ណ្ណបរទេស។

**ប្រការ ៣.-**

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសម្រាប់គ្រឹះស្ថាន ត្រូវចុះបញ្ជីជាក្រុមហ៊ុនភាគហ៊ុន ឬជាសហករណ៍។

**ប្រការ ៤.-**

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈចំនួនពីររយហាសិបលានរៀល (២៥០.០០០.០០០ រៀល)។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៥.-**

ពាក្យសុំអាជ្ញាប័ណ្ណត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ- ប្រភេទមូលប័ត្រតំណាងឱ្យដើមទុន និងចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិង ការអនុវត្តសិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនដែលបានអនុញ្ញាត ឬចំនួនដើមទុនដែលបានបង់

ច- ការបែងចែកភាគហ៊ុននិងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់គ្រឹះស្ថាន

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប(២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធិភាពនូវសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថាន

ឈ- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិនិងរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ។

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគឺជាអង្គភាពដែលបានបង្កើតរួចហើយត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការ ដែលមានការបញ្ជាក់ពីស្នងការគណនី សម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ

ដ- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ៖

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុង ឬ ក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀត ដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និង ល័ក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំនិងទឹកប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលគ្រឹះស្ថានមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ៖ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុលបន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីជាដើម ហើយបើចាំបាច់ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើតនិងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ (បំណុលបន្ទាប់បន្សំជាដើម )

- ចំនួនប្រហាក់ប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើក បៀវត្សដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ទីតាំងនៃសាខាដែលមានហើយឬក៏សាខាដែលបម្រុងបង្កើត
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះទម្រង់ការគណនេយ្យ និង ឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញ សម្រាប់ការិយបរិច្ឆេទគណនេយ្យ បីឆ្នាំ (៣ឆ្នាំ) ខាងមុខ។ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបងៗ (ដូចបានកំណត់ ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឋ- ទម្រង់ការនៃការត្រួតពិនិត្យ ៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុត
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ។

**ប្រការ ៦.-**

ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ ពាក្យសុំត្រូវផ្តល់ព័ត៌មានដូចតទៅ ៖

ក- អត្តសញ្ញាណរបស់ភាគទុនិក ៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាន ទីស្នាក់ ការកណ្តាល និងលក្ខន្តិកៈ។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំ និងទីកន្លែង កំណើត សញ្ជាតិ និង លំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ ធនាគារ ឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ឬទេ។ បើមែនត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមាន ចែងក្នុងមាត្រា ១៨ នៃ ច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្តិនិងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលប័ត្រ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្ត ចំពោះការវិនិយោគបរទេសនៅកម្ពុជា ឬទេ ហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញ ហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយត្រូវ ពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគ-ទុនិកមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថាតើក្រុម ដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិក មានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទាន ឬទេ។ បើមាន ត្រូវរៀបរាប់ឱ្យអស់

ឃ- ប្រាប់ថា តើភាគទុនិកនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុ ឬទេ។ បើមាន ត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ញាណាឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងខាងក្រៅរបស់ភាគទុនិក

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើប អង្កេត ឬទទួលរងនូវការពិន័យជាសំភារៈតាមទម្រង់ការវិជ្ជាជីវៈ រដ្ឋបាលឬតុលាការ ឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងគ្រឹះស្ថាន ដែល បានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកដាក់ពាក្យសុំ ឬទេ ហើយ តើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ- បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត។

**ប្រការ ៧.-**

ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន តាមល័ក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវធ្វើលិខិត ដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី១ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា។

បទបញ្ញានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា ។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចលើកលែងជាលាយលក្ខណ៍អក្សរអនុញ្ញាតឱ្យរួចផុតពីការអនុវត្តមាត្រា ៧ នៅពេលអនុម័តលើអាជ្ញាប័ណ្ណ។

## ជំពូកទី ៣
## ការអនុម័តផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការសំរេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវល័ក្ខខណ្ឌនិងរយៈពេលនៃការអនុវត្តន៍លិខិតអនុញ្ញាត ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេលនិងមានការយល់ព្រមពីធនាគារគារជាតិនៃកម្ពុជា។

**ប្រការ ៩.-**

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៦-២០៩ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦)

ធនាគារជាតិនៃកម្ពុជាផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាព ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០.-**

គ្រឹះស្ថានត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនហាសិបពាន់រៀល(៥០.០០០រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ។

**ប្រការ ១១.-** (ខ្លឹមសារ ត្រូវបានបញ្ជាក់បន្ថែមដោយប្រកាស ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៤)

គ្រឹះស្ថានត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួនមួយលានរៀល (១.០០០.០០០រៀល) នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ចំពោះគ្រឹះស្ថានដែលបានបង្កើតឡើងក្នុងឆ្នាំសោហ៊ុយអាជ្ញាប័ណ្ណត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណគ្រឹះស្ថានដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យ ដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណបានគ្រឹះស្ថានសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀតរហូតដល់ត្រូវដកហូតអាជ្ញាប័ណ្ណ។

## ជំពូកទី ៤
## បទបញ្ញាប្រុងប្រយ័ត្ន

**ប្រការ ១២.-**

ចំពោះគ្រឹះស្ថានបង្កើតថ្មីអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបង់មួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ។

**ប្រការ ១៣.-**

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧.០៦-២០៩ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុន ស្មើនឹងប្រាំភាគរយ(៥%)នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកំរៃការប្រាក់ ដូចខាងក្រោម ៖

ក.ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២) នៃអត្រាការប្រាក់បុនហិរញ្ញប្បទានដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ ក្នុងរយៈពេល៦ខែម្តង។

ខ.ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេសទទួលបានកំរៃការប្រាក់បីភាគប្រាំបី (៣/៨) នៃ អត្រា SIBOR(Sigapore Inter-Bank Offered Rate) ក្នុងរយៈពេល៦ខែម្តង។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងទៅគ្រឹះស្ថានទាំងអស់ពីអត្រាការប្រាក់ ដែលបានអនុវត្តសម្រាប់កាលកំណត់និមួយៗ។

ធនាគារជាតិនៃកម្ពុជានឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះនៅពេលគ្រឹះស្ថាននោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម។

**ប្រការ ១៤.-**

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវតំកល់ទុនបម្រុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើ ដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ ទុនបម្រុង

កាតព្វកិច្ចនេះត្រូវបានរក្សា
ទុកតាមល័ក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញាដោយឡែកស្តីពីទុនបម្រុងកាតព្វកិច្ច។

**ប្រការ ១៥.-**

ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៧-១៣៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦។

**ប្រការ ១៦.-**

គ្រឹះស្ថានត្រូវរក្សាអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចត្រឹមស្មើមួយរយភាគរយ(១០០%)។ អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចតទៅ ៖

ភាគយក : សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ចំនួនទឹកប្រាក់ជំពាក់នៅធនាគារជាតិនិងធនាគារផ្សេង ( សាច់ប្រាក់ងាយស្រួលសុទ្ធ) + ចំណែកទឹកប្រាក់ឱ្យខ្ចីដែលមិនលើសពីប្រតិបត្តិការមួយខែ (លើកលែងតែឥណទានចំពោះអតិថិជនដោយគ្មានកំណត់កាលវសាន្ត )

ភាគបែង : អត្រាភាគរយនៃប្រាក់បញ្ញើមានកាលកំណត់ដែលត្រូវសងក្នុងខែបន្ទាប់ + អត្រាភាគរយនៃគណនីចរន្តនិងអត្រាភាគរយនៃគណនីប្រាក់សន្សំ។ អត្រាភាគរយទាំងនេះត្រូវបានកំណត់តាមប្រកាសដោយឡែក។

**ប្រការ ១៧.-**

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណហើយ ត្រូវអនុវត្តឱ្យសមស្របតាមបញ្ញត្តិទាក់ទងជាមួយចំណាត់ថ្នាក់ ប្រភេទឥណទាននិងកំរិតសំវិធានធនសម្រាប់ការបាត់បង់។

**ប្រការ ១៨.-**

កំរិតឥណទានចំពោះអ្នកខ្ចីឯកត្តជនម្នាក់ឬអ្នកខ្ចីមួយក្រុមដែលរួមបង្កើតជាអ្នកទទួលផលតែមួយដោយសារ មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ត្រូវកំណត់មិនឱ្យលើសពីដប់ភាគរយ (១០%) នៃមូលនិធិផ្ទាល់របស់គ្រឹះស្ថានឡើយ។

## ជំពូកទី ៥
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១៩.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២០.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថាននៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២១.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធទី ១**

# គំរូលិខិត
# របស់ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ
# ចំនួន២០% ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ
# ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ឯកឧត្តមអគ្គទេសាភិបាលជាទីគោរព**

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវព័ត៌មានទាំងឡាយ តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា (តាមលិខិតលេខ............) ទាក់ទងដល់ការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិក) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ)។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មាននេះគ្រប់គ្រាន់និងត្រឹមត្រូវហើយតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាផ្តល់ព័ត៌មានយ៉ាងឆាប់រហ័សជូនធនាគារជាតិនៃកម្ពុជា នូវរាល់ការប្រែប្រួលណាដែលធ្វើឱ្យប្លែកយ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនរួចមកហើយ។

ខ្ញុំបានធ្វើការកត់សម្គាល់ទៅលើបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចស្នើឱ្យភាគទុនិក ដែលមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

ដោយសេចក្តីគោរព

**ហត្ថលេខា**

## ឧបសម្ព័ន្ធទី ២

Photo

4×6

# ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី ឯកត្តជន ឬជនដែលបម្រុងក្លាយទៅជា នាយកចាត់ការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# CURRICULUM VITEA

**and**

**Questionnaire for individual who are, or are proposing to become,**

**<u>Managers of Micro-finance Institutions</u>**

1. គោត្តនាម

Family name.

2. នាមខ្លួន

Given name (s).

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

**4-1.** សូមរៀបរាប់អំពីកាតព្វកិច្ច និង ការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈតួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s)

**4-2.** សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្ដល់ទុនម្នាក់ទៅឱ្យអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណ ហើយបើសិនជាអ្នក មានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការិយមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយអ្នក

ដាក់ពាក្យសុំនោះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

**4-3.** ក្នុងការអនុវត្តន៍ភារកិច្ចរបស់អ្នក តើអ្នកនិងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាត់បង្ហាញរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

**4-4.** សូមរៀបរាប់បើសិនជាអ្នកជា អ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

**5.** អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

6. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុនៈ

Your previous private address(es) during the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

8. សញ្ជាតិ ហើយតើស្មារតីនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

--------------------------------------------------------------------------------

--------------------------------------------------------------------------------

9. ឈ្មោះ និង អាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

Name(s) and address(es) of your bankers within the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

10. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

--------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

**11-1.** ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមកដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនិមួយៗ ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the position held and relevant dates.

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

**11-2.** សូមរៀបរាប់កាលពី១០ឆ្នាំមុនបើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ ភាគរយយ៉ាងតិចនៃដើមទុនឬ នៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**11-3** សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**12.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ, បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបាន ដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**13.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួនធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ , បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

--------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

**14.** តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ, បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

**15.** តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

**16.** តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស, នៅប្រទេសណា, តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិក ណាម្នាក់ដែរឬទេ, បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

17. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធ នឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

18. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

19.សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------------------------------

**20.** បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ - តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុង សំណួរ ៤-១. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធដោយបង្វែរ ព័ត៌មានពិត ឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

***ចូរកត់សម្គាល់ឱ្យបានច្បាស់ថា***៖ រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសំងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4.1? The omission of material facts may represent the provision of misleading information (see declaration below).

**N.B. (note well)** the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

## សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។ ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយ ចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវនិងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬ ផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

**DECLARATION**

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ:

Name:

មុខងារ និងឋានៈដែលទទួលបន្ទុក

Position held:

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

Signed: Date:……. /…….. / …….

ធ៧-០២-៤៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ភាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ
# និងការសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ប្រការ ១ នៃប្រកាសលេខធ៧.០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានលុបចោល និងជំនួសដោយប្រកាសនេះ។

**ប្រការ ២**.-

មីក្រូហិរញ្ញវត្ថុមានន័យថាការផ្តល់សេវាហិរញ្ញវត្ថុដូចជាការផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើចំពោះគ្រួសារ ក្រីក្រ គ្រួសារដែលមានចំណូលតិច និងសហគ្រាសធុនតូច។

**ប្រការ ៣**.-

ការចុះបញ្ជីជាកាតព្វកិច្ចរបស់គ្រប់អង្គការក្រៅរដ្ឋាភិបាលសមាគម និងអង្គភាពផ្សេងទៀតដែលធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុហៅថាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ដែលបានបំពេញល័ក្ខខណ្ឌណាមួយដូចខាងក្រោមៈ

ក- សម្រាប់គ្រឹះស្ថានផ្តល់ឥណទាន

- សំពៀតឥណទានត្រូវមានចំនួន ១០០ លានរៀល ឬ ច្រើនជាង

ខ- សម្រាប់គ្រឹះស្ថានកេណ្ឌប្រមូលប្រាក់សញ្ញ័យ

- ប្រាក់សញ្ញ័យដោយស្ម័គ្រចិត្តដែលប្រមូលបានពីសាធារណជនទូទៅមានចំនួន ១លានរៀល ឬ ច្រើនជាង
- ឬចំនួនអ្នកផ្ញើប្រាក់ ១០០ នាក់ ឬច្រើនជាង។

**ប្រការ ៤**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន ហើយត្រូវបំពេញតាមស្តង់ដារនិងលក្ខណៈវិនិច្ឆ័យ ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ក្នុងន័យអភិបាលកិច្ចល្អ តម្លាភាព និងការគ្រប់គ្រងប្រកបដោយសមត្ថភាពនិងដោយស្មោះត្រង់។

**ប្រការ ៥**.-

ធនាគារជាតិនៃកម្ពុជាផ្តល់វិញ្ញាបនបត្រ័បញ្ជាក់ការចុះបញ្ជី ដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានបំពេញតាមស្តង់ដារ និងលក្ខណៈវិនិច្ឆ័យ ដោយមានផ្តល់ឯកសារនិងព័ត៌មានដែលតម្រូវ ។ វិញ្ញាបនប័ត្រនេះអាចត្រូវបានដកហូត មកវិញ ហើយការចុះបញ្ជីត្រូវលុបចោលបើប្រតិបត្តិករទាំងនោះពុំអនុវត្តតាមលក្ខខណ្ឌដែលធនាគារជាតិនៃកម្ពុជា បានដាក់ចេញ។

**ប្រការ ៦**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលត្រូវបានធនាគារជាតិនៃកម្ពុជា បដិសេធ ឬលុបចោលការចុះបញ្ជីត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួនទាំងអស់ក្នុងរយៈពេល៣ខែ ក្រោយពីបានទទួលសេចក្តីជូនដំណឹងអំពីការសំរេចរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៧**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី ត្រូវផ្តល់របាយការណ៍ស្តីពីសកម្មភាព និងចំណាត់ការរបស់ខ្លួនឱ្យបានទៀងទាត់តាមពេលវេលាកំណត់របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៨**.-

ការសុំអាជ្ញាប័ណ្ណជាកាតព្វកិច្ចរបស់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម ៖

ក- សម្រាប់គ្រឹះស្ថានផ្តល់ឥណទាន

- សំពៀតឥណទាន មានចំនួន ១,០០០ លានរៀល ឬច្រើនជាង
- ឬមានអ្នកខ្ចី ១,០០០ នាក់ ឬច្រើនជាង

ខ- សម្រាប់គ្រឹះស្ថានកេណ្ឌប្រមូលប្រាក់សញ្ញើ

- ប្រាក់សញ្ញើយដោយស្ម័គ្រចិត្តដែលប្រមូលបានពីសាធារណជនទូទៅមានចំនួន ១០០ លានរៀល ឬ ច្រើនជាង
- ឬមានចំនួនអ្នកផ្ញើប្រាក់ ១,០០០ នាក់ ឬច្រើនជាង ។

**ប្រការ ៩**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានកាតព្វកិច្ចសុំអាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២។ គ្រឹះស្ថានដែលពុំបានមកសុំអាជ្ញាប័ណ្ណត្រូវបន្ថយទំហំសកម្មភាពប្រតិបត្តិការ ឱ្យមកត្រឹមលក្ខខណ្ឌត្រូវចុះបញ្ជីតាមប្រការ ៣ ដល់ប្រការ ៧ ខាងលើ។

**ប្រការ ១០**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឬគ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៦-២០៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រកាសស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

កែសម្រួលប្រការ ៩ និងប្រការ ១៣ នៃប្រកាសលេខ ធ៧-០០-០៦ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានដូចខាងក្រោម៖

សូមអានប្រការ ៩ និង ១៣ថ្មី នៃប្រកាសលេខ ធ៧-០០-០៦ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០។

**ប្រការ ២**.-

រាល់ការធ្វើវិសោធនកម្មលក្ខន្តិកៈគ្រឹះស្ថានត្រូវបង់សោហ៊ុយចំនួនដប់ពាន់រៀល (១០.០០០រៀល) ក្នុងមួយទំព័រនៃលក្ខន្តិកៈដែលធ្វើវិសោធនកម្ម។

**ប្រការ ៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៧-១៦៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពី សាធារណជនដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

**ប្រការ ២**.-

គ្រឹះស្ថានដែលមានបំណងសុំអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជន ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

១- មានអាជ្ញាប័ណ្ណប្រកបអាជីវកម្មមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជាយ៉ាងតិចចំនួនបីឆ្នាំ

២-មានស្ថានភាពហិរញ្ញវត្ថុល្អនិងការដឹកនាំរឹងមាំតាមរយៈការធ្វើចំណាត់ថ្នាក់ផ្ទៃក្នុងដោយធនាគារជាតិនៃកម្ពុជា ត្រឹមកំរិតសុវត្ថិភាព ចាប់ពី ២ ឆ្នាំឡើងទៅ មុនថ្ងៃដាក់ពាក្យស្នើសុំ

៣-មានដើមទុនបង់ជំរះអប្បបរមាស្មើនឹង ១០ ពាន់លានរៀល

៤-មានប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ប្រកបដោយប្រសិទ្ធភាព

៥-អនុវត្តតាមប្លង់គណនីឯកភាពរបស់ធនាគារជាតិនៃកម្ពុជា

៦-មានចំណេញដោយស្ថេរភាពយ៉ាងតិចពីរឆ្នាំជាបន្តបន្ទាប់ពីសកម្មភាពប្រតិបត្តិការចំបងរបស់ខ្លួន។

**ប្រការ ៣**.-

បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានត្រូវតែគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១- គ្រឹះស្ថានអាចទទួលប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់តែប៉ុណ្ណោះ ហើយចំនួនប្រាក់បញ្ញើពីអតិថិជនម្នាក់មិនឱ្យលើសពី ៣% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ

២- គ្រឹះស្ថានមិនអាចផ្តល់ឥណទានទៅអតិថិជនម្នាក់លើសពី២% និងទៅក្រុមអតិថិជនជាសម្ព័ន្ធញាតិលើសពី ៣%នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ

៣- គ្រឹះស្ថានត្រូវរក្សាគ្រប់ពេលនូវអនុបាតសាធនភាពមិនឱ្យទាបជាង ១៥% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន

៤- គ្រឹះស្ថានត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត ៥០%

៥- គ្រឹះស្ថានត្រូវរក្សាជាអចិន្ត្រៃយ៍ប្រាក់តំកល់ធានាលើដើមទុនស្មើនឹង១០%នៃដើមទុន ដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា

៦- គ្រឹះស្ថានត្រូវតំកល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន៨% នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនីដែល បានបើកនៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

គ្រឹះស្ថានដែលមានបំណងទទួលប្រាក់បញ្ញើពីអតិថិជន ត្រូវដាក់ពាក្យសុំមកធនាគារជាតិនៃកម្ពុជា

ដើម្បីទទួល បានអាជ្ញាប័ណ្ណដោយឡែកមួយទៀតបន្ថែមពីលើអាជ្ញាប័ណ្ណដែលមានស្រាប់សម្រាប់ទទួលប្រាក់បញ្ញើពីសាធារណជន។ ធនាគារជាតិនៃកម្ពុជានឹងផ្អែកលើលក្ខណៈសម្បត្តិ ដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះដើម្បីវិនិច្ឆ័យផ្តល់ អាជ្ញាប័ណ្ណសម្រាប់ទទួលប្រាក់បញ្ញើពីសាធារណជន។ អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើត្រូវព្យួរបង្ហាញសាធារណជនគ្រប់ពេលជាមួយអាជ្ញាប័ណ្ណដែលមានស្រាប់។

**ប្រការ ៥**.-

គ្រឹះស្ថានណាដែលគ្មានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុផ្សេងទៀតមិនអាចទទួលប្រាក់បញ្ញើពីសាធារណជនបានទេ។

**ប្រការ ៦**.-

គ្រឹះស្ថាន និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

ប្រការ២នៃប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឃ្លាទី២ដែលមានខ្លឹមសារអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់សេវាសញ្ញ័យត្រូវចាត់ទុកជានិរាករណ៍ ចំពោះខ្លឹមសារផ្សេងទៀតក្នុងប្រការ ២ នេះនៅមានសុពលភាពដដែល។

**ប្រការ ៨**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១-១៣៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រាក់តំកល់ធានាលើដើមទុន

ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លាអាមេរិក ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។

**ប្រការ ១**.-

កំណត់ប្រាក់តំកល់ធានាលើដើមទុនដែលត្រូវដាក់ផ្ញើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន១០ភាគរយនៃដើមទុន។

**ប្រការ ២**.-(ផុតកំណត់)

**ប្រការ ៣**.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨)

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬ ទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

**ប្រការ ៤**.-

ប្រាក់តំកល់ធានាលើដើមទុនអាចអនុវត្តជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក។ បន្ទាប់ពីបានបង់ប្រាក់តំកល់ធានាលើដើមទុន ធនាគារសាមីមិនអាចផ្លាស់ប្តូរការជ្រើសរើសនេះបានទេ។ អត្រាប្តូរប្រាក់ប្រើប្រាស់សម្រាប់ការគណនាប្រាក់តំកល់ធានាលើដើមទុននេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដែលមូលនិធិត្រូវបានចុះឥណទានគណនីតំកល់ធានានៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀល ទទួលបានកំរៃការប្រាក់មួយភាគពីរនៃអត្រាការប្រាក់បុនហិរញ្ញប្បទានក្នុងរយៈពេល ៦ ខែម្តងជាធរមាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

(ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩)

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ ខែ។

**ប្រការ ៦**.-

ប្រាក់តំកល់ធានាលើដើមទុនត្រូវបានសងត្រលប់ទៅវិញតែក្នុងករណីមានការជំរះបញ្ជីធនាគារ និងស្របតាមលំដាប់អាទិភាពដែលមានចែងនៅមាត្រា៦៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៤-២០៥ ប្រ.ក

# ប្រកាស
# ស្តីពី
# សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ប្រការ ១**.-

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសម្រាប់ប្រកបមុខរបររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការិយាល័យតំណាង តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម ៖

**ប្រការ ២**.-

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងការិយាល័យតំណាងត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំនៅធនាគារជាតិ នៃកម្ពុជា ដូចខាងក្រោម ៖

ក-ធនាគារពាណិជ្ជ ៖

| | | |
|---|---|---|
| ១- ទីស្នាក់ការកណ្តាល | : | ៧០.០០០.០០០ រៀល |
| ២- សាខាខេត្ត-ក្រុងទី៧ចុះ | : | ៥៦.០០០.០០០ រៀល ក្នុងមួយសាខា |
| ៣- សាខាទី៨ឡើង | : | ២០.០០០.០០០ រៀល ក្នុងមួយសាខា |
| ៤- សាខាស្រុក | : | ១.០០០.០០០ រៀល ក្នុងមួយសាខា |

ខ-ធនាគារឯកទេស ៖

| | | |
|---|---|---|
| ១- ទីស្នាក់ការកណ្តាល | : | ១០.០០០.០០០ រៀល |
| ២- សាខាខេត្ត-ក្រុងទី៧ចុះ | : | ៨.០០០.០០០ រៀល ក្នុងមួយសាខា |
| ៣- សាខាទី៨ឡើង | : | ៥.០០០.០០០ រៀល ក្នុងមួយសាខា |

| | | |
|---|---|---|
| គ-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | : | ១.០០០.០០០ រៀល |
| ឃ-ការិយាល័យតំណាងធនាគារបរទេស | : | ៧០.០០០.០០០ រៀល។ |

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងការិយាល័យតំណាងដែលបើកទីស្នាក់ការកណ្តាល ឬសាខានៅក្នុងឆ្នាំត្រូវ បង់សោហ៊ុយអាជ្ញាប័ណ្ណដូចខាងក្រោម ៖

- ក្នុងត្រីមាសទីមួយ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន : ត្រូវបង់មួយត្រីមាស

**ប្រការ ៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥**.-

ប្រកាសទាំងឡាយពីមុនដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៩-០១២ ប្រ.ក

# ប្រកាស
# ស្តីពី
# សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

**ប្រការ ១** .-

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណជន។

**ប្រការ ២** .-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្នើសុំប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំឱ្យធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ៖

- ទីស្នាក់ការកណ្តាល : ៥.០០០.០០០ រៀល
- សាខា : ១.៥០០.០០០ រៀល ក្នុងមួយសាខា

**ប្រការ ៣** .-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលបើកទីស្នាក់ការកណ្តាល ឬសាខា នៅក្នុងឆ្នាំត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ ដូចខាងក្រោម ៖

- ក្នុងត្រីមាសទីមួយ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន : ត្រូវបង់មួយត្រីមាស

**ប្រការ ៤** .-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនប្រាំសែនរៀល (៥០០.០០០រៀល) នៅពេលដាក់ពាក្យសុំអាជ្ញាប័ណ្ណ។

**ប្រការ ៥** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦** .-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១-១៨៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្ទេរភាគហ៊ុនរបស់ធនាគារ

**ប្រការ ១**.-

ការផ្ទេរភាគហ៊ុនរបស់ធនាគារ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ២**.-

ធនាគារត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុនដែលអាចឱ្យភាគទុនិក ឬក្រុមភាគទុនិកណាមួយទទួលបាន ឬ បាត់បង់ទៅវិញនូវចំនួនមួយភាគពីរ មួយភាគបី មួយភាគប្រាំ មួយភាគដប់ នៃសិទ្ធិបោះឆ្នោតរបស់គេនៅក្នុងធនាគារ។

**ប្រការ ៣**.-

ធនាគារត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុន ដែលនាំឱ្យមានការផ្លាស់ប្តូរអំណាចក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងរបស់ធនាគារ។

**ប្រការ ៤**.-

ធនាគារត្រូវធ្វើប្រតិវេទន៍ជាមុនមកធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុនដែលនាំឱ្យមានកំណើន ឬការថយចុះភាគហ៊ុន ស្មើ ឬ លើសពីប្រាំភាគរយ និងទាបជាងដប់ភាគរយនៃសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយភាគទុនិកណាម្នាក់របស់ធនាគារ។

**ប្រការ ៥**.-

ធនាគារត្រូវបំពេញឱ្យបានតាមរាល់ការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជាចំពោះព័ត៌មានជាក់លាក់ ស្តីពី ភាគទុនិកដែលមានបច្ចុប្បន្ន និងទៅអនាគត។

**ប្រការ ៦**.-

ការខកខានមិនបានធ្វើប្រតិវេទន៍ឬមិនបានស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាតាមបញ្ញត្តិនៃប្រកាសនេះនិងបណ្តាលឱ្យមានការដកហូតភាគហ៊ុនតាមសិទ្ធិបោះឆ្នោតដែលបានផ្ទេរនៅក្នុងការប្រជុំមហាសន្និបាត។

**ប្រការ ៧**.-

សាខារបស់ធនាគារបរទេសដែលបានទទួលអាជ្ញាប័ណ្ណនៅក្នុងប្រទេសកម្ពុជា ត្រូវជូនព័ត៌មានជាប្រចាំមកធនាគារជាតិនៃកម្ពុជា នូវរាល់ការផ្លាស់ប្តូរមានចំនួនច្រើននៃសមាសភាគរបស់ភាគទុនិក នៃក្រុមហ៊ុនមេរបស់ពួកគេ។ ការផ្លាស់ប្តូរត្រូវបានចាត់ទុកថាមានចំនួនច្រើននៅពេលដែលសាខារបស់ធនាគារបរទេសស្នើសុំការអនុញ្ញាតពីអាជ្ញាធរអាណាព្យាបាលរបស់ប្រទេសដើម។

**ប្រការ ៨**.-

រាល់ការផ្ទេរភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជីក្នុងស្រុកត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសប្រាំភាគរយ (០,៥%) នៃតម្លៃចារិកភាគហ៊ុនដែលបានផ្ទេរ។ សោហ៊ុយនេះត្រូវបង់ជូនធនាគារជាតិនៃកម្ពុជា មិនយឺតជាងថ្ងៃដែលបានផ្ទេរទេ។

**ប្រការ ៩**.-

ការខកខានមិនបានអនុវត្តតាមបញ្ញត្តិណាមួយដែលមាននៅក្នុងប្រកាសនេះ ត្រូវទទួលរងនូវការពិន័យ និងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១០**.-

ការធ្វើប្រតិវេទន៍ ឬ សំណើសុំការអនុញ្ញាត ត្រូវអនុវត្តតាមគំរូមួយនៅក្នុងសារាចរណែនាំរបស់ធនាគារជាតិ នៃកម្ពុជា។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១០-០០១ ស.រ.ណ

# សារាចរណែនាំ
# ស្តីពី
# ការកំណត់ចំណាត់ថ្នាក់វិនិយោគ

ដើម្បីអនុវត្តច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ ឱ្យមានភាពរលូនស្របតាមការវិវត្តន៍នៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាណែនាំអំពី ចំណាត់ថ្នាក់វិនិយោគ សម្រាប់ភាគទុនិកមានឥទ្ធិពល ដែលជាគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ និងកាតព្វកិច្ចពាក់ព័ន្ធនានារបស់គ្រឹះស្ថានធនាគារ ដែលទទួលបានអាជ្ញាប័ណ្ណប្រកបមុខរបរធនាគារនៅព្រះរាជាណាចក្រកម្ពុជាដូចតទៅ៖

១- ភាគទុនិកមានឥទ្ធិពលទាំងនេះត្រូវទទួលបានការវាយតម្លៃពីភ្នាក់ងារចាត់ថ្នាក់អន្តរជាតិ (International Rating Agencies) យ៉ាងតិចចំនួនមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិបីគឺ Moody's Asia Pacific, Standard & Poor's Corporation និង Fitch ។ ចំណាត់ថ្នាក់វិនិយោគនេះសំដៅលើចំណាត់ថ្នាក់រយៈពេលវែង (Long Term Rating) ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ណាមួយដូចខាងក្រោម៖

| **Moody's Asia Pacific** | **Standard & Poor's Corporation** | **Fitch** | Grade |
|---|---|---|---|
| **Long Term Rating** | **Long Term Rating** | **Long Term Rating** | |
| Aaa | AAA | AAA | Prime |
| Aa1 | AA+ | AA+ | High Grade |
| Aa2 | AA | AA | |
| Aa3 | AA- | AA- | |
| A1 | A+ | A+ | Upper Medium Grade |
| A2 | A | A | |
| A3 | A- | A- | |
| Baa1 | BBB+ | BBB+ | Lower Medium Grade |
| Baa2 | BBB | BBB | |
| Baa3 | BBB- | BBB- | |

២- ធនាគារពាណិជ្ជ ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០ (ហាសិបពាន់លាន) រៀល។ ធនាគារពាណិជ្ជ ដែលពុំមានភាគទុនិកមានឥទ្ធិពល ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល។ ធនាគារពាណិជ្ជដែល

បង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល ទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬ ភាគទុនិកមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៣- ធនាគារឯកទេស ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល។ ធនាគារឯកទេស ដែលពុំមានភាគទុនិកមានឥទ្ធិពលជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ (សាមសិបពាន់លាន)រៀល។ ធនាគារឯកទេស ដែលបង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាចំនួន ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀលទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬ ភាគទុនិកមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៤- គ្រឹះស្ថានធនាគារត្រូវផ្តល់លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់វិនិយោគ (Confirmation of the Rating) របស់ភាគទុនិកមានឥទ្ធិពលរបស់ខ្លួន ដែលចេញដោយភ្នាក់ងារចាត់ថ្នាក់អន្តរជាតិមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិទាំងបីខាងលើមកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់រៀងរាល់ដើមឆមាសនីមួយៗ។ លើសពីនេះទៀត គ្រឹះស្ថានធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ប្រសិនបើភ្នាក់ងារវាយតម្លៃបន្ថយការធ្វើចំណាត់ថ្នាក់ ភាគទុនិកមានឥទ្ធិពលក្រោមចំណាត់ថ្នាក់វិនិយោគ។

៥- ភាគទុនិកមានឥទ្ធិពលត្រូវចេញលិខិតធានាបង្កើនដើមទុន នៅពេលចំណាត់ថ្នាក់របស់ខ្លួនធ្លាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ឬនៅពេលដែលធនាគារជាតិនៃកម្ពុជា តម្រូវឱ្យបង្កើនដើមទុន ដោយផ្អែកលើការវាយតម្លៃអំពីស្ថានភាពហានិភ័យរបស់ធនាគារ។ លិខិតធានាបង្កើនដើមទុននេះត្រូវមានចែងពីការសន្យា ដែលមិនអាចកែប្រែបាន (Irrevocable) ចំពោះធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់ដើមទុនបន្ថែមនៅក្នុងរវាង ៥ (ប្រាំ) ថ្ងៃធ្វើការ និងបញ្ចប់ការរៀបចំសំណុំឯកសារបង្កើនដើមទុននៅក្នុងរវាង ៣០ ថ្ងៃ ចាប់ពីថ្ងៃផ្ទេរដើមទុន។ លិខិតធានាបង្កើនដើមទុន ត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើនដើមទុនរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬធនាគារមេ ដែលជាភាគទុនិក ដែលមានឥទ្ធិពល និងត្រូវបានជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម។

៦- ការសន្យាផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន ដូចមាននៅក្នុងចំណុច ៤ និង ៥ ខាងលើ ត្រូវមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីភាគទុនិកមានឥទ្ធិពល ។ ឯកសារដែលនឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជារួមមាន៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ការសន្យាផ្តល់សេចក្តីបញ្ជាក់ ការសន្យារាយការណ៍ និង លិខិតធានាបង្កើនដើមទុន)
- លិខិតជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើមអំពីការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ឱ្យមានការសន្យា ផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន និង
- លិខិតធានាបង្កើនដើមទុនរបស់ភាគទុនិកមានឥទ្ធិពល។

៧- ក្នុងករណីដែលគ្រឹះស្ថានធនាគារស្វែងរកជំនួយគាំទ្រពីធនាគារបរទេស គ្រឹះស្ថានធនាគារនោះត្រូវផ្តល់ព័ត៌មាន ដូចខាងក្រោមមកធនាគារជាតិនៃកម្ពុជា ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០៖

- អនុស្សារណៈយោគយល់ ឬលិខិតស្ម័គ្រចិត្តចូលរួមវិនិយោគ ដោយមិនអាចកែប្រែបាន ដោយមានបញ្ជាក់ពីចំនួនភាគហ៊ុន ដែលមានបំណងកាន់កាប់ និងផែនការយុទ្ធសាស្ត្រ ស្តីពី ការវិនិយោគនៅ

កម្ពុជា ដែលឆ្លុះបញ្ចាំងនូវការប្តេជ្ញារយៈពេលវែង និងចំណាប់អារម្មណ៍ក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជា។

- ច្បាប់ចម្លងស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលធនាគារបរទេស និងលិខិតជូនដំណឹងដល់អាជ្ញាធរត្រួតពិនិត្យប្រទេសដើម អំពីគោលបំណងវិនិយោគរបស់ធនាគារបរទេសនោះ។
- សេចក្តីប្រកាសរបស់ធនាគារបរទេសអំពីការយល់ដឹងនូវការទទួលខុសត្រូវរបស់ខ្លួន ជាភាគទុនិកមានឥទ្ធិពល ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ហើយសន្យាអនុវត្តតាមឱ្យបានពេញលេញ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-០១០-១៥១ ប្រ.ក

# ប្រកាស
# ស្តីពី
# អ្នកដំណើរការតតិយភាគី

---

## សម្រេច
## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

គោលបំណងរបស់ប្រកាសនេះគឺដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារ ដែលបានកំណត់ដោយច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា " ធនាគារ " ដើម្បីប្រគល់មួយផ្នែក ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ ឱ្យអ្នកដំណើរការតតិយភាគីមួយឬច្រើន ដូចដែលបានព្រមព្រៀងគ្នារវាងធនាគារ និងអ្នកដំណើរការតតិយភាគីទាំងនោះ និងដែលត្រូវមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ស្របតាមមាត្រា២០៤ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

**ប្រការ ២.-**

**អ្នកដំណើរការតតិយភាគី (Third-Party Processor)** សំដៅដល់បុគ្គលដែលធនាគារបានប្រគល់សិទ្ធិឱ្យធ្វើប្រតិបត្តិការលើមួយផ្នែក ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ធនាគារនោះ។

**ការផ្តល់សេវាពីខាងក្រៅ (Outsourcing)** សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែកដែលធនាគារបានព្រមព្រៀងជាមួយបុគ្គល ឬធនាគារមួយផ្សេងទៀតដើម្បីធ្វើសេវានោះជំនួសខ្លួន។

## ជំពូក ២
## សេវាប្រតិបត្តិការទូទាត់សងប្រាក់

**ប្រការ ៣.-**

១. បុគ្គលដែលមិនមែនជាធនាគារមិនអាចធ្វើអាជីវកម្មពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សងប្រាក់ ឬតាំងខ្លួនឯងជាអ្នកផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់បានឡើយ លុះត្រាតែបុគ្គលនោះ៖

ក. ត្រូវបានធនាគារអនុញ្ញាតឱ្យធ្វើជាអ្នកដំណើរការតតិយភាគីរបស់ខ្លួនតាមការព្រមព្រៀងគ្នា និង

ខ. បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា

២. នៅពេលទទួលបានការអនុញ្ញាតពីធនាគារ និងទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អ្នកដំណើរការតតិយភាគីអាចផ្តល់សេវាមួយផ្នែក ឬច្រើនផ្នែកជំនួសឱ្យធនាគារ ដូចមានចែងនៅក្នុងមាត្រា ២០៣ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ដូចខាងក្រោម៖

ក. ជាអ្នកទំនាក់ទំនង

ខ. ជាអ្នកផាត់ទាត់អន្តរធនាគារដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

គ. ជាអ្នកគ្រប់គ្រង ឬជាអ្នកធ្វើប្រតិបត្តិការលើគណនីអតិថិជនរបស់ធនាគារ និង/ឬ

ឃ. ដើរតួជាកន្លែងផ្ញើ និងទទួលបញ្ជាទូទាត់ដែលត្រូវបានផ្ញើ ឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការផ្ញើ និងទទួលបញ្ជាទូទាត់។ បន្ថែមលើនេះ៖

ង. ជាអ្នកផ្តល់សេវាផ្ទេរប្រាក់តាមទូរស័ព្ទចល័ត ឬតាមមធ្យោបាយផ្សេងទៀត

ច. ជាអ្នកផ្តល់សេវាផាត់ទាត់ និងទូទាត់ ការទូទាត់សងប្រាក់ដោយប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ

**ប្រការ ៤**.-

១. អ្នកដំណើរការតតិយភាគីអាចគ្រប់គ្រង និងធ្វើប្រតិបត្តិការជំនួសឱ្យធនាគារមួយ ឬច្រើននូវប្រព័ន្ធទូទាត់សងប្រាក់សម្រាប់៖

ក. ប្រតិបត្តិការទូទាត់សងប្រាក់ និងការដកសាច់ប្រាក់

ខ. ការផាត់ទាត់ និងទូទាត់ នៅក្នុងប្រទេសកម្ពុជាសម្រាប់ឧបករណ៍ទូទាត់សងប្រាក់ជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

២. ក្នុងករណីនេះ អ្នកដំណើរការតតិយភាគីត្រូវតែបានទទួលការអនុញ្ញាតឱ្យធ្វើសេវាបែបនេះដោយធនាគារមួយ និងធនាគារទាំងអស់ដែលចូលរួមនៅក្នុងប្រព័ន្ធទូទាត់ ហើយការទទួលខុសត្រូវរបស់ធនាគារនីមួយៗ ត្រូវតែបានបែងចែកឱ្យបានត្រឹមត្រូវ។

**ប្រការ ៥**.-

អ្នកដំណើរការតតិយភាគីដែលគ្រប់គ្រងប្រព័ន្ធទូទាត់នឹងត្រូវស្ថិតនៅក្រោមប្រកាសស្តីពី ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ប្រកាសស្តីពីការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ និងប្រកាសស្តីពីប្រតិបត្តិការនៃគណនីទូទាត់ដែលមានស្រាប់របស់ធនាគារជាតិនៃកម្ពុជា និងវិធានការពាក់ព័ន្ធផ្សេងៗទៀតប្រសិនបើមាន។

## ជំពូក ៣

## ការស្នើសុំអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីរបស់ធនាគារ

**ប្រការ ៦**.-

១. មុនពេលអនុញ្ញាតឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាជំនួសឱ្យអ្នកដំណើរការតតិយភាគី។ ពាក្យស្នើសុំនេះត្រូវតែបញ្ជាក់ ឬមានព័ត៌មានដូចតទៅ៖

ក. ឈ្មោះផ្លូវការ អាសយដ្ឋានរស់នៅ និងអាសយដ្ឋានធ្វើអាជីវកម្មរបស់អ្នកដំណើរការតតិយភាគី និងសម្មតិនាមឬឈ្មោះពាណិជ្ជកម្មដែលអ្នកដំណើរការតតិយភាគីបានប្រើប្រាស់ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនជំនួសឱ្យធនាគារ និងការពិពណ៌នាអំពីស្ថានភាពស្របច្បាប់របស់ខ្លួន។

ខ. ការពិពណ៌នាអំពីសេវាប្រតិបត្តិការទូទាត់សងប្រាក់ដែលពីមុនអ្នកដំណើរការតតិយភាគីធ្លាប់បានផ្តល់នៅក្នុងនិងក្រៅប្រទេសកម្ពុជាប្រសិនបើមាន និងសេវាប្រតិបត្តិការទូទាត់សងប្រាក់ ដែលអ្នកដំណើរការតតិយភាគីមានបំណងផ្តល់នៅក្នុងប្រទេសកម្ពុជាជំនួសឱ្យធនាគារ។

គ. ការពិពណ៌នាអំពីមធ្យោបាយស្របច្បាប់ដែលត្រូវអនុវត្ត ដើម្បីការពារមូលនិធិរបស់អតិថិជនពីហានិភ័យណាមួយដែលបណ្តាលមកពីការផ្តល់សេវាពីខាងក្រៅនេះ ការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងកាតព្វកិច្ចស្គាល់អតិថិជនរបស់ខ្លួន ព្រមទាំងវិធានការនានាដើម្បីឱ្យអតិថិជនបានដឹងអំពីតួនាទីរបស់អ្នកដំណើរការតតិយភាគីនៅក្នុងសេវាប្រតិបត្តិការទូទាត់សងប្រាក់។ ក្នុងករណីប្រើប្រាស់ភ្នាក់ងារ ចាំបាច់ត្រូវពណ៌នាអំពីមុខងារ និងស្ថានភាពស្របច្បាប់របស់ភ្នាក់ងារទាំងនោះ។

២. ពាក្យស្នើសុំត្រូវតែភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

- សេចក្តីសម្រេចរបស់គណៈគ្រប់គ្រងធនាគារសាមីដែលអនុញ្ញាតឱ្យធនាគារប្រគល់សេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ខ្លួនមួយផ្នែក ឬច្រើនផ្នែកទៅឱ្យអ្នកដំណើរការតតិយភាគី
- កិច្ចព្រមព្រៀងរវាងធនាគារ និងអ្នកដំណើរការតតិយភាគី ដើម្បីប្រគល់និងទទួលសេវានេះ
- ការអនុញ្ញាតពីក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាល ប្រសិនបើមាន ដើម្បីអនុញ្ញាតឱ្យសាខា ឬបុត្តសម្ព័ន្ធរបស់ខ្លួនធ្វើជាអ្នកដំណើរការតតិយភាគី
- លិខិតធានារបស់ធនាគារដែលសន្យាទទួលខុសត្រូវទាំងស្រុងលើសកម្មភាពរបស់អ្នកដំណើរការតតិយភាគី

៣. ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយ ចំនួន ២.០០០.០០០រៀល (ពីរលានរៀល)។

៤. ធនាគារត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ១០.០០០.០០០ រៀល (ដប់លានរៀល) ជំនួសឱ្យអ្នកដំណើរការតតិយភាគីឱ្យបានត្រឹមថ្ងៃទី១៥ ខែមករា។

៥. ចំពោះធនាគារដែលស្នើសុំអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

៦. ក្នុងករណីការបង់សោហ៊ុយអាជ្ញាប័ណ្ណមានការយឺតយ៉ាវ ធនាគារពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទាន ជាធរមានក្នុងរយៈពេលរហូតដល់ ៣០ ថ្ងៃ (សាមសិបថ្ងៃ)។

**ប្រការ ៧**.-

១. អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីពេលបានចេញឱ្យ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែអ្នកដំណើរការតតិយភាគីធ្វើសកម្មភាពស្របតាមច្បាប់និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមាន ត្រូវបានដោះស្រាយ។

២. ពាក្យស្នើសុំអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព។ ក្នុងករណីដែលការស្នើសុំនោះមានបញ្ចូលសេវាថ្មី ឬមានវិធីខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ធនាគារជាតិនៃកម្ពុជាត្រូវពិចារណាលើបញ្ហានេះដោយចាត់ទុកថាជាការស្នើសុំអាជ្ញាប័ណ្ណថ្មី។

៣. ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើនេះទេ ធនាគារត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ។

៤. ធនាគារដែលនៅតែមិនអាចគោរពតាមកាលបរិច្ឆេទកំណត់ ឬតាមពេលវេលាដែលធនាគារជាតិនៃកម្ពុជាបានពន្យារឱ្យនោះទេ នឹងត្រូវទទួលរងនូវការព្យួរអាជ្ញាប័ណ្ណរបស់អ្នកដំណើរការតតិយភាគី។ ការព្យួរអាជ្ញាប័ណ្ណនឹងត្រូវបានលុបចោលវិញ ប្រសិនបើក្នុងរយៈពេល ២០ថ្ងៃ បន្ទាប់ពីអាជ្ញាប័ណ្ណត្រូវបានព្យួរធនាគារបាន៖

- ក. ដាក់ពាក្យស្នើសុំ និងបង់សោហ៊ុយអាជ្ញាប័ណ្ណជាថ្មីឱ្យអ្នកដំណើរការតតិយភាគី និង
- ខ. បង់ប្រាក់ពិន័យចំនួន ២០០.០០០រៀល (ម្ភៃម៉ឺនរៀល) ក្នុងមួយថ្ងៃ ក្រោយពេលព្យួរអាជ្ញាប័ណ្ណ

៥. ប្រសិនបើធនាគារនៅតែមិនអាចបំពេញបាននូវចំណុច៤ខាងលើ ធនាគារនោះនឹងត្រូវទទួលរងការផាកពិន័យកាន់តែធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានទៅដល់ការដកអាជ្ញាប័ណ្ណអ្នកដំណើរការតតិយភាគីតែម្តង។

**ប្រការ ៨**.-

១. ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការយល់ព្រម ឬបដិសេធពាក្យស្នើសុំនេះក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) ក្រោយពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំពេញលេញ។

២. ធនាគារជាតិនៃកម្ពុជាអាចពន្យាររយៈពេលនៃការដាក់ពាក្យស្នើសុំ ប្រសិនបើមានមូលហេតុសមស្រប។

៣. អាជ្ញាប័ណ្ណត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេវា ឬសកម្មភាពទាំងឡាយដែលត្រូវបានអនុញ្ញាត និង/ឬត្រូវបានរឹតត្បិតចំពោះវិសាលភាព ឬមធ្យោបាយក្នុងការផ្តល់សេវាបែបនេះ។

៤. ធនាគារជាតិនៃកម្ពុជាអាចស្នើទៅគ្រឹះស្ថានធនាគារ និងអ្នកដំណើរការតតិយភាគី ដើម្បីកែប្រែផ្នែកខ្លះនៃកិច្ចព្រមព្រៀងដែលបានចុះហើយ ប្រសិនបើពិនិត្យឃើញថាកិច្ចព្រមព្រៀងទាំងនេះអាចនាំឱ្យមានហានិភ័យហួសប្រមាណចំពោះប្រព័ន្ធជាតិទូទាត់សងប្រាក់ ឬទីផ្សារ។

**ប្រការ ៩**.-

១. ធនាគារដែលប្រគល់សិទ្ធិក្នុងការធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់មួយផ្នែក ឬច្រើនផ្នែកទៅឱ្យអ្នកដំណើរការតតិយភាគី ត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញក្នុងរយៈពេលមិនឱ្យលើស ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព។ ធនាគារត្រូវបំពេញកាតព្វកិច្ចផ្តល់ព័ត៌មាន និងបង់សោហ៊ុយបន្តអាជ្ញាប័ណ្ណជាថ្មីជួសមុខឱ្យអ្នកដំណើរការតតិយភាគី។

២. ពាក្យស្នើសុំអាជ្ញាប័ណ្ណជាថ្មី ត្រូវមានភ្ជាប់ជាមួយនូវ៖

ក. ច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មនាពេលថ្មីៗ បំផុតរបស់ធនាគារ។

ខ. ការពិពណ៌នាអំពីការកែប្រែព័ត៌មានសំខាន់ៗរបស់អ្នកដំណើរការតតិយភាគីនៅក្នុង ពាក្យស្នើសុំអាជ្ញាប័ណ្ណដំបូងរបស់ខ្លួន ដែលមិនបានរាយការណ៍ជូនធនាគារជាតិ នៃកម្ពុជានៅក្នុងរបាយការណ៍ដែលបានតម្រូវ។

គ. បញ្ជីទីតាំងនៅក្នុងប្រទេសកម្ពុជាដែលអ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការ ទូទាត់សងប្រាក់ ឬផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ផ្សេងៗទៀត។

ឃ. ការបង្ហាញឱ្យដឹងពីការតវ៉ាធ្ងន់ធ្ងរណាមួយ ឬសកម្មភាពស្របច្បាប់ដែលទទួលធ្វើ ដោយអតិថិជន ឬភាគីទីបីដែលទាក់ទងនឹងសេវាកម្មផ្តល់អាជ្ញាប័ណ្ណ។

## ជំពូក ៤
## ភារកិច្ច និងការទទួលខុសត្រូវរបស់ធនាគារ

**ប្រការ ១០**.-

ធនាគារដែលបានទទួលអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីត្រូវ៖

១. ទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬកំហុសឆ្គងនានារបស់អ្នកដំណើរការតតិយភាគី និងភ្នាក់ងារដែលធ្វើសកម្មភាពក្រោមការប្រគល់សិទ្ធិរបស់ខ្លួន និងជំនួសឱ្យខ្លួន។

២. ត្រូវធានាថា អ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាព ដែលក្នុងនោះអ្នកដំណើរការតតិយភាគីបានធ្វើសកម្មភាពជំនួសឱ្យខ្លួន ដើម្បីធានានូវការគោរពតាមប្រកាសនេះ និងកាតព្វកិច្ចខាងផ្នែកគតិយុត្តផ្សេងៗទៀត។ ធនាគារមិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ។

៣. ត្រូវធានាថា អ្នកដំណើរការតតិយភាគីដែលធ្វើសកម្មភាពជំនួសឱ្យខ្លួន និងភ្នាក់ងារប្រតិ-ស្រុត បានជម្រាបជូនអតិថិជនអំពីការទទួលខុសត្រូវនេះ។

៤. ត្រូវធានាថា សេវាផ្តល់ដោយអ្នកដំណើរការតតិយភាគី មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេស និងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវ៖

ក. ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ. ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗ និងការផ្តល់សេវាម្តងៗ

គ. ការបដិសេធ និងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ. ការថែរក្សាទុកកំណត់ត្រាឱ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព។

**ប្រការ ១១**.-

ទំនាក់ទំនង និងកាតព្វកិច្ចរបស់ធនាគារចំពោះអតិថិជនរបស់ខ្លួនមិនត្រូវបានប៉ះពាល់ដោយសារតែការប្រើប្រាស់សេវាពីខាងក្រៅនៃសកម្មភាពណាមួយដែលស្ថិតនៅក្រោមប្រកាសនេះទេ។

## ជំពូក ៥
## តួនាទី និងការទទួលខុសត្រូវរបស់អ្នកដំណើរការតតិយភាគី

**ប្រការ ១២**.-

អ្នកដំណើរការតតិយភាគី ដែលធ្វើសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឱ្យធនាគារមានភារកិច្ចដូចតទៅ៖

១. អាចជ្រើសរើសភ្នាក់ងារមួយឬច្រើន ដើម្បីជួយដល់ប្រតិបត្តិការដាក់និងដកសាច់ប្រាក់។

២. ត្រូវមានកិច្ចសន្យាតាមផ្លូវច្បាប់ជាមួយភ្នាក់ងារដែលបានជ្រើសរើស និងត្រូវកំណត់គោលការណ៍ និងនីតិវិធីឱ្យបានច្បាស់លាស់ដើម្បីឱ្យភ្នាក់ងារនេះគោរពតាមទាំងស្រុង។

៣. ត្រូវធានាថាភ្នាក់ងារដែលបានជ្រើសរើសមិនផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់នៅក្រៅដែនសកម្មភាពអនុញ្ញាតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងភ្នាក់ងារ និងអ្នកដំណើរការតតិយភាគីឡើយ។

៤. ត្រូវធានាថា សេវាផ្តល់ដោយខ្លួនឯងផ្ទាល់ ឬភ្នាក់ងារណាមួយដែលខ្លួនតែងតាំង មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេសនិងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវ៖

ក. ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ. ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗនិងការផ្តល់សេវាម្តងៗ

គ. ការបដិសេធនិងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ. ការថែរក្សាទុកកំណត់ត្រាឱ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព។

**ប្រការ ១៣**.-

អ្នកដំណើរការតតិយភាគីមានកាតព្វកិច្ចទទួលខុសត្រូវទាំងស្រុងលើរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន រួមទាំងសកម្មភាពរបស់ភ្នាក់ងារដែលខ្លួនបានជ្រើសរើស ដូចតទៅ៖

១. ទទួលខុសត្រូវលើរាល់សកម្មភាព ឬរាល់កំហុសរបស់ភ្នាក់ងារប្រតិស្រុតដែលផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឱ្យខ្លួនទាំងចំពោះតតិយភាគីផង និងចំពោះធនាគារផង។

២. ត្រូវធានាថា ភ្នាក់ងាររបស់ខ្លួនធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាពដែលក្នុងនោះភ្នាក់ងារបានធ្វើជំនួសឱ្យខ្លួន។ អ្នកដំណើរការតតិយភាគីមិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ។

៣. ត្រូវផ្តល់បញ្ជីឈ្មោះភ្នាក់ងាររបស់ខ្លួន រួមទាំងឈ្មោះ និងអាសយដ្ឋាននៃទីតាំងដែលភ្នាក់ងារទាំងនោះធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធមកធនាគារជាតិនៃកម្ពុជាជារៀងរាល់ខែ។

## ជំពូក ៦
## ការគ្រប់គ្រងគណនី

**ប្រការ ១៤**.-

ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការផ្ទេរប្រាក់ត្រូវតម្រូវឱ្យអ្នកដំណើរការតតិយភាគីបើកគណនីនៅធនាគាររបស់ខ្លួន ដើម្បីតម្កល់ប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់ធ្វើការផ្ទេរ ដូចជាការផ្ទេរតាមទូរស័ព្ទជាដើម។

គណនីរបស់អ្នកដំណើរការតតិយភាគីនេះ មានរូបភាពជាគណនីអាណត្តិព្យាបាលសម្រាប់តម្កល់ប្រាក់ជាបណ្តោះអាសន្ន ដែលនឹងត្រូវបានប្រើសម្រាប់តែការផ្ទេររបស់អតិថិជនប៉ុណ្ណោះ និងមិនត្រូវបានប្រើប្រាស់ក្នុងគោលដៅផ្សេងឡើយ។

ធនាគារសាមីមានតួនាទី តាមដានត្រួតពិនិត្យគណនីនេះជាប្រចាំ ហើយក្នុងករណីមានការបញ្ឈប់សកម្មភាពរបស់អ្នកដំណើរការតតិយភាគី ឬអ្នកដំណើរការតតិយភាគីក្ស័យធន ធនាគារត្រូវតែឃាត់ទុកគណនីនេះ ដើម្បីជាផលប្រយោជន៍របស់អតិថិជន។ សមតុល្យនៃគណនីនេះ មិនមែនជាទ្រព្យសម្បត្តិរបស់អ្នកដំណើរការតតិយភាគីឡើយ។

## ជំពូក ៧
## ការត្រួតពិនិត្យរបាយការណ៍ និងកំណត់ត្រា

**ប្រការ ១៥**.-

១. ធនាគារជាតិនៃកម្ពុជា អាចត្រួតពិនិត្យប្រចាំឆ្នាំចំពោះអ្នកដំណើរការតតិយភាគី ឬប្រសិនបើចាំបាច់ចំពោះធនាគារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនចំនួន ៣០ ថ្ងៃ (សាមសិបថ្ងៃ)។

២. ធនាគារជាតិនៃកម្ពុជា អាចត្រួតពិនិត្យអ្នកដំណើរការតតិយភាគីនៅពេលណាមួយក៏បានដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជា មានហេតុផលជឿថា អ្នកដំណើរការតតិយភាគីកំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ ឬគ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងរំលោភប្រកាសនេះ ឬបទបញ្ជា ដែលចេញផ្សាយក្រោមប្រកាសនេះ។

៣. ប្រសិនបើធនាគារជាតិនៃកម្ពុជាសម្រេចថា ការត្រួតពិនិត្យដល់ទីកន្លែងដូចមានចែងក្នុងចំណុច ១ និង២ខាងលើជាការចាំបាច់ អ្នកដំណើរការតតិយភាគី ឬធនាគារត្រូវទទួលបន្ទុកលើចំណាយសមស្របនៃការត្រួតពិនិត្យនោះ។

៤. ព័ត៌មានដែលទទួលបានក្នុងអំឡុងពេលត្រួតពិនិត្យដែលមានចែងក្នុងប្រកាសនេះ អាចនឹងត្រូវបានបើកចំហដោយអនុលោមតាមប្រការ ១៧ តែប៉ុណ្ណោះ។

**ប្រការ ១៦**.-

១. អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១៥ ថ្ងៃ (ដប់ប្រាំថ្ងៃ) នៃថ្ងៃធ្វើការ នូវរាល់ការកែប្រែព័ត៌មានសំខាន់ៗដែលបានផ្តល់ឱ្យនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណ ដូចដែលបានតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២. ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធ អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីចុងត្រីមាសនីមួយៗ នូវ៖

ក. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃប្រតិបត្តិការទូទាត់សងប្រាក់រួមទាំងតារាងតុល្យការ និង របាយការណ៍ចំណូល-ចំណាយ។

ខ. សកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងរបាយការណ៍សរុបអំពីសកម្មភាពនានា ប្រចាំខែដោយបែងចែកទៅតាមប្រភេទផ្សេងៗ តាមការណែនាំរបស់ធនាគារពាក់ព័ន្ធ។

គ. បញ្ជីសេវានានាដែលអ្នកដំណើរការតតិយភាគីកំពុងធ្វើនាពេលបច្ចុប្បន្ន និងថ្ងៃ និងពេលវេលា នៃការផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់។

ឃ. ព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៧.-**

១. អ្នកដំណើរការតតិយភាគីត្រូវរក្សាទុកនូវកំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ) និងជាពិសេសត្រូវរក្សាទុកកំណត់ត្រាសម្រាប់បញ្ជាក់នូវការគោរពតាមរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះដូចខាងក្រោម ៖

ក. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗ

ខ. សៀវភៅធំដែលបានចុះបញ្ជីយ៉ាងហោចណាស់ប្រចាំខែ អំពីគណនីទ្រព្យសកម្ម ទ្រព្យអកម្ម ដើមទុន ចំណូល និងចំណាយ

គ. របាយការណ៍គណនី និងកំណត់ត្រាផ្ទៀងផ្ទាត់របស់ធនាគារ

ឃ. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗដែលបានទូទាត់សង

ង. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗដែលបានទូទាត់សងក្នុងរយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ)

ច. បញ្ជីឈ្មោះ និងអាសយដ្ឋានចុងក្រោយបង្អស់របស់ភ្នាក់ងារខ្លួនទាំងអស់ និង

ឆ. កំណត់ត្រាផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

២. ឯកសារដែលបានរៀបរាប់ក្នុងចំណុច១ អាចត្រូវបានរក្សាទុកក្នុងទម្រង់កំណត់ត្រាណាមួយក៏បាន។

៣. កំណត់ត្រាទាំងអស់ដែលបានរក្សាទុកដោយអ្នកដំណើរការតតិយភាគី ដូចបានចែងក្នុងចំណុច ១និង២ ត្រូវបានបើកចំហសម្រាប់ការធ្វើអធិការកិច្ចដោយធនាគារជាតិនៃកម្ពុជា អនុលោមតាមប្រការ ១៣។

៤. អ្នកដំណើរការតតិយភាគីត្រូវបំពេញកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ឬបទបញ្ញាផ្សេងៗទៀត។

**ប្រការ ១៨.-**

១. អ្នកដំណើរការតតិយភាគីត្រូវកំណត់ទុកជាមួយនឹងអាជ្ញាធរដែលត្រូវបានតែងតាំងដោយច្បាប់ នូវកំណត់ត្រាទាំងអស់ដែលបានតម្រូវតាមរយៈការរាយការណ៍អំពីរូបិយវត្ថុ ការរក្សាកំណត់ត្រានិងការរាយការណ៍អំពីប្រតិបត្តិការសង្ស័យ ដូចមានចែងក្នុងច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទាន

ភេរវកម្ម។ អ្នកដំណើរការតតិយភាគីត្រូវដាក់កំណត់ចំពោះភ្នាក់ងារប្រតិស្រុតរបស់ខ្លួនអំពីការប្រមូលព័ត៌មាន ដែលគួរឱ្យជឿបានទាំងអស់ ដែលអាជ្ញាធរបានកំណត់សម្រាប់គោលបំណងនេះ។

២. ការតំកល់ទុកទាន់ពេលនូវរបាយការណ៍ពេញលេញ និងត្រឹមត្រូវជាមួយអាជ្ញាធរសមស្របគឺជាការគោរពតាមកាតព្វកិច្ចនៅក្នុងចំណុច១។

**ប្រការ ១៩**.-

១. លើកលែងតែមានចែងខុសពីក្នុងចំណុច២ ព័ត៌មាន ឬរបាយការណ៍ទាំងអស់ដែលធនាគារជាតិនៃកម្ពុជា បានទទួលពីអ្នកដំណើរការតតិយភាគី និងព័ត៌មានទាំងអស់ដែលមាននៅក្នុងឬទាក់ទងនឹងរបាយការណ៍ត្រួតពិនិត្យ ស៊ើបអង្កេត ប្រតិបត្តិការ ឬស្ថានភាពដែលរៀបចំដោយ ឬសម្រាប់ការប្រើប្រាស់របស់ធនាគារជាតិនៃកម្ពុជា ឬរបាយការណ៍ហិរញ្ញវត្ថុ តារាងតុល្យការ គឺជាការសម្ងាត់ និងមិនត្រូវបានបើកចំហជាសាធារណៈឡើយ។

២. ធនាគារជាតិនៃកម្ពុជាអាចបើកចំហព័ត៌មានដែលមិនមែនជាកម្មវត្ថុនៃការបើកចំហក្រោមចំណុច ១ ទៅឱ្យតំណាងភ្នាក់ងាររបស់រដ្ឋាភិបាល ដែលសន្យាជាលាយលក្ខណ៍អក្សរថានឹងរក្សាការសម្ងាត់នៃព័ត៌មានទាំងនោះ ឬធនាគារជាតិនៃកម្ពុជាយល់ឃើញថា ការផ្សព្វផ្សាយព័ត៌មានទាំងនោះគឺជាការចាំបាច់សមស្របសម្រាប់ការពារសាធារណជន និងដើម្បីភាពយុត្តិធម៌ ហើយធនាគារជាតិនៃកម្ពុជាក៏បានជូនដំណឹងជាមុនដល់អ្នកដំណើរការតតិយភាគីអំពីគោលបំណងផ្សព្វផ្សាយព័ត៌មានទាំងនោះ។

៣. ប្រការនេះមិនហាមឃាត់ធនាគារជាតិនៃកម្ពុជាចំពោះការបើកចំហដល់សាធារណជនអំពីបញ្ជីរាយនាមបុគ្គលដែលបានទទួលអាជ្ញាប័ណ្ណក្រោមប្រកាសនេះ ឬទិន្នន័យហិរញ្ញវត្ថុសរុបដែលពាក់ព័ន្ធនឹងអ្នកដំណើរការតតិយភាគី និងភ្នាក់ងារប្រតិស្រុតរបស់អ្នកដំណើរការតតិយភាគីឡើយ។

## ជំពូក ៣
## នីតិវិធីរដ្ឋបាល

**ប្រការ ២០**.-

១. ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណរបស់អ្នកដំណើរការតតិយភាគី ឬចេញបញ្ជាដល់អ្នកដំណើរការតតិយភាគីឱ្យដកហូតការតែងតាំងភ្នាក់ងារ ប្រសិនបើ ៖

- ក. អ្នកដំណើរការតតិយភាគីល្មើសនឹងប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលបានចេញផ្សាយក្រោមប្រកាសនេះ
- ខ. អ្នកដំណើរការតតិយភាគីមិនសហការជាមួយធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យ ឬការអង្កេត
- គ. អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តការក្លែងបន្លំ ធ្វើការបំភ័ន្តដោយចេតនា ឬមានការធ្វេសប្រហែសធ្ងន់ធ្ងរ
- ឃ. ភ្នាក់ងារត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬល្មើសនឹងវិធានដែលបានអនុម័ត ឬបញ្ជាដែលបានចេញក្រោមប្រកាសនេះ

ង. អ្នកដំណើរការតតិយភាគីប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវ

ច. អ្នកដំណើរការតតិយភាគីមានអសាធនភាព ផ្អាកការទូទាត់សងបំណុលរបស់ខ្លួន ឬធ្វើការផ្ទេរសិទ្ធិទូទៅសម្រាប់ផលប្រយោជន៍ឥណទាយករបស់ខ្លួន ឬ

ឆ. អ្នកដំណើរការតតិយភាគីមិនដកភ្នាក់ងារចេញតាមបញ្ជាជាចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជា រួមទាំងការឃើញថាភ្នាក់ងារបានប្រព្រឹត្តល្មើសនឹងប្រកាសនេះផង។

២. ដើម្បីកំណត់ថា អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវធនាគារជាតិនៃកម្ពុជាអាចពិចារណាទៅលើទំហំ និងលក្ខខណ្ឌនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ទំហំនៃការខាតបង់ភាពធ្ងន់ធ្ងរនៃបទល្មើស និងការប្រព្រឹត្តពីមុនរបស់បុគ្គលពាក់ព័ន្ធ។

**ប្រការ ២១**.-

ប្រសិនបើ ធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ការប្រព្រឹត្តល្មើសរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលបានចេញផ្សាយក្រោមប្រកាសនេះអាចនឹងធ្វើឱ្យអ្នកដំណើរការតតិយភាគី អតិថិជនរបស់អ្នកដំណើរការតតិយភាគី ឬសាធារណជនទទួលមហន្តរាយភ្លាមៗ និងមិនអាចស្តារឡើងវិញបាន ឬបណ្តាលឱ្យមានអសាធនភាព ឬធ្វើឱ្យបាត់បង់ទ្រព្យសកម្មរបស់អ្នកដំណើរការតតិយភាគី ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាតម្រូវឱ្យអ្នកដំណើរការតតិយភាគីបញ្ឈប់សកម្មភាពល្មើសនោះភ្លាម។

**ប្រការ ២២**.-

ធនាគារជាតិនៃកម្ពុជាអាចដាក់ពិន័យចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬវិធាន ដែលបានអនុម័ត ឬបញ្ជាដែលបានចេញក្រោមប្រកាសនេះក្នុងចំនួនប្រាក់ ១០០.០០០រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃទៅតាមចំនួនថ្ងៃនៃការប្រព្រឹត្តល្មើស។

**ប្រការ ២៣**.-

១. គ្មានបុគ្គលណាមួយអាចធ្វើរបាយការណ៍ក្លែងបន្លំ បំភ័ន្ត ឬធ្វើលិខិតបញ្ជាក់ក្លែងក្លាយដោយចេតនា នៅក្នុងកំណត់ត្រាដែលបានដាក់ជូន ឬដែលបានតម្រូវឱ្យរក្សាទុកក្រោមប្រកាសនេះ ឬមានចេតនាធ្វើកំណត់ត្រាក្លែងក្លាយ ឬលុបចោលការកត់ត្រាសំខាន់ៗនៅក្នុងរបាយការណ៍នោះឡើយ។

២. គ្មានបុគ្គលណាមួយ អាចធ្វើសកម្មភាពដោយចេតនានៅក្នុងសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ដោយពុំទាន់បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

៣. ប្រសិនបើ ធនាគារជាតិនៃកម្ពុជាមានមូលហេតុច្បាស់ថា បុគ្គលណាបាន ឬកំពុងប្រព្រឹត្តល្មើសនឹងប្រការ ៣ នៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាដើម្បីបញ្ឈប់បុគ្គលនោះភ្លាម។

## ជំពូក ៩
## អវសានប្បញ្ញត្តិ

**ប្រការ ២៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៥**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០០-៤៦ ប្រ.ក

# ប្រកាស
# ស្តីពី
# អនុបាតសាធនភាពរបស់ធនាគារ

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៧-១៣៥ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី វិសោធនកម្ម លើប្រកាសស្តីពី អនុបាតសាធនភាពរបស់ធនាគារ និង ប្រកាស ធ៧-០៤-២០៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាព។

**ប្រការ ១**.-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៤-២០៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤)

ធនាគារទាំងអស់ត្រូវពិនិត្យជាអចិន្ត្រៃយ៍នូវអនុបាតសាធនភាពរបស់ខ្លួនឱ្យបានស្របតាមបញ្ញត្តិនៃប្រកាសនេះ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យឥណទានសរុបមិនត្រូវតិចជាងដប់ប្រាំភាគរយ (១៥%) ឡើយ។

**ប្រការ ២**.-

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិ នៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ប្រការ ៣**.-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៧-១៣៥ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧)

ក- ភាគបែងនៃអនុបាត គឺជាតម្លៃទ្រព្យសកម្មសរុប (តម្លៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធន និងការរំលោះតម្លៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកំរិតហានិភ័យ។ ភាគបែងនេះមិនរាប់បញ្ចូលនូវខ្ទង់ដែលបានដកចេញនៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ខ- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម

ខ.១- ការថ្លឹងសូន្យភាគរយ (zero weighting) ចំពោះ ÷

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលមានវត្ថុបញ្ចាំជាប្រាក់បញ្ញើ នៅធនាគារ
- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ (Claims on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃ កម្ពុជា។

ខ.២- ការថ្លឹង ២០% ចំពោះ ÷

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៣- ការថ្លឹង ៥០% ចំពោះ ÷

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុនដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៤- ការថ្លឹង ១០០% ចំពោះ ÷

- ទ្រព្យសកម្មដទៃទៀតទាំងអស់។

គ- បញ្ញត្តិដូចតទៅនេះ នឹងត្រូវអនុវត្តចំពោះខ្ទង់ក្រៅតារាងតុល្យការ

គ.១- ខ្ទង់ក្រៅតារាងតុល្យការត្រូវបានចាត់ថ្នាក់ជា ៤ ប្រភេទ ស្របតាមតារាងដែលមានក្នុងឧបសម្ព័ន្ធ។ ខ្ទង់ក្រៅតារាងតុល្យការទាំងនេះត្រូវបានយកមកគិត ÷

- តាមតម្លៃទាំងស្រុងរបស់វានៅពេលបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង
- តាមតម្លៃ ៥០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យកំរិតមធ្យម
- តាមតម្លៃ ២០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យធុនល្មម (moderate risk)
- ខ្ទង់ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាបមិនត្រូវបានយកមកគិតទេ។

គ.២- ចំនួនប្រាក់ដែលបានកំណត់ខាងលើ ត្រូវគុណជាមួយនឹងប្រភេទថ្លឹងដែលមានចែងនៅក្នុងកថាខណ្ឌខដែលត្រូវអនុវត្តចំពោះប្រភេទនៃការថ្លឹងរបស់អត្ថគាហកៈឬ ប្រភេទទ្រព្យសកម្មពាក់ព័ន្ធនោះ ។ ប៉ុន្តែ ÷

- ក្នុងករណីនៃការសន្យាដែលមានការធានាពីតតិយជន ការថ្លឹងគឺជាការថ្លឹងដែលអនុវត្តចំពោះអ្នកធានា ឬចំពោះអ្នកដែលត្រូវបានគេធានា
- ក្នុងករណីនៃការធានាចំពោះធនាគារមួយផ្សេងទៀត ទាក់ទងដល់ការសងបំណុលដែលរក្សាទុកនៅធនាគារផ្សេងទៀតនោះ ការថ្លឹងជាការថ្លឹងដែលអនុវត្តចំពោះឥណទេយ្យទាំងនេះ។

**ប្រការ ៤**.-

ធនាគារត្រូវប្រតិវេទអនុបាតសាធនភាពរបស់ខ្លួននៅ ថ្ងៃទី៣០ ខែមិថុនា និង ថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។ លើសពីនេះធនាគារជាតិនៃកម្ពុជានឹងអាចតម្រូវឱ្យធនាគារណាមួយគណនាអនុបាតសាធនភាពរបស់ខ្លួន នៅកាលបរិច្ឆេទផ្សេងទៀត ស្របតាមការចាំបាច់នៃការត្រួតពិនិត្យ។

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ក្នុងសារាចរពីគំរូសម្រាប់គណនាអនុបាតដោយត្រូវប្រកាសពីខ្ទង់ទាំងឡាយក្នុងគំរូនេះ។

ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ច្បាស់អំពីលក្ខណៈពិសេសរបស់ខ្ទង់ដែលត្រូវអនុវត្តការថ្លឹង ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ។

ធនាគារជាតិនៃកម្ពុជា អាចបដិសេធចំពោះការថ្លឹងដែលកំពុងអនុវត្តចំពោះទ្រព្យសកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ប្រសិនបើគិតថាខ្ទង់នោះមិនអាចបំពេញតាមល័ក្ខខណ្ឌជាធរមានបានដោយពេញចិត្តនោះទេ។

**ប្រការ ៥**.-

ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យមានការយកចិត្តទុកដាក់ថា គោលនយោបាយគណនេយ្យខ្សោយ ឬមិនគ្រប់គ្រាន់ធ្វើឱ្យអន្តរាយដល់សារៈប្រយោជន៍នៃកំរិតដើមទុន ដោយបង្កឱ្យមានអនុបាតសាធនភាពមិនត្រឹមត្រូវ ឬមិនអាចជឿបាន។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកថា ការអនុវត្តន៍គណនេយ្យរឹងមាំ និងការវាយតម្លៃត្រឹមត្រូវជាការសំខាន់ ជាពិសេសចំពោះការចាត់ថ្នាក់ត្រឹមត្រូវនិងការធ្វើសំវិធានធនទ្រព្យសកម្មតាមបញ្ញត្តិនៃប្រកាស ស្តីពី ចំណាត់ថ្នាក់ និងការធ្វើសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃ កម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធនៃប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ
# ចំណាត់ថ្នាក់ខ្ពង់ក្រៅតារាងតុល្យការ ដែលមានចែង
# ក្នុងកថាខណ្ឌ ៣-៣.១

ប្រតិបត្តិការទាំងឡាយណាដែលមិនមានចែងក្នុងតារាងខាងក្រោមនេះ ធនាគារត្រូវចាត់ថ្នាក់ខ្ពង់ទាំងនេះក្នុងប្រភេទប្រតិបត្តិការ ដែលមានលក្ខណៈស្រដៀងគ្នា បន្ទាប់ពីបានស្នើសុំធនាគារជាតិនៃកម្ពុជា ប្រសិនបើចាំបាច់។

១- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង

- ការធានាលើឥណទាន (ដកចេញហានិភ័យចំពោះអត្ថគាហកៈ)
- ការទទួលព្រម (acceptance)
- រូបិយបដិភោគ (endorsement) លើផលប័ត្រដែលមិនមានឈ្មោះរបស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុមួយផ្សេងទៀត
- សកម្មភាពប្រតិបត្តិការដោយមានឧបាស្រ័យ (recourse)
- កំរិតឥណទានមិនអាចបដិសេធបាន (irrevocable credit line) ឬការធានាដែលមានលក្ខណៈជំនួសឥណទាន។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យខ្ពស់

២- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម

- ការសន្យាសងប្រាក់តាមឯកសារឥណទាន ដែលបានចេញផ្សាយឬបញ្ជាក់ហើយ នៅពេលដែលទំនិញមិនត្រូវបានប្រើជាវត្ថុបញ្ចាំ
- ការធានានិងសញ្ញាប័ណ្ណឧបត្ថម្ភ (warranties and indemnity bonds) (រួមទាំង tender, performance, customs and tax bonds ) និងការធានាដែលមិនមានលក្ខណៈជំនួសឥណទាន
- កិច្ចសន្យាផ្តល់ឥណទានមិនទាន់ប្រើ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាឱ្យខ្ចីដែលមានកាលកំណត់លើសពីមួយឆ្នាំ
- ប្រតិបត្តិផ្សេងទៀតដែលមានហានិភ័យមធ្យម

៣- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យធនល្មម

- ឯកសារឥណទានដែលត្រូវបានចេញផ្សាយឬបញ្ជាក់ហើយ ទំនិញត្រូវបានប្រើជាវត្ថុបញ្ចាំ និងប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀត
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យធន់ល្មម

៤- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាប

- ឥណទានមិនទាន់ប្រើប្រាស់ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាឱ្យខ្ចីដែលមានកាលកំណត់រហូតពេញមួយឆ្នាំ ឬដែលអាចលុបចោលដោយគ្មានលក្ខខណ្ឌនៅពេលណាក៏បានដោយគ្មានការជូនដំណឹង។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យទាប។

ធ៧-០១-១៣៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ឥណទានចំពោះសម្ព័ន្ធញាតិ

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០២-១៤៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសលេខធ៧-០១-១៣៧ ប្រក ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។

**ប្រការ ១**.-

សម្ព័ន្ធញាតិដូចមានចែងនៅមាត្រាទី៤៩ និង៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ២**.-

ឥណទាននិងឥណទានលើសសមតុល្យចំពោះសម្ព័ន្ធញាតិត្រូវអនុវត្តតាមលក្ខខណ្ឌធម្មតានៃថេរៈវេលា អត្រាការប្រាក់វត្ថុបញ្ចាំនិងកាលវិភាគត្រូវទូទាត់សងវិញ។

លក្ខខណ្ឌធម្មតាក្នុងន័យនេះ គឺជាលក្ខខណ្ឌដែលត្រូវអនុវត្តចំពោះអតិថិជនមិនមែនសម្ព័ន្ធញាតិ ក្នុងកាលៈទេសៈដូចគ្នា។

**ប្រការ ៣**.-

បញ្ញត្តិដែលមានចែងក្នុងមាត្រា ២ មិនអនុវត្តចំពោះបំណុលបំពេញលើដើមទុន ( Subordinated debts) ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងកាន់កាប់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា ដែលជាក្រុមហ៊ុនមេរបស់ពួកគេឡើយ។

**ប្រការ ៤**.-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០២-១៤៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២)

សរុបឥណទានដក់សល់ថ្លឹងចំពោះសម្ព័ន្ធញាតិ មិនត្រូវឱ្យលើសពី១០%នៃមូលនិធិផ្ទាល់សុទ្ធទេ ទោះជាក្នុងករណីណាក៏ដោយ។ ការគណនាឥណទានសម្ព័ន្ធញាតិមិនត្រូវរួមបញ្ចូលការតំកល់ប្រាក់នៅទីស្នាក់ការកណ្តាល ឬនៅក្រុមហ៊ុនមេ ក្រោមលក្ខខណ្ឌពីរដូចខាងក្រោម:

- ទីស្នាក់ការកណ្តាល ឬក្រុមហ៊ុនមេជាធនាគារ
- ត្រូវមានភស្តុតាងបង្ហាញថាធនាគារមានចំណាត់ថ្នាក់ស្មើ ឬខ្ពស់ជាង A- តាមវិធីសាស្ត្រ Standard & Poor ឬតាមវិធីសាស្ត្រសមមូលដោយភ្នាក់ងារចាត់ថ្នាក់ដែលអន្តរជាតិទទួលស្គាល់។

ឥណទានដក់សល់ត្រូវគណនាទៅតាមប្រកាសស្តីពីអនុបាតសាធនភាព (ប្រកាសបច្ចុប្បន្ន លេខ ធ៧-០០-៤៦ ប្រ.ក)។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ត្រូវគណនាស្របតាមប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ (ប្រកាសបច្ចុប្បន្ន លេខ ធ៧-០១០-១៨២ ប្រ.ក )។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ ត្រូវធ្វើប្រតិវេទន៍ប្រចាំត្រីមាសលើឥណទានដែលពាក់ព័ន្ធជូនធនាគារជាតិនៃកម្ពុជាស្របតាមគំរូដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

អត្ថបទចម្លងនៃប្រតិវេទន៍នេះ ត្រូវចម្លងជូនក្រុមប្រឹក្សាភិបាលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៦-២២៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ប្រការ ១**.-

ឥណទានធំ (Large Exposure) គឺជាចំនួនសរុបនៃឥណទាន ឬការសន្យាតាមហត្ថលេខា ដែលកើតចេញ ពីប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយជាមួយអត្ថគាហកតែមួយដែលមានចំនួនប្រាក់លើសពីដប់ភាគរយ (១០%)នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ។ ឥណទានដែលមានចំនួនប្រាក់ធំសំដៅដល់ឥណទាន ដែលមានចំនួនប្រាក់ខ្ពស់បំផុតនៃប្រភេទឥណទានណាមួយ ដូចខាងក្រោម ដែលតទៅនេះហៅថា "ឥណទាន"៖

ក - សមតុល្យនៃឥណទាន ឬនៃការសន្យាតាមហត្ថលេខា

ខ - ចំនួនប្រាក់នៃឥណទាន ឬនៃការសន្យាតាមហត្ថលេខា ដែលបានអនុញ្ញាត។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាជានិច្ចនូវអនុបាតនៃឥណទានធំសរុប ដែលកើតចេញពីប្រតិបត្តិការជាមួយអត្ថគាហកតែមួយ មិនឱ្យលើសពីម្ភៃភាគរយ(២០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ។

**ប្រការ ៣**.-

សម្រាប់ប្រកាសនេះ មូលនិធិផ្ទាល់សុទ្ធត្រូវបានគណនាស្របតាមខ្លឹមសារនៃប្រកាសលេខ ធ៧-០១០-១៨២ ប្រក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

សម្រាប់ប្រកាសនេះ ឥណទានដែលជាប់ទាក់ទងទៅនឹងហានិភ័យនៃការខកខានមិនបានសងរបស់បដិភាគី ត្រូវតែបានថ្លឹង (Risk Weighted) ដូចមានកំណត់នៅក្នុងប្រការ ៣ នៃប្រកាសស្តីពី អនុបាតសាធនភាព លេខធ៧-០០-៤៦ ប្រក ចុះថ្ងៃទី១៦ ខែកម្ភៈ ឆ្នាំ២០០០។ ខ្ទង់ទាំងឡាយដែលបានដកចេញនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ មិនត្រូវបានចាត់ទុកថាជាហានិភ័យឥណទានទេ។

**ប្រការ ៤**.-

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមកតាមបែបមួយ ដែលថានៅពេលដែលបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះដាច់ខាតនឹងនាំឱ្យបុគ្គលផ្សេងទៀតមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬ ច្រើននៅពេលណាដែល៖

ក-បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ-បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ-បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ(de facto management)

ឃ-បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពីដប់ភាគរយ(១០%)ហើយពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នា ដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (Francise)។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ ។

**ប្រការ ៥**.-

ចំពោះឥណទានធំ (Large Exposure) ដែលមានការធានាពីធនាគារផ្សេងទៀត ឬពីគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ការថ្លឹង (Risk Weighted) ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះត្រូវបានកាត់បន្ថយពាក់កណ្តាល និងដោយត្រូវមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ហើយស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម៖

ក- លិខិតដែលផ្តល់ដោយធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិជាអ្នកធានាត្រូវបញ្ជាក់អំពីការសន្យាជាផ្លូវការក្នុងការទូទាត់សងវិញភ្លាមនូវសមតុល្យនៃឥណទាន នៅពេលដែលករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម បានកើតឡើង៖
- ការសងរំលស់មួយគ្រា ត្រូវបានខកខានមិនបានទូទាត់សងនៅថ្ងៃកំណត់ ឬ
- ឥណទានបានក្លាយទៅជាឥណទានមិនដំណើរការ

ខ- លិខិតធានាត្រូវចុះហត្ថលេខា និងទទួលដឹងឮពីរាជ្ញាធរត្រួតពិនិត្យរបស់គ្រឹះស្ថានធនាគារ ឬពីទីស្នាក់ការកណ្តាលនៃគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញលិខិតធានានោះ។

**ប្រការ ៦**.-

យោងទៅតាមការស្នើសុំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចបង្កើនអនុបាតអតិបរមា ដែលមានចែងនៅក្នុងប្រការ២នៃប្រកាសនេះទៅដល់កំរិតអតិបរមាមិនឱ្យលើសពីសាមសិបប្រាំភាគរយ (៣៥%) នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន ដែលផ្តល់ឥណទាននៅក្រោមលក្ខខណ្ឌដូចខាងក្រោម៖

ក- ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់យ៉ាងហោចណាស់ថា "ល្អ" ដោយផ្អែកលើចំណាត់ថ្នាក់ផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ឬទទួលបានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ពីភ្នាក់ងារចាត់ថ្នាក់អន្តរជាតិ។

ខ- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីមានភាពរឹងមាំ ដែលរួមមានផែនការអាជីវកម្ម សាធនភាព លទ្ធភាពរកប្រាក់ចំណេញ និងការគ្រប់គ្រងមានលក្ខណៈល្អប្រសើរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់ឱ្យធនាគារជាតិនៃកម្ពុជា នូវរបាយការណ៍សវនកម្មហិរញ្ញវត្ថុ របាយការណ៍វិភាគឥណទាន និងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត នៅពេលដាក់ពាក្យស្នើសុំផ្តល់ឥណទានលើសពីសមាមាត្រដែលមានចែងក្នុងប្រការ២នៃប្រកាសនេះ។

**ប្រការ ៧**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរក្សាជានិច្ចនូវអនុបាតឥណទានធំ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ដែលមានចំនួនសរុបអតិបរមាមិនឱ្យលើសពីបីរយភាគរយ (៣០០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ។

**ប្រការ ៨.-**

ឥណទានធំដូចដែលមានចែងនៅក្នុងប្រការ១ត្រូវស្ថិតនៅក្រោមនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យផ្ទៃក្នុងជាពិសេសដោយកំរិតកំណត់នៃការប្រគល់សិទ្ធិក្នុងការសំរេចឥណទាន ឬ ដោយការធ្វើយ៉ាងណាឱ្យចំនួនអតិបរមា នៃអនុបាតដែលមានចែងនៅក្នុងប្រការ ២ ដល់ប្រការ ៧ នៃប្រកាសនេះ ត្រូវបានគោរពគ្រប់ពេលវេលា។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវប្រកាន់យកនូវរាល់ជំហានចាំបាច់ដើម្បីរក្សាទុកនូវការកត់ត្រាមជ្ឈការពេញលេញចំពោះឥណទានរបស់ខ្លួន ជាពិសេសឥណទានទាំងឡាយណាដែលផ្តល់ចំពោះអត្ថគាហកដែលមានចំណងទាក់ទងគ្នាទៅវិញទៅមកតាមខ្លឹមសារនៃប្រការ៤ នៃប្រកាសនេះ។ ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យផ្តល់នូវរបាយការណ៍ ស្តីពី ជំហានទាំងឡាយដែលបានអនុវត្ត។

**ប្រការ ៩.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើប្រតិវេទន៍ប្រចាំខែជូនធនាគារជាតិនៃកម្ពុជាស្តីពី ឥណទានធំរបស់ខ្លួន តាមគំរូឧបសម្ព័ន្ធដែលមានភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ១០.-**

ប្រកាសនេះមិនត្រូវបានអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ។

**ប្រការ ១១.-**

ប្រកាសលេខ ធ៧-០០-៥២ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជានិងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៩-២១៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់របាយការណ៍ឥណទានធំ និង
# ពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា គ្រឹះស្ថាន ត្រូវពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ ប្រចាំត្រីមាស នូវឥណទានធំបំផុតចំនួន ៥០។ គ្រឹះស្ថាន ត្រូវសម្រប និងលើកកំពស់គុណភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ខ្លួន ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ២**.-

ហានិភ័យឥណទានប្រមូលផ្តុំអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ដូច្នេះ តម្រូវឱ្យមានការពិនិត្យតាមដានជាពិសេស ដើម្បីវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃការធ្លាក់ចុះស្ថានភាពអ្នកខ្ចីធំៗ ក្នុងកាលៈទេសៈដែលសេដ្ឋកិច្ចមិនអំណោយផល។

លើសពីនេះ ទោះបីមានបទប្បញ្ញត្តិទាក់ទងនឹងហានិភ័យឥណទានធំក្តី ក៏ហានិភ័យឥណទានប្រមូលផ្តុំ ត្រូវតែសមស្របទៅនឹងហានិភ័យដែលអាចទទួលយកបាន និងភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។ ហានិភ័យឥណទានដែលត្រូវបានចាត់ទុកថាប្រមូលផ្តុំខ្លាំងពេក តម្រូវឱ្យមានការវាយតម្លៃឡើងវិញនូវគោលនយោបាយ និងកម្រិតកំណត់ឥណទានជាបន្តបន្ទាប់ និងប្រចាំគ្រា។

**ប្រការ ៣**.-

រាល់ត្រីមាស គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិនូវបញ្ជីអ្នកខ្ចីធំបំផុត ជាឯកត្តជន ឬជាក្រុម ចំនួនហាសិប (៥០)។ របាយការណ៍នេះ ត្រូវមានជាអប្បបរមានូវទិន្នន័យ និងព័ត៌មានទាំងអស់ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ នូវការវាយតម្លៃសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុជារួមរបស់អ្នកខ្ចី ជាពិសេស បើឥណទានត្រូវបានធ្វើចំណាត់ថ្នាក់មិនល្អ រាល់ឯកសារភស្តុតាង ដែលមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ ត្រូវបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ ដើម្បីវាយតម្លៃអំពីសក្តានុពលនៃការខាតបង់ និងផលប៉ះពាល់ផ្សេងទៀត ជាពិសេស អំពីស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាពរបស់គ្រឹះស្ថាន។

របាយការណ៍ប្រចាំត្រីមាសទាំងនេះ ត្រូវមានបញ្ជាក់អំពីវិធានការណ៍ទាំងអស់ដែលគ្រឹះស្ថានបាន និងត្រូវអនុវត្តដើម្បីការពារផលប្រយោជន៍របស់គ្រឹះស្ថាន។

## ជំពូក ២
## ការរួមបញ្ចូលគ្នានូវហានិភ័យ

**ប្រការ ៤.-**

នៅពេលដែលឯកត្តជន ឬនីតិបុគ្គលពីរ ឬច្រើនត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ដោយសារតែមានទំនាក់ទំនងទៅវិញទៅមក គ្រឹះស្ថានត្រូវបូកសរុបហានិភ័យទាំងអស់ឱ្យបានត្រឹមត្រូវ និងរាយលំអិតអ្នកខ្ចីនីមួយៗ និងកម្រិតអនុម័តឥណទានដែលបង្កើតបានជាហានិភ័យរួមបញ្ចូលគ្នា។

**ប្រការ ៥.-**

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមក ដែលប្រសិនបើបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះ នឹងនាំឱ្យបុគ្គលផ្សេងទៀតត្រូវតែមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬច្រើននៅពេលណាដែល ៖

ក- បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ- បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ- បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ(de facto management)

ឃ- បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពីដប់ភាគរយ(១០%) ហើយ ពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នាដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (franchise)។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ។

**ប្រការ ៦.-**

លើសពីនេះ គ្រឹះស្ថានអាចកំណត់នូវកត្តាពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ឬទំនាក់ទំនងទៅវិញទៅមកផ្សេងទៀត ជាពិសេសដោយផ្អែកលើការវិភាគប្រភពដើម និងការប្រមូលផ្តុំនៃលំហូរសាច់ប្រាក់។

**ប្រការ ៧.-**

គ្រឹះស្ថាន ត្រូវរួមបញ្ចូលគ្នានូវហានិភ័យទាំងអស់ឱ្យបានសមស្រប ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពហានិភ័យទាំងមូលទៅលើសំណុំកូនបំណុលដែលមានទំនាក់ទំនងជាមួយគ្នាជាអ្នកខ្ចីតែមួយ។

## ជំពូក ៣
## ទម្រង់ និងខ្លឹមសារ នៃរបាយការណ៍

**ប្រការ ៨.-**

គ្រឹះស្ថានត្រូវរាយការណ៍តាមគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ របាយការណ៍នេះ ត្រូវតែមានខ្លឹមសារគ្រប់គ្រាន់អាចទទួលយកបាន។ ហានិភ័យឥណទានធំបំផុតចំនួន ៥០ ត្រូវតែបានបង្ហាញតាមលំដាប់ចំនួនប្រាក់ថយចុះ។

**ប្រការ ៩**.-

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ត្រូវតែសម្គាល់អត្តសញ្ញាណឱ្យបានច្បាស់លាស់ និងត្រូវតែបញ្ជាក់អំពីប្រភេទនៃទំនាក់ទំនងទៅវិញទៅមក។ ព័ត៌មានលំអិតអំពីទំនាក់ទំនង ក្នុងចំណោមសមាសភាពទាំងឡាយនៃក្រុមអ្នកខ្ចី ត្រូវមានឧបសម្ព័ន្ធភ្ជាប់មកជាមួយរបាយការណ៍។

ព័ត៌មានអំពីអត្តសញ្ញាណទាំងនោះត្រូវមានជាអប្បបរមា ដូចខាងក្រោម ៖

- រូបវន្តបុគ្គលៈ នាមនិងគោត្តនាមទាំងអស់ដែលប្រើជាផ្លូវការ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន មុខរបរ/វិជ្ជាជីវៈ និង វិស័យសេដ្ឋកិច្ច
- នីតិបុគ្គលៈ នាមករណ៍ យីហោ លេខចុះបញ្ជីពាណិជ្ជកម្ម ថ្ងៃបង្កើតក្រុមហ៊ុន អាសយដ្ឋានក្រុមហ៊ុន មុខរបរ វិស័យសេដ្ឋកិច្ច និងព័ត៌មានផ្សេងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃអត្តសញ្ញាណ។

មុនពេលរួមបញ្ចូលហានិភ័យរបស់នីតិបុគ្គល និង/ឬរូបវន្តបុគ្គលដែលត្រូវបានចាត់ថាជាអ្នកខ្ចីតែមួយ គ្រឹះស្ថានត្រូវរាយលំអិតបុគ្គលនីមួយៗតាមកម្រិតអនុម័តឥណទានទាំងអស់។

ការរួមបញ្ចូលគ្នាត្រូវអនុវត្តដោយបូកសរុបដោយឡែកពីគ្នារវាងសមតុល្យដក់សល់ដុលក្នុងតារាងតុល្យការ និងសមតុល្យជាប់កិច្ចសន្យានៃខ្ទង់ក្រៅតារាងតុល្យការ។

**ប្រការ ១០**.-

ចំនួនហានិភ័យឥណទានក្នុងតារាងតុល្យការត្រូវតែរាយការណ៍ដោយប្រើចំនួនដុល ដែលជាចំនួនប្រាក់ដើមដក់សល់ ដោយមិនបញ្ចូលសំវិធានធនជាក់លាក់ និងការប្រាក់លើកលែងតែការប្រាក់នោះត្រូវបានបូកបញ្ចូលជាប្រាក់ដើមដូចមានចែងក្នុងកិច្ចសន្យា។

ហានិភ័យឥណទានធំត្រូវបានរាយលំអិតតាមកម្រិតអនុម័តឥណទាននិងតាមអ្នកខ្ចីនីមួយៗ។ ព័ត៌មានអប្បបរមាដែលត្រូវមាន គឺប្រភេទហានិភ័យ (ឥណទានវិបារូបន៍ ឬឥណទាន) ប្រាក់ដើមដក់សល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង ប្រភេទនៃការរំលោះ និងកាលវសាន្ត។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

**ប្រការ ១១**.-

ហានិភ័យក្រៅតារាងតុល្យការត្រូវតែបានរាយការណ៍ ដោយបូកបញ្ចូលនូវចំនួនសមតុល្យជាប់កិច្ចសន្យា ដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍។

កម្រិតអនុម័តឥណទាននោះ ត្រូវតែបានរាយលំអិតតាមអត្ថគាហកនីមួយៗ ហើយឆ្លុះបញ្ចាំងពីចំនួនសមតុល្យជាប់កិច្ចសន្យាដែលនៅសល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង និងពីកាលវសាន្តបើមាន ហើយត្រូវតែមានបញ្ជាក់ច្បាស់អំពីប្រភេទប្រតិបត្តិការ (ឥណទានវិបារូបន៍ដែលមិនបានប្រើ ការសន្យាឥណទានដែលមិនទាន់បានប្រើប្រាស់ ការធានានិងប្រភេទនៃការធានា)។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

## ជំពូក ៤
## កាលបរិច្ឆេទនៃរបាយការណ៍

**ប្រការ ១២**.-

គ្រឹះស្ថានទាំងអស់ ត្រូវផ្ញើរបាយការណ៍អំពីហានិភ័យឥណទានធំបំផុតចំនួន ៥០ ប្រចាំត្រីមាសគិតត្រឹមចុងខែមិនា មិថុនា កញ្ញា និងធ្នូ មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ ខែទីមួយ នៃត្រីមាសបន្ទាប់។

## ជំពូក ៥
## ទណ្ឌកម្ម

**ប្រការ ១៣**.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូក ៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៤**.-

ប្រកាសនេះមិនអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ។

**ប្រការ ១៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៦**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១-១៨៦ ប្រ.ក

# ប្រកាស
# ស្តីពី
# អចលនទ្រព្យរបស់ធនាគារ

**ប្រការ ១**.-

កម្មសិទ្ធិលើអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារត្រូវបញ្ញត្តិតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារអាចទទួលយកអចលនទ្រព្យបានតែក្នុងករណីពីរ ៖

- អចលនទ្រព្យទាំងនោះត្រូវបានប្រើប្រាស់ដោយផ្ទាល់សម្រាប់ប្រតិបត្តិការធនាគារ
- អចលនទ្រព្យមិនបានប្រើប្រាស់សម្រាប់ប្រតិបត្តិការធនាគារនោះ ប៉ុន្តែអចលនទ្រព្យទាំងនោះ បានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ ដោយការរឹបអូសតាមច្បាប់ និងជួយកាត់បន្ថយហានិភ័យលើបំណុលអាក្រក់។

**ប្រការ ៣**.-

អចលនទ្រព្យដែលធ្វើលទ្ធកម្មដោយធនាគារសម្រាប់គោលដៅប្រតិបត្តិការ ត្រូវតែរក្សាមិនឱ្យលើសពី៣០% នៃមូលនិធិផ្ទាល់សុទ្ធសរុប ដូចមានកំណត់ក្នុងប្រកាសលេខ ធ៧-០១០-១៨២ ប្រក។

**ប្រការ ៤**.-

អចលនទ្រព្យដែលគ្មានទំនាក់ទំនងផ្ទាល់ជាមួយប្រតិបត្តិការធនាគារ ត្រូវលក់ចេញមិនឱ្យលើសពីមួយឆ្នាំ ក្រោយកាលបរិច្ឆេទដែលអចលនទ្រព្យបានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ ហើយអចលនទ្រព្យទាំងនោះត្រូវកត់ត្រាក្នុងបញ្ជីគណនីរបស់ធនាគារតាមតម្លៃជាក់ស្តែងសមស្រប។

**ប្រការ ៥**.-

ការរំលោភលើបញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលរងការពិន័យ និងទណ្ឌកម្មដូចដែលមានចែងនៅត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ធនាគារត្រូវរាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ពីការអនុវត្តន៍ស្របតាមខ្លឹមសារនៃប្រកាសនេះ តាមគំរូដែលកំណត់ដោយសារាចរណែនាំ។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០០-៣៨ ប្រ.ក

# ប្រកាស
# ស្តីពី
# សាច់ប្រាក់ងាយស្រួលរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៤-២០៧ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាស ធ៧-០២-១៨៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី វិសោធនកម្ម លើសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១.-**

ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតទៅនេះហៅថា "ធនាគារ" ត្រូវអនុវត្តឱ្យបានតាមវិធានគ្រប់គ្រងក្នុងគោលបំណងធានាសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម។

**ប្រការ ២.-**

ធនាគារត្រូវគណនាអនុបាតសាច់ប្រាក់ងាយស្រួលលើមូលដ្ឋាន នៃរបាយការណ៍គណនេយ្យប្រចាំខែរបស់ខ្លួន។

**ប្រការ ៣.-**

ភាគយកនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន៖

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះ នៅពេលសមតុល្យនេះតំណាងឱ្យស្ថានភាពនៃអ្នកឱ្យខ្ចី

២- ចំណែកនៃការឱ្យខ្ចីនៅសល់រយៈពេលមិនលើសពី ១ ខែ (លើកលែងតែឥណទានចំពោះអតិថិជនដោយគ្មានកាលវសាន្ត ដូចជា ឥណទានលើសសមតុល្យ)

៣- ប័ណ្ណរតនាគារក្នុងរយៈពេលនៅសល់មិនលើសពី ១ ខែ។

**ប្រការ ៤.-**

ភាគបែងនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន ៖

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះនៅពេលសមតុល្យនេះតំណាងឱ្យស្ថានភាពអ្នកខ្ចី

២- ៨០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និងវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលមានរយៈពេលនៅសល់មិនលើសពី ១ ខែ

៣- ៥០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និង វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលមានរយៈពេលនៅសល់លើសពី ១ ខែ

៤- ៥០ ភាគរយនៃប្រាក់បញ្ញើសញ្ញ័យ

៥- ៦០ ភាគរយនៃប្រាក់បញ្ញើគ្មានកាលកំណត់។

**ប្រការ ៥**.-

សមតុល្យសាច់ប្រាក់ស្មើនឹង ផលសងរវាងសរុបខ្ទង់ឥណពន្ធ ជាមួយសរុបខ្ទង់ឥណទានដូចមានរៀបរាប់ខាងក្រោម៖

១- ខ្ទង់ឥណពន្ធ

ក- សាច់ប្រាក់ និង មាស

ខ- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា

គ- ប្រាក់បញ្ញើនៅធនាគារផ្សេងៗ

ឃ-ចំណែកនៃការឱ្យខ្ចីទៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង ក្នុងរយៈពេលនៅសល់មិនលើសពី១ខែ (លើកលែងតែឥណទានដែលគ្មានកំណត់កាលវសាន្ត)។

២- ខ្ទង់ឥណទាន

- សមតុល្យឥណទាយីលើគណនីប្រាក់បញ្ញើគ្មានកាលកំណត់ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅធនាគារ ឬនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង
- ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងពីធនាគារផ្សេងដោយមានរយៈពេលនៅសល់មិនលើសពី ១ ខែ។

សមតុល្យសាច់ប្រាក់ត្រូវបានចាត់ទុកថា តំណាងឱ្យស្ថានភាពអ្នកឱ្យខ្ចី នៅពេលណាសរុបខ្ទង់ឥណពន្ធ កើនលើសសរុបខ្ទង់ឥណទាន។ សមតុល្យសាច់ប្រាក់ត្រូវចាត់ទុកថាតំណាងឱ្យស្ថានភាពអ្នកខ្ចីនៅពេលណាសរុបខ្ទង់ ឥណទានកើនលើសសរុបខ្ទង់ឥណពន្ធ។

**ប្រការ ៦**.-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៤-២០៧ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ និង ប្រកាស ធ៧-០២-១៨៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២)

នៅរៀងរាល់ពេល ធនាគារត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត ហាសិបភាគរយ (៥០ ភាគរយ)។

**ប្រការ ៧**.-

ធនាគារត្រូវធ្វើប្រតិវេទន៍ប្រចាំខែពីអនុបាតសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ស្របតាមគំរូដែលធនាគារជាតិនៃ កម្ពុជាបានដាក់ចេញ។

**ប្រការ ៨**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-៩៨-៤១៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់ក្នុងស្រុក
# របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

**ប្រការ ១**.-

ដាក់ចេញនូវវិធានការទប់ស្កាត់ការបញ្ចេញទៅក្រៅប្រទេសនូវប្រភពទុនជាប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានក្នុងស្រុករបស់គ្រឹះស្ថានធនាគារ (ធនាគារពាណិជ្ជ) និងគ្រឹះស្ថានហិរញ្ញវត្ថុក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យសញ្ច័យក្នុងស្រុកអាចបម្រើផ្នែកវិនិយោគក្នុងប្រទេសបានទាំងស្រុង។

**ប្រការ ២**.-

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាទុកទាំងអស់ (១០០ ភាគរយ) នូវប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើអន្តរធនាគារ សម្រាប់ការប្រើប្រាស់របស់ខ្លួននៅក្នុងប្រទេស។

សក្ខីកម្មនៃការរក្សាទុកនេះ ត្រូវបានឆ្លុះបញ្ចាំងដោយចំនួនសរុបនៃខ្ទង់ប្រាក់មួយចំនួននៅខាងទ្រព្យសកម្មនៃ តារាងតុល្យការដូចខាងក្រោម ៖

- សាច់ប្រាក់នៅក្នុងដៃ
- ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក
- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (ដកចេញនូវប្រាក់ដំកល់ធានាចំនួន ១០ ភាគរយនៃដើមទុន)
- និងប្រាក់ឱ្យខ្ចីចងការ និងបុរេប្រទាន

ជានិច្ចកាល ចំនួនសរុបនេះយ៉ាងហោចណាស់ត្រូវតែស្មើនឹងប្រាក់បញ្ញើសរុបដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើជាអន្តរធនាគារ។

**ប្រការ ៣**.-

នៅរៀងរាល់ខែ រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានត្រួតពិនិត្យ) នូវតារាងគណនាដែលបានចែងនៅប្រការ ២ ដោយភ្ជាប់ជាមួយរបាយការណ៍ប្រចាំខែ ស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម (តារាងតុល្យការ) ដែលធ្លាប់ផ្ញើមកជាប្រក្រតី។

ក្នុងករណីត្រួតពិនិត្យឃើញតារាងគណនានេះមិនឆ្លើយតបតាមលក្ខខណ្ឌដែលកំណត់នៅប្រការ ២ សាមីគ្រឹះស្ថាន ត្រូវរងការផាកពិន័យចំនួន ១ ភាគរយក្នុងមួយខែ លើចំនួនដែលខ្វះទុកជាការព្រមានលើកដំបូង សម្រាប់រយៈពេលមួយខែ ហួសពីនេះត្រូវរងវិធានការធ្ងន់ធ្ងរថែមទៀតតាមករណីជាក់ស្តែង។

**ប្រការ ៤**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៩-០៧៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្ម
# របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងធានាថា រាល់ឥណទាន និងទ្រព្យសកម្មទាំងអស់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវបានវាយតម្លៃយ៉ាងទៀងទាត់ ដោយប្រើប្រព័ន្ធធ្វើចំណាត់ថ្នាក់ដ៏ប្រុងប្រយ័ត្ន និងធានាថាបានធ្វើសំវិធានធន និងលុបចេញពីបញ្ជី បានទាន់ពេលវេលា និងសមស្របនៅក្នុងគណនីសំវិធានធនឥណទានបាត់បង់ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនិងលទ្ធផលនៃប្រតិបត្តិការរបស់គ្រឹះស្ថាន។

ប្រកាសនេះអនុវត្តចំពោះរាល់ឥណទាន និងបុរេប្រទាន និងទ្រព្យសកម្មដែលមានលក្ខណៈប្រហាក់ប្រហែល រួមបញ្ចូលទាំងឥណទានដែលផ្តល់ដល់បុគ្គលសម្ព័ន្ធ និងសម្ព័ន្ធញាតិផងដែរ ដែលមាននៅក្នុងតារាងតុល្យការរបស់គ្រឹះស្ថាន។

ក្នុងករណីដែលឥណទានមិនដំណើរការជះឥទ្ធិពលលើ សាធនភាព សាច់ប្រាក់ងាយស្រួល ស្ថានភាពចំណូលនៃធនាគារ អ្នកគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលត្រូវធ្វើការវិនិច្ឆ័យមួយផ្អែកលើហានិភ័យ និងសំឡឹងទៅមុខដោយគិតអំពីនិន្នាការនៃចំណាត់ថ្នាក់ទ្រព្យសកម្ម។

**ប្រការ ២**.-

"មូលធនកម្មការប្រាក់" មានន័យថារាល់ការបង្គរ និងការប្រាក់មិនអាចប្រមូលបានដែលត្រូវបូកបញ្ចូលក្នុងប្រាក់ដើមនៃឥណទាននៅថ្ងៃទូទាត់សងប្រាក់ ឬ ថ្ងៃឥណប្រតិទាន។ មូលធនកម្មការប្រាក់ក៏ត្រូវរួមបញ្ចូលផងដែរនូវការប្រាក់មិនបានទូទាត់លើហិរញ្ញប្បទានជាថ្មីឡើងវិញនៃឥណទាន។

សម្រាប់គោលបំណងនៃប្រកាសនេះ មិនអនុញ្ញាតឱ្យធ្វើមូលធនកម្មការប្រាក់ឡើយ លើកលែងតែ ៖

- អ្នកខ្ចីមានសមត្ថភាពក្នុងការទូទាត់សងបំណុលទាំងស្រុង (ប្រាក់ដើមបូកការប្រាក់) ក្នុងស្ថានភាពអាជីវកម្មធម្មតា
- មូលធនកម្មការប្រាក់ត្រូវបានគិតជាមុននាពេលអនុម័តឥណទានដំបូង ដោយផ្អែកលើផែនការកង្វះលំហូរសាច់ប្រាក់ជាបណ្តោះអាសន្នរបស់អ្នកខ្ចី
- ការទូទាត់សងរួមបញ្ចូលទាំងមូលធនកម្មការប្រាក់ផង គឺផ្អែកលើព្រឹត្តិការណ៍អនាគតជាក់លាក់ដែលអាចជឿជាក់បាន។

**"ដំណើរការនៃការប្រមូល"** មានន័យថាការប្រមូលបំណុលត្រូវដំណើរការ តាមលំដាប់ពេលវេលាដែលបានកំណត់ជាក់លាក់តាមរយៈ ៖

- បណ្តឹងទៅតុលាការ រួមទាំងការកាត់សេចក្តីប្រឆាំងអ្នកខ្ចី ឬ

- តាមរយៈការខិតខំប្រមូលបំណុល ដោយមិនប្តឹងទៅតុលាការ ប៉ុន្តែ រំពឹងថាបំណុលនោះ នឹងទទួលបានការទូទាត់សងយ៉ាងពេញលេញក្នុងកំឡុងពេល៩០ថ្ងៃ ឬ ស្តារបំណុលនោះឱ្យមកនៅស្ថានភាពបច្ចុប្បន្ន តាមរយៈការទូទាត់សងនូវចំនួនដែលនៅសល់។

**"ឥណទាន និងបុរេប្រទាន"** អាចត្រូវបានប្រើឆ្លាស់គ្នា រួមមានឥណទាន អប្បហារ បុរេប្រទាន ឥណទានវិបារូបន៍ រូបិយាណត្តិនាំចេញដែលបានទិញ ផលប័ត្រត្រូវទទួល ឬបានទិញ ឬរូបិយាណត្តិនាំចូល កាតព្វកិច្ចរបស់អតិថិជនលើស៊ីការ (Acceptances) ឬ ឧបករណ៍ឥណទាន ផ្សេងទៀតដែលបានផ្តល់ដល់អតិថិជននៃគ្រឹះស្ថានមួយ។

**"ទ្រព្យសកម្មមិនដំណើរការ"** មានន័យថាទ្រព្យសកម្មដែលលែងមានចំណូល។ សម្រាប់គោលបំណងនៃប្រកាសនេះ "ទ្រព្យសកម្មមិនដំណើរការ" ត្រូវបានចាត់ថ្នាក់ក្រោមស្តង់ដារ សង្ស័យ ឬបាត់បង់។

គណនីចរន្ត ដែលប្រើក្រោមរូបភាពជាឥណទានវិបារូបន៍ និងការពន្យារពេលឥណទានផ្សេងទៀត ដែលមិនបានរៀបចំជាមុននូវកាលវិភាគទូទាត់សងត្រូវបានចាត់ទុកថា "មិនដំណើរការ" នៅពេលដែលស្ថានភាពណាមួយក្នុងចំណោមស្ថានភាពដូចខាងក្រោមកើតមានឡើង ៖

- បំណុលរបស់អតិថិជនប្រើប្រាស់លើសពីកម្រិតអនុម័តក្នុងរយៈពេល ៩០ថ្ងៃបន្តបន្ទាប់គ្នា ឬច្រើនជាងនេះ
- ឥណទានរបស់អតិថិជនហួសកាលកំណត់លើសពី ៩០ ថ្ងៃ ឬ ច្រើនជាងនេះ
- អតិថិជនមិនបានបង់ការប្រាក់តាមកាលកំណត់បង់ក្នុងរយៈពេល ៩០ ថ្ងៃ ឬ ច្រើនជាងនេះ ឬ
- គណនីចរន្តមិនមានសកម្មភាពក្នុងរយៈពេល ៩០ ថ្ងៃ ឬ មិនមានប្រាក់បញ្ញើគ្រប់គ្រាន់សម្រាប់សងការប្រាក់ដែលជំពាក់ក្នុងកំឡុងពេលប្រើប្រាស់ឥណទាន។

**"ខ្ទង់ក្រៅតារាងតុល្យការ"** មានន័យថាខ្ទង់ទាំងឡាយណាដែលមិនបានបង្ហាញនៅក្នុងតារាងតុល្យការ ប៉ុន្តែនាំឱ្យមានហានិភ័យឥណទាន។ ហានិភ័យទាំងនោះរួមមាន ការធានា ការធ្វើស៊ីការ ការធានាលើប្រតិបត្តិការ លិខិតឥណទាន និងខ្ទង់ក្រៅតារាងតុល្យការផ្សេងទៀត ដែលធនាគារជាតិនៃកម្ពុជា កំណត់ថាអាចនាំឱ្យមានហានិភ័យឥណទាន។

**"ហួសកាលកំណត់ ឬ លើសកាលកំណត់"** មានន័យថា ឥណទានដែល ៖

- អតិថិជនមិនបានបង់ប្រាក់ដើម ឬ ការប្រាក់តាមកាលកំណត់រយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ ឬ
- ចំនួនការប្រាក់ ដែលស្មើនឹងការប្រាក់បង្គរក្នុងរយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ ត្រូវបានបញ្ចូលជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី។

គណនីចរន្ត ដែលប្រើក្រោមរូបភាពជាឥណទានវិបារូបន៍ និងការពន្យារពេលឥណទានផ្សេងទៀត ដែលមិនមានរៀបចំជាមុននូវកាលវិភាគទូទាត់សង ត្រូវចាត់ទុកថាហួសកាលកំណត់នៅពេលដែលមានស្ថានភាពណាមួយខាងក្រោមនេះ ៖

- អតិថិជនបានប្រើឥណទានលើសកម្រិតអនុម័តរយៈពេល ៣០ ថ្ងៃ ជាប់ៗគ្នា ឬ ច្រើន ជាងនេះ
- ឥណទានរបស់អតិថិជនហួសកាលកំណត់ប្រើរយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ
- អតិថិជនមិនបានបង់ការប្រាក់រយៈពេល ៣០ថ្ងៃ ឬច្រើនជាងនេះ
- គណនីចរន្តមិនមានសកម្មភាពរយៈពេល ៣០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។

**"ចំណាយសំវិធានធនសម្រាប់ឥណទានបាត់បង់"** មានន័យថា ជាគណនីមួយនៃរបាយការណ៍ចំណេញ-ខាតដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើន ឬបន្ថយសំវិធានធនឥណទានបាត់បង់ក្នុងតារាងតុល្យការដើម្បីរក្សាគណនីនោះ នៅកម្រិតមួយគ្រប់គ្រាន់សម្រាប់ស្រូបយកការខាតបង់ ដែលបានគិតទុកនៅក្នុងសំពៀតឥណទាន។

**"សំវិធានធនសម្រាប់ឥណទានបាត់បង់"** មានន័យថា ជាគណនីមួយនៃតារាងតុល្យការដែលបង្កើតឡើងសម្រាប់ការចំណាយសំវិធានធននៅក្នុងរបាយការណ៍ចំណេញ-ខាត និងសម្រាប់កាត់កងជាមួយចំណែកឥណទានបាត់បង់ដែលត្រូវលុបចោល។ គណនីសំវិធានធនឥណទានបាត់បង់ត្រូវកាត់កងជាមួយឥណទានដុល សម្រាប់គោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

**"ឥណទានរៀបចំឡើងវិញ"** មានន័យថា ឥណទានដែលត្រូវបានធ្វើការកែប្រែកាលកំណត់សង ឬធ្វើហិរញ្ញប្បទានឡើងវិញ ស្របតាមកិច្ចសន្យាដែលកំណត់ការទូទាត់សងទៅតាមគ្រាជាថ្មី ដោយសារភាពទន់ខ្សោយនៃស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និង/ឬកង្វះលទ្ធភាពក្នុងការទូទាត់សងឥណទាន ដូចដែលបានព្រមព្រៀងពីដំបូង។

## ជំពូក ២
## ការធ្វើចំណាត់ថ្នាក់ឥណទាន និងទ្រព្យសកម្ម

**ប្រការ ៣.-**

គ្រប់ឥណទាន និងទ្រព្យសកម្មទាំងអស់ត្រូវបានចាត់ថ្នាក់ដោយផ្អែកទៅលើសមត្ថភាពសងរបស់សមភាគី។ សមត្ថភាពសងនេះត្រូវបានវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែងនិងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ និង
- គុណភាពនៃការរៀបចំឯកសារ។

ករណីប្រភពដំបូងនៃការទូទាត់សងមិនអាចធានាបានចំពោះការទូទាត់សង ឥណទានអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬមិនដំណើរការ ទោះបីជាឥណទាននោះមានលក្ខណៈ ចរន្ត ឬអាចនឹងត្រូវទូទាត់ដោយវត្ថុធានាក៏ដោយ។ ការធ្វើចំណាត់ថ្នាក់ឡើងវិញក៏អាចធ្វើផងដែរ ប្រសិនបើ សមភាគីមិនអាច

បំពេញតាមលក្ខខណ្ឌដើមនៃការទូទាត់សង ឬបើឥណទានដែល ដំណើរការមិនល្អ នោះត្រូវបានដោះស្រាយដោយបច្ចេកទេសនៃការផ្លាស់ប្តូរលក្ខខណ្ឌ បុនហិរញ្ញប្បទាន ឬ បុរេប្រទានបន្ថែម។

ក្នុងករណីដែល ការធ្វើចំណាត់ថ្នាក់នីមួយៗនៃឥណទានផ្អែកលើលក្ខណៈវិនិច្ឆ័យមិនច្បាស់លាស់ ការធ្វើចំណាត់ថ្នាក់ដ៏តឹងរឹងជាងនេះត្រូវតែអនុវត្ត។ ការចាត់ថ្នាក់ឥណទានមិនកម្រិត ត្រឹមតែនិយមន័យ ដូចមានចែងក្នុងប្រការ ៤ ខាងក្រោមនេះទេ។ ក្នុងករណីដែលការវិភាគស្ថានភាពហិរញ្ញវត្ថុ សមត្ថភាព និងឆន្ទៈសងត្រឡប់មកវិញរបស់អ្នកខ្ចីបានបង្ហាញឱ្យឃើញថាមានស្ថានភាពធ្ងន់ធ្ងរ នោះចំណាត់ថ្នាក់ឥណទានត្រូវធ្វើឡើងឱ្យកាន់តែមានភាពតឹងរឹងបន្ថែមទៀត។

**ប្រការ ៤**.-

រាល់ទ្រព្យសកម្មត្រូវតែចាត់ថ្នាក់ជា ៥ ប្រភេទ ដូចខាងក្រោម:

**១- ធម្មតា:** ទ្រព្យសកម្មប្រភេទនេះត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់សងរបស់សមភាគីនាពេលបច្ចុប្បន្ន និងជាទ្រព្យសកម្មកំពុងដំណើរការដោយអនុលោមទៅតាមកិច្ចសន្យា និងរំពឹងថានៅតែបន្តដំណើរការបែបនេះរហូតតទៅ។

**២- ឃ្លាំមើល** (Watch): ទ្រព្យសកម្មប្រភេទនេះនឹងត្រូវបានធានា និងមិនទាន់ហួសកាលកំណត់សង ប៉ុន្តែមានចំណុចខ្សោយខ្លះដែលជាសក្តានុពលនឹងធ្វើឱ្យគុណភាពទ្រព្យសកម្មចុះខ្សោយ ឬនាំឱ្យស្ថានភាពគ្រឹះស្ថានមិនត្រូវបានការពារនៅពេលណាមួយខាងមុខ បើចំណុចខ្សោយទាំងនោះមិនត្រូវបានកែតម្រូវទេនោះ។ ឧទាហរណ៍ ខ្លះៗនៃចំណុចខ្សោយទាំងនោះរួមមាន ភាពគ្មានលទ្ធភាពត្រួតពិនិត្យឱ្យបានសមស្រប ដោយសារតែកិច្ចសន្យាខ្ចីប្រាក់មានចន្លោះប្រហោង ភាពអន់ថយនៃស្ថានភាព ឬ ការគ្រប់គ្រងវត្ថុបញ្ចាំ ការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ឬ និន្នាការចុះខ្សោយ នៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី ហើយបើមិនបានត្រួតពិនិត្យទេនឹងនាំឱ្យខូចខាត ដល់សមត្ថភាពទូទាត់សងរួមទាំងហានិភ័យដែលអាចកើតមានឡើងធំជាងហានិភ័យដែលបានគិតនាពេលចាប់ផ្តើមផ្តល់ឥណទាន។ ឥណទានប្រភេទនេះមិនគួរប្រើប្រាស់ជាការសម្របសម្រួលនៅពេលចាត់ថ្នាក់រវាងឥណទានធម្មតា និង ឥណទានក្រោមស្តង់ដារទេ។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ "ការឃ្លាំមើល" ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ៣០ថ្ងៃ ប៉ុន្តែតិចជាង ៩០ថ្ងៃ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៣០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រា ប្រើប្រាស់ឥណទាន។

ឥណទានណាដែលហួសកាលកំណត់សងចំនួន ៣០ ថ្ងៃ ឬ លើសពីនេះ ប៉ុន្តែតិចជាង ៩០ ថ្ងៃត្រូវចាត់ថ្នាក់ប្រភេទឃ្លាំមើល ឬ អន់ជាងនេះ។

នៅពេលដែលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ៣០ ថ្ងៃ ទៅ ៩០ ថ្ងៃ ត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬ អន់ជាងនេះ។

**៣- ក្រោមស្តង់ដារ** : ទ្រព្យសកម្មប្រភេទនេះមិនត្រូវបានការពារគ្រប់គ្រាន់ ដោយទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់សមភាគីឡើយ។ ជាពិសេសប្រភពធនធានចំបងសម្រាប់សងបំណុលមានមិនគ្រប់គ្រាន់ ដើម្បីសងបំណុល

ដែលធនាគារ ត្រូវតែសំឡឹងមើលទៅប្រភពធនធានបន្ទាប់ដូចជា វត្ថុបញ្ចាំ ការលក់អចលនទ្រព្យ បុនហិរញ្ញប្បទាន ឬ ក៏ការបំពេញទុនបន្ថែមសម្រាប់ទូទាត់បំណុល។ ឥណទានក្រោមស្តង់ដារបានបង្ហាញយ៉ាងច្បាស់នូវចំណុចខ្សោយ ដែលធ្វើឱ្យប៉ះពាល់ដល់ការទូទាត់សងបំណុលត្រឹមត្រូវតាមលំដាប់លំដោយ។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ " ក្រោមស្តង់ដារ " ប្រសិនបើ ប្រើលើសកម្រិតអនុម័តច្រើនជាង ៩០ថ្ងៃ ឬឥណទានវិបារូបន៍ដែលមានចំនួនប្រាក់តិចតួចនៅខ្វង់ឥណទានក្នុងរយៈពេល ៩០ថ្ងៃ ឬ លើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៩០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានដែលហួសកាលកំណត់សងចំនួន ៩០ ថ្ងៃ ឬ លើសពីនេះ ប៉ុន្តែតិចជាង ១៨០ ថ្ងៃ ត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតក្រោមស្តង់ដារ។

នៅពេលដែលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ៩០ ថ្ងៃ ទៅ ១៨០ ថ្ងៃ ត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ឬ អន់ជាងនេះ។

**៤-សង្ស័យ:** ទ្រព្យសកម្មប្រភេទនេះ មានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទានមិនមានការធានាបានល្អ។ យោងតាមហេតុការណ៍ជាក់ស្តែង ស្ថានភាព និងតម្លៃចំណុចខ្សោយទាំងនេះបាននាំឱ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានមកវិញទាំងស្រុងទេ។ លទ្ធភាពបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែ ដោយសារតែមានការរង់ចាំលើ ព្រឹត្តិការណ៍ជាក់លាក់ និងសមស្របណាមួយដែលនឹងកាត់បន្ថយកម្រិតបាត់បង់នោះ បរិមាណពិតប្រាកដនៃបំណុលដែលត្រូវបាត់បង់មិនអាចកំណត់បានទាំងស្រុង។ បើព្រឹត្តិការណ៍ដែលរង់ចាំនោះមិនបានកើតឡើងក្នុងរយៈពេល ១៨០ ថ្ងៃ ហើយការទូទាត់សងត្រូវបានពន្យារពេលបន្ថែមទៀត នោះការចាត់ថ្នាក់ទៅជាឥណទានបាត់បង់ត្រូវតែអនុវត្ត។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ " សង្ស័យ " ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ១៨០ថ្ងៃ ឬឥណទានវិបារូបន៍ដែលមានចំនួនប្រាក់តិចតួចនៅខ្វង់ឥណទានក្នុងរយៈពេល ១៨០ថ្ងៃ ឬ លើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ១៨០ ថ្ងៃ ឬប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានណាមួយដែលហួសកាលកំណត់សងចំនួន ១៨០ ថ្ងៃ ឬ លើសពីនេះត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាបំណុលសង្ស័យ ឬអន់ជាងនេះ។

នៅពេលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ១៨០ ទៅ ៣៦០ ថ្ងៃ ត្រូវបានបញ្ចូលក្នុងប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាបំណុលសង្ស័យ ឬ អន់ជាងនេះ។

**៥-បាត់បង់:** ទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ឬ នៅមានតម្លៃតិចតួច ត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។ ការខាត

បង់ត្រូវទទួលស្គាល់ក្នុងអំឡុងពេលដែលឥណទានទាំងនោះត្រូវបានរកឃើញថា មិនអាចប្រមូលបាន។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ "បាត់បង់" ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ៣៦០ ថ្ងៃ ឬឥណទានវិបារូបន៍ដែលមានចំនួនប្រាក់តិចតួចនៅខ្ទង់ឥណទានក្នុងរយៈពេល ៣៦០ថ្ងៃ ឬ លើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៣៦០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានណាមួយដែលហួសកាលកំណត់សងចំនួន ៣៦០ ថ្ងៃ ឬលើសពីនេះត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់។

នៅពេលការទូទាត់សងការប្រាក់សម្រាប់រយៈពេល ៣៦០ ថ្ងៃ ឬលើសពីនេះត្រូវបានបញ្ចូលក្នុងប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។

**ប្រការ ៥**.-

ឥណទានវិបារូបន៍ ទោះជាមានរយៈពេលប្រសិទ្ធភាពយ៉ាងណាក៏ដោយ ត្រូវតែបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានរយៈកាលខ្លីតែប៉ុណ្ណោះ។ ឥណទានវិបារូបន៍ត្រូវតែបានធ្វើចំណាត់ថ្នាក់ជាឥណទានរយៈកាលខ្លី។

**ប្រការ ៦**.-

បើគ្រឹះស្ថានមួយបានផ្តល់ឥណទាន ឬ ទ្រព្យសកម្មច្រើនប្រភេទទៅឱ្យសមភាគីម្នាក់ ឬ មួយក្រុម ហើយមានឥណទាន ឬ ទ្រព្យសកម្មមួយត្រូវបានធ្វើការចាត់ថ្នាក់មិនល្អ ដូច្នេះគ្រឹះស្ថានត្រូវវាយតម្លៃឡើងវិញនូវឥណទានផ្សេងទៀត ដែលបានផ្តល់ទៅអតិថិជននោះ នឹងត្រូវធ្វើចំណាត់ថ្នាក់ឥណទានទាំងនោះទៅក្នុងប្រភេទដូចគ្នានឹងឥណទាន ដែលបានធ្វើចំណាត់ថ្នាក់រួចហើយ។ ការចាត់ថ្នាក់នេះត្រូវគិតបញ្ចូលទាំងកិច្ចសន្យាក្នុងខ្ទង់ក្រៅតារាងតុល្យការ លើកលែងតែកិច្ចសន្យានោះមិនតម្រូវឱ្យគ្រឹះស្ថានទូទាត់សងប្រាក់។ ប៉ុន្តែផលប័ត្រពាណិជ្ជកម្ម រួមទាំងលិខិតឥណទានដែលបានទទួលធ្វើស៊ីការដោយបហារិត ហើយការទូទាត់សងបានទៀងទាត់ និងត្រឹមត្រូវអាចរក្សាចំណាត់ថ្នាក់ធម្មតាបាន។

## ជំពូក ៣
## ឥណទានរៀបចំឡើងវិញ

**ប្រការ ៧**.-

ការរៀបចំឥណទានឡើងវិញអាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណា ដែលមានដំណើរការអាជីវកម្មល្អនាពេលខាងមុខ ហើយដែលកំពុងជួប ឬរំពឹងថាជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់វិញនូវប្រាក់ដើម និង/ឬ ការប្រាក់។

**ប្រការ ៨**.-

គ្រឹះស្ថានត្រូវបានហាមឃាត់អនុវត្តការរៀបចំបំណុលឡើងវិញ ដោយគ្រាន់តែក្នុងគោលបំណងជៀសវាង ៖

- ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន ឬ

- ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់ ឬ
- បញ្ឈប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ។

**ប្រការ ៩**.-

ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និងសមត្ថភាពសងប្រាក់វិញរបស់អ្នកខ្ចីទៅតាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថានភាពទីផ្សារ និងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែងនិងប្រុងប្រយ័ត្ន។

**ប្រការ ១០**.-

ការរៀបចំឡើងវិញនៃឥណទាន ត្រូវធ្វើឡើងដោយក្រុមការងារមួយដែលត្រូវតែនៅដាច់ដោយឡែកពីក្រុមដែលទទួលខុសត្រូវលើដំណើរការឱ្យខ្ចី។ ក្នុងករណីដែលការចូលរួមរបស់ភ្នាក់ងារ ឬ បុគ្គលិកនៅក្នុងក្រុមដំណើរការឱ្យខ្ចីនេះមិនអាចជៀសបាននោះ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន ត្រូវតាមដានផ្ទាល់ឱ្យបានតឹងតែងលើការរៀបចំឡើងវិញនៃឥណទាន។

**ប្រការ ១១**.-

បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ គ្រឹះស្ថានត្រូវចាត់ថ្នាក់ឥណទាននោះដូចខាងក្រោម ៖

- មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាសង្ស័យ ឬ បាត់បង់
- មិនផ្លាស់ប្តូរសម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា ឃ្លាំមើល ឬ ក្រោមស្តង់ដារ។

ការចាត់ថ្នាក់នេះមិនត្រូវឱ្យល្អជាងមុនឡើយ លុះត្រាតែការប្រាក់ និងប្រាក់ដើម ត្រូវបានសងមកវិញក្នុងអំឡុងបីគ្រាសងរំលស់ និងក្នុងរយៈពេលមិនតិចជាងបីខែ។ បន្ទាប់ពីរយៈពេលនេះ ឥណទានដែលត្រូវបានរៀបចំឡើងវិញអាចត្រូវបានចាត់ថ្នាក់ទៅតាមប្រការ ៤ នៃប្រកាសនេះ។

## ជំពូក ៤
## ភាតព្វកិច្ចធ្វើសំវិធានធន

**ប្រការ ១២**.-

គ្រឹះស្ថានទាំងអស់ ត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឱ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសំពៀតឥណទានដែលអាចកើតឡើង។

១- ពីរដងក្នុងមួយឆ្នាំ ឬញឹកញាប់ជាងនេះប្រសិនបើចាំបាច់ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យមានគណៈគ្រប់គ្រងវាយតម្លៃពីលទ្ធភាពប្រមូលបំណុលមកវិញនៃឥណទានទាំងអស់ រាប់បញ្ចូលទាំងការប្រាក់ដែលបានបង្គរ និងមិនទាន់បានសង ហើយត្រូវតែតម្រូវឱ្យមានការចុះបញ្ជីសមស្របដើម្បី (១) រាយការណ៍អំពីចំណូលឱ្យបានត្រឹមត្រូវ និង (២) ធានាថាការធ្វើសំវិធានធនសម្រាប់ឥណទានបាត់បង់ ត្រូវបានធ្វើគ្រប់គ្រាន់ដើម្បីទូទាត់សងការបាត់បង់ដែលអាចកើតមាន។ គណៈគ្រប់គ្រងត្រូវតែរក្សាការកត់ត្រាកំណត់ហេតុនៃការវាយតម្លៃនិងការចុះបញ្ជី និងផ្តល់ការកត់ត្រា និងបញ្ជីទាំងនោះមកធនាគារជាតិនៃកម្ពុជា សវនកម្មផ្ទៃក្នុង និងសវនករខាងក្រៅ សម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង។

២- ការកើនឡើង និងការថយចុះរបស់គណនីប្រាក់សំវិធានធនសម្រាប់ឥណទានបាត់បង់ត្រូវបានធ្វើឡើងតាមរយៈការចុះទៅក្នុងគណនីចំណាយសំវិធានធនចំពោះឥណទានបាត់បង់នៅក្នុងរបាយការណ៍ចំណេញ-ខាត។

៣- ក្នុងការកំណត់ការបាត់បង់ដែលអាចកើតមានចំពោះឥណទានណាមួយ ឬ ចំពោះសំពៀតឥណទានទាំងមូល រាល់កត្តាពាក់ព័ន្ធត្រូវតែបានយកមកពិចារណា រួមមានយ៉ាងហោចនូវប្រវត្តិបទពិសោធន៍ឥណទានបាត់បង់ពីមុន ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និន្នាការនានានៃការមិនសងបំណុល ប្រសិទ្ធភាពនៃគោលនយោបាយឱ្យខ្ចី និងនីតិវិធីនៃការប្រមូលបំណុលរបស់គ្រឹះស្ថាន និងភាពត្រឹមត្រូវនិងទាន់ពេលវេលាក្នុងការពិនិត្យឡើងវិញលើសំពៀតឥណទានរបស់គ្រឹះស្ថាន។

**ប្រការ ១៣**.-

សំវិធានធន ត្រូវធ្វើតាមសមាមាត្រអប្បបរមាស្របតាមចំណាត់ថ្នាក់ដែលបានកំណត់ដូចខាងក្រោម។ នៅពេលដែលមានព័ត៌មានដែលអាចទុកចិត្តបាន បញ្ជាក់ថាការបាត់បង់អាចច្រើនជាង ចំនួនអប្បបរមានោះ សមាមាត្រនៃសំវិធានធនត្រូវធ្វើឡើងឱ្យកាន់តែធំជាងនេះ។

១- សំវិធានធនទូទៅ

- សម្រាប់ឥណទានថ្នាក់ "ធម្មតា" ១% នៃឥណទានដុលសរុប។

២- សំវិធានធនជាក់លាក់

- សម្រាប់ឥណទានថ្នាក់ "ឃ្លាំមើល" ៣% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "ក្រោមស្តង់ដារ" ២០% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "សង្ស័យ" ៥០% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "បាត់បង់" ១០០% នៃឥណទានដុល។

**ប្រការ ១៤**.-

គ្រឹះស្ថាន ត្រូវរក្សាការកត់ត្រាឱ្យបានត្រឹមត្រូវ ដើម្បីជាការគាំទ្រដល់ការវាយតម្លៃឥណទាន ដែលអាចបាត់បង់ និងធ្វើសំវិធានធនឱ្យបានគ្រប់គ្រាន់សម្រាប់ឥណទានបាត់បង់។

សំវិធានធនជាក់លាក់ (Specific provision) ត្រូវកត់ត្រានៅក្នុងគណនីរបស់គ្រឹះស្ថាន ហើយចាត់ទុកជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងគ្រាដែលត្រូវធ្វើសំវិធានធននោះ។ សំវិធានធនមិនត្រូវធ្វើរំលស់នៅតាមគ្រានោះទេ។ នៅពេលណាដែលសមតុល្យគណនី របស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះមិនត្រូវយកមកគិតសម្រាប់គណនាសំវិធានធនទេ។

ស្របតាមមូលដ្ឋានបង្គរនៃគណនេយ្យ (accrual basis accounting) ការប្រាក់បង្គរលើគណនីអតិថិជន ត្រូវបានកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត។ ប៉ុន្តែមិនត្រូវអនុវត្តតាមទម្រង់ការបែបនេះទេ ចំពោះទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាបំណុលក្រោមស្តង់ដារ បំណុលសង្ស័យ ឬបំណុលបាត់បង់។ ក្នុងស្ថានភាពនេះ ការប្រាក់បង្គរត្រូវកត់ត្រាខាងឥណទាននៃគណនីសម្រាប់ការប្រាក់ព្យួរ។

## ជំពូក ៥
## ការលុបចោលឥណទាននិងបុរេប្រទាន

**ប្រការ ១៥**.-

គ្រឹះស្ថានត្រូវតែលុបឥណទាន និងបុរេប្រទាន ឬ មួយផ្នែកនៃឥណទានចេញពីតារាងតុល្យការរបស់ខ្លួននៅពេលដែលគ្រឹះស្ថានបាត់សិទ្ធិតាមកិច្ចសន្យាគ្រប់គ្រងលើឥណទាន ឬនៅពេលដែលឃើញថា ឥណទានមួយផ្នែក ឬ ទាំងមូលមិនអាចប្រមូលវិញបាន ឬ គ្មានសង្ឃឹមថាឥណទាននេះអាចប្រមូលបានមកវិញទេ។ ជាទូទៅ ករណីដូចខាងក្រោម ជាសញ្ញាណអាចនាំទៅដល់ការលុបចោលឥណទាន ឬមួយផ្នែកនៃឥណទាន ៖

- ក-គ្រឹះស្ថានបាត់សិទ្ធិតាមកិច្ចសន្យាក្នុងការគ្រប់គ្រងឥណទានទាំងស្រុង ឬមួយផ្នែក ដូចដែលបានសម្រេចដោយតុលាការ
- ខ-គ្រប់ប្រភេទនៃមូលប័ត្រ ឬ វត្ថុបញ្ចាំដែលត្រូវបានរឹបអូសនិងលក់បញ្ចេញ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងឥណទានទាំងមូល
- គ- គ្រឹះស្ថានមិនអាចប្រមូល ឬលែងមានមូលហេតុសមស្របក្នុងការធានាថានឹងប្រមូលឥណទានគ្រប់ចំនួនដែលត្រូវទារស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន និងបុរេប្រទាន
- ឃ-អ្នកខ្ចីប្រាក់បានក្ស័យធន ឬកំពុងតែស្ថិតនៅក្នុងដំណាក់កាលស្ដារនីតិសម្បទា ផ្នែកហិរញ្ញវត្ថុ និងកំពុងតែជួបការលំបាកក្នុងការសងបំណុល
- ង-ឥណទានត្រូវបានចាត់ថ្នាក់ជាប្រភេទឥណទានបាត់បង់។

រាល់គោលនយោបាយឥណទាន ត្រូវតែលំអិតឱ្យបានគ្រប់គ្រាន់អំពីនីតិវិធីនៃការលុបចេញពីបញ្ជីឥណទាន ដើម្បីបន្ថយឱ្យនៅជាអប្បបរមានៃការរំលោភផ្សេងៗ។

## ជំពូក ៦
## ការត្រួតពិនិត្យឥណទាន

**ប្រការ ១៦**.-

នៅពេលអនុវត្តការត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃកម្ពុជាពិនិត្យឡើងវិញនូវគោលការណ៍ និងដំណើរការចាត់ថ្នាក់ទ្រព្យសកម្ម និងអាចចាត់ថ្នាក់ទ្រព្យសកម្មអនុលោមតាមបញ្ញត្តិ ដែលបានចែងក្នុងប្រកាសនេះ។ ទ្រព្យសកម្មដែលត្រូវបានចាត់ថ្នាក់ក្នុងអំឡុងពេលនេះ ត្រូវរក្សាទុកក្នុងប្រភេទដែលធនាគារជាតិនៃកម្ពុជាបានវាយតម្លៃរហូតទាល់តែបានបំពេញលក្ខខណ្ឌទាំងអស់ទើបអាចចាត់ថ្នាក់ទៅក្នុងប្រភេទមួយផ្សេងទៀត។ ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់នៃគ្រឹះស្ថាន ត្រូវតែចាត់វិធានការគ្រប់គ្រាន់ជាបន្ទាន់រហូតដល់បទប្បញ្ញត្តិ ត្រូវបានប្រតិបត្តិតាមពេញលេញ រួមមានការកែសម្រួលគោលការណ៍ នីតិវិធី និងដំណើរការអនុវត្ត។

**ប្រការ ១៧**.-

សវនករខាងក្រៅ ត្រូវពិនិត្យឡើងវិញនូវគោលនយោបាយ នីតិវិធី និងដំណើរការចាត់ថ្នាក់ទ្រព្យសកម្មនៅពេលធ្វើសវនកម្មតាមគ្រារបស់ខ្លួន។ សវនករខាងក្រៅ ត្រូវវាយតម្លៃដោយផ្អែកលើ ការអង្កេតការប្រតិបត្តិតាមគោលនយោបាយនិងបទបញ្ជាផ្ទៃក្នុង ដែលបានដាក់ចេញដោយក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ព្រមទាំងគុណភាពនៃការចាត់ថ្នាក់ទ្រព្យសកម្ម ដែលបាន អនុវត្តដោយគ្រឹះស្ថាន។

ផ្អែកតាមការអង្កេត សវនករខាងក្រៅ ត្រូវវិនិច្ឆ័យលើភាពត្រឹមត្រូវនៃចំណូលដែលបានទទួលស្គាល់ លើភាពគ្រប់គ្រាន់នៃសំវិធានធនដែលបានអនុវត្ត លើគុណភាពនិងឯករាជ្យភាពនៃការវាយតម្លៃវត្ថុធានាដែលត្រូវបានអនុវត្តទាំងផ្ទៃក្នុង និងពីខាងក្រៅ។ សវនករខាងក្រៅ ត្រូវចងក្រងឯកសារសំខាន់ៗដែលមានផលប៉ះពាល់ដល់ចំណូលដែលត្រូវបានទទួលស្គាល់ និងលើស្ថានភាពសាធនភាពរបស់គ្រឹះស្ថាន។ សវនករខាងក្រៅក៏ត្រូវយកចិត្តទុកដាក់ជាពិសេស ទៅលើការចាត់ថ្នាក់ទ្រព្យសកម្មដែលទាក់ទងនឹងប្រាក់កម្ចី និងឥណទានផ្សេងទៀតដែលបានផ្តល់ទៅឱ្យបុគ្គលសម្ព័ន្ធនិងភាគីសម្ព័ន្ធញាតិ ដោយត្រូវមានផ្តល់យោបល់ជាក់លាក់នៅក្នុងរបាយការណ៍ដែលបានផ្តល់ជូនធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៨**.-

សវនករផ្ទៃក្នុង ត្រូវពិនិត្យឡើងវិញតាមគ្រាលើសំពៀតទ្រព្យសកម្មទាំងមូល។ ការពិនិត្យឡើងវិញនោះ ត្រូវបានអនុវត្តទូលំទូលាយយ៉ាងតិចមួយឆ្នាំម្តង។ នៅពេលអនុវត្តការពិនិត្យឡើងវិញកាន់តែញឹកញាប់នៅពេលនោះ សវនករផ្ទៃក្នុងត្រូវប្រើប្រាស់វិធីសាស្ត្រជ្រើសរើសប៉ាន់គំរូ។ ប៉ុន្តែ ចំពោះហានិភ័យធំៗ សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញជាប្រព័ន្ធ។

សវនករផ្ទៃក្នុង ត្រូវវាយតម្លៃដោយផ្អែកលើការអង្កេតផ្ទាល់ខ្លួននិងដោយឯករាជ្យនូវការប្រតិបត្តិតាមគោលនយោបាយនិងបទបញ្ជាផ្ទៃក្នុង ដែលបានដាក់ចេញដោយក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ព្រមទាំងគុណភាពនៃការចាត់ថ្នាក់ទ្រព្យសកម្មដែលបានអនុវត្តដោយគ្រឹះស្ថាន។

សវនករផ្ទៃក្នុង ត្រូវវិនិច្ឆ័យភាពត្រឹមត្រូវនៃចំណូលដែលបានទទួលស្គាល់ លើភាពគ្រប់គ្រាន់នៃសំវិធានធនដែលបានអនុវត្ត លើគុណភាពនិងឯករាជ្យភាពនៃការវាយតម្លៃវត្ថុធានាដែលត្រូវបានអនុវត្តទាំងផ្ទៃក្នុងនិងពីខាងក្រៅ។ សវនករផ្ទៃក្នុង ត្រូវបញ្ជូនជាបន្ទាន់នូវបញ្ហាសំខាន់ៗជូនទៅ ក្រុមប្រឹក្សាភិបាលដើម្បីមានអនុសាសន៍ចាត់វិធានការកែតម្រូវគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងឱ្យបានឆាប់រហ័ស។

ជាចុងក្រោយ សវនករផ្ទៃក្នុង ក៏ត្រូវវិនិច្ឆ័យពីគុណភាពនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលបានរៀបចំឡើង ដើម្បីត្រួតពិនិត្យហានិភ័យឥណទាននិងគោលបំណងនៃការធ្វើសេចក្តីសម្រេច ក៏ដូចជាលើភាពត្រឹមត្រូវ និងការបញ្ជូនទិន្នន័យបានទាន់ពេលវេលាទៅអ្នកគ្រប់គ្រងគ្រឹះស្ថាន។

## ជំពូក ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៩**.-

ត្រូវចាត់ទុកជានិរាករណ៍ប្រកាសដូចខាងក្រោមនេះ ៖

- ប្រកាស ធ៧-០០-៥១ ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០។

- ប្រកាស ធ៧-០២-១៤៥ ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០២។

**ប្រការ ២០**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២១**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៩-០២០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ

**ប្រការ ១**.-

ធនាគារពាណិជ្ជ ត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងប្រាំបីភាគរយ(៨%)ចំពោះប្រាក់រៀល និងដប់ពីរភាគរយ(១២%)ចំពោះប្រាក់រូបិយប័ណ្ណ។

**ប្រការ ២**.-

ធនាគារជាតិនៃកម្ពុជានឹងផ្តល់កំរៃការប្រាក់ ដូចខាងក្រោមៈ

- ចំពោះប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀលចំនួនប្រាំបីភាគរយ(៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%)
- ចំពោះប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រូបិយប័ណ្ណចំនួនដប់ពីរភាគរយ(១២%) ក្នុងនោះ ប្រាំបីភាគរយ (៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%) និងបួនភាគរយ (៤%) បន្ថែមទៀត ផ្តល់អត្រាការប្រាក់តាមប្រកាសស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក។

**ប្រការ ៣**.-

ប្រកាសលេខ ធ៧-០៨-០៦៣ ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ច លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រាៈ **ជា ចាន់តូ**

ធ៧-០៩-០៧៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចឱ្យបានគ្រប់គ្រាន់ ក្នុងរយៈពេលតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងប្រតិបត្តិការសាច់ប្រាក់ងាយស្រួលប្រកបដោយសុវត្ថិភាព និងភាពរឹងមាំ។

**ប្រការ ២.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ ៖

**រយៈពេលមូលដ្ឋាន** : ជារយៈពេល១៤ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវយកប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ មកកំណត់ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា

**រយៈពេលតម្កល់** : ជារយៈពេល១៤ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មបម្រុងដើម្បីអនុលោមតាមប្រកាសនេះ

**មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ** : ជាចំនួនសរុបនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ក្នុងរយៈពេលមូលដ្ឋានចែកនឹង១៤។ ផលចែកដែលជាមធ្យមភាគប្រចាំថ្ងៃ ត្រូវប្រើសម្រាប់កំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់។ មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ត្រូវគណនាដោយឡែកពីគ្នា សម្រាប់ប្រាក់រៀល និងរូបិយប័ណ្ណ ស្របទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

**អត្រាប្រាក់បម្រុងកាតព្វកិច្ច** : ជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកជាមធ្យមក្នុងរយៈពេលតម្កល់។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់សម្រាប់ប្រាក់រៀល និងសម្រាប់រូបិយប័ណ្ណ តាមរយៈបទប្បញ្ញត្តិដោយឡែក។

**មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់** : ជាប្រាក់បម្រុងកាតព្វកិច្ចដែលបានតម្កល់បូកនឹងចំនួនទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១៤ថ្ងៃ ចែកនឹង ១៤។ មធ្យមភាគនៃការរក្សាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ត្រូវបានគណនាដោយឡែកពីគ្នា ចំពោះប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ ស្របទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

**ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា :** ជាផលគុណរវាងអត្រាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមួយមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ។ ចំនួននេះត្រូវបានគណនានៅមុនរយៈពេលត្រូវតម្កល់ ហើយត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាទៅតាមកាលកំណត់។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវបានគណនាសារជាថ្មី និងដោយឡែកពីគ្នារៀងរាល់១៤ថ្ងៃ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ជារៀល និងជារូបិយប័ណ្ណ។

**កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** : ជាចំនួន ៨០% នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវតម្កល់ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលតម្កល់នៅក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាននីមួយៗដែលមាននៅធនាគារជាតិនៃកម្ពុជា។ កម្រិតអប្បបរមានេះ ត្រូវអនុវត្តទាំងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងរូបិយប័ណ្ណផ្សេងៗ។

**ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់** : ជាចំនួនទ្រព្យសកម្មបម្រុងដែលត្រូវរក្សាក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់រកមធ្យមភាគនៃទ្រព្យសកម្មអប្បបរមា និងដើម្បីឱ្យស្របទៅតាមការកំណត់របស់បទប្បញ្ញត្តិជាធរមាន។

ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់ រួមមានដូចជា:

- ប្រាក់រៀល : សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ជារៀល ក្នុងរយៈពេលតម្កល់ ១៤ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា
- រូបិយប័ណ្ណ : សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា។

របាយការណ៍ប្រាក់បម្រុងកាតព្វកិច្ច មានពីរប្រភេទ ៖

- របាយការណ៍រយៈពេលមូលដ្ឋាន: ជាតារាងដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ជាមួយនេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងពេល៣ថ្ងៃ បន្ទាប់ពីចប់រយៈពេលមូលដ្ឋាន។ របាយការណ៍នេះត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០% និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀល និង រូបិយប័ណ្ណ។
- របាយការណ៍រយៈពេលតម្កល់ : ជាតារាងដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ជាមួយនេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងពេល៣ថ្ងៃ បន្ទាប់ពីចប់រយៈពេលតម្កល់។ របាយការណ៍នេះ ត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀល និងរូបិយប័ណ្ណ ហើយត្រូវបង្ហាញភស្តុតាងថាបានប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ៨០%។

## ជំពូក ២
## ប្រាក់បម្រុងកាតព្វកិច្ច

**ប្រការ ៣**.-

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍អនុវត្តគោលនយោបាយរូបិយវត្ថុផង និងជាកាតព្វកិច្ចត្រួតពិនិត្យគ្រឹះស្ថានផង។ អត្រាប្រាក់បម្រុងកាតព្វកិច្ចអាចមានការផ្លាស់ប្តូរទៅតាមគោលដៅអនុវត្តគោលនយោបាយរូបិយវត្ថុ និងកាលៈទេសៈសេដ្ឋកិច្ចសកល។ ដូច្នេះ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

គ្រឹះស្ថាន ត្រូវបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលប្រុងប្រយ័ត្ន និងសមស្របដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

## ជំពូក ៣
## ទ្រព្យសកម្មអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

**ប្រការ ៥**.-

គ្រឹះស្ថាន ត្រូវរក្សាទុកជាមធ្យមនូវសមតុល្យគ្រប់គ្រាន់នៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា។

**ប្រការ ៦**.-

សាច់ប្រាក់ក្នុងដៃ មិនត្រូវចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន ដើម្បីតម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាឡើយ។

ទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម ៖

- សមតុល្យប្រចាំថ្ងៃក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ជារៀល របស់គ្រឹះស្ថានដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា
- សមតុល្យប្រចាំថ្ងៃ ក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណរបស់គ្រឹះស្ថានដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា។

## ជំពូក ៤
## រយៈពេលមូលដ្ឋាន និងរយៈពេលតម្កល់

**ប្រការ ៧**.-

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្អែកលើរយៈពេលពីរផ្សេងគ្នា ដែលមានរយៈពេល ១៤ ថ្ងៃប្រតិទិនជាបន្តបន្ទាប់ គឺ "រយៈពេលមូលដ្ឋាន" និង "រយៈពេលតម្កល់"។

**ប្រការ ៨**.-

រយៈពេលមូលដ្ឋាន ជារយៈពេល១៤ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានគណនាមធ្យមភាគប្រចាំថ្ងៃនៃប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ដើម្បីកំណត់ប្រាក់បម្រុងកាតព្វកិច្ចមធ្យមប្រចាំថ្ងៃ និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ សម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា។ ចំនួនប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមដែលត្រូវរក្សាទុកក្នុងរយៈពេលតម្កល់ ត្រូវគណនាដោយយកមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗក្នុងរយៈពេលមូលដ្ឋាន គុណជាមួយអត្រាប្រាក់បម្រុងកាតព្វកិច្ចជាធរមាន។

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលមូលដ្ឋាន ក្នុងអំឡុងពេល៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

**ប្រការ ៩**.-

រយៈពេលតម្កល់ចាប់ផ្តើមនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

រយៈពេលតម្កល់មានរយៈពេល១៤ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មដែលអាចទទួលយកបានស្របតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមនៅគ្រប់១៤ថ្ងៃនៃរយៈពេលមូលដ្ឋាន។

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលតម្កល់ ក្នុងអំឡុងពេល៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលតម្កល់។

## ជំពូក ៥
## មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់

**ប្រការ ១០**.-

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្តល់នូវភាពទន់ភ្លន់ខ្លះ ដោយសារទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ត្រូវបានគិតជាមធ្យមក្នុងរយៈពេលតម្កល់។ ប៉ុន្តែ គ្រឹះស្ថាន ត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីធានាប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់អប្បបរមា ដូចមានចែងនៅក្នុងប្រការ ១៣ នៃប្រកាសនេះ។

មធ្យមភាគទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់លើកលែងតែសមតុល្យគណនីជាត់ទាត់ ត្រូវកំណត់តាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា នៅទូទាំងរយៈពេលត្រូវតម្កល់។ គ្រឹះស្ថាន បានប្រតិបត្តិតាមប្រកាសនេះ ប្រសិនបើចំនួនមធ្យមភាគទ្រព្យសកម្មដែលអាចទទួលយកបានត្រូវបានរក្សានៅគ្រប់រយៈពេលតម្កល់យ៉ាងតិចបំផុតស្មើ ឬលើសពី ១០០% (មួយរយភាគរយ) នៃចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលបានគណនាដោយផ្អែកលើតួលេខនៅក្នុងរបាយការណ៍រយៈពេលមូលដ្ឋានពីមុនមក។

**ប្រការ ១១**.-

គណនីជាត់ទាត់ជាប្រាក់រៀលរបស់គ្រឹះស្ថានមានសមតុល្យវិជ្ជមាន ជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល។ សមតុល្យនេះនឹងត្រូវបានយកមកបូកបញ្ចូលគ្នារាល់ថ្ងៃ ហើយសមតុល្យសរុបនេះត្រូវបូកជាមួយសមតុល្យសរុបគណនីប្រាក់បម្រុងកាតព្វកិច្ចនៅចុងគ្រានៃរយៈពេលតម្កល់។ ផលចែករវាងចំនួនសរុបខាងលើជាមួយ១៤ ត្រូវបានយកមកប្រៀបធៀបជាមួយចំនួនប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវប្រតិបត្តិតាម។

**ប្រការ ១២**.-

សមតុល្យគណនីជាត់ទាត់ជារូបិយប័ណ្ណ មិនមែនជាទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណទេ។

## ជំពូក ៦
## កម្រិតកំណត់អប្បបរមានៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ និងឱនភាពប្រាក់បម្រុងកាតព្វកិច្ច

**ប្រការ ១៣**.-

ទោះបីជា ការគិតមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចក្នុងរយៈពេល ១៤ ថ្ងៃ អនុញ្ញាតឱ្យមានភាពទន់ភ្លន់ខ្លះ ក៏គ្រឹះស្ថានត្រូវរក្សាទុកជាអចិន្ត្រៃយ៍ក្នុងរយៈពេលតម្កល់១៤ថ្ងៃ នូវកម្រិតកំណត់កាតព្វកិច្ចប្រចាំ

ថ្ងៃស្មើនឹង៨០% នៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចដែលបានកំណត់ក្នុងរយៈពេលមូលដ្ឋាន ជារៀល និងជារូបិយប័ណ្ណ។

គ្រឹះស្ថានត្រូវប្រតិបត្តិតាមប្រចាំថ្ងៃនូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០% នៅទូទាំងរយៈពេលតម្កល់ ដោយរក្សាឱ្យបានយ៉ាងតិចបំផុតនូវចំនួនសមតុល្យក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារៀល នៅធនាគារជាតិនៃកម្ពុជា។ ទោះបីជា សមតុល្យគណនីផាត់ទាត់ជាទ្រព្យសកម្មដែលអាចទទួលយកបានជាប្រាក់រៀល ក៏គ្រឹះស្ថានមិនត្រូវបញ្ចូលសមតុល្យគណនីផាត់ទាត់នេះ ជាមួយសមតុល្យគណនីទ្រព្យសកម្មបម្រុង ដើម្បីឱ្យប្រតិបត្តិតាមកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០%។

**ប្រការ ១៤**.-

ការល្មើសនឹងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង ៨០% និងការរក្សាទុកមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាមិនគ្រប់គ្រាន់ក្នុងរយៈពេលតម្កល់ ត្រូវចាត់ទុកថាមានឱនភាពប្រាក់បម្រុងកាតព្វកិច្ចនឹងរងការផាកពិន័យ និងវិធានការត្រួតពិនិត្យគ្រឹះស្ថានដោយធនាគារជាតិនៃកម្ពុជា។

## ជំពូក ៧
## ការពិន័យនិងវិធានការត្រួតពិនិត្យ

**ប្រការ ១៥**.-

ករណីមានឱនភាពកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង៨០% នៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ ត្រូវរងការផាកពិន័យស្មើនឹងពីរភាគរយ (២%) នៃចំនួនឱនភាពនោះ (៨០% នៃប្រាក់បម្រុងកាតព្វកិច្ចដកប្រាក់តម្កល់ក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច) ចំពោះឱនភាពលើកទី ១ នៃរយៈពេលតម្កល់។ ក្នុងករណីដែលមានឱនភាពដដែលកើតឡើងនៅរយៈពេលតម្កល់តែមួយ នោះការផាកពិន័យនឹងកើនដល់បួនភាគរយ (៤%)។

**ប្រការ ១៦**.-

ឱនភាពប្រាក់បម្រុងកាតព្វកិច្ច ដោយសារការតម្កល់មិនគ្រប់គ្រាន់នូវមធ្យមភាគនៃទ្រព្យសកម្មបម្រុងក្នុងរយៈពេលតម្កល់ ត្រូវទទួលរងការផាកពិន័យស្មើនឹងពីរភាគរយ ( ២% ) នៃចំនួនប្រាក់ឱនភាពដែលបានមកពីភាពខុសគ្នារវាងចំនួននៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់ និងមធ្យមភាគទ្រព្យសកម្មបម្រុងដែលបានតម្កល់។ ក្នុងករណីមានឱនភាពជាបន្តបន្ទាប់ នោះការផាកពិន័យនឹងត្រូវកើនឡើងដល់បួនភាគរយ (៤%)។

**ប្រការ ១៧**.-

ការល្មើសកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ និងឱនភាពនៃប្រាក់បម្រុងកាតព្វកិច្ចអាចបង្ហាញថាមានបញ្ហាក្នុងការគ្រប់គ្រងជាក់ស្តែង និង/ឬ បញ្ហាជាសក្តានុពលលើសាច់ប្រាក់ងាយស្រួល។ ធនាគារជាតិនៃកម្ពុជា នឹងចាត់វិធានការត្រួតពិនិត្យដ៏សមស្របដើម្បីកែតម្រូវស្ថានភាពនេះ និងប្រើសិទ្ធិអំណាចដាក់ពិន័យដូចដែលមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូក ៨
## វិធានការអន្តរកាល

**ប្រការ ១៨**.-

នីតិវិធីនៃការប្តូរពីប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចចាស់ មកប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចថ្មីដូចមានចែងនៅក្នុងប្រកាសនេះ នឹងត្រូវបានណែនាំក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

## ជំពូក ៩
## អវសានប្បញ្ញត្តិ

**ប្រការ ១៩**.-

ប្រកាស និងសារាចរណែនាំ ត្រូវចាត់ទុកជានិរាករណ៍:

- បទប្បញ្ញត្តិ ធ៧-៩៣-២៨២ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ដោយស្ថាប័នរូបិយវត្ថុ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣
- សារាចរណែនាំ ធ៧-៩៣-២៨៧ សរណន ស្តីពី របៀបតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ព្រមទាំងការរាយការណ៍ស្តីពីប្រាក់បម្រុងកាតព្វកិច្ចនេះ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣
- សារាចរណែនាំ ធ៧-០៨-០២ ស្តីពីរយៈពេលមូលដ្ឋាន និងរយៈពេលដែលត្រូវតម្កល់ និងថ្ងៃរាយការណ៍ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨។

**ប្រការ ២០**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២១**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

# របាយការណ៍ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១.- របាយការណ៍រយៈពេលមូលដ្ឋាន

របាយការណ៍នេះត្រូវលម្អិតអំពីសមតុល្យប្រាក់បញ្ញើ និងប្រាក់កម្ចីប្រចាំថ្ងៃទៅតាមប្រភេទរូបិយប័ណ្ណ នៅក្នុងរយៈពេលមូលដ្ឋាន ដែលបង្ហាញអំពីចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាសម្រាប់រក្សាទុកនៅក្នុងរយៈពេលតម្កល់ ព្រមទាំងបង្ហាញពីកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០%។

របាយការណ៍រយៈពេលមូលដ្ឋាននេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល៣ (បី)ថ្ងៃ ចាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន ៖

- តារាង : របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារៀល
- តារាង1B : របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និង រូបិយប័ណ្ណផ្សេងៗ គិតជាដុល្លារអាមេរិក។ តារាងនេះប្រើសម្រាប់គណនាសង្ខេបតួលេខសរុបបញ្ចូលគ្នាតាមថ្ងៃ តាមប្រភេទរូបិយប័ណ្ណ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ច។ របាយការណ៍សង្ខេបនេះនឹងត្រូវបានភ្ជាប់បន្ថែមដោយតារាងលម្អិតជាច្រើនទៀតតាមប្រភេទរូបិយប័ណ្ណដែលគ្រឹះស្ថានបានធ្វើប្រតិបត្តិការជាក់ស្តែង
    - តារាង1B-01: របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក
    - តារាង1B-02: របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
    - តារាង1B-03: របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
    - តារាង 1B-04: របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណផ្សេងៗទៀត គិតជាដុល្លារអាមេរិក ជាតារាងបន្ថែមចំពោះរូបិយប័ណ្ណផ្សេងៗ ដែលខុសពីរូបិយប័ណ្ណខាងលើទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

## ២.- របាយការណ៍រយៈពេលតម្កល់

របាយការណ៍នេះបង្ហាញពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មបម្រុង ដែលរក្សានៅធនាគារជាតិនៃកម្ពុជា និងឱនភាពកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃតាមរយៈការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមប្រចាំថ្ងៃ។

គ្រឹះស្ថាន ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ រយៈពេលតម្កល់ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលតម្កល់។

- តារាង 2A: របាយការណ៍រយៈពេលតម្កល់ ស្ដីពីប្រាក់បម្រុងកាតព្វកិច្ចជារៀល។ របាយការណ៍ នេះ ប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨0% ដែលទទួលបានពីតារាង 1A។
- តារាង 2B: របាយការណ៍រយៈពេលតម្កល់ ស្ដីពីប្រាក់បម្រុងកាតព្វកិច្ចគិតជាដុល្លារអាមេរិក។

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជារៀល

## Report of Base Period on Reserve Requirement in Riel

**ឈ្មោះធនាគារ**/Name of Bank: តារាង : ១ ក

**រយៈពេលមូលដ្ឋាន**/Base Period : Table: 1 A

**រយៈពេលតម្កល់**/Maintenance Period : (ឯកតាគិតជាលានរៀល)

**រយៈពេលត្រូវរាយការណ៍**/Reporting Period : (Riel in Millions)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន<br>Date of Base Period | **ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗជារៀល**<br>**Deposits and other borrowings base in Riel** | | | | | |
|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត<br>Demand Deposit | ប្រាក់បញ្ញើសំចៃ<br>Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់<br>Term Deposit | ប្រាក់បញ្ញើផ្សេងៗ<br>Other Deposits | បំណុលផ្សេងទៀត<br>Other Liabilities | **សរុប**<br>**Total** |
| | 1 | 2 | 3 | 4 | 5 | **6=1+2+3+4+5** |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| | | | | | - | - |
| **សរុប** Total | - | - | - | - | - | - |
| **មធ្យមប្រចាំថ្ងៃ**<br>Daily Average | - | - | - | - | - | - |

| | |
|---|---|
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintainance period: | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៨%) Reserve Requirement Rate (8%) | 0.08 |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារៀល** Minimum reserve requirements In riel | - |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | - |

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Checked By | Prepared By |

## របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗគិតជាដុល្លារអាមេរិក
## Report of Base Period on Reserve Requirement in USD and Other Currencies Converted into USD

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period :
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង: ១ ខ
Table: 1 B
(ជាដុល្លារអាមេរិក)
(In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន<br>Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ជាដុល្លារអាមេរិក<br>Deposits and other borrowings base in USD | ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗ ជាអឺរ៉ូ គិតជាដុល្លារអាមេរិក<br>Deposits and other borrowings in EUR Converted in USD | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ជា បាតថៃ គិតជាដុល្លារអាមេរិក<br>Deposits and other borrowings in THB Converted in USD | ប្រាក់បញ្ញើនិងប្រាក់ កម្ចី ផ្សេងៗ ជា...គិត ជាដុល្លារអាមេរិក<br>Deposits and other borrowings in … Converted in USD* | **សរុបប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ គិតជាដុល្លារអាមេរិក**<br>**Total Deposits and other Borrowings Base Conveted into USD** |
|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | **5=1+2+3+4** |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| | | | | - | - |
| **សរុប** Total | - | - | - | - | - |
| **មធ្យមប្រចាំថ្ងៃ**<br>Daily Average | - | - | - | - | - |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា**<br>(មធ្យមប្រចាំថ្ងៃ x ១២%)<br>Minimum Reserve Requirement<br>(Daily Average x12%) | - | - | - | - | - |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintainance period: | | | | | |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាដុល្លារអាមេរិក** (ទំរង់: ១ខ០១ +១ខ០២ +១ខ០៣ + ១ខ០៤+ .....)<br>Minimum reserve requirements in USD ( Form: 1B01+1B02+1B03+1B04+ …… ) | | | | | |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | | | | | |

* កំណត់សម្គាល់/Note:

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

*កូឡោនច្រើនអាចត្រូវបន្ថែមសម្រាប់រូបិយប័ណ្ណផ្សេងៗទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*
*There will be additional collumns as needed for each of the Foreign Currencies the Institutions transact in*

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Checked By | Prepared By |

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក

## Report of Base Period on Reserve Requirement in USD

ឈ្មោះធនាគារ/Name of Bank: តារាង: ១ខ-០១

រយៈពេលមូលដ្ឋាន/Base Period: Table: 1 B-01

រយៈពេលតម្កល់/Maintenance Period : (ជាដុល្លារអាមេរិក)

រយៈពេលត្រូវរាយការណ៍/Reporting Period: (In USD)

| កាលបរិច្ឆេទនៃ រយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗជាដុល្លារអាមេរិក Deposits and other borrowings base in USD | | | | | |
|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | **សរុប Total** |
| | 1 | 2 | 3 | 4 | 5 | **6=1+2+3+4+5** |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| **សរុប** Total | - | - | - | - | - | - |
| **មធ្យមប្រចាំថ្ងៃ** Daily Average | - | - | - | - | - | - |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintainance period: | | | | | | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (១២%) Reserve Requirement Rate (12%) | | | | | | 0.12 |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាដុល្លារអាមេរិក** Minimum reserve requirements In USD | | | | | | - |
| **កម្រិតអប្បបរមានៃការតម្កល់ប្រាក់បម្រុង** (៨០%) Daily compulsory threshold (80%) | | | | | | - |

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Checked By | Prepared By |

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក

## Report of Base Period on Reserve Requirement in EUR Converted into USD

ឈ្មោះធនាគារ/Name of Bank:

រយៈពេលមូលដ្ឋាន/Base Period:

រយៈពេលតម្កល់/Maintenance Period:

រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង: ១ខ-០២
Table: 1 B-02
(ឯកតាជាអឺរ៉ូ)
(In EUR)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន<br>Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាអឺរ៉ូ<br>Deposits and other borrowings base in EUR | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត<br>Demand Deposit | ប្រាក់បញ្ញើសំចៃ<br>Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់<br>Term Deposit | ប្រាក់បញ្ញើផ្សេងៗ<br>Other Deposits | បំណុលផ្សេងទៀត<br>Other Liabilities | សរុប<br>Total | អត្រាប្តូរប្រចាំថ្ងៃ អឺរ៉ូ/ដុល្លារអ.រ<br>Daily Ex. Rate EUR/USD | សរុបគិតជាដុល្លារអ.រ<br>Total Converted into UDS |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | **8=6/7** |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| | | | | | | - | | - |
| **សរុប** Total | - | - | - | - | - | - | | $0.00 |
| **មធ្យមប្រចាំថ្ងៃ**<br>Daily Average | - | - | - | - | - | - | | **$0.00** |

| | |
|---|---|
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintainance period: | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (១២%) Reserve Requirement Rate (12%) | 0.12 |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាអឺរ៉ូ គិតជាដុល្លារអាមេរិក** Minimum reserve requirements Converted into USD | **$0.00** |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | **$0.00** |

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

**នាយក**
Manager

**អ្នកពិនិត្យ**
Checked By

**អ្នកធ្វើតារាង**
Prepared By

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក
## Report of Base Period on Reserve Requirement in THB Converted into USD

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period :
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង: ១ខ-០៣
Table: 1 B-03
(ឯកតាជាថៃបាត)
(In THB)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាថៃបាត Deposits and other borrowings base in THB | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | សរុប Total | អត្រាប្តូរប្រាក់ប្រចាំថ្ងៃ ថៃបាត/ដុល្លារអ.រ Daily Ex. Rate EUR/USD | សរុបគិតជាដុល្លារអ.រ Total Converted into UDS |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | 8=6/7 |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុប Total | - | - | - | - | - | - | | $0.00 |
| មធ្យមប្រចាំថ្ងៃ Daily Average | - | - | - | - | - | - | | $0.00 |
| ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period: | | | | | | | | |
| អត្រាប្រាក់បម្រុងកាតព្វកិច្ច (១២%) Reserve Requirement Rate (12%) | | | | | | | | 0.12 |
| ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា ថៃបាតគិតជាដុល្លារអាមេរិក Minimum reserve requirements Converted into USD | | | | | | | | $0.00 |
| កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Daily compulsory threshold (80%) | | | | | | | | $0.00 |

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

| នាយក Manager | អ្នកពិនិត្យ Checked By | អ្នកធ្វើតារាង Prepared By |
|---|---|---|

# របាយការណ៍រយៈពេលមូលដ្ឋាន ស្ដីពី ប្រាក់បម្រុងកាតព្វកិច្ចជា... គិតជាដុល្លារអាមេរិក

## Report of Base Period on Reserve Requirement in …… Converted into USD*

ឈ្មោះធនាគារ/Name of Bank:

រយៈពេលមូលដ្ឋាន/Base Period: 

រយៈពេលតម្កល់/Maintenance Period :

រយៈពេលត្រូវរាយការណ៍/Reporting Period:

<u>តារាង: ១ខ-០៣</u>
<u>Table: 1 B-03</u>
(ឯកតាជា...)
(In ...)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា... Deposits and other borrowings base in ... | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | សរុប Total | អត្រាប្តូរប្រចាំថ្ងៃ ថៃបាត/ដុល្លារអ.រ Daily Ex. Rate EUR/USD | សរុបគិតជាដុល្លារអ.រ Total Converted into UDS |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | **8=6/7** |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុប** Total | - | - | - | - | - | - | | $0.00 |
| **មធ្យមប្រចាំថ្ងៃ** Daily Average | **-** | **-** | **-** | **-** | **-** | **-** | | **$0.00** |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintainance period: | | | | | | | | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (១២%) Reserve Requirement Rate (12%) | | | | | | | | 0.12 |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា... គិតជាដុល្លារអាមេរិក** Minimum reserve requirements Converted into USD | | | | | | | | **$0.00** |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | | | | | | | | **$0.00** |

*** កំណត់សម្គាល់/Note:**

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*
*There will be additional table as needed for each of the foreign currencies the institutions transact in*

Reporting Date:

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Checked By | Prepared By |

## របាយការណ៍រយៈពេលតម្កល់ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជារៀល
## Report of Maintenance Period on Reserve Requirement in KHR

ឈ្មោះធនាគារ/Name of Bank:

រយៈពេលមូលដ្ឋាន/Base Period:

រយៈពេលតម្កល់/Maintenance Period:

រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង : ២ ក
Table: 2 A
(ឯកតាគិតជាលានរៀល)
(In Million Riel)

| កាលបរិច្ឆេទនៃរយៈពេលត្រូវតម្កល់<br>Date of Maintenance period | សមតុល្យប្រាក់បម្រុងកាតព្វកិច្ចជារៀល នៅធនាគារជាតិនៃកម្ពុជា<br>Reserve Requirement Account Balance in KHR at NBC | កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%)<br>Minimum threshold of reserve maintenance (80%) | **អតិរេក/(ឱនភាព) ប្រាក់បម្រុងកាតព្វកិច្ច ប្រចាំថ្ងៃ**<br>**Daily Compulsory Threshold Surplus/(Deficit):** | សមតុល្យគណនីជាត់ទាត់ជារៀល នៅធនាគារជាតិនៃកម្ពុជា<br>Clearing Account Balance in KHR at NBC | សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ប្រចាំថ្ងៃ នៅធនាគារជាតិ នៃកម្ពុជា<br>Daily Reserve Requirement and Clearing Account balance at NBC |
|---|---|---|---|---|---|
| | 1 | 2 | 3=1-2 | 4 | 5=1+4 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **សរុប** Total | 0.00 | | | 0.00 | 0.00 |
| **មធ្យមប្រចាំថ្ងៃ**<br>Daily Average | 0.00 | | | 0.00 | 0.00 |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា (ទម្រង់: ១ក) Minimum Reserve Requirement (Form: 1A):** | | | | | 0.00 |
| **- អតិរេកប្រាក់បម្រុងកាតព្វកិច្ច Reserve Requirement Surplus:** | | | | | - |
| **- ឱនភាពប្រាក់បម្រុងកាតព្វកិច្ច Reserve Requirement Deficit:** | | | | | - |

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩
Reporting date:

**នាយក**/Manager　　**អ្នកពិនិត្យ**/Checked By　　**អ្នកធ្វើតារាង**/Prepared By

# របាយការណ៍រយៈពេលតម្កល់ ស្ដីពី ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក

## Report of Maintenance Period on Reserve Requirement in USD

**ឈ្មោះធនាគារ**/Name of Bank:

**រយៈពេលមូលដ្ឋាន**/Base Period:

**រយៈពេលតម្កល់**/Maintenance Period:

**រយៈពេលត្រូវរាយការណ៍**/Reporting Period:

តារាង: ២ ខ
Table: 2 A
(ឯកតាគិតជាដុល្លារអាមេរិក)
(In USD)

| កាលបរិច្ឆេទនៃរយៈពេលត្រូវតម្កល់<br>Date of Maintenance Period | សមតុល្យគណនី ប្រាក់បម្រុងកាតព្វកិច្ច ជាដុល្លារនៅធនាគារជាតិ នៃកម្ពុជា<br>Reserve Requirement Account Balance in USD at NBC | កំរិតកំណត់កាតព្វកិច្ច ប្រចាំថ្ងៃ (៨០%)<br>Minimum threshold of reserve maintenance (80%) | **អតិរេក/(ឱនភាព) ប្រាក់បម្រុងកាតព្វកិច្ច ប្រចាំថ្ងៃ**<br>**Daily compulsory threshold Surplus/(Deficit):** |
|---|---|---|---|
| | 1 | 2 | 3=1-2 |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| | | | - |
| **សរុប** Total | **0.00** | | |
| **មធ្យមប្រចាំថ្ងៃ**<br>Daily Average | **0.00** | | |
| - ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា (ទំរង់:១ខ):<br>Minimum Reserve Requirements (Form: 1B): | - | | |
| **- អតិរេកប្រាក់បម្រុងកាតព្វកិច្ច:**<br>Reserve Requirement Surplus: | - | | |
| - **ឱនភាពប្រាក់បម្រុងកាតព្វកិច្ច:**<br>Reserve Requirement Deficit: | - | | |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០៩
Reporting date:

**នាយក**/Manager **អ្នកពិនិត្យ**/Checked By **អ្នកធ្វើតារាង**/Prepared By

ឧបសម្ព័ន្ធ២ នៃប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

# សេចក្តីណែនាំ
# អនុវត្តប្រកាសស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា
# របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**១.- របាយការណ៍រយៈពេលមូលដ្ឋានៈ**

របាយការណ៍រយៈពេលមូលដ្ឋានលើកទី១ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃអង្គារ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃច័ន្ទ ទី០២ ខែមិនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលមូលដ្ឋានលើកទី១នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបានត្រឹមថ្ងៃព្រហស្បតិ៍ ទី០៥ ខែមិនា ឆ្នាំ២០០៩ អនុវត្តចំពោះប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចថ្មី។

របាយការណ៍រយៈពេលមូលដ្ឋានលើកទី២ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃអង្គារ៍ ទី០៣ ខែមិនា ឆ្នាំ២០០៩ ដល់ថ្ងៃច័ន្ទ ទី១៦ ខែមិនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលមូលដ្ឋានលើកទី២នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបានត្រឹមថ្ងៃព្រហស្បតិ៍ ទី១៩ ខែមិនា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលមូលដ្ឋានបន្ទាប់មកទៀតត្រូវអនុវត្តដោយស្វ័យប្រវត្តិ ក្នុងរយៈពេល ១៤ ថ្ងៃប្រតិទិន ដោយរាប់ចាប់ពីរយៈពេលមូលដ្ឋានមុន។

**២.- របាយការណ៍រយៈពេលតម្កល់ៈ**

របាយការណ៍រយៈពេលតម្កល់លើកទី១ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃសុក្រ ទី០៦ ខែមិនា ឆ្នាំ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមិនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលតម្កល់លើកទី១នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៩ ព្រោះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៩ ជាថ្ងៃអាទិត្យ ដូចនេះ ថ្ងៃផុតកំណត់នៃរបាយការណ៍ត្រូវលើកទៅ ថ្ងៃច័ន្ទ ទី២៣ ខែមិនា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលតម្កល់លើកទី២ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃសុក្រ ទី២០ ខែមិនា ឆ្នាំ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី០២ ខែមេសា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលតម្កល់លើកទី២ នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបាននៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ព្រោះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ជាថ្ងៃអាទិត្យ ដូចនេះ ថ្ងៃផុតកំណត់នៃរបាយការណ៍ត្រូវលើកទៅ ថ្ងៃច័ន្ទ ទី០៦ ខែមេសា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលតម្កល់បន្ទាប់មកទៀតត្រូវអនុវត្តដោយស្វ័យប្រវត្តិ ក្នុងរយៈពេល ១៤ ថ្ងៃ ប្រតិទិន ដោយរាប់ចាប់ពីរយៈពេលតម្កល់មុន។

**៣.- អន្តរកាលចំពោះការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា**

គ្រឹះស្ថានត្រូវរក្សាជាមធ្យមនូវប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់ខ្លួន ដោយផ្អែកទៅលើតួលេខ ដែលបានរាយការណ៍សម្រាប់រយៈពេលមូលដ្ឋានចាស់ចាប់ពីថ្ងៃសុក្រ ទី០៩ ខែមករា ឆ្នាំ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ រហូតដល់ ថ្ងៃព្រហស្បតិ៍ ទី០៥ ខែមិនា ឆ្នាំ២០០៩ ដែលជារយៈពេលតម្កល់ចាស់។

ចាប់ពីថ្ងៃសុក្រ ទី០៦ ខែមិនា ឆ្នាំ២០០៩ គ្រឹះស្ថានទាំងអស់ត្រូវអនុវត្តកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ស្មើ ៨០% និងប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមសម្រាប់រយៈពេលតម្កល់។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាតាមប្រព័ន្ធថ្មីសម្រាប់រយៈពេលមូលដ្ឋានលើកទីមួយ ត្រូវអនុវត្តចាប់ពីថ្ងៃអង្គារ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃច័ន្ទ ទី០២ ខែមិនា ឆ្នាំ២០០៩ ដោយរាប់ចាប់ពីថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៩ ថយក្រោយចំនួន១៧ថ្ងៃ។

**៤.- ថ្ងៃឈប់សម្រាកជាសាធារណៈ**

ប្រសិនបើថ្ងៃរាយការណ៍ត្រូវចំថ្ងៃចុងសប្ដាហ៍ ឬថ្ងៃឈប់សម្រាកជាសាធារណៈ គ្រឹះស្ថានត្រូវផ្ញើរបាយ-ការណ៍មកធនាគារជាតិនៃកម្ពុជា នៅថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់សម្រាក។

ធ៧-០១០-១៨២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ

**ប្រការ ១**.-

គ្រឹះស្ថានធនាគារត្រូវគណនាមូលនិធិផ្ទាល់សុទ្ធឱ្យស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។ រាល់អនុបាត និងកម្រិតកំណត់ប្រុងប្រយ័ត្នដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ ត្រូវគណនាឱ្យស្របតាមវិធាននៃការគណនានេះ។ លើសពីនេះ ដើមទុនឬទាយជ្ជទានដែលបានបង់ និងមូលនិធិផ្ទាល់សុទ្ធត្រូវតែស្មើ ឬលើសពីដើមទុនអប្បបរមាដែលត្រូវបានអនុវត្តចំពោះគ្រឹះស្ថាននោះ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុង សំដៅធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកាតព្វកិច្ចជាបទបញ្ជាទាំងអស់ ទាក់ទងនឹងអនុបាតសាធនភាពអប្បបរមា និងកម្រិតកំណត់ដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ។

**ប្រការ ៣**.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានធនាគារអនុវត្តនីតិវិធីពិសេស ក្រោមរូបភាពជាការដកចេញនូវខ្ទង់មួយចំនួនថែមទៀតពីការគណនាមូលនិធិផ្ទាល់សុទ្ធ ដោយមិនគិតដល់វិធានទូទៅនៃការគណនាដូចមានចែងនៅក្នុងប្រកាសនេះ។ ការអនុវត្តនីតិវិធីពិសេសនេះគឺ ដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមបទបញ្ជា និងដើម្បីឆ្លុះបញ្ចាំងឱ្យឃើញហានិភ័យជាក់ស្តែងនិងហានិភ័យជាសក្តានុពល ក្នុងគោលបំណងប្រុងប្រយ័ត្ន។

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការអនុវត្តនីតិវិធីពិសេសនេះ ហើយគ្រឹះស្ថានធនាគារត្រូវអនុវត្តតាមភ្លាម រហូតដល់មានការណែនាំផ្សេងជាលាយលក្ខណ៍អក្សរ។

**ប្រការ ៤**.-

មូលនិធិផ្ទាល់សុទ្ធសរុបមានសមាសធាតុ ២ ដាច់ដោយឡែកពីគ្នាគឺ ៖

- ដើមទុនថ្នាក់ទីមួយ (ដើមទុនស្នូល) និង
- ដើមទុនថ្នាក់ទីពីរ (ដើមទុនបំពេញបន្ថែម)

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយទេ ឬ មិនត្រូវលើសពី ៥០% នៃមូលនិធិផ្ទាល់សុទ្ធសរុបឡើយ ។

មុននឹងចេញរបាយការណ៍ពាក់ព័ន្ធ ធនាគារត្រូវពិនិត្យ ផ្ទៀងផ្ទាត់ ដើម្បីធានាការប្រតិបត្តិតាមកម្រិតកំណត់នេះ ។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការសមស្រប។

**ប្រការ ៥.-**

ដើមទុនថ្នាក់ទីមួយ ត្រូវគណនាដូចខាងក្រោម ៖

I- **សរុបរង** A: (**ខ្ទង់ត្រូវបូក**)

- ដើមទុន ឬទាយជ្ជទាន ដែលបានបង់
ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងអំពីសេចក្តីសម្រេចដល់គ្រឹះស្ថានដែលបានស្នើសុំក្នុងរយៈពេល២ (ពីរ) ថ្ងៃធ្វើការ ចាប់ពីថ្ងៃបានទទួលសំណុំឯកសារគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។

សេចក្តីសម្រេចរបស់ធនាគារជាតិនៃកម្ពុជាអាចភ្ជាប់ជាមួយនូវវិធានការ និងលក្ខខណ្ឌមួយចំនួន ដែលអាចតម្រូវឱ្យមានការតាមដានបន្ថែមទៀត ក្នុងគោលបំណងធ្វើឱ្យការវាយតម្លៃស្ថានភាពទូទៅរបស់គ្រឹះស្ថានកាន់តែ

ប្រសើរឡើងដោយយកចិត្តទុកដាក់លើការត្រួតពិនិត្យដល់ទីកន្លែង និងពិនិត្យកាត់បន្ថយតម្លៃ (Haircut) ឱ្យបានសមស្របតាមវត្ថុធានាដែលដាក់បញ្ចាំ និងការងារផ្សេងទៀតដែលចាំបាច់ក្នុងការសម្រេចឱ្យបានច្បាស់លាស់។

**ប្រការ ១១**.-

ឥណទានវិបារូបន៍ អាចត្រូវបានផ្តល់ជាប្រាក់ដុល្លារអាមេរិក ឬជាប្រាក់រៀលដោយផ្អែកលើកង្វះសាច់ប្រាក់ងាយស្រួលដែលបានព្យាករណ៍ទុកជាមុនដោយគ្រឹះស្ថានស្នើសុំ។

ឥណទានវិបារូបន៍ដែលបានស្នើសុំ ត្រូវផ្អែកលើប្រាក់បម្រុងកាតព្វកិច្ចដែលគ្រឹះស្ថានត្រូវប្រតិបត្តិតាម។ សំណើសុំឥណទានវិបារូបន៍មិនត្រូវលើសពី ៥០% នៃប្រាក់បម្រុងកាតព្វកិច្ច។

សោហ៊ុយទម្រង់ការ និងអត្រាការប្រាក់លើឥណទានវិបារូបន៍នេះ គឺជាអត្រាការប្រាក់មិនលើកទឹកចិត្តនឹងត្រូវបានកំណត់តាមការជាក់ស្តែងដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ១២**.-

ឥណទានវិបារូបន៍ នឹងត្រូវបានផ្តល់ដល់គ្រឹះស្ថានក្នុងគោលបំណងជួយដោះស្រាយកង្វះសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីដំបូងចាប់ពី១ (មួយ)សប្តាហ៍ ដល់១ (មួយ)ខែ។

ឥណទានវិបារូបន៍អាចត្រូវបានពន្យារពេលជាថ្មី ដែលមិនអាចលើសពី១ (មួយ)ខែ និងមិនអាចលើសពី ២(ពីរ) ដងឡើយ។ ក្នុងករណីដែលគ្រឹះស្ថាននៅតែមានសាធនភាព និងស្ថិតក្នុងស្ថានភាពដំណើរការបាន គ្រឹះស្ថានអាចបន្តអនុវត្តផែនការសមស្របដែលបានស្នើឡើង ប៉ុន្តែបើផែនការសកម្មភាពមិនគ្រប់គ្រាន់ ធនាគារជាតិនៃកម្ពុជានឹងដាក់វិធានការកែតម្រូវបន្ទាន់បន្ថែមទៀត ដែលជាចុងបញ្ចប់អាចដោះស្រាយបញ្ហាសាច់ប្រាក់ងាយស្រួលប្រកបដោយនិរន្តរភាព។

បើការអនុវត្តផែនការស្តារស្ថានភាពដែលបានស្នើ ពុំអាចនាំទៅដល់ការដោះស្រាយស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានឱ្យមាននិរន្តរភាពនិងប្រសើរឡើងក្រោយពីការពន្យារពេលឥណទានវិបារូបន៍ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការត្រួតពិនិត្យសមស្របណាមួយ ដើម្បីដោះស្រាយបញ្ហារបស់គ្រឹះស្ថាន និងធ្វើសេចក្តីសម្រេចចិត្ត។

## ជំពូក ៤
## វត្ថុធានាសមស្រប និងការកាត់បន្ថយតម្លៃ

**ប្រការ ១៣**.-

ក្រៅពីវត្ថុធានាដែលមានចែងក្នុងមាត្រា ៣៦ និង ៣៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានអាចស្នើដាក់ឥណទានដែលបានផ្តល់ឱ្យអតិថិជនរបស់ខ្លួន ជាវត្ថុបញ្ចាំក្នុងគោលបំណងធានាលើការសុំខ្ចីឥណទានវិបារូបន៍។

ឥណទានដាក់បញ្ចាំបែបនេះ ត្រូវតែជាឥណទានដំណើរការ (ស្តង់ដារ) នៅក្នុងបញ្ជីរបស់គ្រឹះស្ថាន។ ឥណទានមិនដំណើរការ (ក្រោមស្តង់ដារ សង្ស័យ បាត់បង់) មិនអាចចាត់ទុកជាវត្ថុបញ្ចាំសម្រាប់ធានាឥណទានវិបារូបន៍នឹងត្រូវបានបដិសេធដោយធនាគារជាតិនៃកម្ពុជា។ ឥណទានដែលអាចទទួលយកបានត្រូវឆ្លើយតបតាមរាល់លក្ខខណ្ឌ និងកាតព្វកិច្ចដែលមានចែងក្នុងបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទានដែលចេញដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថាន ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា នូវបញ្ជីលំអិតនៃវត្ថុធានា និងឥណទានដែលបានផ្តល់ឱ្យអតិថិជន ដូចជា ប្រាក់ដើម ឈ្មោះអតិថិជន ប្រភេទឥណទាន ចំណាត់ថ្នាក់ឥណទាន រយៈពេលឱ្យខ្ចី តារាងសងរំលោះ ចំនួនប្រតិបត្តិការ កាលវសាន្ត និងវត្ថុបញ្ចាំសម្រាប់ធានាឥណទាន។

ឥណទាន និងឥណទានផ្សេងទៀតដែលបានផ្តល់ឱ្យសម្ព័ន្ធញាតិមិនត្រូវបានទទួលយក ហើយធនាគារជាតិនៃកម្ពុជា នឹងតម្រូវឱ្យមានវត្ថុបញ្ចាំជំនួសបន្ថែមផ្សេងទៀត។ ធនាគារជាតិនៃកម្ពុជា នឹងបដិសេធវត្ថុធានាក្នុងករណីដែលមានការសង្ស័យអំពីទំនាក់ទំនងជិតស្និទ្ធជាមួយសម្ព័ន្ធញាតិខាងផ្នែកសេដ្ឋកិច្ច ឬ អាជីវកម្ម។ សេចក្តីសម្រេចបដិសេធរបស់ធនាគារជាតិនៃកម្ពុជាមិនមែនជាកម្មវត្ថុនៃការតវ៉ាឡើយ។

ឥណទាន និងឥណទានផ្សេងទៀតដែលបានដាក់ជាវត្ថុធានាត្រូវតែបានធ្វើពិពិធកម្ម ដើម្បីជៀសវាងបញ្ហាប្រមូលផ្តុំណាមួយដូចជា ហានិភ័យចំពោះអ្នកខ្ចីតែម្នាក់ ក្រុមអ្នកខ្ចីតែមួយ និងវិស័យសេដ្ឋកិច្ចតែមួយ។ ធនាគារជាតិនៃកម្ពុជា នឹងធានាភាពសមស្របនៃការធ្វើពិពិធកម្មហានិភ័យ ដោយតម្រូវឱ្យមានទ្រព្យសកម្មច្រើនសម្រាប់ដាក់បញ្ចាំ និងពិនិត្យឡើងវិញនូវតម្រូវការនៃពិពិធកម្មនោះ។

គ្រឹះស្ថានមិនត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវឥណទាន ឬឥណទានផ្សេងទៀត ជាវត្ថុបញ្ចាំដែលដល់កាលវសាន្តនៅក្នុងរយៈពេលនៃឥណទានវិបារូបន៍ឡើយ។

**ប្រការ ១៤**.-

វត្ថុធានា ត្រូវមានតម្លៃតាមតម្លៃចុះបញ្ជីនៅកាលបរិច្ឆេទជិតបំផុតទៅនឹងការរៀបចំបញ្ជីវត្ថុធានា ដែលត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៥**.-

ធនាគារជាតិនៃកម្ពុជា កាត់បន្ថយ ៤០% នៃតម្លៃវត្ថុបញ្ចាំសរុបដែលដាក់ធានាលើឥណទានវិបារូបន៍ មានន័យថា បើវត្ថុបញ្ចាំមានតម្លៃ ១០០ ឥណទានវិបារូបន៍អាចផ្តល់បានត្រឹមតែ ៦០ ប៉ុណ្ណោះ។

ធនាគារជាតិនៃកម្ពុជា អាចបង្កើនកម្រិតកាត់បន្ថយតម្លៃថែមទៀតទៅតាមទំហំហានិភ័យជាក់ស្តែង បើពិនិត្យឃើញនូវភស្តុតាងថា វត្ថុបញ្ចាំជាឥណទានមិនដំណើរការ ឬតម្រូវឱ្យចាត់ថ្នាក់ជាឥណទានមិនដំណើរការនៅក្នុងបញ្ជីរបស់គ្រឹះស្ថាន។

## ជំពូក ៥
## វត្ថុដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា

**ប្រការ ១៦**.-

ឥណទាន និងទ្រព្យសកម្មសមស្របដទៃទៀតដែលបានដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា ជាវត្ថុធានាលើឥណទានវិបារូបន៍ ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នៅក្នុងបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថាន។

ការដាក់វត្ថុបញ្ចាំ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអនុលោមតាមទម្រង់គតិយុត្ត និងបទបញ្ញាជាធរមាន ដើម្បីការពារផលប្រយោជន៍របស់ធនាគារជាតិនៃកម្ពុជា និងដើម្បីទប់ស្កាត់ការប្តឹងទាមទាររួមគ្នាពីសំណាក់ភាគីឱ្យខ្ចីផ្សេងទៀតដែលមានវត្ថុបញ្ចាំ។

ធនាគារជាតិនៃកម្ពុជា ជាឥណទាយកមានអាទិភាពទទួលបានសំណងពេញលេញនៃឥណទានវិបារូបន៍ ការប្រាក់បង្គរ ការផាកពិន័យ និងសោហ៊ុយទម្រង់ការផ្សេងទៀត។

**ប្រការ ១៧.-**

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិពេញលេញលើវត្ថុដែលបានដាក់បញ្ចាំ និងអាចមានវិធានការត្រួតពិនិត្យ និងប្ដឹងទៅតុលាការ បើគ្រឹះស្ថានមានចេតនាលាក់បាំងព័ត៌មានពាក់ព័ន្ធនឹងវត្ថុបញ្ចាំ ដែលអាចរារាំងសិទ្ធិរបស់ធនាគារជាតិនៃកម្ពុជាលើវត្ថុបញ្ចាំនោះ។

ដើម្បីធានាអាទិភាពជាឥណទាយក ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រឹះស្ថានផ្ដល់ឯកសារច្បាប់ដើម រួមមានកិច្ចសន្យា ឯកសារឥណទាន ឯកសារភស្ដុតាងផ្សេងៗទៀត ប័ណ្ណកម្មសិទ្ធិ និងវត្ថុផ្សេងទៀតដែលបានដាក់បញ្ចាំធានាឥណទានទាំងនោះ។

ក្នុងករណីដែលព្រឹត្តិការណ៍ណាមួយដូចមានចែងនៅក្នុងប្រការ ២១ ចំណុច ក និង ខ កើតឡើង គ្រឹះស្ថានត្រូវផ្ដល់វត្ថុធានាជំនួសសមស្រប និងឯកសារពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងកថាខណ្ឌ២នៃប្រការនេះបន្ទាប់ពីមានការព្រមព្រៀងជាមុនពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា អាចប្រគល់ឯកសារច្បាប់ដើមទាក់ទងទៅនឹងឥណទាន និងឥណទានផ្សេងទៀត ដែលត្រូវបានដកចេញពីសំណុំវត្ថុធានា។

**ប្រការ ១៨.-**

គ្រឹះស្ថាន ត្រូវបង្ហាញវត្ថុធានាដែលដាក់បញ្ចាំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ក្នុងទម្រង់ជាកំណត់សម្គាល់ ដោយសង្ខេបនូវចំនួនប្រាក់ និងលក្ខណៈចម្បងៗនៃទ្រព្យសកម្ម ដែលបានដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលឥណទានវិបារូបន៍នៅមានសុពលភាពនាការិយបរិច្ឆេទនៃរបាយការណ៍ ។

## ជំពូក ៦
## ការពិនិត្យគុណភាពវត្ថុបញ្ចាំឡើងវិញ

**ប្រការ ១៩.-**

ធនាគារជាតិនៃកម្ពុជា ពិនិត្យវត្ថុបញ្ចាំឡើងវិញតាមវិធីសាស្ត្រសមស្របមុននឹងសម្រេចជាចុងក្រោយលើលក្ខខណ្ឌនៃការស្នើសុំឥណទានវិបារូបន៍។

ការពិនិត្យវត្ថុបញ្ចាំឡើងវិញទាំងនេះ ត្រូវធ្វើឡើងតាមរយៈការត្រួតពិនិត្យដល់ទីកន្លែង ក្នុងគោលបំណងផ្ទៀងផ្ទាត់នូវចំណុចមួយចំនួនដូចខាងក្រោមៈ

- ភាពត្រឹមត្រូវនៃកម្មសិទ្ធិវត្ថុដាក់បញ្ចាំដែលបានស្នើសុំ
- លក្ខណៈរបស់វត្ថុធានារួមមាន អត្ថិភាព និងសុពលភាពនៃវត្ថុធានា ប័ណ្ណកម្មសិទ្ធិ និងមធ្យោបាយកាត់បន្ថយហានិភ័យឥណទានផ្សេងទៀត ដើម្បីធានាឥណទានដែលបានស្នើដាក់បញ្ចាំ
- ការខកខានមិនបានធ្វើចំណាត់ថ្នាក់នៅក្នុងបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថាននោះ ក៏ដូចជាការកត់ត្រាចំណាត់ថ្នាក់ឥណទានដំណើរការ និងឥណទានមិនដំណើរការក្នុងគ្រាកន្លងមក និង
- លក្ខខណ្ឌទាំងឡាយ ដែលក្នុងនោះឥណទាន និងទ្រព្យសកម្មដែលត្រូវបានស្នើដាក់ជាវត្ថុបញ្ចាំសម្រាប់ធានា ដើម្បីការពារនូវផលប្រយោជន៍របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ២០**.-

ចំពោះវត្ថុធានាដែលត្រូវបដិសេធដោយសារបញ្ហាមិនដំណើរការ ឬការព្រួយបារម្ភផ្សេងៗទៀត ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានធ្វើចំណាត់ថ្នាក់ឡើងវិញជាបន្ទាន់លើលក្ខខណ្ឌចុះកិច្ចបញ្ជិកាគណនេយ្យ និងការធ្វើសំវិធានធនហានិភ័យស្របទៅនឹងតម្រូវការដូចមានចែងក្នុងបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន។

## ជំពូក ៧
## ភាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា

**ប្រការ ២១**.-

គ្រឹះស្ថាន មានកាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា បន្ទាប់ពីបានទទួលឥណទានវិបារូបន៍រហូតដល់ធនាគារជាតិនៃកម្ពុជាលែងមានតម្រូវការអំពីរបាយការណ៍ទាំងនោះ។

កាតព្វកិច្ចរាយការណ៍នេះ នឹងត្រូវផ្អែកលើកាលៈទេសៈមិនល្អដែលជះឥទ្ធិពលលើស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន និងស្របតាមទម្រង់ហានិភ័យជារួមដែលវាយតម្លៃដោយធនាគារជាតិនៃកម្ពុជា លើស្ថានភាពទូទៅរបស់គ្រឹះស្ថាននោះ។ ភាពញឹកញាប់នៃរបាយការណ៍ ត្រូវតែសមស្របទៅតាមការវាយតម្លៃហានិភ័យ។

គ្រឹះស្ថានដែលទទួលបានឥណទានវិបារូបន៍ ត្រូវមានកាតព្វកិច្ចរាយការណ៍ជាអប្បបរមាមកធនាគារជាតិនៃកម្ពុជា ដូចតទៅ ៖

- ក- រាល់ការសម្រេចធ្វើចំណាត់ថ្នាក់លើវត្ថុដែលដាក់បញ្ចាំ ក្នុងអំឡុងពេលសុពលភាពនៃឥណទានវិបារូបន៍ និងរាល់សំណើពាក់ព័ន្ធនឹងការដាក់វត្ថុបញ្ចាំថ្មីជំនួសវត្ថុបញ្ចាំ ដែលត្រូវបានធ្វើចំណាត់ថ្នាក់។
- ខ- រាល់ព្រឹត្តិការណ៍ដែលកើតមានចំពោះវត្ថុបញ្ចាំនៅធនាគារជាតិនៃកម្ពុជា ដោយមិនកំណត់ត្រឹមតែការមិនសងប្រាក់ ឬការទូទាត់សងមុនកាលកំណត់
- គ- ការវិវឌ្ឍនៃការអនុវត្តផែនការស្តារស្ថានភាព និងផលប៉ះពាល់លើស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន
- ឃ- ការលំបាកដែលកើតមានឡើងដោយមិនបានដឹងមុនក្នុងការអនុវត្តផែនការស្តារស្ថានភាព និង បញ្ហាប្រឈមផ្សេងៗទៀត ដើម្បីស្តារសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានឱ្យស្ថិតក្នុងកម្រិតគ្រប់គ្រាន់។

នៅពេលកាលៈទេសៈតម្រូវ ដោយសារកង្វល់អំពីកង្វះសាច់ប្រាក់ងាយស្រួលធ្ងន់ធ្ងរ និងការធ្លាក់ចុះកាន់តែធ្ងន់ធ្ងរនូវស្ថានភាពរបស់គ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជា នឹងតម្រូវឱ្យមានរបាយការណ៍ប្រចាំថ្ងៃ ស្តីពីលំហូរចូល និង ចេញ ក៏ដូចជារបាយការណ៍ស្តីពីការព្យាករណ៍គំលាតសាច់ប្រាក់ងាយស្រួលនៅថ្ងៃបន្ទាប់មកទៀត។

**ប្រការ ២២**.-

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់នៅពេលដែលមានការពន្យារពេលឥណទានវិបារូបន៍ ហើយអាចឈានទៅដល់ការត្រួតពិនិត្យដល់ទីកន្លែង ក្នុងគោលបំណងតាមដានទាំងស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាព។

## ជំពូក ៨
## អវសានប្បញ្ញត្តិ

**ប្រការ ២៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៤**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១-១១៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនិងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគមចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួនឱ្យបានស្របតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ២**.-

ការប្រាក់ចំពោះឥណទានដែលបានផ្តល់ឱ្យតាមខ្លឹមសារនៃប្រកាសនេះ ត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយបានន័យថា ការប្រាក់លើឥណទានសម្រាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ។

**ប្រការ ៣**.-

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជនត្រូវមានបង្ហាញតារាងពីការសងរំលោះឥណទាន។

**ប្រការ ៤**.-

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០២-១៨៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ចំណាត់ថ្នាក់និងសំវិធានធនលើឥណទាន
# អនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរៀបចំប្រព័ន្ធព័ត៌មានគណនេយ្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ព័ត៌មានជាអចិន្ត្រៃយ៍ដល់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជា៤ថ្នាក់ ដោយផ្អែកទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់ និងឥណប្រតិទាននៃការទូទាត់សងប្រាក់ដើមនិងការប្រាក់ ដូចខាងក្រោម ៖

- បំណុលស្តង់ដារៈ ស្ថានភាពហិរញ្ញវត្ថុល្អ និងការសងទៀងទាត់នៃប្រាក់ដើម និងការប្រាក់។
- បំណុលក្រោមស្តង់ដារៈ ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់៣០ថ្ងៃឬច្រើនជាង។
- បំណុលសង្ស័យៈ ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោមៈ
    - ៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង ១ឆ្នាំ។
    - ១៨០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទានលើសពី ១ឆ្នាំ។
- បំណុលបាត់បង់ៈ ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោមៈ
    - ៩០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង ១ឆ្នាំ។
    - ៣៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទានលើសពី ១ឆ្នាំ។

**ប្រការ ៣**.-

ធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើសំវិធានធនលើឥណទាន ដូចខាងក្រោមៈ

- បំណុលក្រោមស្តង់ដារៈ ១០%ដោយមិនគិតដល់តម្លៃទ្រព្យសម្បត្តិ ដែលបានដាក់បញ្ចាំ លើកលែងតែសាច់ប្រាក់
- បំណុលសង្ស័យៈ ៣០%ដោយមិនគិតដល់តម្លៃទ្រព្យសម្បត្តិ ដែលបានដាក់បញ្ចាំលើកលែងតែសាច់ប្រាក់
- បំណុលបាត់បង់ៈ ១០០% បើគ្រឹះស្ថានអាចបង្ហាញភស្តុតាងតាមករណីនីមួយៗនូវតម្លៃទីផ្សារជាក់ស្តែងនៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ចំនួនឥណទានដែលពុំមានសំភារៈធានាត្រូវធ្វើសំវិធានធន។

សំវិធានធនត្រូវបានគណនាតាមសមតុល្យឥណទានដែលបានធ្វើចំណាត់ថ្នាក់ ដោយមិនគិតបញ្ចូលការប្រាក់បង្គរ។ សំវិធានធនត្រូវបានកត់ត្រាក្នុងគណនីរបស់គ្រឹះស្ថាន ហើយគិតបញ្ចូលទៅក្នុងគណនីចំណេញ-ខាតក្នុងខែដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ។

**ប្រការ ៤**.-

ការប្រាក់បង្គរលើឥណទានត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាតនៅពេលកត់ត្រាបង្គរ។ ប៉ុន្តែចំពោះឥណទានដែលបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ និងការប្រាក់បង្គរដែលមិនបានសងពេលនេះនឹងត្រូវផ្ទេរចេញពីគណនីចំណេញ-ខាតហើយយកទៅចុះឥណទានក្នុងគណនីព្យួរទុក។ ដូចគ្នានេះដែរ ការប្រាក់បង្គរលើឥណទានណាមួយ បន្ទាប់ពីបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារនឹងត្រូវចុះឥណទានក្នុងគណនីព្យួរទុក។

**ប្រការ ៥**.-

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០២-៤៨ ប្រ.ក

# ប្រកាស
# ស្តីពី
# អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ត្រូវរក្សាសាច់ប្រាក់ងាយស្រួលឱ្យបានគ្រប់គ្រាន់ជាអចិន្ត្រៃយ៍យ៉ាងហោចណាស់ស្មើនឹងមួយរយភាគរយ (១០០%)។

**ប្រការ ២**.-

អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចខាងក្រោម ៖

- ភាគយក : សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ឥណទានដែលឥណប្រតិទាននៅសល់តិចជាងមួយខែ។
- ភាគបែង : ម្ភៃប្រាំភាគរយ (២៥%) នៃប្រាក់សន្សំដោយស្ម័គ្រចិត្តមិនរួមបញ្ចូលប្រាក់សន្សំកាតព្វកិច្ច។

**ប្រការ ៣**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្តល់ឯកសារពីការគណនាអនុបាតសាច់ប្រាក់ងាយស្រួលប្រចាំខែរបស់ខ្លួនតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០២-៤៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការរក្សាប្រាក់បម្រុងកាតព្វកិច្ចចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន ៥ ភាគរយ (៥%) នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់បញ្ញើដែលមាននៅក្នុងតារាងតុល្យការរបស់គ្រឹះស្ថាន និងក្នុងរបាយការណ៍បែងចែកប្រភេទប្រាក់បញ្ញើដែលគ្រឹះស្ថានប្រមូលបាននៅចុងខែនីមួយៗ។ ការគណនាប្រាក់បម្រុងកាតព្វកិច្ចត្រូវដកចេញប្រាក់សន្សំកាតព្វកិច្ចដែលជាលក្ខខណ្ឌក្នុងការផ្តល់ឥណទាន។

**ប្រការ ៣**.-

ប្រាក់បម្រុងកាតព្វកិច្ចដូចក្នុងប្រការ២ ដែលបានគណនានៅខែណាមួយ ត្រូវរក្សាទុកក្នុងគណនីរបស់គ្រឹះស្ថាននៅធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី១៥ នៃខែបន្ទាប់រហូតដល់ថ្ងៃទី១៤ នៃខែបន្ទាប់ទៀតហើយការគណនានិងរក្សាទុកប្រាក់បម្រុងកាតព្វកិច្ចត្រូវអនុវត្តដូចគ្នានេះជាបន្តបន្ទាប់តាមគ្រានីមួយៗ។

**ប្រការ ៤**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានឱនភាពប្រាក់បម្រុងកាតព្វកិច្ចត្រូវបំពេញជាបន្ទាន់នៅពេលណាដែលគ្រឹះស្ថានទាំងនេះទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៧-១៣៣ ប្រ.ក

# ប្រកាស
# ស្តីពី
# អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលតទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវពិនិត្យជាអចិន្ត្រៃយ៍នូវអនុបាតសាធនភាពរបស់ខ្លួនឱ្យបានស្របតាមបញ្ញត្តិនៃប្រកាសនេះ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យទ្រព្យសកម្មសរុបដែលបានថ្លឹងមិនត្រូវតិចជាងដប់ប្រាំភាគរយ (១៥%) ឡើយ។

**ប្រការ ២**.-

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

**ប្រការ ៣**.-

ក- ភាគបែងនៃអនុបាត គឺជាតម្លៃទ្រព្យសកម្មសរុប (តម្លៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធន និង ការរំលោះតម្លៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកម្រិតហានិភ័យ។ ភាគបែងនេះមិនរាប់បញ្ចូលនូវខ្ទង់ដែលបានដកចេញនៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ខ- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម៖

ខ.១- ការថ្លឹងសូន្យភាគរយ (Zero Weighting) ចំពោះ៖

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលមានវត្ថុបញ្ចាំជាប្រាក់បញ្ញើនៅធនាគារ
- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ (Claim on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.២- ការថ្លឹង ២០% ចំពោះ ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៣- ការថ្លឹង ៥០% ចំពោះ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៤- ការថ្លឹង ១០០% ចំពោះ ៖

- ទ្រព្យសកម្មដទៃទៀតទាំងអស់
- ខ្ទង់ក្រៅតារាងតុល្យការទាំងអស់។

**ប្រការ ៤.-**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥.-**

ប្រការ១៥ នៃប្រកាសលេខធ៧-០០-០៦ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៧-១៣២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគណនាដូចតទៅ ៖

I- **សរុប** A : ខ្ទង់ត្រូវបូក

- ដើមទុន ឬទាយជ្ជទានដើមទុន
- ទុនបម្រុងក្រៅពីទុនបម្រុងពីការវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ចំណេញរក្សាទុកសម្រាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយសម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ [១]
- ខ្ទង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា [២] ។

II- **សរុប** B : ខ្ទង់ត្រូវដក

- ចំពោះភាគទុនិក : នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាន ឥណទាន មូលបត្រ និងកិច្ចសន្យារបស់ជនពាក់ព័ន្ធខាងលើ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់តាមតម្លៃចុះបញ្ជី
- ការខាតបង្គរ
- ចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ (រួមបញ្ចូលទាំងសំវិធានធនសម្រាប់បំណុលនិងមូលបត្រសង្ស័យ)។

---

[១] ក្រោយពីដកភាគលាភដែលត្រូវបែងចែក

[២] ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំក្នុងលក្ខខណ្ឌដែលៈ

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណាដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ ព្រមទាំងសំវិធានធន និងតម្លៃគណនីកែតម្រូវ
- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវបានផ្ទៀងផ្ទាត់ដោយស្នងការគណនី

III- **សរុប** C : **មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន = A - B**

IV - **សរុប** D: ខ្ទង់ត្រូវបូក

- ទុនបម្រុងពីការវាយតម្លៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- អនុបំណុល (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូល ១០០% នៃចំនួនមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន
- ខ្ទង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធមិនឱ្យលើសពីចំនួននៃមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន[៣]។

V- **សរុប** E: ខ្ទង់ត្រូវដក

- ភាគកម្មមូលនិធិផ្ទាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា
- ខ្ទង់ផ្សេងៗ [៤]។

VI- **សរុប** F: សរុបមូលនិធិផ្ទាល់សុទ្ធ = C + D - E

**ប្រការ ២**.-

មូលនិធិផ្ទាល់សុទ្ធដែលបានគណនាមកនេះ ត្រូវបានយកមកគិតគូរសម្រាប់ការគណនាអនុបាតប្រុងប្រយ័ត្ន និងអនុបាតផ្សេងទៀត។

**ប្រការ ៣**.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៤**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

---

[៣] ខ្ទង់ផ្សេងៗអាចរួមមានខ្ទង់ទាំងឡាយដូចខាងក្រោមនេះ ÷

- មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ
- មូលនិធិសាធារណៈដែលបែងចែកសម្រាប់ធានាប្រភេទប្រតិបត្តិការឥណទាន
- ឧបត្ថម្ភធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ

[៤] ឧទាហរណ៍ៈ ចំណាយដែលត្រូវបែងចែកសម្រាប់ច្រើនការិយបរិច្ឆេទ

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០២-២១៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តប្លង់គណនីសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ដាក់ចេញប្លង់គណនីនិងកាតព្វកិច្ចបើកចំហព័ត៌មានសម្រាប់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឱ្យអនុវត្តដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។

**ប្រការ ២**.-

ការអនុវត្តន៍ប្លង់គណនីនិងកាតព្វកិច្ចបើកចំហព័ត៌មានត្រូវចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣។

**ប្រការ ៣**.-

របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ផ្សេងៗ ដែលត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា សម្រាប់ខែមករា ឆ្នាំ២០០៣ និងគ្រាបន្តបន្ទាប់ត្រូវបំពេញត្រឹមត្រូវលើមូលដ្ឋានប្លង់គណនីនិងកាតព្វកិច្ចបើកចំហព័ត៌មាន។

**ប្រការ ៤**.-

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបង្កើតបន្ថែម ឬលុបចោលឈ្មោះនិងលេខគណនីតាមការចាំបាច់។

**ប្រការ ៥**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ត្រូវអនុវត្តតាមផងដែរនូវស្តង់ដារគណនេយ្យកម្ពុជាដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលកាតព្វកិច្ចគណនេយ្យកំណត់ដោយធនាគារជាតិនៃកម្ពុជា មានភាពខុសគ្នាពីស្តង់ដារគណនេយ្យកម្ពុជា កាតព្វកិច្ចដែលតម្រូវដោយធនាគារជាតិនៃកម្ពុជាត្រូវមានប្រសិទ្ធភាពអនុវត្ត។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០២-៤៧ ប្រ.ក

# ប្រកាស
# ស្តីពី
# គម្រូរបាយការណ៍សម្រាប់ប្រតិបត្តិករគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ

**ប្រការ ១**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់ ស្តីអំពី លទ្ធផលហិរញ្ញវត្ថុ សំពៀតឥណទាន ប្រាក់បញ្ញើដែលប្រមូលបានព្រមទាំងបណ្តាញសាខា។

**ប្រការ ២**.-

រាល់ត្រីមាស ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានៅក្នុងខែចុងក្រោយនៃត្រីមាសនីមួយៗនូវរបាយការណ៍ដូចខាងក្រោម ៖

- របាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណេញ-ខាត
- របាយការណ៍លំអិតតាមប្រភេទប្រាក់បញ្ញើ
- របាយការណ៍លំអិតប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍លំអិតតាមប្រភេទឥណទាន
- របាយការណ៍លំអិតឥណទានតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ស្តីពីចំណាត់ថ្នាក់ឥណទាន និងអនុបាតបំណុល
- របាយការណ៍ស្តីពីបណ្តាញសាខា

**ប្រការ ៣**.-

រៀងរាល់ខែ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា រួមទាំងការគោរពតាមបទប្បញ្ញត្តិក្នុងរយៈពេល១៥ថ្ងៃ នៃចុងខែនីមួយៗនូវរបាយការណ៍ដូចខាងក្រោម ៖

- របាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណេញ-ខាត
- របាយការណ៍ក្រៅតារាងតុល្យការ
- របាយការណ៍លំអិតតាមប្រភេទប្រាក់បញ្ញើ
- របាយការណ៍លំអិតប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍លំអិតតាមប្រភេទឥណទាន
- របាយការណ៍លំអិតឥណទានតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ស្តីពីចំណាត់ថ្នាក់ឥណទាន សំវិធានធន និងអនុបាតបំណុល
- តារាងឥណទានចំពោះសម្ព័ន្ធញាតិ
- តារាងហានិភ័យធំៗ

- ការគណនាអនុបាតគ្រប់គ្រាន់នៃដើមទុន
- ការគណនាអនុបាតសាច់ប្រាក់ងាយស្រួល។

**ប្រការ ៤**.-

នៅចុងត្រីមាសនីមួយៗគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ត្រូវផ្ញើរបាយការណ៍ស្តីពីការវិវត្តន៍នៃបណ្តាញសាខារបស់ខ្លួន។

**ប្រការ ៥**.-

រៀងរាល់ឆ្នាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវរៀបចំរបាយការណ៍ផ្ញើមកធនាគារជាតិនៃកម្ពុជាឱ្យបានមុនថ្ងៃទី៣០ ខែមេសា នៃឆ្នាំបន្ទាប់ ដូចខាងក្រោម ៖

- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈគ្រប់គ្រង
- ស្ថិតិបុគ្គលិក និងបៀវត្សរ៍
- អង្គការលេខចុងក្រោយ ដោយមាននាម គោត្តនាម និងឋានៈរបស់និយោជិតកំពុងបម្រើការ។

**ប្រការ ៦**.-

របាយការណ៍ទាំងអស់ ត្រូវរៀបចំស្របតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៧**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឬគ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៨**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជានិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៦-២១២ ប្រ.ក

# ប្រកាស
# ស្តីពី
# កាលបរិច្ឆេទផ្ញើរបាយការណ៍ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្ញើរាល់របាយការណ៍ប្រចាំគ្រាមកធនាគារជាតិនៃកម្ពុជាតាមកាលបរិច្ឆេទដូចបានកំណត់ខាងក្រោម :

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមករៀងរាល់ពេលព្រឹក នៅថ្ងៃធ្វើការបន្ទាប់
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវផ្ញើមករៀងរាល់ថ្ងៃអង្គារ៍ នៃសប្តាហ៍បន្ទាប់
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់
- របាយការណ៍ប្រចាំឆ្នាំ (របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យដោយសវនករគណនីឯករាជ្យ) ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមេសា នៃឆ្នាំបន្ទាប់
- របាយការណ៍ប្រាក់បម្រុងកាតព្វកិច្ច ត្រូវផ្ញើមកតាមកាលបរិច្ឆេទនៃប្រតិទិនដែលធនាគារជាតិនៃកម្ពុជាបានកំណត់ និងចែកជូនតាមឆ្នាំនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំបន្ទាប់។

**ប្រការ ២**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវឆ្លើយតបរាល់លិខិតបទដ្ឋានតាមកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជា កំណត់ឱ្យឆ្លើយនិងអនុវត្ត។

**ប្រការ ៣**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យរាយការណ៍នៅថ្ងៃធ្វើការបន្ទាប់ក្នុងករណីកាលបរិច្ឆេទដែលបានកំណត់ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើត្រូវចំថ្ងៃឈប់សម្រាក ឬថ្ងៃបុណ្យជាតិ។

**ប្រការ ៤**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនបានអនុវត្តតាមប្រការ ១ និងប្រការ ២ ខាងលើត្រូវរងពិន័យតាមការកំណត់ដូចខាងក្រោម៖

ក- ចំពោះរបាយការណ៍:

| <u>ចំនួនថ្ងៃដែលយឺតយ៉ាវ</u> | <u>ចំនួនទឹកប្រាក់និងរូបភាពពិន័យ</u> |
|---|---|
| - ចាប់ពី ១ ដល់ ៥ថ្ងៃ | ៥០.០០០ រៀល ក្នុង១ថ្ងៃ |
| - ចាប់ពី ៦ ដល់ ១០ថ្ងៃ | ៣០០.០០០ រៀល ក្នុង១ថ្ងៃ |
| - ចាប់ពី ១១ ដល់ ១៥ថ្ងៃ | ៧០០.០០០ រៀល ក្នុង១ថ្ងៃ |

ចាប់ពី១៦ថ្ងៃឡើងទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ។

ខ-ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៈ

| ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់និងរូបភាពពិន័យ |
|---|---|
| - ចាប់ពី ១ ដល់ ៥ថ្ងៃ | ៥០.០០០ រៀល ក្នុង១ថ្ងៃ |
| - ចាប់ពី ៦ ដល់ ១០ថ្ងៃ | ៣០០.០០០ រៀល ក្នុង១ថ្ងៃ |

ចាប់ពី១១ថ្ងៃឡើងទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និង មានការផ្សព្វផ្សាយជាសាធារណៈ។

**ប្រការ ៥**.-

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧.០២-២០៣ ប្រ.ក

# ប្រកាស
# ស្តីពី
# នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់
# ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៥-២១២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្ម លើប្រកាសស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១**.-

កំណត់នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថាគ្រឹះស្ថានហិរញ្ញវត្ថុ ដោយបង្កើតជាមុននូវបទដ្ឋានសម្រាប់ការអនុវត្តន៍របស់គ្រឹះស្ថានហិរញ្ញវត្ថុ និងដើម្បីអនុវត្តការត្រួតពិនិត្យប្រកបដោយការឯកភាព និងភាពត្រឹមត្រូវ។

**ប្រការ ២**.-

១. "សកម្មភាពកែតម្រូវបន្ទាន់" គឺជាទណ្ឌកម្មខាងវិន័យ និងការដាក់កំហិតជាផ្លូវការ សម្រាប់អនុវត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២. "អនុបាតសាធនភាព" គឺជាអនុបាតដែលត្រូវបានគណនាតាមប្រកាសលេខ ធ៧-០០-៤៦ ប្រក ស្តីពីអនុបាតសាធនភាពរបស់ធនាគារ។

៣. "ផែនការស្តារដើមទុន "គឺជាផែនការផ្លូវការចុះហត្ថលេខាដោយក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានហិរញ្ញវត្ថុហើយត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា។ ផែនការនេះត្រូវចែងលំអិតពីសកម្មភាពយុទ្ធសាស្ត្រ និងការសន្យាដែលក្រុមប្រឹក្សាភិបាលត្រូវអនុវត្ត ដើម្បីសម្រេចឱ្យបានដើមទុនគ្រប់គ្រាន់តាមអនុបាតសាធនភាព។ ផែនការនេះត្រូវមានចែងផងដែរនូវគោលដៅហិរញ្ញវត្ថុជាតួលេខ និងកាលវិភាគដើម្បីសម្រេចឱ្យបាននូវគោលដៅនោះ។

៤. "អភិបាលបណ្តោះអាសន្ន" គឺជាបុគ្គលដែលបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ស្របតាមមាត្រា ៥៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងដឹកនាំ និងជាតំណាងឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ។ បុគ្គលដែលបានតែងតាំងមានកាតព្វកិច្ចត្រូវវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងគ្រប់គ្រងសកម្មភាពបច្ចុប្បន្នដើម្បីការពារឱ្យបាននូវសាធនភាពរបស់អង្គភាពចំណុះច្បាប់ និងរក្សាសិទ្ធិអ្នកផ្ញើប្រាក់ និងឥណទាយក។

៥. "ការប្រជុំអំពីដើមទុន" គឺជាការប្រជុំផ្លូវការរៀបចំដោយធនាគារជាតិនៃកម្ពុជា ដើម្បីជូនដំណឹងដល់នាយកនៃគ្រឹះស្ថានហិរញ្ញវត្ថុអំពីកង្វះខាតដើមទុនធ្ងន់ធ្ងរនៅគ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន និងអំពីកាលវិភាគជាក់លាក់សម្រាប់បង្កើនដើមទុន។

**ប្រការ ៣**.-

(ធ្វើវិសោធនកម្មដោយប្រកាស ធ៧-០៥-២១២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥)

តាមនីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបែងចែកជាប្រភេទដោយផ្អែកលើអនុបាតសាធនភាពរបស់ខ្លួនដូចបានកំណត់ក្នុងប្រកាសវិសោធនកម្មស្តីពីអនុបាតសាធនភាព។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ថា :

ក. មានដើមទុនល្អប្រសើរ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស២០ភាគរយ

ខ. មានដើមទុនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស១៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម២០ភាគរយ

គ. មានដើមទុនមិនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស១០ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ១៥ភាគរយ

ឃ. ខ្វះដើមទុនច្រើននៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ១០ភាគរយ

ង. ខ្វះដើមទុនធ្ងន់ធ្ងរ នៅពេលអនុបាតសាធនភាពរបស់ខ្លួននៅក្រោម៥ភាគរយ។

**ប្រការ ៤**.-

នៅពេលចាប់ផ្តើមមានដើមទុនមិនគ្រប់គ្រាន់ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានកាតព្វកិច្ចរៀបចំ និងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជា ឱ្យបានក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលដើមទុនមានមិនគ្រប់គ្រាន់។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងដល់គ្រឹះស្ថានហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ពីការយល់ព្រមទទួលយកបានផែនការស្តារដើមទុនក្នុងរយៈពេល៣០ថ្ងៃគិតពីថ្ងៃទទួល ឬពីការយឺតយ៉ាវ និងមូលហេតុនៃការយឺតយ៉ាវ។

**ប្រការ ៥**.-

ផែនការស្តារដើមទុនដែលអាចទទួលយកបាន ត្រូវបង្ហាញឱ្យឃើញពីលទ្ធភាពអនុវត្តបានការស្តារដើមទុន និងត្រូវមាន ៖

ក. តារាងតុល្យការនិងថវិកាបច្ចុប្បន្ន គំរោងថវិការយៈកាលវែង ផែនការជាយុទ្ធសាស្ត្រ ការវិភាគស្ថានភាពទីផ្សារដោយផ្អែកលើការសន្មតប្រាកដនិយម និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

ខ. មធ្យោបាយសម្រាប់អនុវត្តការស្តារដើមទុន ត្រូវរៀបរាប់ផងដែរអំពី ៖

- ជំហានដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវអនុវត្តសំដៅបង្កើនដើមទុនឱ្យបានគ្រប់គ្រាន់ឡើងវិញ
- កំរិតនៃដើមទុនដែលត្រូវសំរេចឱ្យបានរៀងរាល់ត្រីមាសនៃឆ្នាំផែនការនិមួយៗ
- ប្រភេទនិងកំរិតនៃសកម្មភាពដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវប្រតិបត្តិ
- ព័ត៌មានដទៃទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

ក្រៅពីការរៀបចំនិងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជា ភាគទុនិកមានឥទ្ធិពលត្រូវធានាជាលាយលក្ខណ៍អក្សរថាគ្រឹះស្ថានហិរញ្ញវត្ថុនោះនឹងបំពេញកាតព្វកិច្ចក្នុងការអនុវត្តន៍ផែនការស្តារដើមទុន។ ការធានានេះត្រូវមានរៀបរាប់អំពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគទុនិកមានឥទ្ធិពលក្នុងការអនុវត្តន៍ផែនការស្តារដើមទុន។ ក្រៅពីនេះ ការធានាក៏ត្រូវមានការសន្យាថាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនឹង ៖

ក. ចាត់វិធានការណ៍ដែលតម្រូវដោយផែនការស្តារដើមទុន

ខ. ធានាជ្រើសរើសអ្នកគ្រប់គ្រងថ្មីមានសមត្ថភាព

គ. រឹតត្បិតប្រតិបត្តិការរវាងគ្រឹះស្ថានហិរញ្ញវត្ថុជាមួយបុគ្គលដែលជាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនោះ

ឃ. បញ្ឈប់សកម្មភាពណាដែលមានហានិភ័យ ឬពុំមានលក្ខណៈសមស្រប។

អាស្រ័យទៅលើក្រុមហ៊ុនដែលពាក់ព័ន្ធ ការធានាត្រូវមានប័ណ្ណសងតាមបញ្ជា ការដាក់បញ្ចាំទ្រព្យសម្បត្តិ ការអះអាងដ៏សមស្របពីស្មាក្តីក្រុមហ៊ុន សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងសកម្មភាពត្រួតពិនិត្យផ្សេងទៀតដែលធានាការអនុវត្តន៍។

**ប្រការ ៧**.-

គ្រឹះស្ថានហិរញ្ញវត្ថុមានដើមទុនមិនគ្រប់គ្រាន់ដែលមិនបានដាក់ជូន ឬមិនបានអនុវត្តផែនការស្តារដើមទុនដែលអាចទទួលយកបាន និងគ្រឹះស្ថានហិរញ្ញវត្ថុដែលខ្វះដើមទុនច្រើនត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចខាងក្រោមនេះ ៖

ក. ត្រូវមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា មុនពេលបើកប្រាក់រង្វាន់ ឬមុនពេលបង្កើនប្រាក់កំរៃជូនដល់អ្នកគ្រប់គ្រងជាន់ខ្ពស់

ខ. ត្រូវបញ្ជាឱ្យបំពេញដើមទុនឡើងវិញ

គ. ត្រូវមានការដាក់កំហិតលើប្រតិបត្តិការជាមួយបុគ្គសម្ព័ន្ធ

ឃ. ត្រូវមានការដាក់កំហិតលើអត្រាការប្រាក់ចំពោះប្រាក់បញ្ញើ។

វិធានការប្រកបដោយឆន្ទានុសិទ្ធិផ្សេងទៀត ក៏អាចសំរេចដោយឯកច្ឆន្ទពីធនាគារជាតិនៃកម្ពុជា

ក. តម្រូវឱ្យរឹតត្បិតមិនឱ្យមានកំណើនទ្រព្យសកម្ម ឬតម្រូវឱ្យកាត់បន្ថយទ្រព្យសកម្មសរុប

ខ. តម្រូវឱ្យរឹតត្បិតសកម្មភាពអាជីវកម្ម

គ. តម្រូវឱ្យលាលែងពីតំណែងនាយកប្រតិបត្តិមួយ ឬច្រើន

ឃ. បញ្ជាឱ្យជួលអ្នកគ្រប់គ្រងជាន់ខ្ពស់ថ្មីដែលមានគុណវុឌ្ឍិគ្រប់គ្រាន់

ង. បញ្ជាឱ្យបញ្ឈប់ការទទួលប្រាក់បញ្ញើពីធនាគារទំនាក់ទំនង

ច. បញ្ជាឱ្យដកខ្លួនចេញពីបុគ្គសម្ព័ន្ធ ដែលបណ្តាលឱ្យមានហានិភ័យខ្ពស់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ

ឆ. តែងតាំងអភិបាលបណ្តោះអាសន្ន។

**ប្រការ ៨**.-

នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានដឹងថាខ្វះដើមទុនធ្ងន់ធ្ងរ ត្រូវកោះប្រជុំអំពីដើមទុន។

គ្រឹះស្ថានហិរញ្ញវត្ថុដែលខ្វះដើមទុនធ្ងន់ធ្ងរមិនអាចធ្វើសកម្មភាពដូចខាងក្រោមបានឡើយ ៖

ក. លក់ទ្រព្យសកម្មយ៉ាងច្រើន ឬបដិសេធការធានារបស់អតិថិជន

ខ. ផ្តល់ឥណទានថ្មីចំពោះអតិថិជន

គ. កែប្រែវិធីគណនេយ្យ លើកលែងតែវិធីនេះមិនស្របតាមច្បាប់

ឃ. បើកប្រាក់កំរៃ ឬ ប្រាក់រង្វាន់

ង. ផ្តល់ការប្រាក់លើទ្រព្យអកម្មខ្ពស់ជាងអត្រាទីផ្សារ។

អភិបាលបណ្តោះអាសន្នត្រូវបានតែងតាំងក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីបានជូនដំណឹងពីការប្រជុំអំពីដើមទុន។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៧-១៣៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណង ដើម្បីបង្ការហានិភ័យនៃការប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២**.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

- "ហានិភ័យនៃការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ខាងហិរញ្ញវត្ថុ ដែលកើតឡើងពីចលនាឡើងចុះនៃអត្រាប្តូរប្រាក់។
- "ហានិភ័យនៃការទូទាត់ការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយទូទាត់សងនូវរូបិយវត្ថុដែលខ្លួនបានលក់ តែអាចមិនទទួលមកវិញនូវរូបិយវត្ថុដែលខ្លួនបានទិញពីប្រតិបត្តិការប្តូរប្រាក់។
- "ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណណាមួយ" ជាសមតុល្យសុទ្ធនៃរាល់ទ្រព្យសកម្ម ទ្រព្យអកម្ម និងខ្ទង់ក្រៅតារាងតុល្យការនៃរូបិយប័ណ្ណនោះ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណយិកគឺជាស្ថានភាពវែង ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណទាយី គឺជាស្ថានភាពខ្លី។

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពមួយដើម្បីកំណត់វាស់វែង តាមដាន និងត្រួតពិនិត្យនូវទំហំនិងប្រភពហានិភ័យនៃការប្តូរប្រាក់ និងហានិភ័យនៃការទូទាត់ការប្តូរប្រាក់ក្នុងកំឡុងពេលនៃថ្ងៃជួញដូរនិងនៅពេលបិទបញ្ជីប្រចាំថ្ងៃ។ លក្ខណៈនិងទំហំរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះត្រូវស្របតាមទំហំនៃប្រតិបត្តិការប្តូរប្រាក់ និងស្ថានភាពប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ។

**ប្រការ ៤**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាគ្រប់ពេល នូវស្ថានភាពចំហសុទ្ធជារូបិយប័ណ្ណណាមួយ ឬសរុបជារូបិយប័ណ្ណទាំងអស់ទោះក្នុងស្ថានភាពវែងឬខ្លីក៏ដោយមិនឱ្យលើសពី ២០ភាគរយនៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះឡើយ។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ប្រចាំខែ ទាំងហាដកូពី (Hard copy) និងសូហ្វកូពី (Soft copy) ស្តីពីស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណឱ្យបានទៀងទាត់តាមគំរូក្នុង ឧបសម្ព័ន្ធភ្ជាប់ជាមួយ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវធានាផងដែរថាស្ថានភាពរូបិយប័ណ្ណត្រូវបានរាយការណ៍ត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

បទបញ្ជាលេខធ៧-៩៥-០១ បបជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ធនាគារពាណិជ្ជនិងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

## តារាង ឧបសម្ព័ន្ធ

## ការគណនាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ

**ឈ្មោះធនាគារ.............**

Bank's Name

## Net Open Position

អត្រាប្តូរប្រាក់ ១ដុល្លារ (Exchange Rate 1USD) =

នាកាលបរិច្ឆេទ....................................

មូលនិធិផ្ទាល់សុទ្ធគិតជាលានរៀល (Bank's Net Worth)

As at………………………..

គិតជាលានរៀល In Million KHR

| រូបិយប័ណ្ណ Currency | ខ្ទង់ផ្សេងៗបន្ទាប់ពីដកចេញសំវិធានធន Elements after deduction of affected provision | | | | ស្ថានភាពរូបិយប័ណ្ណចំហសុទ្ធ Net Open Position | រូបិយប័ណ្ណចំហសុទ្ធ/ មូលនិធិផ្ទាល់សុទ្ធ (%) Net Open Position / Net Worth (%) | កំរិតកំណត់ (%) Limit (%) | ភាពលើស (១) Excess (1) |
|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | | | |
| | ទ្រព្យសកម្ម Assets | ទ្រព្យអកម្ម និងមូលធន Liabilities and Capital | រូបិយប័ណ្ណត្រូវទទួល Currencies Receivable | រូបិយប័ណ្ណត្រូវចំណាយ Currencies Payable | + (វែង) ឬ - (ខ្លី) +(Long) or -(Short) | | | |
| | + | - | ខ្ទង់ក្រៅតារាងតុល្យការ + Off Balance Sheet + | ខ្ទង់ក្រៅតារាងតុល្យការ - Off Balance Sheet - | (១ + ២ + ៣ + ៤) (1+2+3+4) | | | |
| USD | | | | | | | 20% | |
| KHR | | | | | | | 20% | |
| EUR | | | | | | | 20% | |
| SGD | | | | | | | 20% | |
| HKD | | | | | | | 20% | |
| THB | | | | | | | 20% | |
| JPY | | | | | | | 20% | |
| VND | | | | | | | 20% | |
| srb (Grand Total) | | | | | | | | |
| | (២) | (៣) | | | (៤) | | | |

(១) នៅពេលដែលមានភាពលើស គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវពន្យល់ជាលាយលក្ខណ៍អក្សរពីមូលហេតុនិងវិធានការកែសំរួល

(1) Where there is an excess, the bank shall submit a written explanation of the origin of each excess, and the measures taken to remedy the situation.

(២) ចំនួនសរុបទ្រព្យសកម្មក្នុងតារាងតុល្យការ

(2) Total equal to total assets on the balance sheet

(៣) ចំនួនសរុបទ្រព្យអកម្ម និងមូលធនក្នុងតារាងតុល្យការ

(3) Total equal to total liabilities on the balance sheet

(៤) ចំនួនសរុប = សូន្យ

(4) Total = Zero

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

| នាយក Bank's Manager | អ្នកធ្វើតារាង Prepared By |
|---|---|

ធ៧-០១១-២៤៣ ប្រ.ក

# ប្រកាស
## ស្តីពី
## តម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ។

**ប្រការ ២**.-

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឲ្យភាន់ច្រឡំ និងត្រូវធានាថាអតិថិជនបានទទួលព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ។

**ប្រការ ៣**.-

អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ នៅមុនពេល ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌ អត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤**.-

អតិថិជនត្រូវទទួលបានព័ត៌មានជាមុន អំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

**ប្រការ ៥**.-

ព័ត៌មានអតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់ ហើយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនអតិថិជននូវប្រព័ន្ធធនាគារស្មួល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ការរក្សាព័ត៌មានអតិថិជនជាសម្ងាត់មិនត្រូវអនុវត្តចំពោះការផ្តល់ព័ត៌មានអតិថិជនដល់ប្រព័ន្ធព័ត៌មានឥណទាននោះទេ។

**ប្រការ ៦**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

*ឧបសម្ព័ន្ធ*

# តារាងព័ត៌មានសម្រាប់អតិថិជន

តារាងនេះសម្រាប់ផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ តារាងនេះកំណត់ចេញនូវថ្លៃដើមពេលបច្ចុប្បន្ន និងកម្រៃផ្សេងៗ សម្រាប់ឥណទានដែលទទួលបាន ហើយធនាគារអាចកែប្រែថ្លៃដើម និងកម្រៃទាំងនេះ ក្នុងករណីចាំបាច់។ សូមមេត្តាកត់សំគាល់ថាការផ្តល់នូវតារាងនេះមិនត្រូវចាត់ទុកថាជាការផ្តល់ឥណទានដល់អតិថិជនដោយធនាគារនោះទេ។

ឈ្មោះធនាគារ/និមិត្តសញ្ញា ឈ្មោះអ្នកសួរព័ត៌មាន ____________________

១. សាខា ____________________ ប្រភេទនៃខ្ចង់ឥណទាន ____________________

**ចំនួនឥណទាន និងការប្រាក់/កម្រៃផ្សេងៗរបស់ធនាគារ**

(គិតជាប្រាក់រៀល)

២. ចំនួនស្នើសុំ(ចំនួនប្រាក់ដើម) __________

៣. (ដក: ចំនួនត្រូវទូទាត់ក្នុងគ្រាទី១/ការប្រាក់បានបង់មុន) __________

៤. ចំនួនសុទ្ធដែលអតិថិជនបានទទួល __________

៥. អត្រាដែលស្នើសុំ ________ %ក្នុង១ឆ្នាំ

៦. អត្រាការប្រាក់មានប្រសិទ្ធភាព ________ %ក្នុង១ឆ្នាំ

៧. ការទូទាត់ប្រចាំខែ __________

៨. ចំនួនដងដែលត្រូវទូទាត់សង __________

៩. ការប្រាក់សរុប __________

១០.កម្រៃធ្វើប្រតិបត្តិការ __________

១១.កម្រៃផ្សេងៗរបស់ធនាគារ (សូមបញ្ជាក់ ប្រសិនបើមាន)

________________________________________ __________

១២. កម្រៃផ្សេងៗសរុប (ជួរទី១០ + ជួរទី១១) __________

១៣. ការប្រាក់សរុបបូកកម្រៃផ្សេងៗសរុប (ជួរទី៩ + ជួរទី១២) __________

១៤. សរុបចំនួននៅជំពាក់ (ជួរទី២ + (៣) ឬជួរទី៤ + ជួរទី១៣) __________

១៥. កាលបរិច្ឆេទនៃការចាប់ផ្តើមទូទាត់សង ______________________

**<u>កម្រៃបន្ថែម</u>**

ធនាគារនឹងគិតកម្រៃសម្រាប់

| | ការទូទាត់សងដោយផ្នែក | ការទូទាត់សងពេញលេញ |
|---|---|---|
| **(ក) ការទូទាត់សងឥណទានមុនពេលកំណត់** | | |
| ១៦.ប្រសិនបើសងក្នុងកំឡុងពេល | __________ឆ្នាំ | __________ឆ្នាំ |
| ១៧.ចំនួននៃការទូទាត់សងអប្បបរមាគឺ | __________ | |
| ១៨.កម្រៃលើការទូទាត់សងមុនពេលកំណត់ | __________ | __________ |
| ១៩.កម្រៃធ្វើប្រតិបត្តិការ | __________ | __________ |
| ២០.កំឡុងពេលជូនដំណឹងដែលតម្រូវ | __________ | __________ |

**(ខ) ការទូទាត់យឺតយ៉ាវតាមគ្រានិមួយៗ**

២១.ការប្រាក់ដែលត្រូវគិតគឺ ______%ក្នុង១ឆ្នាំ(សម្រាប់ចំនួនដែលជំពាក់)

២២.កម្រៃធ្វើប្រតិបត្តិការ __________

២៣.កម្រៃផ្សេងៗ ______________________

**<u>កម្រៃសម្រាប់គតិយជន</u>**

២៤. ព័ត៌មានខាងលើ មិនរាប់បញ្ចូលកម្រៃសម្រាប់គតិយជន មានដូចជាតែមប្រ៊ី កម្រៃផ្នែកច្បាប់ កម្រៃលើការវាយតំលៃបុព្វលាភ ធានារ៉ាប់រង។ល។ សូមមេត្តាត្រួតពិនិត្យជាមួយគូរភាគីខាងលើស្តីពីកម្រៃទាំងឡាយ។

**គោលនយោបាយធានារ៉ាប់រងដែលទាមទារឲ្យមាន**

---

មន្ត្រីដែលមានវត្តមាន ______________________ ហត្ថលេខា ______________________

កាលបរិច្ឆេទ ______________________

ធ៧-០៤-០៣៨ ប្រ.ក

# ប្រកាស
# ស្តីពី
# ភាគព្វកិច្ចអនុវត្តតាមខ្លឹមសារនិងការពិត

**ប្រការ ១**.-

គណនេយ្យកម្មរបស់ធនាគារត្រូវបង្ហាញពីទស្សនៈពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ និងកាតព្វកិច្ចបើកចំហព័ត៌មានស្របទៅតាមគោលការណ៍គណនេយ្យនៃស្តង់ដារគណនេយ្យអន្តរជាតិ និងស្តង់ដារគណនេយ្យកម្ពុជា។ វិធានទូទៅនេះត្រូវតែបានអនុវត្តជាពិសេសលើពីរចំណុចគឺ : គោលការណ៍នៃខ្លឹមសារមានទម្ងន់លើទម្រង់ និងការទទួលស្គាល់កំរៃការប្រាក់លើមូលដ្ឋានបង្គរ។

**ប្រការ ២**.-

ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងប្រតិបត្តិការដោយមិនគ្រាន់តែបំពេញឱ្យត្រឹមត្រូវតាមគោលការណ៍នៃទម្រង់ប៉ុណ្ណោះទេ មានន័យថាការកត់ត្រាគណនេយ្យត្រូវផ្តល់សារសំខាន់លើខ្លឹមសារជាជាងលើទម្រង់។

**ប្រការ ៣**.-

ជាទូទៅធនាគារមិនត្រូវប្រើប្រាស់គណនេយ្យសម្រាប់លាក់បាំងប្រតិបត្តិការខ្លះដោយគ្រាន់តែប្រើប្រាស់ទម្រង់ឱ្យស្របតាមច្បាប់និងប្រកាសប៉ុណ្ណោះទេ ចំណែកឯខ្លឹមសារនៃប្រតិបត្តិការបែរជាអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងប្រកាសទៅវិញ។

ជាក់ស្តែងប្រតិបត្តិការដែលប៉ះពាល់ដល់គោលការណ៍ខ្លឹមសារមានទម្ងន់លើទម្រង់ត្រូវបានអនុវត្តតាមរូបភាពជាកិច្ចសន្យាជួល ឬទិញអចលនទ្រព្យដោយទូទាត់មុនរយៈពេលវែង ប៉ុន្តែតាមខ្លឹមសារមានន័យថាម្ចាស់ធនាគារបានដកដើមទុនរបស់ខ្លួនចេញទៅវិញ។

**ប្រការ ៤**.-

ក្នុងករណីដែលធនាគារជាតិនៃកម្ពុជារកឃើញប្រតិបត្តិការណាមួយដែលបញ្ជិកាគណនេយ្យមិនបានឆ្លុះបញ្ចាំងពីគោលការណ៍ខ្លឹមសារសេដ្ឋកិច្ច ក៏ប៉ុន្តែដោយគ្រាន់តែតម្រូវតាមគោលការណ៍ទម្រង់ឬកាតព្វកិច្ចនោះ ប្រតិបត្តិការនេះនឹងត្រូវបានតម្រូវឱ្យរៀបចំចុះបញ្ជិកាគណនេយ្យឡើងវិញតាមខ្លឹមសារពិត។

**ប្រការ ៥**.-

ក្នុងករណីភាគទុនិកដកដើមទុនដោយផ្អែកលើគោលការណ៍ទម្រង់ដើម្បីបង្កើនប្រាក់ចំណេញ ឬទ្រព្យសកម្ម ឬកាត់បន្ថយការខាតបង់ ឬទ្រព្យអកម្ម ចំនួនប្រាក់នៃប្រតិបត្តិការទាំងនោះនឹងត្រូវបានដកចេញពីដើមទុនផ្ទាល់និងមូលនិធិផ្ទាល់សុទ្ធ ហើយបើចាំបាច់ធនាគារត្រូវតែបង់បំពេញដើមទុនឡើងវិញ។

**ប្រការ ៦**.-

ដោយមិនគិតដល់ប្រការ ៥ ធនាគារជាតិនៃកម្ពុជាអាចដាក់ទណ្ឌកម្មតាមមាត្រាទី ៣៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា និងមាត្រាទី ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

គណនេយ្យកម្មចំណាយនិងចំណូលរបស់ធនាគារត្រូវតែអនុវត្តស្របតាមស្តង់ដារគណនេយ្យកម្ពុជា ដែលដូចគ្នាទៅនឹងស្តង់ដារគណនេយ្យអន្តរជាតិ។

គណនេយ្យកម្មការប្រាក់ត្រូវបានកំណត់ដូចតទៅ :

- ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលផលប្រយោជន៍សេដ្ឋកិច្ចទៅអនាគតរំពឹងថាអាចហូរចូលទៅក្នុងសហគ្រាស ហើយការរំពឹងទុកពីផលប្រយោជន៍ទាំងនេះត្រូវបានវាស់ស្ទង់ថាអាចជឿទុកចិត្តបាន។
- ការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានសមាមាត្រពេលវេលាដែលត្រូវយកមកគិតគូរពីប្រសិទ្ធភាពនៃផលចំណូលពីទ្រព្យសកម្ម។
- ការទទួលស្គាល់ចំណូល និងចំណាយការប្រាក់មានសារសំខាន់ក្នុងការកំណត់លទ្ធភាពចំណេញរបស់ធនាគារ។
- ចំណូលការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានបង្គរ លើកលែងតែក្នុងករណីឥណទានមិនដំណើរការ និងឥណទានមិនបានរៀបចំឡើងវិញ។

**ប្រការ ៨**.-

ដើម្បីផ្តល់នូវព័ត៌មានប្រកបដោយគុណភាពកំរិតខ្ពស់ ធនាគារត្រូវកត់ត្រាជាប្រចាំថ្ងៃនូវ :

- ការប្រាក់ដែលបានសងនិងបានទទួលពីអតិថិជន ធនាគារ អ្នកដំពាក់បំណុល និងឥណទាយកដទៃទៀត។
- ការរំលស់អចលនទ្រព្យនិងទ្រព្យសកម្មផ្សេងៗទៀត ប្រសិនបើចាំបាច់។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៤

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៥-០៥៤ ប្រ.ក

# ប្រកាស
# ស្តីពី
# គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន

**ប្រការ ១.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានស្របតាមគោលនយោបាយឥណទានត្រឹមត្រូវ និងប្រុងប្រយ័ត្នការប្រតិបត្តិជាទូទៅនិងនីតិវិធីក្នុងការផ្តល់ឥណទានដែលត្រូវតែបានអនុម័តនិងពិនិត្យឡើងវិញដោយត្រឹមត្រូវពីគណៈគ្រប់គ្រង និង/ឬ ក្រុមប្រឹក្សាភិបាល។

**ប្រការ ២.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើត ៖

១. គោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរសម្រាប់ដាក់ចេញនូវគោលនយោបាយឥណទាននីតិវិធីនិងកំណត់សិទ្ធិអំណាចឱ្យខ្ចីរបស់មន្ត្រីឥណទាន និង/ឬ គណៈកម្មការឥណទាន និងក្រុមប្រឹក្សាភិបាលហើយគោលនយោបាយនិងនីតិវិធីទាំងនោះត្រូវតែបានបញ្ជូនទៅបុគ្គលិកដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ឥណទាន។

២. សំណុំឯកសារឥណទានរបស់អ្នកសុំខ្ចីទាំងអស់ត្រូវតែមានព័ត៌មានថ្មីៗគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។

**ប្រការ ៣.-**

គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចឱ្យខ្ចីត្រូវមានការវិភាគឥណទាន ដំណើរការអនុម័តឥណទាន នីតិវិធីពិនិត្យឥណទានឡើងវិញតាមគ្រា កំរិតកំណត់អនុម័តឥណទានរបស់មន្ត្រី និង/ឬ គណៈកម្មការឥណទាន វត្ថុធានា និងព័ត៌មានចាំបាច់ផ្សេងៗទៀត។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៥-០២ ស.រ.ណ.ន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាពនៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

សារាចរណែនាំនេះ ជាការណែនាំពីការចាំបាច់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានប្រព័ន្ធត្រួតពិនិត្យតម្លាភាពនៅក្នុងប្រព័ន្ធគណនេយ្យ ដើម្បីអាចលើកកំពស់ភាពត្រឹមត្រូវនៃការកត់ត្រាបញ្ជីគណនេយ្យ ហើយអាចរំលេច និងកែតម្រូវកំហុសឆ្គងទាំងឡាយបានឆាប់រហ័ស។ ប្រព័ន្ធត្រួតពិនិត្យតម្លាភាពជាចំណែកមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងមូលរបស់ធនាគារ និងកាត់បន្ថយហានិភ័យប្រតិបត្តិការជាអប្បបរមានៅក្នុងប្រតិបត្តិការធនាគារ។ ជាស្តង់ដារអប្បបរមា ធនាគារនីមួយៗត្រូវធានាថាចំណុចដូចខាងក្រោមនេះ មានចំណែកក្នុងប្រព័ន្ធត្រួតពិនិត្យតម្លាភាព:

**ការបែងចែកតួនាទីរបស់បុគ្គលិក**

គ្រប់ធនាគារ មិនត្រូវអនុញ្ញាតឱ្យបុគ្គលិកតែម្នាក់អនុវត្តគ្រប់ផ្នែកទាំងអស់នៃប្រតិបត្តិការធនាគារទេ។ ឧទាហរណ៍ បុគ្គលិកតែម្នាក់មិនត្រូវផ្តល់អនុសាសន៍ អនុម័ត វិភាគ ចំណាយប្រាក់ កត់ត្រាបញ្ជី និងត្រួតពិនិត្យវត្ថុធានានៅក្នុងប្រតិបត្តិការឥណទានទេ។ បុគ្គលិកទទួលខុសត្រូវប្រតិបត្តិការកំព្យូទ័រមិនត្រូវឱ្យបង្កើតកម្មវិធីផង ឬកែប្រែកម្មវិធីផងទេ។ បេឡាធិការដែលជាអ្នកទទួលប្រាក់បញ្ញើសម្រាប់បញ្ចូលក្នុងគណនីអតិថិជនមិនត្រូវឱ្យទទួលខុសត្រូវចំពោះសៀវភៅធំទេ។ ជាទូទៅមុខងារកត់ត្រារក្សាទុក និងអនុញ្ញាតត្រូវកំណត់ដោយឡែកពីគ្នាសម្រាប់ប្រតិបត្តិការធនាគារនិមួយៗ។

ធនាគារត្រូវជៀសវាងស្ថានភាពទំនាស់ផលប្រយោជន៍ នៅពេលចាត់តាំងភារកិច្ចឱ្យបុគ្គលិកដើម្បីធានាឱ្យមានប្រព័ន្ធតម្លាភាពដ៏ត្រឹមត្រូវ។

**ការកត់ត្រានិងកិច្ចបញ្ជិកាគណនេយ្យ**

ក្នុងករណីមានការចុះបញ្ជីទិន្នានុប្បវត្តិដោយដៃ ការចុះបញ្ជីទាំងនោះត្រូវតែមានការអនុញ្ញាតត្រឹមត្រូវពីមន្ត្រីធនាគារ។ មន្ត្រីធនាគារនេះត្រូវចុះហត្ថលេខាលើសក្ខីប័ត្រគណនេយ្យទុកជាភស្តុតាងនៃការអនុញ្ញាតមុនពេលប្រតិបត្តិការអាចចុះបញ្ជីនៅក្នុងសៀវភៅធំ។ ក្នុងការចុះបញ្ជីកុំព្យូទ័រ ការអនុញ្ញាតជានិច្ចកាលធ្វើឡើងនៅលើអេក្រង់កុំព្យូទ័រដោយផ្ទាល់។ ទោះយ៉ាងណាក៏ដោយ សិទ្ធិប្រើប្រាស់និងអនុញ្ញាតរបស់បុគ្គលិកត្រូវរក្សាទុកនៅក្នុងសំនុំឯកសារកុំព្យូទ័រ ហើយត្រូវតែមានការពិនិត្យឡើងវិញយ៉ាងត្រឹមត្រូវពីសំណាក់គណៈគ្រប់គ្រងក្នុងការបញ្ចូលការអនុញ្ញាតនិងការកែប្រែទិន្នន័យ។

**គណនីនៅស្ងៀម ឬ គ្មានសកម្មភាព**

ធនាគារត្រូវបែងចែកគណនីនៅស្ងៀមនិងគ្មានសកម្មភាពពីគណនីមានសកម្មភាព ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យគណនីទាំងនោះ។ គណនីមួយត្រូវបានចាត់ទុកថានៅស្ងៀមប្រសិនបើគណនីនេះគ្មានសកម្មភាពលើសពី១២ ខែ។ ធនាគារត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះគណនីចរន្ត និងគណនីសន្សំរបស់អតិថិជនដែលគ្មានសកម្មភាព។ ប្រព័ន្ធត្រួតពិនិត្យតម្លាភាពតម្រូវឱ្យមានការអនុញ្ញាតជាក់លាក់ពីមន្ត្រីជាន់ខ្ពស់ធនាគារក្នុងករណីដែលគណនីមិនមានសកម្មភាពពីមុនមក ស្រាប់តែមានសកម្មភាពឡើងវិញ។

គ្រប់ធនាគារត្រូវផ្ទេរសមតុល្យឥណទានរបស់គណនីអតិថិជន ដែលមិនមានសកម្មភាពរយៈពេល១០ឆ្នាំ ជាប់គ្នាទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអភិបាលកិច្ចដោយអនុលោមទៅតាមមាត្រា៧១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**សមតុល្យប្រចាំខែនៃគណនីសាខា**

រាល់គ្រាកំណត់ណាមួយធនាគារត្រូវផ្ទៀងផ្ទាត់ថាសមតុល្យគណនីសាខា និងការកត់ត្រានៅក្នុងគណនីសាខាស៊ីគ្នាទៅនឹងគណនីមេនិងសៀវភៅធំ។ ការផ្ទៀងផ្ទាត់នេះត្រូវធ្វើឡើងយ៉ាងហោចណាស់មួយដងក្នុងមួយខែ។

**ការរាប់ទ្រព្យសកម្មជាក់ស្តែង**

ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរ ដើម្បីរាប់ទ្រព្យសកម្មជាក់ស្តែងរាល់គ្រាកំណត់ណាមួយឱ្យវាស៊ីទៅនឹងគណនីមេនិងសៀវភៅធំ។ ចំណុចដូចខាងក្រោមបង្ហាញភាពញឹកញាប់អប្បបរមានៃការរាប់ ៖

| ទ្រព្យសកម្មជាក់ស្តែង | ភាពញឹកញាប់ |
|---|---|
| សាច់ប្រាក់នៅក្នុងដៃ | ប្រចាំខែ |
| មូលបត្រ | ប្រចាំខែ |
| វិញ្ញាបនបត្រប្រាក់បញ្ញើ | ប្រចាំខែ |
| វត្ថុធានា | ប្រចាំឆមាស |
| ប័ណ្ណឥណទេយ្យ | ប្រចាំត្រីមាស |
| ប័ណ្ណទូទាត់មានកាលកំណត់ | ប្រចាំត្រីមាស |
| លិខិតឥណទានមិនទាន់ទូទាត់ | ប្រចាំឆមាស |
| ការធានា | ប្រចាំឆមាស |
| ទ្រព្យសម្បត្តិ | ប្រចាំឆមាស |
| អចលនទ្រព្យ | ប្រចាំឆមាស |

**ការផ្ទៀងផ្ទាត់សាច់ប្រាក់ជាមួយធនាគារ**

ធនាគារត្រូវធានាថា ការផ្ទៀងផ្ទាត់សាច់ប្រាក់ត្រូវអនុវត្តចំពោះគ្រប់គណនីប្រាក់បញ្ញើនៅបរទេស (គណនី Nostro) យ៉ាងតិចមួយខែម្តង។ ប្រតិបត្តិការដែលមិនអាចផ្ទៀងផ្ទាត់បាន ត្រូវធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងឈានទៅសន្និដ្ឋានឱ្យបានត្រឹមត្រូវ។ ការផ្ទៀងផ្ទាត់សាច់ប្រាក់ជាមួយធនាគារត្រូវមានការត្រួតពិនិត្យដោយមន្ត្រីធនាគារដែលត្រូវអនុម័តផង។

**គណនីព្យួរទុក**

ប្រតិបត្តិការដែលបានកត់ត្រានៅក្នុងគណនីព្យួរទុកត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ហើយផ្ទេរយ៉ាងត្រឹមត្រូវទៅកាន់លេខគណនីនៃប្លង់គណនីឯកភាព។ ខ្ទង់ព្យួរទុកមិនត្រូវរក្សាទុកឱ្យលើសពី២-៣ថ្ងៃទេ។ គណៈគ្រប់គ្រងធនាគារ ត្រូវលុបចោលខ្ទង់នៃគណនីព្យួរទុកប្រសិនបើមិនអាចរកលេខគណនីណាមួយក្នុងប្លង់គណនីឯកភាពមកដាក់បានទេ។ គណនីនេះ មិនត្រូវយកមកប្រើប្រាស់នៅពេលប្លង់គណនីឯកភាពមានលេខគណនីសម្រាប់កត់ត្រាប្រតិបត្តិការ។

## នីតិវិធីក្នុងការផ្ទុកទិន្នន័យ និងនីតិវិធីប្រមូលទិន្នន័យមកវិញក្នុងករណីមានអន្តរាយ

ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងការផ្ទុកទិន្នន័យនៃកំណត់ត្រាគណនេយ្យ កំណត់ត្រាអតិថិជនចាស និងខ្សែអាត់កុំព្យូទ័រ បញ្ជីវត្ថុធានានិងឯកសារដទៃទៀតដែលមានតម្លៃ។ ក្នុងចំណោមខ្ទង់មានបញ្ហា ដែលត្រូវពិចារណាផ្សេងទៀតដូចជា ភាពញឹកញាប់នៃការផ្ទុកទិន្នន័យ ទីតាំងរក្សាទុកឯកសារ ឧបករណ៍ផ្ទុកឯកសារ និងនីតិវិធី។ ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរស្តីពីការប្រមូលទិន្នន័យមកវិញក្នុងករណីមានអន្តរាយ និងផែនការបន្តអាជីវកម្មឡើងវិញ។

នីតិវិធីក្នុងការផ្ទុកទិន្នន័យនិងនីតិវិធីប្រមូលទិន្នន័យមកវិញក្នុងករណីមានអន្តរាយ ត្រូវមានការសាកល្បងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។ ឯកសារត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ។

## សវនកម្មផ្ទៃក្នុង

គ្រប់ធនាគារត្រូវបង្កើតឱ្យមានផ្នែកសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ទៅកាន់គណៈគ្រប់គ្រងខ្ពស់បំផុត ដែលមានឯករាជ្យភាពពីមុខងារប្រតិបត្តិដើម្បីរក្សាឯករាជ្យភាពនិងប្រសិទ្ធភាព។

គ្រប់ធនាគារត្រូវចងចាំពីប្រកាសលេខ ធ៧-០០-០៤ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ ត្រង់មាត្រាទី ១ ស្តីពីសវនកម្មផ្ទៃក្នុង។

ភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥

**នាយកដ្ឋានត្រួតពិនិត្យ**

ហត្ថលេខៈ **ផាន់ ហួរ គិម វ៉ាដា**

ធ៧-០៨-២១១ ប្រ.ក

# ប្រកាស
# ស្តីពី
# អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងពង្រឹងអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅហៅថា "គ្រឹះស្ថាន" ដោយរៀបចំឱ្យមានរចនាសម្ព័ន្ធគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ រួមមានក្រុមប្រឹក្សាភិបាលឯករាជ្យ និងសកម្ម គណៈប្រតិបត្តិនិងគណៈកម្មការជំនាញ ដែលចាំបាច់ប្រកបដោយគុណវុឌ្ឍិ សមត្ថភាព សុចរិតភាព ដើម្បីដឹកនាំ គ្រប់គ្រងគ្រឹះស្ថានឱ្យមានប្រសិទ្ធភាព។

**ប្រការ ២**.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចតទៅ:

- ក្រុមប្រឹក្សាភិបាល — ជាគណៈគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការគ្រប់គ្រង និងស្ថានភាពរបស់គ្រឹះស្ថាន ក្នុងនាមភាគទុនិក ដូចជាក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលគ្រប់គ្រងដោយច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឬក្រុមប្រឹក្សាត្រួតពិនិត្យដែលមានភារកិច្ចសមមូលនៃក្រុមហ៊ុនដែលមានទម្រង់គតិយុត្តិផ្សេងគ្នា។

-គណៈប្រតិបត្តិ — ជាក្រុមបុគ្គលដែលទទួលខុសត្រូវលើការគ្រប់គ្រងដោយប្រសិទ្ធភាពលើគ្រឹះស្ថានស្របតាមប្រការ ៦ នៃប្រកាសលេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស ឥណទានជនបទ ឬ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

-គណៈកម្មការសវនកម្ម — ជាគណៈកម្មការជំនាញដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាល ត្រូវកំណត់អំពីសមាជិកភាព ភារកិច្ច នីតិវិធី ប្រតិបត្តិ និងលក្ខខណ្ឌដែលក្នុងនោះសវនករ និងបុគ្គលដទៃទៀតរបស់គ្រឹះស្ថាន ត្រូវជាប់ពាក់ព័ន្ធក្នុងការងាររបស់ខ្លួន។

-គណៈកម្មការគ្រប់គ្រងហានិភ័យ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាពភារកិច្ច និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ។

-គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាព ភារកិច្ចនិងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ។

- អ្នកគ្រប់គ្រងជាន់ខ្ពស់ ជាក្រុមប្រតិបត្តិគន្លឹះ ដែលមានភារកិច្ចមើលការខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃរបស់គ្រឹះស្ថាន។

## ជំពូក ២

## ក្រុមប្រឹក្សាភិបាលឯករាជ្យ សកម្ម និងមានគុណវុឌ្ឍិ

**ប្រការ ៣**.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវ ៖

- ឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របមួយដោយធនាគារជាតិនៃកម្ពុជា ដែលជាផ្នែកមួយនៃការផ្តល់អាជ្ញាប័ណ្ណ
- យល់ពីតួនាទីរបស់ខ្លួន រួមទាំងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន
- បើចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដើម្បីរក្សាបានជំនាញរួមគ្នា
- យល់ពីភារកិច្ចរបស់ខ្លួនចំពោះភាគទុនិក ចំពោះគ្រឹះស្ថាន និងចំពោះអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ
- យល់ដឹងអំពីបរិស្ថានច្បាប់ និងបទប្បញ្ញត្តិទាំងមូល ដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើង
- តាមដានស្ថានភាពទីផ្សារបច្ចុប្បន្ន និងយល់ដឹងអំពីបរិស្ថានប្រកួតប្រជែងនៃអាជីវកម្មរបស់គ្រឹះស្ថាន
- មានពេលវេលា និងថាមពលដែលអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤**.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវសកម្មការងារ យ៉ាងហោចណាស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវៈ

- អនុម័តយុទ្ធសាស្ត្រ គោលនយោបាយហានិភ័យ និងនីតិវិធីគ្រប់គ្រងហានិភ័យទាំងនោះ
- រៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឱ្យការពិភាក្សាមានប្រសិទ្ធភាព
- ជ្រើសរើស ត្រួតពិនិត្យ ផ្លាស់ប្តូរនាយកប្រតិបត្តិសំខាន់ៗ
- សាកសួរអ្នកគ្រប់គ្រងជាន់ខ្ពស់
- រៀបចំប្រព័ន្ធរាយការណ៍មួយដែលអាចជួយឱ្យការអនុវត្តកាតព្វកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលមានលក្ខណៈយល់ដឹងបាន និងទាន់ពេល
- ជួបជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ និងសវនករផ្ទៃក្នុងឱ្យបានទៀងទាត់
- វាយតម្លៃការប្រតិបត្តិរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ឱ្យបានទៀងទាត់

- វាយតម្លៃគោលនយោបាយរបស់គ្រឹះស្ថានឱ្យបានទៀងទាត់ទៅលើការអនុវត្ត និងបញ្ហាជាសក្តានុពល ដែលអាចសម្គាល់បាន
- អនុវត្តនូវការវិនិច្ឆ័យសម្រាប់ពេលអនាគត ដើម្បីសម្គាល់នូវបញ្ហាជាសក្តានុពលដែលគ្រឹះស្ថានត្រូវប្រឈម និងធានាថាសកម្មភាពកែតម្រូវសមស្របត្រូវបានអនុវត្តជាបន្ទាន់ បើចាំបាច់

សមាជិកក្រុមប្រឹក្សាភិបាលនឹងត្រូវប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ សមាជិកនោះត្រូវបានដកចេញពីតំណែង ក្នុងករណីបុគ្គលនោះមិនបានចូលរួមអង្គប្រជុំក្រុមប្រឹក្សាភិបាលបីដងជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ។

ក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជាជាបន្ទាន់រាល់ការផ្លាស់ប្តូរកម្មសិទ្ធិភាគហ៊ុន និង/ឬ សិទ្ធិបោះឆ្នោតនៅក្នុងគ្រឹះស្ថាន។ កាតព្វកិច្ចជូនដំណឹងនេះមិនត្រូវធ្វើឡើងចំពោះតែការផ្លាស់ប្តូរការកាន់កាប់ដើមទុនឈានដល់ ៥% ឬ ២០% ឬ នៃសិទ្ធិបោះឆ្នោត ប៉ុន្តែការជូនដំណឹងក៏ត្រូវធ្វើឡើងចំពោះការផ្លាស់ប្តូរដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គ្រឹះស្ថាន តាមរយៈការកាន់កាប់សមាមាត្រភាគហ៊ុន ឬនៃសិទ្ធិបោះឆ្នោត។ ការជូនដំណឹងនេះជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាលដោយមិនគិតដល់កាតព្វកិច្ច ដែលតម្រូវដោយបទប្បញ្ញត្តិផ្សេងទៀតពាក់ព័ន្ធទៅនឹងភាគហ៊ុនថ្មី ឬភាគហ៊ុនដែលបានផ្ទេរ និង/ឬនៃសិទ្ធិបោះឆ្នោត។

**ប្រការ ៥**.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចេះវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ហើយត្រូវ ៖
- ជៀសវាងទំនាស់ផលប្រយោជន៍
- មិនត្រូវចូលរួមធ្វើសេចក្តីសម្រេចនៅពេលមានទំនាស់ផលប្រយោជន៍
- ជំរុញសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថាន។

**ប្រការ ៦**.-

១- សម្រាប់ធនាគារពាណិជ្ជ លើកលែងតែសាខាធនាគារបរទេស ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកឯករាជ្យយ៉ាងតិចពីររូប។ សមាជិកឯករាជ្យត្រូវមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រងផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។

២- សម្រាប់ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិច ៣រូប ដែលក្នុងនោះមួយរូបត្រូវតែជាសមាជិកឯករាជ្យដូចបានចែងក្នុងចំណុច ១ ខាងលើ។ ប្រសិនបើគ្រឹះស្ថាននោះមានសមាជិកលើសពី៣រូប គ្រឹះស្ថានត្រូវធានាថាយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកត្រូវតែជាសមាជិកឯករាជ្យ។

៣- សាខាធនាគារបរទេស ត្រូវអនុវត្តគោលនយោបាយអភិបាលកិច្ចត្រឹមត្រូវ និងនីតិវិធីអនុលោមតាមគោលការណ៍ដែលបានកំណត់នៅក្នុងប្រកាសនេះ។ ភាពរឹងមាំនៃអភិបាលកិច្ចរបស់សាខាធនាគារបរទេសត្រូវសមស្របនឹងកម្រិតស្វ័យភាពនៃការគ្រប់គ្រងដែលស្នាក់ការកណ្តាលបរទេសបានផ្តល់ឱ្យនាយកប្រតិបត្តិក្នុងស្រុក។

**ប្រការ ៧**.-

គ្រឹះស្ថានត្រូវបង្កើតគណៈកម្មការសវនកម្ម និងគណៈកម្មការហានិភ័យ ហើយអាចបង្កើតគណៈកម្មការជំនាញផ្សេងទៀតតាមការចាំបាច់ ឬតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៨**.-

គណៈកម្មការសវនកម្មរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ និងបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកច្បាប់ និងធនាគារ។

គណៈកម្មការសវនកម្ម ត្រូវទទួលខុសត្រូវជាអប្បបរមាដោយ ៖

- ធានាថាព័ត៌មានដែលបានផ្តល់ជូនសាធារណជន និងធនាគារជាតិនៃកម្ពុជា ត្រឹមត្រូវនិងអាចជឿជាក់បាន
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ ដែលបានប្រើដើម្បីរៀបចំគណនីដោយឡែក និងគណនីរួមបញ្ចូលគ្នា ប្រសិនបើមាន
- វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃថាតើប្រព័ន្ធសម្រាប់វាស់វែងតាមដាន និងត្រួតពិនិត្យហានិភ័យមានសង្គតិភាព និងផ្តល់អនុសាសន៍លើសកម្មភាពអនុវត្តបន្តនៅពេលណាដែលសមស្រប។

**ប្រការ ៩**.-

គណៈកម្មការហានិភ័យរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយបុគ្គលដែលមានជំនាញខាងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ។ បុគ្គលនោះត្រូវមានឯករាជ្យពីការងារគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ។

គណៈកម្មការហានិភ័យត្រូវទទួលខុសត្រូវជាអប្បបរមា លើការតាមដានត្រួតពិនិត្យ ការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

**ប្រការ ១០**.-

ប្រសិនបើគ្រឹះស្ថានមានគណៈកម្មការតែងតាំង និងផ្តល់តម្លៃការ គណៈកម្មការនេះត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យដែលមានជំនាញផ្នែកច្បាប់ និងធនាគារ។

គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវទទួលខុសត្រូវជាអប្បបរមា ដោយ ៖

- ធានាថាគោលនយោបាយផ្តល់តម្លៃការ មានសង្គតិភាពទៅនឹងគោលដៅរយៈពេលវែង និងតម្លៃរួម (Corporate Value) របស់គ្រឹះស្ថាន
- ផ្តល់អនុសាសន៍លើនីតិវិធីដើម្បីជ្រើសរើស និងផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល
- ផ្តល់អនុសាសន៍ចំពោះបុគ្គលឯករាជ្យដែលនឹងក្លាយជាសមាជិកគណៈកម្មការដូចមានយោងក្នុងប្រកាសនេះ
- អនុម័តការតែងតាំងអ្នកគ្រប់គ្រងជាន់ខ្ពស់។

## ជំពូក ៣
## គោលដៅជាយុទ្ធសាស្ត្រ និងតម្លៃរួមរបស់គ្រឹះស្ថាន

**ប្រការ ១១**.-

ក្រុមប្រឹក្សាភិបាលត្រូវកំណត់តម្លៃរួម និងធានាថាតម្លៃរួមទាំងនោះត្រូវបានផ្សព្វផ្សាយយល់ដឹង និងទទួលយកទាំងគ្រឹះស្ថាន។ តម្លៃទាំងនេះត្រូវគិតពីផលប្រយោជន៍របស់ភាគទុនិក និងអ្នកផ្ញើប្រាក់ផងដែរ។

**ប្រការ ១២**.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយនិងនីតិវិធីត្រូវបានបង្កើតឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រតិបត្តិតាមទាំងស្រុង ជាពិសេសទាក់ទងទៅនឹងចំណុចដូចខាងក្រោមៈ

- ទំនាស់ផលប្រយោជន៍
- ការផ្តល់ឥណទានដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិត
- ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងបុគ្គលសម្ព័ន្ធ។

**ប្រការ ១៣**.-

ទំនាស់ផលប្រយោជន៍ដែលមានសក្តានុពលត្រូវតែមានការយកចិត្តទុកដាក់ជាពិសេសពីក្រុមប្រឹក្សាភិបាលៈ

- នៅពេលដែលគ្រឹះស្ថានជាផ្នែកមួយនៃចង្កោមក្រុមហ៊ុន
- ទំនាស់ផលប្រយោជន៍ត្រូវតែទប់ស្កាត់ គ្រប់គ្រង និងបើកចំហ
- ត្រូវកំណត់របាំងព័ត៌មាន ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍
- ព័ត៌មានរបស់អតិថិជនត្រូវតែច្បាស់លាស់ និងត្រឹមត្រូវអំពីទំនាស់ផលប្រយោជន៍
- អ្នកត្រួតពិនិត្យត្រូវតែបានជូនដំណឹងយ៉ាងដិតដល់អំពីទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល។

## ជំពូក ៤
## ភាពច្បាស់លាស់ស្តីពីការទទួលខុសត្រូវ

**ប្រការ ១៤**.-

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ និងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតវិធានច្បាស់លាស់ ដើម្បីផ្ទេរភារកិច្ចរបស់ខ្លួនទៅបុគ្គលិក។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតផងដែរនូវកាតព្វកិច្ចរាយការណ៍ច្បាស់លាស់ក្នុងគោលបំណងគាំទ្រដល់ការតាមដានការប្រតិបត្តិតាមវិធានដែលត្រូវបានបង្កើតឡើងខាងលើប្រកបដោយប្រសិទ្ធភាព។

អ្នកគ្រប់គ្រងជាន់ខ្ពស់ដែលជាផ្នែកមួយនៃគណៈប្រតិបត្តិ ដូចដែលបានកំណត់និយមន័យក្នុងប្រការ ២ នៃប្រកាសនេះ ត្រូវឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របមួយដោយធនាគារជាតិនៃកម្ពុជាមុននឹងទទួលភារកិច្ចជាអ្នកប្រតិបត្តិជាន់ខ្ពស់នៅក្នុងគ្រឹះស្ថាន។

**ប្រការ ១៥**.-

នៅក្នុងក្រុមសម្ព័ន្ធធនាគារ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុមសម្ព័ន្ធ និងនៅថ្នាក់ក្រុមហ៊ុននីមួយៗដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម។ ក្រុមប្រឹក្សាភិបាលរបស់បុគ្គលសម្ព័ន្ធ

ណាមួយត្រូវរក្សាឱ្យបានពេញលេញនូវការទទួលខុសត្រូវលើអភិបាលកិច្ចរបស់ខ្លួន។ ដូចគ្នានេះដែរ ការផ្ដល់សេវាសំខាន់ៗពីប្រភពខាងក្រៅគ្រឹះស្ថានមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការពិនិត្យមើលសកម្មភាព និងការគ្រប់គ្រងហានិភ័យបានឡើយ។

**ប្រការ ១៦**.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា មានការត្រួតពិនិត្យសមស្រប ត្រឹមត្រូវពីអ្នកគ្រប់គ្រងជាន់ខ្ពស់ស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវមានជំនាញជាចាំបាច់។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវលើសេចក្ដីសម្រេច និងសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលយក និងអនុវត្តតាមទាំងស្រុងនូវគោលនយោបាយដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង និងត្រូវរាយការណ៍ឱ្យបានទៀងទាត់ទៅក្រុមប្រឹក្សាភិបាលអំពីទម្រង់ហានិភ័យ លទ្ធផលនៃការអនុវត្តបញ្ហាផ្សេងៗ វិវាទចម្បងរបស់គ្រឹះស្ថាន និងបញ្ហាចំពោះមុខ និងជាសក្ដានុពលនៃបទប្បញ្ញត្តិ។

## ជំពូក ៥
## ការលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃសវនកម្ម

**ប្រការ ១៧**.-

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រូវប្រើប្រាស់ការងាររបស់សវនករ និងមុខងារត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព:

- អ្នកគ្រប់គ្រងត្រូវផ្សព្វផ្សាយឱ្យមានការទទួលស្គាល់ពីសារៈសំខាន់នៃការងាររបស់សវនករខាងក្នុង និងខាងក្រៅទូទាំងគ្រឹះស្ថាន
- លទ្ធផលរកឃើញរបស់សវនកម្មផ្ទៃក្នុងត្រូវតែប្រើប្រាស់សម្រាប់សកម្មភាពកែតម្រូវដោយប្រសិទ្ធភាពគ្រប់កាលៈទេសៈដែលតម្រូវ
- ការអនុវត្តទាន់ពេលវេលានូវសកម្មភាពកែតម្រូវដែលចាំបាច់ និងប្រកបដោយប្រសិទ្ធភាពត្រូវតែពិចារណាយោងតាមភាពធ្ងន់ធ្ងរនៃការរកឃើញ និងហានិភ័យដែលនាំឱ្យមានការធ្លាក់ដុនដាបជាបន្តបន្ទាប់នៃទម្រង់ហានិភ័យរួម និងស្ថានភាពប្រតិបត្តិតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថាន។

## ជំពូក ៦
## គោលនយោបាយលាភការ

**ប្រការ ១៨**.-

តាមការចាំបាច់ ក្រុមប្រឹក្សាភិបាល និងគណៈកម្មការតែងតាំងនិងផ្ដល់តម្លៃការ ត្រូវធានាថាការអនុវត្តនិងគោលនយោបាយលាភការមានសង្គតិភាពជាមួយនឹងវប្បធម៌សាជីវកម្ម (Corporate Culture) យុទ្ធសាស្ត្រនិងគោលដៅរយៈពេលវែង និងបរិយាកាសត្រួតពិនិត្យរបស់គ្រឹះស្ថាន។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ ឬ អនុម័តលាភការដល់សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់។

តម្លៃការជូនទៅនាយកមិនប្រតិបត្តិ ត្រូវសមាមាត្រទៅនឹងការចូលរួមរបស់អ្នកទាំងនោះ ប៉ុន្តែការផ្តល់តម្លៃការនោះមិនទាក់ទងនឹងលទ្ធផលរយៈពេលខ្លីរបស់គ្រឹះស្ថានទេ។

រង្វាន់លើកទឹកចិត្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវមានគោលដៅបង្កើនតម្លៃរួម (Corporate Value) រយៈពេលវែង។

## ជំពូក ៧
## តម្លាភាព

**ប្រការ ១៩**.-

គ្រឹះស្ថានត្រូវតែដឹកនាំគ្រប់គ្រងប្រកបដោយមានតម្លាភាព។ ការបើកចំហដល់សាធារណជនត្រូវតែសមាមាត្រទៅនឹងទំហំ សកម្មភាព ភាពស្មុគស្មាញ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន។ ការបើកចំហយ៉ាងហោចណាស់ត្រូវមានដូចខាងក្រោម ៖

- រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថាន
- រចនាសម្ព័ន្ធភាគទុនិក
- រចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម បើអាចធ្វើបានត្រូវឱ្យសមស្របទៅនឹងកម្មសិទ្ធិភាពភាគហ៊ុន ដែលត្រូវបានកាន់កាប់
- រចនាសម្ព័ន្ធចាត់តាំង
- រង្វាន់លើកទឹកចិត្ត
- ក្រមប្រតិបត្តិ ឬ ក្រមសីលធម៌
- គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍
- គោលនយោបាយឥណទាន និងកម្រិតកំណត់ដែលត្រូវអនុវត្តចំពោះសម្ព័ន្ធញាតិនិងបុគ្គលសម្ព័ន្ធ។

## ជំពូក ៨
## ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន

**ប្រការ ២០**.-

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់:

- ត្រូវយល់ដឹងអំពីរចនាសម្ព័ន្ធប្រតិបត្តិការរបស់គ្រឹះស្ថានរួមទាំងនៅពេលដែលគ្រឹះស្ថានធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការ ឬតាមរយៈរចនាសម្ព័ន្ធណាមួយដែលរារាំងដល់តម្លាភាព
- ត្រូវធានាថា អ្នកគ្រប់គ្រងជាន់ខ្ពស់អនុវត្តតាមគោលនយោបាយច្បាស់លាស់ចំពោះប្រតិបត្តិការដែលត្រូវបានធ្វើតាមរយៈរចនាសម្ព័ន្ធ ឬ យុត្តាធិការ ដែលគ្មានតម្លាភាព
- ត្រូវមានគោលនយោបាយសមស្របសម្រាប់ការអនុម័ត និងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធហិរញ្ញវត្ថុ ឧបករណ៍ ឬ ផលិតផល ដែលមានភាពស្មុគស្មាញ
- ត្រូវធានាថា សវនកម្មផ្ទៃក្នុងមិនត្រូវទុកឱ្យរចនាសម្ព័ន្ធ ឬ សកម្មភាពទាំងនេះស្ថិតនៅក្រៅការត្រួតពិនិត្យឡើងវិញជាប្រចាំរបស់ខ្លួនឡើយ

- ត្រូវធានាថាការផ្តល់សេវាពីខាងក្រៅ ចំពោះសកម្មភាពសំខាន់ៗ នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យគ្រប់គ្រាន់ និងធានាថាហានិភ័យដែលផ្សារភ្ជាប់និងការផ្តល់សេវាពីខាងក្រៅនេះ ត្រូវបានសម្គាល់ និងតាមដានពេញលេញ។

## ជំពូក ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ២១**.-

១- បន្ទាប់ពីប្រកាសនេះចូលជាធរមាន ធនាគារពាណិជ្ជ និងធនាគារឯកទេសលើកលែងតែសាខាធនាគារបរទេស ត្រូវអនុវត្តឱ្យបានពេញលេញនូវបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយនៃអភិបាលកិច្ច ជាពិសេសប្រការ ៦ នៃប្រកាសនេះ ដោយមិនឱ្យលើសពី :

- ១២ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកលើសពី៣០០នាក់ ឬ ទ្រព្យសកម្មសរុបច្រើនជាង ៤០០ពាន់លានរៀល
- ១៨ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកពី ១៥០នាក់ ដល់ ៣០០នាក់ ឬ ទ្រព្យសកម្មសរុបពី ២០០ពាន់លានរៀល ដល់៤០០ពាន់លានរៀល និង
- ២៤ខែ សម្រាប់គ្រប់គ្រឹះស្ថានដទៃទៀតដែលមានចំនួនបុគ្គលិកតិចជាង ១៥០នាក់ ឬ ទ្រព្យសកម្មសរុបតិចជាង ២០០ពាន់លានរៀល។

២- ក្នុងអំឡុងពេល៩ខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជា ដោយរៀបរាប់លំអិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពី :

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការសម្រាប់បំពេញមុខតំណែងក្នុងអង្គការលេខដែលបានគ្រោងទុក
- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវ ចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយគណៈកម្មការដែលត្រូវបង្កើតឡើង។

៣- ផែនការសកម្មភាពអង្គការលេខដែលបានគ្រោងទុក និងការទទួលខុសត្រូវដែលបានរៀបរាប់ខាងលើឱ្យបានច្បាស់លាស់ត្រូវរាយការណ៍ទាន់ពេលវេលាមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ២២**.-

ក្នុងអំឡុងពេល៩ខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន សាខាធនាគារបរទេសត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា ស្តីពី គោលនយោបាយ និងនីតិវិធីនៃអភិបាលកិច្ចដោយត្រូវរៀបរាប់ពី:

- ស្វ័យភាពនៃសិទ្ធិសម្រេចដែលផ្តល់ដោយទីស្នាក់ការកណ្តាល
- គោលនយោបាយ និងនីតិវិធីនៃអភិបាលកិច្ច និងការគ្រប់គ្រងដោយទីស្នាក់ការកណ្តាលដែលសាខាត្រូវអនុវត្តតាម

- បណ្តាញនៃការរាយការណ៍របស់គណៈប្រតិបត្តិសាខាទៅសមាជិកក្រុមប្រឹក្សាភិបាល និងការទទួលខុសត្រូវក្នុងគ្រឹះស្ថាន ដែលកំណត់ដោយទីស្នាក់ការកណ្តាល
- ការផ្តល់សិទ្ធិអំណាចដោយទីស្នាក់ការកណ្តាលចំពោះគណៈប្រតិបត្តិសាខាក្នុងស្រុក និង
- នីតិវិធី និងគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងសិទ្ធិអំណាចដែលតម្រូវដោយទីស្នាក់ការកណ្តាលដើម្បីឱ្យសាខាមានសិទ្ធិធ្វើប្រតិបត្តិការ។

ច្បាប់ចម្លងនៃរាល់ឯកសារខាងលើ ត្រូវភ្ជាប់ជាមួយរបាយការណ៍ផ្តល់មកធនាគារជាតិនៃ កម្ពុជា។

ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធ្វើបច្ចុប្បន្នកម្មតាមគ្រានូវរបាយការណ៍ទាំងនោះសំដៅវាយតម្លៃភាពខ្លាំងនិងភាពខ្សោយនៃការត្រួតពិនិត្យ និងអភិបាលកិច្ចរបស់សាខាធនាគារបរទេស។

**ប្រការ ២៣**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យបានពេញលេញមិនឱ្យលើសពី២៤ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន។ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជាដោយរៀបរាប់លំអិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពី :

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការសម្រាប់បំពេញមុខតំណែង ក្នុងអង្គការលេខដែលបានគ្រោងទុក
- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយគណៈកម្មការដែលត្រូវបង្កើតឡើង។

ក្នុងករណីចាំបាច់ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពខាងលើមកធនាគារជាតិនៃកម្ពុជាក្នុងអំឡុងពេល ៩ ខែ។

## ជំពូក ១០
## អវសានប្បញ្ញត្តិ

**ប្រការ ២៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថាននៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៥**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៨-២១២ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដាក់ពាក្យ ស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ប្រកាសនេះកំណត់នូវតម្រូវការអប្បបរមាចំពោះបុគ្គលដែលមានមុខងារសំខាន់នៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ឬបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវទទួលរងការវាយតម្លៃថាមាន "លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប" ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។

គោលបំណងនៃប្រកាសនេះរួមមានៈ

១- ការពារផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើ និងបុគ្គលដែលពាក់ព័ន្ធដោយធានាថាគ្រឹះស្ថានត្រូវបានគ្រប់គ្រង និងដឹកនាំយ៉ាងត្រឹមត្រូវនិងប្រុងប្រយ័ត្ន

២- ដាក់ចេញនូវក្របខណ្ឌអប្បបរមាស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដែលគ្រឹះស្ថានអាចយកទៅប្រើប្រាស់ដើម្បីកំណត់ចំពោះបុគ្គលដែលនឹងទទួលតំណែងសំខាន់ៗ

៣- ដោះស្រាយហានិភ័យដែលបណ្តាលមកពីការគ្រប់គ្រងមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងររបស់គ្រឹះស្ថាន និងទប់ស្កាត់ការគំរាមកំហែងជាសក្តានុពលដល់ប្រព័ន្ធធនាគារទាំងមូល និងការពារផលប្រយោជន៍របស់អ្នកដាក់ប្រាក់បញ្ញើ។

**ប្រការ ២**.-

គ្រឹះស្ថានទាំងអស់ ត្រូវមានគោលនយោបាយផ្ទៃក្នុងគ្រប់គ្រាន់ដែលហ្មត់ចត់និងច្បាស់លាស់តាមស្តង់ដារសម្រាប់ជ្រើសរើសនាយកប្រតិបត្តិ និងអ្នកគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ទោះបីជាការទទួលខុសត្រូវសំខាន់ក្នុងការកំណត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវពឹងផ្អែកជាចម្បងលើភាគទុនិក។ អាជ្ញាធរត្រួតពិនិត្យក៏ទទួលខុសត្រូវផងដែរក្នុងការវាយតម្លៃពីភាពស្មោះត្រង់ សុចរិត កិត្តិនាម ចំណេះដឹង និងសមត្ថភាពរបស់បុគ្គលសំខាន់ៗក្នុងពេលបច្ចុប្បន្ន និងអនាគតក្នុងលក្ខខណ្ឌនៃការដឹកនាំគ្រឹះស្ថានប្រកបដោយប្រសិទ្ធភាព។

បុគ្គលទាំងនេះ ត្រូវអនុវត្តឱ្យពេញលេញស្របតាមប្រកាសលេខ ធ៧-០៨-២១១ ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៣**.-

ក្នុងការអនុវត្តនូវលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ធនាគារជាតិនៃកម្ពុជា កំណត់ផងដែរសម្រាប់បុគ្គលដែលមានតំណែងសំខាន់ៗនៅក្នុងគ្រឹះស្ថានត្រូវមានកម្រិតសមត្ថភាព និងបទពិសោធន៍សមស្របទៅនឹង

ការទទួលខុសត្រូវរបស់ខ្លួន។ ការវាយតម្លៃសមត្ថភាពនិងបទពិសោធន៍ដោយផ្អែកលើទំហំនិងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន ក៏ដូចជាទំហំនិងភាពស្មុគស្មាញនៃអាជីវកម្ម និងភាពជឿនលឿនហួសហេតុនៃប្រតិបត្តិការ។

## ជំពូក ២
## បុគ្គលសំខាន់ៗ ត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របដោយធនាគារជាតិនៃកម្ពុជា

**ប្រការ ៤**.-

បុគ្គលសំខាន់ៗត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដោយធនាគារជាតិនៃកម្ពុជារួមមាន :

១- ក្រុមប្រឹក្សាភិបាល

២- អ្នកគ្រប់គ្រងជាន់ខ្ពស់ ដូចមានចែងនៅក្នុងប្រការ២ នៃប្រកាសលេខ ធ៧-០៨-២១១ ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣- នាយកសាខាធនាគារបរទេស និង

៤- បុគ្គលដែលមានតួនាទីជំនួសដោយការកំណត់ ឬបុគ្គលដែលទទួលបានសិទ្ធិប្រទានពីបុគ្គលដូចមានចែងខាងលើ។

**ប្រការ ៥**.-

ការឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដែលមានចែងនៅក្នុងប្រការ៤ ត្រូវអនុវត្តគ្រប់កាលៈទេសៈនៃការស្នើសុំដូចខាងក្រោមៈ

១- ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រតិបត្តិការធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា

២- ការដាក់ពាក្យសុំបើកបុត្តសម្ព័ន្ធរបស់ធនាគារបរទេសនៅកម្ពុជា

៣- ការដាក់ពាក្យសុំបើកសាខាធនាគារបរទេសនៅកម្ពុជា

៤- រាល់ការសម្រេចរបស់កិច្ចប្រជុំភាគទុនិក ឬក្រុមប្រឹក្សាភិបាលដែលបណ្តាលឱ្យមានការកើនឡើងចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៥- រាល់ការសម្រេចរបស់ធនាគារបរទេសដែលបង្កើតបុត្តសម្ព័ន្ធនៅកម្ពុជាដែលបណ្តាលឱ្យមានការកែប្រែ ឬផ្លាស់ប្តូរចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៦- រាល់ការសម្រេចទាំងឡាយណាដែលនាំទៅដល់ការតែងតាំងបុគ្គលជំនួស ឬបុគ្គលដែលទទួលសិទ្ធិប្រទានដូចមានចែងក្នុងប្រការ៤ ចំនុច ១, ២ និង ៣ និង

៧- រាល់ការផ្លាស់ប្តូរដែលកើតមានបន្ទាប់ពីការបញ្ឈប់ ឬការលាឈប់របស់បុគ្គលទាំងនោះ។

## ជំពូក ៣
## តម្រូវការព័ត៌មាន

**ប្រការ ៦**.-

នៅក្នុងដំណើរការដាក់ពាក្យសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានថ្មី គ្រឹះស្ថានត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវព័ត៌មានដែលទាក់ទងនឹងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របនៃបុគ្គលសំខាន់ៗសម្រាប់ជាឯកសារភ្ជាប់ជា

មួយពាក្យស្នើសុំ និងផ្តល់បន្ថែមនូវរចនាសម្ព័ន្ធចាត់តាំងដែលមានបញ្ជាក់ពីមុខងារ និងការទទួលខុសត្រូវនៃបុគ្គលទាំងនោះ។

**ប្រការ ៧**.-

ចំពោះគ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ រាល់ការផ្លាស់ប្តូរបុគ្គលសំខាន់ៗត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាមិនឱ្យលើសពី៣០ថ្ងៃ បន្ទាប់ពីការលាលែង ការចូលនិវត្តន៍ ឬការបញ្ឈប់បុគ្គលសំខាន់ៗនោះ។

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិនិត្យឡើងវិញនូវលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របនៃបុគ្គលដែលត្រូវបានស្នើសម្រាប់តំណែងទំនេរ ឬតំណែងទើបបង្កើតថ្មីមុនពេលសម្រេចតែងតាំង។ ធនាគារជាតិនៃកម្ពុជា មិនអាចបញ្ជាក់អំពីការទទួលយល់ព្រមការតែងតាំងទាំងនោះបានទេ មុនពេលបានទទួល និងសិក្សាឡើងវិញនូវព័ត៌មានដែលតម្រូវឱ្យមាន។

ធនាគារជាតិនៃកម្ពុជាអាចនឹងសំភាសន៍ជាមួយបុគ្គលដែលបានស្នើ ដើម្បីឱ្យប្រាកដអំពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របនៃបុគ្គលក្នុងឋានៈដែលត្រូវបានផ្តល់ឱ្យ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថានទាំងមូល។

**ប្រការ ៨**.-

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងនូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថានក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលឯកសារគ្រប់គ្រាន់ និងអាចទទួលយកបាន។

## ជំពូក ៤
## ការវាយតម្លៃ និងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

**ប្រការ ៩**.-

បុគ្គលសម្រាប់តំណែងសំខាន់ៗនឹងត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យច្រើនប្រភេទ ដើម្បីកំណត់ថាបុគ្គលទាំងនោះមានលក្ខខណ្ឌត្រឹមត្រូវនិងសមស្របគ្រប់គ្រាន់ដើម្បីបំពេញនូវការទទួលខុសត្រូវដូចខាងក្រោម:

១- ភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ

២- ការសិក្សា ចំណេះដឹង និងសមត្ថភាព

៣- ស្ថានភាពហិរញ្ញវត្ថុរឹងមាំ

**ប្រការ ១០**.-

ធនាគារជាតិនៃកម្ពុជានឹងធ្វើការពិចារណាលើកត្តាសមស្របជាច្រើនដើម្បីវាយតម្លៃពីភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវយ៉ាងតិចបំផុតមានដូចខាងក្រោម :

១- បុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម និងបទឧក្រិដ្ឋ ឬកំហុសខាងវិន័យ

២- បុគ្គលដែលមានកំហុសដោយសារការក្លែង ឬផ្តល់នូវភស្តុតាងក្លែងបន្លំ

៣-ចំពោះភាគទុនិកដែលមានឥទ្ធិពល ឬបុគ្គលដែលមានសិទ្ធិត្រួតពិនិត្យត្រូវបានទទួលទណ្ឌកម្មខាងវិន័យ ឬព្យួរការងារដោយអាជ្ញាធរត្រួតពិនិត្យ ឬគ្រឹះស្ថានវិជ្ជាជីវៈ ឬតុលាការជាសាធារណៈ ឬជាឯកជន

៤-បុគ្គលដែលមានតួនាទីទទួលខុសត្រូវ ឬជាម្ចាស់ក្រុមហ៊ុន ឬស្ថាប័នដែលធ្លាប់ត្រូវបានបដិសេធពេលចុះបញ្ជីពាណិជ្ជកម្ម ឬបញ្ឈប់អាជីវកម្ម ឬត្រូវបានដកហូតអាជ្ញាប័ណ្ណ

៥-បុគ្គលដែលត្រូវបញ្ឈប់ពីការងារ ឬបង្ខំឱ្យលាលែងពីតំណែងដោយសារតែពាក់ព័ន្ធលើបញ្ហាភាពសុចរិត ឬភាពស្មោះត្រង់

៦-បុគ្គលដែលត្រូវបានដកហូតពីតំណែងជានាយក ឬជាអ្នកគ្រប់គ្រងដោយសារតែបានប្រព្រឹត្តខុស

៧-បុគ្គលដែលគ្មានសីលធម៌ និងសច្ចៈធម៌ ក្នុងការទំនាក់ទំនងជាមួយអតិថិជន ថ្នាក់ដឹកនាំសវនករ និងអាជ្ញាធរផ្សេងទៀត

៨-បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពដូចជា ការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ការក្លែងបន្លំ ឬអំពើពុករលួយ ទោះបីជាការប្រព្រឹត្តនោះមិនឈានដល់ការផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងប្រទេសខ្លះក្តី។

៩- បុគ្គលដែលគ្មានការវិនិច្ឆ័យ និងការសម្រេចចិត្តដោយឯករាជ្យ ដើម្បីប្រតិបត្តិតួនាទីរបស់ខ្លួន

១០-បុគ្គលដែលមិនបានត្រៀមជាស្រេច និងមិនមានបំណងប្រតិបត្តិតាមកាតព្វកិច្ច បទប្បញ្ញត្តិ និងការអនុវត្តដ៏ល្អសំដៅទ្រទ្រង់សុវត្ថិភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារ។

**ប្រការ ១១**.-

បុគ្គលត្រូវមានការសិក្សា ចំណេះដឹង បទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីស្វែងយល់នូវតម្រូវការបច្ចេកទេសអាជីវកម្ម ហានិភ័យដែលពាក់ព័ន្ធ និងដំណើរការគ្រប់គ្រងទាំងឡាយដោយមានការទទួលខុសត្រូវ ដើម្បីអនុវត្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពរឹងមាំ ដោយគិតដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់។

ធនាគារជាតិនៃកម្ពុជា នឹងពិចារណារាល់កត្តាពាក់ព័ន្ធទាំងឡាយក្នុងការវាយតម្លៃកម្រិតយល់ដឹងនិងសមត្ថភាពវិជ្ជាជីវៈនៃបុគ្គល យ៉ាងតិចបំផុតមានដូចខាងក្រោមៈ

១-បុគ្គលដែលមានប្រវត្តិសិក្សាសមស្របនាំឱ្យមានការយល់ដឹងត្រឹមត្រូវ និងគ្រប់គ្រាន់អំពីអាជីវកម្ម និងហានិភ័យដែលពាក់ព័ន្ធ។

២-បុគ្គលដែលបានបង្ហាញថាមានសមត្ថភាពក្នុងការអនុវត្តតួនាទីប្រកបដោយជោគជ័យតាមរយៈគុណវុឌ្ឍិ បទពិសោធន៍ និងការប្រតិបត្តិមុខតំណែងពីមុនមក។

៣-បុគ្គលដែលមានចំណេះដឹងផ្នែកអាជីវកម្ម និងការទទួលខុសត្រូវចំពោះមុខតំណែង ហើយការយល់ដឹងនេះមានភាពសមស្របទៅនឹងទម្រង់ហានិភ័យរបស់គ្រឹះស្ថានព្រមទាំងទំហំភាពស្មុគ្រស្មាញនៃអាជីវកម្ម និងភាពជឿនលឿនហួសហេតុនៃប្រតិបត្តិការ។

៤-បុគ្គលធ្លាប់ទទួលទណ្ឌកម្មខាងវិន័យដោយអាជ្ញាធរត្រួតពិនិត្យ និងសមាគមវិជ្ជាជីវៈ និងពាណិជ្ជកម្មត្រូវបានបណ្តេញចេញ ឬតម្រូវឱ្យលាឈប់ពីមុខតំណែង ឬពីគ្រឹះស្ថានដោយសារការធ្វេសប្រហែស អសមត្ថភាព ការក្លែងបន្លំ ឬការគ្រប់គ្រងមិនត្រឹមត្រូវ និង

៥-បុគ្គលដែលបាត់បង់សមត្ថភាពក្នុងការបំពេញការងារដែលអាចជះឥទ្ធិពលលើសមត្ថភាព និងសុភវិនិច្ឆ័យឯករាជ្យរបស់ខ្លួន។

**ប្រការ ១២**.-

ធនាគារជាតិនៃកម្ពុជានឹងពិចារណាផងដែរលើភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំក្នុងការវាយតម្លៃពីភាពត្រឹមត្រូវនិងសមស្រប។

ការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងត្រឹមត្រូវនៃការងារហិរញ្ញវត្ថុរបស់បុគ្គលជាការបង្ហាញនូវសមត្ថភាពរបស់បុគ្គលនោះក្នុងការរួមចំណែកដើម្បីធានាសុវត្ថិភាព ភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត។ លើសពីនេះ ស្ថានភាពហិរញ្ញវត្ថុផ្ទាល់របស់បុគ្គលដូចបានលើកឡើងខាងលើមិនរឹងមាំអាចប៉ះពាល់ផងដែរលើសុភវិនិច្ឆ័យឯករាជ្យរបស់បុគ្គលនោះ។

ធនាគារជាតិនៃកម្ពុជា នឹងពិចារណារាល់កត្តាពាក់ព័ន្ធទាំងអស់យ៉ាងតិចបំផុតមានដូចខាងក្រោម :

១- បុគ្គលនោះជាកម្មវត្ថុក្នុងការវិនិច្ឆ័យការងារណាមួយដោយតុលាការ ឬជាកម្មវត្ថុក្នុងការដាក់ទណ្ឌកម្មខាងវិន័យនៅចំពោះមុខសមាគមវិជ្ជាជីវៈជាពិសេស ប្រសិនបើនៅតែមានបណ្តឹងដែលទាក់ទងនឹងសកម្មភាពនោះមិនទាន់បានដោះស្រាយ

២- បុគ្គលនោះ មានសមតុល្យឥណទានហួសកាលកំណត់នៅធនាគារផ្សេង និងមិនទាន់បានជម្រះស្ថានភាពនេះនៅឡើយ

៣- បុគ្គលនោះ បានធ្វើការសម្រុះសម្រួលជាមួយម្ចាស់បំណុលបានដាក់ពាក្យសុំក្ស័យធនត្រូវបានវិនិច្ឆ័យថាក្ស័យធនទ្រព្យសម្បត្តិត្រូវបានរឹបអូស ឬជាប់ពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់ទាក់ទងនឹងចំណុចណាមួយដែលបានលើកឡើងខាងលើ ។

## ជំពូក ៥
## ការត្រួតពិនិត្យលើលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់បុគ្គលសំខាន់

**ប្រការ ១៣**.-

គ្រឹះស្ថានត្រូវបង្កើតគោលនយោបាយ និងនីតិវិធីក្នុងគោលបំណងធានាថាបុគ្គលសំខាន់ ឬបុគ្គលដែលត្រូវបានតែងតាំងរួចហើយ ឬបុគ្គលដាក់ពាក្យសុំកាន់តំណែងដែលនៅទំនេរត្រូវអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របជាអប្បបរមា។

**ប្រការ ១៤**.-

ប្រសិនបើបុគ្គលសំខាន់លែងអនុវត្តតាមតម្រូវការអប្បបរមានៃលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របទៀត ហើយគ្រឹះស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាអំពីស្ថានភាពនេះមិនឱ្យលើសពី ៣០ថ្ងៃ បន្ទាប់ពីការពិតត្រូវបានរកឃើញ។ ទោះបីជាកាលៈទេសៈដែលនាំឱ្យចាត់ទុកថាភាពមិនត្រឹមត្រូវនិងមិនសមស្រប មិនទាន់ច្បាស់លាស់ក៏ដោយ ការរាយការណ៍បែបនេះមកធនាគារជាតិនៃកម្ពុជា ត្រូវតែបានអនុវត្ត និងគាំទ្រដោយការពិពណ៌នាលំអិតអំពីហេតុការណ៍ពិត និងកាលៈទេសៈនោះ។ ធនាគារជាតិនៃកម្ពុជា នឹងឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបាននូវសំណុំឯកសារពេញលេញដើម្បីសម្រេចថាបដិសេធ ឬមិនបដិសេធលើការរក្សាទុកនូវបុគ្គលសំខាន់ៗក្នុងមុខតំណែង។

**ប្រការ ១៥**.-

គ្មានបុគ្គលសំខាន់ណាម្នាក់ត្រូវបានតែងតាំងនៅក្នុងគ្រឹះស្ថាន មុនពេលទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជាឡើយ។

គ្មានបុគ្គលសំខាន់ណាម្នាក់ដែលលែងបំពេញបានតាមតម្រូវការអប្បបរមា ដែលមានចែងនៅក្នុងប្រកាសនេះនៅរក្សាតួនាទីរបស់ខ្លួនដដែលឡើយ។

**ប្រការ ១៦**.-

ចំពោះបេក្ខជនថ្មីដែលត្រូវទទួលខុសត្រូវមុខងារសំខាន់ៗ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ដែលមិនបានបំពេញតាមតម្រូវការទាំងស្រុងដោយមូលហេតុណាមួយដូចជា កង្វះខាតការសិក្សា ការបំពាក់បំប៉ន ឬបទពិសោធន៍ ធនាគារជាតិនៃកម្ពុជាអាចសម្រេចចិត្ត " មិនបដិសេធ " ប្រសិនបើដឹងជាមុននូវស្ថានភាពផ្សេងៗ ដូចជាការចូលរួមវគ្គសិក្សាបន្ថែម ឬត្រូវបានតែងតាំងដំបូងក្នុងមុខតំណែងរង ឬជាអ្នកទទួលសិទ្ធិប្រទានសម្រាប់បំពេញការងារសាកល្បងក្នុងរយៈពេលដែលត្រូវបំពេញការសិក្សានោះ ដែលមិនត្រូវលើសពី ១៨ខែ។

ធនាគារជាតិនៃកម្ពុជា នឹងវាយតម្លៃការបំពេញតាមលក្ខខណ្ឌដែលបានដាក់ចេញក្នុងរយៈពេលសាកល្បងការងារនៅចុងបញ្ចប់រយៈពេលដែលបានកំណត់ខាងលើ។ រាល់ព័ត៌មាន ឯកសារ និងកំណត់ត្រាលទ្ធផលការងារ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់នៃរយៈពេលសាកល្បងការងារនោះ។ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ ៧ ធនាគារជាតិនៃកម្ពុជា អាចតម្រូវនិងធ្វើការសំភាសន៍បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ ដើម្បីផ្តល់ជាទស្សនៈលើលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់បុគ្គលនោះនៅក្នុងការបំពេញលក្ខខណ្ឌសុភវិនិច្ឆ័យ និងសមត្ថភាពគ្រប់គ្រង និងលទ្ធផលដែលសម្រេចបានក្នុងរយៈពេលសាកល្បងការងារដោយប្រសិទ្ធភាព។

## ជំពូក ៦
## ទណ្ឌកម្ម

**ប្រការ ១៧**.-

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន និងទិន្នន័យជាភស្តុតាងដែលបានភ្ជាប់ជាមួយនឹងឯកសារស្នើសុំតែងតាំងតំណែងបុគ្គលសំខាន់នៅក្នុងគ្រឹះស្ថាន។ ប្រសិនបើការរាយការណ៍លិខិតថ្កោលទោស និងរបាយការណ៍ដែលចេញផ្សាយដោយសមាគមវិជ្ជាជីវៈ ឬអាជ្ញាធរត្រួតពិនិត្យដែលបានបញ្ជូនមកមានភាពមិនត្រឹមត្រូវ ឬក្លែងបន្លំ ធនាគារជាតិនៃកម្ពុជាត្រូវដាក់នូវទណ្ឌកម្មខាងវិន័យ និងការផាកពិន័យដល់គ្រឹះស្ថានក៏ដូចជាបុគ្គលដែលបានបញ្ជូនព័ត៌មានទាំងនោះដោយចេតនា។ ការប្រព្រឹត្តបែបនេះអាចនាំឱ្យឈានដល់ការបដិសេធចំពោះការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១៨**.-

ប្រសិនបើក្នុងរយៈពេលនៃដំណើរការត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថាន មន្ត្រីទទួលបន្ទុករបស់ធនាគារជាតិនៃកម្ពុជាបានរកឃើញថា :

ក. បុគ្គលសំខាន់មិនបានឆ្លងកាត់ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដូចមានចែងក្នុងប្រកាសនេះ

ខ. បុគ្គលសំខាន់មិនបានបំពេញតាមតម្រូវការអប្បបរមាដើម្បីក្លាយជាបុគ្គលដែលមានលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

គ. ទោះបីមិនត្រូវបានកំណត់ជា " បុគ្គលសំខាន់ " ក៏ដោយតែបុគ្គលនោះអនុវត្តការងារទទួលខុសត្រូវ និងដឹកនាំគ្រឹះស្ថានទាំងស្រុង

ឃ. បុគ្គលដែលរងនូវការបដិសេធពីធនាគារជាតិនៃកម្ពុជា នៅតែបំពេញការងារសំខាន់ក្នុងគ្រឹះស្ថាន

ង. បន្ទាប់ពីការសាកល្បងការងារក្នុងរយៈពេលកំណត់ ១៨ខែ បុគ្គលសំខាន់មិនបានអនុវត្តតាមការតម្រូវ ដូចមានចែងនៅក្នុងប្រការ ១៦ នៃប្រកាសនេះ ឬ

ច. បុគ្គលសំខាន់លែងអនុវត្តតាមការតម្រូវអប្បបរមាទៀតហើយ ទោះបីជាធនាគារជាតិនៃកម្ពុជា បានយល់ព្រមថាបុគ្គលនោះបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របចាប់ពីដំបូងក៏ដោយ។

គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

**ប្រការ ១៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថាននៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២០**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និង ត្រា: **ជា ចាន់តូ**

ធ៧-០១០-១៧២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលការណ៍**

១.១. ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដ៏ពេញលេញមួយនៅតែជាមធ្យោបាយប្រកបដោយប្រសិទ្ធភាព ទោះបីគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ជាអ្នកទទួលខុសត្រូវលើសុវត្ថិភាព និងភាពរឹងមាំនៃប្រតិបត្តិការ ព្រមទាំងការគោរពតាមច្បាប់និងបទបញ្ជាផ្សេងៗក៏ដោយ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាមធ្យោបាយសម្រាប់ :

ក. ជួយដល់គណៈគ្រប់គ្រងក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន

ខ. ជួយដល់ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និង

គ. គាំទ្រការយល់ដឹងអំពីហានិភ័យ និងការឆ្លើយតបចំពោះការអនុវត្តវិធានការកែតម្រូវផ្សេងៗ។

១.២. គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនដោយផ្អែកលើទំហំ និងភាពស្មុគស្មាញនៃសកម្មភាព រចនាសម្ព័ន្ធក្រុមសាជីវកម្ម និងប្រភេទគ្រឹះស្ថានដែលបានបង្កើតក្នុងនិងក្រៅប្រទេសព្រមទាំងប្រភេទហានិភ័យដែលគ្រឹះស្ថានត្រូវប្រឈម។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានលក្ខណៈសមស្របនឹងភាពស្មុគស្មាញនៃប្រតិបត្តិការនិងសកម្មភាពមានបុគ្គលិកគ្រប់គ្រាន់ ព្រមទាំងមានធនធានសមស្របផ្សេងទៀតសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាពដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានផែនការយថាភាព (Contingency Planning) និងការសាកល្បងជាដើម។

១.៣. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងក៏សំដៅជម្រុញស្មារតីទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗផងដែរដោយផ្អែកលើវិធាននៃការទទួលខុសត្រូវលើភារកិច្ចច្បាស់លាស់ ដែលងាយយល់សម្រាប់គ្រឹះស្ថានទាំងមូល។ វិធានទាំងនេះត្រូវមានចែងអំពីបែបបទរាយការណ៍ច្បាស់លាស់ទៅគណៈគ្រប់គ្រង គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ឬគណៈប្រតិបត្តិដែលមានឋានៈស្មើ។ វិធានទាំងនេះត្រូវមានចែងអំពីបែបបទនៃការផ្ទេរសិទ្ធិអំណាចដើម្បីធានាថាអ្នកទទួលសិទ្ធិអំណាចបានយល់ដឹងច្បាស់លាស់អំពីការផ្ទៀងផ្ទាត់និងការត្រួតពិនិត្យពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិអំណាចទាំងនោះ ទៅតាមឋានានុក្រមនៃការគ្រប់គ្រង។

១.៤. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានយ៉ាងតិចនូវ :

ក. ប្រព័ន្ធត្រួតពិនិត្យសម្រាប់នីតិវិធីប្រតិបត្តិការ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង

ខ. រចនាសម្ព័ន្ធនៃប្រព័ន្ធគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា

គ. ប្រព័ន្ធវាស់វែងលទ្ធផលនិងហានិភ័យ

ឃ. ប្រព័ន្ធកំណត់អត្តសញ្ញាណ វាស់វែង និងតាមដានហានិភ័យ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យហានិភ័យតាមរយៈការដាក់ចេញនូវវិធានការកែតម្រូវ

ង. ការបែងចែកភារកិច្ច ការទប់ស្កាត់ទំនាស់ផលប្រយោជន៍ ព្រមទាំងគោលនយោបាយ និងនីតិវិធីដោះស្រាយទំនាស់

ច. គោលនយោបាយ នីតិវិធី និងដំណើរការប្រតិបត្តិតាម (Compliance)

ឆ. ប្រព័ន្ធព័ត៌មាននិងរក្សាទុកឯកសារ និង

ជ. ប្រព័ន្ធសម្រាប់តាមដានស្ថានភាព និងលំហូរសាច់ប្រាក់និងមូលបត្រ។

១.៥. បើចាំបាច់ គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅកម្រិតគួបសរុបមួយដែលមានប្រសិទ្ធភាពក្នុងការកំណត់ វាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យនៅកម្រិតគួបសរុបនេះ។ ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅកម្រិតគួបសរុបនេះ គ្រឹះស្ថានចាំបាច់ត្រូវកំណត់ច្បាស់លាស់នូវមុខងារភារកិច្ច បែបបទរាយការណ៍ និងគណនេយ្យភាព។

**ប្រការ ២.- គោលបំណង**

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានគោលបំណង ផ្តល់លក្ខខណ្ឌប្រសើរបំផុត ដើម្បីធានាសុវត្ថិភាព ជំនឿទុកចិត្ត និងភាពគ្រប់ជ្រុងជ្រោយ ដើម្បី :

២.១. ធានាថាប្រតិបត្តិការ រចនាសម្ព័ន្ធ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានអនុលោមតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រមសីលធម៌ ទម្លាប់នៃការអនុវត្តប្រតិបត្តិការ និងយុទ្ធសាស្ត្រអាជីវកម្មដែលត្រូវបានកំណត់ដោយគណៈប្រតិបត្តិ។

២.២. ធានាឱ្យមានការប្រតិបត្តិតាមម៉ឹងម៉ាត់តាមនីតិវិធីនៃការសម្រេចចិត្ត និងគោលនយោបាយ និងនីតិវិធីនៃការទទួលយកហានិភ័យទោះជាហានិភ័យពាក់ព័ន្ធប្រភេទណាក៏ដោយ និងតាមបទដ្ឋាននៃការគ្រប់គ្រងដូចបានកំណត់ ឬអនុម័តដោយគណៈប្រតិបត្តិ។ ជាពិសេស គោលនយោបាយ និងនីតិវិធីទាំងនេះត្រូវមានទម្រង់ជាសកម្មភាពនិងប្រតិបត្តិការដែលត្រូវបានអនុញ្ញាតនិងហាមឃាត់ ព្រមទាំងកម្រិតកំណត់ដែលត្រូវអនុវត្តចំពោះប្រភេទហានិភ័យនីមួយៗជាដើម។

២.៣. ធានាគុណភាពនៃព័ត៌មានគណនេយ្យនិងហិរញ្ញវត្ថុ ទោះបីជាសម្រាប់គណៈប្រតិបត្តិ ឬអ្នកសម្រេចចិត្ត ឬអាជ្ញាធរត្រួតពិនិត្យ ឬការផ្សព្វផ្សាយជាសាធារណៈក្តី។

២.៤. ពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងឡាយក្នុងការវាយតម្លៃ កត់ត្រា រក្សាទុក និងផ្សព្វផ្សាយព័ត៌មានជាពិសេសដោយធានាថានីតិវិធី និងប្រព័ន្ធលំនាំសវនកម្ម (Audit Trail System) មានប្រសិទ្ធភាព និងអាចទាញយករាល់ឯកសារគតិយុត្ត ឬឯកសារគាំទ្រគណនេយ្យនៅគ្រាដំបូងនៃការចុះបញ្ជិកាទៅក្នុងប្រព័ន្ធគណនេយ្យ ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានវិទ្យា។

២.៥. ធានាគុណភាពនិងភាពសមស្របនៃប្រព័ន្ធព័ត៌មាន និងទំនាក់ទំនងនៅក្នុងគ្រឹះស្ថានទាំងនៅកម្រិតដាច់ដោយឡែកនិងកម្រិតគួបសរុប និងបើចាំបាច់ចំពោះអាជ្ញាធរ និងសវនករឯករាជ្យតាមរយៈការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃប្រចាំគ្រា។

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **"គណៈកម្មការសវនកម្ម"** :
ជាគណៈកម្មការដែលត្រូវបានបង្កើតឡើងដោយគណៈប្រតិបត្តិដើម្បីជួយក្នុងការបំពេញភារកិច្ច។ គណៈប្រតិបត្តិត្រូវកំណត់សមាជិកភាព ភារកិច្ច និងនីតិវិធី និងលក្ខខណ្ឌប្រតិបត្តិការសម្រាប់សវនករឯករាជ្យ សវនករផ្ទៃក្នុង និងបុគ្គលដទៃទៀតដែលពាក់ព័ន្ធនៅក្នុងការងាររបស់គណៈកម្មការសវនកម្ម។ គណៈកម្មការសវនកម្មត្រូវដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ឬសមាជិកគណៈប្រតិបត្តិម្នាក់ដែលមិនទទួលបន្ទុកផ្ទាល់ ក្នុងសកម្មភាពកំណត់ការទទួលយកហានិភ័យ ឬការអភិវឌ្ឍអាជីវកម្មរបស់គ្រឹះស្ថាន។
គណៈកម្មការសវនកម្មត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ឬគណៈសម្រេចដែលមានឋានៈស្មើ ហើយត្រូវមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖
  ក. ធានាថាព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធនឹងហានិភ័យមានភាពច្បាស់លាស់ និងវាយតម្លៃលើភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ និងវិធីវាយតម្លៃដែលត្រូវបានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុដាច់ដោយឡែក និងរួបសរុប (Consolidated) បើចាំបាច់។
  ខ. វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសចំពោះសង្គតភាពនៃប្រព័ន្ធវាស់វែងតាមដាន និងត្រួតពិនិត្យហានិភ័យ ព្រមទាំងលើកវិធានការជាអនុសាសន៍បន្ថែម បើចាំបាច់។
  គ. តាមដានប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវ ជាពិសេសឃ្លាំមើលអនុសាសន៍របស់សវនកម្មផ្ទៃក្នុងដែលមិនទាន់បានអនុវត្ត ឬអនុវត្តមិនទាន់សម្រេច និងបន្តជួយគាំទ្រដល់ការងាររបស់សវនកម្មផ្ទៃក្នុង។
- **"ផលិតផលថ្មី/សកម្មភាពថ្មី"** : សំដៅដល់ប្រតិបត្តិការថ្មី សេវាកម្មថ្មី ការចូលភាគកម្មថ្មី ការប្រើសេវាតតិយភាគីថ្មី ឬអ្វីផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរ/ការលើកកំពស់/ការអភិវឌ្ឍន៍ បច្ចេកវិទ្យាព័ត៌មាន ទិដ្ឋភាពគតិយុត្ត ការប្រតិបត្តិតាម និងការវាយតម្លៃហានិភ័យ កិច្ចការពារ អតិថិជន ការកែប្រែសំខាន់ៗលើគោលនយោបាយ នីតិវិធី/ដំណើរការនិងរចនាសម្ព័ន្ធ ការកែប្រែ និងការលើកកម្ពស់កិច្ចបញ្ជិកា និងប្លង់គណនីជាដើម ដែលប្រសិនបើមិនអនុវត្តឱ្យបានត្រឹមត្រូវទេនឹងអាចបង្កជាហានិភ័យប្រតិបត្តិការ ការប្រតិបត្តិតាមច្បាប់ ឬប្រភេទហានិភ័យផ្សេងទៀតរបស់គ្រឹះស្ថានដែលមិនអាចកំណត់អត្តសញ្ញាណបាន។ មុននឹងដាក់ឱ្យប្រើប្រាស់ផលិតផលថ្មី ឬអនុវត្តសកម្មភាពថ្មី ហានិភ័យទាំងនេះត្រូវតែបានវាយតម្លៃជាមុនដោយពិនិត្យទៅលើមុខងារពាក់ព័ន្ធ
ដូចជាប្រតិបត្តិការ ការទ្រទ្រង់ និងការត្រួតពិនិត្យ និងបើចាំបាច់ ចាត់វិធានការសមស្របដើម្បីដំណើរការត្រួតពិនិត្យ តាមដាន គ្រប់គ្រង និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងសកម្មភាព និងផលិតផលថ្មីនោះ។

- **"គណៈប្រតិបត្តិ"** : សំដៅដល់ក្រុមប្រឹក្សាភិបាលចំពោះក្រុមហ៊ុនសាជីវកម្ម ដែលការទទួលខុសត្រូវប្រតិបត្តិ ផ្អែកតែលើក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាប្រតិបត្តិចំពោះក្រុមហ៊ុនសាជីវកម្មដែលមានក្រុមប្រឹក្សាត្រួតពិនិត្យ។
- **"ការវាយតម្លៃទម្រង់ហានិភ័យ"** : (Supervisory risk-profile assessment) : ការវិភាគគ្រប់ជ្រុងជ្រោយលើស្ថានភាពរបស់គ្រឹះស្ថាន ដោយផ្អែកលើរាល់ទិន្នន័យ និងព័ត៌មានដែលបានផ្តល់ឱ្យអាជ្ញាធរត្រួតពិនិត្យ។ ការវាយតម្លៃនេះមានគោលបំណងវាយតម្លៃរាល់ហានិភ័យរបស់គ្រឹះស្ថាន (ជាពិសេស សាធនភាព សាច់ប្រាក់ងាយស្រួល ឥណទាន/សមភាគី(Counterparty) ទីផ្សារ និងអត្រាការប្រាក់) រួមទាំងកត្តាផ្សេងៗទៀតដូចជា គុណភាពសវនកម្មផ្ទៃក្នុង ហានិភ័យប្រមូលផ្តុំអាជីវកម្មប្រមូលផ្តុំ ការផ្តល់មូលនិធិប្រមូលផ្តុំ សមត្ថភាពក្នុងការទប់ទល់នឹងការវិវត្តន៍ជាអវិជ្ជមាននៃទីផ្សារ និងអាជីវកម្ម រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ និងប្រសិទ្ធភាពធនធានមនុស្សគ្រប់គ្រាន់ ការបែងចែកមុខងារភារកិច្ច សក្តានុពលនៃទំនាស់ផលប្រយោជន៍ ឯករាជ្យភាពនៃមុខងារ "គន្លឹះ" ប្រសិទ្ធភាពនៃបែបបទរាយការណ៍ ដំណើរការនិងហេដ្ឋារចនាសម្ព័ន្ធ ព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន អភិបាលកិច្ចសាជីវកម្ម ការគាំទ្ររបស់ភាគទុនិក ផែនការយថាភាព នីតិវិធី និងប្រសិទ្ធភាពនៃដំណោះស្រាយបើកអាប់ (back up) តាមរយៈការសាកល្បងប្រចាំគ្រា។
- **"ការវាយតម្លៃទម្រង់ហានិភ័យរួបសរុប"** : ជាការវាយតម្លៃទម្រង់ហានិភ័យដែលធនាគារជាតិនៃកម្ពុជាអនុវត្តនៅកម្រិតរួបសរុប ក្នុងនាមខ្លួនជាអ្នកត្រួតពិនិត្យរួបសរុប។ ក្នុងករណីចាំបាច់ ការវាយតម្លៃនេះក៏ត្រូវអនុវត្តចំពោះកម្រិតនៃកុងក្លូមេរ៉ាហិរញ្ញវត្ថុ (Financial Conglomerate) ផងដែរ។
- **"ហានិភ័យឥណទាន/ហានិភ័យសមភាគី"** : ហានិភ័យទាំងនេះកើតឡើងដោយសារតែការខកខានមិនគោរពតាមកិច្ចសន្យានៃសមភាគីណាមួយ ឬនៃសមភាគីច្រើនដែលរួមគ្នាជា " អត្តគាហកៈ " តែមួយដូចដែលបានចែងនៅក្នុងប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ហានិភ័យបែបនេះត្រូវតែបានពិចារណាជារួម ទាំងចំពោះស្ថានភាពក្នុងតារាងតុល្យការ និងទាំងការសន្យានិងយថាភាពផ្សេងៗនៅក្រៅតារាងតុល្យការ។
- **"ហានិភ័យទីផ្សារ"** : ជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុកើតឡើងពីបម្រែបម្រួលថ្លៃទ្រព្យសកម្មនៅលើទីផ្សាររូបិយវត្ថុ ទីផ្សារទុននិងហិរញ្ញវត្ថុ។ ហានិភ័យទីផ្សាររួមបញ្ចូលទាំងហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យដើមទុន និងហានិភ័យពាក់ព័ន្ធនឹងទំនិញ។
- **"ហានិភ័យអត្រាការប្រាក់"** : ជាហានិភ័យនៃប្រតិបត្តិការដែលមាននៅក្នុងបញ្ជិកាធនាគារ (Banking book transactions) ទាំងក្នុងនិងក្រៅតារាងតុល្យការ នៅពេលមានបម្រែបម្រួលអត្រាការប្រាក់ដែលកើតឡើងពីអតុល្យភាពរវាងលក្ខខណ្ឌនៃការទទួលទុន និងការឱ្យខ្ចី។ ហានិភ័យនេះប៉ះពាល់ដោយផ្ទាល់ទៅលើគម្លាតការប្រាក់សុទ្ធរបស់គ្រឹះស្ថាន ដែលគណៈកម្មការជាក់លាក់មួយ ដូចជាគណៈកម្មការគ្រប់គ្រងទ្រព្យសកម្មនិងទ្រព្យអកម្មជាដើម ត្រូវតាមដាន និងគ្រប់គ្រងឱ្យបានត្រឹមត្រូវរួមជាមួយនឹងស្ថានភាពសាច់ប្រាក់ងាយស្រួលជារួម។ បញ្ជិកាធនាគារសំដៅដល់ខ្នង់ចំណូល និងចំណាយការប្រាក់នៅលើមូលដ្ឋានបង្គរ។ ហានិភ័យអត្រាការប្រាក់ដែលពាក់ព័ន្ធនឹងបម្រែបម្រួលថ្លៃ

ឧបករណ៍អាចជួញដូរបាន ដែលកើតឡើងពីការចុះបញ្ជិកាតាមថ្លៃទីផ្សារ ឬថ្លៃសមស្រប ត្រូវតែបានចាត់ទុកជាហានិភ័យទីផ្សារ។

- **"ហានិភ័យសាច់ប្រាក់ងាយស្រួល"** : ជាហានិភ័យក្នុងលក្ខខណ្ឌទីផ្សារមួយ ដែលគ្រឹះស្ថានអាចពុំមានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួន ឬគ្មានលទ្ធភាពដោះស្រាយ (to unwind) ឬកាត់កងស្ថានភាពបំណុលមួយដែលជាលទ្ធផលគ្រឹះស្ថាននោះត្រូវបានចាត់ទុកថាខកខានមិនគោរពកិច្ចសន្យាដោយអ្នកចូលរួមទីផ្សារដទៃទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួលត្រូវគិតទាំងសាច់ប្រាក់ជារូបិយវត្ថុនិងរូបិយប័ណ្ណ និងទាំងទ្រព្យសកម្មចុះបញ្ជីឬជួញដូរផ្សេងៗ ដែលគ្រឹះស្ថានកំពុងមានប្រតិបត្តិការ។
- **"ហានិភ័យទូទាត់"/ "ហានិភ័យប្រគល់"** : ជាហានិភ័យដែលការទូទាត់នៅក្នុងប្រព័ន្ធទូទាត់មិនបានកើតឡើងដូចបានរំពឹងទុក។ ហានិភ័យនេះកើតឡើងក្នុងអំឡុងពេលដែលបញ្ជាទូទាត់សងប្រាក់ឬបញ្ជាប្រគល់ឧបករណ៍ហិរញ្ញវត្ថុមួយដែលបានទិញ/លក់ ហើយដែលមិនអាចត្រូវបានលុបចោលវិញជាឯកតោភាគី និងក្នុងអំឡុងពេលនៃការទទួលសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុជាបញ្ចប់។
- **"ហានិភ័យប្រតិបត្តិការ"**: ជាហានិភ័យកើតឡើងពីភាពមិនគ្រប់គ្រាន់ ឬកំហុសឆ្គងពីនីតិវិធីផ្ទៃក្នុងបុគ្គលិក (Personnel) ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឬកត្តាខាងក្រៅផ្សេងទៀត។
- **"ហានិភ័យគតិយុត្ត"** : ជាហានិភ័យកើតឡើងពីវិវាទរវាងសមភាគីណាមួយដែលបណ្ដាលមកពីភាពមិនច្បាស់លាស់ ភាពមិនត្រឹមត្រូវ ឬភាពទន់ខ្សោយ ឬអ្វីផ្សេងទៀត ដែលអាចកើតឡើងចំពោះគ្រឹះស្ថាននៅក្នុងពេលធ្វើប្រតិបត្តិការ។ ហានិភ័យគតិយុត្តជាប្រភេទហានិភ័យមួយស្ថិតនៅក្រោមហានិភ័យប្រតិបត្តិការ។
- **"ហានិភ័យអន្តរការិយកម្ម"** : ជាហានិភ័យដែលសមភាគីដើម (Principal) ឬសមភាគីខកខានមិនគោរពតាមកិច្ចសន្យាពាក់ព័ន្ធនឹងប្រតិបត្តិការ ឧបករណ៍ហិរញ្ញវត្ថុដែលគ្រឹះស្ថានបានធានាការប្រគល់ ឬការទូទាត់បញ្ចប់នូវឧបករណ៍ហិរញ្ញវត្ថុនោះ។
- **"ផែនការនិរន្តភាពអាជីវកម្ម"** : គឺជាសំណុំវិធានការ និងនីតិវិធីសម្រាប់ធានានិរន្តភាពអាជីវកម្មសំខាន់ៗ របស់គ្រឹះស្ថានដោយផ្អែកលើសេណារីយ៉ូនៃវិបត្តិផ្សេងៗ រួមមានការប៉ះទង្គិចធ្ងន់ធ្ងរ ឬស្ថានភាពមិនអំណោយផល តាមការសមស្របនិងជាបណ្ដោះអាសន្នទៅតាមករណី ប៉ុន្តែវិធានការទាំងនោះត្រូវមានគោលដៅបន្តអនុវត្តប្រតិបត្តិការជាធម្មតាឡើងវិញឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។ ផែនការនិរន្តភាពអាជីវកម្មនេះអាចត្រូវបានបំបែកជា "ផែនការយថាភាព" ជាច្រើនដូចជា "ផែនការយថាភាពនៃសាច់ប្រាក់ងាយស្រួល" "ផែនការយថាភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបើកអាប់" ឬ "ផែនការគ្រប់គ្រងវិបត្តិ" ជាដើម។
- **"ហានិភ័យនៃការមិនប្រតិបត្តិតាម"** : ជាហានិភ័យនៃការទទួលរងវិធានការខាងវិន័យ វិធានការរដ្ឋបាល ឬទណ្ឌកម្មតាមផ្លូវតុលាការ ឬជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរ ឬការបាត់បង់កិត្តិសព្ទ ដែលកើតឡើងពីការមិនគោរពតាមច្បាប់ និងបទបញ្ញាជាធរមាន បទដ្ឋានវិជ្ជាជីវៈនិងក្រមសីលធម៌ បទបញ្ញារបស់អាជ្ញាធរទីផ្សារ ពាក់ព័ន្ធនឹងសកម្មភាពធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយនិងសេចក្តីណែនាំផ្សេងៗ ដែលចេញដោយគ្រឹះស្ថាន។

- **"សកម្មភាពរបស់តតិយភាគី"** (Outsourced activities) : ជាសកម្មភាពដែលគ្រឹះស្ថានបានទុកចិត្តផ្តល់សេវាកម្មសំខាន់ៗមួយចំនួនឱ្យតតិយភាគីជាអ្នកប្រតិបត្តិជំនួស តាមរយៈការចុះកិច្ចសន្យាបន្តផ្តល់នូវសេវាកម្ម និងធ្វើសកម្មភាពទាំងនោះជាអចិន្ត្រៃយ៍ និងជាប្រក្រតី។ សេវាកម្ម និងសកម្មភាពសំខាន់ៗទាំងនោះសំដៅលើសេវាកម្ម ឬសកម្មភាពដែលការអនុវត្តមិនបានទាន់ពេលវេលាដោយភាគីនៃកិច្ចសន្យាបន្តនាំឱ្យមានការបង្អាក់ដល់ប្រតិបត្តិការប្រក្រតីរបស់គ្រឹះស្ថាន និងអាចនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពបំពេញកាតព្វកិច្ចឬកិត្តិសព្ទរបស់គ្រឹះស្ថាន។
- **"ហានិភ័យប្រមូលផ្តុំ"** : ជាហានិភ័យដោយផ្ទាល់ឬដោយប្រយោល ដែលបណ្តាលពីហានិភ័យចំពោះសមភាគី/ក្រុម ឬសមភាគីពាក់ព័ន្ធផ្សេងទៀតតែមួយ ចំពោះអ្នកចេញផ្សាយតែមួយនៃមូលបត្រចំពោះវិស័យសេដ្ឋកិច្ច/តំបន់ភូមិសាស្ត្រនិងប្រទេសតែមួយ និងចំពោះប្រភេទទ្រព្យសកម្ម ឬវត្ថុបញ្ចាំណាមួយ ឬជាហានិភ័យដែលកើតឡើងពីហានិភ័យធំៗ ចំពោះសមភាគីមួយដែលគ្រឹះស្ថានមានប្រតិបត្តិការជាមួយដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗ។
- **"នីតិវិធី វិស្សលប្លូវីង"** (Whistle blowing procedure) : ជានីតិវិធីសម្រាប់ដោះស្រាយស្ថានភាពទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬជាសក្តានុពល ឬការមិនប្រតិបត្តិតាម ដែលកើតមានក្នុងដំណើរការប្រតិបត្តិការជាប្រក្រតីតាមរយៈការដាក់ចេញនូវបែបបទរាយការណ៍ឯករាជ្យនិងសមស្រប និងការបង្កើតវិធានការពារចំពោះមន្ត្រីបុគ្គលិក ដែលបំពេញភារកិច្ចដោយសុចរិត និងដើម្បីផលប្រយោជន៍របស់គ្រឹះស្ថានទាំងមូល។

## ជំពូក ២
## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

### ប្រការ ៤.- ភារទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់

៤.១. ក្រុមប្រឹក្សាភិបាលមានភារកិច្ចបង្កើតក្របខណ្ឌទូទៅសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសមស្របអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ។ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ក្នុងគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព ហើយត្រូវវាយតម្លៃប្រចាំគ្រា និងកែលម្អ បើចាំបាច់។

៤.២. ក្រុមប្រឹក្សាភិបាលត្រូវបង្កើតគណៈកម្មការជាន់ខ្ពស់ ដែលស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន តែងតាំងសមាជិកភាព កំណត់ច្បាស់លាស់នូវមុខងារភារកិច្ចរបស់គណៈកម្មការទាំងនោះ និងលក្ខខណ្ឌផ្សេងៗដែលប្រធានគណៈកម្មការត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។ ក្រៅពីគណៈកម្មការដែលបានកំណត់នៅក្នុងប្រកាសស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាល ត្រូវពិចារណាបង្កើតគណៈកម្មការផ្សេងទៀត បើចាំបាច់ ឱ្យស្របតាមភាពស្មុគស្មាញ ទំហំប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ក្នុងគោលដៅទទួលយក និងគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន។

៤.៣. គោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ត្រូវមានចែងផងដែរអំពីលក្ខខណ្ឌសម្រាប់ការអនុវត្តសកម្មភាពថ្មី ការផ្តល់សេវាកម្មថ្មី ឬការចូលរួមភាគកម្មផ្នែកហិរញ្ញវត្ថុថ្មីរបស់គ្រឹះស្ថាន។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវលើដំណើរការវាយតម្លៃហានិភ័យជាដំបូងនេះ និងក្នុងករណីចាំបាច់ត្រូវពិភាក្សាក្នុងគណៈកម្មការផលិត

ផលថ្មី និងសកម្មភាពថ្មី (New Activities and Products Committee) ផងដែរក្នុងគោលដៅធានាភាពសមស្រប និងសមត្ថភាពរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ មុខងារគណនេយ្យ និងការរាយការណ៍ ព្រមទាំងនីតិវិធីប្រតិបត្តិតាម មុននឹងអនុវត្តសកម្មភាពថ្មី និងការចូលរួមភាគកម្មថ្មីទាំងនេះ។

រាល់ការវាយតម្លៃនិងអនុសាសន៍ពាក់ព័ន្ធ ត្រូវបានធ្វើឡើងជាផ្លូវការ និងដាក់ជូនក្រុមប្រឹក្សាភិបាល។ កំណត់ហេតុប្រជុំរបស់គណៈកម្មការទាំងឡាយត្រូវតែបានរក្សាទុកជាឯកសារ និងផ្ញើជូនអាជ្ញាធរត្រួតពិនិត្យ សវនករផ្ទៃក្នុង និងសវនករឯករាជ្យ តាមការស្នើសុំ។

ប្រសិនបើអនុសាសន៍នោះលើកឡើងអំពីលក្ខខណ្ឌដំបូងដែលត្រូវបំពេញ ឬអំពីដំណាក់កាលសាកល្បង គោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានចែងនូវនីតិវិធីផ្សេងៗ សម្រាប់វាយតម្លៃលើប្រសិទ្ធភាពមុននឹង អនុវត្តសកម្មភាពថ្មី និងផ្តល់សេវាកម្មថ្មី ព្រមទាំងមុននឹងអនុវត្តផែនការវិនិយោគតាមរយៈការចូលរួមភាគកម្ម ហិរញ្ញវត្ថុ ឬបង្កើតបុគ្គលសម្ព័ន្ធ។ ដំណើរការគ្រប់គ្រងហានិភ័យ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងត្រូវធ្វើឡើងនៅ កម្រិតរួបសរុបក្នុងករណីបុគ្គលសម្ព័ន្ធ និងការចូលរួមភាគកម្ម។ ជាពិសេសទៅទៀត ផលប៉ះពាល់ជាសក្តានុពល លើស្ថានភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងសាធនភាព និងសាច់ប្រាក់ងាយស្រួលត្រូវតែបានវាយតម្លៃយ៉ាង ប្រុងប្រយ័ត្ន និងទាមទារការយកចិត្តទុកដាក់ខ្ពស់ពីក្រុមប្រឹក្សាភិបាល។

៤.៤. ជាគោលការណ៍ទូទៅ ប្រធានគណៈកម្មការជាន់ខ្ពស់ដែលទទួលបន្ទុកការងារត្រួតពិនិត្យផ្ទៃក្នុង សវនកម្មផ្ទៃក្នុង ការបង្កើតផលិតផលថ្មី និងសកម្មភាពថ្មី ការគ្រប់គ្រងហានិភ័យ និងគណៈកម្មការតែងតាំងនិង ផ្តល់តម្លៃការ ត្រូវជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ដែលមិនពាក់ព័ន្ធនឹងការគ្រប់គ្រងឬការអភិវឌ្ឍអាជីវកម្ម ឬប្រតិបត្តិការប្រចាំថ្ងៃរបស់គ្រឹះស្ថាន។ រចនាសម្ព័ន្ធ និងការជ្រើសរើសប្រធានគណៈកម្មការនីមួយៗត្រូវតែបាន ធ្វើឡើងដោយពិចារណាជានិច្ចដល់ទំនាស់ផលប្រយោជន៍ជាសក្តានុពល និងត្រូវបម្រើគោលបំណងផ្តល់ព័ត៌មាន ទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពជូនក្រុមប្រឹក្សាភិបាល និងជួយទ្រទ្រង់ដល់ការសម្រេចចិត្តដ៏ត្រឹមត្រូវ។

៤.៥. ក្រុមប្រឹក្សាភិបាលត្រូវរៀបចំផងដែរនូវគោលនយោបាយទទួលយកហានិភ័យដែលត្រូវតែបាន ពិនិត្យឡើងវិញដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និងបើចាំបាច់ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមគ្រឹះស្ថាន ឬគ្រឹះស្ថានកុងគ្លូមេរ៉ាហិរញ្ញវត្ថុ និងការអភិវឌ្ឍទីផ្សារ។ ជាពិសេស គោលនយោបាយ ទាំងនេះត្រូវកំណត់អំពីសកម្មភាពហាមឃាត់ គោលការណ៍ទទួលយកនិងបញ្ចៀសហានិភ័យ (risk tolerance and aversion principles) ជាបឋមក្រោមរូបភាពជាខែល ហានិភ័យសាច់ប្រាក់ងាយស្រួល និងសាធនភាព អប្បបរមា (solvency buffers) កម្រិតកំណត់លើហានិភ័យប្រមូលផ្តុំ និងគោលនយោបាយដោះស្រាយ ស្ថានភាពវិបត្តិ (ផែនការយថាភាព)។ គោលនយោបាយទាំងនេះត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រា ហើយមន្ត្រី មុខងារប្រតិបត្តិតាម (compliance functions) ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវការវាយតម្លៃដែលមានគោល ដៅដើម្បីធានានូវការយល់ច្បាស់លាស់ និងការអនុវត្តបានពេញលេញនូវគោលនយោបាយនោះ។

៤.៦. ក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវក្នុងការផ្តល់ធនធានមនុស្សគ្រប់គ្រាន់ និងមានគុណវុឌ្ឍិ ដើម្បីបំពេញតួនាទីត្រួតពិនិត្យផ្ទៃក្នុងនេះជាអចិន្ត្រៃយ៍ និងប្រចាំគ្រា។ ក្នុងគោលដៅទទួលយក និងគ្រប់គ្រង ហានិភ័យដោយប្រុងប្រយ័ត្ន ធនធានទាំងនេះត្រូវឱ្យស្របតាមភាពស្មុគស្មាញ ទំហំប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់ គ្រឹះស្ថាន។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធានាដែរថាសវនកម្មផ្ទៃក្នុងអាចប្រព្រឹត្តិទៅដោយឯករាជ្យតាមរយៈ ១) ការ មានបុគ្គលិកគ្រប់គ្រាន់ ២) ការមានលទ្ធភាពពេញលេញក្នុងការទទួលបានព័ត៌មាន និងទិន្នន័យចាំបាច់សម្រាប់

បំពេញបេសកកម្មរបស់ខ្លួនក្នុងគ្រឹះស្ថានទាំងមូល និង ៣) ការបំពាក់នូវបច្ចេកវិទ្យាព័ត៌មានសមស្រប លទ្ធភាពប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ការបណ្តុះបណ្តាលធនធានសម្រាប់រៀបចំវិធីសាស្ត្រ និងផែនការសវនកម្ម ។

**ប្រការ ៥.- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង : ការត្រួតពិនិត្យអចិន្ត្រៃយ៍ និងប្រចាំគ្រា**

៥.១. ក្រុមប្រឹក្សាភិបាល ឬគណៈដែលមានឋានៈស្មើ ត្រូវអនុម័តគោលនយោបាយ និងរចនាសម្ព័ន្ធជារួម ពាក់ព័ន្ធនឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន។ ប្រព័ន្ធនេះត្រូវមានបញ្ចូលទាំងមុខងារត្រួតពិនិត្យជាអចិន្ត្រៃយ៍ និងប្រចាំគ្រា។

៥.២. ការត្រួតពិនិត្យអចិន្ត្រៃយ៍ត្រូវបានបង្កើត និងរៀបចំឡើង ដើម្បីត្រួតពិនិត្យជាប្រចាំនូវ :

ក. ការប្រតិបត្តិតាមច្បាប់និងបទបញ្ញាជាធរមាន បទដ្ឋានវិជ្ជាជីវៈនិងក្រមសីលធម៌ និងបទបញ្ញាដោយឡែកផ្សេងទៀតចេញដោយអាជ្ញាធរទីផ្សារ ដែលទាក់ទងនឹងសកម្មភាពធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយ និងការណែនាំផ្សេងៗរបស់គណៈមានសិទ្ធិសម្រេច (decision-making body) ។

ខ. អត្ថិភាពនិងប្រសិទ្ធភាពនៃនីតិវិធីនិងដំណើរការ ដើម្បីជៀសវាង ឬដោះស្រាយស្ថានភាពទំនាស់ផលប្រយោជន៍ បើចាំបាច់។

គ. ការអនុម័តសុវត្ថិភាព និងការធ្វើសុពលភាពនៃប្រតិបត្តិការដែលបានបញ្ចប់ស្របតាមគោលនយោបាយ នីតិវិធី និងដំណើរការដែលមានស្រាប់ ពាក់ព័ន្ធនឹងសិទ្ធិអំណាច ការបែងចែកភារកិច្ច និងឯករាជ្យភាពនៃការសម្រេចចិត្ត និងការពិនិត្យឡើងវិញ។

ឃ. ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងជាក់លាក់ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ ការវាស់វែង កម្រិតកំណត់ និងការតាមដាននូវរាល់ប្រភេទហានិភ័យដែលពាក់ព័ន្ធនឹងសកម្មភាពនិងប្រតិបត្តិការរបស់គ្រឹះស្ថាន។

៥.៣. គ្រឹះស្ថានត្រូវមានធនធានមនុស្សសមរម្យទាំងបរិមាណនិងគុណភាព រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផងដែរ សម្រាប់ការត្រួតពិនិត្យអចិន្ត្រៃយ៍ ដែលត្រូវតែបានអនុវត្តតាមរយៈការចាត់តាំង ដូចតទៅះ

ក. មន្ត្រីបុគ្គលិកដែលមានឋានានុក្រមសមស្របនឹងរចនាសម្ព័ន្ធចាត់តាំង ដោយមានការទទួលខុសត្រូវត្រួតពិនិត្យច្បាស់លាស់ និងមិនមានទំនាស់ផលប្រយោជន៍ជាមួយការទទួលខុសត្រូវផ្នែកប្រតិបត្តិការផ្សេងទៀតរបស់គ្រឹះស្ថាន ឬ

ខ. មន្ត្រីបុគ្គលិកដែលមានភារកិច្ចអនុវត្តតែការត្រួតពិនិត្យអចិន្ត្រៃយ៍ប៉ុណ្ណោះ ហើយដែលត្រូវការរាយការណ៍ដោយផ្ទាល់ ឬដោយប្រយោល តែដោយឯករាជ្យភាពជូនសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យម្នាក់ ឬគណៈមានឋានៈស្មើ ឬ

គ. មន្ត្រីបុគ្គលិកដែលមានភារកិច្ចផ្នែកប្រតិបត្តិការ ដែលភារកិច្ចនោះពុំមានទំនាស់ផលប្រយោជន៍ ជាមួយមុខងារត្រួតពិនិត្យ និងដែលបានចែកដាច់ដោយឡែកនិងច្បាស់លាស់ពីមុខងារប្រតិបត្តិការ ឬ

ឃ. បន្សំណាមួយនៃវិធីទាំងបីខាងលើដែលសមស្របតាមប្រភេទ ភាពស្មុគស្មាញ និងទំហំហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃ និងដោយអាស្រ័យលើរចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន។

៥.៤. សវនកម្មផ្ទៃក្នុងត្រូវអនុវត្តការត្រួតពិនិត្យប្រចាំគ្រាដែលត្រូវមានឯករាជ្យភាពពីមុខងារត្រួតពិនិត្យអចិន្ត្រៃយ៍ និងពីផ្នែកប្រតិបត្តិការ។ លើសពីនេះ សវនកម្មផ្ទៃក្នុងមិនត្រូវទទួលខុសត្រូវលើការងារណាដែលមានទំនាស់ផលប្រយោជន៍ និងអាចរំខានដល់ឯករាជ្យភាពនៃការវាយតម្លៃឡើយ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ទៅប្រធានគណៈកម្មការសវនកម្ម។

៥.៥. គ្រឹះស្ថានត្រូវស្នើសុំការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា មុននឹងធ្វើការតែងតាំងជាផ្លូវការនូវប្រធានសវនកម្មផ្ទៃក្នុង និងប្រធានមុខងារប្រតិបត្តិតាម ដោយត្រូវភ្ជាប់មកជាមួយនូវប្រវត្តិរូប ការពិពណ៌នាលំអិតអំពីសាវតាវិជ្ជាជីវៈនិងបទពិសោធន៍ វិញ្ញាបនបត្របញ្ជាក់ការសិក្សា ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត។ ធនាគារជាតិនៃកម្ពុជា អាចជូនដំណឹងអំពីការបដិសេធរបស់ខ្លួន ចំពោះការតែងតាំងនោះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលឯកសារត្រឹមត្រូវពេញលេញស្តីពីការតែងតាំង។ ធនាគារជាតិនៃកម្ពុជា មានសិទ្ធិធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយ ឬលើកសំណើផ្សេងៗទៅកាន់ប្រធានសវនកម្មផ្ទៃក្នុងនិងប្រធានមុខងារប្រតិបត្តិតាម។ រាល់ការផ្លាស់ប្តូរ បញ្ឈប់ ឬបណ្តេញចេញ នូវប្រធានសវនកម្មផ្ទៃក្នុង និងប្រធានមុខងារប្រតិបត្តិតាម ត្រូវតែបានជូនដំណឹងជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ហើយសេចក្តីសម្រេចនេះត្រូវតែបានធ្វើឡើងដោយមានហេតុផលសមរម្យ ( duly motivated ) និងត្រូវរាយការណ៍ច្បាស់លាស់ជូនធនាគារជាតិនៃកម្ពុជា។

៥.៦. ចំពោះក្រុមហិរញ្ញវត្ថុនិងកុងគ្លូមេរ៉ាហិរញ្ញវត្ថុ មន្ត្រីបុគ្គលិកទទួលបន្ទុកសវនកម្មផ្ទៃក្នុង និងមុខងារប្រតិបត្តិតាមនៅកម្រិតគួបសរុបត្រូវមានកាតព្វកិច្ចរាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌ ៥.៥ ខាងលើ។ របាយការណ៍ទាំងនេះត្រូវតែមានភ្ជាប់ជាមួយនូវវចនាសម្ព័ន្ធចាត់តាំងគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងដែលអាចងាយយល់អំពីបែបបទរាយការណ៍ និងអំពីទំនាក់ទំនងជាមួយមន្ត្រីបុគ្គលិកទទួលបន្ទុកដទៃទៀតរបស់ស្ថាប័នផ្សេងៗដែលស្ថិតនៅក្នុងក្រុមគ្រឹះស្ថាន ឬ កុងគ្លូមេរ៉ាហិរញ្ញវត្ថុជាមួយគ្នា។

## ជំពូក ៣
## សេវាកម្មផ្តល់ដោយតតិយភាគី

### ប្រការ ៦.- សេវាកម្មផ្តល់ដោយតតិយភាគី ដែលមិនមែនជាសវនកម្មផ្ទៃក្នុង

៦.១. សេវាកម្មដែលផ្តល់ដោយតតិយភាគី( Outsourced activities and services ) ដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវៈ

ក. ស្ថិតក្រោមការត្រួតពិនិត្យលើការប្រតិបត្តិតាម ដើម្បីធានាថាសកម្មភាពទាំងនេះមិនត្រូវបានហាមឃាត់ដោយច្បាប់ឬបទបញ្ញាណាមួយឬដោយគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។

ខ. មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងតតិយភាគីនិងគ្រឹះស្ថាន។

គ. បានអនុវត្តក្នុងក្របខណ្ឌគោលនយោបាយផ្លូវការមួយ ស្តីពី ការត្រួតពិនិត្យអ្នកផ្តល់សេវាកម្មជាតតិយភាគីរបស់គ្រឹះស្ថាន។

៦.២. ក្នុងទំនាក់ទំនងជាមួយអ្នកផ្តល់សេវាកម្មជាតតិយភាគី គ្រឹះស្ថានត្រូវធានាថា តតិយភាគីនោះ

ក. ធានាកម្រិតគុណភាពដែលឆ្លើយតបនឹងប្រតិបត្តិការធម្មតានៃសេវាកម្ម ហើយក្នុងករណីមានហេតុការណ៍កើតឡើង តតិយភាគីត្រូវប្រើប្រាស់នីតិវិធី និងយន្តការយថាភាព (Contingency

procedures and mechanisms) សំដៅផ្តល់សេវាកម្មឡើងវិញក្នុងរយៈពេលមួយដែលគ្រឹះស្ថានអាចទទួលយកបាន។

ខ. អនុវត្តយន្តការបន្ទាន់ (emergency mechanisms) ក្នុងករណីមានការលំបាកធ្ងន់ធ្ងរប៉ះពាល់ដល់និរន្តភាពនៃសេវាកម្ម ឬគ្រឹះស្ថានត្រូវធានាថាផែនការនិរន្តភាពរបស់ខ្លួនបានគិតគូរទៅដល់សេណារីយ៉ូ ដែលក្នុងនោះតតិយភាគីគ្មានលទ្ធភាពផ្តល់សេវាដល់គ្រឹះស្ថានឡើងវិញបាន។

គ. មិនត្រូវកែប្រែធំដុំលើសេវាកម្មរបស់ខ្លួន ដោយគ្មានការយល់ព្រមជាមុនពីគ្រឹះស្ថានឡើយ និងក្នុងរយៈពេលសមស្របមួយដែលចាំបាច់សម្រាប់ចាត់វិធានការជំនួស។

ឃ. ប្រតិបត្តិតាមនីតិវិធីរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងការអនុវត្តការត្រួតពិនិត្យសេវាកម្មដែលផ្តល់ដោយតតិយភាគី។

ង. ផ្តល់ដល់គ្រឹះស្ថាននូវរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់អំពីសេវាកម្មរបស់ខ្លួន បើចាំបាច់ ហើយគ្រឹះស្ថានអាចចុះពិនិត្យដល់ទីកន្លែងស្របតាមកាតព្វកិច្ចបើកចំហរព័ត៌មានដែលបានកំណត់។

ច. ត្រូវរាយការណ៍ទៅគ្រឹះស្ថានជាប្រចាំអំពីដំណើរការផ្តល់សេវាកម្ម និងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

ឆ. ផ្តល់ដល់ធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មានចាំបាច់ ទាក់ទិននឹងការអនុវត្តភារកិច្ចរបស់ខ្លួន ហើយក្នុងករណីចាំបាច់ធនាគារជាតិនៃកម្ពុជាអាចធ្វើការត្រួតពិនិត្យ និងសម្ភាសន៍ផ្ទាល់នៅទីស្នាក់ការរបស់តតិយភាគី។

៦.៣. ផ្អែកលើការវាយតម្លៃហានិភ័យរបស់ខ្លួន សវនកម្មផ្ទៃក្នុងត្រូវធ្វើសវនកម្មឡើងវិញតាមគ្រា ដោយផ្តោតជាសំខាន់លើសេវាកម្មរបស់តតិយភាគី។ ភាពញឹកញាប់នៃសវនកម្មនេះត្រូវអាស្រ័យទៅនឹងហានិភ័យពាក់ព័ន្ធផ្សេងៗរបស់គ្រឹះស្ថាន។ ជាពិសេសការប្រតិបត្តិតាមបទប្បញ្ញត្តិដូចបានកំណត់ខាងលើ ត្រូវតែបានវាយតម្លៃជាក់លាក់រួមទាំងអត្ថិភាព សង្គតភាព និងប្រសិទ្ធភាពនៃយន្តការបន្ទាន់ និងផែនការយថាភាពផងដែរ។

## ប្រការ ៧.- សេវាកម្មតតិយភាគីចំពោះការធ្វើសវនកម្មផ្ទៃក្នុង

៧.១. ចំពោះគ្រឹះស្ថានខ្នាតតូចដែលស្ថិតនៅក្នុងក្រុមធនាគារ ឬក្រុមហិរញ្ញវត្ថុមួយ ក្រុមប្រឹក្សាភិបាលក្រោមការទទួលខុសត្រូវរបស់ខ្លួនអាចពិចារណាជ្រើសរើសតតិយភាគីសម្រាប់ការងារសវនកម្មផ្ទៃក្នុង។ ប៉ុន្តែតតិយភាគីនេះមិនត្រូវជាក្រុមហ៊ុនសវនកម្មឯករាជ្យដែលទទួលបន្ទុកធ្វើសវនកម្មលើគ្រឹះស្ថាននោះ ឬជាសម្ព័ន្ធរបស់ក្រុមហ៊ុននោះឡើយ។ មុននឹងជ្រើសរើសក្រុមហ៊ុនឯកទេសឬនាយកដ្ឋានសវនកម្មនៃក្រុមហ៊ុនមេរបស់ខ្លួនសម្រាប់ដំណើរការសវនកម្ម គ្រឹះស្ថានត្រូវតែសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវទិន្នន័យ និងព័ត៌មានចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្ត។

៧.២. នៅពេលសម្រេចជ្រើសរើសតតិយភាគីសម្រាប់ធ្វើសវនកម្មផ្ទៃក្នុង សមាជិកក្រុមប្រឹក្សាភិបាលដែលទទួលបន្ទុកត្រូវធានាថា :

ក. សេវាកម្មដែលតតិយភាគីផ្តល់ឱ្យគ្រឹះស្ថានសមស្របនឹងសកម្មភាព រចនាសម្ព័ន្ធ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់គ្រឹះស្ថាន។

ខ. សវនកម្មត្រូវអនុវត្តស្របតាមបទដ្ឋានល្អបំផុតនៃទីផ្សារ និងដោយអ្នកមានវិជ្ជាជីវៈដែលមានការសិក្សាជំនាញ និងបទពិសោធន៍ក្នុងការធ្វើសវនកម្ម។

គ. ថវិកាគ្រប់គ្រាន់សម្រាប់ធ្វើសវនកម្មផ្ទៃក្នុងដើម្បីធានាការគោរពតាមរាល់គោលការណ៍ ដូចដែលបានកំណត់ក្នុងប្រកាសនេះជាពិសេស ដើម្បីធានាឯករាជ្យភាពពេញលេញនៃសវនកម្ម ការវាយតម្លៃ និងអនុសាសន៍ និង

ឃ. តតិយភាគីមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើសវនកម្មលើគ្រប់ផ្នែកទាំងអស់នៃមុខងារ និងប្រតិបត្តិការស្របតាមផែនការសវនកម្មគ្រប់ជ្រុងជ្រោយ ដែលគ្របដណ្តប់លើរាល់ហានិភ័យ និងដែលតម្រូវដោយបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងប្រកាសនេះស្តីពី វដ្ត និងវិសាលភាពនៃសវនកម្ម។

៧.៣. លើសពីនេះ រាល់កាតព្វកិច្ចដូចមានចែងក្នុងប្រការ ៦ ពាក់ព័ន្ធនឹងសកម្មភាពរបស់តតិយភាគីត្រូវតែបានគោរពតាមយ៉ាងម៉ឺងម៉ាត់ ពីព្រោះសវនកម្មផ្ទៃក្នុងត្រូវបានចាត់ទុកថាជាសកម្មភាពសំខាន់ដូចមានចែងក្នុងប្រការ ៣។ ជាពិសេសផែនការយថាភាពសមស្របត្រូវមានចែងអំពីដំណោះស្រាយដទៃទៀត ដើម្បីជៀសវាងការបង្អាក់ ឬការពន្យារណាមួយ ក្នុងការបំពេញផែនការសវនកម្ម ក្រោមការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលទទួលបន្ទុក។

## ជំពូក ៤
## ការប្រតិបត្តិតាម

### ប្រការ ៨.- ការតែងតាំង និងការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាម

៨.១ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តរចនាសម្ព័ន្ធនៃមុខងារប្រតិបត្តិតាម (Compliance Function) ឱ្យបានសមស្រប ដើម្បីគាំទ្រដល់ការបំពេញភារកិច្ច និងការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព ស្របតាមទំហំភាពស្មុគស្មាញ បណ្តាញ ការចូលភាគកម្ម និងហានិភ័យពាក់ព័ន្ធនឹងអាជីវកម្មរបស់គ្រឹះស្ថាន។ មុខងារប្រតិបត្តិតាមត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាមម្នាក់ដែលមិនពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ជាសក្តានុពល។ មន្ត្រីមុខងារប្រតិបត្តិតាមត្រូវរាយការណ៍ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក។

៨.២. ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ឈប់ ការបណ្តេញចេញ ឬការលាលែងរបស់មន្ត្រីមុខងារប្រតិបត្តិតាម ត្រូវតែបានជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងចំណុច ៥.៥ និង ៥.៦ នៃប្រការ៥ ។

៨.៣. មន្ត្រីបុគ្គលិកទទួលបន្ទុកត្រួតពិនិត្យអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងគោលនយោបាយ "ស្គាល់អតិថិជនរបស់ខ្លួន" ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ត្រីមុខងារប្រតិបត្តិតាម។ អាស្រ័យលើរចនាសម្ព័ន្ធនៃមុខងារប្រតិបត្តិតាមគោលនយោបាយនិងនីតិវិធី ត្រូវតែអាចជួយគាំទ្រយ៉ាងពេញលេញចំពោះកិច្ចសហការរវាងមន្ត្រីមុខងារប្រតិបត្តិតាមនិងមន្ត្រីបុគ្គលិក ព្រមទាំងផ្នែកដទៃទៀតដែលពាក់ព័ន្ធនិងការត្រួតពិនិត្យការប្រតិបត្តិតាម ដូចជានាយកដ្ឋានហិរញ្ញវត្ថុ និងការរាយការណ៍គណនេយ្យ និងគតិយុត្តជាដើម។ មន្ត្រីមុខងារប្រតិបត្តិតាមត្រូវតែចូលរួមជាប្រព័ន្ធក្នុងការអនុវត្តនីតិវិធីវីស្ស៊លប្លូវីង (whistle blowing) ដូចមានចែងក្នុងប្រការ១១។

## ប្រការ ៩.- ប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាម

៩.១. ប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាមត្រូវតែបានបង្កើត និងរៀបចំឱ្យស្របតាមគោលនយោបាយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវតែមានដំណើរការ និងនីតិវិធីសមស្របប្រកបដោយប្រសិទ្ធភាពក្រោមការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាម ដូចមានចែងក្នុងប្រការ ៨។

៩.២. គ្រឹះស្ថានត្រូវផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់មន្ត្រីបុគ្គលិកដែលពាក់ព័ន្ធស្តីពីនីតិវិធីត្រួតពិនិត្យការប្រតិបត្តិតាមឱ្យស្របតាមប្រតិបត្តិការ និងការត្រួតពិនិត្យដែលមន្ត្រីទាំងនោះអនុវត្ត។

៩.៣. ប្រព័ន្ធនិងនីតិវិធីត្រួតពិនិត្យការប្រតិបត្តិតាមទាំងឡាយ ត្រូវតែបានរៀបចំឡើងដើម្បីទប់ស្កាត់ហានិភ័យនៃការមិនប្រតិបត្តិតាមដូចមានចែងក្នុងប្រការ ៣ និងដើម្បីដោះស្រាយឱ្យបានឆាប់បំផុតនូវបញ្ហា ឬការបារម្ភអំពីការមិនប្រតិបត្តិតាមជាសក្តានុពលណាមួយ។ ក្នុងគោលបំណងនេះ គ្រឹះស្ថានត្រូវបង្កើតនីតិវិធីនិងដំណើរការសម្រាប់វាយតម្លៃការប្រតិបត្តិតាមដែលរួមមាៈ

- នីតិវិធីសម្រាប់ការផ្តល់ការអនុម័តជាមុន និងជាប្រព័ន្ធ រួមទាំងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីមន្ត្រីមុខងារប្រតិបត្តិតាម ឬពីបុគ្គលទទួលសិទ្ធិពីមន្ត្រីមុខងារប្រតិបត្តិតាមក្នុងគោលបំណងនេះ ចំពោះផលិតផលថ្មីនិងសកម្មភាពថ្មី ការអនុវត្តឬការកែប្រែសំខាន់ៗទៅលើផលិតផល និងសេវាកម្មដែលមានស្រាប់ និង
- នីតិវិធីសម្រាប់ត្រួតពិនិត្យប្រតិបត្តិការ ដែលបានបញ្ចប់រួចហើយ។

៩.៤. ជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាម គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធតាមដានមួយអំពីការកែប្រែបទបញ្ញា ឬវិធានទាំងឡាយដែលត្រូវអនុវត្តទៅលើប្រតិបត្តិការរបស់គ្រឹះស្ថាន ដែលមានដំណើរការជាប្រក្រតី និងជាញឹកញាប់តាមដែលអាចអនុវត្តបាន ហើយក្នុងបរិការនេះជូនដំណឹងភ្លាមដល់មន្ត្រីបុគ្គលិកពាក់ព័ន្ធស្តីពីការកែប្រែទាំងនោះ។

# ជំពូក ៥
# ទំនាស់ផលប្រយោជន៍ : ការទប់ស្កាត់ និងដំណោះស្រាយ

## ប្រការ ១០.- នីតិវិធី និងយន្តការទប់ស្កាត់ទំនាស់ផលប្រយោជន៍

១០.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធី និងយន្តការដើម្បីទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍។ នីតិវិធីនិងយន្តការទាំងនេះត្រូវពឹងផ្អែកជាពិសេសលើវិធាន និងគោលការណ៍ច្បាស់លាស់ដែលត្រូវបានបង្កើតឡើងដូចជាឯករាជ្យភាពនៃការត្រួតពិនិត្យ ការបែងចែកមុខងារភារកិច្ច ការប្រគល់សិទ្ធិនិងគណនេយ្យ ភាពសមស្របឯករាជ្យភាពនៃដំណើរការផ្ទៀងផ្ទាត់គណនី ឬការជៀសវាងការលើកទឹកចិត្តជាអវិជ្ជមាន ក្រោមរូបភាពជាការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដែលអាចធ្វើឱ្យមានឥទ្ធិពលមិនល្អដល់ការគ្រប់គ្រង និងការជ្រើសរើសហានិភ័យដោយប្រុងប្រយ័ត្ន ការកាន់កាប់មូលបត្រ ការត្រួតពិនិត្យលើគុណភាពទ្រព្យសកម្ម/ស្ថានភាពសាច់ប្រាក់ងាយស្រួលនិងអសាធនភាពជាដើម។

១០.២. ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍ជាសក្តានុពល និងត្រូវវាយតម្លៃគោលនយោបាយនោះឡើងវិញប្រចាំគ្រា។ បើចាំបាច់គោលនយោបាយនេះត្រូវបានពិនិត្យឡើងវិញ និងកែលម្អស្របតាមការវាយតម្លៃប្រចាំគ្រានោះ។

១០.៣. មុខងារប្រតិបត្តិតាមត្រូវធានា ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ និងនីតិវិធីទាំងនោះ និងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុកនូវរាល់កំហុស ឬបញ្ហាដែលបានរកឃើញ។ ហេតុការណ៍កើតឡើងត្រូវមានកំណត់ត្រាជាឯកសារ ហើយត្រូវមានការផ្តល់អនុសាសន៍សម្រាប់ជាវិធានការកែតម្រូវផងដែរ។ រាល់វិធានការកែតម្រូវដែលបានដាក់ចេញត្រូវតែបានអនុវត្តតាមភ្លាមដោយគ្មានបង្អង់។

## ប្រការ ១១.- នីតិវិធីវីស្សលប្ល៉ូវីង

១១.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធីវីស្សលប្ល៉ូវីង “Whistle Blowing Procedures” ដូចមានចែង ក្នុងប្រការ ៣ ដែលត្រូវក្រសោបនូវតួនាទីរបស់មន្ត្រីមុខងារប្រតិបត្តិតាមផងដែរ ដែលត្រូវតែរក្សារបាយការណ៍ជាការសម្ងាត់ ជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក និងចាត់វិធានការដោះស្រាយសមស្រប។

១១.២. មន្ត្រីបុគ្គលិករបស់គ្រឹះស្ថានត្រូវយល់ដឹងច្បាស់លាស់អំពីដំណើរការ និងនីតិវិធីវីស្សលប្ល៉ូវីង និងត្រូវដឹងថានីតិវិធីនោះផ្តល់ការការពារចំពោះខ្លួន ប៉ុន្តែ ក៏ទាមទារនូវការបំពេញភារកិច្ចដោយសុចរិតផងដែរ។

# ជំពូក ៦
# សវនកម្មផ្ទៃក្នុង

## ប្រការ ១២.- រចនាសម្ព័ន្ធនៃសវនកម្មផ្ទៃក្នុង

១២.១. សវនកម្មផ្ទៃក្នុងត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង ដែលត្រូវបានចាត់តាំងស្របតាមបទប្បញ្ញត្តិនិងកាតព្វកិច្ចដូចមានចែងក្នុងចំណុច ៥.៥ និង៥.៦ នៃប្រការ ៥ នៃប្រកាសនេះ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានឯករាជ្យភាពពេញលេញ រាយការណ៍ផ្ទាល់ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក និងមិនត្រូវមានភារកិច្ចត្រួតពិនិត្យអចិន្ត្រៃយ៍ ឬការងារប្រតិបត្តិការឡើយ។ ជាពិសេស ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវទទួលបន្ទុកលើមុខងារប្រតិបត្តិតាមទេ ហើយដូចនេះគឺពុំអាចមានតួនាទីពីរទន្ទឹមគ្នាជាមន្ត្រីមុខងារប្រតិបត្តិតាមរបស់គ្រឹះស្ថានឡើយ។

១២.២. ប្រសិនបើសវនកម្មផ្ទៃក្នុងត្រូវបានធ្វើឡើងដោយតតិយភាគី រាល់លក្ខខណ្ឌនៃការប្រើប្រាស់តតិយភាគីនោះ ត្រូវតែគោរពតាមកាតព្វកិច្ចដូចមានចែងក្នុងប្រការ ៧ និងគោលការណ៍ដូចមានចែងក្នុងជំពូកនេះ។

១២.៣. មុខងារសវនកម្មផ្ទៃក្នុងត្រូវតែមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់ទាំងបរិមាណនិងគុណភាពស្របតាមទំហំ ភាពស្មុគស្មាញនៃអាជីវកម្ម និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ តាមករណីចាំបាច់ បែបបទរាយការណ៍ ការវាយតម្លៃការអនុវត្ត ការចាត់ចែងមន្ត្រីបុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងវិធីសាស្ត្រ និងនីតិវិធីសវនកម្មត្រូវធ្វើឡើងក្នុងកម្រិតជាក្រុម ។

## ប្រការ ១៣.- គោលបំណងនៃមុខងារសវនកម្មផ្ទៃក្នុង

១៣.១. សវនកម្មផ្ទៃក្នុង មានភារកិច្ចអនុវត្តការងារសវនកម្ម និងធ្វើការអង្កេតប្រចាំគ្រា និងគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងផ្ដល់ដល់ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងនូវការវាយតម្លៃនិងអនុសាសន៍ ដោយមានឯកសារគាំទ្រលើចំណុចដូចខាងក្រោម :

- ប្រសិទ្ធភាពនៃការកំណត់អត្តសញ្ញាណ វាស់វែង តាមដាន គ្រប់គ្រង ដាក់កម្រិតកំណត់ និងបើចាំបាច់ នីតិវិធីនិងដំណើរការកាត់បន្ថយហានិភ័យ។
- ប្រសិទ្ធភាពនៃនីតិវិធីនិងដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងភាពសមស្របនៃដំណើរការដែលបានបង្កើតឡើងដើម្បីទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍ ឬបើចាំបាច់ ដើម្បីដោះស្រាយស្ថានភាពនោះដោយប្រុងប្រយ័ត្ន និង
- ភាពសមស្របនិងប្រសិទ្ធភាពនៃការត្រួតពិនិត្យការប្រតិបត្តិតាម និងការគោរពពេញលេញ នូវគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។

១៣.២. ការងារសវនកម្ម ត្រូវមានផែនការប្រចាំឆ្នាំ និងត្រូវកំណត់អាទិភាពស្របតាមការវាយតម្លៃហានិភ័យរបស់សវនកម្មផ្ទៃក្នុង។ ផ្នែកហានិភ័យនិងអាទិភាពដែលបានកំណត់ត្រូវកត់ត្រាទុកជាឯកសារ និងគាំទ្រដោយវិធីសាស្ត្រវាយតម្លៃហានិភ័យដ៏សមស្រប ដែលត្រូវដាក់ជូននិងអនុម័តដោយក្រុមប្រឹក្សាភិបាល ឬគណៈកម្មការសវនកម្ម។ ការងារសវនកម្ម ត្រូវប្រព្រឹត្តិទៅក្នុងអំឡុងវដ្តសវនកម្មមួយដែលមានរយៈពេលខ្លីតាមដែលអាចធ្វើបាន និងត្រូវគ្របដណ្ដប់រាល់ផ្នែកហានិភ័យទាំងអស់របស់គ្រឹះស្ថាន។ ក្នុងអំឡុងវដ្តសវនកម្ម រាល់ផ្នែកហានិភ័យទាំងអស់ត្រូវតែបានធ្វើសវនកម្ម។ លើសពីនេះ ផ្នែកដែលមានហានិភ័យខ្ពស់ត្រូវរងសវនកម្មច្រើនដងនៅក្នុងវដ្តសវនកម្មទាំងមូល។

១៣.៣. រាល់បញ្ហា និងកង្វល់សំខាន់ៗពាក់ព័ន្ធនឹងសវនកម្ម ត្រូវមានកត់ត្រាជាឯកសារច្បាស់លាស់ដោយមានភ្ជាប់ជាមួយនូវអនុសាសន៍ចំពោះក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសំដៅដោះស្រាយបញ្ហានោះប្រកបដោយប្រសិទ្ធភាព និងដោយគ្មានការពន្យារមិនសមហេតុផល។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃវិធានការកែតម្រូវតាមអនុសាសន៍ត្រូវស្ថិតនៅក្រោមយន្តការតាមដានមួយ និងតាមករណីចាំបាច់ត្រូវអនុវត្តជាបន្តដើម្បីវាយតម្លៃប្រសិទ្ធភាពនៃវិធានការណ៍កែតម្រូវទាំងនេះ។ អនុសាសន៍ដែលមិនទាន់បានអនុវត្ត ចាំបាច់ត្រូវរាយការណ៍ប្រចាំគ្រា និងយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុកដែលជាប្រធានសវនករផ្ទៃក្នុង និងទៅសមាជិកគណៈកម្មការសវនកម្មឯទៀតតាមការស្នើសុំរបស់ប្រធានគណៈកម្មការសវនកម្ម។

## ប្រការ ១៤.- ធនធាន យុទ្ធសាស្ត្រ និងនីតិវិធីសវនកម្ម

១៤.១. សវនកម្មផ្ទៃក្នុង ត្រូវមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់សម្រាប់អនុវត្តវដ្តសវនកម្មប្រកបដោយប្រសិទ្ធភាព។ សវនករផ្ទៃក្នុងត្រូវមានថវិកាស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ចំណាយទាំងអស់ទាក់ទិននឹងការបណ្ដុះបណ្ដាលផ្នែកសវនកម្ម ដំណើរបេសកកម្ម និងចំណាយប្រើប្រាស់តតិយភាគីសម្រាប់បំពេញភារកិច្ចរបស់ខ្លួន។

១៤.២. ភាពគ្រប់គ្រាន់នៃមន្ត្រីបុគ្គលិកនិងទម្រង់សវនកម្មជាក់លាក់ ត្រូវបានវាយតម្លៃប្រចាំគ្រាស្របតាមកំណើនអាជីវកម្ម ភាពស្មុគ្រស្មាញនិងទំហំនៃប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំងសាជីវកម្ម បច្ចេកវិទ្យាដែលបានអនុវត្តនិងហានិភ័យពាក់ព័ន្ធផ្សេងៗ។ ការវាយតម្លៃនេះត្រូវធ្វើឡើងជាផ្លូវការ និងត្រូវរាយការណ៍ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក។

១៤.៣. ការវាយតម្លៃហានិភ័យនិងសវនកម្ម ត្រូវធ្វើឡើងស្របតាមបទដ្ឋានវិជ្ជាជីវៈ និងតាមករណីចាំបាច់ ត្រូវពិនិត្យឡើងវិញស្របតាមការអនុវត្តដ៏ល្អបំផុត និងត្រូវបានទ្រទ្រង់ដោយវិធីសាស្ត្រ នីតិវិធី និងក្បួនណែនាំផ្សេងៗជាលាយលក្ខណ៍អក្សរ។ ឯកសារ និងវិធីសាស្ត្រទាំងនេះអាចត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មការសវនកម្ម សវនករឯករាជ្យ និងអាជ្ញាធរត្រួតពិនិត្យ តាមការស្នើសុំ។

## ជំពូក ៧
## គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ

### ប្រការ ១៥.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

១៥.១. ក្រុមប្រឹក្សាភិបាលត្រូវបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យ សម្រាប់ទប់ទល់ប្រភេទហានិភ័យសំខាន់ៗកើតឡើងពីសកម្មភាព ភាពស្មុគស្មាញ និងទំហំរបស់គ្រឹះស្ថាន។ ការគោរពតាមគោលនយោបាយគ្រប់គ្រងហានិភ័យនេះជាប្រចាំ ត្រូវតែជាផ្នែកមួយនៃការត្រួតពិនិត្យរបស់មុខងារប្រតិបត្តិតាម ហើយគោលនយោបាយនេះក៏ជាផ្នែកមួយនៅក្នុងប្រព័ន្ធរក្សាទុកឯកសាររបស់គ្រឹះស្ថាន ដូចមានចែងក្នុងជំពូក១០ ផងដែរ។

១៥.២. គណៈគ្រប់គ្រងត្រូវទទួលខុសត្រូវបង្កើតនីតិវិធី និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃដំណើរការសមស្របសំដៅកំណត់អត្តសញ្ញាណ វាស់វែង តាមដាន ដាក់កម្រិតកំណត់ គ្រប់គ្រង និងតាមករណីចាំបាច់ កាត់បន្ថយហានិភ័យផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ នីតិវិធីនិងដំណើរការទាំងនេះត្រូវបានវាយតម្លៃ និងពិនិត្យឡើងវិញប្រចាំគ្រាស្របតាមការអនុវត្តដ៏ល្អបំផុត ការអភិវឌ្ឍន៍ទីផ្សារ និងអាជីវកម្មថ្មី។ ភាពគ្រប់គ្រាន់នៃនីតិវិធី និងដំណើរការជាក់លាក់ដែលបានអនុវត្តត្រូវបានវាយតម្លៃឡើងវិញជាប្រព័ន្ធមុននឹងអនុវត្តសកម្មភាពថ្មី ចូលរួមភាគកម្មថ្មី ព្រមទាំងមុននឹងផ្តល់ផលិតផល និងសេវាកម្មថ្មីដល់អតិថិជន និងសមភាគីទីផ្សាររបស់គ្រឹះស្ថាន។

### ប្រការ ១៦.- ប្រសិទ្ធភាពនៃនីតិវិធី ដំណើរការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន

១៦.១. នីតិវិធី ដំណើរការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានរៀបចំនិងបង្កើតឡើងស្របតាមគោលការណ៍របស់ក្រុមប្រឹក្សាភិបាលនៅក្នុងគោលនយោបាយពាក់ព័ន្ធផ្សេងៗ និងត្រូវស្ថិតក្រោមការវាយតម្លៃការប្រតិបត្តិតាម និងក្នុងករណីចាំបាច់ត្រូវបានពិនិត្យឡើងវិញផងដែរ។

១៦.២. ដើម្បីធានាប្រសិទ្ធភាព នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យនិងប្រព័ន្ធព័ត៌មានត្រូវ

ក. អាចកំណត់អត្តសញ្ញាណ វាស់វែង ឬវាយតម្លៃហានិភ័យបានត្រឹមត្រូវ។

ខ. ទ្រទ្រង់សេចក្ដីសម្រេច ស្របតាមវេទយិតភាពនៃហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសចំពោះការវិវត្តជាអវិជ្ជមាននៃទីផ្សារ ស្ថានភាពហិរញ្ញវត្ថុមិនល្អរបស់កូនបំណុល ឬរបស់សមភាគី និងជាទូទៅចំពោះការយកចិត្តទុកដាក់ដែលត្រូវមានក្នុងគោលបំណងគ្រប់គ្រងដ៏ប្រុងប្រយ័ត្ន ជាដើម។

គ. គួបសរុបហានិភ័យទាំងនោះ (Consolidation of such risks) ដើម្បីកំណត់អត្តសញ្ញាណតាមដាន និងគ្រប់គ្រងបញ្ហាហានិភ័យប្រមូលផ្ដុំប្រកបដោយប្រសិទ្ធភាព។

ឃ. បានរៀបចំនិងអនុវត្តតាមដែលអាចទ្រទ្រង់ពេញលេញនូវការទទួលខុសត្រូវ និងគណនេយ្យភាព ស្របតាមសិទ្ធអំណាច ការប្រគល់សិទ្ធ និងកម្រិតកំណត់ដែលអនុវត្តបាន និង

ង. ផ្ដល់សញ្ញាអាសន្នតាមឋានានុក្រម និងជូនក្រុមប្រឹក្សាភិបាល អំពីការមិនអនុវត្តកម្រិតកំណត់ ឬការប្រើប្រាស់សិទ្ធអំណាច និងការប្រគល់សិទ្ធលើសដែនកំណត់ សំដៅចាត់វិធានការកែតម្រូវបន្ទាន់តាមករណីចាំបាច់។

១៦.៣. ប្រសិទ្ធភាព និងភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រាជាឯករាជ្យដោយសវនករផ្ទៃក្នុងក្រោមការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងជាន់ខ្ពស់។ តាមករណីចាំបាច់ នីតិវិធីនិងដំណើរការ និងប្រព័ន្ធព័ត៌មានទាំងនេះត្រូវជួយដល់ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពនៅកម្រិតគួបសរុបផងដែរ។

១៦.៤. ភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានត្រូវបានវាយតម្លៃឡើងវិញជាប្រព័ន្ធមុននឹងអនុវត្តសកម្មភាពថ្មី ចូលរួមភាគកម្មថ្មី ព្រមទាំងមុននឹងផ្ដល់ផលិតផល និងសេវាកម្មថ្មីដល់អតិថិជន និងសមភាគីទីផ្សាររបស់គ្រឹះស្ថាន។

១៦.៥. ឯកសារស្ដីពីនីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានត្រូវតែបានធ្វើបច្ចុប្បន្នកម្ម និងជាផ្នែកមួយនៃប្រព័ន្ធរក្សាទុកឯកសារដូចមានចែងក្នុងជំពូក ១០ ខាងក្រោម។

## ជំពូក ៨
## ប្រព័ន្ធគណនេយ្យ និង ព័ត៌មាន

### ប្រការ ១៧.- ការប្រតិបត្តិតាមបទដ្ឋានច្បាប់និងបទប្បញ្ញត្តិ និង ការរក្សាទុកឯកសារ

១៧.១. គ្រឹះស្ថានត្រូវប្រតិបត្តិតាមបទដ្ឋានច្បាប់និងបទប្បញ្ញត្តិដែលអនុវត្ត ចំពោះកិច្ចបញ្ជិកាគណនេយ្យរបាយការណ៍ហិរញ្ញវត្ថុ និងការបើកចំហរព័ត៌មានហិរញ្ញវត្ថុ ព្រមទាំងត្រូវមានការត្រួតពិនិត្យសមស្រប ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការប្រតិបត្តិតាមបទដ្ឋានទាំងនេះ។ គណៈកម្មការសវនកម្មត្រូវពិភាក្សា និងអនុម័តដោយប្រុងប្រយ័ត្ននូវជម្រើសផ្សេងៗ ប្រសិនបើមាន ហើយជម្រើសនោះត្រូវបានទុកដាក់ជាឯកសារត្រឹមត្រូវ និងត្រូវគោរពតាមយ៉ាងហ្មត់ចត់។

១៧.២. គ្រឹះស្ថានត្រូវបង្កើត និងរក្សាទុកឱ្យបានគ្រប់គ្រាន់ នូវឯកសារអំពីប្លង់គណនីដែលបានអនុវត្តកិច្ចបញ្ជិកាគណនេយ្យសម្រាប់កត់ត្រាប្រតិបត្តិការ និងហេតុការណ៍ដែលនាំឱ្យមានកិច្ចបញ្ជិកាគណនេយ្យ ព្រមទាំងប្រព័ន្ធព័ត៌មានគណនេយ្យដែលបានអនុវត្ត។

## ប្រការ ១៨.- ដំណើរការនិងនីតិវិធីនៃលំនាំសវនកម្ម ប្រកបដោយប្រសិទ្ធភាព

១៨.១. ចំពោះព័ត៌មានដែលបានបង្ហាញក្នុងតារាងតុល្យការ ក្រៅតារាងតុល្យការ របាយការណ៍ចំណូល-ចំណាយ និងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ការរៀបចំដំណើរការគណនេយ្យត្រូវបង្កើតនូវសំណុំនីតិវិធីនិងដំណើរការ ហៅថាលំនាំសវនកម្ម (audit trail) ដើម្បីអាចៈ

ក. បង្កើតឡើងវិញនូវរាល់ប្រតិបត្តិការតាមលំដាប់លំដោយនៃពេលវេលា។

ខ. គាំទ្ររាល់ព័ត៌មានដោយឯកសារច្បាប់ដើម ដែលអនុញ្ញាតដល់ការរកឃើញប្រតិបត្តិការដោយផ្ទាល់ តាំងពីឯកសារដើមរហូតដល់ឯកសារសង្ខេប និងផ្ទុយមកវិញ។

គ. គិតគូរអំពីបម្រែបម្រួលនៃសមតុល្យពីកាលបរិច្ឆេទបិទបញ្ជី ទៅថ្ងៃបន្ទាប់ដោយរក្សាទុកពេញលេញនូវកំណត់ត្រានៃប្រតិបត្តិការដែលនាំឱ្យមានបម្រែបម្រួលលើសមតុល្យគណនីទាំងនោះ។

១៨.២. ប្រសិទ្ធភាពនៃលំនាំសវនកម្ម ត្រូវតែបានសាកល្បង និងវាយតម្លៃប្រចាំគ្រា។

## ប្រការ ១៩.- សន្និធិទ្រព្យសកម្មដែលគ្រឹះស្ថានកាន់កាប់ក្នុងនាមអតិថិជន និងតតិយភាគី

១៩.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធី និងរក្សាកំណត់ត្រាត្រឹមត្រូវបង្ហាញអំពីសន្និធិ លំហូរចេញ និងលំហូរចូលនៃទ្រព្យសកម្មដែលគ្រឹះស្ថានបានកាន់កាប់ក្នុងនាមអតិថិជន និងតតិយភាគី ដូច្នេះទ្រព្យសម្បត្តិទាំងនោះមិនត្រូវបានកត់ត្រា ឬរាយការណ៍ជាទ្រព្យសម្បត្តិផ្ទាល់របស់គ្រឹះស្ថានទេ។

១៩.២. គ្រឹះស្ថានត្រូវញែកទ្រព្យសកម្មខាងលើ រវាងទ្រព្យសកម្មជាប្រាក់បញ្ញើ និងទ្រព្យសកម្មជាវត្ថុបញ្ចាំសម្រាប់ធានាការសន្យាដែលបានធ្វើឡើងក្នុងគោលបំណងជាក់លាក់ណាមួយ ឬសម្រាប់កិច្ចព្រមព្រៀងដែលជាប្រយោជន៍ដល់ម្ចាស់ប្រាក់បញ្ញើ។

## ប្រការ ២០.- ការត្រួតពិនិត្យឯករាជ្យ ការបែងចែកមុខងារភារកិច្ច និងការផ្ទៀងផ្ទាត់ប្រចាំគ្រា

២០.១. គ្រឹះស្ថានត្រូវអនុវត្តនីតិវិធី និងដំណើរការ ដែលទ្រទ្រង់ដល់ការបែងចែកប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចការត្រួតពិនិត្យឯករាជ្យ និងការផ្ទៀងផ្ទាត់ប្រចាំគ្រា សំដៅការពារទ្រព្យសកម្មរបស់គ្រឹះស្ថាន និងដើម្បីកំណត់អត្តសញ្ញាណបានឆាប់រហ័សនូវរាល់ភាពខុសគ្នាសំខាន់ៗ។

២០.២. នីតិវិធី និងដំណើរការទាំងនោះត្រូវបញ្ជាក់ជាពិសេសអំពីការបែងចែកច្បាស់លាស់នូវភារកិច្ចពាក់ព័ន្ធនឹងការសន្យាការចំណាយមូលនិធិ និងកិច្ចបញ្ជិកាទ្រព្យសកម្ម និងទ្រព្យអកម្មរបស់គ្រឹះស្ថាន។ ដំណើរការនេះត្រូវតែបានផ្ទៀងផ្ទាត់ និងវាយតម្លៃឡើងវិញប្រចាំគ្រា។

២០.៣. នីតិវិធី និងដំណើរការទាំងនេះត្រូវក្រសោបនូវតារាងត្រួតពិនិត្យ ការផ្ទៀងផ្ទាត់គណនី ការពិនិត្យនិងថ្លឹងថ្លែង (ការត្រួតពិនិត្យទ្វេដង ការធ្វើសុពលភាពដោយឯករាជ្យនៃការចុះបញ្ជិកាគណនេយ្យ ការចុះហត្ថលេខាពីររួមគ្នា ឬដំណើរការប្រហាក់ប្រហែលផ្សេងទៀតនៅក្នុងប្រព័ន្ធគណនេយ្យ) ការត្រួតពិនិត្យឡើងវិញដោយល្អិតល្អន់លើទ្រព្យសកម្មជាសន្និធិ ព្រមទាំងព័ត៌មានអំពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនោះដែលត្រូវផ្តល់ជូនគណៈគ្រប់គ្រង។ រាល់ភាពខុសគ្នាត្រូវតែបានអង្កេតភ្លាម កត់ត្រាទុកជាឯកសារ និងដោះស្រាយដោយ

ប្រុងប្រយ័ត្ន។ បើចាំបាច់ គ្រឹះស្ថានត្រូវពិចារណាភ្លាមអំពីផលប៉ះពាល់នៃភាពខុសគ្នានេះទៅលើចំណូលដែលបានរាយការណ៍ និងមូលនិធិផ្ទាល់សុទ្ធដែលត្រូវតែកែតម្រូវជាបន្ទាន់។

## ជំពូក ៩
## ប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ

### ប្រការ ២១.- ប្រសិទ្ធភាពនៃប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ

២១.១. គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធវាស់វែងនិងវិភាគហានិភ័យ ស្របតាមប្រភេទ និងទំហំប្រតិបត្តិការ និងភាពស្មុគស្មាញនៃសកម្មភាពរបស់គ្រឹះស្ថាន។ ប្រព័ន្ធនេះត្រូវតែអាចវាយតម្លៃឱ្យបានទាន់ពេលវេលា និងជឿទុកចិត្តបានចំពោះរាល់ប្រភេទហានិភ័យរបស់គ្រឹះស្ថានជាពិសេសហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ និងបើចាំបាច់ ហានិភ័យទីផ្សារ ហានិភ័យអន្តរការិយកម្ម ហានិភ័យប្រគល់ និងហានិភ័យទូទាត់។

២១.២. បើចាំបាច់ ប្រព័ន្ធនេះត្រូវបានរៀបចំ និងបង្កើតឡើងដើម្បីជួយដល់ការវាយតម្លៃ និងការវិភាគហានិភ័យនៅកម្រិតគួបសរុប ហើយជាពិសេសអាចកំណត់អត្តសញ្ញាណ និងតាមដានបានសមស្របនូវហានិភ័យប្រមូលផ្តុំ និងអាចគាំទ្រដល់សេចក្តីសម្រេចទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពអំពីការគ្រប់គ្រងហានិភ័យ។

២១.៣. ប្រព័ន្ធទាំងនេះ និងនីតិវិធីទ្រទ្រង់ផ្សេងៗ ត្រូវស្ថិតក្រោមការពិនិត្យផ្ទៃក្នុងឡើងវិញដោយទៀងទាត់ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយ និងភាពសមស្របទៅនឹងប្រភេទ ទំហំ ភាពស្មុគស្មាញនៃសកម្មភាព និងរចនាសម្ព័ន្ធសាជីវកម្មរបស់គ្រឹះស្ថាន។

### ប្រការ ២២.- ដំណើរការត្រួតពិនិត្យអចិន្ត្រៃយ៍ ដើម្បីធានាការប្រតិបត្តិតាមកាតព្វកិច្ច និងកម្រិតកំណត់

ប្រព័ន្ធវាស់វែងហានិភ័យ និងលទ្ធផល និងការត្រួតពិនិត្យរបស់គ្រឹះស្ថាន ត្រូវមានលទ្ធភាពតាមដានជាអចិន្ត្រៃយ៍នូវរាល់កាតព្វកិច្ច ឬកម្រិតកំណត់ផ្សេងៗ។ រាល់កំហុសដែលបានរកឃើញត្រូវតែបានដោះស្រាយ និងរាយការណ៍ភ្លាមទៅប្រធានមុខងារប្រតិបត្តិតាម។ របាយការណ៍នោះត្រូវមានបញ្ជាក់អំពីដើមហេតុនៃកំហុស ព្រមទាំងវិធានការកែតម្រូវទាំងឡាយដើម្បីដោះស្រាយហានិភ័យនៃការមិនប្រតិបត្តិតាម។ វិធានការកែតម្រូវនេះក៏ត្រូវមានគោលបំណងជៀសវាងនូវកំហុសដដែលៗផងដែរ និងសំដៅពិនិត្យឡើងវិញនូវរាល់ការត្រួតពិនិត្យកន្លងមក បើមានការវាយតម្លៃថាការត្រួតពិនិត្យកន្លងមកនោះមិនសមស្រប និងគ្មានប្រសិទ្ធភាព។

## ជំពូក ១០
## ប្រព័ន្ធរក្សាទុកឯកសារ

### ប្រការ ២៣.- គោលនយោបាយ នីតិវិធី សមត្ថកិច្ច ការប្រគល់សិទ្ធិ និងរបាយការណ៍

២៣.១. គ្រឹះស្ថានត្រូវអនុម័ត វាយតម្លៃឡើងវិញ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវគោលនយោបាយ នីតិវិធីការកំណត់សិទ្ធិអំណាច និងការប្រគល់សិទ្ធិ រចនាសម្ព័ន្ធចាត់តាំង ប្រព័ន្ធព័ត៌មាន សកម្មភាព អភិបាលកិច្ច និង

របនាសម្ព័ន្ធសាជីវកម្ម ប្រសិនបើជាគ្រឹះស្ថានដែលរងការគួបសរុប (Consolidated Entity) ឬគ្រឹះស្ថានដែលត្រូវធ្វើការគួបសរុប (Consolidated Entity) ។

២៣.២. ការកំណត់សិទ្ធិអំណាច និងការប្រគល់សិទ្ធិ ត្រូវមានរៀបចំជាឯកសារច្បាស់លាស់ សម្រាប់ឱ្យភាគីពាក់ព័ន្ធទាំងអស់ រួមមានអគ្គនាយក: មុខងារគ្រប់គ្រងហានិភ័យនិងត្រួតពិនិត្យ រួមទាំងមុខងារប្រតិបត្តិតាមផងដែរ។ ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថាន និងបើចាំបាច់របស់ក្រុមគ្រឹះស្ថានត្រូវតែអាចធានាថាភាគីពាក់ព័ន្ធទាំងអស់ទទួលបានព័ត៌មានច្បាស់លាស់អំពីវិធាននៃការសម្រេចផ្ទៃក្នុងនេះ។ គ្រឹះស្ថានក៏ត្រូវមានដំណើរការត្រួតពិនិត្យគ្រប់គ្រាន់ផងដែរ ដើម្បីធានាថាសមត្ថកិច្ច និងការប្រគល់សិទ្ធិមិនត្រូវបានប្រើប្រាស់លើសដែនកំណត់ ឬខុសគោលដៅ។

២៣.៣. គោលនយោបាយ និងនីតិវិធីត្រូវតែបានផ្តល់ទៅគណៈគ្រប់គ្រង និងមន្ត្រីបុគ្គលិកជាលាយលក្ខណ៍អក្សរ បើចាំបាច់ការអនុវត្តគោលនយោបាយ និងនីតិវិធីទាំងនោះត្រូវតែបានទ្រទ្រង់ដោយការបណ្តុះបណ្តាលសមស្របផងដែរ។ គោលនយោបាយ និងនីតិវិធីទាំងនោះត្រូវតែមានការត្រួតពិនិត្យ ការប្រតិបត្តិតាមមុននឹងដាក់ឱ្យអនុវត្ត។ គោលនយោបាយ និងនីតិវិធីទាំងនោះត្រូវមានបញ្ជាក់ច្បាស់លាស់អំពីដំណើរការដែលត្រូវបានអនុវត្ត សំដៅធានាការបែងចែកភារកិច្ច ឯករាជ្យភាពនៃការត្រួតពិនិត្យ និងការទប់ស្កាត់ ឬដំណោះស្រាយទំនាស់ផលប្រយោជន៍ជាសក្តានុពល។

២៣.៤. ក្រោមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ២៣.១ ដល់កថាខណ្ឌ ២៣.៣ ខាងលើ ជាពិសេសគ្រឹះស្ថានត្រូវបង្កើត វាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំ នូវរាល់ឯកសារផ្សេងៗ សំដៅទ្រទ្រង់ដល់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងមូល ស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។ ឯកសារទាំងនោះ អាចផ្តល់ជូនភាគីពាក់ព័ន្ធទាំងអស់សម្រាប់ប្រើប្រាស់ ដែលរួមមាន ៖

ក. ការពិពណ៌នាអំពីការទទួលខុសត្រូវនៅគ្រប់កម្រិតទាំងអស់

ខ. ការកំណត់មុខងារ តួនាទី និងធនធានដែលបានបែងចែក សម្រាប់ការបំពេញមុខងារ និងតួនាទីទាំងនោះ

គ. ការពិពណ៌នាអំពីបែបបទ និងយន្តការនៃបែបបទរាយការណ៍ សំដៅធានាឯករាជ្យភាព ប្រសិទ្ធភាព និងភាពគ្មានទំនាស់ផលប្រយោជន៍

ឃ. ការពិពណ៌នាអំពីប្រព័ន្ធ និងដំណើរការវាស់វែងហានិភ័យ។ បើចាំបាច់ វិធីសាស្ត្រវាស់វែងហានិភ័យជាក់លាក់ ដូចជារង្វាស់ស្ថិតិលើហានិភ័យចំណាយសម្រាប់ផ្លាស់ប្តូរ ការចុះបញ្ជិកាតាមថ្លៃទីផ្សារ ជាដើម ត្រូវមានកត់ត្រាទុកជាឯកសារ និងត្រូវអនុម័តដោយឯករាជ្យពីប្រតិបត្តិការអាជីវកម្ម

ង. ការពិពណ៌នាអំពីប្រព័ន្ធតាមដានហានិភ័យដែលបានអនុវត្តសម្រាប់ការតាមដានហានិភ័យ ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ការពិពណ៌នាអំពីប្រព័ន្ធត្រួតពិនិត្យ វិធានការកែតម្រូវចាំបាច់បើមាន និងការពិពណ៌នាអំពីសញ្ញាអាសន្ន ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាភិបាល។

**ប្រការ ២៤.- ការរៀបចំប្រព័ន្ធព័ត៌មាន និងរក្សាទុកឯកសារ**

២៤.១. ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថានត្រូវតែធានាការរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ នូវរាល់សេចក្តីសម្រេច ឬហេតុការណ៍សំខាន់ៗពាក់ព័ន្ធនឹងអាជីវកម្ម ប្រតិបត្តិការ និងរចនាសម្ព័ន្ធ ដើម្បីងាយស្រួលរក និងប្រើប្រាស់ព័ត៌មានទាំងនោះ។

២៤.២. ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថានក៏ត្រូវទ្រទ្រង់ដល់ការបែងចែកព័ត៌មានបានសមស្របនៅក្នុងគ្រឹះស្ថានទាំងមូលផងដែរ ហើយការបែងចែកនេះត្រូវផ្តោតជាចម្បងលើព័ត៌មានពាក់ព័ន្ធនឹងបញ្ហាត្រួតពិនិត្យផ្ទៃក្នុង និងជាពិសេស កាតព្វកិច្ច និងបទប្បញ្ញត្តិស្តីពីការប្រតិបត្តិតាម។

២៤.៣. ផែនការយថាភាព និងនីតិវិធីពាក់ព័ន្ធផ្សេងៗ ត្រូវតែជាផ្នែកមួយនៃប្រព័ន្ធរក្សាទុកឯកសាររបស់គ្រឹះស្ថាន ហើយបើចាំបាច់ត្រូវតែមានចែងច្បាស់លាស់ស្របតាមផែនការយថាភាព និងនីតិវិធីសម្រាប់កម្រិតក្រុមគ្រឹះស្ថាន និងនីតិវិធីដូចមានចែងក្នុងកថាខណ្ឌ ៦.៣ នៃប្រការ ៦ ស្តីពីសេវាកម្មផ្តល់ដោយតតិយភាគី។

២៤.៤. រាល់គោលនយោបាយ នីតិវិធី ការកំណត់សិទ្ធអំណាច ការប្រគល់សិទ្ធិ របាយការណ៍ និងកំណត់ហេតុ ត្រូវតែផ្តល់ឱ្យសវនករផ្ទៃក្នុង មន្ត្រីមុខងារប្រតិបត្តិតាម អាជ្ញាធរត្រួតពិនិត្យ ព្រមទាំងសវនករឯករាជ្យ ដើម្បីប្រើប្រាស់តាមការស្នើសុំ ។

**ប្រការ ២៥.- របាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង**

២៥.១. គ្រឹះស្ថានត្រូវតែរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលពិពណ៌នាអំពីរចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងគោលនយោបាយ នីតិវិធី និងយន្តការពាក់ព័ន្ធផ្សេងៗ។ របាយការណ៍នេះក៏ត្រូវវាយតម្លៃផងដែរទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមកំណើន និងពិពិធកម្មនៃអាជីវកម្ម និងការកែប្រែផ្សេងៗ នៅក្នុងគ្រឹះស្ថាន។

២៥.២. បើចាំបាច់ របាយការណ៍នេះក៏ត្រូវមានចែងច្បាស់លាស់អំពីការត្រួតពិនិត្យផ្ទៃក្នុងនោះ ដោយមានគោលនយោបាយ និងរចនាសម្ព័ន្ធដែលបានបង្កើតឡើងនៅកម្រិតគួបសរុបផងដែរ។

២៥.៣. សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក ត្រូវទទួលខុសត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំដែលនឹងត្រូវបានពិភាក្សានៅក្នុងគណៈកម្មការសវនកម្ម។ បើសមស្រប ឬចាំបាច់ អនុសាសន៍អំពីវិធានការកែតម្រូវ ឬកែលម្អ ត្រូវបានលើកឡើងជូនក្រុមប្រឹក្សាភិបាល។

២៥.៤. គ្រឹះស្ថានត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំនេះជូនធនាគារជាតិនៃកម្ពុជា ដោយមានហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក យ៉ាងយូរបំផុតនៅថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់។

## ជំពូក ១១
## ផែនការយថាភាព និងការសាកល្បង

**ប្រការ ២៦.- កាតព្វកិច្ចចំពោះផែនការយថាភាព**

២៦.១. គ្រឹះស្ថានមានកាតព្វកិច្ចវាយតម្លៃហានិភ័យប្រចាំគ្រា ក្នុងគោលបំណងកំណត់អត្តសញ្ញាណហានិភ័យ ហានិភ័យប្រមូលផ្តុំ វេទយិតភាពសំខាន់ៗ ចំពោះព្រឹត្តិការណ៍ និងការវិវត្តជាអវិជ្ជមានដែលអាច

បណ្តាលឱ្យមានការរអាក់រអួលធ្ងន់ធ្ងរ ដូចជាការខកខានមិនបានសង ឬមិនបានប្រគល់ឱ្យទាន់ពេលវេលា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ការមិនប្រតិបត្តិតាមចម្បងៗ ឬការឈប់ដំណើរការនៃប្រព័ន្ធ។

២៦.២. ការវាយតម្លៃប្រចាំគ្រាខាងលើ នាំឱ្យកើតមានដំណើរការគ្រប់គ្រងគ្រាអាសន្ន និងដំណើរការចេញសេចក្តីសម្រេច សម្រាប់ដោះស្រាយស្ថានភាពវិបត្តិ ជាពិសេស តាមរយៈការដោះស្រាយសេណារីយ៉ូអវិជ្ជមានដែលសមស្រប និងដែលត្រូវដោះស្រាយឱ្យបានក្នុងពេលវេលាដ៏ខ្លី។ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយសម្រាប់ដោះស្រាយស្ថានភាពវិបត្តិ ផែនការយថាភាព និងការសាកល្បង និងទំនាក់ទំនងជាមួយអាជ្ញាធរ និងសាធារណជន ដែលនឹងត្រូវអនុវត្តក្រោមការទទួលខុសត្រូវរបស់មាជិកក្រុមប្រឹក្សាភិបាលម្នាក់ឬច្រើននាក់ ដែលមានការចាត់តាំងច្បាស់លាស់។

២៦.៣. គ្រឹះស្ថានមានកាតព្វកិច្ចបង្កើតផែនការនិរន្តភាពអាជីវកម្ម ដូចមានចែងក្នុងប្រការ ៣ ស្របតាមហានិភ័យដែលបានកំណត់អត្តសញ្ញាណ ដោយការវាយតម្លៃប្រចាំគ្រា ដូចមានចែងក្នុងចំណុច ២៦.២ ខាងលើ។ យ៉ាងហោចណាស់ ផែនការនិរន្តភាពអាជីវកម្មនេះ និងនីតិវិធីនានា ត្រូវមានចែងអំពីការផ្តល់មូលនិធិយថាភាព (contingency funding) និងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលគ្រាអាសន្ន ក៏ដូចជាដំណោះស្រាយ និងដំណើរការបែកអាប់ (Back up) ដើម្បីដោះស្រាយការខូចខាតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

២៦.៤. ផែនការយថាភាព និងដំណើរការ ត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រា ស្របតាមការវិវត្តទីផ្សារ និងអាជីវកម្ម ភាពស្មុគស្មាញនៃរចនាសម្ព័ន្ធ និងបច្ចេកវិទ្យាពាក់ព័ន្ធ ភាពគ្រប់គ្រាន់នៃនីតិវិធី និងដំណើរការជំនួសដែលមានកម្រិតទាបជាងកាតព្វកិច្ចអប្បបរមា ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព និងជាទូទៅដោយពិចារណាអំពីផលប៉ះពាល់នៃយថាភាពដែលអាចមើលឃើញជាមុនថាជាសក្តានុពលចំពោះការប្រតិបត្តិតាម និងហានិភ័យកិត្តិសព្ទ។

## ជំពូក ១២
## ពិន័យ និងកាតព្វកិច្ចបង្កើនសាធនភាព

### ប្រការ ២៧.- ពិន័យក្នុងករណីមិនប្រតិបត្តិតាម ឬអប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចដាក់ពិន័យចំពោះគ្រឹះស្ថានណាដែលមិនប្រតិបត្តិតាម ឬល្មើសនឹងបទប្បញ្ញត្តិផ្សេងៗនៃប្រកាសនេះ យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏ត្រូវយកចិត្តទុកដាក់ដល់ការរំលោភ និងកង្វះខាត ព្រមទាំងផលប៉ះពាល់ជាសក្តានុពលទៅលើការវាយតម្លៃទម្រង់ហានិភ័យជារួមរបស់គ្រឹះស្ថាន ទាំងនៅកម្រិតដាច់ដោយឡែក និងនៅកម្រិតគួបសរុបផងដែរ។

### ប្រការ ២៨.- កាតព្វកិច្ចបង្កើនសាធនភាព

២៨.១. ក្នុងករណីមានកង្វះខាតធ្ងន់ធ្ងរនៅក្នុងដំណើរការគ្រប់គ្រងហានិភ័យ ឬជាទូទៅនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានដែលមានទម្រង់ហានិភ័យខ្ពស់ដោយសារតែកង្វះខាតនោះ ដើម្បីបង្កើនកាតព្វកិច្ចសាធនភាពថែមទៀត។

២៨.២. កាតព្វកិច្ចបង្កើនសាធនភាពនេះ តម្រូវជាពិសេសចំពោះគ្រឹះស្ថានណាដែលមិនអនុវត្តតាមវិធានការកែតម្រូវចាំបាច់ បន្ទាប់ពីមានអធិបញ្ញាពីធនាគារជាតិនៃកម្ពុជា។

២៨.៣. កាតព្វកិច្ចបង្កើនសាធនភាពមិនត្រូវលើសពីសាមសិប (៣០) ភាគរយនៃអនុបាតសាធនភាពអប្បបរមាឡើយ និងមិនត្រូវបានលើកលែងពីកាតព្វកិច្ចនេះវិញ ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនពេញចិត្តទាំងស្រុងចំពោះប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវដែលបានអនុវត្តនោះឡើយ។ ផ្អែកលើកម្រិតកាតព្វកិច្ចសាធនភាពអប្បបរមានាបច្ចុប្បន្នចំនួនដប់ប្រាំ (១៥) ភាគរយ កាតព្វកិច្ចបង្កើនសាធនភាពអតិបរមាត្រូវមានកម្រិតដប់ប្រាំបួនក្បៀសប្រាំ (១៩,៥) ភាគរយ។

២៨.៤. កាតព្វកិច្ចបង្កើនសាធនភាព និងការលើកលែងពីការអនុវត្តវិធានការត្រួតពិនិត្យប្រុងប្រយ័ត្ននេះត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថាន។

## ជំពូក ១៣
## អន្តរប្បញ្ញត្តិ

### ប្រការ ២៩.- ការអនុវត្តប្រកាសនេះ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែអនុវត្តឱ្យបានពេញលេញតាមបទប្បញ្ញត្តិនៃប្រកាសនេះ យ៉ាងយូរបំផុតនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ តទៅ។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពត្រូវមានការវាយតម្លៃជារួមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលមានស្រាប់របស់គ្រឹះស្ថាន និងលើការកំណត់ជំហានដែលត្រូវអនុវត្តដើម្បីសម្រេចតាមប្រកាសនេះ ។

### ប្រការ ៣០.- ការវាយតម្លៃ និងផែនការសកម្មភាព

៣០.១. ផ្អែកលើការវាយតម្លៃចាំបាច់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកំណត់អត្តសញ្ញាណនូវផ្នែកទាំងឡាយ ដូចជាគោលនយោបាយ នីតិវិធី ដំណើរការវាយតម្លៃ ក្របខណ្ឌរចនាសម្ព័ន្ធ ប្រព័ន្ធព័ត៌មានគ្រប់គ្រងជាដើម ដែលទាមទារនូវសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងបង្កើតផែនការសកម្មភាពលម្អិតអំពីជំហានដែលត្រូវប្រកាន់យក និងមធ្យោបាយបន្ថែមសម្រាប់ធ្វើសកម្មភាពនោះ។

៣០.២. បើចាំបាច់ ផែនការសកម្មភាពនេះត្រូវមានចែងអំពីសកម្មភាពដែលត្រូវអនុវត្តដើម្បីប្រតិបត្តិតាមនៅកម្រិតគួបសរុប។

៣០.៣. ផែនការសកម្មភាពនេះត្រូវចែងលម្អិតអំពីលំហូរការងារ (flow charts) រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន ការពិពណ៌នាអំពីមុខងារ លក្ខខណ្ឌការងាររបស់គណៈកម្មការនានា គោលនយោបាយ និងនីតិវិធីក៏ដូចជាសមាសធាតុថវិកា ដើម្បីទ្រទ្រង់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពទាំងនោះយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។

៣០.៤. ច្បាប់ថតចម្លងនៃផែនការសកម្មភាព និងឯកសារភស្តុតាងផ្សេងៗ ដូចមានចែងក្នុងចំណុច ៣០.៣ ខាងលើ ឬឯកសារចាំបាច់បន្ថែមទៀត ត្រូវបញ្ជូនមកធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។ គ្រឹះស្ថានដែលមានការយឺតយ៉ាវក្នុងការផ្តល់ផែនការសកម្មភាពនេះមកធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលរងពិន័យ។

## ជំពូក ១៤
## អវសានប្បញ្ញត្តិ

**ប្រការ ៣១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៣២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១០-០០២ ស.រ.ណ

ភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០

# សារាចរណែនាំ
# ស្តីពី
# ការជ្រើសរើសស្នងការគណនីឯករាជ្យ សម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ដើម្បីអនុវត្តច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខធ៧-០៤-២០៤ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងដើម្បីបង្ហាញ ពីតម្លាភាពរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា សម្រេចៈ

១- គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវជ្រើសរើសស្នងការគណនីឯករាជ្យ ដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន។

២- គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្តល់ឈ្មោះស្នងការគណនីឯករាជ្យ ឬ ដៃគូសវនកម្ម (Audit Partner) មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិននីមួយៗ។

៣- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវផ្លាស់ប្តូរស្នងការគណនីឯករាជ្យរៀងរាល់ ៣ ឆ្នាំម្តង។

៤- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាសាខា ឬ ជាបុត្រសម្ព័ន្ធរបស់ធនាគារបរទេស អាចជ្រើសរើសស្នងការគណនីឯករាជ្យស្របតាមទីស្នាក់ការកណ្តាលរបស់ខ្លួន ដោយគ្រាន់តែផ្លាស់ប្តូរដៃគូសវនកម្ម (Audit Partner) រៀងរាល់បីឆ្នាំ ហើយការអនុវត្តនេះមិនគិតដល់ការផ្លាស់ប្តូរ ឬ ការកំណត់រយៈពេលដូចមានចែងក្នុងចំណុច ៣ នៃសារាចរនេះទេ។

៥- ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបដិសេធស្នងការគណនីឯករាជ្យ ឬ ដៃគូសវនកម្ម ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានជ្រើសរើស ដោយពុំចាំបាច់ផ្តល់ហេតុផលឡើយ។

៦- សារាចរណែនាំលេខ ធ៧-០៥-០០១ សរណន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការជ្រើសរើសស្នងការគណនីឯករាជ្យ សម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចាត់ទុកជានិរាករណ៍។

សារាចរណែនាំនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

ហត្ថលេខា និងត្រាៈ **ជា ចាន់តូ**

ធ៧-០៨-០៨៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

## ប្រការ ១.- ដែនកំណត់

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យថា "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" គឺសំដៅចំពោះ គ្រឹះស្ថាន និងវិជ្ជាជីវៈដូចខាងក្រោម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ហើយត្រូវបានហៅថា "បុគ្គលរាយការណ៍ " នៅក្នុងច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ៖

ក) ធនាគារ រួមទាំងសាខាធនាគារបរទេស

ខ) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ) សហករណ៍ឥណទាន

ឃ) ក្រុមហ៊ុនភតិសន្យា

ង) បញ្ជរប្តូរប្រាក់/អ្នកប្តូរប្រាក់

ច) សេវាផ្ទេរប្រាក់

ឆ) ឈ្មួញលោហធាតុ និងត្បូងថ្មមានតម្លៃ

ជ) គ្រឹះស្ថាន ឬវិជ្ជាជីវៈដទៃទៀតដែលកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។

## ប្រការ ២ .- គោលការណ៍ទទួលស្គាល់អតិថិជន

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបង្កើតគោលការណ៍ និងនីតិវិធីទទួលស្គាល់អតិថិជន ហើយត្រូវមានវិធានការសមស្រប រួមមានសាវតារហានិភ័យនៅក្នុងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ខ្លួនដើម្បីកំណត់ហានិភ័យ ផ្សេងៗដែលបានបង្កើតឡើងដោយប្រភេទនៃអតិថិជននីមួយៗ ឬអតិថិជនជារូបវន្តបុគ្គលនីមួយៗ។

## ប្រការ ៣ .- ការកំណត់សាវតារហានិភ័យ

៣.១ ក្នុងការកំណត់សាវតារហានិភ័យតាមប្រភេទអតិថិជននីមួយៗ ឬតាមអតិថិជនជារូបវន្តបុគ្គលនីមួយៗ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ យ៉ាងហោចណាស់ត្រូវយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនដូចខាងក្រោម ៖

- ប្រភពដើមរបស់អតិថិជន និងទីតាំងអាជីវកម្ម
- សាវតារ និងបុគ្គលិកលក្ខណៈពិសេសរបស់អតិថិជន
- លក្ខណៈអាជីវកម្មរបស់អតិថិជន
- រចនាសម្ព័ន្ធកម្មសិទ្ធិសម្រាប់អតិថិជនជាក្រុមហ៊ុន និង
- ព័ត៌មានផ្សេងៗ ដែលអាចបញ្ជាក់ថា អតិថិជនមានហានិភ័យខ្ពស់ ។

៣.២ បន្ទាប់ពីទទួលស្គាល់អតិថិជនជាលើកដំបូង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតាមដានសកម្មភាពគណនីអតិថិជនជាប្រចាំដើម្បីធានាថាសកម្មភាពគណនីនេះស្របទៅនឹងសាវតារអតិថិជន។ ក្នុងករណីមានភាពមិនស្របគ្នា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវវាយតម្លៃឡើងវិញថា ជាអតិថិជនមានហានិភ័យខ្ពស់។

**ប្រការ ៤ .- ការហាមឃាត់គណនីអនាមិក និងគណនីបតិដ្ឋកម្ម**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវធានាថា ការបើកគណនីត្រូវតែមានឈ្មោះម្ចាស់គណនី និងត្រូវរក្សាទុកឈ្មោះម្ចាស់គណនីគ្រប់ពេលទាំងអស់។ លើសពីនេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវសម្គាល់អត្តសញ្ញាណអតិថិជនដូចមានចែងនៅក្នុងប្រការ ៦ និង ៧ នៃប្រកាសនេះ ហើយត្រូវធានាថាគ្មានអតិថិជនណាម្នាក់ត្រូវបានអនុញ្ញាតឱ្យបើក ឬធ្វើប្រតិបត្តិការគណនីណាមួយដែលមានឈ្មោះប្រឌិតមិនត្រឹមត្រូវ ឬក្លែងក្លាយ។

**ប្រការ ៥ .- ការយកចិត្តទុកដាក់ស្គាល់អតិថិជន**

៥.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងទាមទារឱ្យមានភស្តុតាងគ្រប់គ្រាន់ ព្រមទាំងកត់ត្រាទុកឱ្យបានត្រឹមត្រូវនូវអត្តសញ្ញាណ និងលក្ខណៈគតិយុត្តរបស់បុគ្គលដែលស្នើសុំធ្វើប្រតិបត្តិការ។ ភស្តុតាងទាំងនេះត្រូវតែជាឯកសារដែលអាចជឿជាក់បាន។

៥.២ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវធ្វើឡើងនៅពេលដែល ៖

- បង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ដូចជា ការបើកគណនី ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចុះកិច្ចសន្យាអាជីវកម្មផ្សេងទៀត
- អនុវត្តប្រតិបត្តិការ ដែលកើតឡើងតែមួយដង ឬម្តងម្កាល ដែលមានទឹកប្រាក់លើសពី ១០.០០០ ដុល្លារអាមេរិក (៤០ លានរៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត) ឬការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិកដែលមានទឹកប្រាក់លើសពី ១.០០០ ដុល្លារអាមេរិក (៤លានរៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត)
- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុសង្ស័យថា ជាការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ
- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុសង្ស័យពីភាពត្រឹមត្រូវ ឬភាពគ្រប់គ្រាន់នៃព័ត៌មានដែលបានទទួលកន្លងមក។

៥.៣ ក្នុងការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ យ៉ាងហោចណាស់ត្រូវ ៖

- សម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់បុគ្គលដែលអនុវត្តប្រតិបត្តិការដោយប្រើប្រាស់ប្រភពឯកសារ ទិន្នន័យ ឬព័ត៌មានដែលឯករាជ្យ និងអាចជឿជាក់បានយោងតាមប្រការ ៦ ឬ ៧ នៃប្រកាសនេះ
- កំណត់ថា អតិថិជនកំពុងធ្វើប្រតិបត្តិការជំនួសបុគ្គល ឬអត្ថគាហកណាមួយ
- ស្វែងយល់ពីអត្ថគាហក និងរចនាសម្ព័ន្ធត្រួតពិនិត្យរបស់អតិថិជន។ អត្ថគាហកត្រូវបានផ្តល់និយមន័យនៅក្នុងប្រការ ៨ នៃប្រកាសនេះ
- ប្រមូលព័ត៌មានស្តីពីគោលបំណង និងលក្ខណៈនៃទំនាក់ទំនងអាជីវកម្ម និង
- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងពិនិត្យពិច័យជាបន្តបន្ទាប់ដើម្បីធានាថាព័ត៌មានដែលបានទទួលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងសមស្របជាមួយចំណេះដឹងរបស់គ្រឹះស្ថានធនាគារនិង

ហិរញ្ញវត្ថុ អំពីអាជីវកម្ម និងសាវតារហានិភ័យរបស់អតិថិជន និងប្រសិនបើចាំបាច់ត្រូវដឹងពីប្រភពមូលនិធិ។

៥.៤ ការបដិសេធរបស់អតិថិជនក្នុងការផ្តល់ព័ត៌មាន និងមិនសហការក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចចាត់ទុកជាការសង្ស័យ។

៥.៥ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមិនត្រូវបើកគណនី ផ្តើមទំនាក់ទំនងអាជីវកម្ម ឬធ្វើប្រតិបត្តិការ ឬក្នុងករណីដែលទំនាក់ទំនងអាជីវកម្មមានស្រាប់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបញ្ឈប់ទំនាក់ទំនងទាំងនោះ ប្រសិនបើអតិថិជនមិនអនុវត្តតាមការតម្រូវនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន។ ស្ថានការណ៍បែបនេះត្រូវកត់ត្រាក្នុង របាយការណ៍ប្រតិបត្តិការសង្ស័យដែលត្រូវផ្ញើជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**ប្រការ ៦.- អតិថិជនជាឯកត្តបុគ្គល**

៦.១ ក្នុងការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនជាឯកត្តបុគ្គល គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវប្រមូលព័ត៌មានដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខអត្តសញ្ញាណប័ណ្ណ លេខលិខិតឆ្លងដែន លេខយោងឯកសារ បញ្ជាក់ពីអត្តសញ្ញាណអាជីវកម្ម/មុខរបរ សញ្ជាតិ និងអាសយដ្ឋាន។

៦.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវតម្រូវឱ្យឯកត្តបុគ្គលផ្តល់ឯកសារដើម និងថតចម្លងទុកនូវឯកសារមួយ ឬច្រើនជាង ដូចខាងក្រោម ៖

- អត្តសញ្ញាណប័ណ្ណ
- លិខិតឆ្លងដែន ឬ
- ឯកសារបញ្ជាក់ពីអត្តសញ្ញាណប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានភ្ជាប់មកជាមួយនូវរូបថតរបស់អតិថិជន ដែលចេញផ្សាយដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ ៧ .- អតិថិជនជាក្រុមហ៊ុន**

៧.១ ក្នុងការបង្កើតទំនាក់ទំនងជាមួយអតិថិជនជាក្រុមហ៊ុន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវតម្រូវឱ្យក្រុមហ៊ុន/អាជីវកម្មផ្តល់ឯកសារដើម និងថតចម្លងទុកនូវឯកសារដូចខាងក្រោម៖

- អនុស្សារណៈ លក្ខន្តិកៈ វិញ្ញាបនបត្រក្រុមហ៊ុន ភាពជាដៃគូ
- ឯកសារអត្តសញ្ញាណ របស់នាយក ភាគទុនិក ដៃគូ
- សេចក្តីសម្រេចចិត្ត របស់ក្រុមប្រឹក្សាភិបាល ឬ នាយក
- លិខិតផ្ទេរសិទ្ធិដល់បុគ្គលណាម្នាក់ជាតំណាងឱ្យក្រុមហ៊ុន/អាជីវកម្ម
- សិទ្ធិអំណាច ឬ ការអនុញ្ញាតឱ្យធ្វើអាជីវកម្ម ។

៧.២ លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវស្រាវជ្រាវ ឬសាកសួរពីប្រវត្តិរបស់ក្រុមហ៊ុន/អាជីវកម្មដើម្បីធានាថាក្រុមហ៊ុនមិនទាន់ត្រូវបាន ឬមិនស្ថិតនៅក្នុងដំណើរការជំរះបញ្ជី ឬមានបញ្ហាលំបាកអ្វីឡើយ។

៧.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនីដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល។ ពេលផ្លាស់ប្តូរហត្ថលេខីត្រូវយកចិត្តទុកដាក់ដើម្បីធានាថាហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ។

៧.៤ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវពិនិត្យមើលការចុះបញ្ជីរបស់ក្រុមហ៊ុន/អាជីវកម្ម ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មាន ដែលទទួលបានអំពីអត្តសញ្ញាណរបស់ក្រុមហ៊ុន/អាជីវកម្ម និងអភិបាលម្ចាស់ភាគទុនិក និងនាយកនៃក្រុមហ៊ុននោះ។

៧.៥ នៅពេលដែលអតិថិជនឬម្ចាស់គ្រប់គ្រងភាគទុនិកជាសាជីវកម្មដែលមានកាតព្វកិច្ចបើកចំហព័ត៌មាននៅក្នុងទីផ្សារភាគហ៊ុនដែលបានទទួលស្គាល់ នោះអត្តសញ្ញាណរបស់ភាគទុនិកនៃសាជីវកម្មពុំចាំបាច់ត្រូវស្វែងរក ឬផ្ទៀងផ្ទាត់ឡើយ។

៧.៦ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក៏ត្រូវដឹងពីរចនាសម្ព័ន្ធកម្មសិទ្ធិរបស់អតិថិជនជាក្រុមហ៊ុន និងកំណត់ប្រភពទុនរបស់ក្រុមហ៊ុន/អាជីវកម្ម។ ប្រការនេះនឹងជួយឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរកឃើញការសង្ស័យណាមួយដែលទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធ ឬភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុនឬការផ្លាស់ប្តូរសាវតារអតិថិជន និងសកម្មភាពតាមរយៈគណនីរបស់ក្រុមហ៊ុន/អាជីវកម្ម។

**ប្រការ ៨ .- អត្តគាហក**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនឱ្យបានហ្មត់ចត់ដូចបានអនុវត្តចំពោះអតិថិជនជាឯកត្តបុគ្គល នៅពេលសង្ស័យថា មានប្រតិបត្តិការមួយត្រូវបានធ្វើឡើងក្នុងនាមអត្តគាហកហើយ មិនមែនធ្វើឡើងសម្រាប់អតិថិជនដែលកំពុងធ្វើប្រតិបត្តិការនោះ។ អត្តគាហកជាបុគ្គលដែលបានកាន់កាប់ផ្តាច់មុខ ឬ ត្រួតពិនិត្យ អតិថិជនណាម្នាក់ ឬជាបុគ្គលត្រូវបានធ្វើប្រតិបត្តិការជំនួស។ អត្តគាហកក៏រាប់បញ្ចូលនូវបុគ្គលដែលកាន់កាប់ផ្តាច់មុខលើនីតិបុគ្គលឬការរៀបចំចាត់ចែងណាមួយផងដែរ។

**ប្រការ ៩ .- អង្គការក្រៅរដ្ឋាភិបាល និងមូលនិធិ**

៩.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាលឬ មូលនិធិដែលមានទំនាក់ទំនងអាជីវកម្ម ផ្តល់ឯកសារបង្កើតស្ថាប័ន ឬឯកសារប្រហាក់ប្រហែលគ្នាផ្សេងទៀត ដើម្បីធានាថាអង្គការក្រៅរដ្ឋាភិបាល និងមូលនិធិនោះត្រូវបានបង្កើត និងចុះបញ្ជីបានត្រឹមត្រូវ។

៩.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនីដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល។ ពេលផ្លាស់ប្តូរហត្ថលេខីត្រូវយកចិត្តទុកដាក់ដើម្បីធានាថា ហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ។

៩.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវស្វែងយល់អំពីការត្រួតពិនិត្យនិងការសម្រេចចិត្តរបស់អង្គការក្រៅរដ្ឋាភិបាល/មូលនិធិ និងការប្រើប្រាស់ប្រភពមូលនិធិ។

**ប្រការ ១០ .- គណនីអាណត្តិព្យាបាល និងគណនីតំណាង**

១០.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវកំណត់ថាតើអតិថិជនកំពុងតំណាងឱ្យបុគ្គលផ្សេងទៀតដែលជាអ្នកទទួលអាណត្តិព្យាបាលអ្នកតំណាង ឬភ្នាក់ងារ។

១០.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចាត់វិធានការសមស្របដើម្បីឱ្យដឹងពីភាពជាម្ចាស់កម្មសិទ្ធិរចនាសម្ព័ន្ធគ្រប់គ្រង និងទំនាក់ទំនង ក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ ក្នុងការកាន់កាប់គណនីអាណត្តិព្យាបាល ឬគណនីតំណាង និងត្រូវប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ស្តីពីអត្តសញ្ញាណរបស់អ្នកទូទាត់ អ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងហត្ថលេខីដែលទទួលបានការអនុញ្ញាតអ្នកគ្រប់គ្រង និងអត្តគាហក ។

១០.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវធានាថា តម្រូវការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវបានបំពេញសម្រាប់អត្ថគាហក នៅពេលបង្កើតគណនីអាណត្តិព្យាបាល ឬគណនីតំណាង ។

១០.៤ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវតម្រូវឱ្យមានការធានាជាលាយលក្ខណ៍អក្សរពីអ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងថាភស្តុតាងស្តីពីអត្តសញ្ញាណរបស់អត្ថគាហកត្រូវបានប្រមូលកត់ត្រា និងរក្សាទុក ហើយអ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងនោះពេញចិត្តនឹងប្រភពមូលនិធិ។ លើសពីនេះព័ត៌មានស្តីពីអត្តសញ្ញាណ ទាំងនេះចាំបាច់ ត្រូវផ្តល់ឱ្យជាបន្ទាន់តាមការស្នើសុំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១១ .- គណនីអតិថិជន**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវដឹងអំពីប្រតិបត្តិការគណនីអតិថិជនតាមរយៈមេធាវី និងគណនេយ្យករដែលបណ្តាលឱ្យមានការបារម្ភ ហើយត្រូវរាយការណ៍ពីប្រតិបត្តិការទាំងឡាយដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ប្រសិនបើមានការសង្ស័យណាមួយកើតឡើង ។

**ប្រការ ១២ .- ក្រុមហ៊ុនសំបក** (Shell Company)

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនត្រូវបើកគណនី ឬធ្វើអាជីវកម្មជាមួយក្រុមហ៊ុនដែលមិនធ្វើសកម្មភាពអាជីវកម្ម ឬពុំមានរូបភាពអាជីវកម្មនៅក្នុងប្រទេស ប៉ុន្តែប្រតិបត្តិការហិរញ្ញវត្ថុអាចត្រូវបានធ្វើឡើងតាមរយៈក្រុមហ៊ុន ដែលជានីតិបុគ្គលទាំងនោះ ។

**ប្រការ ១៣ .- ការពឹងផ្អែកលើអន្តរការី ឬតតិយភាគីសម្រាប់ការយកចិត្តទុកដាក់ស្គាល់អតិថិជន ដើម្បីផ្តើមអាជីវកម្ម**

១៣.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រុងប្រយ័ត្ននិងធានាថា ខ្លួនមិនងាយពេញចិត្ត និងមិនពឹងផ្អែកទាំងស្រុងលើការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលធ្វើឡើងដោយអន្តរការីឬតតិយភាគី។ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែជាការទទួលខុសត្រូវចុងក្រោយរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៣.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវពេញចិត្តថាអន្តរការីៈ

- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនដោយការសម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ថាប្រភពឯកសារ ទិន្នន័យ ឬព័ត៌មានមានភាពឯករាជ្យ និងអាចជឿជាក់បាន
- សម្គាល់អត្តសញ្ញាណអត្ថគាហក ហើយចំពោះអតិថិជនជាក្រុមហ៊ុនត្រូវយល់ពី ភាគទុនិក និងការគ្រប់គ្រង
- យល់ពីគោលបំណង និងលក្ខណៈអាជីវកម្ម
- មានប្រព័ន្ធសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលអាចទទួលបានឯកសារ អត្តសញ្ញាណ ទិន្នន័យដោយពុំមានការពន្យារពេល
- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រួតពិនិត្យជាប្រចាំសារឡើងវិញ ដើម្បីផ្ទៀងផ្ទាត់ការយកចិត្តទុកដាក់ស្គាល់អតិថិជននិង
- ត្រូវបានធ្វើបញ្ញត្តិកម្ម និងត្រួតពិនិត្យយ៉ាងត្រឹមត្រូវដោយអាជ្ញាធរពាក់ព័ន្ធអំពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ១៤ .- អតិថិជនមិនជួបផ្ទាល់**

១៤.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើត និងទំនាក់ទំនង

អាជីវកម្មមិនជួបផ្ទាល់ ហើយអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនតាមរយៈអន្តរកម្មជួបផ្ទាល់ ឬតាមរយៈអន្តរការី ដូចដែលបានតម្រូវដោយប្រការ ១៣ នៃប្រកាសនេះមុននឹងបង្កើតទំនាក់ទំនងបែបនេះជាមួយអតិថិជនរបស់ខ្លួន។

១៤.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវបានតម្រូវឱ្យអនុវត្តយន្តការតាមដាន និងរាយការណ៍ដើម្បីសម្គាល់អត្តសញ្ញាណជាសក្តានុពលនៃសកម្មភាពសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ១៥ .- ធនាគារទំនាក់ទំនង**

១៥.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាថាគ្រឹះស្ថានមិនទទួលរងនូវការគំរាមកំហែងពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈគណនីទំនាក់ទំនងជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត។

១៥.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានទំនាក់ទំនងបែបនេះត្រូវប្រមូល និងវាយតម្លៃព័ត៌មានស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទំនាក់ទំនងទាំងនោះយ៉ាងហោចណាស់ដូចជា៖

- ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង
- ផលិតផល និងសកម្មភាពអាជីវកម្ម
- ច្បាប់ បទប្បញ្ញត្តិ និងការត្រួតពិនិត្យដែលពាក់ព័ន្ធ
- ការត្រួតពិនិត្យ និងវិធានការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- របាយការណ៍ប្រចាំឆ្នាំ។

១៥.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបង្កើត ឬបន្តទំនាក់ទំនងសកម្មភាពធនាគារទៅវិញទៅមកជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទំនាក់ទំនងបានលុះត្រាតែខ្លួនបានពេញចិត្តលើការវាយតម្លៃព័ត៌មានដែលប្រមូលបាន។

១៥.៤ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចងក្រងឯកសារទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនីមួយៗដែលទាក់ទងនឹងសកម្មភាពធនាគារទំនាក់ទំនង។

១៥.៥ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវសម្រេច និងអនុម័តបង្កើត ឬបន្តទំនាក់ទំនងជាមួយធនាគារទំនាក់ទំនង។

១៥.៦ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវធានាថា ទំនាក់ទំនងជាមួយធនាគារទំនាក់ទំនងមិនត្រូវ បានធ្វើឡើងជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទំនាក់ទំនងដែលពុំមានរូបរាង ហើយមិនមែនជាសម្ព័ន្ធរបស់ក្រុមហិរញ្ញវត្ថុ ដែលមានការគ្រប់គ្រងតាមច្បាប់ ។

១៥.៧ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវពង្រឹងការយកចិត្តទុកដាក់ស្គាល់អាជីវករជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទំនាក់ទំនងដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ដោយផ្ទាល់នៃគណនីទំនាក់ទំនងអតិថិជនរបស់ខ្លួនដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជំនួសអតិថិជន ដូចជាការទូទាត់សងតាមគណនី។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់អតិថិជនបែបនេះ ដូចដែលបានតម្រូវចំពោះអន្តរការិយកម្មផ្តើមអាជីវកម្ម។

១៥.៨ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះទំនាក់ទំនងជាមួយគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុទំនាក់ទំនងពីប្រទេសទាំងឡាយ ដែលពុំមានការអនុវត្តគ្រប់គ្រាន់តាមវិធានការប្រឆាំងការ

សំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានទទួលយកជាអន្តរជាតិ។ ការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលបានពង្រឹងរួចហើយ គឺជាតម្រូវការចាំបាច់ដើម្បីវាយតម្លៃហានិភ័យនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ១៦ .- ការផ្ទេរប្រាក់/ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិក**

១៦.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលអនុវត្ត ឬចូលរួមប្រតិបត្តិការផ្ទេរប្រាក់ចេញ/ការផ្ទេរចេញតាមប្រព័ន្ធអេឡិកត្រូនិកត្រូវមានព័ត៌មានចាំបាច់ស្តីពីអ្នកផ្តើមប្រតិបត្តិការ ឈ្មោះ អាសយដ្ឋាន លេខគណនី លេខអត្តសញ្ញាណ ឬ លេខយោងអតិថិជន និងសេចក្តីលំអិតនៃប្រតិបត្តិការ។

១៦.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលជួយសម្រួល ឬធ្វើសកម្មភាពជាអន្តរការីចំពោះប្រតិបត្តិការផ្ទេរប្រាក់/ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិកត្រូវធានាថាព័ត៌មានស្តីពីអ្នកផ្តើមប្រតិបត្តិការនៅតែត្រូវបានរក្សាទុកជាមួយសារផ្ទេរប្រាក់/សារផ្ទេរតាមអេឡិកត្រូនិកនោះ។

១៦.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលទទួលប្រតិបត្តិការផ្ទេរប្រាក់/ការផ្ទេរចូលតាមប្រព័ន្ធអេឡិចត្រូនិក ដោយទទួលព័ត៌មានពុំគ្រប់គ្រាន់ស្តីពីអ្នកផ្តើមប្រតិបត្តិការត្រូវពង្រឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន ហើយអាចចាត់ទុកប្រតិបត្តិការនេះជាប្រតិបត្តិការសង្ស័យ។

១៦.៤ ប្រតិបត្តិការផ្ទេរប្រាក់/ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិកដែលមានទឹកប្រាក់តិចជាង ១.០០០ ដុល្លារអាមេរិក (៤លានរៀល) ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀតមិនចាំបាច់មានព័ត៌មានដូចដែលបានតម្រូវខាងលើនោះទេ។

១៦.៥ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវពិនិត្យជាពិសេសចំពោះអតិថិជនដែលមានហានិភ័យខ្ពស់ដោយយកចិត្តទុកដាក់លើកត្តាមួយចំនួន ដូចជា ឈ្មោះអត្ថគាហក ទិសដៅ និងចំនួនប្រាក់ដែលត្រូវផ្ទេរ។ លើសពីនេះប្រសិនបើការផ្ទេរប្រាក់/ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិកនេះមិនស៊ីគ្នានឹងសកម្មភាព/អាជីវកម្មធម្មតារបស់អតិថិជន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវទាមទារឱ្យអតិថិជនពន្យល់បន្ថែមពីលក្ខណៈនៃប្រតិបត្តិការផ្ទេរប្រាក់/ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិក។

**ប្រការ ១៧ .- បុគ្គលពាក់ព័ន្ធនយោបាយ**

១៧.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវពិនិត្យមើលអតិថិជនថ្មីៗ និងបច្ចុប្បន្ន បន្ថែមលើការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនដើម្បីឱ្យដឹងថាអតិថិជនជាបុគ្គលពាក់ព័ន្ធ ឬពុំពាក់ព័ន្ធនយោបាយដូចមានចែងនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ពីអតិថិជននោះ និងត្រូវស្វែងរកព័ត៌មានដែលមានជាសាធារណៈដើម្បីកំណត់កម្រិតហានិភ័យនៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

១៧.២ ខណៈដែលបុគ្គលពាក់ព័ន្ធនយោបាយត្រូវបានសម្គាល់អត្តសញ្ញាណ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាត់វិធានការសមស្របដើម្បីកំណត់ពីប្រភពទ្រព្យសម្បត្តិ និងមូលនិធិរបស់បុគ្គលនោះ។

១៧.៣ គណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវសម្រេចចិត្តក្នុងការចូលរួម ឬបន្តទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលពាក់ព័ន្ធនយោបាយ។

១៧.៤ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបង្កើតសាវតារហានិភ័យនៃបុគ្គលពាក់ព័ន្ធនយោបាយម្នាក់ៗដោយផ្អែកលើព័ត៌មានដែលប្រមូលបានពីអតិថិជន និងការស្រាវជ្រាវឯករាជ្យព្រមទាំងយល់ពីលក្ខណៈនៃទំនាក់

ទំនងអាជីវកម្ម និងសកម្មភាពប្រតិបត្តិការ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតាមដានជាប្រចាំនូវទំនាក់ទំនង និងសកម្មភាពទប់ទល់ហានិភ័យ និងបញ្ហាដែលកើតឡើងពីដំណើរការត្រួតពិនិត្យត្រូវរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបើចាំបាច់។

**ប្រការ ១៨ .- ប្រតិបត្តិការធនាគារកម្មឯកជន** (Private Banking)

១៨.១ អាជីវកម្មធនាគារកម្មឯកជន ត្រូវបានផ្តល់ឱ្យអតិថិជនដែលមានមូលនិធិផ្ទាល់សុទ្ធខ្ពស់និងបុគ្គលពិសេសហើយឯកសិទ្ធិពិសេសសម្ងាត់ និងឯកជននៃប្រតិបត្តិការបែបនេះអាចផ្តល់លទ្ធភាពដល់ការបំភាន់ពីសំណាក់អ្នកសំអាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម។

១៨.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះអាជីវកម្មធនាគារកម្មឯកជន។ នីតិវិធីផ្ទៀងផ្ទាត់និងសម្គាល់អត្តសញ្ញាណត្រូវតែរឹតបន្តឹងជាងនីតិវិធីសម្គាល់អត្តសញ្ញាណធម្មតាជាពិសេសវិធានការផ្ទៀងផ្ទាត់បន្ថែមត្រូវអនុវត្តទាក់ទងនឹងអត្តសញ្ញាណលក្ខណៈអាជីវកម្ម និងប្រភពមូលនិធិអតិថិជន។

១៨.៣ អតិថិជនថ្មី និងអតិថិជនមានស្រាប់ទាំងអស់ដែលទទួលសេវាប្រតិបត្តិការធនាគារកម្មឯកជនត្រូវតែមានការអនុម័តពីគណៈគ្រប់គ្រងជាន់ខ្ពស់ ពោលគឺមិនមែនពីអ្នកគ្រប់គ្រងផ្នែកទំនាក់ទំនងប្រតិបត្តិការ ធនាគារកម្មឯកជនដែលជាអ្នករៀបចំដំណើរការផង និងអនុម័តពាក្យសុំផងទេ។

១៨.៤ មន្ត្រីប្រតិបត្តិ និងសវនករត្រូវតែបានអនុញ្ញាតឱ្យធ្វើសវនកម្ម និងពិនិត្យឡើងវិញលើប្រតិបត្តិការរបស់អតិថិជនជាធនាគារកម្ម។

**ប្រការ ១៩ .- អាជីវករប្តូរប្រាក់**

១៩.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថាអាជីវករប្តូរប្រាក់ដែលមានគណនីនៅគ្រឹះស្ថានបានទទួលអាជ្ញាប័ណ្ណ និងធ្វើប្រតិបត្តិការប្តូរប្រាក់ស្របច្បាប់។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធានាថាលក្ខណៈ និងបរិមាណនៃប្រតិបត្តិការនៅក្នុងគណនីអាជីវករប្តូរប្រាក់បានឆ្លុះបញ្ចាំងនូវលក្ខណៈនៃអាជីវកម្មរបស់អាជីវករទាំងនោះ ។

១៩.២ ប្រសិនបើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរកឃើញសកម្មភាពខុសគ្នាណាមួយនៅក្នុងគណនីរបស់អាជីវករប្តូរប្រាក់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យនោះមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

**ប្រការ ២០ .- អតិថិជនមានហានិភ័យខ្ពស់ផ្សេងទៀត**

២០.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជន ចំពោះអតិថិជនមានហានិភ័យខ្ពស់ផ្សេងទៀត រួមបញ្ចូលអតិថិជនដែលមានហានិភ័យខ្ពស់ ដូចមានចែងនៅក្នុងប្រការ ១៨ និង ១៩នៃប្រកាសនេះ ដើម្បីធានាថាគ្រឹះស្ថានមិនត្រូវបានបំភាន់ដោយអ្នកសំអាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម។

២០.២ ការលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជនបែបនេះយ៉ាងហោចណាស់ត្រូវមាន៖

- ព័ត៌មានលំអិតបន្ថែមទៀតពីអតិថិជន ជាពិសេសគោលបំណងនៃប្រតិបត្តិការ និងប្រភពនៃមូលនិធិ
- ការស្រាវជ្រាវឯករាជ្យ និងរកប្រភពព័ត៌មានបន្ថែមអំពីអតិថិជន និង
- ការអនុម័តពីគណៈគ្រប់គ្រងថ្នាក់ខ្ពស់។

**ប្រការ ២១ .- គណនីមានស្រាប់**

២១.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាថាកំណត់ត្រារអតិថិជនមានស្រាប់នៅតែធ្វើបច្ចុប្បន្នកម្ម និងមានភាពពាក់ព័ន្ធ។ លើសពីនេះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រមូលភស្តុតាងបន្ថែម ស្តីពី អត្តសញ្ញាណអតិថិជនមានស្រាប់ប្រសិនបើចាំបាច់ដើម្បីធានាអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនស្របតាមបទដ្ឋានដែលបានកំណត់ដោយប្រកាសនេះ។

២១.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តការពិនិត្យឡើងវិញឱ្យបានទៀងទាត់លើកំណត់ត្រាមានស្រាប់របស់អតិថិជន។ ការពិនិត្យឡើងវិញនេះយ៉ាងហោចណាស់ធ្វើឡើងនៅពេលៈ

- ប្រតិបត្តិការសំខាន់ៗកើតឡើង
- មានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគណនីដែលមានសកម្មភាព
- មានការផ្លាស់ប្តូរបទដ្ឋាននៃការរៀបចំឯកសាររបស់អតិថិជនយ៉ាងច្រើន ឬ
- ព័ត៌មានដែលទទួលបានពីអតិថិជនពុំគ្រប់គ្រាន់។

២១.៣ ប្រសិនបើគ្មានព្រឹត្តិការណ៍ដូចខាងលើកើតឡើង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវពិចារណាដោយផ្អែកលើការវាយតម្លៃហានិភ័យ និងត្រូវប្រមូលព័ត៌មានបន្ថែមពីអតិថិជនមានស្រាប់ដែលចាត់ទុកថាមានហានិភ័យខ្ពស់ឱ្យស្របតាមបទដ្ឋានបច្ចុប្បន្នរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ២២ .- ការរក្សាទុកឯកសារកត់ត្រា**

២២.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាទុកកំណត់ត្រាឯកសារ និងឯកសារចម្លងទាំងអស់ដែលទាក់ទងនឹងគ្រប់រូបភាពនៃប្រតិបត្តិការឱ្យបានយ៉ាងតិចរយៈពេល ៥ឆ្នាំ នៅក្រោយពេលធ្វើប្រតិបត្តិការ។ គ្រប់ទិន្នន័យ អត្តសញ្ញាណ កំណត់ត្រា ឯកសារ លិខិតទំនាក់ទំនងអាជីវកម្ម និង ឯកសារចម្លង ដែលទទួលបានក្នុងពេលអនុវត្តនីតិវិធីយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែរក្សាទុកឱ្យបានយ៉ាងតិច ៥ឆ្នាំ បន្ទាប់ពីបិទគណនី ឬបន្ទាប់ពីបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ។

២២.២ ករណីដែលកំណត់ត្រាជាកម្មវត្ថុនៃការស៊ើបអង្កេតជាបន្តបន្ទាប់ ឬនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ កំណត់ត្រានោះត្រូវរក្សាទុកឱ្យបានលើសពីរយៈពេលដែលបានកំណត់រហូតដល់អាជ្ញាធរដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតបញ្ជាក់ថាឯកសារទាំងនោះលែងមានសារប្រយោជន៍។

**ប្រការ ២៣ .- ដាននៃសវនកម្ម**

២៣.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវធានាថារាល់ឯកសារនិងកំណត់ត្រាដែលបានរក្សាទុកបង្កើតជាដាននៃសវនកម្មចំពោះប្រតិបត្តិការនីមួយៗ ដែលជួយភ្នាក់ងារត្រួតពិនិត្យនិងភ្នាក់ងារមានសមត្ថកិច្ចដើម្បីតាមដានមូលនិធិ។

២៣.២ កំណត់ត្រាដែលបានរក្សាទុកទាំងនោះត្រូវតែអាចជួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឱ្យបង្កើតប្រវត្តិ និងលក្ខណៈ និងបង្កើតប្រតិបត្តិការនីមួយៗឡើងវិញបាន។ កំណត់ត្រាទាំងនោះយ៉ាងហោចណាស់ត្រូវមានៈ

- ប្រភពមូលនិធិ ដូចជាវិធីសាស្ត្រនៃការទទួល និង/ឬអ្នកផ្តើមប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក
- អត្តសញ្ញាណបុគ្គលដែលធ្វើប្រតិបត្តិការ ប្រសិនបើមិនមែនជាម្ចាស់គណនី

- ប្រភេទប្រតិបត្តិការ និង
- ការណែនាំ និងទិសដៅនៃការផ្ទេរមូលនិធិ

**ប្រការ ២៤ .- ទម្រង់ឯកសារដែលរក្សាទុក**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាទុកឯកសារពាក់ព័ន្ធជាច្បាប់ដើម ឬថតចម្លង ឬមីក្រូហ្វីល ឬក្នុងទម្រង់អេឡិកត្រូនិកតែត្រូវមានសុវត្ថិភាព និងអាចយកមកប្រើប្រាស់នៅពេលត្រូវការ ហើយត្រូវមានលក្ខណៈត្រឹមត្រូវ និងទាន់ពេលវេលា។

**ប្រការ ២៥.- ការតាមដានបន្ត**

២៥.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាបន្តចំពោះទំនាក់ទំនង ជាមួយអតិថិជនទាំងអស់ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកតាមហានិភ័យ។ វិធីសាស្ត្រនេះត្រូវធានាថាសារការហានិភ័យរបស់អតិថិជនត្រូវបានធ្វើបច្ចុប្បន្នកម្ម។

២៥.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ជាពិសេស និងបន្តអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់គ្រប់ប្រតិបត្តិការធំៗមិនប្រក្រតី ស្មុគស្មាញ ឬគំរូនៃប្រតិបត្តិការមិនប្រក្រតីដើម្បីកំណត់ថាតើប្រតិបត្តិការទាំងនេះមាន ឬពុំមានគោលបំណងស្របច្បាប់ច្បាស់លាស់។

**ប្រការ ២៦ .- ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រប់គ្រាន់មួយដើម្បីអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនសម្រាប់សម្គាល់អត្តសញ្ញាណ និងរកឱ្យឃើញនូវប្រតិបត្តិការទាំងឡាយណាដែលខ្លួនសង្ស័យ ឬមានមូលដ្ឋានសមស្របដើម្បីសង្ស័យលើប្រតិបត្តិការដែលជាប់ពាក់ព័ន្ធនឹងផលដែលបានមកពីសកម្មភាពខុសច្បាប់ ឬអតិថិជនដែលជាប់ទាក់ទងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវផ្តល់ឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនូវព័ត៌មានទៀងទាត់ទាន់ពេលវេលាដើម្បីអាចរកសកម្មភាពសង្ស័យ។

**ប្រការ ២៧ .- ការយកចិត្តទុកដាក់ពិសេស**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាបន្តបន្ទាប់អាស្រ័យលើទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការជាមួយឯកត្តបុគ្គល អាជីវកម្ម ក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុមកពីបណ្តាប្រទេសដែលមិនបានអនុវត្តពេញលេញតាមវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលទទួលស្គាល់ជាអន្តរជាតិ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវសួរសំណួរបន្ថែមពីគោលបំណង និងប្រវត្តិប្រតិបត្តិការ និងទំនាក់ទំនងអាជីវកម្មបែបនេះឱ្យបានលំអិតជាលាយលក្ខណ៍អក្សរ និងបញ្ជូនដល់អាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ ២៨ .- របាយការណ៍ប្រតិបត្តិការសាច់ប្រាក់**

២៨.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនូវប្រតិបត្តិការសាច់ប្រាក់ដែលស្មើ ឬលើសពី ៤០ លានរៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

២៨.២ ប្រតិបត្តិការសាច់ប្រាក់ត្រូវផ្តល់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកំឡុងពេល ១៤ ថ្ងៃក្រោយកាលបរិច្ឆេទនៃប្រតិបត្តិការ ហើយត្រូវបំពេញក្នុងទម្រង់ "របាយការណ៍ប្រតិបត្តិការសាច់ប្រាក់" ដែលបានអនុម័តដោយ

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ឬទម្រង់ដែលបានអនុម័តសម្រាប់ការរាយការណ៍តាមអេឡិកត្រូនិក។ ច្បាប់ចម្លងនៃទម្រង់របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ត្រូវបានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី៤។

២៨.៣ ប្រតិបត្តិការសាច់ប្រាក់ដែលអាចរាយការណ៍បាន រួមមានប្រតិបត្តិការសាច់ប្រាក់ច្រើនសន្ទឹកសន្ធាប់របស់អតិថិជនម្នាក់/គណនីមួយដែលមានចំនួនសរុបនៃប្រតិបត្តិការរួមគ្នាក្នុងមួយថ្ងៃលើសពី ៤០ លានរៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

## ប្រការ ២៩ .- របាយការណ៍ប្រតិបត្តិការសង្ស័យ

២៩.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យបង្កើតប្រព័ន្ធរាយការណ៍ និងបញ្ជូនរបាយការណ៍ពីប្រតិបត្តិការសង្ស័យភ្លាមៗមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ នៅពេលនិយោជិតរបស់ខ្លួនសង្ស័យ ឬមានមូលដ្ឋានសមស្របសង្ស័យថា ប្រតិបត្តិការនោះជាប់ពាក់ព័ន្ធនឹងប្រាក់បានមកពីផលនៃបទល្មើស ឬ អតិថិជនជាប់ពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម។ ឧទាហរណ៍នៃប្រតិបត្តិការសង្ស័យ ត្រូវបានលើកឡើងក្នុងតារាងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។ ឧទាហរណ៍ទាំងនេះមិនមែនសរុបជារួមទេគឺ គ្រាន់តែផ្តល់ជាវិធីសាស្ត្រមូលដ្ឋានអំពីការសំអាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើតសេចក្តីណែនាំផ្ទៃក្នុងផ្ទាល់ខ្លួនអំពីការរាយការណ៍ប្រតិបត្តិការសង្ស័យដោយផ្សារភ្ជាប់ជាមួយច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្ម និងបញ្ញត្តិដែលបានចែងនៅក្នុងប្រកាសនេះរួមទាំងមានតារាងផ្ទាល់ខ្លួនស្តីពីសូចនាករប្រតិបត្តិការសង្ស័យផងដែរ។

២៩.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនៅពេលដែលអតិថិជនថ្មី ឬអតិថិជនមានស្រាប់មិនបានបំពេញនូវកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនដោយគ្មានហេតុផលសមស្រប ដោយពុំគិតថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលយក បដិសេធ បន្ត ឬបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជននោះ។

## ប្រការ ៣០ .- យន្តការរាយការណ៍

៣០.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីថ្នាក់គ្រប់គ្រងជាន់ខ្ពស់មួយរូបធ្វើជាមន្ត្រីប្រតិបត្តិទទួលខុសត្រូវក្នុងការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ មន្ត្រីប្រតិបត្តិដែលទទួលបានការតែងតាំងត្រូវដើរតួនាទីជាអ្នកទំនាក់ទំនងតែម្នាក់គត់ សម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថារាល់របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលបានធ្វើឡើងដោយនិយោជិតត្រូវបានផ្តល់ឱ្យមន្ត្រីប្រតិបត្តិយ៉ាងសមស្រប ។

៣០.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវណែនាំនិយោជិតឱ្យរាយការណ៍ប្រតិបត្តិការសង្ស័យទៅមន្ត្រីប្រតិបត្តិទោះបីជាគេពុំដឹងច្បាស់ថាប្រតិបត្តិការនោះជាសកម្មភាពខុសច្បាប់ ឬ ពិតជាកើតឡើងក៏ដោយ។

៣០.៣ នៅពេលទទួលបានរបាយការណ៍ប្រតិបត្តិការសង្ស័យ មន្ត្រីប្រតិបត្តិត្រូវវាយតម្លៃ និងកំណត់ភ្លាមៗពីមូលដ្ឋានសមហេតុផលក្នុងការសង្ស័យ និងត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនេះជាបន្ទាន់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងរយៈពេល ២៤ម៉ោង ប្រសិនបើមន្ត្រីប្រតិបត្តិគិតថាគ្មានមូលហេតុសមហេតុផលទេនោះត្រូវកត់ត្រាតែមតិរបស់ខ្លួនប៉ុណ្ណោះ។

៣០.៤ របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលបញ្ជូនមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដោយមន្ត្រីប្រតិបត្តិត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដូចមានក្នុងឧបសម្ព័ន្ធទី៣ ហើយត្រូវប្រគល់ដោយសុវត្ថិភាពដោយផ្ទាល់ដៃ ឬតាមសំបុត្រដែលមានសុវត្ថិភាព និងតាមអេឡិកត្រូនិកជាដើម។

៣០.៥ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថានៅពេលរៀបចំ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនោះត្រូវរក្សាការសម្ងាត់ និងអាចដឹងព័ត៌មាននេះបានត្រឹមតែបុគ្គលិកដែលមានសិទ្ធិប៉ុណ្ណោះ។

៣០.៦ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់សិទ្ធិឱ្យមន្ត្រីប្រតិបត្តិការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងការផ្តល់ព័ត៌មាននិងឯកសារចាំបាច់បន្ថែមទៅតាមសំណើសុំ និងឆ្លើយតបរាល់ការសាកសួរដែលពាក់ព័ន្ធនឹងរបាយការណ៍ប្រតិបត្តិការសង្ស័យ ។

**ប្រការ ៣១ .- ការហាមឃាត់ការផ្តល់ព័ត៌មាន**

៣១.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាប្រព័ន្ធរាយការណ៍ដែលបានបង្កើតសម្រាប់បញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានដំណើរការជាសម្ងាត់។

៣១.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាអតិថិជនដែលបានរាយការណ៍នេះមិនត្រូវបានផ្តល់ព័ត៌មាន ឬមិនបានដឹងថាមានរបាយការណ៍ប្រតិបត្តិការនេះទេ។ បុគ្គលិកទាំងអស់ត្រូវយល់ដឹងអំពីមាត្រាទី ១៥ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានចែងអំពីការហាមឃាត់បុគ្គលណាដែលបានដឹងអំពីប្រតិបត្តិការសង្ស័យមិនត្រូវផ្តល់ព័ត៌មានឬរាយការណ៍ទាំងនោះទៅបុគ្គលផ្សេងក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

**ប្រការ ៣២ .- បញ្ហាផ្សេងទៀត**

៣២.១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរក្សាទុកឯកសាររបាយការណ៍ប្រតិបត្តិការសង្ស័យដែលនិយោជិតបានផ្ញើទៅមន្ត្រីប្រតិបត្តិ និងបានផ្ញើបន្តមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

៣២.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការសមហេតុផលដើម្បីធ្វើយ៉ាងណាឱ្យមន្ត្រី និងនិយោជិតដែលពាក់ព័ន្ធនឹងការអនុវត្ត ឬសម្របសម្រួលប្រតិបត្តិការរបស់អតិថិជនយល់ដឹងពីនីតិវិធីរាយការណ៍។

**ប្រការ ៣៣ .- ការរកឃើញ និងការរាយការណ៍ពីហិរញ្ញប្បទានភេរវកម្ម**

៣៣.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចាត់វិធានការចាំបាច់ ដើម្បីអនុវត្តឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ និង ច្បាប់ និងបទប្បញ្ញត្តិស្តីពីហិរញ្ញប្បទានភេរវកម្ម។

៣៣.២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវធានាថាប្រព័ន្ធ និងយន្តការរាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានពង្រីកគ្របដណ្តប់លើការសង្ស័យពីហិរញ្ញប្បទានភេរវកម្ម។

៣៣.៣ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាមូលដ្ឋានទិន្នន័យដែលមានឈ្មោះ និងព័ត៌មានលំអិតរបស់ភេរវករដែលមានក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ ហើយត្រូវយកចិត្តទុកដាក់ដល់ការបញ្ចូលគ្នារវាងមូលដ្ឋានទិន្នន័យរបស់ខ្លួន និងបញ្ជីឈ្មោះបុគ្គលដែលបានសម្គាល់អត្តសញ្ញាណផ្សេងទៀត។ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្ម និងមានទំនាក់ទំនងគ្នាហើយផ្តល់លទ្ធភាពងាយស្រួលដល់និយោជិតក្នុងការប្រើប្រាស់សម្រាប់សំគាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងការបង្កកគណនី/មូលនិធិ។

៣៣.៤ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវពិនិត្យមើលឈ្មោះរបស់អតិថិជនថ្មី និងអតិថិជនមានស្រាប់ជាមួយនឹងឈ្មោះដែលមាននៅក្នុងមូលដ្ឋានទិន្នន័យ។ ប្រសិនបើមានឈ្មោះដូចគ្នា គ្រឹះស្ថានធនាគារ និង

ហិរញ្ញវត្ថុត្រូវចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជននោះ។ ប្រសិនបើឈ្មោះអតិថិជន និងឈ្មោះនៅក្នុងមូលដ្ឋានទិន្នន័យជាឈ្មោះតែមួយហើយជាមនុស្សតែម្នាក់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កកគណនីរបស់អតិថិជននោះ និងត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជាបន្ទាន់។ នៅពេលដែលមានការសង្ស័យថាប្រតិបត្តិការមួយពាក់ព័ន្ធនឹងភេរវករ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**ប្រការ ៣៤ .- ការគ្រប់គ្រងហានិភ័យ**

៣៤.១ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដើម្បីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលស្របតាមការតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិ។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវឱ្យមានការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងមានប្រសិទ្ធភាព។

៣៤.២ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវដឹង និងយល់ពីវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលតម្រូវដោយច្បាប់ បញ្ញត្តិករ បទដ្ឋានតាមវិស័យនីមួយៗ និងការអនុវត្តដ៏ប្រសើរក៏ដូចជាសារសំខាន់នៃការបង្កើតឱ្យមានវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីទប់ស្កាត់ការរំលោភបំពានរបស់អ្នកសំអាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម មកលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាភិបាលត្រូវត្រួតពិនិត្យឱ្យបានល្អិតល្អន់លើវិធានការទូទៅប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវអនុវត្តដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៣៤.៣ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវដឹងពីហានិភ័យនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធនឹងរាល់សេវាកម្ម និងផលិតផលអាជីវកម្មរបស់ខ្លួន។

៣៤.៤ ក្រុមប្រឹក្សាភិបាលត្រូវធានាថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុយ៉ាងតិចបំផុតត្រូវមានគោលការណ៍ស្តីពីនីតិវិធី និងការត្រួតពិនិត្យការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវជួយក្រុមប្រឹក្សាភិបាលក្នុងការបង្កើតគោលការណ៍ ហើយត្រូវធានាថា គោលការណ៍នេះស្របតាមហានិភ័យដែលពាក់ព័ន្ធនឹងលក្ខណៈអាជីវកម្ម ភាពស្មុគស្មាញ និងទំហំប្រតិបត្តិការដែលអនុវត្តដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៣៤.៥ ក្រុមប្រឹក្សាភិបាលត្រូវធានាថា គ្រឹះស្ថានមានការអនុវត្តនីតិវិធីសម្រាប់វិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រួមទាំងគោលការណ៍ទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារ ការតាមដានជាប្រចាំ ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រឆាំងហិរញ្ញប្បទានភេរវកម្ម។

៣៤.៦ ក្រុមប្រឹក្សាភិបាលត្រូវវាយតម្លៃការអនុវត្តរបស់គណៈគ្រប់គ្រងជាន់ខ្ពស់លើគោលការណ៍ប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានអនុម័តតាមរយៈរបាយការណ៍ប្រចាំគ្រា។

៣៤.៧ ក្រុមប្រឹក្សាភិបាលត្រូវកំណត់សិទ្ធិនិងការទទួលខុសត្រូវក្នុងការអនុវត្តវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយត្រូវធានាថាមានការបែងចែកភារកិច្ចរវាងការអនុវត្តគោលការណ៍ និងនីតិវិធី និងការត្រួតពិនិត្យ។ ក្រុមប្រឹក្សាភិបាលត្រូវធានាឱ្យមាន៖

- ការតែងតាំងមន្ត្រីប្រតិបត្តិម្នាក់ដើម្បីធានាថាគោលការណ៍ នីតិវិធី និង ការត្រួតពិនិត្យ ត្រូវបានអនុវត្ត និង

- ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុងលើការសិក្សា និងវាយតម្លៃការត្រួតពិនិត្យដើម្បីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

៣៤.៨ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យឡើងវិញ និងវាយតម្លៃគោលការណ៍ និងនីតិវិធីស្តីពីវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលស្របនឹងការផ្លាស់ប្តូរ និងការរីកចម្រើននៃផលិតផល សេវាកម្ម និងប្រព័ន្ធបច្ចេកវិទ្យា ព្រមទាំងស្របនឹងនិន្នាការនៃបច្ចេកទេសសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវក្នុងការអនុវត្តភាពផ្លាស់ប្តូរចាំបាច់លើគោលការណ៍និងនីតិវិធីដោយមានការអនុម័តពីក្រុមប្រឹក្សាភិបាល ដើម្បីធានាថាគោលការណ៍ថ្មីនេះមានភាពរឹងមាំ និងសមស្រប។

៣៤.៩ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវផ្តល់ការបណ្តុះបណ្តាល និងការអប់រំឱ្យបានគ្រប់គ្រាន់ដល់និយោជិតរបស់ខ្លួនស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ៣៥.- សុចរិតភាពបុគ្គលិក**

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បង្កើតប្រព័ន្ធវាយតម្លៃនិយោជិតដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យឱ្យបានគ្រប់គ្រាន់ថាសុចរិតភាពបុគ្គលិករបស់ខ្លួនទាំងថ្មី និងចាស់មិនត្រូវបានរំលោភ។ ប្រព័ន្ធវាយតម្លៃនិយោជិតនេះ យ៉ាងហោចណាស់ត្រូវពិនិត្យមើលព័ត៌មានរបស់បុគ្គលរួមមានលិខិតថ្កោលទោស ប្រវត្តិការងារ និងហិរញ្ញវត្ថុរបស់បុគ្គលិកថ្មីដែលជាផ្នែកមួយនៃដំណើរការជ្រើសរើសបុគ្គលិក។

**ប្រការ ៣៦ .- មន្ត្រីប្រតិបត្តិ**

៣៦.១ គណៈគ្រប់គ្រងជាន់ខ្ពស់ទទួលខុសត្រូវតែងតាំងមន្ត្រីប្រតិបត្តិជាថ្នាក់នាយកគ្រប់គ្រងជាន់ខ្ពស់ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថា មន្ត្រីប្រតិបត្តិអនុវត្តការទទួលខុសត្រូវ ចំពោះការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព។ មន្ត្រីប្រតិបត្តិដើរតួជាអ្នកទំនាក់ទំនងសម្រាប់វិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានបង្កើតរួមមានការបណ្តុះបណ្តាលនិយោជិត និង ការរាយការណ៍ពីប្រតិបត្តិការសង្ស័យ។

៣៦.២ នៅពេលតែងតាំង ឬផ្លាស់ប្តូរមន្ត្រីប្រតិបត្តិគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអំពីព័ត៌មានលំអិតនៃមន្ត្រីប្រតិបត្តិនោះ រួមមាន ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល និងប្រវត្តិពាក់ព័ន្ធផ្សេងៗទៀត។

៣៦.៣ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកំណត់ និងចងក្រងជាឯកសារឱ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីប្រតិបត្តិ។ តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីប្រតិបត្តិក្នុងការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម យ៉ាងហោចណាស់ត្រូវធានាថា ៖

- អនុវត្តតាមគោលការណ៍នៃវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តប្រកបដោយប្រសិទ្ធភាព នូវនីតិវិធីសមស្របស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលរួមមានគោលការណ៍ទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាកំណត់ត្រា ការតាមដានបន្ត ការរាយការណ៍ពីប្រតិបត្តិការសង្ស័យ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម

- វាយតម្លៃទៀងទាត់លើយន្តការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាថា យន្តការនោះមានលក្ខណៈគ្រប់គ្រាន់ឆ្លើយតបតាមនិន្នាការប្រែប្រួល
- បណ្តាញទំនាក់ទំនងទៅវិញទៅមកពីនិយោជិតទៅមន្ត្រីត្រូវបានរក្សាឱ្យមានសុវត្ថិភាព ហើយ ព័ត៌មានទាំងអស់ត្រូវបានរក្សាជាការសម្ងាត់
- អនុវត្តស្របតាមតម្រូវការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- និយោជិតទាំងអស់ត្រូវដឹងពីវិធានការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមាន គោលការណ៍ យន្តការត្រួតពិនិត្យ និងបណ្តាញរាយការណ៍ ដើម្បីធានាពីប្រសិទ្ធភាពនៃវិធានការ ទាំងនោះ
- សម្គាល់អត្តសញ្ញាណហានិភ័យនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលពាក់ព័ន្ធនឹង ផលិតផល ឬ សេវាកម្មថ្មី ឬ ដែលកើតឡើងពីការប្រែប្រួលនៃប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ រួមមានការណែនាំឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី និងដំណើរការថ្មី។

៣៦.៤ មន្ត្រីប្រតិបត្តិត្រូវមានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីអនុវត្តការទទួលខុសត្រូវប្រកបដោយ ប្រសិទ្ធភាព រួមមានចំណេះដឹងពីកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលតម្រូវដោយ ច្បាប់ និងបទប្បញ្ញត្តិ ការវិវឌ្ឍន៍ និងបច្ចេកទេសថ្មីៗនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ៣៧ .- កម្មវិធីបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលបុគ្គលិក**

៣៧.១ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវមានកម្មវិធីបណ្តុះបណ្តាល និងបង្កើនការយល់ដឹងស្តីពីវិធានការ និង ការអនុវត្តការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់និយោជិតរបស់ខ្លួន។

៣៧.២ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាឱ្យមានបណ្តាញទំនាក់ទំនងសមស្រប ដើម្បីផ្តល់ព័ត៌មានដល់ បុគ្គលិកគ្រប់ថ្នាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពីគោលការណ៍ និងនីតិវិធីប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម។

៣៧.៣ និយោជិតត្រូវដឹងពីគោលការណ៍ត្រួតពិនិត្យ និងកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្ប-ទានភេរវកម្មដែលបានបញ្ជាក់នៅក្នុងប្រកាស និងនៅក្នុងក្បួនខ្នាតត្រួតពិនិត្យផ្ទៃក្នុងស្តីពី ការប្រឆាំងការសំអាត ប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

៣៧.៤ ក្បួនត្រួតពិនិត្យផ្ទៃក្នុងនៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវមានយ៉ាងហោច ណាស់៖

- ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- អនុសាសន៍ ៤០ និង អនុសាសន៍ពិសេស ៩ របស់ក្រុមការងារហិរញ្ញវត្ថុ
- ឯកសារយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់គណៈកម្មការបាសែលស្តីពី ការត្រួតពិនិត្យធនាគារ និង
- វិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានបង្កើតឡើង ដើម្បីបំពេញតម្រូវការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

៣៧.៥ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ យ៉ាងហោចណាស់ត្រូវអនុវត្តតាមតម្រូវការបណ្តុះបណ្តាលដូចខាងក្រោមសម្រាប់និយោជិតនៅតាមផ្នែកផ្សេងៗក្នុងគ្រឹះស្ថានរបស់ខ្លួន៖

**និយោជិតថ្មី**

ប្រវត្តិទូទៅនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តម្រូវការនិងកាតព្វកិច្ចសម្គាល់អត្តសញ្ញាណ និងរាយការណ៍ប្រតិបត្តិការសង្ស័យជូនបុគ្គលដែលទទួលបានការតែងតាំងត្រឹមត្រូវក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយត្រូវទទួលបានការណែនាំឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃការមិនបង្ហាញព័ត៌មានប្រាប់អតិថិជន។

**និយោជិតជួរមុខ**

និយោជិតដែលទាក់ទងផ្ទាល់ជាមួយអតិថិជន ជាអ្នកទំនាក់ទំនងដំបូងជាមួយអ្នកសំអាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មដែលមានសក្តានុពល ត្រូវបណ្តុះបណ្តាលអំពីការសម្គាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងវិធានការចាំបាច់ត្រូវអនុវត្តនៅពេលដែលប្រតិបត្តិការមួយមានលក្ខណៈគួរឱ្យសង្ស័យ កត្តាដែលអាចនាំដល់ការសង្ស័យ ការរាយការណ៍ប្រតិបត្តិការដែលមាន ចំនួនសាច់ប្រាក់ច្រើន និងការពង្រឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន។

**និយោជិត-ការបើកគណនី/អតិថិជនថ្មី**

និយោជិតដែលទទួលខុសត្រូវបើកគណនី ឬទទួលអតិថិជនថ្មី យ៉ាងហោចណាស់ត្រូវទទួលការបណ្តុះបណ្តាលដូចគ្នានឹងនិយោជិតជួរមុខ។ លើសពីនេះ និយោជិតគ្រប់រូបត្រូវទទួលបានការបណ្តុះបណ្តាលពីការសម្គាល់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់អតិថិជន ការបើកគណនី ឬការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន។

**អ្នកត្រួតពិនិត្យ និង អ្នកគ្រប់គ្រង**

កម្រិតខ្ពស់បំផុតនៃការណែនាំដែលគ្របដណ្តប់គ្រប់ទិដ្ឋភាពនៃនីតិវិធីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញ-ប្បទានភេរវកម្មត្រូវបានផ្តល់ទៅឱ្យអ្នកត្រួតពិនិត្យ និងអ្នកគ្រប់គ្រង ដែលរួមមានការពិន័យចំពោះការមិនគោរពតាមការតម្រូវនៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងនីតិវិធីកំណត់ការប្រឆាំងហិរញ្ញ-ប្បទានភេរវកម្ម ។

៣៧.៦ កម្មវិធីបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលទាំងនេះត្រូវធ្វើឡើងជាទៀងទាត់ដោយផ្តល់វគ្គសិក្សាថ្មីៗដល់និយោជិត។ និយោជិតថ្មីត្រូវបណ្តុះបណ្តាលក្នុងរយៈពេលបីខែមុនការចាប់ផ្តើមបំពេញការងារ ហើយចំពោះ និយោជិតជួរមុខ អ្នកត្រួតពិនិត្យ និងអ្នកគ្រប់គ្រងត្រូវផ្តល់វគ្គសិក្សាថ្មីៗប្រចាំឆ្នាំ។

## ប្រការ ៣៨ .- សវនកម្មផ្ទៃក្នុង

៣៨.១ ក្រុមប្រឹក្សាភិបាលត្រូវធានាថា សវនករផ្ទៃក្នុងត្រួតពិនិត្យប្រសិទ្ធភាព និងការប្រតិបត្តិតាមតម្រូវការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលមានក្នុងច្បាប់ បទប្បញ្ញត្តិ និងប្រកាសនេះ។

៣៨.២ ក្រុមប្រឹក្សាភិបាលត្រូវកំណត់ និងរៀបចំឯកសារឱ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង យ៉ាងហោចណាស់ត្រូវមាន៖

- ការសាកល្បងប្រសិទ្ធភាពនៃគោលការណ៍ នីតិវិធី និងការត្រួតពិនិត្យលើវិធានការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- ការធានាប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រួមមានការតែងតាំងមន្ត្រីប្រតិបត្តិ កម្មវិធីបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលបុគ្គលិក យន្តការពិនិត្យតាមដាននិយោជិត ក្បួនផ្ទៃក្នុងស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង
- ការធានាថា វិធានការបានបង្កើតស្របគ្នានឹងការរីកចម្រើន និងបំរែបំរួលបច្ចុប្បន្ននៃតម្រូវការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលជាប់ពាក់ព័ន្ធ។

៣៨.៣ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ពីការតែងតាំង ឬការផ្លាស់ប្តូរសវនករផ្ទៃក្នុង និងពីវិធីសាស្ត្រនិងនីតិវិធី ដែលបានអនុវត្តដោយសវនករផ្ទៃក្នុង។

៣៨.៤ សវនករផ្ទៃក្នុងត្រូវបញ្ជូនរបាយការណ៍ជាលាយល័ក្ខអក្សរពីការរកឃើញសវនកម្មទៅក្រុមប្រឹក្សាភិបាលឱ្យបានទៀងទាត់។ របាយការណ៍សវនកម្មប្រចាំឆ្នាំត្រូវបានប្រើប្រាស់ដើម្បីគូសបញ្ជាក់ពីភាពមិនគ្រប់គ្រាន់នៃវិធានការ និងប្រព័ន្ធត្រួតពិនិត្យការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាភិបាលត្រូវចាត់វិធានការចាំបាច់ក្នុងការកែតម្រូវស្ថានការណ៍នេះ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនការរកឃើញ និងរបាយការណ៍សវនកម្មបែបនេះមកធនាគារជាតិនៃកម្ពុជា ឱ្យបានទៀងទាត់ ក្រោយពីបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ប្រការ ៣៩** .-

ប្រកាសនេះជំនួស និងនិរាករណ៍ប្រកាសស្តីពីនីតិវិធីជាបទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណ នៃការសំអាតប្រាក់ នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ និងសារាចរណែនាំស្តីពីប្រតិបត្តិការសង្ស័យ និងគោលនយោបាយស្គាល់អតិថិជនដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០០៣។

**ប្រការ ៤០** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤១** .-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធទី ១ នៃប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
# ការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

យោងតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

**ការសំអាតប្រាក់មានន័យថា៖**

១. ការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណង បិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណា ដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។

២. ការបិទបាំង ឬ ការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។

៣. ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះ បានមកពីបទល្មើស។

៤. ការចូលរួមការប៉ុនប៉ងប្រព្រឹត្តដោយជួយ និងជម្រុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របតាមមាត្រា៣ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ហិរញ្ញប្បទានភេរវកម្ម** គឺជាការផ្តល់ដោយចេតនានូវសេវាហិរញ្ញវត្ថុ ឬ សេវាផ្សេងទៀត ក្នុងគោលបំណងប្រើប្រាស់សេវានេះ ឬដោយដឹងថាមូលនិធិនេះនឹងត្រូវបាន ឬអាចប្រើទាំងមូល ឬមួយផ្នែកសម្រាប់គាំទ្រភេរវកម្ម សកម្មភាពរបស់ភេរវករ ឬ អង្គការចាត់តាំងរបស់ភេរវកម្ម។

## ឧបសម្ព័ន្ធទី ២ នៃប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឧទាហរណ៍នៃប្រតិបត្តិការសង្ស័យ

### ប្រតិបត្តិការសាច់ប្រាក់ ការដាក់ប្រាក់បញ្ញើ និងការដកប្រាក់បញ្ញើ

១. ការដាក់ប្រាក់បញ្ញើជាសាច់ប្រាក់ដែលមានចំនួនច្រើនខុសប្រក្រតី ដោយឯកត្តបុគ្គល ឬក្រុមហ៊ុនដែលសកម្មភាពអាជីវកម្មរបស់គេធ្វើឡើងតាមរយៈមូលប្បទានប័ត្រ និងឧបករណ៍ដទៃទៀត។

២. ការកើនឡើងយ៉ាងគំហុកនៃការដាក់ប្រាក់បញ្ញើជាសាច់ប្រាក់របស់ឯកត្តបុគ្គល ឬអាជីវកម្មណាមួយដោយគ្មានមូលហេតុជាក់ស្តែង ជាពិសេសប្រសិនបើប្រាក់បញ្ញើនេះត្រូវបានផ្ទេរក្នុងកំឡុងពេលដ៏ខ្លីចេញពីគណនី និង/ឬ ទៅកាន់ទិសដៅដែលជាធម្មតាមិនជាប់ពាក់ព័ន្ធនឹងអតិថិជន។

៣. គណនីក្រុមហ៊ុនមានប្រតិបត្តិការដាក់ និងដកជាសាច់ប្រាក់ ជាជាងប្រតិបត្តិការដែលធ្វើឡើងតាមរូបភាពជាឥណទាន ឬជាឥណពន្ធដែលជាធម្មតាជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម (មូលប្បទានប័ត្រ លិខិតឥណទាន រូបិយយាណត្តិ ។ល។ )។

៤. អតិថិជនដែលជានិច្ចកាល បង់ជាសាច់ប្រាក់ ដើម្បីស្នើសុំមូលប្បទានប័ត្រធនាគារ ការផ្ទេរប្រាក់ ឬឧបករណ៍រូបិយវត្ថុ ដែលអាចជួញដូរបាន ឬដែលអាចទូទាត់បានផ្សេងៗទៀត។

៥. អតិថិជនដែលយកក្រដាសប្រាក់ប្រភេទតូចៗមានបរិមាណច្រើនមកប្តូរយកក្រដាសប្រាក់ប្រភេទធំៗ។

៦. សាខាធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានប្រតិបត្តិការជាសាច់ប្រាក់ច្រើនជាងធម្មតា (ស្ថិតិរបស់ទីស្នាក់ការកណ្តាលបង្ហាញភាពមិនប្រក្រតីនៃប្រតិបត្តិការជាសាច់ប្រាក់)។

៧. អតិថិជនដែលដាក់ប្រាក់បញ្ញើ ក្នុងនោះមានក្រដាសប្រាក់ ឬឧបករណ៍ទូទាត់ក្លែងក្លាយ។

៨. អតិថិជនដែលផ្ទេរប្រាក់មានចំនួនច្រើនទៅ ឬមកពីបរទេសដោយបញ្ជាឱ្យទូទាត់ជាសាច់ប្រាក់។

៩. ការទិញ ឬលក់រូបិយប័ណ្ណបរទេសដែលមានចំនួនច្រើនដោយទូទាត់ជាសាច់ប្រាក់ ទោះបីជាអតិថិជនមានគណនីជាមួយធនាគារក៏ដោយ។

១០. អតិថិជនដែលដាក់ប្រាក់បញ្ញើជាញឹកញាប់ ហើយមានចំនួនច្រើន ប៉ុន្តែមូលប្បទានប័ត្រដែលដកប្រាក់ពីគណនីនោះត្រូវបានទូទាត់ឱ្យឯកត្តបុគ្គល និងក្រុមហ៊ុនដែលជាធម្មតាមិនជាប់ពាក់ព័ន្ធនឹងអាជីវកម្មលក់រាយរបស់គេ។

១១. ប្រាក់បញ្ញើរបស់អង្គភាពអាជីវកម្ម ដោយរួមបញ្ចូលឧបករណ៍រូបិយវត្ថុ ដែលជាធម្មតាមិនជាប់ពាក់ព័ន្ធនឹងអាជីវកម្មបែបនោះ។

១២. ការរួមបញ្ចូលគ្នានៃការដាក់ប្រាក់បញ្ញើជាសាច់ប្រាក់ និងឧបករណ៍រូបិយវត្ថុទៅក្នុងគណនីមួយ ដែលប្រតិបត្តិការបែបនេះហាក់ដូចជាមិនជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ជាធម្មតានៃគណនីនេះ។

១៣. ប្រតិបត្តិការចំរុះដែលធ្វើឡើងក្នុងថ្ងៃតែមួយនៅសាខាតែមួយរបស់គ្រឹះស្ថានហិរញ្ញវត្ថុតែមួយ ប៉ុន្តែមានការប៉ុនប៉ងជាក់ស្តែង ដោយប្រើប្រាស់បេឡាករផ្សេងគ្នា។

១៤. ការបែងចែកប្រាក់បញ្ញើតាមរយៈសាខាផ្សេងៗរបស់គ្រឹះស្ថានហិរញ្ញវត្ថុតែមួយ ឬតាមរយៈបុគ្គលច្រើនរូបដែលចូលមកសាខាតែមួយក្នុងពេលដូចគ្នា។

១៥. ការដាក់ឬការដកសាច់ប្រាក់ ក្នុងចំនួនមួយទាបជាងតិចតួចនៃកម្រិតកំណត់លើការសម្គាល់អត្តសញ្ញាណ ឬលើកម្រិតរាយការណ៍។

១៦. អតិថិជនបង្ហាញប្រាក់ដែលមិនទាន់រាប់ ហើយបន្ទាប់ពីរាប់រួចអតិថិជននោះកាត់បន្ថយចំនួនប្រាក់ឱ្យនៅទាបជាងកម្រិតមួយដែលតម្រូវឱ្យរាយការណ៍ ឬសម្គាល់អត្តសញ្ញាណ។

១៧. ការដាក់ឬដកឧបករណ៍រូបិយវត្ថុចំរុះត្រឹមចំនួនមួយទាបជាងតិចតួចនៃកំរិតកំណត់ ដែលត្រូវរាយការណ៍ឬសម្គាល់អត្តសញ្ញាណ ជាពិសេសប្រសិនបើឧបករណ៍នោះមានចុះលេខតាមលំដាប់លំដោយ។

**គណនី**

១៨.គណនីដែលដើរតួនាទីគណនីឆ្លងកាត់ (Pass Through Account) ដោយមានចំនួនឥណទាន និងឥណពន្ធច្រើន ហើយសមតុល្យជាមធ្យមប្រចាំខែទាប។

១៩ អតិថិជនដែលមានបំណងរក្សាគណនីអតិថិជន ឬ គណនីអ្នកទទួលអាណត្តិព្យាបាលដែលមិនស៊ីសង្វាក់គ្នាទៅនឹងប្រភេទអាជីវកម្ម រួមទាំងប្រតិបត្តិការអាជីវកម្មដែលជាប់ពាក់ព័ន្ធនឹងឈ្មោះអ្នកតំណាង។

២០.ការបើកគណនីច្រើនដោយបុគ្គលមួយរូប ដោយដាក់ប្រាក់បញ្ញើមានចំនួនតិចតួចជាច្រើនដែលសរុបចំនួនទាំងអស់មិនស៊ីគ្នានឹងប្រាក់ចំណូលដែលបានរំពឹងទុករបស់បុគ្គលនោះ។

២១.បុគ្គល ឬក្រុមហ៊ុនដែលមានគណនី មិនមានបង្ហាញពីសកម្មភាពធនាគារឬអាជីវកម្មធ្លាល់ប្រក្រតី ប៉ុន្តែត្រូវបានប្រើប្រាស់ដើម្បីទទួល ឬបញ្ចេញប្រាក់ចំនួនច្រើនដោយគ្មានគោលបំណង ឬទំនាក់ទំនងជាក់លាក់ចំពោះម្ចាស់គណនី និង/ឬ អាជីវកម្មរបស់គាត់ (ឧទាហរណ៍ កំណើនដ៏ច្រើននៃផលចំណូលលើគណនី)។

២២.ការស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មាននៅពេលបើកគណនី ការប៉ុនប៉ងកាត់បន្ថយកម្រិតព័ត៌មានឱ្យដល់កម្រិតអប្បបរមា ឬព័ត៌មានដែលត្រូវផ្តល់ឱ្យមានការលំបាក ឬតម្លៃថ្លៃសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្ទៀងផ្ទាត់។

២៣.អតិថិជនដែលមានគណនីនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាច្រើនដែលស្ថិតនៅក្នុងតំបន់តែមួយ ហើយប្រមូលប្រាក់ពីគណនីនៅគ្រឹះស្ថានផ្សេងៗនោះ ផ្ទេរទៅគណនីរបស់តតិយភាគីជាទៀងទាត់។

២៤.ទូទាត់ជាមូលប្បទានប័ត្រមានចំនួនទឹកប្រាក់ច្រើនរបស់តតិយភាគី ដែលត្រូវបានចិដ្ឋិលេខដើម្បីជាផលប្រយោជន៍អតិថិជន។

២៥. គណនីមិនដំណើការដែលមានចំនួនទឹកប្រាក់តិចតួច ស្រាប់តែមួយរំពេចទទួលបានប្រាក់បញ្ញើជាច្រើន ហើយបន្ទាប់មកត្រូវបានដកចេញវិញជារៀងរាល់ថ្ងៃ រហូតដល់ចំនួនប្រាក់ផ្ទេរនោះត្រូវបានដកអស់។

២៦.ការប្រើប្រាស់ឧបករណ៍ដាក់ប្រាក់សុវត្ថិភាពច្រើន ដែលមិនស៊ីគ្នានឹងទំហំអាជីវកម្មរបស់ធនាគារ។

២៧.អតិថិជនដែលចៀសវាងមិនធ្វើការទាក់ទង ជាមួយបុគ្គលិករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សម្រាប់ការធ្វើប្រតិបត្តិការអាជីវកម្ម។

២៨.កំណើនការដាក់ប្រាក់បញ្ញើជាសាច់ប្រាក់ច្រើន ឬឧបករណ៍អាចជួញដូរបានរបស់ក្រុមហ៊ុនឬសហគ្រាសវិជ្ជាជីវៈ ដោយប្រើប្រាស់គណនីរបស់អតិថិជនឬក្រុមហ៊ុនក្នុងស្រុក ឬគណនីអាណត្តិព្យាបាល (trust account) ជាពិសេស ប្រសិនបើការដាក់ប្រាក់បញ្ញើទាំងនោះត្រូវបានផ្ទេរភ្លាមៗ រវាងគណនីក្រុមហ៊ុនរបស់អតិថិជនផ្សេងទៀត និងគណនីអាណត្តិព្យាបាល។

២៩.អតិថិជនដែលបដិសេធមិនព្រមផ្តល់ព័ត៌មាន ដែលក្នុងកាលៈទេសៈធម្មតា អាចធ្វើឱ្យអតិថិជនមានសិទ្ធិទទួលបានឥណទានឬទទួលបានសេវាកម្មធនាគារដទៃទៀត ដែលត្រូវបានចាត់ទុកថាមានតម្លៃ។

៣០.បុគ្គលច្រើនរូប ដែលធ្វើការទូទាត់ទៅកាន់គណនីតែមួយ ដោយពុំមានពន្យល់ឱ្យបានគ្រប់គ្រាន់។

៣១.មូលនិធិ ដែលឆ្លងកាត់គណនីដ៏លឿន ឧទាហរណ៍ ដូចជា គណនីដើមគ្រា និងចុងគ្រាប្រចាំថ្ងៃ មានចំនួនទាបដែលមិនឆ្លុះបញ្ចាំងទៅនឹងបរិមាណដ៏ច្រើននៃលំហូរប្រាក់ដុល្លារឆ្លងកាត់គណនីមួយ។

៣២.គណនីដែលបានបើកក្នុងនាមអ្នកប្តូរប្រាក់ដែលទទួលបានប្រាក់បញ្ញើតាមការចាត់ចែង (ឧទាហរណ៍ចំនួនប្រាក់បញ្ញើថេរជាទៀងទាត់)។

៣៣.គណនីដែលបានធ្វើប្រតិបត្តិការក្នុងនាមក្រុមហ៊ុនបរទេសជាមួយនឹងចលនាមូលនិធិតាមការចាត់ចែង។

៣៤.គណនីដែលទទួលបានប្រាក់បញ្ញើម្តងម្កាល ហើយក្នុងអំឡុងពេលខ្លះ គណនីនេះមិនមានសកម្មភាព។ ដូច្នេះ គណនីបែបនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើឱ្យមានភាពស្របច្បាប់នៃប្រភពហិរញ្ញវត្ថុ ដែលសកម្មភាពក្លែងបន្លំបន្ថែមទៀតអាចត្រូវបានធ្វើឡើង។

៣៥.គណនីដែលមានសិទ្ធិចុះហត្ថលេខាពីបុគ្គលច្រើនគ្នា ប៉ុន្តែបុគ្គលទាំងនោះមិនមានទំនាក់ទំនងរវាងគ្នានឹងគ្នាទាំងក្នុងចំណងទាក់ទងជាគ្រួសារ ឬអាជីវកម្ម។

៣៦.គណនីដែលបើកដោយស្ថាប័ន ឬអង្គភាពស្របច្បាប់ដែលមានអាសយដ្ឋានដូចគ្នានឹងស្ថាប័ន ឬអង្គការស្របច្បាប់ដទៃទៀត ប៉ុន្តែបុគ្គលតែមួយ ឬបុគ្គលផ្សេងទៀត មានសិទ្ធិចុះហត្ថលេខានៅពេលដែលមិនមានហេតុផលខាងផ្លូវច្បាប់ឬសេដ្ឋកិច្ចជាក់ស្តែងសម្រាប់ការចាត់ចែងបែបនោះ (ឧទាហរណ៍ បុគ្គលមួយចំនួនដែលបម្រើការជានាយកសម្រាប់ក្រុមហ៊ុនច្រើន ដែលមានទីស្នាក់ការនៅតំបន់តែមួយ ។ល។)។

៣៧.គណនីដែលបានបើកក្នុងនាមស្ថាប័នស្របច្បាប់ ដែលទើបតែបង្កើតឡើងថ្មីៗ ហើយកម្រិតនៃប្រាក់បញ្ញើខ្ពស់ជាងការរំពឹងទុក បើប្រៀបធៀបទៅនឹងប្រាក់ចំណូលរបស់ស្ថាបនិកនៃស្ថាប័ននោះ។

៣៨.គណនីដែលបានបើកក្នុងនាមស្ថាប័នស្របច្បាប់ ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពរបស់សមាគម ឬអង្គការមូលនិធិដែលមានគោលដៅជាប់ពាក់ព័ន្ធនឹងការទាមទារ ឬតម្រូវការរបស់អង្គការភេរវកម្ម។

៣៩.គណនីដែលបានបើកក្នុងនាមស្ថាប័នស្របច្បាប់ សមាគម ឬអង្គការមូលនិធិដែលអាចពាក់ព័ន្ធនឹងអង្គការភេរវកម្ម ហើយដែលបង្ហាញពីចលនាសាច់ប្រាក់ខ្ពស់ជាងកម្រិតប្រាក់ចំណូលដែលបានរំពឹងទុក។

**ធនាគារកម្មអន្តរជាតិ និងហិរញ្ញប្បទានពាណិជ្ជកម្ម**

៤០. អតិថិជនដែលត្រូវបានណែនាំឱ្យស្គាល់ដោយសាខា បុត្រសម្ព័ន្ធបរទេស ឬធនាគារផ្សេងទៀតដែលមានមូលដ្ឋាននៅក្នុងតំបន់សង្ស័យ (ឧទាហរណ៍ ដូចជាប្រទេសដែលគ្រប់ដណ្តប់ដោយការផលិតគ្រឿងញៀន ឬការចរាចរគ្រឿងញៀន ប្រទេសដែលកំណត់ដោយអាជ្ញាធរជាតិដែនដី ឬប្រទេសដែលមិនមានកិច្ចសហប្រតិបត្តិការរបស់ក្រុមការងារហិរញ្ញវត្ថុ)។

៤១.ការប្រើប្រាស់លិខិតឥណទាន និងវិធីសាស្ត្រដទៃទៀតនៃហិរញ្ញប្បទានពាណិជ្ជកម្ម ដើម្បីចលនាមូលនិធិពីប្រទេសមួយទៅប្រទេសមួយ ដែលពាណិជ្ជកម្មបែបនេះមិនស៊ីសង្វាក់គ្នាទៅនឹងសកម្មភាពអាជីវកម្មធម្មតារបស់អតិថិជន។

៤២.អតិថិជនដែលទូទាត់ចំនួនប្រាក់ច្រើន ហើយទៀងទាត់ រួមមានប្រតិបត្តិការតាមអេឡិកត្រូនិក (Wire transactions) ដែលមិនអាចសម្គាល់អត្តសញ្ញាណឱ្យបានច្បាស់លាស់ ជាប្រតិបត្តិការពិតប្រាកដ ឬទទួលការទូទាត់ចំនួនច្រើននិងទៀងទាត់ពីប្រទេសដែលមានការពាក់ព័ន្ធនឹងការផលិត កែច្នៃ ឬលក់គ្រឿងញៀន ដោយអង្គការភេរវកម្មឬកន្លែងគ្មានពន្ធ (Tax heavens)។

៤៣.បង្កើតសមតុល្យមានចំនួនច្រើន មិនស្របនឹងចំណូលដែលបានដឹងនៃអាជីវកម្មរបស់អតិថិជន និងការផ្ទេរជាបន្តបន្ទាប់ទៅកាន់គណនីនៅបរទេស។

៤៤.ការផ្ទេរមូលនិធិតាមអេឡិកត្រូនិក ដែលមិនមានការពន្យល់ពីអតិថិជន ចេញ ឬ ចូល ឬ គ្មានការឆ្លងកាត់តាមរយៈគណនី។

៤៥.ការស្នើសុំជារឿយៗ ឬការទូទាត់នូវមូលប្បទានប័ត្រទេសចរណ៍ ឬរូបិយណត្តិជារូបិយប័ណ្ណបរទេស ឬឧបករណ៍អាចជួញដូរផ្សេងទៀត ដែលបានចេញផ្សាយ ឬជួញដូរពីបរទេស។

៤៦.អតិថិជនដែលផ្ញើ ឬទទួលការផ្ទេរតាមអេឡិកត្រូនិកទៅកាន់/មកពីប្រទេសគ្មានពន្ធ (Tax heavens) ជាពិសេសប្រសិនបើ មិនមានហេតុផលអាជីវកម្មជាក់ស្តែង សម្រាប់ការផ្ទេរប្រាក់បែបនេះឬ ការផ្ទេរដែលមិនសមស្របទៅនឹងសកម្មភាពអាជីវកម្មឬប្រវត្តិអតិថិជន។

**និយោជិត និងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

៤៧.ការផ្លាស់ប្តូរអាកប្បកិរិយារបស់និយោជិត ឧទាហរណ៍ ជីវភាពរស់នៅ ដែលមានការចាយវាយច្រើន ការចៀសវាងមិនឈប់សម្រាកក្នុងពេលវិស្សមកាល។

៤៨.ការប្រែប្រួលលទ្ធផលការងាររបស់និយោជិត និងភ្នាក់ងារ ឧទាហរណ៍ ដូចជាបុគ្គលិកផ្នែកលក់ផលិតផលជាសាច់ប្រាក់ ដែលមានលទ្ធផលការងារកើនឡើងដោយឥតរំពឹងទុក និងគួរឱ្យកត់សម្គាល់។

៤៩.កិច្ចព្រមព្រៀងណាមួយជាមួយភ្នាក់ងារដែលអត្តសញ្ញាណរបស់អត្ថគាហកចុងក្រោយ ឬសមភាគីមិនត្រូវបានបញ្ចេញឱ្យដឹង ដែលមានលក្ខណៈផ្ទុយនឹងនីតិវិធីធម្មតាសម្រាប់ប្រភេទអាជីវកម្ម។

៥០.លទ្ធផលការងារខ្លាំងភ្លាមៗរបស់បុគ្គលិក ក្នុងការទំនាក់ទំនងជាពិសេស ឬក្នុងទំនាក់ទំនងសេវាធនាគារ ជាសម្ងាត់ ដូចជាសេវាធនាគារឯកជន ឬសេវាអាណត្តិព្យាបាល ឬការកើនឡើងភ្លាមៗនៃទ្រព្យសម្បត្តិ/ការចំណាយរបស់បុគ្គលិកនោះ។

**ធនាគារកម្មឯកជន និងសេវាកម្មអាណត្តិព្យាបាល**

៥១.អ្នកផ្តល់គណនីធនាគារកម្មឯកជន និងគណនីអាណត្តិព្យាបាល ដែលផ្ទេរគណនីពីគណនីរបស់ពួកគេទៅឱ្យភាគីផ្សេងទៀត ឬអត្ថប្រយោជន៍អាជីវកម្មនៃភ្នាក់ងារកាន់កាប់គណនី ឬអត្ថគាហកផ្សេងទៀត។

**កម្ចីដែលមាន និងគ្មានការធានា**

៥២.អតិថិជនដែលទូទាត់ឥណទានមានបញ្ហា ដោយឥតរំពឹងទុក។

៥៣.ការស្នើសុំខ្ចីដោយដាក់បញ្ចាំទ្រព្យសម្បត្តិនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬនៅតតីយភាគីដែលប្រភពដើមរបស់ទ្រព្យសម្បត្តិនោះមិនត្រូវបានដឹង ឬទ្រព្យសម្បត្តិនោះមិនស៊ីសង្វាក់គ្នានឹងស្ថានភាពរបស់អតិថិជន។

៥៤.សំណើសុំរបស់អតិថិជនឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ ឬចាត់ចែងការរួមចំណែកហិរញ្ញវត្ថុដល់កិច្ចសន្យាណាមួយ ដែលមិនមានភាពច្បាស់លាស់ ជាពិសេសជាប់ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ។

៥៥. អតិថិជនដែលទូទាត់ដោយផ្នែក ឬទាំងស្រុង ចំពោះឥណទានដែលមានវត្ថុបញ្ចាំជាអចលនទ្រព្យ (Mortgage Loan) និងទ្រព្យផ្សេងៗទៀតដែលមិនស៊ីសង្វាក់គ្នានឹងសមត្ថភាពរកចំណូល ឬមូលដ្ឋានទ្រព្យសកម្មរបស់ពួកគេ។

**ការផ្ទេរប្រាក់តាមអេឡិកត្រូនិក (Wire Transfer)**

៥៦.ការផ្ទេរតាមអេឡិកត្រូនិកដែលតម្រូវឱ្យធ្វើឡើងមានចំនួនតិចតួច ដោយព្យាយាមចៀសវាងតម្រូវការនៃការសម្គាល់អត្តសញ្ញាណ ឬរាយការណ៍។

៥៧.ការផ្ទេរតាមអេឡិកត្រូនិកទៅកាន់ឬសម្រាប់បុគ្គលដែលមិនត្រូវបានគេផ្តល់ឱ្យព័ត៌មានស្តីពីអ្នកផ្តើមប្រតិបត្តិការ ឬពីបុគ្គលដែលធ្វើប្រតិបត្តិការជំនួស។

៥៨.ការប្រើប្រាស់គណនីអាជីវកម្ម ឬផ្ទាល់ខ្លួនចំរុះ ឬគណនីរបស់អង្គការមិនរកប្រាក់ចំណេញ ឬសប្បុរសធម៌ដើម្បីប្រមូល និងបន្ទាប់មកបង្វែរមូលនិធិភ្លាមៗ ឬក្នុងរយៈពេលដ៏ខ្លីទៅឱ្យអត្ថគាហកតូចៗនៅបរទេស។

**បុគ្គលិកលក្ខណៈរបស់អតិថិជន ឬសកម្មភាពអាជីវកម្មរបស់ពួកគេ**

៥៩.មូលនិធិបានមកពីអាជីវកម្ម ដែលជាកម្មសិទ្ធិរបស់បុគ្គលមួយចំនួនឬជាប់ពាក់ព័ន្ធនឹងបុគ្គលមួយចំនួន ដែលមានប្រភពដើមមកពីប្រទេសដែលមានការព្រួយបារម្ភដូចគ្នា ដោយធ្វើសកម្មភាពជាតំណាងឱ្យប្រភេទអាជីវកម្មស្រដៀងគ្នា។

៦០.អាសយដ្ឋានរួមគ្នារបស់បុគ្គលមួយចំនួនដែលពាក់ព័ន្ធនឹងប្រតិបត្តិការជាសាច់ប្រាក់ ជាពិសេសនៅពេលដែលអាសយដ្ឋានជាទីតាំងអាជីវកម្ម និង/ឬហាក់ដូចជាទាក់ទងនឹងមុខរបរដែលបានលើកឡើង (ឧទាហរណ៍ ដូចជា និស្សិត ឬបុគ្គលគ្មានមុខរបរ បុគ្គលដែលធ្វើការដោយខ្លួនឯង ។ល។)

៦១.មុខរបរដែលបានលើកឡើងដោយអតិថិជនមិនស៊ីគ្នាទៅនឹងកម្រិត ឬប្រភេទសកម្មភាព (ឧទាហរណ៍ ដូចជា និស្សិត ឬបុគ្គលគ្មានមុខរបរដែលទទួល ឬផ្ញើប្រាក់ចំនួនច្រើនតាមអេឡិកត្រូនិក ឬដកប្រាក់ជារៀងរាល់ពេលនូវចំនួនអតិបរមា នៅកន្លែងជាច្រើននៃតំបន់ភូមិសាស្ត្រដ៏ធំទូលាយមួយ) ។

៦២.ទាក់ទិននឹងអង្គការមិនរកប្រាក់ចំណេញ ឬសប្បុរសធម៌ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវធ្វើឡើង ដោយមិនមានគោលបំណងសេដ្ឋកិច្ចសមហេតុផល ឬមិនជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពអង្គការនោះ និងភាគីផ្សេងទៀតនៅក្នុងប្រតិបត្តិការនេះ។

៦៣.ភាពមិនស៊ីសង្វាក់គ្នាដែលមិនមានការពន្យល់ ដែលកើតចេញពីដំណើការនៃការកំណត់អត្តសញ្ញាណ ឬការផ្ទៀងផ្ទាត់អតិថិជន (ឧទាហរណ៍ ប្រទេសតាំងទីលំនៅបច្ចុប្បន្ន ឬពីមុន ប្រទេសដែលចេញលិខិតឆ្លងដែន ប្រទេសដែលបានទស្សនកិច្ចដោយផ្អែកលើលិខិតឆ្លងដែន ព្រមទាំងឯកសារផ្សេងៗដែលបញ្ជាក់ពីឈ្មោះ អាសយដ្ឋាន និងថ្ងៃខែឆ្នាំកំណើត)។

**ប្រតិបត្តិការជាប់ពាក់ព័ន្ធនឹងទីកន្លែងដែលមានការព្រួយបារម្ភ**

៦៤.ការដាក់ប្រាក់បញ្ញើដែលធ្វើឡើងជាបន្តបន្ទាប់ក្នុងរយៈពេលដ៏ខ្លី ដោយអ្នកផ្ទេរប្រាក់តាមអេឡិកត្រូនិក ជាពិសេស ទៅកាន់ឬឆ្លងកាត់ទីកន្លែងដែលមានការព្រួយបារម្ភ (ឧទាហរណ៍ ប្រទេសដែលត្រូវបានកំណត់ដោយអាជ្ញាធរជាតិដែនដី ឬប្រទេសដែលមិនមានកិច្ចសហប្រតិបត្តិការជាមួយក្រុមការងារហិរញ្ញវត្ថុ។)

៦៥.គណនីអាជីវកម្មដែលធ្វើការផ្ញើប្រាក់តាមអេឡិកត្រូនិកចេញ-ចូលមានចំនួនច្រើនបានកើតឡើង និងមិនមានសកម្មភាពអាជីវកម្ម ឬគោលដៅសេដ្ឋកិច្ចជាក់លាក់ ជាពិសេសនៅពេលដែលសកម្មភាពផ្ទេរប្រាក់នេះធ្វើឡើងទៅកាន់ ឆ្លងកាត់ មកពីកន្លែងដែលមានការព្រួយបារម្ភ។

៦៦.អតិថិជនដែលទទួលបានឧបករណ៍ឥណទាន ឬជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្ម ដែលពាក់ព័ន្ធនឹងចលនាមូលនិធិទៅកាន់ ឬមកពីកន្លែងដែលមានការបារម្ភ នៅពេលដែលមិនមានហេតុផលអាជីវកម្មសមស្របក្នុងការទំនាក់ទំនងទីកន្លែងទាំងនោះ ។

ធ៧-០០- ៥០ ប្រ.ក

# ប្រកាស
# ស្តីពី
# ដំណើរការគណនេយ្យកម្មសម្រាប់ប្រតិបត្តិការរូបិយប័ណ្ណ

**ប្រការ ១**.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១- រូបិយវត្ថុរាយការណ៍** មានន័យថា រូបិយវត្ថុដែលបានប្រើសម្រាប់កត់ត្រាគណនី និងសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ ស្ថិតនៅក្នុងរយៈពេលបណ្តោះអាសន្ននៃការងារគណនេយ្យ ប្រាក់ដុល្លារអាមេរិកត្រូវបានប្រើជារូបិយវត្ថុរាយការណ៍ រហូតដល់ពេលណាដែលដំណើរការបដិដុល្លារូបនីយកម្មសេដ្ឋកិច្ចកម្ពុជាបានជឿនលឿនសមស្រប។

**២ - រូបិយប័ណ្ណ** មានន័យថារូបិយប័ណ្ណក្រៅពីរូបិយវត្ថុរាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**៣- អត្រាប្តូរប្រាក់** មានន័យថាអនុបាតរវាងមួយឯកត្តានៃរូបិយវត្ថុមួយ និងចំនួនទឹកប្រាក់ជារូបិយវត្ថុមួយទៀត ដែលក្នុងនោះ ឯកត្តានេះអាចត្រូវបានប្តូរពីមួយទៅមួយក្នុងពេលកំណត់មួយ។

**៤- អត្រាប្តូរប្រាក់ដល់ដៃ** (spot rate) មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់សម្រាប់ ប្រតិបត្តិការប្តូរដោយប្រគល់ប្រាក់ដល់ដៃភ្លាម។

**៥- អត្រាប្តូរប្រាក់មានកាលកំណត់** (forward rate) មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាប្តូរប្រាក់នាកាលបរិច្ឆេទច្បាស់លាស់មួយទៅអនាគត។

**៦- អត្រាប្តូរប្រាក់នៅពេលបិទ** (closing rate) មានន័យថា អត្រាប្តូរប្រាក់ដល់ដៃនាកាលបរិច្ឆេទនៃការធ្វើតារាងតុល្យការ។

**៧- ប្រតិបត្តិការជារូបិយប័ណ្ណ** មានន័យថា ប្រតិបត្តិការមួយដែលត្រូវចារិកឬទាមទារឱ្យទូទាត់ជារូបិយប័ណ្ណ រួមបញ្ចូលទាំងប្រតិបត្តិការប្តូរប្រាក់ដែលបង្កើតឱ្យមានស្ថានភាពប្តូរប្រាក់ (foreign exchange position)។

**ប្រការ ២**.-

ប្រតិបត្តិការជារូបិយប័ណ្ណត្រូវបានកត់ត្រាស្របតាមបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ។ ដូច្នេះ ប្រព័ន្ធគណនេយ្យប្រើប្រាស់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែបានរៀបចំយ៉ាងណា ដើម្បីអាចផ្តល់ព័ត៌មានដែលតម្រូវដោយប្រកាសនេះ។

លោហៈធាតុមានតម្លៃដូចជា មាស និង ប្រាក់ ដែលត្រូវបានរក្សាទុកតាមទម្រង់ដែលអាចជួញដូរបានត្រូវអនុវត្តតាមវិធាននៃការវាយតម្លៃ ដែលមានចែងនៅក្នុងប្រការ ៦ នៃប្រកាសនេះ។

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកត់ត្រាប្រតិបត្តិការប្តូរប្រាក់ដល់ដៃ ឬមានកាលកំណត់ក្នុងគណនីដែលបានបើក និងចារិកតាមប្រភេទរូបិយប័ណ្ណនីមួយៗ ដែលបានប្រើ។

សម្រាប់គោលបំណងនៃប្រកាសនេះ រាល់ការទិញឬការលក់រូបិយប័ណ្ណដែលភាគីទាំងអស់មិនបានពន្យារពេល ឬបានពន្យារតែក្នុងរយៈពេលជាទំលាប់ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាប្តូរប្រាក់ដល់ដៃ។ ដូច្នេះ កិច្ចសន្យាប្តូរប្រាក់ដល់ដៃ **(Spot Contract)** ត្រូវបានឱ្យនិយមន័យថាជាកិច្ចសន្យាប្តូរប្រាក់ណាមួយ ក្នុងរយៈពេល២ថ្ងៃធ្វើការ **(2 business days)** នៃកាលវសាន្ត **(maturity)** លើកលែងតែរយៈពេលខ្លីជាងរយៈពេលជាទំលាប់ ឬ ទាមទារដោយទីផ្សារក្នុងស្រុក។

សម្រាប់គោលបំណងនៃប្រកាសនេះ រាល់ការទិញ ឬ ការលក់រូបិយប័ណ្ណដែលភាគីទាំងអស់សំរេចពន្យាររយៈពេលជាទំលាប់វែងជាង២ថ្ងៃធ្វើការ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាប្តូរប្រាក់មានកាលកំណត់ **(forward contracts)**។

**ប្រការ ៤**.-

បដិភាគនៃការកត់ត្រាគណនេយ្យរូបិយប័ណ្ណទាក់ទងទៅនឹងប្រតិបត្តិការប្តូរប្រាក់ ដូចជាប្រតិបត្តិការដែលជាប់ទាក់ទងដល់ស្ថានភាពរូបិយប័ណ្ណ **(foreign currency position)** ត្រូវបានកត់ត្រាក្នុងគណនីស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ និងចារិកទៅតាមប្រភេទរូបិយប័ណ្ណដែលបានប្រើ។

ការកត់ត្រាគណនេយ្យជារូបិយវត្ថុរាយការណ៍ដែលទាក់ទងជាមួយប្រតិបត្តិការប្តូរប្រាក់ត្រូវបានចុះបញ្ជិកា ក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ ឬ ក្រៅតារាងតុល្យការ។

ជាលទ្ធផល ប្រតិបត្តិការជារូបិយប័ណ្ណនិងជារូបិយវត្ថុរាយការណ៍ត្រូវបានកត់ត្រាចូលក្នុងសៀវភៅធំ **(Ledger)** សមស្រប ហើយសៀវភៅធំនីមួយៗត្រូវមានតុល្យភាពដោយប្រើគណនីឆ្លុះបញ្ចាំង **(mirror accounts)** ដូចខាងក្រោម ៖

* ស្ថានភាពប្តូរប្រាក់ជារូបិយប័ណ្ណចែកជា ៖

- ស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ
- ស្ថានភាពប្តូរប្រាក់នៅក្រៅតារាងតុល្យការ

* ស្ថានភាពប្តូរប្រាក់ជារូបិយវត្ថុរាយការណ៍សមមូល (ឬតម្លៃបដិភាគ) ចែកជា ៖

- ស្ថានភាពប្តូរប្រាក់សមមូលនៅក្នុងតារាងតុល្យការ
- ស្ថានភាពប្តូរប្រាក់សមមូលនៅក្រៅតារាងតុល្យការ ។

**ប្រការ ៥**.-

ដើមទុនដែលបានមកពីការទិញ ឬលក់ក្នុងប្រតិបត្តិការប្តូរប្រាក់ដល់ដៃ **(foreign exchange transactions)** ដែលមានកាលវសាន្ត **(maturity)** ជាទំលាប់២ថ្ងៃធ្វើការ និងក្នុងប្រតិបត្តិការប្តូរប្រាក់មានកាលកំណត់ ត្រូវតែកត់ត្រាក្នុងគណនីក្រៅតារាងតុល្យការសមស្របនាកាលបរិច្ឆេទដែលប្រតិបត្តិការកើតឡើង។ នៅពេលប្រគល់រូបិយប័ណ្ណ ប្រតិបត្តិការត្រូវបានកត់ត្រាចូលក្នុងតារាងតុល្យការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

នាកាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យនីមួយៗ ទ្រព្យសកម្ម ទ្រព្យអកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ត្រូវបានឱ្យតម្លៃតាមថ្លៃទីផ្សារ។ អត្រាទីផ្សារដែលអនុវត្តចំពោះខ្ទង់ទ្រព្យសកម្ម និងខ្ទង់ទ្រព្យអកម្ម និងចំពោះការសន្យាប្តូរប្រាក់ដល់ដៃ គឺជាអត្រាប្តូរប្រាក់នៅពេលបិទនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ។

អត្រាប្តូរប្រាក់ទីផ្សារដែលអនុវត្តចំពោះការសន្យាប្តូរប្រាក់មានកាលកំណត់ គឺជាអត្រាប្តូរប្រាក់មានកាលកំណត់នៃរូបិយប័ណ្ណពាក់ព័ន្ធសម្រាប់រយៈកាលដែលនៅសល់ ដូចជាអត្រាប្តូរប្រាក់មានកាលកំណត់នៅទីផ្សារត្រូវស្របទៅនឹងកាលវសាន្តនៃការសន្យា។

**ប្រការ ៧**.-

នាកាលបរិច្ឆេទរបាយការណ៍គណនេយ្យនីមួយៗ វិសមភាពនៃចំនួនប្រាក់ជារូបិយវត្ថុរាយការណ៍ដែលបានមកពីការវាយតម្លៃគណនីស្ថានភាពប្តូរប្រាក់ស្របតាមបញ្ញត្តិនៃប្រការ ៥ ម៉្យាង និងម៉្យាងទៀតចំនួនប្រាក់ដែលបានបង្ហាញក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ត្រូវបានកត់ត្រាចូលក្នុងគណនីចំណេញ-ខាត។ បដិភាគនៃការកត់ត្រានេះ ត្រូវបានកត់ត្រាចូលក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ចារិកជារូបិយវត្ថុរាយការណ៍។

នៅពេលដែលមិនទាន់អាចកត់ត្រាឥណពន្ធលើគណនីក្នុងតារាងតុល្យការបាន ដោយកត់ត្រាឥណទាននៃគណនីក្រៅតារាងតុល្យការ និងផ្ទុយមកវិញប្រាក់ចំណេញ និងខាតដែលបានកត់ត្រាក្នុងគណនីចំណេញខាត និងដែលកើតចេញពីស្ថានភាពប្តូរប្រាក់ក្រៅតារាងតុល្យការត្រូវតែមានតុល្យភាពដោយប្រើគណនីមួយដែលធ្វើឱ្យមានតុល្យភាពនៃ តារាងតុល្យការ។

វិសមភាពទាំងឡាយដែលទាក់ទងដល់ប្រតិបត្តិការដែលក្នុងនោះហានិភ័យនៃការប្តូរប្រាក់រ៉ាប់រងដោយរដ្ឋត្រូវតែកត់ត្រាចូលក្នុងគណនីកែតម្រូវ។

**ប្រការ ៨**.-

ចំណូលនិងចំណាយបង្គរជារូបិយប័ណ្ណដែលទាក់ទងដល់ឥណទាននិងកម្ចី មូលប័ត្រ ឬ ប្រតិបត្តិការក្រៅតារាងតុល្យការ ត្រូវបានឱ្យតម្លៃតាមអត្រាប្តូរប្រាក់ដល់ដៃនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ ហើយត្រូវកត់ត្រាចូលក្នុងគណនី ចំណេញខាតតាមគ្រាដែលកំណត់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងយ៉ាងយឺតបំផុតដល់កាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យ។

ចំណូលដែលត្រូវទទួល និងចំណាយដែលត្រូវសងជារូបិយប័ណ្ណមិនបង្គរទាក់ទងដល់ប្រតិបត្តិការក្នុងតារាងតុល្យការឬក្រៅតារាងតុល្យការ ត្រូវតែបង្ហាញនៅក្នុងគណនីដោយឡែក នៅពេលណាដែលចំណូលនិងចំណាយទាំងនេះ ត្រូវបានការពារការខាតបង់ **(maturity)**។

**ប្រការ ៩**.-

ដើម្បីធានាឱ្យការធ្វើរបាយការណ៍ពីហានិភ័យប្តូរប្រាក់ស៊ីសង្វាក់គ្នាទូទាំងប្រព័ន្ធធនាគារយ៉ាងហោចណាស់ការវាយតម្លៃឡើងវិញត្រូវតែអនុវត្តនាកាលបរិច្ឆេទបិទបញ្ជីនៅខែនីមួយៗ។ ប្រសិនបើកាលបរិច្ឆេទនេះមិនមែនជាថ្ងៃធ្វើការ ការវាយតម្លៃបិទបញ្ជីត្រូវធ្វើនៅថ្ងៃធ្វើការមុននោះ។

**ប្រការ ១០**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៧-១៦៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍

**ប្រការ ១**.-

គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចុះកិច្ចបញ្ជិកាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកដោយប្រើអត្រាប្តូរប្រាក់មធ្យមផ្លូវការដែលប្រកាសដោយធនាគារជាតិនៃកម្ពុជាតាមគ្រានីមួយៗ។

**ប្រការ ២**.-

រាល់លិខិតបទដ្ឋាននានាដែលធ្វើឡើងសម្រាប់ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ត្រូវតែប្រើជាភាសាខ្មែរ។

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាដែលមិនគោរពតាមប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ៤**.-

ប្រកាសលេខធ ៥-៩៣-២០៨ ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការប្រើប្រាស់ភាសា និងឯកត្តារូបិយវត្ថុសម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទ ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា : **ជា ចាន់តូ**

ធ៧-០១១-១៨៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការចែករំលែកព័ត៌មានឥណទាន

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងបង្កើតក្របខណ្ឌសមស្របសម្រាប់ការចែករំលែកព័ត៌មានឥណទាននៅកម្ពុជា ដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយការជឿទុកចិត្ត ការប្រកួតប្រជែង ការទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់។

**ប្រការ ២.- និយមន័យ**

- **សកម្មភាពមិនអំណោយផល** សំដៅដល់ការបដិសេធឥណទាន ឬការកែប្រែលក្ខខណ្ឌឥណទាន ឬកម្ចីដោយផ្អែកលើព័ត៌មាននៅក្នុងរបាយការណ៍ឥណទាន។
- **អ្នកប្រើប្រាស់ប្រតិស្រុតិ (Authorized user)** សំដៅដល់បុគ្គលទាំងឡាយណាដែលទទួលបានការអនុញ្ញាតឱ្យមានសិទ្ធិបញ្ចូលនិងទាញយកទិន្នន័យពីជាតាបេស្ស (Database)។ អ្នកប្រើប្រាស់ប្រតិស្រុតិ រួមមាន និយោជិតដែលចាត់តាំងដោយអ្នកផ្តល់ទិន្នន័យ និយោជិតរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងមន្ត្រីបុគ្គលិកដែលបានចាត់តាំងដោយធនាគារជាតិនៃកម្ពុជា។
- **ថ្ងៃធ្វើការ** សំដៅដល់ថ្ងៃដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាធ្វើប្រតិបត្តិការអាជីវកម្ម។
- **ក្រមប្រតិបត្តិ** សំដៅដល់វិធាន និងបទបញ្ជាសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានតាមការព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងអ្នកប្រើប្រាស់ប្រតិស្រុតិ។
- **កាលបរិច្ឆេទចាប់ផ្តើម** សំដៅដល់ថ្ងៃដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ចាប់ផ្តើមធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទានដល់អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិរបស់ខ្លួន។
- **ការយល់ព្រម** សំដៅដល់ការអនុញ្ញាតដោយស្ម័គ្រចិត្ត និងជាលាយលក្ខណ៍អក្សរដែលចុះហត្ថលេខាដោយអតិថិជនដើម្បីអនុញ្ញាតឱ្យអ្នកផ្តល់ទិន្នន័យ បញ្ចូលព័ត៌មានរបស់ខ្លួនទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងចែករំលែកជាមួយអ្នកប្រើប្រាស់ប្រតិស្រុតិក្នុងគោលបំណងប្រើប្រាស់ដូចមានចែងក្នុងប្រកាសនេះ។
- **អតិថិជន** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលដែលទិន្នន័យរបស់ខ្លួនត្រូវបាន ឬអាចត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទោះក្នុងទំនាក់ទំនងជាកិច្ចសន្យាជាមួយនឹងអ្នកឱ្យខ្ចី ឬពាក្យសុំខ្ចីប្រាក់ដែលចុះហត្ថលេខាដោយអតិថិជន ឬក្នុងគោលបំណងស្របច្បាប់ណាមួយផ្សេងទៀត។
- **គ្រឹះស្ថានចំណុះច្បាប់** សំដៅដល់គ្រឹះស្ថានដូចមានចែងនៅក្នុងច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

- **ព័ត៌មានឥណទាន** សំដៅដល់ព័ត៌មានទាក់ទងនឹងកាតព្វកិច្ចខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់អតិថិជន រួមទាំងសាវតាទូទាត់សងប្រាក់ ការធានាព័ត៌មានដែលអាចប្រើប្រាស់បានជាសាធារណៈ និងទិន្នន័យពាក់ព័ន្ធផ្សេងទៀតដែលអាចប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចផ្តល់ឥណទាន។
- **ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់គ្រឹះស្ថានបទបញ្ជា ស្តង់ដារ បច្ចេកវិទ្យា និងទិន្នន័យដែលផ្តល់លទ្ធភាពឱ្យមានការផ្លាស់ប្តូរព័ត៌មានឥណទានក្នុងចំណោមគ្រឹះស្ថានចំណុះច្បាប់ទាំងអស់។
- **សកម្មភាពចែករំលែកព័ត៌មានឥណទាន** សំដៅដល់សកម្មភាពទាំងឡាយណា ដែលស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះ រួមមានការផ្តល់របាយការណ៍ឥណទាន និងការផ្តល់សេវាពាក់ព័ន្ធផ្សេងៗទៀត។
- **អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់អង្គភាពដែលធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ហើយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។
- **អ្នកផ្តល់ទិន្នន័យ** សំដៅដល់ ១/គ្រឹះស្ថានចំណុះច្បាប់ និង២/គ្រឹះស្ថានដទៃទៀតដែលផ្តល់ឥណទានតាមរូបភាពណាមួយ ហើយស្ម័គ្រចិត្តផ្តល់ព័ត៌មានដល់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។
- **ព័ត៌មានឥណទានវិជ្ជមាន/ទិន្នន័យឥណទាន** សំដៅដល់ព័ត៌មាន ឬទិន្នន័យរបស់អតិថិជនរួមទាំង ពាក្យស្នើសុំឥណទាន និងគុណភាពឥណទានសរុប ដូចជា ទំហំប្រាក់កម្ចី កាលវសាន្ត លក្ខខណ្ឌនៃការសងប្រាក់ និងវត្ថុបញ្ចាំ ជាដើម។
- **ព័ត៌មានឥណទានអវិជ្ជមាន** សំដៅដល់ព័ត៌មានទាក់ទងនឹងការហួសពេលកំណត់សង ការមិនបានសងប្រាក់កម្ចីតាមពេលកំណត់ ការលុបចោលប្រាក់កម្ចី ឬស្ថានភាពមិនសងប្រាក់នៃប្រតិបត្តិការឥណទានរវាងអតិថិជន និងអ្នកផ្តល់ទិន្នន័យ។
- **វិធានបដិការ** សំដៅដល់សំណុំវិធានដែលកំណត់ កម្រិតនៃការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់ទិន្នន័យ។
- **ក្រុមប្រឹក្សាផ្តល់យោបល់** សំដៅដល់គណៈកម្មការផ្តល់យោបល់ដែលត្រូវបានបង្កើតឡើងដោយអ្នកផ្តល់ទិន្នន័យ អ្នកជំនាញឯករាជ្យ ក្រុមប្រឹក្សាភិបាល ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរដែលពាក់ព័ន្ធដទៃទៀត។

## ជំពូកទី ២
## ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងការផ្តល់អាជ្ញាប័ណ្ណ

### ប្រការ ៣.- ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលនឹងបង្កើតឡើងត្រូវមានប្រសិទ្ធភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាន ដើម្បីធានាប្រព្រឹត្តកម្មស្មើភាព និងត្រឹមត្រូវសម្រាប់អ្នកផ្តល់ទិន្នន័យ និងអ្នកចូលរួមក្នុងទីផ្សារឥណទានផ្សេងទៀត ។

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.- ការហាមឃាត់**

**១.** គ្មានបុគ្គលណាអាចធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ឬបង្ហាញដល់សាធារណជនថាខ្លួនធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ដោយពុំមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

**២.** គ្មានបុគ្គលណា ត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យអនុវត្តសកម្មភាពចែករំលែកព័ត៌មានឥណទានបានឡើយ លើកលែងតែនីតិបុគ្គលដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**៣.** ប្រការនេះពុំអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាដែលធ្វើប្រតិបត្តិការចែករំលែកព័ត៌មានឥណទានឡើយ។

**ប្រការ ៥.- ការដាក់ពាក្យសុំអាជ្ញាប័ណ្ណ**

នីតិបុគ្គលណាដែលមានបំណងចង់ប្រកបអាជីវកម្មលើសកម្មភាពចែករំលែកព័ត៌មានឥណទានត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តាមគំរូពាក្យសុំអាជ្ញាប័ណ្ណដែលបានកំណត់ ។

**ប្រការ ៦.- ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណ**

រាល់ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវតែភ្ជាប់មកជាមួយនូវព័ត៌មាន និងឯកសារពាក់ព័ន្ធដូចខាងក្រោម ៖

**ក.** ឯកសារពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងនឹងស្ថានភាពស្របច្បាប់របស់ក្រុមហ៊ុន

**ខ.** របាយការណ៍ទាក់ទងនឹងបទពិសោធន៍ពីមុនៗរបស់ស្ថាបនិកក្រុមហ៊ុន នៅក្នុងវិស័យធនាគារ និងឥណទាន រួមទាំងបញ្ជីឈ្មោះរបស់ភាគទុនិក ចំនួនប្រាក់ដែលបានដាក់វិនិយោគ និងការវិនិយោគនៅក្រុមហ៊ុនផ្សេងទៀត

**គ.** សមាសភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់

**ឃ.** ក្រុមអ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រសាកលវិទ្យាល័យ និងមានបទពិសោធន៍គ្រប់គ្រាន់ពាក់ព័ន្ធក្នុងទីផ្សារឥណទាន វិស័យធនាគារ ឬហិរញ្ញវត្ថុ

**ង.** រចនាសម្ព័ន្ធអង្គភាព ផែនការអាជីវកម្មបី (៣) ឆ្នាំសម្រាប់ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែក ព័ត៌មានឥណទាន ប្រព័ន្ធព័ត៌មានវិទ្យា នីតិវិធីផ្ទៃក្នុង និងសៀវភៅណែនាំប្រតិបត្តិការ

**ច.** ការសិក្សាពីភាពអាចធ្វើបានតាមផែនការអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់អាជីវកម្ម ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនានាជាមួយអ្នកផ្គត់ផ្គង់ផ្សេងទៀត

**ឆ.** រចនាសម្ព័ន្ធកម្មសិទ្ធិ និងអភិបាលកិច្ច រួមទាំងសមាសភាពនៃក្រុមប្រឹក្សាភិបាល និងលក្ខណៈវិនិច្ឆ័យ

**ជ.** ផែនការនិរន្តរភាព

**ឈ.** សំណើគោលនយោបាយកំណត់ថ្លៃ

**ញ.** ក្រមប្រតិបត្តិ និងវិធានពាក់ព័ន្ធផ្សេងទៀតសម្រាប់ដំណើរការប្រព័ន្ធ

**ដ.** សេចក្តីប្រកាសរបស់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តតាមក្រមប្រតិបត្តិនេះ។

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យផ្តល់ឯកសារចាំបាច់ផ្សេងទៀតសម្រាប់ការវាយតម្លៃលើពាក្យស្នើសុំនេះ។

**ប្រការ ៧.- នីតិវិធីសម្រាប់ការដាក់ពាក្យសុំ**

អ្នកដាក់ពាក្យសុំទាំងអស់ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ រួមជាមួយឯកសារពាក់ព័ន្ធដទៃទៀតមកធនាគារជាតិនៃកម្ពុជា។

នៅក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំគ្រប់គ្រាន់ រួមទាំងឯកសារពាក់ព័ន្ធ និងការបង់សោហ៊ុយសិក្សាសំណុំលិខិត ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងដល់អ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីការឯកភាព ឬការបដិសេធលើពាក្យសុំនោះ។

## ជំពូកទី ៣
## គោលការណ៍នៃការប្រើប្រាស់ព័ត៌មាន

**ប្រការ ៨.- ទិសដៅនៃសេវាចែករំលែកព័ត៌មាន**

ការផ្តល់សេវាចែករំលែកព័ត៌មានឥណទានមានទិសដៅដូចខាងក្រោម៖

**ក.** វាយតម្លៃអំពីលទ្ធភាពសង និងការជំពាក់បំណុលរបស់អតិថិជននៅពេលដាក់ពាក្យស្នើសុំខ្ចីឥណទាន ឬប្រាក់កម្ចី

**ខ.** គាំទ្រធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីត្រួតពិនិត្យ ដើម្បីតាមដានលំហូរឥណទានក្នុងប្រព័ន្ធហិរញ្ញវត្ថុ វិភាគទិន្នន័យសម្រាប់ធ្វើរបាយការណ៍អំពីស្ថិរភាពហិរញ្ញវត្ថុ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**គ.** វាយតម្លៃហានិភ័យឥណទាន និង/ឬ ពិនិត្យឡើងវិញ ឬ ផ្តល់ឥណទាន ឬប្រាក់កម្ចី

**ឃ.** វាយតម្លៃហានិភ័យនៃប្រតិបត្តិការដែលមានការខកខានទូទាត់សងប្រាក់

**ង.** ផ្តល់សិទ្ធិឱ្យអតិថិជនមានលទ្ធភាពផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃព័ត៌មានរបស់ខ្លួនផ្ទាល់ដែលមានក្នុងរបាយការណ៍ឥណទាន

**ច.** វាយតម្លៃ ឬធ្វើសវនកម្មអំពីប្រសិទ្ធភាព ភាពអាចទុកចិត្តបាន និងការប្រតិបត្តិតាមបទប្បញ្ញត្តិ ជាធរមានចំពោះប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ព័ត៌មានដែលមាននៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្រៅពីទិសដៅដូចមានចែងក្នុងប្រការនេះឡើយ លើកលែងតែទទួលបានការយល់ព្រមជាក់លាក់ជាមុនពីអតិថិជន។

**ប្រការ ៩.- ភារកិច្ចរបស់ភាគីពាក់ព័ន្ធក្នុងការធានាគុណភាពទិន្នន័យ**

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីប្រាកដថាព័ត៌មានអតិថិជនដែលបានប្រមូល ប្រើប្រាស់ និងបើកចំហ គឺជាព័ត៌មានដែលត្រឹមត្រូវពេញលេញ និងដែលបានធ្វើបច្ចុប្បន្នកម្ម។ ទិន្នន័យនឹងត្រូវប្រមូលដោយប្រើប្រាស់មធ្យោបាយត្រឹមត្រូវ និងស្របច្បាប់ហើយនឹងត្រូវបញ្ចូលតែព័ត៌មានចាំបាច់ ដូចជាអត្តសញ្ញាណដែលមានសុពលភាព និងសាវតាសងឥណទានរបស់អតិថិជន។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យមានកាតព្វកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

១. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវ៖

**ក**. បង្កើតឱ្យមាននីតិវិធីសមស្របដើម្បីធានាឱ្យបាននូវភាពពេញលេញ និងភាពត្រឹមត្រូវនៃព័ត៌មាន

**ខ**. ធានាថាទិន្នន័យនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំស្របតាមក្រមប្រតិបត្តិ

**គ**.បង្កើតយន្តការសមស្របសម្រាប់កែតម្រូវ និងលុបទិន្នន័យដើម្បីធានាថារាល់អ្នកប្រើប្រាស់ទាំងអស់ ដែលបានចូលយកទិន្នន័យមិនត្រឹមត្រូវក្នុងរយៈពេលបី (៣) ខែកន្លងមកត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីកំហុស និងកែតម្រូវទិន្នន័យដោយស្របទៅតាមពេលកំណត់ជាក់លាក់ដូចមានចែងនៅក្នុងក្រមប្រតិបត្តិ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថាអ្នកប្រើប្រាស់ទាំងអស់ដែលមានសិទ្ធិប្រើប្រាស់ទិន្នន័យក្នុងរយៈពេលបី (៣)ខែចុងក្រោយនេះបានដឹងពីកំហុស និងទទួលបានព័ត៌មានត្រឹមត្រូវវិញ ហើយច្បាប់ចម្លងនៃទិន្នន័យនោះក៏នឹងត្រូវផ្ញើទៅឱ្យអតិថិជនផងដែរ

**ឃ**.ទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ អតិថិជន នូវកំហុសទិន្នន័យនានាដែលបានកើតឡើងក្នុងពេលដំណើរការ ឬចែកចាយទិន្នន័យឥណទានដែលបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវ៖

- កែតម្រូវទិន្នន័យភ្លាមៗ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថា អ្នកប្រើប្រាស់ទាំងអស់ដែលបានប្រើប្រាស់ទិន្នន័យក្នុងរយៈពេលបី (៣) ខែចុងក្រោយបានដឹងពីកំហុសនេះ និងទទួលបានព័ត៌មានត្រឹមត្រូវវិញបន្ទាប់ពីបានធ្វើបច្ចុប្បន្នកម្ម
- ទទួលរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នកម្មនោះ ដោយប្រគល់ទៅឱ្យអតិថិជនតាមអាសយដ្ឋាន ដែលមាននៅក្នុងឯកសារដែលគ្រប់គ្រងដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- ទទួលខុសត្រូវចំពោះការប្តឹងទាមទាររបស់អតិថិជនពីកំហុសដែលអាចបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិស័ព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់
- ប្រឹងប្រែងតាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយការខូចខាតនានាដែលទទួលរងដោយអតិថិជនដោយសារតែទិន្នន័យមិនត្រឹមត្រូវនេះ។

**ង**. ទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ ធនាគារជាតិនៃកម្ពុជា ឬ តតិយជនណាមួយ សម្រាប់រាល់ការទាមទារពាក់ព័ន្ធនឹងការពន្យារពេល ការរំខាន ឬការខកខានមិនបានផ្តល់ព័ត៌មានឥណទាន ឬរបាយការណ៍ស្ថិតិ លើកលែងតែហេតុការណ៍ទាំងនោះបណ្តាលមកពីការបង្គាប់បញ្ជារបស់រាជរដ្ឋាភិបាល ការធ្វើវិទ្ធង្សនា កុប្បកម្ម ការបំផ្លាញ ទ្រព្យសម្បត្តិជាសាធារណៈ ការបដិសេធសេវាពីអ្នកផ្តល់សេវាអ៊ិនធឺណេត(ISP) ឬរាល់មូលហេតុដទៃទៀតដែលហួសពីសមត្ថកិច្ចរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**ច**. មិនត្រូវផ្ទេរ លក់ ឬជួលរាល់ព័ត៌មានឥណទានដែលត្រូវបានបញ្ជូនមកដោយអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិ

២. អ្នកផ្តល់ទិន្នន័យត្រូវទទួលខុសត្រូវចំពោះ៖

ក. ព័ត៌មានមិនត្រឹមត្រូវណាដែលខ្លួនបានផ្ដល់ឱ្យអ្នកផ្ដល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ខ. ការប្ដឹងទាមទាររបស់អតិថិជនអំពីកំហុសនានា ដែលអាចបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ កិត្តិស័ព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្ដាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់ស្របតាមការសម្រេចដែលធ្វើឡើងក្រោមយន្តការដំណោះស្រាយវិវាទ ដូចមានចែងក្នុងប្រការ២៦ នៃប្រកាសនេះ

គ. ការខិតខំកាត់បន្ថយការខូតខាតរបស់អតិថិជនដែលបណ្ដាលមកពីទិន្នន័យមិនត្រឹមត្រូវតាមរយៈការបង្កើតឱ្យមាននូវគោលនយោបាយ និងតម្រូវការនីតិវិធីចាំបាច់នានា។

អ្នកផ្ដល់ទិន្នន័យនីមួយៗ ត្រូវមានវិធានក្នុងការសម្រេចផ្ដល់ឥណទានរបស់ខ្លួន។ ព័ត៌មានឥណទាន និងសេវាដទៃទៀតដែលផ្ដល់ដោយប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់ទុកជាឧបករណ៍មួយសម្រាប់ដំណើរការនៃការសម្រេចលើហានិភ័យឥណទាន ប៉ុន្តែការសម្រេចទាំងនោះមិនត្រូវធ្វើឡើងដោយគ្រាន់តែផ្អែកទៅលើមូលដ្ឋានព័ត៌មានឥណទានដែលបានទទួលពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានមួយប៉ុណ្ណោះទេ។

**ប្រការ ១០.- សុវត្ថិភាពទិន្នន័យ**

អ្នកផ្ដល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្ដល់ទិន្នន័យត្រូវធានាសុវត្ថិភាពនិងភាពត្រឹមត្រូវនៃដាតាបេស្ស (Database) ឱ្យបានគ្រប់ពេលវេលា។ ដើម្បីបង្ការការប្រើប្រាស់មិនត្រឹមត្រូវ ឬការចូលយកព័ត៌មាន ទិន្នន័យ ប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតទិន្នន័យរាល់ដំណើរការចាំបាច់នានាត្រូវមានវិធានការដូចខាងក្រោម ៖

**១.** ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមានប្រព័ន្ធ កិច្ចដំណើរការ និងនីតិវិធីក្នុងការទាញយកទិន្នន័យមកវិញ និងត្រូវមានផែនការស្ដារគ្រោះមហន្តរាយ ដើម្បីទប់ស្កាត់ការបាត់បង់ ឬការខូចខាតទិន្នន័យ។

ក. ការចូលទៅក្នុងដាតាបេស្ស ត្រូវបានអនុញ្ញាតចំពោះតែអ្នកប្រើប្រាស់ប្រតិស្រុតិប៉ុណ្ណោះ

ខ. អ្នកផ្ដល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតយន្តការសមស្របដើម្បីធានាថាទិន្នន័យត្រូវបានឱ្យប្រើប្រាស់សម្រាប់តែទិសដៅដែលបានអនុញ្ញាតប៉ុណ្ណោះ ឬសម្រាប់ទិសដៅស្របច្បាប់ផ្សេងទៀត ដោយមានការយល់ព្រមពីអតិថិជន ស្របតាមប្រការ ៨ នៃប្រកាសនេះ។

**២.** អ្នកផ្ដល់ទិន្នន័យត្រូវធានាឱ្យមានជាស្រេចនូវនីតិវិធី គោលនយោបាយ និងវិធានការសុវត្ថិភាពគ្រប់គ្រាន់។ គោលនយោបាយ វិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មាន ត្រូវតែអនុម័តដោយក្រុមប្រឹក្សាភិបាលនៃអ្នកផ្ដល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងធនាគារជាតិនៃកម្ពុជា។ វិធានការដែលបានអនុម័តត្រូវឆ្លុះបញ្ចាំងពីលក្ខណៈបច្ចេកទេស រចនាសម្ព័ន្ធចាត់តាំង និងបច្ចេកវិទ្យា។

**ប្រការ ១១.- រយៈពេលរក្សាទុកទិន្នន័យ**

**១.** ព័ត៌មានប្រមូលដោយប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានបែងចែកក្នុងចំណោមអ្នកផ្ដល់ទិន្នន័យសម្រាប់រយៈពេលដប់ (១០) ឆ្នាំ គិតពីថ្ងៃឥណទានត្រូវបានទូទាត់សងគ្រប់ចំនួនក្នុងករណីព័ត៌មានវិជ្ជមាន។

**២.** ទិន្នន័យអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវបែងចែកក្នុងរយៈពេលបី (៣) ឆ្នាំ គិតចាប់ពីថ្ងៃដែលសេចក្ដីសម្រេចនោះចូលជាស្ថាពរ។

**៣.** ទិន្នន័យក្ស័យធន នឹងត្រូវបែងចែកក្នុងរយៈពេលប្រាំ (៥) ឆ្នាំ គិតពីថ្ងៃប្រកាសក្ស័យធន។

**៤.** ព័ត៌មានអវិជ្ជមាន នឹងត្រូវបែងចែកក្នុងរយៈពេលបី (៣) ឆ្នាំ គិតពីថ្ងៃកំណត់សងប្រាក់។

**ប្រការ ១២.- សិទ្ធិអតិថិជន**

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងភាគីពាក់ព័ន្ធត្រូវធានាថា៖

**ក.** សិទ្ធិរបស់បុគ្គលទៅលើទិន្នន័យរបស់ខ្លួនត្រូវបានគោរព

**ខ.** អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតឱ្យមានផ្នែកមួយដែលមាននីតិវិធី និងវិធានច្បាស់លាស់ដើម្បីដោះស្រាយការតវ៉ា និងសំណើរបស់បុគ្គលដែលពាក់ព័ន្ធនឹងទិន្នន័យរបស់ខ្លួន

**គ.** ទិន្នន័យពាក់ព័ន្ធនឹងនិន្នាការនយោបាយ ជំនឿសាសនា ពណ៌សម្បុរ ពូជសាសន៍ និងព័ត៌មានឯកជនរបស់បុគ្គល មិនត្រូវបានប្រមូលឬរក្សាទុកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ

**ឃ.** ទិន្នន័យត្រូវបានប្រមូលសម្រាប់តែប្រើប្រាស់ក្នុងគោលបំណងដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។ ទិន្នន័យដែលបានប្រមូល ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីមានចែងក្នុងប្រការ ៨ នេះត្រូវមានការយល់ព្រមច្បាស់លាស់ពីអតិថិជន។

## ជំពូកទី ៤
## អ្នកផ្តល់ទិន្នន័យ

**ប្រការ ១៣.- គ្រឹះស្ថានចំណុះច្បាប់**

១. គ្រឹះស្ថានចំណុះច្បាប់ត្រូវចូលរួមផ្តល់រាល់ព័ត៌មានឥណទានទាំងវិជ្ជមាន និងអវិជ្ជមានទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជារៀងរាល់ខែ។ ការខកខានមិនបានចូលរួមផ្តល់ទិន្នន័យ និង/ឬការខកខានមិនបានចូលប្រើប្រាស់ទិន្នន័យ នឹងត្រូវរងការដាក់ទណ្ឌកម្មដូចមានចែងក្នុងច្បាប់ជាធរមាន។

២. ការយល់ព្រមរបស់អតិថិជន គឺជាការចាំបាច់សម្រាប់ការប្រមូលទិន្នន័យ និងការចូលប្រើប្រាស់ទិន្នន័យ។ ធនាគារជាតិនៃកម្ពុជា នឹងរៀបចំទម្រង់នៃកិច្ចព្រមព្រៀងជាស្តង់ដារសម្រាប់ឱ្យគ្រឹះស្ថានចំណុះច្បាប់ប្រើប្រាស់។

៣. គ្រឹះស្ថានចំណុះច្បាប់ មានរយៈពេលប្រាំបួន (៩) ខែក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធផ្តល់ទិន្នន័យប្រចាំខែរបស់ខ្លួន។

៤. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងផ្តល់សេវាស្មើភាពចំពោះអ្នកចូលរួមទាំងអស់ ដោយគ្មានការរើសអើងចំពោះអ្នកផ្តល់ទិន្នន័យឡើយ។

**ប្រការ ១៤.- អ្នកប្រើប្រាស់និងអ្នកផ្តល់ទិន្នន័យផ្សេងទៀត**

១. គ្រឹះស្ថានក្រៅពីគ្រឹះស្ថានចំណុះច្បាប់ អាចចូលរួមផ្តល់ និងចូលប្រើប្រាស់ទិន្នន័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នៅពេលណាដែលទទួលបានការយល់ព្រមជាមុនពីអតិថិជន និងធនាគារជាតិនៃកម្ពុជា។

២. អ្នកប្រើប្រាស់និងអ្នកផ្តល់ទិន្នន័យទាំងអស់ ទោះបីស្ថិត ឬមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ត្រូវស្ថិតនៅក្រោមវិធាន កាតព្វកិច្ច និងទណ្ឌកម្ម ដូចមានចែងនៅក្នុងប្រកាសនេះ។

៣. យោងតាមវិធានបដិការ គ្រឹះស្ថានដែលមិនបានរាយការណ៍រាល់ព័ត៌មានដែលតម្រូវ នឹងមិនត្រូវបានអនុញ្ញាតឱ្យទទួលព័ត៌មានទាំងឡាយណាដែលបានបញ្ចូលក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយអ្នកផ្តល់ទិន្នន័យផ្សេងទៀតឡើយ។

៤. ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យមានការចូលរួមរបស់អ្នកផ្តល់ទិន្នន័យថ្មី នៅពេលដែលធនាគារជាតិនៃកម្ពុជា យល់ឃើញថាសកម្មភាពរបស់គេមានភាពចាំបាច់នៅក្នុងទីផ្សារឥណទានកម្ពុជា។

## ជំពូកទី ៥
## ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

### ប្រការ ១៥.- អភិបាលកិច្ចសាជីវកម្ម

**១.** អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិកយ៉ាងតិចចំនួនប្រាំពីរ (៧) រូប ដែលក្នុងនោះសមាជិកមួយ (១) រូប ជាតំណាងមកពីធនាគារជាតិនៃកម្ពុជា និងមួយ (១) រូបទៀត ជាអភិបាលឯករាជ្យ។

**២.** សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ អំពីប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ។ គ្មានជនណាម្នាក់ ត្រូវតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ ប្រសិនបើជននោះត្រូវបានផ្តន្ទាទោសពី ៖

**ក.** បទឧក្រិដ្ឋណាមួយ

**ខ.** បទលួច បទក្លែងបន្លំ ឬបទរំលោភលើសេចក្តីទុកចិត្ត

**គ.** បទគៃបំបាត់

**ឃ.** ព្រឹទ្ធិកម្ម

**ង.** បទសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

**ច.** ការចេញមូលប្បទានបត្រគ្មានសាច់ប្រាក់

**ឆ.** ការក្ស័យធនផ្ទាល់ខ្លួន ការដាក់ទ្រព្យសម្បត្តិក្រោមអភិបាលបណ្តោះអាសន្ន ឬការជម្រះបញ្ជីទ្រព្យសម្បត្តិ។

**៣.** នាយកប្រតិបត្តិ ត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល។ គ្មានជនណាម្នាក់នឹងត្រូវបានតែងតាំងជានាយកប្រតិបត្តិទេ ប្រសិនបើជននោះជា ៖

**ក.** ជនដែលទទួលទោសពីបទឧក្រិដ្ឋណាមួយ

**ខ.** អនីតិជន ឬអសមត្ថជនតាមផ្លូវច្បាប់

**គ.** ជនដែលទទួលទោសពីបទលួច ឬក្លែងបន្លំដែលបណ្តាលឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ

**ឃ.** ជនដែលត្រូវបានបណ្តេញចេញពីមុខតំណែង ដោយសារតែបានយកមុខតំណែងទៅប្រើប្រាស់ក្នុងគោលបំណងមិនត្រឹមត្រូវ ឬបានប្រព្រឹត្តអំពើពុករលួយក្នុងអំឡុងពេលដប់ (១០) ឆ្នាំចុងក្រោយនេះ

**ង.** ជនដែលត្រូវបានផ្តន្ទាទោសពីបទរំលោភលើសេចក្តីទុកចិត្ត និង

**ច.** នាយកប្រតិបត្តិ ឬសមាជិកក្រុមប្រឹក្សាភិបាលរបស់អ្នកប្រើប្រាស់ និងអ្នកផ្តល់ទិន្នន័យ ។

៤. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតផ្នែកមួយដើម្បីអនុវត្តការគោរពសិទ្ធិអតិថិជន ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងវិធានការសុវត្ថិភាព។

៥. ក្រុមប្រឹក្សាភិបាលត្រូវធានាថា ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៦
## ដំណើរការនៃប្រព័ន្ធ

### ប្រការ ១៦.- ប្រភពទិន្នន័យ

១. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងប្រមូល បញ្ចូល និងផ្សព្វផ្សាយព័ត៌មានឥណទាន និងទិន្នន័យពាក់ព័ន្ធនឹងបុគ្គល និងសហគ្រាស ពីប្រភពដូចខាងក្រោម ៖

ក. គ្រឹះស្ថានចំណុះច្បាប់ អ្នកប្រើប្រាស់ និងអ្នកផ្តល់ទិន្នន័យផ្សេងទៀត

ខ. ព័ត៌មានពីប្រភពផ្សេងទៀតដែលមានជាសាធារណៈតាមមធ្យោបាយស្របច្បាប់ ។

២. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចមានលទ្ធភាពប្រើប្រាស់ព័ត៌មានដែលអាចរកបានជាសាធារណៈ និងពីប្រភពផ្សេងទៀតដូចខាងក្រោម ៖

ក. ស្ថាប័ន ឬអង្គភាពទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីអចលនវត្ថុ និងចុះបញ្ជីកម្មសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ខ. ស្ថាប័ន ឬអង្គភាពទទួលបន្ទុករក្សាទុកឯកសារសម្គាល់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតឆ្លងដែន និងលេខបង់ពន្ធ ជាដើម។

៣. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចប្រមូលទិន្នន័យពីសេចក្តីសម្រេចរបស់តុលាការ និងដំណើរការក្ស័យធនបើមាន តាមរយៈមធ្យោបាយស្របច្បាប់។

### ប្រការ ១៧.- ការប្រមូល និងការចែកចាយ

១. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវប្រមូល រៀបចំ និងរក្សាទុកព័ត៌មានឥណទានដែលទទួលបានពីអ្នកផ្តល់ទិន្នន័យ និងពីប្រភពផ្សេងទៀតតាមដែលអាចធ្វើទៅបានរាប់បញ្ចូលទាំងសេចក្តីណែនាំអំពីប្រតិបត្តិការក្នុងការការពារទិន្នន័យពីការប្រើប្រាស់មិនត្រឹមត្រូវ ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតនៃប្រព័ន្ធ។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមាននីតិវិធីត្រួតពិនិត្យគុណភាព ដើម្បីធានាឱ្យបាននូវនិរន្តរភាពសេវាកម្ម។

២. អ្នកផ្តល់ទិន្នន័យ ត្រូវផ្តល់សំពៀតឥណទានទាំងអស់ដោយអនុលោមតាមទម្រង់ និងគំរូដែលកំណត់ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានការព្រមព្រៀងជាមួយក្រុមប្រឹក្សាផ្តល់យោបល់។ ទម្រង់ដំបូងនឹងត្រូវយកតាមទម្រង់ដែលមានក្នុងឧបសម្ព័ន្ធ ១ (ទម្រង់ឯកសារ)។ ទម្រង់ឯកសារនេះចែកចេញជាពីរផ្នែកៈ ផ្នែកទី១ ចែងពីព័ត៌មានស្តីពីអត្តសញ្ញាណរបស់អ្នកខ្ចី និងអ្នកធានា និងផ្នែកទី២ ចែងពីទិន្នន័យនៃប្រតិបត្តិការឥណទាន។

៣. អ្នកផ្តល់ទិន្នន័យ ត្រូវផ្តល់ឯកសារដំបូងក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីកាលបរិច្ឆេទចាប់ផ្តើម។

ក. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបញ្ចូលទិន្នន័យពាក់ព័ន្ធស្របតាមទម្រង់ឯកសារ ដែលបានទទួលពីអ្នកផ្តល់ទិន្នន័យក្នុងរយៈពេលប្រាំ (៥) ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលទិន្នន័យនោះ

ខ. អ្នកផ្តល់ទិន្នន័យទាំងអស់ ត្រូវផ្តល់ព័ត៌មានឥណទានដែលបានធ្វើបច្ចុប្បន្នកម្មរបស់ខ្លួនជារៀងរាល់ខែយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥នៃខែបន្ទាប់

គ. សំណុំឯកសារដែលផ្តល់ដោយអ្នកប្រើប្រាស់ត្រូវផ្តល់ជូនតាមទម្រង់ ដែលបង្កើតដោយក្រុមប្រឹក្សាភិបាល និងឯកភាពដោយក្រុមប្រឹក្សាផ្តល់យោបល់។

៤. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវទទួលខុសត្រូវចំពោះដាតាបេស្ស (Database) របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងត្រូវផ្តល់សេវាព័ត៌មានឥណទានដល់គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ផ្សេងទៀត អនុលោមតាមប្រកាសនេះ ក្រមប្រតិបត្តិ ឬបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

៥. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវទទួលខុសត្រូវចំពោះការលេចធ្លាយទិន្នន័យដោយសារការខូចខាតនៃប្រព័ន្ធ ឬការប្រើប្រាស់ទិន្នន័យមិនសមស្របពីសំណាក់និយោជិតរបស់ខ្លួន។

៦. គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត មិនត្រូវលក់ ឬលាតត្រដាងព័ត៌មានឥណទានដល់តតិយជនឡើយ។ គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀតមិនត្រូវប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីផ្តល់សេវាកម្មឱ្យតតិយជន ឬធ្វើយុទ្ធនាការស្វែងរកទីផ្សារ ក្រៅពីអតិថិជនរបស់ខ្លួនឡើយ។

៧. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចកែប្រែលក្ខខណ្ឌសេវាកម្ម ដើម្បីធានា ឬលើកកម្ពស់គុណភាពសេវាកម្ម។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវធ្វើសេចក្តីជូនដំណឹងដល់អ្នកផ្តល់ទិន្នន័យក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ មុនលក្ខខណ្ឌថ្មីចូលជាធរមាន។

**ប្រការ ១៨.- ការចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

១. គ្រឹះស្ថានចំណុះច្បាប់ទាំងអស់ ត្រូវប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីវិភាគលើឥរិយាបទនៃការសងប្រាក់របស់អ្នកដាក់ពាក្យសុំខ្ចីប្រាក់ នៅពេលដែលគ្រឹះស្ថានចំណុះច្បាប់នេះទទួលបានពាក្យសុំខ្ចីប្រាក់ថ្មី ឬពាក្យសុំបន្ត ឬពន្យារឥណទានចាស់ ដោយមិនគិតពីទំហំនៃឥណទានឡើយ។

ក. សិទ្ធិចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានផ្តល់ឱ្យតែអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិដែលស្ថិតក្រោមលក្ខខណ្ឌដូចមានចែងនៅក្នុងក្រមប្រតិបត្តិ

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវរៀបចំ ដំណើរការ នីតិវិធី និងវិធានដើម្បីកំណត់អ្នកប្រើប្រាស់ប្រតិស្រុតិដែលនឹងត្រូវបានអនុញ្ញាត។

២. អ្នកផ្តល់ទិន្នន័យផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាត្រូវផ្តល់ព័ត៌មានឥណទាន និងចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយឈរលើមូលដ្ឋានស្ម័គ្រចិត្ត និងអនុលោមតាមវិធានបដិការ និងក្រមប្រតិបត្តិ។

៣. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវធានាថា សេវាកម្មមានសុវត្ថិភាព ស្ថិរភាព និងអាចប្រើប្រាស់បាន ហើយត្រូវធានាថាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានសមត្ថភាពពេញលេញក្នុងការផ្តល់សេវាកម្មដល់អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិ។

៤. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមិនទទួលខុសត្រូវ ចំពោះការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ដោយសារតែអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិបានចែករំលែក ឬបានបើកចំហលេខកូដ ឬពាក្យសម្ងាត់របស់ខ្លួនឱ្យតតិយជនចូលប្រើប្រាស់។

៥. អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិទាំងអស់ ត្រូវគោរពតាមនីតិវិធី និងវិធានការពារសុវត្ថិភាពដែលបានអនុម័ត និងមានចែងនៅក្នុងក្រមប្រតិបត្តិ។

**ប្រការ ១៩.- សេវាកម្មផ្សេងទៀត**

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្នើសុំការណែនាំពីក្រុមប្រឹក្សាផ្តល់យោបល់មុនពេលដាក់ឱ្យប្រើប្រាស់សេវាកម្ម ឬផលិតផលថ្មី។ ក្រុមប្រឹក្សានេះ ត្រូវធ្វើរបាយការណ៍ដែលមានសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើភាពត្រឹមត្រូវនៃផលិតផលចំពោះឥណទាយកទាំងអស់ និងផលប៉ះពាល់ចំពោះអតិថិជន។ ក្រុមប្រឹក្សា ត្រូវប្រគល់របាយការណ៍នេះឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃស្នើសុំ។

**ប្រការ ២០.- គោលនយោបាយកំណត់ថ្លៃ**

១. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចយកសោហ៊ុយ កម្រៃ ឬពិន័យចំពោះការប្រើប្រាស់សេវាកម្មរបស់ខ្លួន ដោយផ្អែកលើគោលនយោបាយមួយប្រកបដោយតម្លាភាព និងសមស្របតាមសេវាកម្មដែលបានផ្តល់។

២. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្នើសុំការយល់ព្រមពីធនាគារជាតិនៃកម្ពុជាចំពោះការកែប្រែគោលនយោបាយកំណត់ថ្លៃ មុនពេលដាក់ឱ្យអនុវត្ត។ ធនាគារជាតិនៃកម្ពុជានឹងពិនិត្យពិចារណាពាក្យស្នើសុំនិងសំណុំលិខិតពាក់ព័ន្ធ ដោយអនុម័តយល់ព្រម ឬបដិសេធក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃធ្វើការ។

## ជំពូកទី ៧
## សិទ្ធិអតិថិជន

**ប្រការ ២១.- សេចក្តីជូនដំណឹងអំពីសិទ្ធិឯកជន**

១. ផ្អែកលើលក្ខខណ្ឌយល់ព្រមរបស់អតិថិជន អ្នកផ្តល់ទិន្នន័យត្រូវជូនដំណឹងដល់អតិថិជននូវរាល់ការបញ្ជូនព័ត៌មានឥណទានរបស់អតិថិជនទៅឱ្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទាំងនៅពេលដាក់ពាក្យសុំខ្ចី សុំបន្ត ឬសុំពន្យារពេលឥណទាន។ លក្ខខណ្ឌនៃការយល់ព្រមរបស់អតិថិជនត្រូវមានព័ត៌មានដូចខាងក្រោម ៖

- **ក.** ឈ្មោះអ្នកផ្តល់ទិន្នន័យ
- **ខ.** គោលបំណងនៃការប្រមូលព័ត៌មានឥណទាន
- **គ.** ឈ្មោះ និងអាសយដ្ឋាននៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- **ឃ.** ទីកន្លែង និងបែបបទទទួលព័ត៌មានឥណទាន ក្នុងករណីតម្រូវឱ្យមានការកែប្រែ ឬកែសម្រួលព័ត៌មានឥណទាន

**៦**.គ្រឹះស្ថានចំណុះច្បាប់ និង អង្គភាពមិនមែនគ្រឹះស្ថានចំណុះច្បាប់ នៅពេលបានក្លាយជាអ្នកផ្តល់ទិន្នន័យត្រូវបញ្ចូលកំណត់សម្គាល់អំពីសិទ្ធិឯកជនក្នុងពាក្យសុំខ្ចីឥណទាននិងកម្ចី ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ និងត្រូវប្រើគំរូកិច្ចព្រមព្រៀងជាស្តង់ដារដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៣។

**២.** ប្រសិនបើមានសកម្មភាពមិនអំណោយផល ប៉ះពាល់ដល់អតិថិជន ដោយសារលទ្ធផលនៃការវិភាគព័ត៌មានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកផ្តល់ទិន្នន័យត្រូវជូនដំណឹងដល់អតិថិជនក្នុងរយៈពេលប្រាំ (៥) ថ្ងៃធ្វើការ។

**ប្រការ ២២.- ការសម្ងាត់វិជ្ជាជីវៈ**

**១.** ព័ត៌មានឥណទានជាព័ត៌មានសម្ងាត់ ដែលត្រូវបានប្រើប្រាស់សម្រាប់តែទិសដៅដូចបានអនុញ្ញាតក្នុងប្រការ ៨ នៃប្រកាសនេះ។ ការសម្ងាត់នេះត្រូវតែបានអនុវត្តឱ្យបានម៉ឺងម៉ាត់ ហើយអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិមិនត្រូវលក់ ឬផ្តល់ព័ត៌មានឥណទាននេះដល់តតិយជនណាម្នាក់បានឡើយ។

**២.** ធនាគារជាតិនៃកម្ពុជា និយោជិតដែលបានអនុញ្ញាតដោយអ្នកប្រើប្រាស់ប្រតិស្រុតិ និងអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានតែប៉ុណ្ណោះ អាចចូលប្រើប្រាស់ព័ត៌មាន និងសម្រាប់តែការបំពេញតួនាទីរបស់ខ្លួនប៉ុណ្ណោះ។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវអនុវត្តរាល់វិធានការចាំបាច់នានា ដើម្បីធានាថា អភិបាល និងនិយោជិតរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានរក្សាបានជាប្រចាំនូវការសម្ងាត់នៃព័ត៌មានឥណទាន។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមានវិធានការសមស្រប ដើម្បីបង្ការការចូលទៅយកព័ត៌មានឥណទានដោយគ្មានការអនុញ្ញាត ហើយត្រូវរៀបចំនិងអនុវត្តគោលនយោបាយ និងនីតិវិធីរក្សាសុវត្ថិភាពសម្រាប់ការគ្រប់គ្រងការចូលទៅយកព័ត៌មានឥណទាន។

**៣.** ធនាគារជាតិនៃកម្ពុជា មានសិទ្ធិចូលយកព័ត៌មានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយពុំមានបង់សោហ៊ុយ និងកម្រៃដើម្បីបំពេញមុខងាររបស់ខ្លួនជាអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានចំណុះច្បាប់ និងមានសិទ្ធិចូលយកព័ត៌មានដទៃទៀតដែលទាក់ទងទៅនឹងគ្រឹះស្ថានមិនចំណុះច្បាប់ ដើម្បីតាមដានស្ថិរភាពជាទូទៅនៃវិស័យហិរញ្ញវត្ថុ។

**៤.** ធនាគារជាតិនៃកម្ពុជា មានសិទ្ធិត្រួតពិនិត្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីបំពេញមុខងារត្រួតពិនិត្យរបស់ខ្លួន ក្នុងការរក្សាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព ភាពត្រឹមត្រូវនិងស្របច្បាប់នៃប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

**៥.** អភិបាល និងនិយោជិតនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកប្រើប្រាស់ប្រតិស្រុតិ និងនិយោជិតនៃអ្នកផ្តល់ទិន្នន័យ ត្រូវចុះហត្ថលេខាជាមុនលើកិច្ចព្រមព្រៀងស្តីពីការរក្សាការសម្ងាត់ មុនមានសិទ្ធិចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

**ប្រការ ២៣.- សិទ្ធិលើព័ត៌មាន**

**១.** អតិថិជនមានសិទ្ធិស្នើសុំរបាយការណ៍ព័ត៌មានរបស់ខ្លួនមួយច្បាប់មួយដងក្នុងមួយឆ្នាំ ។

**ក.** របាយការណ៍ ត្រូវផ្តល់ឱ្យអតិថិជនទៅតាមអាសយដ្ឋានរបស់អតិថិជន ដែលមាននៅក្នុងសំណុំឯកសារនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងរយៈពេលដប់ (១០) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើ។ អតិថិជនអាចស្នើសុំរបាយការណ៍នោះភ្លាមៗ តាមអត្រាកម្រៃដែលបានកំណត់ដោយអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

**ខ.** អតិថិជនត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យបានច្បាស់លាស់ មុនពេលទទួលបានព័ត៌មានឥណទានរបស់ខ្លួន

**គ.** អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវផ្តល់ជូនអតិថិជននូវព័ត៌មានឥណទានរបស់ខ្លួនមួយច្បាប់មួយដងក្នុងមួយឆ្នាំ រួមមានឈ្មោះរបស់អ្នកផ្តល់ទិន្នន័យ និងបញ្ជីអ្នកផ្តល់ទិន្នន័យទាំងអស់ ដែលបានទទួលព័ត៌មានឥណទានរបស់សាមីជន ក្នុងអំឡុងពេលប្រាំមួយ (៦) ខែកន្លងមក។

**២.** អតិថិជនមានសិទ្ធិស្នើសុំកែប្រែព័ត៌មានឥណទានដែលមិនត្រឹមត្រូវ ឬមិនគ្រប់ជ្រុងជ្រោយនៅពេលណាក៏បាន។

**ក.** នៅពេលទទួលបានសំណើសុំឱ្យកែតម្រូវព័ត៌មានឥណទានដែលមិនត្រឹមត្រូវ ឬមិនគ្រប់ជ្រុងជ្រោយ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវជូនដំណឹង និងបញ្ជូនរាល់ព័ត៌មានដែលពាក់ព័ន្ធ ទៅឱ្យអ្នកផ្តល់ទិន្នន័យដើម្បីពិនិត្យ និងកែតម្រូវព័ត៌មានឥណទានក្នុងរយៈពេលដប់ (១០) ថ្ងៃធ្វើការ

**ខ.** អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវជូនដំណឹងដល់អតិថិជនតាមអាសយដ្ឋានដើមដែលមានក្នុងសំណុំឯកសារនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មិនហួសពីរយៈពេលដប់ (១០) ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការឆ្លើយតបពីអ្នកផ្តល់ទិន្នន័យ អំពីលទ្ធផលនៃការតវ៉ារបស់អតិថិជនទាំងនោះ។

**៣.** នីតិវិធីលម្អិតអំពីសិទ្ធិអតិថិជន អាចរកបានពីអ្នកផ្តល់ទិន្នន័យនិងអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានទាំងអស់ដោយផ្ទាល់ ឬតាមគេហទំព័ររបស់អ្នកទាំងនោះ។

## ជំពូកទី ៨
## ការត្រួតពិនិត្យ

### ប្រការ ២៤.- តួនាទីរបស់ធនាគារជាតិនៃកម្ពុជា

**១.** ធនាគារជាតិនៃកម្ពុជា មានតួនាទីរៀបចំបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យរាល់សកម្មភាពចែករំលែកព័ត៌មានឥណទាន រួមទាំងទំនាក់ទំនងជាមួយអ្នកផ្តល់សេវា ឬអ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិ ពាក់ព័ន្ធនឹងប្រសិទ្ធភាព និងដំណើរការត្រឹមត្រូវ នៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

**២.** ធនាគារជាតិនៃកម្ពុជា មានសិទ្ធិ៖

**ក.** ផ្តល់ ព្យួរ និងដកហូតអាជ្ញាប័ណ្ណរបស់អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

**ខ.** តាមដានការប្រតិបត្តិតាមវិធាន បទប្បញ្ញត្តិ ក្រមប្រតិបត្តិ លក្ខខណ្ឌ នីតិវិធី និងប្រព័ន្ធប្រតិបត្តិការនានា

**គ.** ត្រួតពិនិត្យភាពសមស្របនៃយន្តការ ក្នុងការធានានិរន្តរភាពនៃសេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន រាប់ទាំងលក្ខខណ្ឌនៃការបើកដំណើរការនិងការបញ្ឈប់អាជីវកម្មនិងលក្ខខណ្ឌផ្សេងៗទៀត

**ឃ.** តាមដានការអនុវត្តរាល់សេចក្តីសម្រេចដែលបានអនុម័តដោយក្រុមប្រឹក្សាផ្តល់យោបល់

**ង.** តម្រូវឱ្យអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទានអនុម័តវិធានការចាំបាច់ សម្រាប់ការចូលរួមជាកាតព្វកិច្ចពីគ្រឹះស្ថានចំណុះច្បាប់ទាំងអស់ និងការចូលរួមដោយស្ម័គ្រចិត្តពីគ្រឹះស្ថានមិនចំណុះច្បាប់ដែលធ្វើប្រតិបត្តិការ នៅក្នុងទីផ្សារឥណទាន

**ច.** ដាក់ពិន័យ និងទណ្ឌកម្មទៅលើភាគីទាំងអស់ដែលចូលរួមក្នុងសកម្មភាពប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមិនកម្រិតត្រឹមអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ និងអតិថិជននោះទេ។

**ប្រការ ២៥.- ក្រុមប្រឹក្សាផ្តល់យោបល់**

**១.** ក្រុមប្រឹក្សាផ្តល់យោបល់ ត្រូវមានសមាជិក ពីប្រាំ (០៥) រូប ដល់ដប់មួយ (១១) រូប។

**២.** ក្រុមប្រឹក្សាផ្តល់យោបល់ ត្រូវស្ថិតក្រោមការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវកោះប្រជុំយ៉ាងតិច ២ដងក្នុង១ឆ្នាំ ឬច្រើនជាងនេះ តាមការចាំបាច់។

**៣.** ដើម្បីធានាបាននូវប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន និងសុវត្ថិភាពនៃប្រព័ន្ធ ក្រុមប្រឹក្សាផ្តល់យោបល់ ត្រូវកោះប្រជុំឱ្យបានទៀងទាត់ ដើម្បីអនុម័តចំណុចដូចខាងក្រោម ៖

**ក.** ចក្ខុវិស័យជាយុទ្ធសាស្ត្រនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា

**ខ.** ទម្រង់ និងខ្លឹមសារនៃសំណុំឯកសារព័ត៌មានឥណទាន

**គ.** វិធានប្រតិបត្តិការសម្រាប់ការគ្រប់គ្រង សេវាចែករំលែកព័ត៌មានឥណទាន

**ឃ.** បច្ចុប្បន្នកម្មរយៈពេល បញ្ចូល និង បើកចំហទិន្នន័យព័ត៌មានឥណទាន

**ង.** ផលិតផល និងសេវាទាំងអស់របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងវិធីសាស្ត្របញ្ជូនដទៃទៀតរាប់បញ្ចូលទាំងបច្ចេកវិទ្យា និងវិធានការសុវត្ថិភាពផង

**ច.** ការចូលរួមរបស់សមាជិកថ្មី

**ឆ.** ភាពគ្រប់គ្រាន់នៃបច្ចេកវិទ្យា និងភាពស៊ីសង្វាក់គ្នា (Homogenization) នៃសេវាព័ត៌មានវិទ្យាក្នុងការផ្តល់ទិន្នន័យ

**ជ.** ខ្លឹមសារនៃសៀវភៅណែនាំពីប្រតិបត្តិការ និងបច្ចេកទេសទាក់ទងនឹងសុវត្ថិភាព ប្រតិបត្តិការ សិទ្ធិអតិថិជន ការដោះស្រាយវិវាទ និងរាល់ការកែប្រែខ្លឹមសារនេះ

**ឈ.** ខ្លឹមសារនៃក្រមប្រតិបត្តិ

**ញ.** ភាពសមស្របនៃសេវា និងផលិតផលដែលបានផ្តល់ និងគោលនយោបាយកំណត់ថ្លៃ

**ដ.** កម្មវិធីអប់រំសម្រាប់មន្ត្រីឥណទានដើម្បីប្រើប្រាស់ទិន្នន័យឱ្យបានត្រឹមត្រូវ

**ឋ.** ផ្តល់អនុសាសន៍ដល់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទាក់ទងនឹងការផ្តល់សេវា ឬការប្រព្រឹត្តទៅរបស់អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត។

**ប្រការ ២៦.- យន្តការដោះស្រាយវិវាទ**

**១.** រាល់បណ្តឹងពាក់ព័ន្ធនឹងសុក្រឹត្យភាព ឬព័ត៌មានឥណទាន ត្រូវបញ្ជូនទៅកាន់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីអង្កេត។

២. នៅពេលទទួលបានបណ្តឹង អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវអង្កេតចំពោះវិវាទនោះ និងត្រូវឆ្លើយតបក្នុងរយៈពេលដប់ (១០ ) ថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបណ្តឹងដោយៈ

**ក.** អង្កេតលើភាពត្រឹមត្រូវនៃការតវ៉ា ឬបណ្តឹងផ្សេងទៀត

**ខ.** ឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចទៅអ្នកប្តឹង

**គ.** កែសម្រួលរាល់ព័ត៌មានមិនត្រឹមត្រូវ ឬមិនគ្រប់ជ្រុងជ្រោយក្នុងរយៈពេលដប់ (១០) ថ្ងៃធ្វើការ។

៣. អតិថិជនដែលមិនពេញចិត្តចំពោះការសម្រេចនេះ អាចប្តឹងទៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ដប់ (១០) ថ្ងៃធ្វើការ ។

៤. ប្រសិនបើអតិថិជនមិនពេញចិត្តចំពោះការសម្រេចរបស់ធនាគារជាតិនៃកម្ពុជា អតិថិជនអាចបន្តប្តឹងទៅតុលាការ។

## ជំពូកទី ៩
## នីតិវិធីរដ្ឋបាល

### ប្រការ ២៧.- ការប្រព្រឹត្តល្មើស

អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិ ដែលទទួលបានព័ត៌មានឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងប្រើប្រាស់ព័ត៌មានឥណទានទាំងនោះក្នុងគោលបំណងផ្សេងក្រៅពីគោលបំណងនៃប្រកាសនេះត្រូវទទួលខុសត្រូវចំពោះការរំលោភលើបញ្ញត្តិនៃការសម្ងាត់វិជ្ជាជីវៈ និងទោសដូចមានចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

### ប្រការ ២៨.- ការពិន័យរដ្ឋបាល

បុគ្គលណាដែលបានប្រព្រឹត្តិល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវរងការពិន័យរដ្ឋបាលដូចខាងក្រោមៈ

១. ជនណាដែលប្រតិបត្តិដោយខ្លួនឯង ឬប្រតិបត្តិជំនួសឱ្យនីតិបុគ្គលក្នុងសកម្មភាពចែករំលែកព័ត៌មានឥណទានដោយមិនមានអាជ្ញាប័ណ្ណ ត្រូវរងការពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ២៥០.០០០.០០០ (ពីររយហាសិបលាន) រៀល ដោយមិនគិតដល់ការបិទគ្រឹះស្ថាននោះឡើយ។

២. បុគ្គល ឬអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិណា ដែលប្រើប្រាស់ព័ត៌មានឥណទានទទួលបានមកពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងគោលបំណងក្រៅពីទិសដៅដែលមានចែងនៅក្នុងប្រការ ៨ នៃប្រកាសនេះនឹងត្រូវរងការពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ២៥០.០០០.០០០ (ពីររយហាសិបលាន) រៀល ។

៣. រាល់បុគ្គលទាំងឡាយ មិនថាជាគ្រឹះស្ថានចំណុះច្បាប់ ឬគ្រឹះស្ថានមិនចំណុះច្បាប់ ត្រូវរងការពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងករណីៈ

**ក.** ប្រព្រឹត្តល្មើសនឹងក្រមប្រតិបត្តិ ឬ ខកខានមិនបានផ្តល់ព័ត៌មានឥណទានឱ្យបានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវដល់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានតាមពេលកំណត់

**ខ.** ខកខានមិនបានឆ្លើយតបតាមការស្នើសុំព័ត៌មាន របស់ធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយនោះ

គ. មានចេតនាផ្តល់ព័ត៌មានមិនពិត ឬមិនគ្រប់ជ្រុងជ្រោយទាក់ទងនឹងបណ្តឹង ឬការអង្កេតអតិថិជនមកឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ឃ. ខកខានមិនបានអនុវត្តតាមពេលកំណត់ស្របតាមសិទ្ធិអតិថិជន។

៤. ក្រៅពីការពិន័យរដ្ឋបាលខាងលើ បុគ្គលដែលប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ឬក្នុងក្រុមប្រតិបត្តិ អាចរងទណ្ឌកម្មខាងវិន័យ និងទណ្ឌកម្មខាងព្រហ្មទណ្ឌ តាមច្បាប់ជាធរមាន។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

### ប្រការ ២៩.- រយៈពេលអនុវត្ត

អ្នកផ្តល់ទិន្នន័យទាំងអស់ត្រូវរៀបចំ នីតិវិធី ដំណើរការ និងប្រព័ន្ធរបស់ខ្លួនឱ្យស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងប្រកាសនេះក្នុងរយៈពេលប្រាំបួន (០៩) ខែ គិតចាប់ពីថ្ងៃប្រកាសនេះចូលជាធរមាន។

បន្ទាប់ពីរយៈពេលកំណត់នេះ ធនាគារជាតិនៃកម្ពុជានឹងចាប់ផ្តើមអនុវត្តការពិន័យ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

### ប្រការ ៣០.- និរាករណ៍

ប្រកាសលេខ ធ៧-០៦-០៧៣ ប្រ.ក ស្តីពី ការប្រើប្រាស់និងការការពារព័ត៌មានឥណទាន ប្រកាសលេខ ធ៧-០៦-១០១ ប្រ.ក ស្តីពី ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រកាសលេខ ធ៧-០៦-១០២ ប្រ.ក ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រកាសលេខ ធ៧-០៦-១០៣ ប្រ.ក ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រកាសលេខ ធ៧-០៦-១០៤ ប្រ.ក ស្តីពី ការបង្កើតក្រុមប្រតិបត្តិនិងលេខាធិការដ្ឋាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់ទុកជានិរាករណ៍។

### ប្រការ ៣១.- ការអនុវត្ត

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

### ប្រការ ៣២.- ការចូលជាធរមាន

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១១

**ទេសាភិបាល**

ហត្ថលេខា និង ត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធ ១

## ក)　ទិន្នន័យសម្គាល់អត្តសញ្ញាណ

**រូបវន្តបុគ្គល**

(១)　នាមត្រកូល និងនាមខ្លួន

(២)　ភេទ

(៣)　ថ្ងៃ ខែ ឆ្នាំកំណើត

(៤)　អាសយដ្ឋានស្នាក់នៅ

(៥)　លេខអត្តសញ្ញាណប័ណ្ណ (លិខិតឆ្លងដែន បណ្ណ័សម្គាល់អ្នកបោះឆ្នោត ឬឯកសារសម្គាល់អត្តសញ្ញាណជាតិ)

(៦)　លេខសម្គាល់អត្តសញ្ញាណកម្មបង់ពន្ធ

**នីតិបុគ្គល**

(១)　ឈ្មោះអង្គភាព

(២)　រចនាសម្ព័ន្ធចាត់តាំងនិងរូបភាពគតិយុត្ត

(៣)　ទីតាំង

(៤)　លេខ និងកាលបរិច្ឆេទចុះបញ្ជីជានីតិបុគ្គល

(៥)　លេខអត្តសញ្ញាណកម្មបង់ពន្ធ

(៦)　នាមត្រកូល និងនាមខ្លួនរបស់នាយកប្រតិបត្តិ អភិបាល និងម្ចាស់ភាគហ៊ុន និង

(៧)　លេខអត្តសញ្ញាណកម្មបង់ពន្ធ នៃនាយកប្រតិបត្តិ អភិបាល និងម្ចាស់ភាគហ៊ុន

## ខ)　ទិន្នន័យឥណទាន

(១)　កាលបរិច្ឆេទផ្តល់ឥណទាន និងទូទាត់សងប្រាក់ដើម និងការប្រាក់ តាមការព្រមព្រៀង

(២)　ឥណទានសរុប ឬឥណទានដទៃទៀតដែលបានផ្តល់ឱ្យអតិថិជន

(៣)　រូបិយវត្ថុ

(៤)　សមតុល្យដក់សល់បច្ចុប្បន្ន

(៥)　ចំណាត់ថ្នាក់ឥណទានតាមប្រភេទហានិភ័យ

(៦)　កាលបរិច្ឆេទនៃសកម្មភាពទូទាត់សងប្រាក់ចុងក្រោយ

(៧)　ប្រភេទវត្ថុបញ្ចាំសម្រាប់ធានាឥណទាន ប្រសិនបើមាន

(៨)　ប្រភេទឥណទាន (និក្ខេប កម្ចីអតិថិជន និងឥណទានវិបារូបន៍ ។ល។)

(៩)　ឈ្មោះឥណទាយក/ឬលេខពិសេស (Unique) របស់ឥណទាយក

(១០)　មូលប្បទានបត្រដែលមិនបានទូទាត់សងប្រាក់

**(១១)** ឥណទានគ្មានលទ្ធភាពសង សមតុល្យនៅជំពាក់

**(១២)** សេចក្តីសម្រេចតុលាការពាក់ព័ន្ធនឹងកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ និង

**(១៣)** ព័ត៌មានដទៃទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា សម្រាប់ការត្រួតពិនិត្យ។

ក្នុងករណី អ្នកផ្តល់ឥណទានដែលលក់ទំនិញ ឬផ្តល់សេវាក្រោមរូបភាពជាឥណទាន ឬដោយមានលក្ខខណ្ឌពន្យារការទូទាត់សងប្រាក់ ៖

**(១)** បរិមាណទំនិញ និងសេវាដែលផ្តល់ក្រោមរូបភាពជាឥណទាន និងកាតព្វកិច្ចចាំបាច់មួយចំនួន

**(២)** កាលបរិច្ឆេទនៃការផ្តល់សេវា

**(៣)** កាលវិភាគនៃការទូទាត់សងប្រាក់ ដែលបានព្រមព្រៀង និង

**(៤)** ព័ត៌មានស្តីពីសមាសភាព និងប្រភេទវត្ថុបញ្ចាំដែលធានា កាតព្វកិច្ចទូទាត់សងប្រាក់ ។

## ឧបសម្ព័ន្ធ ២
## គំរូ កំណត់សម្គាល់អំពីសិទ្ធិឯកជន

*(កំណត់សម្គាល់អំពីសិទ្ធិឯកជន ត្រូវមាននៅក្នុងពាក្យសុំខ្ចីឥណទាន និងកម្ចីរបស់អ្នកផ្តល់ទិន្នន័យ)*

### កំណត់សម្គាល់អំពីសិទ្ធិឯកជន

យើង (ឈ្មោះគ្រឹះស្ថាន) នឹងប្រមូលព័ត៌មានរបស់ (អតិថិជន) យកទៅបញ្ចូលនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាប្រព័ន្ធដែលស្ថិតក្រោមការត្រួតពិនិត្យ របស់ធនាគារជាតិនៃកម្ពុជា។ ព័ត៌មានដែលប្រមូលបាននឹងត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃការផ្តល់ឥណទាន ហើយព័ត៌មាននេះនឹងត្រូវបានចែករំលែកដល់ឥណទាយកដទៃទៀត ដែលចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុលោមតាមបញ្ញត្តិដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និងក្នុងក្រមប្រតិបត្តិ។ ប្រសិនបើលោកអ្នក(អតិថិជន)ចង់បាន ឬចង់កែតម្រូវព័ត៌មានរបស់ខ្លួន លោកអ្នក (អតិថិជន) អាចស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយភ្ជាប់ជាមួយឯកសារសម្គាល់អត្តសញ្ញាណ ហើយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងឆ្លើយតបជូនលោកអ្នក (អតិថិជន) វិញ។

## ឧបសម្ព័ន្ធ ៣
## គំរូនៃការយល់ព្រម

*(លក្ខខណ្ឌនៃការយល់ព្រមនេះ ត្រូវមាននៅក្នុងពាក្យសុំខ្ចីឥណទាន កម្ចី និង ពាក្យសុំពន្យារទូទាត់សងប្រាក់របស់អ្នកផ្តល់ទិន្នន័យ។)*

**ការយល់ព្រម**

ខ្ញុំបាទ/នាងខ្ញុំ យល់ព្រមឱ្យគ្រឹះស្ថាន.........................................................ប្រមូលព័ត៌មានដែលមាននៅក្នុងពាក្យសុំ និងព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងពាក្យសុំនេះ ព្រមទាំងបើកចំហព័ត៌មានទាំងនេះ ទៅឱ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រការ ៨ នៃប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំបាទ/នាងខ្ញុំយល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងគ្រឹះស្ថាន (ឈ្មោះ.........និងអាសយដ្ឋានរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងគ្រឹះស្ថាន..............................) ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការផ្សព្វផ្សាយទិន្នន័យ។ ខ្ញុំបាទ/នាងខ្ញុំ មានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធី ដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាននិង/ឬក្រមប្រតិបត្តិ។

ធ៧-០២-២២០ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការលើមូលប័ត្ររបស់ធនាគារ
# ដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

**ប្រការ ១**.-

ធនាគារជាតិនៃកម្ពុជាគាំទ្រ និងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់ និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលប័ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសំរបសំរួលនីតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងសំរួលការផ្តល់ឥណទាន និងការជួញដូរមូលប័ត្រជាអន្តរធនាគារ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តនូវស្តង់ដារ ពិសេសសម្រាប់ធ្វើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារការី ឬជាប្រតិបត្តិករមូលប័ត្រ។

**ប្រការ ២**.-

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារការី ឬជាប្រតិបត្តិករមូលប័ត្របើធនាគារនោះផ្តល់ការធានា ឬជួញដូរ ឬធ្វើប្រព្រឹត្តកម្មមូលប័ត្រ។ ប្រសិនបើការទិញនិងលក់មូលប័ត្ររយៈពេលខ្លីតាមរូបភាពដដែលៗបង្ហាញឱ្យប្រតិបត្តិករមូលប័ត្រ ឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលប័ត្រធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលប័ត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ។

**ប្រការ ៣**.-

ការសំរបសំរួលនីតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតឱ្យធនាគារផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជាតាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជា ដោយមានការសួរបញ្ជាក់តបវិញ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់និងធនាគារទទួលប្រាក់ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោលដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយ បង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលរបស់សាមីធនាគាររៀងៗខ្លួនផងដែរ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសម្រាប់មូលប័ត្ររបស់រដ្ឋាភិបាល នៅពេលណាដែលមូលប័ត្រនេះត្រូវបានចេញផ្សាយ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសម្រាប់ការជួញដូរមូលប័ត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារនឹងត្រូវបង្កើតឡើងនៅពេលនោះ។

**ប្រការ ៤**.-

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារដែលធ្វើសកម្មភាពជួញដូរមូលប័ត្រ។ នីតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងការត្រួតពិនិត្យលើគោលនយោបាយនិងកំរិតហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការ

ជួញដូរ និងការបែងចែកភារកិច្ចការងារបណ្តុះបណ្តាល និងកម្មវិធីផ្តល់កំរៃដល់ប្រតិបត្តិករ និងបុគ្គលិក ការកាន់កាប់មូលប័ត្រនិងការកត់ត្រាការជួញដូរ និងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ។ ការត្រួតពិនិត្យបែបនេះអាចជាផ្នែកមួយនៃការត្រួតពិនិត្យជារួមទៅលើធនាគារ ឬអាចមានលក្ខណៈដោយឡែកពីការត្រួតពិនិត្យដទៃទៀត។

**ប្រការ ៥**.-

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចម្លង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយ លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលនៃធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១១-០៨២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត

**ប្រការ ១**.-

គ្រប់គ្រឹះស្ថានធនាគារតទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវរាល់កាតព្វកិច្ចដែលកំណត់ដោយបទបញ្ញាជាធរមាន។ ការអនុវត្តជាអចិន្ត្រៃយ៍នេះអាចនឹងសម្រេចបានតាមរយៈគោលនយោបាយច្បាស់លាស់ នីតិវិធីនិងដំណើរការសមស្រប និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងត្រួតពិនិត្យហានិភ័យ។ ការផ្គួបផ្សំគ្នានៃចំណុចខ្សោយចម្បងៗ រួមជាមួយការទទួលយកហានិភ័យហិរញ្ញវត្ថុអាចនាំឱ្យមានទម្រង់ហានិភ័យពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មដែលជាបំណុល និងកំណើនខ្លាំងនៃភាពងាយរងគ្រោះ ព្រមទាំងធ្វើឱ្យអន្តរាយដល់សមត្ថភាពទប់ទល់នឹងការវិវត្តអវិជ្ជមានដែលអាចប៉ាន់ប្រមាណជាមុន។ ដើម្បីវាយតម្លៃទម្រង់ហានិភ័យបានពេញលេញនៅកម្រិតគ្រឹះស្ថានធនាគារ និងបើចាំបាច់នៅកម្រិតគួបសរុប ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ក្នុងគោលបំណងប៉ាន់ប្រមាណជាមុននូវការវិវត្តអវិជ្ជមានជាសក្តានុពល និងដោះស្រាយទាន់ពេលវេលាដោយដាក់ចេញអធិបញ្ញាសមស្រប ដើម្បីអនុវត្តសកម្មភាពកែតម្រូវចាំបាច់ប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាព។

**ប្រការ ២**.-

ការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត សំដៅដល់ដំណើរការតាមដានត្រួតពិនិត្យអចិន្ត្រៃយ៍លើមូលដ្ឋាននៃការវាយតម្លៃទម្រង់ហានិភ័យ ការប៉ាន់ប្រមាណនិងស្ត្រេសតេស្ត (Stress-testing) ផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីកំណត់អត្តសញ្ញាណ កត្តានៃភាពងាយរងគ្រោះ និងភាពចុះខ្សោយរបស់គ្រឹះស្ថានឬក្រុមគ្រឹះស្ថានដែលរងការត្រួតពិនិត្យ និងប៉ាន់ប្រមាណអំពីបញ្ហានិងកង្វល់នៃការត្រួតពិនិត្យឱ្យបានទាន់ពេលវេលា សំដៅដោះស្រាយជាបន្ទាន់ទប់ស្កាត់ស្ថានភាពហិរញ្ញវត្ថុចុះខ្សោយជាលំដាប់និងពង្រឹងសមត្ថភាពទប់ទល់ស្ថានភាពអវិជ្ជមានរបស់ទីផ្សារតាមរយៈសកម្មភាពត្រួតពិនិត្យសមស្រប ។

**ប្រការ ៣**.-

ការអនុវត្តនិងសកម្មភាពត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ពឹងផ្អែកលើលទ្ធផលនៃការវាយតម្លៃទម្រង់ហានិភ័យប្រចាំគ្រា និងគ្រប់ជ្រុងជ្រោយនៅកម្រិតគ្រឹះស្ថាននិងកម្រិតគួបសរុប បើចាំបាច់។

ការវាយតម្លៃទម្រង់ហានិភ័យសំដៅដល់ការវិភាគគ្រប់ជ្រុងជ្រោយអំពីស្ថានភាពរបស់គ្រឹះស្ថានដោយផ្អែកលើរាល់ទិន្នន័យនិងព័ត៌មានដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា។

ការវាយតម្លៃនេះមានគោលបំណងវាយតម្លៃរាល់ហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសហានិភ័យសាធនភាព សាច់ប្រាក់ងាយស្រួល ឥណទាន/សមភាគី ទីផ្សារនិងអត្រាការប្រាក់ និងប្រសិទ្ធភាពនិង ឯករាជ្យភាពនៃសវនកម្មនិងការត្រួតពិនិត្យផ្ទៃក្នុង បញ្ហាហានិភ័យ/អាជីវកម្ម/និងការផ្តល់មូលនិធិប្រមូលផ្តុំ ពិពិធកម្ម សំពៀត

ឥណទាន ការកំណត់អត្តសញ្ញាណនៃភាពទន់ខ្សោយចំពោះសមត្ថភាពរបស់គ្រឹះស្ថានក្នុងការទប់ទល់នឹងការវិវត្ត អវិជ្ជមាននៃទីផ្សារឬអាជីវកម្ម ការរៀបចំនិងប្រសិទ្ធភាពគ្រប់គ្រងហានិភ័យ ការចាត់ចែងបុគ្គលិក ការបែងចែកភារកិច្ច និងទំនាស់ផលប្រយោជន៍ជាសក្តានុពល ឯករាជ្យភាពនៃមុខងារ "គន្លឹះ" ដូចជាការត្រួតពិនិត្យផ្ទៃក្នុងឬការប្រតិបត្តិតាមប្រសិទ្ធភាពនៃបែបបទរាយការណ៍ នីតិវិធីនិងដំណើរការប្រគល់សិទ្ធ/គណនេយ្យភាព ហេដ្ឋារចនាសម្ព័ន្ធនិងដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធគ្រប់គ្រងព័ត៌មាន អភិបាលកិច្ចសាជីវកម្មនិងប្រសិទ្ធភាពរបស់គណៈកម្មការដែលបានបង្កើត ការគាំទ្ររបស់ភាគទុនិក ផែនការយថាភាពសម្រាប់ដោះស្រាយហានិភ័យធំៗ នីតិវិធីនិងប្រសិទ្ធភាពនៃដំណោះស្រាយបែកអាប់ (Back up) ដែលគាំទ្រដោយការធ្វើតេស្តទៀងទាត់ប្រចាំគ្រា។

ជាពិសេស ការវាយតម្លៃនេះអាចអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណបានទាន់ពេលវេលានូវចំណុចខ្សោយចម្បងៗ និងបញ្ហាជាសក្តានុពល ដែលកើតឡើងដោយសារការគួបបញ្ចូលគ្នានូវហានិភ័យដែលអាចនាំឱ្យមានកត្តាងាយរងគ្រោះពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុល។

**ប្រការ ៤**.-

ធនាគារជាតិនៃកម្ពុជានឹងប្រើប្រាស់សេណារីយូ (Scenarios) និងរង្វាស់នៃការធ្វើស្ត្រេសតេស្ត (Stress-testing measures) ក៏ដូចជាការប៉ាន់ប្រមាណផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវាយតម្លៃផ្អែកលើរង្វាស់ស្ត្រេសមេទ្រិក (Stress Metrics)។ ការធ្វើស្ត្រេសតេស្ត (Stress testing) និងការប៉ាន់ប្រមាណនេះក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនៃផែនការយថាភាពជាពិសេសដូចជាផែនការផ្តល់មូលនិធិយថាភាព និងផែនការស្តារសាធនភាពនៅក្រោមស្ថានភាពឬការវិវត្តទីផ្សារជាអវិជ្ជមាន ជាដើម។

ក្នុងការអនុវត្តការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងពិចារណាផងដែរអំពីការប្តេជ្ញារបស់ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ក្នុងការវាយតម្លៃឡើងវិញប្រចាំគ្រាលើប្រសិទ្ធភាពនៃគោលនយោបាយទទួលយកហានិភ័យ រចនាសម្ព័ន្ធចាត់តាំង ការរៀបចំ និងឯករាជ្យភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។ ការវាយតម្លៃឡើងវិញនេះត្រូវបានអនុវត្តជាពិសេស ក្នុងករណី:

ក. មានការប្រែប្រួលចម្បងចំពោះសកម្មភាពរបស់គ្រឹះស្ថាន ដូចជាសកម្មភាពថ្មី ហានិភ័យថ្មី និងប្រតិបត្តិការថ្មី

ខ. មានការប្រែប្រួលចម្បងនៅក្នុងរចនាសម្ព័ន្ធសាជីវកម្ម ដូចជាការចូលភាគកម្ម ឬការបង្កើតបុត្តសម្ព័ន្ធឯកទេសថ្មី និង

គ. មានការវិវត្តអវិជ្ជមាននៃទីផ្សារ និងការប្រែប្រួលបរិស្ថានប្រកួតប្រជែង ដែលនាំឱ្យមានការដោះស្រាយនូវចំណុចខ្សោយជាសក្តានុពលក្នុងផែនការយថាភាព។

**ប្រការ ៥**.-

ផ្អែកលើការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងធ្វើការវិនិច្ឆ័យផ្អែកលើទស្សនៈអនាគត និងដោះស្រាយជាបន្ទាន់នូវបញ្ហាជាសក្តានុពលនៅក្នុងកម្រិតគ្រឹះស្ថាន និងក្នុងកម្រិតគួបសរុប បើចាំបាច់។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញវិធានការកែតម្រូវជាបន្ទាន់ចំពោះគ្រឹះស្ថាន បើចាំបាច់។ ការបង្គាប់ឱ្យអនុវត្ត

អធិបញ្ញាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការកែតម្រូវសមស្រប ចាំបាច់ត្រូវពិចារណាស្របតាមផលប៉ះពាល់ជាសក្តានុពលចំពោះស្ថិរភាពហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ធនាគារជាតិនៃកម្ពុជា នឹងពិចារណាដាក់ឱ្យអនុវត្តកាតព្វកិច្ចបង្កើនអនុបាតសាធនភាពចំពោះគ្រឹះស្ថាន ឬក្រុមគ្រឹះស្ថានដែលមានទម្រង់ហានិភ័យក្នុងការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុលដែលមានកត្តាងាយរងគ្រោះធ្ងន់ធ្ងរ និង/ឬដែលអាចមានការគំរាមកំហែងធ្ងន់ធ្ងរចំពោះម្ចាស់ប្រាក់បញ្ញើ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនេះជាការសម្រេចរបស់ធនាគារជាតិនៃកម្ពុជា ប៉ុន្តែមិនត្រូវលើសពី៣០ (សាបសិប) ភាគរយ នៃកាតព្វកិច្ចអនុបាតសាធនភាពអប្បបរមាដែលអនុវត្តចំពោះគ្រឹះស្ថានឡើយ។

**ប្រការ ៧**.-

ធនាគារជាតិនៃកម្ពុជាអាចលើកលែងកាតព្វកិច្ចបង្កើនអនុបាតសាធនភាព លុះត្រាតែទម្រង់ហានិភ័យដែលបានវាយតម្លៃឡើងវិញនោះលែងជាកង្វល់នៃការត្រួតពិនិត្យ ក្រោយពីបានពិចារណាលើប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវ។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនៅកម្រិតគួបសរុបត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរចំពោះគ្រឹះស្ថាន និងមិនត្រូវជាផ្នែកមួយនៃកាតព្វកិច្ចបើកចំហរព័ត៌មាននោះទេ។

**ប្រការ ៨**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គបេឡា អគ្គាធិការដ្ឋានអង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និង ត្រា: **ជា ចាន់តូ**

ធ៥-០៩-២២៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់កិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីផ្តល់ដល់អ្នកចូលរួមក្នុងទីផ្សារនូវក្របខណ្ឌកិច្ចសន្យាដែលមានការធានា ក្នុងគោលបំណងជម្រុញប្រតិបត្តិការកម្ចីអន្តរធនាគារ ដោយមានវត្ថុបញ្ចាំដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។ នៅក្នុងន័យនៃប្រកាសនេះ ពាក្យថាទទួលទិញវិញ (Repos) សំដៅដល់ពាក្យប៉ង់ស្យុង ដូចមានចែងនៅក្នុងមាត្រា២៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

នៅពេលដែលចុះហត្ថលេខាលើកិច្ចសន្យាមេ ភាគីទាំងពីរព្រមព្រៀងថា ប្រតិបត្តិការទទួលទិញវិញទាំងអស់ដែលត្រូវបានធ្វើរវាងភាគីទាំងពីរ ត្រូវតែអនុលោមតាមគោលការណ៍ដែលមានចែងក្នុងកិច្ចសន្យាមេនេះលើកលែងតែភាគីទាំងពីរបានព្រមព្រៀងជាក់លាក់ផ្សេងពីនេះ។ លើសពីនេះប្រតិបត្តិការទទួលទិញវិញនីមួយៗដែលធ្វើរវាងភាគីទាំងពីរ ត្រូវតែបានបញ្ជាក់ដោយមធ្យោបាយសមស្រប និងជាលាយលក្ខណ៍អក្សរ។

តាមកាលៈទេសៈតម្រូវ កិច្ចសន្យាមេបង្កើនភាពទន់ភ្លន់ក្នុងការគ្រប់គ្រងហានិភ័យនៃសមតុល្យឥណទានតាមរយៈការគណនាចំនួនសុទ្ធនៃឥណទានដែលនៅសល់ដោយរួមបញ្ចូលនូវរាល់ស្ថានភាពហានិភ័យនៃប្រតិបត្តិការទទួលទិញវិញទាំងអស់ ដែលស្ថិតក្រោមវិធាននៃកិច្ចសន្យាមេ។

**ប្រការ ២.-**

ក្រោមកាលៈទេសៈធម្មតា កិច្ចសន្យាមេនៃប្រតិបត្តិការទទួលទិញវិញ ត្រូវចាត់ទុកជាសំខាន់ថាជាមធ្យោបាយដើម្បីគ្រប់គ្រងហានិភ័យគូភាគី ដោយប្រមើលទុកជាមុននូវកំរិតកំណត់ដែលបើសិនជាថ្លៃទីផ្សារឡើងឬចុះដល់ ឬ ហួសកំរិតកំណត់នោះ នឹងអាចនាំឱ្យភាគីដែលទទួលរងហានិភ័យ ទាមទារវត្ថុបញ្ចាំបន្ថែមឬមួយក្នុងទម្រង់ជា Margin Calls ជាមូលបត្រឬ Margin Calls ជាសាច់ប្រាក់។ នៅពេលសមស្របនិងនៅពេលដែលភាគីទាំងពីរព្រមព្រៀងគ្នាលើបែបបទខាងលើ ការកាត់បន្ថយហានិភ័យគូភាគី អាចនឹងបានមកដោយសារការជួបគ្នានូវការបន្ថែម Margin Calls ជាមូលបត្រនិង Margin Calls ជាសាច់ប្រាក់។

បើគ្មានហេតុការណ៍ខកខានទេភាគីទាំងពីរនឹងបំពេញរាល់កាតព្វកិច្ចទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនីមួយៗក្រោមកិច្ចសន្យាមេ ដោយអនុលោមតាមលក្ខខណ្ឌជាក់លាក់នៃការបញ្ជាក់ទៅវិញទៅមកដែលចេញដោយភាគីទាំងពីរ។

ដូច្នេះ ប្រតិបត្តិការទទួលទិញវិញនីមួយៗដែលស្ថិតក្រោមកិច្ចសន្យាមេគឺជាការជួបគ្នានូវប្រតិបត្តិការពីរដែលត្រូវតែបានធ្វើឡើងព្រមគ្នាក្នុងពេលតែមួយ។ ប្រតិបត្តិការម្ខាង គឺភាគីឱ្យខ្ចីប្រាក់ផ្តល់ឥណទានដល់ភាគីខ្ចីប្រាក់ និងប្រតិបត្តិការម្ខាងទៀត ភាគីខ្ចីប្រាក់លក់កម្មសិទ្ធិពេញលេញនៃមូលបត្រទៅឱ្យភាគីឱ្យខ្ចីប្រាក់ដោយប្តេជ្ញា ទទួលទិញមូលបត្រវិញនាកាលវសានតាមថ្លៃព្រមព្រៀងគ្នា ដែលបានបញ្ជាក់ជាមុនក្នុងកិច្ចសន្យា។ ផ្នែកម្ខាងៗនៃប្រតិបត្តិការទទួលទិញវិញត្រូវបានចាត់ទុកថាជាការផ្តល់ការធានាដល់ភាគីនិមួយៗនៃកិច្ចសន្យា។

**ប្រការ ៣**.-

ភាគីទាំងពីរនៃកិច្ចសន្យាមេ ត្រូវតែព្រមព្រៀងគ្នាលើមូលបត្រសម្រាប់ប្រតិបត្តិការទទួលទិញវិញ។ យោងទៅលើការវិវត្តរបស់ទីផ្សារ ភាគីទាំងពីរត្រូវតែធ្វើបញ្ជីមូលបត្រ ហើយបញ្ជីនោះត្រូវចាត់ទុកជាកិច្ចសន្យាបន្ថែមទៅលើកិច្ចសន្យាមេ។

មូលបត្រទាំងនោះអាចក្លាយជាកម្មវត្ថុនៃហានិភ័យថ្លៃ ដូច្នេះវាត្រូវតែឆ្លើយតប និងអនុលោមទៅនឹងការរារាំងនិងការហាមឃាត់ដែលបានកំណត់នៅក្នុងកិច្ចសន្យាមេ ជាពិសេសចំពោះការផ្លាស់ប្តូរអត្រាការប្រាក់នៅក្នុងទីផ្សារ។ ដូច្នេះ ភាគីទាំងពីរត្រូវតែព្រមព្រៀងគ្នាលើគ្រាដែលត្រូវធ្វើការវាយតម្លៃវត្ថុបញ្ចាំតាមតម្លៃទីផ្សារ និងប្រភពព័ត៌មានថ្លៃ ដែលត្រូវប្រើសម្រាប់វាយតម្លៃនោះ។ លើសពីនេះ ស្ថានភាពហានិភ័យគូភាគីត្រូវតែបានព្រមព្រៀងគ្នា ហើយមូលបត្រដែលពាក់ព័ន្ធ និង/ឬ Margin Calls ជាសាច់ប្រាក់ត្រូវតែបានបញ្ជាក់។

ចំពោះស្ថានភាពហានិភ័យឥណទានដែលនៅសល់ដែលគ្មានការធានា អ្នកចូលរួមទីផ្សារត្រូវបង្កើតគោលនយោបាយ និងនីតិវិធីសមស្របក៏ដូចជាដំណើរការឱ្យបានគ្រប់គ្រាន់ ដើម្បីពិនិត្យនិងគ្រប់គ្រងស្ថានភាពហានិភ័យ និងដំណើរការបញ្ជាក់របស់ភាគីទាំងសងខាង។

**ប្រការ ៤**.-

អ្នកចូលរួមទីផ្សារត្រូវតែបង្កើតនីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងឱ្យបានគ្រប់គ្រាន់ដើម្បីការពារការខកខានមិនបានអនុវត្តកាតព្វកិច្ចទាន់ពេលវេលានៅពេលធ្វើប្រតិបត្តិការ។ ក៏ប៉ុន្តែ ប្រសិនបើភាគីណាមួយខកខានមិនបានទូទាត់ឬប្រគល់មូលបត្រដោយសារតែបញ្ហាប្រតិបត្តិការ ភាគីនោះត្រូវតែជូនដំណឹងភ្លាមទៅភាគីម្ខាងទៀតអំពីបញ្ហាដែលបានកើតឡើង ហើយទទួលខុសត្រូវចំពោះការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតឡើងដោយសារតែការខកខានមិនបានទូទាត់ឬប្រគល់ឱ្យទាន់ពេលវេលានោះ តាមលក្ខខណ្ឌនិងខចែងនៃកិច្ចសន្យា។

ក្នុងករណីបានដឹងមុននូវហេតុការណ៍ខកខានអនុវត្តកិច្ចសន្យាមេ ភាគីម្ខាងទៀតត្រូវតែជូនដំណឹងទៅភាគីខកខានអំពីការបញ្ចប់មុនពេលកំណត់ នូវប្រតិបត្តិការទាំងអស់ក្រោមកិច្ចសន្យាមេ និងគណនាចំនួនបំណុលសុទ្ធតាមតម្លៃទីផ្សារនៃគ្រប់កាតព្វកិច្ចពាក់ព័ន្ធទាំងអស់របស់ប្រតិបត្តិការ ដែលកំពុងអនុវត្តនៅថ្ងៃខកខាន។ បំណុលសុទ្ធដែលនៅសល់នេះ ត្រូវតែប្រគល់ទៅឱ្យអភិបាលបណ្តោះអាសន្ន ឬអ្នកជម្រះបញ្ជីនិងតុលាការដើម្បីដោះស្រាយដោយយោងទៅលើកាលៈទេសៈនៃការខកខាននោះ។ ប្រសិនបើភាគីម្ខាងទៀតត្រូវសងបំណុលសុទ្ធចុងក្រោយទៅឱ្យភាគីខកខាន ការទូទាត់សងត្រូវតែធ្វើទៅឱ្យកាតព្វកិច្ចសុទ្ធទៅវិញទៅមក ដោយសារការបញ្ចប់មុនពេលកំណត់បណ្តាលមកពីការខកខាន។

**ប្រការ ៥**.-

ដើម្បីធានា កុំឱ្យមានការជំទាស់លើការគណនាសមតុល្យសុទ្ធចុងក្រោយ និងយន្តការនៃការជំនួសមូលបត្រក្នុងប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេ អ្នកចូលរួមក្នុងទីផ្សារត្រូវតែប្រើប្រាស់គំរូកិច្ចសន្យាមេដែលជាឧបសម្ព័ន្ធនៃប្រកាសនេះទាំងស្រុង។

**ប្រការ ៦**.-

ដើម្បីអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជានឹងតម្រូវឱ្យអ្នកចូលរួមក្នុងទីផ្សារចុះហត្ថលេខាជាមុនលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការទីផ្សារចំហ ឬប្រតិបត្តិការអប្បហារ។

**ប្រការ ៧.-**

មុនពេលចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ អ្នកចូលរួមក្នុងទីផ្សារត្រូវតែធានាថា ពួកគេបានបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងគ្រប់គ្រាន់ក្នុងការវាយតម្លៃទីផ្សារ ពិនិត្យនិងគ្រប់គ្រងហានិភ័យគូភាគីរបស់ខ្លួន ដែលពាក់ព័ន្ធនឹងកិច្ចសន្យាមេឱ្យបានគ្រប់ជ្រុងជ្រោយ។

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយផងដែរ នូវសេចក្តីណែនាំលើបទប្បញ្ញត្តិស្តីអំពីការចុះកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ចាំបាច់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ និងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់លើទម្រង់របាយការណ៍តាមបទប្បញ្ញត្តិ។

ធនាគារជាតិនៃកម្ពុជា នឹងចេញផ្សាយសេចក្តីណែនាំបន្ថែមស្តីពីការគណនាស្ថានភាពថ្លឹងហានិភ័យដែលពាក់ព័ន្ធដោយស្ថានភាពហានិភ័យនៃឥណទាននៅសល់ដែលមានធានា ពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩.-**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៥-០១០-១៨៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

## សម្រេច

### ប្រការ ១.- គោលបំណង

ធនាគារជាតិនៃកម្ពុជាចេញផ្សាយមូលបត្រអាចជួញដូរបានក្នុងគោលបំណងដូចខាងក្រោម ៖

- ជម្រុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងការផ្តល់ឥណទានអន្តរធនាគារ ផ្អែកលើមូលដ្ឋានសុវត្ថិភាព ដោយមូលបត្រដែលត្រូវបានចេញផ្សាយអាចយកមកប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់ប្រតិបត្តិការទទួលទិញវិញ(Repo)។
- ផ្តល់ឱ្យអ្នកចូលរួមក្នុងទីផ្សារនូវជម្រើសទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលមួយទៀតបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា និងបង្កើតឧបករណ៍បន្ថែមក្នុងគោលដៅជួយគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់របស់ធនាគារជាតិ នៃកម្ពុជា។

នៅពេលមានការស្នើសុំពីអ្នកកាន់មូលបត្រនឹងអាចត្រូវផ្ទេរទៅឱ្យអ្នកចូលរួមក្នុងទីផ្សារណាមួយផ្សេងទៀតបាន លុះត្រាតែអ្នកទទួលមូលបត្របានបើកគណនីបញ្ញើសាច់ប្រាក់ និងគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃកម្ពុជាដែលមានតួនាទីជាអ្នកថែរក្សាមូលបត្រដែលខ្លួនបានចេញផ្សាយ។

### ប្រការ ២ .- លក្ខណៈនិងប្រភេទមូលបត្រដែលបានចេញផ្សាយ

១- មូលបត្រនឹងត្រូវបានចេញផ្សាយតាមសំណើរបស់អ្នកទិញ ដូចជាប្រាក់បញ្ញើមានកាលកំណត់ដែលដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជាដែរ។ មូលបត្រដែលបានចេញផ្សាយ នឹងទទួលបានអត្រាការប្រាក់ថេរដែលកំណត់ដោយធនាគារជាតិនៃកម្ពុជានៅពេលមានការបញ្ជាទិញ។ ការប្រាក់នឹងត្រូវបានបង្គរតាមមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងនៃឆ្នាំនីមួយៗ។ គូប៉ុង (Coupon) ដែលត្រូវបានគិតបង្គរតាមអាយុកាលនៃមូលបត្រនឹងត្រូវបានទូទាត់សងរួមគ្នាជាមួយតម្លៃចារឹករបស់មូលបត្រនៅកាលវសាន្តទៅឱ្យអ្នកកាន់មូលបត្រ ដូចបានកំណត់ក្នុងប្រការ ៦.២ នៃប្រកាសនេះ។

២- មូលបត្រ ត្រូវបានចេញផ្សាយជាអរូបិយ (Dematerialize) ដូច្នេះត្រូវតែបានដាក់ផ្ញើក្នុងគណនីបញ្ញើមូលបត្រដែលបើកដោយអ្នកទិញនៅធនាគារជាតិនៃកម្ពុជា មុនពេលបញ្ជាទិញ។ គំរូហត្ថលេខាអ្នកមានសិទ្ធិសម្រាប់ការទិញ និងការផ្ទេរមូលបត្រត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា។

៣- ការទិញនឹងត្រូវបានបញ្ជាក់ដោយធនាគារជាតិនៃកម្ពុជា។ ការកាន់កាប់មូលបត្រនេះ ត្រូវបានបង្ហាញដោយទៀងទាត់ផងដែរនៅក្នុងរបាយការណ៍គណនីមូលបត្រ។

៤- មូលបត្ររបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវបានចេញផ្សាយជារូបិយវត្ថុជាតិ និងជារូបិយប័ណ្ណ។ មូលបត្រទាំងនេះ នឹងត្រូវបានសម្គាល់ដោយលេខមាលាមូលបត្រ និងលេខសម្គាល់អត្តសញ្ញាណនៅក្នុងលេខមាលានេះមានដូចជា តម្លៃចារឹក រូបិយប័ណ្ណ អត្រាការប្រាក់ និងកាលវសាន្ត។

៥- មូលបត្រចារឹកជារូបិយវត្ថុជាតិមានកាលវសាន្តៈ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ ៦ខែ ៩ខែ និង១ឆ្នាំ។ មូលបត្រដែលចារឹកជារូបិយប័ណ្ណ មានកាលវសាន្តៈ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ និង៦ខែ។ ធនាគារជាតិនៃកម្ពុជានឹងកំណត់តម្លៃចារឹកនៃមូលបត្រនៅពេលចេញផ្សាយ។

## ប្រការ ៣ .- ការថែរក្សា និងការចុះបញ្ជីមូលបត្រ

១- ដូចបានចែងក្នុងប្រការ២ កថាខណ្ឌ២ ខាងលើ មូលបត្រត្រូវចេញផ្សាយជាអរូបិយ (Dematerialize)។ មូលបត្រទាំងនេះ ចាំបាច់ត្រូវដាក់ផ្ញើក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

២- បែបបទនៃការចុះបញ្ជី និងការផ្ទេរកម្មសិទ្ធិមូលបត្រត្រូវធ្វើដោយធនាគារជាតិនៃកម្ពុជា។

## ប្រការ ៤ .- ម្ចាស់កម្មសិទ្ធិលើមូលបត្រ

១- កម្មសិទ្ធិលើមូលបត្រអរូបិយ (Dematerialize) ត្រូវបានបញ្ជាក់ជាភស្តុតាងដោយការធ្វើលេខាចារឹកដោយទៀងទាត់នៅក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកចេញផ្សាយ និងជាអ្នកថែរក្សាមូលបត្រ។

ដូច្នេះ រាល់ការផ្លាស់ប្តូរកម្មសិទ្ធិចាំបាច់ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីបញ្ជាក់លើការផ្ទេរកម្មសិទ្ធិនេះឱ្យទៅអ្នកលក់និងអ្នកទិញមូលបត្រ។

២- ការបញ្ជាក់របស់ធនាគារជាតិនៃកម្ពុជា ទៅឱ្យអ្នកទិញតែម្ខាងមិនមែននិងមិនអាចចាត់ទុកជាប័ណ្ណសម្គាល់កម្មសិទ្ធិអាចជួញដូរបាននោះទេ និងដូចនេះអ្នកចូលរួមក្នុងទីផ្សារ មិនអាចធ្វើបិដ្ឋិលេខដើម្បីផ្ទេរកម្មសិទ្ធិមូលបត្រទាំងនោះបានឡើយ។

ការផ្ទេរកម្មសិទ្ធិនេះ អាចធ្វើឡើងស្របច្បាប់បានលុះត្រាតែធនាគារជាតិនៃកម្ពុជា ទទួលបានបញ្ជាពីភាគីទាំងពីរ ក្នុងការធ្វើប្រតិបត្តិការទិញ-លក់ផ្តាច់ ឬប្រតិបត្តិការដាក់វត្ថុធានា ជាពិសេសក្នុងទម្រង់ជាប្រតិបត្តិការទទួលទិញវិញ ឬដាក់បញ្ចាំជាវត្ថុធានាតែប៉ុណ្ណោះ។

**ប្រការ ៥ .- ប្រតិបត្តិការទទួលទិញវិញ (Repo)**

១- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានទទួលយកសម្រាប់ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ។ ក៏ប៉ុន្តែ ដើម្បីធានាសុវត្ថិភាពតាមកិច្ចសន្យា និងតាមផ្លូវច្បាប់សម្រាប់ប្រតិបត្តិការទាំងនោះ អ្នកចូលរួមក្នុងទីផ្សារទាំងឡាយ ត្រូវតែចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា។

២- ជាគោលការណ៍ ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ ត្រូវរួមបញ្ចូលនូវដំណាក់កាលពេញលេញដែលអនុវត្តដោយភាគីទាំងពីរ ក្នុងការបញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិនៃមូលបត្រ ដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញ។

៣- ចំពោះប្រតិបត្តិការដែលមានរយៈពេលខ្លី ភាគីនៃកិច្ចសន្យាអាចមិនចាំបាច់បញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិមូលបត្រដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញនោះឡើយ។ ក្នុងករណីនេះ អ្នកលក់មូលបត្រ (ភាគីខ្ចីប្រាក់) ត្រូវតែដើរតួជាអ្នកថែរក្សាមូលបត្របន្ទាប់ឱ្យអ្នកទិញមូលបត្រ (ភាគីឱ្យខ្ចីប្រាក់) និងចុះបញ្ជិកាគណនេយ្យជាបន្តបន្ទាប់ដើម្បីជាភស្តុតាងនៃការផ្ទេរកម្មសិទ្ធិ។

៤- ប្រតិបត្តិការទទួលទិញវិញអាចធ្វើបានដោយប្រើរូបិយប័ណ្ណខុសៗគ្នា យោងតាមកិច្ចសន្យាទ្វេភាគីរបស់ភាគីទាំងពីរ។ ក្នុងករណីនេះ ភាគីខ្ចីប្រាក់ជាអ្នកទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់ (អ្នកលក់មូលបត្រសន្យាថានឹងទិញមូលបត្រវិញតាមតម្លៃដែលបានព្រមព្រៀងទុកជាមុន)។ លើសពីនេះ ភាគីដែលទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញ និងទទួលបន្ថែមម៉ាជីនខលសាច់ប្រាក់ (Cash Margin Calls) ប្រសិនបើចាំបាច់។

**ប្រការ ៦ .- ការបញ្ជាក់ និងការបញ្ជាផ្ទេរ**

១- ការបញ្ជាក់លើការទិញ ដោយធនាគារជាតិនៃកម្ពុជា មិនរួមបញ្ចូលកម្មសិទ្ធិភាពលើមូលបត្រ ដែលបានទិញនោះទេ។ ដូច្នេះការបញ្ជាក់នេះ មិនអាចចាត់ទុកជាវិញ្ញាបនបត្រ ដែលអាចធ្វើបិដ្ឋិលេខដោយអ្នកចូលរួមទីផ្សារ ព្រោះថាការធ្វើបិដ្ឋិលេខនោះនឹងមិនរួមបញ្ចូលសិទ្ធិកាន់កាប់លើមូលបត្រនោះឡើយ។

២- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ជាមូលបត្រអរូបិយ (Dematerialize) ភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ គឺជាលទ្ធផលនៃការធ្វើលេខាចារឹកដោយទៀងទាត់លើមូលបត្រទាំងនោះនៅក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ នៅកាលវសាន្ត តម្លៃចារឹកនៃមូលបត្រ និងគូប៉ុងដែលបានបង្គរ ត្រូវបានផ្ទេរដោយស្វ័យប្រវត្តិ ចូលក្នុងគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធជាមួយគណនីបញ្ញើមូលបត្រនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកចូលរួមទីផ្សារមានបំណងវិនិយោគឡើងវិញនូវ

ចំនួនប្រាក់ទាំងអស់ ឬមួយផ្នែកនៃចំនួនប្រាក់ដែលបានទទួលអ្នកចូលរួមនោះត្រូវផ្តល់បញ្ជាទៅធនាគារជាតិនៃកម្ពុជាឱ្យបានមុនកាលវសាន្តចំនួនពីរថ្ងៃនៃថ្ងៃធ្វើការ។

៣- នៅពេលចេញផ្សាយមូលបត្រ ក្រោយពីទទួលបានបញ្ជាទិញជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយអ្នកទទួលសិទ្ធិ ធនាគារជាតិនៃកម្ពុជានឹងចុះឥណពន្ធក្នុងគណនីចរន្តដោយស្វ័យប្រវត្តិនិងចុះឥណទានគណនីបញ្ញើមូលបត្រដែលពាក់ព័ន្ធរបស់អ្នកកាន់កាប់មូលបត្រ នៅថ្ងៃប្រសិទ្ធិភាពដែលកំណត់នៅលើបញ្ជាទិញ។ អ្នកទិញ និងអ្នកចូលរួមដេញថ្លៃត្រូវធានាថា មានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនីដើម្បីទូទាត់សងថ្លៃមូលបត្រដែលបានទិញ ឬដេញថ្លៃបាន។

៤- ដើម្បីអនុវត្តការផ្ទេរកម្មសិទ្ធិមូលបត្រដែលត្រូវបានលក់និងទិញយកវិញ តាមរយៈប្រតិបត្តិការទទួលទិញវិញ ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យភាគីទាំងពីរបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរដោយឡែកពីគ្នាទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនោះ។ ដើម្បីជៀសវាងការយឺតយ៉ាវ ភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ឱ្យគ្នាទៅវិញទៅមកនូវបញ្ជារបស់ខ្លួន ហើយត្រូវធានាថា ការបញ្ជាក់ទាំងនោះមានខ្លឹមសារស្របគ្នាទាំងស្រុង។

៥- ក្នុងដំណើរការនៃប្រតិបត្តិការទទួលទិញវិញ ទោះបីភាគីទាំងពីរយល់ព្រមទូទាត់ម៉ាជីនជាសាច់ប្រាក់ ឬដាក់បន្ថែមម៉ាជីនជាមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរ ដែលមានខ្លឹមសារស្របគ្នាទៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលបានចែងក្នុងកថាខណ្ឌទី ៤ ខាងលើ។

៦- ទោះបីជាភាគីទាំងពីរសម្រេចចិត្តទិញលក់ផ្ដាច់ជាមួយគ្នានូវមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាទៅធនាគារជាតិនៃកម្ពុជា ទាំងការផ្ទេរមូលបត្រដែលបានទិញ ឬលក់ នោះផង និងការទូទាត់សាច់ប្រាក់ដោយបញ្ជាក់អំពីថ្ងៃប្រសិទ្ធភាព និងចំនួនប្រាក់ដែលត្រូវបានទូទាត់សងផងដែរ។ ចរិតលក្ខណៈនៃមូលបត្រដែលត្រូវបានទិញ ឬលក់ ត្រូវតែបានបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់ដោយភាគីទាំងពីរនៅលើប្រតិបត្តិការដែលបានធ្វើ។

## ប្រការ ៧ .- ឥណទានអូវើណាយដែលមានការធានា និងឌីសខោនវិនដូ

**(Overnight Secured Facilities and Discount Window)**

១- ក្រោមលក្ខខណ្ឌដែលនឹងត្រូវមានចែងក្នុងប្រកាសដោយឡែករបស់ធនាគារជាតិនៃកម្ពុជា មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានប្រើប្រាស់ជាវត្ថុធានាសម្រាប់ការផ្តល់ឥណទានអូវើណាយ (Overnight) ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ឱ្យអ្នកចូលរួមទីផ្សារក្នុងការបំពេញសមតុល្យជាត់ទាត់អវិជ្ជមានរបស់ខ្លួនរយៈពេលមួយថ្ងៃ។ ឥណទាននេះ មិនត្រូវបានចាត់ទុកជាប្រភពទុនអចិន្ត្រៃយ៍របស់សមាជិកសភាជាត់ទាត់ឡើយ ហើយធនាគារជាតិនៃកម្ពុជានឹងផ្តល់ឥណទាននេះតាមអត្រាការប្រាក់ផាកពិន័យ។

២- ឥណទានអូវើណាយ (Overnight) ត្រូវបានធានាដោយមូលបត្រកាន់កាប់ដោយសមាជិកសភាផាត់ទាត់តាមតម្លៃចារឹកសមមូល ឬខ្ពស់ជាងកំរិតឥណទាន។ ធនាគារជាតិនៃកម្ពុជា នឹងផ្ទេរកម្មសិទ្ធិនៃវត្ថុធានាក្រោយពីបញ្ជាក់អំពីការផ្តល់ឥណទានអូវើណាយ (Overnight) នោះដល់អគ្គគាហក។ ធនាគារជាតិនៃកម្ពុជានឹងសងមូលបត្រត្រឡប់វិញនៅថ្ងៃបន្ទាប់ក្រោយពីគណនីផាត់ទាត់មានសមតុល្យវិជ្ជមានឡើងវិញ។

៣- មូលបត្រដែលកាន់កាប់ដោយអ្នកចូលរួមទីផ្សារអាចប្រើប្រាស់សម្រាប់បំពេញតម្រូវការសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ននិងរយៈពេលខ្លី។ ប្រតិបត្តិការនេះត្រូវតែមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា និងត្រូវបានផ្តល់សម្រាប់ចន្លោះពេលពី ២ថ្ងៃរហូតដល់ ២សប្តាហ៍នៃថ្ងៃធ្វើការ។ ការចូលទៅប្រើឥណទានអប្បហារ នឹងមិនត្រូវបានជំនួសដោយឥណទានវិបារូបន៍ឡើយ ដោយឥណទានទាំងពីរនេះមានលក្ខណៈខុសគ្នា។ ការធ្វើប្រតិបត្តិការអប្បហារ ជាមួយធនាគារជាតិនៃ កម្ពុជានឹងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដែលថាមូលបត្រនោះមានតម្លៃអាចទទួលយកបាន (អាចជួញដូរបាន)។ បញ្ជីមូលបត្រ ដែលអាចទទួលយកបានសម្រាប់ធ្វើប្រតិបត្តិការអប្បហារ និងអត្រាអប្បហារ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

៤- ប្រតិបត្តិការដែលដំណើរការក្នុងឱសខោនវីនដូ នឹងត្រូវគាំទ្រដោយកិច្ចសន្យាមេ សម្រាប់ប្រតិបត្តិការទទួលទិញវិញ ដែលចុះហត្ថលេខាដោយធនាគារជាតិនៃកម្ពុជា និងអគ្គគាហកមូលបត្រ។ ធនាគារជាតិនៃកម្ពុជានឹងផ្ទេរមូលបត្រ ដែលត្រូវបានជ្រើសរើស និងព្រមទទួលយក នៅថ្ងៃចាប់ផ្តើម និងនៅកាលវសានត្តនៃប្រតិបត្តិការ។

## ប្រការ ៨ .- ប្រតិបត្តិការទីផ្សារចំហ និងការដេញថ្លៃ

១- ទន្ទឹមនឹងការបញ្ជាទិញជាធម្មតានៃមូលបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា តាមអត្រាដែលបានកំណត់ ធនាគារជាតិនៃកម្ពុជា ក៏អាចរៀបចំដាក់ឱ្យដេញថ្លៃមូលបត្រ ដោយការជូនដំណឹងជាមុនតាមចំនួនដែលបានកំណត់ទៅឱ្យអ្នកចូលរួមដេញថ្លៃ។

២- ការដេញថ្លៃនេះ នឹងត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រតិបត្តិការទីផ្សារចំហ និងធ្វើឱ្យសម្រេចគោលដៅនៃគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ របស់ធនាគារជាតិនៃកម្ពុជា។

## ប្រការ ៩ .- អ្នកចូលរួមក្នុងការដេញថ្លៃ និងការអនុវត្តប្រតិបត្តិការទីផ្សារចំហ

១- ការរៀបចំ និងលក្ខខណ្ឌផ្សេងៗសម្រាប់ការចូលរួមដេញថ្លៃ នឹងត្រូវបានបញ្ជាក់ នៅក្នុងសេចក្តីជូនដំណឹងដោយឡែកៗពីគ្នា រៀងរាល់ការដេញថ្លៃនីមួយៗ ដែលនឹងប្រព្រឹត្តទៅតាមការផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីអញ្ជើញអ្នកចូលរួមដូចមានចែងក្នុងកថាខណ្ឌ ២ ខាងក្រោមឱ្យចូលរួមដេញថ្លៃ។

២- ការដេញថ្លៃ នឹងត្រូវអនុញ្ញាតចំពោះអ្នកចូលរួមក្នុងទីផ្សាររូបិយវត្ថុជាប្រក្រតី។ ក៏ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាអាចអនុញ្ញាតឱ្យអ្នកផ្សេងទៀតចូលរួមដេញថ្លៃ ដូចជាអាជីវករប្តូរប្រាក់ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀតជាដើម។ អ្នកដែលត្រូវបានអញ្ជើញឱ្យចូលរួមដេញថ្លៃ ត្រូវមានបញ្ជាក់នៅក្នុងសេចក្តីជូន

ដំណឹងស្តីពីការដេញថ្លៃនីមួយៗ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជារួមជាមួយនឹងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ឬសមស្របសម្រាប់ការរៀបចំខ្លួន និងការដាក់ពាក្យសុំចូលដេញថ្លៃ។

**ប្រការ ១០.-ការប្រើប្រាស់មូលបត្ររបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ជាវត្ថុធានាក្នុងប្រតិបត្តិការការទូទាត់ដុលតាមពេលវេលាពិត** (RTGS)

មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា នឹងត្រូវបានទទួលយកជាវត្ថុធានា ដើម្បីធានាដំណើរការនៃប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត។ បែបបទបង្កើតឱ្យមានជាប្រក្រតីនូវវត្ថុធានានោះ នឹងត្រូវបានចែងនៅក្នុងបទបញ្ញាស្តីពី ប្រតិបត្តិការប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត ។

**ប្រការ ១១** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២** .-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៥-០៣-០០៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់

## សម្រេច

ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក។

**ប្រការ ១**.- កំណត់អត្រាការប្រាក់បញ្ញើមានរយៈពេលកំណត់ជារៀល និងជាដុល្លារអាមេរិកសម្រាប់ផ្តល់ជូនអតិថិជនដែលបានផ្ញើប្រាក់នៅធនាគារជាតិនៃកម្ពុជាក្រៅពីអតិថិជនជាស្ថាប័នរដ្ឋដែលពាក់ព័ន្ធជាមួយថវិកាដូចតទៅ៖

ក- អត្រាការប្រាក់បញ្ញើជារៀល

- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល៣ខែ ១.០០% ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល៦ខែ ១.២០% ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ១ ឆ្នាំ ២.០០% ក្នុងមួយឆ្នាំ

ខ- (ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩)

អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ១ខែ ៣ខែ ៦ខែ ១ឆ្នាំ ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនតាមអត្រា១/២ នៃ SIBOR (Singapore Inter -Bank Offered Rate)។

**ប្រការ ២**.- អត្រាការប្រាក់ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣ តទៅរហូតដល់មានការកែប្រែជាថ្មី។

**ប្រការ ៣**.- រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤**.- អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥**.- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៥-០៩-០១១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក

**ប្រការ ១**.-

អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ១ខែ ៣ខែ ៦ខែ ១ឆ្នាំ ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនតាមអត្រា១/២ នៃ SIBOR (Singapore Inter-Bank Offered Rate)។

**ប្រការ ២**.-

អត្រាការប្រាក់លើប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច (Reserve Requirement) ដែលត្រូវទទួលការប្រាក់ត្រូវបានផ្តល់ជូនតាមមាត្រា ១/២ នៃSIBOR គិតលើមូលដ្ឋានមួយខែ។

**ប្រការ ៣**.-

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ខែ។

**ប្រការ ៤**.-

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០៩-២១៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

**ប្រការ ១** .-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ។

**ប្រការ ២** .-

រាល់ដំណាច់ខែនីមួយៗ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីអត្រាការប្រាក់ជាមធ្យមដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៣** .-

ប្រកាសលេខ ធ៥-៩៥-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥** .-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-៩៨-៤១១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ តាមរយៈធនាគារជាតិនៃកម្ពុជា

**ប្រការ ១**.-

បញ្ឈប់ការផ្តល់ទិដ្ឋាការឱ្យធនាគារពាណិជ្ជនាំចេញនូវសាច់ប្រាក់ជាដុល្លារអាមេរិកតទៅទៀត ដោយអនុញ្ញាតឱ្យធ្វើការផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ធនាគារពាណិជ្ជដែលមានបំណងផ្ទេរសាច់ប្រាក់ដុល្លារចេញ ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់)។

**ប្រការ ៣**.-

សោហ៊ុយសេវាក្នុងប្រតិបត្តិការផ្ទេរប្រាក់ នឹងត្រូវកំណត់ទៅតាមកាលៈទេសៈតម្រូវការសាច់ប្រាក់ដុល្លារអាស្រ័យដោយអគ្គនាយកដ្ឋានធនាគារជាតិនៃកម្ពុជា ជាអ្នកសំរេចចេញសេចក្តីជូនដំណឹងឱ្យអនុវត្តជាក់ស្តែងប្រចាំគ្រានីមួយៗ។

**ប្រការ ៤**.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ជាពិសេសប្រកាសលេខ ធ៧-៩៨-៣៦៦ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ និងប្រកាស លេខធ៩-៩៨-៣៨៦ ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាមានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៥-០០-១៥០ ប្រ.ក

# ប្រកាស
# ស្តីពី
# សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិក

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

១. បង្កើតសភាផាត់ទាត់សម្រាប់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកតទៅនេះហៅថា "សភាផាត់ទាត់" ដើម្បីផ្តល់នូវសេវាចំពោះអតិថិជននៃប្រព័ន្ធធនាគារ ដែលមានសំណូមពរទូទាត់ប្រចាំថ្ងៃនូវមូលប្បទានប័ត្រក្នុងចំណោមសមាជិកសភាផាត់ទាត់បើកគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

២. ដាក់ចេញនូវបទបញ្ញានៃសភាផាត់ទាត់តទៅនេះហៅថា "បទបញ្ញា" ដែលកំណត់អំពីលក្ខខណ្ឌទាំងឡាយសម្រាប់អនុវត្តចំពោះសេវានេះក្នុងប្រការបន្តបន្ទាប់ដូចខាងក្រោម។

**ប្រការ ២.- អំពីសមាជិកភាព**

១. ធនាគារដែលមានគោលបំណងចូលជាសមាជិកសភាផាត់ទាត់ត្រូវដាក់ពាក្យស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ១។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាម៉ីនឹងត្រូវបានធនាគារជាតិនៃកម្ពុជាបញ្ចូលជាសមាជិកនៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់។ សមាជិកសភាផាត់ទាត់ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាមដូចមានក្នុងឧបសម្ព័ន្ធ ២។

២. ធនាគារដែលមិនមែនជាសមាជិកត្រូវបានអនុញ្ញាតឱ្យមានតំណាងក្នុងសភាផាត់ទាត់ជំនួសខ្លួនដោយធនាគារជាសមាជិក ចំពោះសំណូមពរផាត់ទាត់និងទូទាត់មូលប្បទានប័ត្រ។ ការសុំឱ្យមានតំណាងនេះត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយធនាគារជាតិនៃកម្ពុជាជាមុន។

**ប្រការ ៣.- លក្ខណៈសម្បត្តិជាសមាជិក**

១. ធនាគារដែលធនាគារជាតិនៃកម្ពុជាចេញអាជ្ញាប័ណ្ណឱ្យប្រកបអាជីវកម្មអាចសុំចូលជាសមាជិក។ បែបបទនៃការស្នើសុំរួមមាន៖

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬអ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាមនិងគំរូហត្ថលេខា។

លើសពីនេះទៀតធនាគារជាសមាជិកត្រូវ៖

- មានគណនីចរន្តនិងគណនីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា
- បង់សោហ៊ុយសេវាតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

២.ធនាគារជាសមាជិកត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ។

**ប្រការ ៤.- ការបាត់បង់សមាជិកភាព**

១. ធនាគារដែលត្រូវបានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាប័ណ្ណពុំអាចចូលរួមក្នុងសភាផាត់ទាត់បានទេ។

២. ធនាគារអាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាផាត់ទាត់ឱ្យតែធនាគារនោះបានធ្វើការសម្រប សម្រួលត្រឹមត្រូវជាមួយនឹងធនាគារជាសមាជិកមួយទៀតឱ្យកាន់កាប់មូលប្បទានប័ត្រ ដើម្បីផាត់ទាត់ ជំនួសខ្លួនដោយមានការយល់ព្រមជាមុនជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥.- ធនាគារទូទាត់**

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃអំពីទឹកប្រាក់សរុបនៃមូល-ប្បទានប័ត្រដែលសភាផាត់ទាត់បានបញ្ជូនទៅនិងទទួលយក និងគណនីទឹកប្រាក់សុទ្ធដែលត្រូវចុះឥណពន្ធ ឬចុះឥណទានគណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ។

**ប្រការ ៦.- អំពីការគ្រប់គ្រង**

១. ធនាគារជាតិនៃកម្ពុជាត្រូវជ្រើសរើសប្រធានសភាផាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាផាត់ទាត់។ ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និងតាមដានមុខងារប្រចាំថ្ងៃទៅឱ្យអ្នកដឹកនាំផាត់ទាត់។ ប្រធានសភាផាត់ទាត់ និងអ្នកដឹកនាំផាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា។

២. ករណីកើតមានវិវាទរវាងតំណាងរបស់ធនាគារសមាជិកក្នុងពេលប្រគល់ ឬទទួលការទូទាត់ ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសម្រេចរបស់អ្នកដឹកនាំផាត់ទាត់ អាចត្រូវទទួលយកជាបណ្ដោះអាសន្នដោយមានទិដ្ឋាការរបស់ប្រធានសភាផាត់ទាត់។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសម្រេចការដោះស្រាយត្រូវធ្វើដោយផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

**ប្រការ ៧.- គណៈកម្មាធិការប្រតិបត្តិការ**

១. ការងារសភាផាត់ទាត់អាចត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការដែលរួមមានតំណាងមួយរូបរបស់ធនាគារសមាជិកនីមួយៗ និងដឹកនាំដោយប្រធានមួយរូបជ្រើសរើសដោយសមាជិក។ ប្រធានត្រូវបម្រើការរយៈពេលមួយឆ្នាំ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំង និងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាផាត់ទាត់។

២. គណៈកម្មាធិការប្រតិបត្តិការមានមុខងារដូចតទៅ៖

- ពិគ្រោះផ្ដល់យោបល់ដើម្បីលើកកម្ពស់គុណភាពប្រតិបត្តិការផាត់ទាត់
- ពង្រឹងសណ្ដាប់ធ្នាប់និងវិន័យរបស់តំណាងសមាជិក
- អនុវត្តឱ្យបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជាឬដោយគណៈកម្មាធិការ។

៣. គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់ ៤ដង ក្នុងមួយឆ្នាំ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយលក្ខណ៍អក្សររបស់សមាជិកពីររូបយ៉ាងតិចដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា។

**ប្រការ ៨.- ការកែប្រែបទបញ្ជា**

ខ្លឹមសារ និងលក្ខខណ្ឌនៃបទបញ្ជាជាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការជាត់ទាត់ទៅ ខេត្ត-ក្រុង ដទៃទូទាំងប្រទេសបន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូទាត់។

## ជំពូកទី ២

## និយមន័យនៃពាក្យបច្ចេកទេស

**ប្រការ ៩.-**

ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ជាមាននិយមន័យដូចតទៅ៖

១.ថ្ងៃធ្វើការ (Business Day) គឺថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ឬថ្ងៃបន្ថែមណាមួយដែលធនាគារជាតិនៃកម្ពុជាបានកំណត់បើកធ្វើការ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សម្រាកជាសាធារណៈទេ។

២.សភាជាត់ទាត់ (Clearing House) គឺជាមណ្ឌលសម្រួលការជាត់ទាត់ដែលធ្វើឡើងដោយធនាគារជាតិនៃកម្ពុជានៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ។

៣.ឧបករណ៍ទូទាត់ (Payment or item) គឺជាមូលប្បទានប័ត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ មូលប្បទានប័ត្រគឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយឱ្យទូទាត់ប្រាក់គណនីនោះទៅឱ្យអត្ថគាហក។

៤.ឧបករណ៍បង្វិលវិញឬមិនទូទាត់ (Returned or unpaid item) គឺជាមូលប្បទានប័ត្រដែលមិនអាចទូទាត់ដោយសមាជិកទទួលដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ៣។ មូលប្បទានប័ត្រត្រូវចាត់ទុកថាបានទូទាត់បញ្ចប់ជាមួយនឹងមូលនិធិដែលបានសងទៅអត្ថគាហក លុះត្រាតែគ្រាជាត់ទាត់នៃមូលប្បទានប័ត្របង្វិលវិញត្រូវបិទ។

៥.ឧបករណ៍ដែលអាចទទួលយកបាន(Eligible items)នៅសភាជាត់ទាត់រួមមាន៖

ក. មូលប្បទានប័ត្រ និងរូបិយាណត្តិជាដុល្លារអាមេរិករបស់ធនាគារដែលបានចេញផ្សាយដោយតតិយជនត្រូវសងឱ្យតតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតិនៅភ្នំពេញ។

ខ. មូលប្បទានប័ត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

គ. ឧបករណ៍ឥណពន្ធខ្លះទៀតដែលធនាគារជាតិនៃកម្ពុជាកំណត់ថាអាចទទួលយកបាន។ មូល-ប្បទានប័ត្របានចេញផ្សាយតាមទម្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយធនាគារមានលំនាំ

ស្តង់ដារដូចដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ មូលប្បទានប័ត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬបារាំង។

៦.សមាជិក(Participant) គឺជាធនាគារដែលបានយល់ព្រមចូលរួមក្នុងសភាផាត់ទាត់ក្រោមខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជានេះ។

៧.ការចូលរួម(Participation) គឺជាវត្តមានក្នុងគ្រាផាត់ទាត់ប្រចាំថ្ងៃរបស់សភាផាត់ទាត់។ សមាជិកត្រូវចូលរួមរាល់គ្រាផាត់ទាត់ទោះបីមាន ឬគ្មានមូលប្បទានប័ត្រដើម្បីបញ្ជូនទៅសមាជិកដទៃក្តី។

៨.សមាជិកទទួល (Receiving Participant) គឺជាសមាជិកដែលទទួលការទូទាត់ជាមូលប្បទានប័ត្រតាមរយៈសភាផាត់ទាត់។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង (Paying Bank)។

៩.សមាជិកប្រគល់ (Sending Participant) គឺជាសមាជិកដែលប្រគល់មូលប្បទានប័ត្រសម្រាប់ការទូទាត់តាមរយៈសភាផាត់ទាត់។

១០.កិច្ចបញ្ជិកា (Books) គឺជាការកត់ត្រាគណនេយ្យលើគណនីអតិថិជន ដែលបើកនៅធនាគារ និងគណនីចរន្តរបស់ធនាគារដែលបើកនៅធនាគារជាតិនៃកម្ពុជា។

១១.ការកត់ត្រា (Posting) គឺជាការចុះឥណពន្ធគណនីអតិថិជនសម្រាប់មូលប្បទានប័ត្រដោយធនាគារទទួល។

១២.ការទូទាត់(Settlement) គឺជាលេខនានៃឥណពន្ធសុទ្ធ ឬឥណទានសុទ្ធក្នុងគណនីផាត់ទាត់របស់ធនាគារជាសមាជិកសម្រាប់ការផាត់ទាត់ប្រចាំថ្ងៃ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ននិងអាចដកហូតមកវិញចំពោះការទូទាត់ណាដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ជា។

១៣.លេខអត្តសញ្ញាណ (Routing Number) គឺជាលេខសម្គាល់របស់សមាជិកដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយធនាគារជាតិនៃកម្ពុជា។ លេខអត្តសញ្ញាណត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាផាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសមស្របលើមូលប្បទានប័ត្រដោយអនុលោមតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា។

១៤.គ្រាផាត់ទាត់(Session) គឺជាការប្រជុំរបស់សមាជិកសភាផាត់ទាត់ដើម្បីប្តូរមូលប្បទានប័ត្រទៅវិញទៅមក។ គ្រាផាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាផាត់ទាត់បន្ទាប់បន្សំសម្រាប់បង្វិលវិញនូវមូលប្បទានប័ត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល។ ប៉ុន្តែប្រធានអាចសម្រេចយកគ្រាផាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយប្រសិនបើយល់ថាចាំបាច់។

១៥.គណនីផាត់ទាត់ (Clearing Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជាសម្រាប់ការទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាផាត់ទាត់។ គណនីនេះត្រូវបានប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់ដោយសមាជិក។

១៦.គណនីប្រាក់បម្រុងកាតព្វកិច្ច(Reserve Requirement Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជា ដើម្បីអនុវត្តតាមប្រកាសស្តីពីប្រាក់បម្រុងកាតព្វកិច្ចដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។ គណនីនេះមិនអាចប្រើសម្រាប់ការទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់ដោយសមាជិកបានទេ។

១៧.គណនីប្រាក់តម្កល់ធានា(Deposit Guaranty Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជាដោយត្រូវតម្កល់ប្រាក់ចំនួនស្មើនឹងដប់ភាគរយ (១០%) នៃដើមទុនចុះក្នុងលក្ខន្តិកៈ។ គណនីនេះមិនអាចប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់ដោយសមាជិកបានទេ។

## ជំពូកទី ៣

## ការទទួលខុសត្រូវរបស់ធនាគារប្រគល់

**ប្រការ១០**.-

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាផាត់ទាត់ ដើម្បីប្រគល់មូលប្បទានប័ត្រទៅឱ្យសមាជិកដទៃ។ ការប្រគល់មូលប្បទានប័ត្រទ្វេភាគីក្រៅពីគ្រាប្រជុំនៃសភាផាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងពិសេសទៅវិញទៅមករវាងសមាជិកសភាផាត់ទាត់ផ្ទាល់។

**ប្រការ ១១**.-

សមាជិកប្រគល់ត្រូវៈ

**១. អនុញ្ញាតនិងកំណត់អត្តសញ្ញាណនៃការប្រគល់**

មូលប្បទានប័ត្រទាំងអស់ត្រូវបោះត្រារបស់សមាជិកប្រគល់និងកាលបរិច្ឆេទនៃការបញ្ជូននៅខាងខ្នងនៃមូលប្បទានប័ត្រនីមួយៗ។

**២.រៀបចំការប្រគល់ឱ្យបានត្រឹមត្រូវ**

សមាជិកប្រគល់ម្នាក់ៗត្រូវរៀបចំតារាងនៃមូលប្បទានប័ត្រជាពីរច្បាប់គំរូ PPC001 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានប័ត្រនីមួយៗ និងតម្លៃសរុបនៃមូលប្បទានប័ត្រដែលត្រូវដកប្រាក់ (Draw on) ពីសមាជិកដទៃ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ៤។ តារាងគំរូ PPC001 ត្រូវបានរៀបចំសម្រាប់សមាជិកនីមួយៗដោយបង្ហាញនូវៈ

ក. ទឹកប្រាក់សរុប និងចំនួននៃមូលប្បទានប័ត្រចេញផ្សាយនៅបណ្តាទីស្នាក់ការភ្នំពេញដែលបានបង្ហាញដល់សមាជិកទាំងនោះនិង

ខ. មូលប្បទានប័ត្រមិនទូទាត់បង្វិលវិញនិងមិនអាចទទួលយកបាន។

សមាជិកប្រគល់ម្នាក់ៗត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPC001។

**៣.ចូលរួមទៀងទាត់ក្នុងគ្រាផាត់ទាត់**

មូលប្បទានប័ត្រត្រូវបានយកទៅសភាផាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗសមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាផាត់ទាត់លើសពី ៥នាទីអាចត្រូវផ្អាកមិនឱ្យចូលរួមគ្រាផាត់ទាត់នោះដោយអ្នកដឹកនាំផាត់ទាត់។ សមាជិកដែលត្រូវផ្អាកមិនឱ្យចូលរួមក្នុងគ្រាផាត់ទាត់មិនអាចប្រគល់មូលប្បទានប័ត្រទៅសមាជិកដទៃឡើយ។ ប៉ុន្តែសមាជិកនោះត្រូវទទួលយកហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានប័ត្រដែលសមាជិកដទៃប្រគល់ឱ្យខ្លួន។

**៤.អនុញ្ញាតឱ្យចុះឥណពន្ធគណនីចំពោះមូលប្បទានប័ត្របង្វិលវិញ**

ក្នុងករណីមានកាលបង្វិលវិញនៃមូលប្បទានប័ត្រ ដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ។

**៥.រក្សាទុកនូវការកត់ត្រា**

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការធ្វើឬការទូទាត់ដាច់ពីគ្នាសម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទបង្ហាញដំបូង។ ប៉ុន្តែនេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការកែតម្រូវការទូទាត់យឺតជាងរយៈពេលនេះទេ។

## ជំពូកទី ៥

## ការទទួលខុសត្រូវរបស់ធនាគារកណ្តាល

**ប្រការ ១២**.-

ធនាគារទទួលត្រូវទទួលយកមូលប្បទានប័ត្រ ដែលបានប្រគល់ឱ្យខ្លួននៅសភាផាត់ទាត់រៀងរាល់ថ្ងៃដោយរួមបញ្ចូលទាំងមូលប្បទានប័ត្រមិនទូទាត់ដូចមានចែងក្នុងប្រការ ១១។ មូលប្បទានប័ត្រដែលត្រូវប្រគល់ឱ្យសមាជិកទទួលក៏ប៉ុន្តែមិនបានទទួលយក ដោយសារតែការមិនបានចូលរួមក្នុងគ្រាផាត់ទាត់ឬត្រូវបានផ្អាកមិនឱ្យចូលរួមដោយសារការមកដល់យឺតក្នុងថ្ងៃនោះត្រូវចាត់ទុកថាបានប្រគល់នៅថ្ងៃនោះដើម្បីសំណូមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានប័ត្រមិនទូទាត់។

**ប្រការ ១៣**.-

សមាជិកទទួលត្រូវៈ

**១.បញ្ជាក់នូវការយល់ព្រមទទួល (Certify Acceptance)**

សមាជិកទទួលត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC001 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានប័ត្រនៅសភាផាត់ទាត់។ សមាជិកទទួលនីមួយៗត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង

PPC002 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធឬឥណទានក្នុងគណនីផាត់ទាត់របស់ខ្លួនជាលទ្ធផលនៃគ្រាផាត់ទាត់។

**២.ទូទាត់សងឬបង្វិលវិញនូវមូលប្បទានប័ត្រ (Settlement for or return payment)**

មូលប្បទានប័ត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សង ឬត្រូវបានបង្វិលវិញ។សមាជិកទទួលកាន់កាប់មូលប្បទានប័ត្រជាការផ្ញើទុក (In trust) រហូតដល់គេបានទទួលឥណទានពីបញ្ញើរ័ក (Drawer) នៃមូលប្បទានប័ត្រដោយចុះចូលគណនីរបស់អតិថិជនខ្លួន។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីផាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ។

**៣.បង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ (Return unpaid or dishonored payment)**

ក.បទប្បញ្ញត្តិទូទៅ (General Provision)

មូលប្បទានប័ត្រមិនទូទាត់ ឬបដិសេធត្រូវបានបង្វិលមកវិញតាមរយៈសភាផាត់ទាត់។ សមាជិកទទួលត្រូវបញ្ជាក់ឱ្យច្បាស់លើមូលប្បទានប័ត្របង្វិលវិញនូវមូលហេតុ ដែលបានព្រមព្រៀងដូចមានរាយនាមក្នុងឧបសម្ព័ន្ធ៣ និងឈ្មោះរបស់សមាជិកទទួល។

ខ.បង្វិលវិញឱ្យទាន់ពេល (Timely Return)

មូលប្បទានប័ត្រដែលត្រូវបង្វិលវិញតាមរយៈសភាផាត់ទាត់ ត្រូវធ្វើការបង្វិលវិញឱ្យទាន់ពេល ហើយសមាជិកទទួលមិនត្រូវបានបង្ខំឱ្យទទួលខុសត្រូវចំពោះមូលប្បទានប័ត្រនោះទេប្រសិនបើមូលប្បទានប័ត្រនោះត្រូវបានបង្វិលវិញមិនយឺតជាងម៉ោង ៣:០០ រសៀលនៃថ្ងៃផាត់ទាត់។ មូលប្បទានប័ត្រ មិនត្រូវបានចាត់ទុកថាទូទាត់បញ្ចប់ជាមួយនឹងការសងជម្រះជាសាច់ប្រាក់ទេរហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ។

គ.ការទូទាត់សម្រាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួលត្រូវបង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ ដែលបានបញ្ជាក់ច្បាស់ជាមូលប្បទានប័ត្របង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសម្រាប់សមាជិកទទួល (គំរូ PPC001)។

ឃ.ការផុតកំណត់នៃសិទ្ធិបង្វិលវិញ(Expiration of return privilege)

មូលប្បទានប័ត្រអាចមិនទូទាត់និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ។ មូលប្បទានប័ត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ (Dishonor) លើកទីពីរត្រូវតែដកចេញពីបណ្តាញនៃសភាផាត់ទាត់ដោយទុកឱ្យធ្វើបេឡានិច័យផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

**៤.ការរក្សាទុកនូវការកត់ត្រា**

សមាជិកទទួលត្រូវរក្សាទុកនូវថាសកុំព្យូទ័រ ឬក្រដាសតារាងនិងវត្ថុសំអាងជាក់ស្តែងផ្សេងៗទៀតដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសម្រាប់ប្រតិបត្តិការរបស់សភាផាត់ទាត់ សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទទទួល។ សមាជិកទទួលមិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតម្រូវការស្តីពីប្រតិបត្តិការ ដែលកើតមានឡើងបន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់។

**៥.ការបង្វិលវិញនៃមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងករណីមានកំហុស**

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជាសម្រាប់ការទូទាត់ប្រចាំថ្ងៃនិងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថាមានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារឱ្យសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់នូវមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួនទៅឱ្យធនាគារជាតិនៃកម្ពុជា។ បន្ទាប់មកធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានប័ត្រនោះទៅឱ្យសមាជិកដែលប្រគល់ពីដំបូងវិញ។

**៦.ការធានានូវសិទ្ធិប្រទានរបស់អតិថិជន**

សមាជិកទាំងឡាយត្រូវបានរំឭកថា៖

ក.ការចុះឥណពន្ធគណនីរបស់អតិថិជនទាមទារត្រូវមានសិទ្ធិប្រទានរបស់អតិថិជន។ មូលប្បទានប័ត្រដែលមានហត្ថលេខាក្លែងក្លាយ គឺគ្មានសិទ្ធិប្រទាននោះទេ ហើយជាធម្មតាមិនអាចត្រូវចុះឥណពន្ធគណនីរបស់អតិថិជនឡើយ។

ខ.អ្នកកាន់ឬអ្នកធ្វើបិដ្ឋិលេខ(ចារពីខ្នង) មូលប្បទានប័ត្រមិនអាចត្រូវចាត់ទុកជាមធ្យោបាយដែលគ្មានការក្លែងក្លាយឡើយ។ ដូច្នេះ សមាជិកអាចទទួលតែមូលប្បទានប័ត្រពីបុគ្គលណាដែលខ្លួនស្គាល់ ឬដែលត្រូវបានសម្គាល់អត្តសញ្ញាណត្រឹមត្រូវ។

## ជំពូកទី ៥

## ការទទួលខុសត្រូវរបស់ធនាគារជាតិនៃកម្ពុជា

**ប្រការ ១៤**.-

ធនាគារជាតិនៃកម្ពុជាគឺជាសមាជិកមួយនៃសភាផាត់ទាត់ដែលអាចទទួល និងប្រគល់មូលប្បទានប័ត្រដូចគ្នានឹងសមាជិកដទៃសម្រាប់សងឱ្យគេឬទារយកពីគេ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាសម្រួលដល់គ្រាផាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួនដែលបានបើកឱ្យសមាជិកទាំងអស់។

**ប្រការ ១៥.- ការរៀបចំគំរូ (Preparation of form)**

អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំនូវគំរូ PPC002 និង PPC003 ដោយឧបករណ៍អេឡិកត្រូនិកដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ៤ ដោយបញ្ចូលក្នុងតារាងកិច្ចការកុំព្យូទ័ររបស់សមាជិក (គំរូ PPC001) ពីថាសដែលបានយកមកក្នុងគ្រាផាត់ទាត់។

**ប្រការ ១៦.- ការទូទាត់ (Settlement)**

១. ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗដោយការចុះឥណពន្ធ និងចុះឥណទានគណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា។ នៅពេលដែលចំនួនទឹកប្រាក់សរុប នៃមូលប្បទានប័ត្រប្រគល់លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល លើសចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រប្រគល់គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ។ នៅពេលដែលអ្នកដឹកនាំផាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាផាត់ទាត់មានតុល្យភាពហើយនោះអ្នកដឹកនាំផាត់ទាត់ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងឬតារាងបោះពុម្ពចេញនៃគំរូ PPC002 របស់សមាជិកនីមួយៗទុកជាប្រកាសឥណពន្ធ ឬឥណទានក្នុងគណនីចរន្តរបស់សមាជិកនោះ។ បន្ទាប់មក អ្នកដឹកនាំផាត់ទាត់ត្រូវប្រកាសថាគ្រាផាត់ទាត់ត្រូវបញ្ចប់។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាផាត់ទាត់បានឡើយ។

២. ក្នុងករណីដែលសមាជិកទទួលមានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់សមាជិកនោះមានរយៈពេល ២ម៉ោង ដើម្បីសម្របសម្រួលមូលនិធិពីធនាគារផ្សេងមួយទៀតដើម្បីដាក់បញ្ចូលក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា។ នេះគឺជាប្រភពចំបង និងរំពឹងបាននៃមូលនិធិសម្រាប់ការទូទាត់។

**ប្រការ ១៧.- សមតុល្យដែលបានតម្កល់នៅធនាគារជាតិនៃកម្ពុជា (Balance maintained at NBC)**

សមាជិកទាំងអស់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចុះឥណពន្ធលើគណនីចរន្ត របស់ពួកគេនូវចំនួនទឹកប្រាក់ដែលជាលទ្ធផលនៃការផាត់ទាត់មូលប្បទានប័ត្រ និងត្រូវតម្កល់មូលនិធិក្នុងគណនីចរន្តទាំងនោះឱ្យមានគ្រប់គ្រាន់ដើម្បីចុះឥណពន្ធ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធនាគារសមាជិកតម្កល់ឱ្យបានគ្រប់គ្រាន់នូវប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងគណនីផ្សេង ដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន។

**ប្រការ ១៨.- ការទូទាត់មិនបាន (Failure to settle)**

១. ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធសុទ្ធរបស់ខ្លួនក្នុងសភាផាត់ទាត់ក្នុងរយៈពេលអនុញ្ញាត ២ម៉ោង នោះទេ អ្នកដឹកនាំផាត់ទាត់នឹងជូនដំណឹងចំពោះ ប្រធានសភាផាត់ទាត់ដែលនឹងកំណត់នូវវិធានការកែលំអ។ ប្រសិនបើធនាគារជាតិនៃកម្ពុជាបានប្រកាសថា សមាជិកនោះ"មានកំហុស (In Default)" ប្រធានសភាផាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត។

គ្រាផាត់ទាត់មិនត្រូវបានប្រកាសបិទទេលើកលែងតែគណនីទាំងអស់ ត្រូវបានចុះឥណពន្ធជាស្ថាពរ នៅថ្ងៃផាត់ទាត់នោះ។

២. ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាផាត់ទាត់ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺចុះបញ្ច្រាសនូវឥណទាន ដែលបានផ្តល់ឱ្យធនាគារទទួលចំពោះមូលប្បទាន-ប័ត្ររបស់ខ្លួនដែលយកទៅឱ្យសភាផាត់ទាត់ និងចុះបញ្ច្រាសនូវឥណពន្ធ ចំពោះមូលប្បទានប័ត្រដែលបានយកដោយធនាគារដទៃ ហើយគណនាជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាមនោះ។ អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំគំរូជាថ្មីដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់។ ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការផាត់ទាត់ឡើយ។

**ប្រការ ១៩.- ព្រំដែននៃការទទួលខុសត្រូវ (Limited of Liability)**

ធនាគារជាតិនៃកម្ពុជាមិនទទួលខុសត្រូវ និងមិនទទួលសងឡើយក្នុងករណីដែលសមាជិកមានការខាតបង់ក្នុងទំនាក់ទំនងជាមួយសមាជិកសភាផាត់ទាត់លើកលែងតែក្នុងករណីនៃការធ្វេសប្រហែស និងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់។ ការតវ៉ាទាំងអស់អំពីការបែងចែកមិនត្រឹមត្រូវការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានប័ត្រ កំហុសរបស់សមាជិក។ល។ ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់ លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ជីរបស់ធនាគារជាតិនៃកម្ពុជាដើម្បីកត់ត្រាប្រតិបត្តិការ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ញាសម្រាប់មូលប្បទានប័ត្ររបស់ខ្លួនផ្ទាល់ ដែលបានបញ្ចូលដើម្បីផាត់ទាត់និងទូទាត់តាមរបៀបដូចគ្នានឹងសមាជិកដទៃទៀត។

## ជំពូកទី៦

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ២០.- អាសយដ្ឋានសម្រាប់ការជូនដំណឹង (Address for notices)**

១. ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសភាផាត់ទាត់ដូចដែលតម្រូវដោយបទបញ្ញាត្រូវតែបញ្ជាក់អាសយដ្ឋានដូចតទៅនេះ៖

ប្រធាន

សភាផាត់ទាត់នៃមូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជា

២២-២៤ មហាវិថីព្រះនរោត្តម

ប្រអប់សំបុត្រ២៥

ភ្នំពេញ កម្ពុជា

២. ការជូនដំណឹងជាលាយលក្ខណ៍អក្សររវាងសមាជិក ដែលតម្រូវដោយបទបញ្ជានេះត្រូវបញ្ជូនទៅអាសយដ្ឋានដែលសមាជិកបានចង្អុលបង្ហាញជារៀងរាល់ពេល។ ការបញ្ជាក់ពីអាសយដ្ឋានសមស្របនឹងត្រូវមានប្រសិទ្ធភាព ចាប់ពីពេលបានទទួល ឬនៅពេលផុតកំណត់នៃពេលវេលាដែលបានកំណត់ពីមុនមក ក្នុងករណីនេះការជូនដំណឹងជាមុនគឺជាការចាំបាច់។

**ប្រការ ២១**.- **តំណាងទទួលសិទ្ធិ (Authorized representatives)**

សមាជិកត្រូវផ្តល់តារាងនៃតំណាងទទួលសិទ្ធិទាំងអស់ ដោយមានគំរូហត្ថលេខាគ្រប់គ្នាបញ្ជូនទៅអាសយដ្ឋានដូចមានចែងក្នុងប្រការ២០ ខាងលើ។

**ប្រការ ២២**.- **ច្បាប់សម្រាប់គ្រប់គ្រង (Governing Law)**

ប្រតិបត្តិការដែលស្ថិតនៅក្រោមបទបញ្ជានេះត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងបទបញ្ជាផ្សេងទៀតរបស់ធនាគារជាតិនៃកម្ពុជាដែលបានផ្សព្វផ្សាយឱ្យអនុវត្តនូវគ្រប់ករណី។

**ប្រការ ២៣**.- **លក្ខខណ្ឌភាពអាសន្ន (Emergency Condition)**

ការដឹកនាំប្រតិបត្តិការផាត់ទាត់ប្រចាំថ្ងៃអាចត្រូវពន្យារពេលពេញមួយថ្ងៃធ្វើការ ឬអាចត្រូវលើកទៅថ្ងៃបន្ទាប់ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបានដោយសារតែមានភាពអាសន្នដូចជាអាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ ការចលាចលធំៗក្នុងទីក្រុង ឬក្នុងប្រទេស។ ក្នុងកាលៈទេសៈនេះ ធនាគារជាតិនៃកម្ពុជា នឹងផ្តល់ការណែនាំជាក់លាក់ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសម្រាប់អនុវត្តក្នុងការផាត់ទាត់ ឬត្រូវបង្វិលវិញ។ ទោះយ៉ាងណាក្តីសមាជិកនីមួយៗគួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួនចំពោះការរំខាន និងត្រូវទទួលខុសត្រូវក្នុងការរក្សាគម្រោងការនិងទីកន្លែងដំណើរការដោយមានសម្ភារៈបរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសម្រាប់រយៈពេលបន្ទាន់ៗ។

**ប្រការ ២៤**.- **អំពីស្ថិតិ (Statistics)**

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រង និងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានផាត់ទាត់ប្រចាំថ្ងៃពេញមួយខែដោយបញ្ចូលព័ត៌មានស្តីពីមូលប្បទានប័ត្របង្វិលវិញ (មូលប្បទានប័ត្រមិនទូទាត់)។ លំដាប់លំដោយនៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសម្រាប់ឆ្នាំនេះ និងឆ្នាំមុន។ ព័ត៌មានស្តីពីការផាត់ទាត់របស់ធនាគារសមាជិកនីមួយៗមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេលើកលែងតែចំពោះធនាគារសាមី។

**ប្រការ ២៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងធនាគារជាសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ២៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់**

ឈ្មោះអ្នកសុំ :.......................................................................................................................

ហ៊ាន: :...................................................................................................................................

អាសយដ្ឋាន :........................................................................................................................

អាសយដ្ឋានប្រៃសណីយ៍ :......................................................................................................

ទូរស័ព្ទ :..............................................................................................................................

**ជូនចំពោះលោកប្រធានសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ**

ក្រោយពីបានស្វែងយល់ប្រកាសស្តីពីសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកលេខ...... ចុះថ្ងៃទី.........ខែ........ឆ្នាំ..........និងដើម្បីសម្រួលដល់ការប្រើប្រាស់មូលប្បទានប័ត្ររវាងធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ។

យើងខ្ញុំសុំស្នើលោកប្រធានសភាផាត់ទាត់មេត្តាពិនិត្យ និងសម្រេចឱ្យធនាគារយើងខ្ញុំបានចូលជាសមាជិកនៃសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកដោយអនុគ្រោះ។

សូមជូនភ្ជាប់ជាមួយនូវៈ

- ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណធ្វើអាជីវកម្មធនាគារ ១ច្បាប់
- លិខិតឧទ្ទេសនាមនិងគំរូហត្ថលេខា ៣ច្បាប់

យើងខ្ញុំសន្យាថានឹងគោរពអនុវត្តនូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ភ្នំពេញ, ថ្ងៃទី..........ខែ.........ឆ្នាំ២០០

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**

**ឧបសម្ព័ន្ធ ១-ខ** ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារ**......................................................

សូមឧទ្ទេសនាមនូវឈ្មោះនិងគំរូហត្ថលេខារបស់លោក-លោកស្រីក្នុងធនាគារយើងខ្ញុំដែលមានសិទ្ធិចុះហត្ថលេខាជាផ្លូវការលើលិខិតយុត្តិការ និងសំបុត្រស្នាមផាត់ទាត់របស់ធនាគារយើងខ្ញុំនៅធនាគារជាតិនៃកម្ពុជា ដើម្បីបម្រើការងារផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ។

ក/-<u>គណៈកម្មាធិការសភាផាត់ទាត់</u>៖

| | | |
|---|---|---|
| នាយកធនាគារ<br>ឈ្មោះ...................................... | | |
| តំណាងទទួលសិទ្ធិ<br>ឋានៈ.....................................<br>ឈ្មោះ...................................... | | |

ខ/-<u>តំណាងចូលរួមគ្រាផាត់ទាត់</u> (វត្តមានចាំបាច់ ១រូប)

| | | |
|---|---|---|
| តំណាង<br>ឋានៈ........................................<br>ឈ្មោះ...................................... | | |
| តំណាងទទួលសិទ្ធិ<br>ឋានៈ.....................................<br>ឈ្មោះ...................................... | | |

ពេលដែលលោក-លោកស្រីខាងលើមានការផ្លាស់ប្តូរភារកិច្ច យើងខ្ញុំនឹងឧទ្ទេសនាមនិងគំរូហត្ថលេខាជាថ្មីឡើងវិញ។

គំរូហត្ថលេខានេះមានប្រសិទ្ធភាពប្រើប្រាស់ចាប់

ពីថ្ងៃទី...................ដល់............................ ភ្នំពេញ, ថ្ងៃទី........ខែ............ឆ្នាំ២០០

ភ្នំពេញ, ថ្ងៃទី.......ខែ...........ឆ្នាំ២០០ ហត្ថលេខា

ប្រធានសភាផាត់ទាត់

<u>ឧបសម្ព័ន្ធ ២</u> [១]

## បញ្ជីរាយនាមសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិក

| លេខរៀង | ឈ្មោះធនាគារ | អក្សរសម្គាល់ | លេខអត្តសញ្ញាណ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| ៦ | | | |
| ៧ | | | |
| ៨ | | | |
| ៩ | | | |
| ១០ | | | |
| ១១ | | | |
| ១២ | | | |
| ១៣ | | | |
| ១៤ | | | |
| ១៥ | | | |
| ១៦ | | | |
| ១៧ | | | |
| ១៨ | | | |
| ១៩ | | | |
| ២០ | | | |

[១] *បញ្ជីរាយនាមសមាជិកនេះនឹងត្រូវបានកត់ត្រាតែធនាគារដែលធនាគារជាតិនៃកម្ពុជាបានយល់ព្រមឱ្យចូលជាសមាជិកសភាផាត់ទាត់។*

ឧបសម្ព័ន្ធ ៣

មូលហេតុដែលបានព្រមព្រៀងសម្រាប់ការបង្វិលវិញនូវមូលប្បទានប័ត្រ

១- សំវិធានវត្ថុគ្មានឬមិនគ្រប់គ្រាន់

២- សំវិធានវត្ថុមិនទាន់បានជម្រះ

៣- បញ្ឈប់ការទូទាត់

៤- បុរេបរិច្ឆេទនិងកាលបរិច្ឆេទមិនត្រឹមត្រូវ

៥- ហួសកាលបរិច្ឆេទ (លើសពី៦ខែ)

៦- ចំនួនជាអក្សរនិងជាលេខខុសគ្នា

៧- ខ្វះចំនួនទឹកប្រាក់ជាអក្សរ

៨- ហត្ថលេខារបស់បហារ័កខុសពីគំរូហត្ថលេខា

៩- ខ្វះហត្ថលេខារបស់បហារ័ក

១០- ខ្វះហត្ថលេខារបស់បហារ័កចំពោះការផ្លាស់ប្តូរ

១១- មិនចេញផ្សាយតាមគំរូធនាគារ

១២- មូលប្បទានប័ត្រខ្វេចខ្ទី

១៣- គណនីត្រូវបានបិទ

១៤- គ្មានគណនី

១៥- បហារ័កទទួលមរណៈភាព

១៦- បហារ័កធនក្ស័យត្រូវជម្រះបញ្ជី

១៧- ខ្វះត្រារបស់បហារ័ក (ក្នុងករណីដែលមានចែងក្នុងគំរូហត្ថលេខា)

១៨- គណនីឃាត់ទុក

**<u>ឧបសម្ព័ន្ធ៤</u>** គំរូ PPC001: កត់ត្រាមូលប្បទានប័ត្ររបស់ធនាគារនីមួយៗប្រគល់ឱ្យសភាផាត់ទាត់

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកនីក្រុងភ្នំពេញ

មូលប្បទានប័ត្រប្រគល់ដោយធនាគារ.............................................ចំពោះធនាគារ............................

ថ្ងៃទី...........................................

| | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជាដុល្លារ | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជាដុល្លារ |
|---|---|---|---|---|---|
| 1 | | | 35 | | |
| 2 | | | 36 | | |
| 3 | | | 37 | | |
| 4 | | | 38 | | |
| 5 | | | 39 | | |
| 6 | | | 40 | | |
| 7 | | | 41 | | |
| 8 | | | 42 | | |
| 9 | | | 43 | | |
| 10 | | | 44 | | |
| 11 | | | 45 | | |
| 12 | | | 46 | | |
| 13 | | | 47 | | |
| 14 | | | 48 | | |
| 15 | | | 49 | | |
| 16 | | | 50 | | |
| 17 | | | 51 | | |
| 18 | | | 52 | | |
| 19 | | | 53 | | |
| 20 | | | 54 | | |
| 21 | | | បូកសរុបមូលប្បទានប័ត្រថ្មី | | |
| 22 | | | | | |
| 23 | | | មូលប្បទានប័ត្របង្វិលវិញ | | |
| 24 | | | | | |
| 25 | | | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជាដុល្លារ |
| 26 | | | | | |
| 27 | | | 1 | | |
| 28 | | | 2 | | |
| 29 | | | 3 | | |
| 30 | | | 4 | | |
| 31 | | | 5 | | |
| 32 | | | 6 | | |
| 33 | | | 7 | | |
| 34 | | | 8 | | |
| | សរុប | | សរុបមូលប្បទានប័ត្របង្វិលវិញ | | |
| | | សរុបមូលប្បទានប័ត្រថ្មី និងមូលប្បទានប័ត្របង្វិលវិញ | | | |

សម្រាប់ប្រើប្រាស់ក្នុងសភាផាត់ទាត់

ហត្ថលេខា...............................

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

**សម្រង់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកមិនអាចទូទាត់បាន**

មូលប្បទានប័ត្រនៃគ្រាផាត់ទាត់ ថ្ងៃទី.......................................

ពីធនាគារ...........................................................................

ចំពោះធនាគារ.....................................................................

សម្រាប់គ្រាផាត់ទាត់ថ្ងៃទី.......................................................

| លេខរៀង | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|---|
| | | |
| សរុបៈ | | |

មូលប្បទានប័ត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPC001នៃគ្រាផាត់ទាត់ថ្ងៃទី.............................

សម្រាប់មូលប្បទានប័ត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ។

ហត្ថលេខា"ធនាគារប្រគល់".................................

ហត្ថលេខា"ធនាគារទទួល"..................................

គំរូ PPC002 :កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានប័ត្របានប្រគល់ឱ្យសភាផាត់ទាត់

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

មូលប្បទានប័ត្រប្រគល់ដោយ.................................. "ឈ្មោះធនាគារ" ឥណពន្ធគណនី:........................

នៅ............ "ម៉ោង" នាគ្រាផាត់ទាត់.......................... "កាលបរិច្ឆេទ" ឥណទានគណនី:........................

| ល.រ | លេខសម្គាល់ ធនាគារ | ធនាគារ | មូលប្បទានប័ត្រប្រគល់ "សំវិធានវត្ថុត្រូវទទួល" | ចំនួន | មូលប្បទានប័ត្រទទួល "សំវិធានវត្ថុត្រូវសងធនាគារដទៃ" | ចំនួន |
|---|---|---|---|---|---|---|
| 1 | | | | | | |
| 2 | | | | | | |
| 3 | | | | | | |
| 4 | | | | | | |
| 5 | | | | | | |
| 6 | | | | | | |
| 7 | | | | | | |
| 8 | | | | | | |
| 9 | | | | | | |
| 10 | | | | | | |
| 11 | | | | | | |
| 12 | | | | | | |
| 13 | | | | | | |
| 14 | | | | | | |
| 15 | | | | | | |
| 16 | | | | | | |
| | | | | | | |
| | សរុប: | | | | | |

ហត្ថលេខា........................... "ធនាគារប្រគល់ឬទទួល"

ហត្ថលេខា............................ "ធនាគារជាតិនៃកម្ពុជា"

គំរូ PPC003: កត់ត្រានូវលទ្ធផលផាត់ទាត់សរុបតាមធនាគារនីមួយៗ

**សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ**

នៅ............ "ម៉ោង" នាគ្រាផាត់ទាត់......................... "កាលបរិច្ឆេទ"

| ល.រ | លេខសម្គាល់ធនាគារ | ធនាគារ | "សំវិធានវត្ថុត្រូវសងធនាគារដទៃ " | ចំនួន | "សំវិធានវត្ថុត្រូវទទួលពីធនាគារដទៃ " | ចំនួន |
|---|---|---|---|---|---|---|
| 1 | | | | | | |
| 2 | | | | | | |
| 3 | | | | | | |
| 4 | | | | | | |
| 5 | | | | | | |
| 6 | | | | | | |
| 7 | | | | | | |
| 8 | | | | | | |
| 9 | | | | | | |
| 10 | | | | | | |
| 11 | | | | | | |
| 12 | | | | | | |
| 13 | | | | | | |
| 14 | | | | | | |
| 15 | | | | | | |
| 16 | | | | | | |
| | | សរុបៈ | | | | |

ហត្ថលេខា.............................. "ធនាគារជាតិនៃកម្ពុជា"

ធ ៥-០០-១៧០ ប្រ.ក

# ប្រកាស
# ស្តីពី
# សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ដាក់ចេញនូវបទបញ្ជាសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ដែលកំណត់អំពីលក្ខខណ្ឌទាំងឡាយ សម្រាប់អនុវត្តចំពោះការងារទូទាត់ប្រចាំថ្ងៃ នូវមូលប្បទានប័ត្រក្នុងចំណោមសមាជិកសភាផាត់ទាត់លើគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម។

**ប្រការ ២**.- **អំពីសមាជិកភាព**

១- ធនាគារដែលមានបំណងចូលជាសមាជិកសភាផាត់ទាត់ ត្រូវដាក់ពាក្យស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ ១។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាមីនឹងត្រូវបានធនាគារជាតិនៃកម្ពុជា បញ្ចូលជាសមាជិកនៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់។ សមាជិកនៃសភាផាត់ទាត់ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាម ដូចមានក្នុងឧបសម្ព័ន្ធ ២។

២- ធនាគារដែលមិនមែនជាសមាជិក ត្រូវបានអនុញ្ញាតឱ្យមានតំណាងក្នុងសភាផាត់ទាត់ជំនួសខ្លួន ដោយធនាគារជាសមាជិក ចំពោះសំណូមពរផាត់ទាត់ និងទូទាត់មូលប្បទានប័ត្រ ។ ការសុំឱ្យមានតំណាងនេះ ត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយធនាគារជាតិនៃកម្ពុជា ជាមុន។

**ប្រការ ៣**.- **លក្ខណៈសម្បត្តិជាសមាជិក**

១- ធនាគារដែលធនាគារជាតិនៃកម្ពុជាចេញអាជ្ញាប័ណ្ណឱ្យប្រកបអាជីវកម្មអាចសុំចូលជាសមាជិក។ បែបបទនៃការស្នើសុំរួមមាន៖

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬ អ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាម និង គំរូហត្ថលេខា។

លើសពីនេះទៀត ធនាគារជាសមាជិកត្រូវះ

– មានគណនីចរន្តជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា

– បង់សោហ៊ុយសេវា តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

២- ធនាគារជាសមាជិក ត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ។

**ប្រការ ៤.- ការបាត់បង់សមាជិកភាព**

១- ធនាគារដែលត្រូវបានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាប័ណ្ណ ពុំអាចចូលរួមក្នុងសភាផាត់ទាត់បានទេ ។

២- ធនាគារ អាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាផាត់ទាត់ ឱ្យតែធនាគារនោះបានធ្វើការសម្របសម្រួលត្រឹមត្រូវជាមួយនឹងធនាគារមួយទៀតជាសមាជិក ឱ្យកាន់កាប់មូលប្បទានប័ត្រដើម្បីផាត់ទាត់ជំនួសខ្លួន ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា ជាមុន។

**ប្រការ ៥.- ធនាគារទូទាត់**

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃ អំពីទឹកប្រាក់សរុបនៃមូលប្បទានប័ត្រ ដែលសភាផាត់ទាត់បានបញ្ជូនទៅ និងទទួលយក និងគណនាទឹកប្រាក់សុទ្ធដែលត្រូវចុះឥណពន្ធ ឬ ចុះឥណទាន គណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ។

**ប្រការ ៦.- អំពីការគ្រប់គ្រង**

១- ធនាគារជាតិនៃកម្ពុជា ត្រូវជ្រើសតាំងប្រធានសភាផាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាផាត់ទាត់។ ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និងតាមដានមុខងារប្រចាំថ្ងៃទៅឱ្យអ្នកដឹកនាំផាត់ទាត់។ ប្រធានសភាផាត់ទាត់ និងអ្នកដឹកនាំផាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា។

២- ករណីកើតមានវិវាទរវាងតំណាងរបស់ធនាគារសមាជិក ក្នុងពេលប្រគល់ ឬទទួលការទទួលការទូទាត់ ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសម្រេចរបស់អ្នកដឹកនាំផាត់ទាត់ អាចត្រូវទទួលយកជាបណ្តោះអាសន្នដោយមានទិដ្ឋាការរបស់ប្រធានសភាផាត់ទាត់។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសម្រេច ការដោះស្រាយត្រូវធ្វើដោយផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

**ប្រការ ៧.-** **គណៈកម្មាធិការប្រតិបត្តិការ**

១- ការងារសភាផាត់ទាត់អាចត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការដែលរួមមានតំណាងមួយរូបរបស់ធនាគារសមាជិកនីមួយៗ និងដឹកនាំដោយប្រធានមួយរូបជ្រើសរើសដោយសមាជិក។ ប្រធានត្រូវបម្រើការរយៈពេលមួយឆ្នាំ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំង និងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាផាត់ទាត់។

២- គណៈកម្មាធិការប្រតិបត្តិការ មានមុខងារដូចតទៅ ៖

- ពិគ្រោះផ្តល់យោបល់ដើម្បីលើកកំពស់គុណភាពប្រតិបត្តិការផាត់ទាត់
- ពង្រឹងសណ្តាប់ធ្នាប់ និងវិន័យរបស់តំណាងសមាជិក
- អនុវត្តឱ្យបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយគណៈកម្មាធិការ។

៣- គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់៤ដងក្នុងមួយឆ្នាំ ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយលក្ខណ៍អក្សររបស់សមាជិកពីររូបយ៉ាងតិចដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា។

**ប្រការ ៨.-** **ការកែប្រែបទបញ្ជា**

ខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជាផាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយ តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការផាត់ទាត់ទៅខេត្ត-ក្រុងដទៃទូទាំងប្រទេស បន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូទាត់។

## ជំពូកទី ២
## និយមន័យនៃពាក្យបច្ចេកទេស

**ប្រការ ៩.-**

ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ជាមាននិយមន័យដូចតទៅនេះ ៖

១- ថ្ងៃធ្វើការ ( Business day ) គឺពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ឬ ថ្ងៃបន្ថែមណាមួយដែលធនាគារជាតិនៃកម្ពុជាបានកំណត់បើកធ្វើការ ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សម្រាកជាសាធារណៈទេ។

២- សភាផាត់ទាត់ ( Clearing House ) គឺជាមណ្ឌលសំរួលការផាត់ទាត់ ដែលធ្វើឡើងដោយធនាគារជាតិនៃកម្ពុជា នៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ។

៣- ឧបករណ៍ទូទាត់ ( Payment or Item ) គឺជាមូលប្បទានប័ត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ មូលប្បទានប័ត្រគឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយឱ្យទូទាត់ប្រាក់ពីគណនីនោះទៅឱ្យអត្ថគាហក។

៤- ឧបករណ៍បង្វិលវិញ ឬ មិនទូទាត់ ( Returned or unpaid item )គឺជាមូលប្បទានប័ត្រដែលមិនអាចទូទាត់ដោយសមាជិកទទួល ដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ ៣

៥- ឧបករណ៍ដែលអាចទទួលយកបាន ( Eligible items ) នៅសភាផាត់ទាត់រួមមាន ៖

ក- មូលប្បទានប័ត្ររបស់ធនាគារ ដែលបានចេញផ្សាយដោយតតិយជន ត្រូវសងទៅឱ្យតតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតិនៅភ្នំពេញ

ខ- មូលប្បទានប័ត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

គ- ឧបករណ៍ឥណពន្ធខ្លះទៀតដែលធនាគារជាតិនៃកម្ពុជា កំណត់ថាអាចទទួលយកបាន។ មូលប្បទានប័ត្រត្រូវបានចេញផ្សាយតាមទ្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយធនាគារមានលំនាំស្តង់ដារដូចដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ មូលប្បទានប័ត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬ បារាំង ។

៦- សមាជិក ( Participant ) គឺជាធនាគារដែលបានយល់ព្រមចូលរួមក្នុងសភាផាត់ទាត់ក្រោមខ្លឹមសារ និងលក្ខខណ្ឌនៃបទបញ្ជានេះ។

៧- ការចូលរួម ( Participation ) គឺជាវត្តមានក្នុងគ្រាផាត់ទាត់ប្រចាំថ្ងៃរបស់សភាផាត់ទាត់។ សមាជិកត្រូវចូលរួមរាល់គ្រាផាត់ទាត់ ទោះបីមាន ឬគ្មានមូលប្បទានប័ត្រដើម្បីបញ្ជូនទៅសមាជិកដទៃក្តី។

៨- សមាជិកទទួល ( Receiving Participant ) គឺជាសមាជិកដែលទទួលការទូទាត់ជាមូលប្បទានប័ត្រតាមរយៈសភាផាត់ទាត់។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង ( Paying Bank )។

៩- សមាជិកប្រគល់ ( Sending Participant ) គឺជាសមាជិកដែលប្រគល់មូលប្បទានប័ត្រសម្រាប់ការទូទាត់តាមរយៈសភាផាត់ទាត់។

១០- កិច្ចបញ្ជិកា ( Books ) គឺជាការកត់ត្រាគណនេយ្យលើគណនីអតិថិជន ដែលបើកនៅធនាគារ និងគណនីចរន្តរបស់ធនាគារ ដែលបើកនៅធនាគារជាតិនៃកម្ពុជា។

១១- ការកត់ត្រា ( Posting ) គឺជាការចុះឥណពន្ធគណនីអតិថិជនសម្រាប់មូលប្បទានប័ត្រដោយធនាគារទទួល។

១២- ការទូទាត់ ( Settlement ) គឺជាលេខនានៃឥណពន្ធសុទ្ធ ឬឥណទានសុទ្ធក្នុងគណនីផាត់ទាត់របស់ធនាគារជាសមាជិក សម្រាប់ការផាត់ទាត់ប្រចាំថ្ងៃ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ន និងអាចត្រូវដកហូតមកវិញចំពោះការទូទាត់ណាដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ញា។

១៣- លេខអត្តសញ្ញាណ ( Routing number ) គឺជាលេខសម្គាល់របស់សមាជិក ដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយធនាគារជាតិនៃកម្ពុជា។ លេខអត្តសញ្ញាណត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាផាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសមស្របលើមូលប្បទានប័ត្រ ដោយអនុលោមតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា។

១៤- គ្រាផាត់ទាត់ ( Session ) គឺជាការប្រជុំរបស់សមាជិកសភាផាត់ទាត់ដើម្បីប្តូរមូលប្បទានប័ត្រទៅវិញទៅមក។ គ្រាផាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាផាត់ទាត់បន្ទាប់បន្សំសម្រាប់បង្វិលវិញនូវមូលប្បទានប័ត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល។ ប៉ុន្តែ ប្រធានអាចសម្រេចយកគ្រាផាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយ ប្រសិនបើយល់ថាចាំបាច់។

១៥- គណនីផាត់ទាត់ ( Clearing Account ) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជា សម្រាប់ទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាផាត់ទាត់។ គណនីនេះត្រូវបានប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់ធនាគារប្រគល់

**ប្រការ ១០._**

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាផាត់ទាត់ ដើម្បីប្រគល់មូលប្បទានប័ត្រទៅឱ្យសមាជិកដទៃ។ ការប្រគល់មូលប្បទានប័ត្រទ្វេភាគី ក្រៅពីគ្រាប្រជុំនៃសភាផាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងទៅវិញទៅមក ពិសេសរវាងសមាជិកសភាផាត់ទាត់ផ្ទាល់។

**ប្រការ ១១.-**

សមាជិកប្រគល់ត្រូវ ៖

**១- អនុញ្ញាត និងកំណត់អត្តសញ្ញាណនៃការប្រគល់**

មូលប្បទានប័ត្រទាំងអស់ត្រូវបោះត្រារបស់សមាជិកប្រគល់ និងកាលបរិច្ឆេទនៃការបញ្ជូន នៅខាងខ្នងនៃមូលប្បទានប័ត្រនីមួយៗ។

**២- រៀបចំការប្រគល់ឱ្យបានត្រឹមត្រូវ**

សមាជិកប្រគល់ម្នាក់ៗ ត្រូវរៀបចំតារាងនៃមូលប្បទានប័ត្រជាពីរច្បាប់ គំរូ PPC001 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានប័ត្រនីមួយៗ និងតម្លៃសរុបនៃមូលប្បទានប័ត្រដែលត្រូវដកប្រាក់ ( Draw on ) ពីសមាជិកដទៃ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ៤។ តារាងគំរូ PPC001 ត្រូវបានរៀបចំសម្រាប់សមាជិកនីមួយៗ ដោយបង្ហាញនូវ ៖

ក- ទឹកប្រាក់សុរប និងចំនួននៃមូលប្បទានប័ត្រចេញផ្សាយនៅបណ្តាទីស្នាក់ការភ្នំពេញដែលបានបង្ហាញដល់សមាជិកទាំងនោះ និង

ខ- មូលប្បទានប័ត្រមិនទូទាត់ បង្វិលវិញ និងមិនអាចទទួលយកបាន។

សមាជិកប្រគល់ម្នាក់ៗ ត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPC001 ។

**៣- ចូលរួមទៀងទាត់ក្នុងគ្រាជាត់ទាត់**

មូលប្បទានប័ត្រត្រូវបានយកទៅសភាជាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗ សមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាជាត់ទាត់លើសពី៥នាទី អាចត្រូវផ្អាកមិនឱ្យចូលរួមគ្រាជាត់ទាត់នោះ ដោយអ្នកដឹកនាំជាត់ទាត់។ សមាជិកដែលត្រូវផ្អាកមិនឱ្យចូលរួមក្នុងគ្រាជាត់ទាត់ មិនអាចប្រគល់មូលប្បទានប័ត្រទៅសមាជិកដទៃឡើយ។ ប៉ុន្តែ សមាជិកនោះត្រូវទទួលយក ហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានប័ត្រដែលសមាជិកដទៃប្រគល់ឱ្យខ្លួន។

**៤- អនុញ្ញាតឱ្យចុះឥណពន្ធគណនីចំពោះមូលប្បទានប័ត្របង្វិលវិញ**

ក្នុងករណីមានការបង្វិលវិញនៃមូលប្បទានប័ត្រដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ។

**៥- រក្សាទុកនូវការកត់ត្រា**

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ ដើម្បីបង្កើតឡើងវិញនូវការផ្ញើ ឬការទូទាត់ដាច់ពីគ្នា សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទបង្ហាញដំបូង។ ប៉ុន្តែ នេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវ ផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការទូទាត់យឺតជាងរយៈពេលនេះទេ។

## ជំពូកទី ៤

## ការទទួលខុសត្រូវរបស់ធនាគារទទួល

**ប្រការ ១២**.-

ធនាគារទទួល ត្រូវទទួលយកមូលប្បទានប័ត្រ ដែលបានប្រគល់ឱ្យខ្លួននៅសភាជាត់ទាត់រៀងរាល់ថ្ងៃដោយរួមបញ្ចូលទាំងមូលប្បទានប័ត្រមិនទូទាត់ដូចមានចែងក្នុងប្រការ ១១។ មូលប្បទានប័ត្រ ដែលត្រូវប្រគល់ឱ្យសមាជិកទទួល ក៏ប៉ុន្តែមិនបានទទួលយកដោយសារតែការមិន

បានចូលរួមក្នុងគ្រាផាត់ទាត់ ឬត្រូវបានផ្អាកមិនឱ្យចូលរួម ដោយសារការមកដល់យឺតក្នុងថ្ងៃនោះ ត្រូវចាត់ទុកថាបានប្រគល់នៅថ្ងៃនោះ ដើម្បីសំណូមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានប័ត្រមិនទូទាត់។

**ប្រការ ១៣**.- សមាជិកទទួលត្រូវ ៖

**១- បញ្ជាក់នូវការយល់ព្រមទទួល (Certify Acceptance)**

សមាជិកទទួល ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC001 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានប័ត្រនៅសភាផាត់ទាត់ ។ សមាជិកទទួលនីមួយៗ ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC002 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធ ឬ ឥណទានក្នុងគណនីផាត់ទាត់របស់ខ្លួនជាលទ្ធផលនៃគ្រាផាត់ទាត់ ។

**២- ទូទាត់សង ឬបង្វិលវិញនូវមូលប្បទានប័ត្រ (Settle for or return payment)**

មូលប្បទានប័ត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សង ឬត្រូវបានបង្វិលវិញ។ សមាជិកទទួលកាន់កាប់មូលប្បទានប័ត្រជាការផ្ញើទុក (In Trust) រហូតដល់គេបានទទួលឥណទានពីបហារិក (Drawer) នៃមូលប្បទានប័ត្រ ដោយចុះចូលគណនីរបស់អតិថិជនខ្លួន។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីផាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ។

**៣- បង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ (Return unpaid or dishonored payment)**

ក- បទប្បញ្ញត្តិទូទៅ (General Provision)

មូលប្បទានប័ត្រមិនទូទាត់ ឬបដិសេធ ត្រូវបានបង្វិលមកវិញតាមរយៈសភាផាត់ទាត់។ សមាជិកទទួល ត្រូវបញ្ជាក់ឱ្យច្បាស់លើមូលប្បទានប័ត្របង្វិលវិញនូវមូលហេតុ ដែលបានព្រមព្រៀងដូចមានរាយក្នុងឧបសម្ព័ន្ធ ៣ និងឈ្មោះរបស់សមាជិកទទួល។

ខ- បង្វិលវិញឱ្យទាន់ពេល (Timely return)

មូលប្បទានប័ត្រដែលត្រូវបង្វិលវិញតាមរយៈសភាផាត់ទាត់ ត្រូវធ្វើការបង្វិលវិញឱ្យទាន់ពេល ហើយសមាជិកទទួលមិនត្រូវបានបង្ខំឱ្យទទួលខុសត្រូវចំពោះមូលប្បទាន-ប័ត្រនោះទេ ប្រសិនបើមូលប្បទានប័ត្រនោះត្រូវបានបង្វិលវិញ មិនយឺតជាងម៉ោង

៣:០០ រសៀល នៃថ្ងៃផាត់ទាត់។ មូលប្បទានប័ត្រមិនត្រូវបានចាត់ទុកថា ទូទាត់បញ្ចប់ជាមួយនឹងការសងជំរះ ជាសាច់ប្រាក់ទេរហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ ។

គ- ការទូទាត់សម្រាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួល ត្រូវបង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ដែលបានបញ្ជាក់ច្បាស់ថា មូលប្បទានប័ត្របង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់ ។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសម្រាប់សមាជិកទទួល (គំរូ PPC001) ។

ឃ- ការផុតកំណត់នៃសិទ្ធិបង្វិលវិញ (Expiration of return privilege)

មូលប្បទានប័ត្រអាចមិនទូទាត់ និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ។ មូលប្បទានប័ត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ (Dishonor) លើកទីពីរ ត្រូវតែដកចេញពីបណ្តាញនៃសភាផាត់ទាត់ ដោយទុកឱ្យធ្វើបេឡានិច័យ ផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

## ៤- ការរក្សាទុកនូវការកត់ត្រា

សមាជិកទទួល ត្រូវរក្សានូវថាសកុំព្យូទ័រ ឬក្រដាសតារាង និងវត្ថុសំអាងជាក់ស្តែងផ្សេងទៀត ដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសម្រាប់ប្រតិបត្តិការរបស់សភាផាត់ទាត់ សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទទទួល។ សមាជិកទទួល មិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតម្រូវការស្តីពីប្រតិបត្តិការ ដែលកើតមានឡើងបន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់ ។

## ៥- ការបង្វិលវិញនៃមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងករណីមានកំហុស

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា សម្រាប់ការទូទាត់ប្រចាំថ្ងៃ និងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថា មានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារឱ្យសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់នូវមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួនទៅឱ្យធនាគារជាតិនៃកម្ពុជា។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានប័ត្រនោះ ទៅឱ្យសមាជិកដែលប្រគល់ពីដំបូងវិញ។

## ជំពូកទី ៥
## ការទទួលខុសត្រូវរបស់ធនាគារជាតិ នៃកម្ពុជា

**ប្រការ ១៤**.-

ធនាគារជាតិនៃកម្ពុជា គឺជាសមាជិកមួយនៃសភាផាត់ទាត់ ដែលអាចទទួល និងប្រគល់មូលប្បទានប័ត្រដូចគ្នានឹងសមាជិកដទៃសម្រាប់សងឱ្យគេឬទារយកពីគេ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាសំរួលដល់គ្រាផាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួន ដែលបានបើកឱ្យសមាជិកទាំងអស់។

**ប្រការ ១៥**.- **ការរៀបចំគំរូ (Preparation of form)**

អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំនូវគំរូ PPC002 និង PPC003 ដោយឧបករណ៍អេឡិកត្រូនិកដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ៤ ដោយបញ្ចូលក្នុងតារាងកិច្ចការកុំព្យូទ័ររបស់សមាជិក (គំរូ PPC001) ពីថាសដែលបានយកមកក្នុងគ្រាផាត់ទាត់។

**ប្រការ ១៦**.- **ការទូទាត់ (Settlement)**

១- ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗ ដោយការចុះឥណពន្ធ និងចុះឥណទាន គណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រប្រគល់ លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល លើសចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រប្រគល់ គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ។ នៅពេលដែលអ្នកដឹកនាំផាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាផាត់ទាត់មានតុល្យភាពហើយនោះ អ្នកដឹកនាំផាត់ទាត់ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងឬតារាងបោះពុម្ពចេញនៃគំរូ PPC002 របស់សមាជិកនីមួយៗ ទុកជាប្រកាសឥណពន្ធ ឬឥណទានក្នុងគណនីចរន្តរបស់សមាជិកនោះ។ បន្ទាប់មកអ្នកដឹកនាំផាត់ទាត់ត្រូវប្រកាសថាគ្រាផាត់ទាត់ត្រូវបញ្ចប់។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាផាត់ទាត់បានឡើយ។

២- ក្នុងករណីដែលសមាជិកទទួល មានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់ សមាជិកនោះមានរយៈពេល២ម៉ោងដើម្បីសំរបសំរួលមូលនិធិពីធនាគារផ្សេងមួយទៀត ដើម្បីដាក់បញ្ចូលក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា។ នេះគឺជាប្រភពចំបង និងរំពឹងបាននៃមូលនិធិសម្រាប់ការទូទាត់។

**ប្រការ ១៧.- សមតុល្យដែលបានតំកល់នៅធនាគារជាតិនៃកម្ពុជា** (Balance maintained at NBC)

សមាជិកទាំងអស់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធលើគណនីចរន្តរបស់ពួកគេ នូវចំនួនទឹកប្រាក់ដែលជាលទ្ធផលសុទ្ធនៃការផាត់ទាត់មូលប្បទានប័ត្រ និងត្រូវតំកល់មូលនិធិក្នុងគណនីចរន្តទាំងនោះឱ្យមានគ្រប់គ្រាន់ដើម្បីចុះឥណពន្ធ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធនាគារសមាជិកតំកល់ឱ្យបានគ្រប់គ្រាន់នូវប្រាក់បញ្ញើជារូបិយ-ប័ណ្ណក្នុងគណនីផ្សេងដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន។

**ប្រការ ១៨.- ការទូទាត់មិនបាន** (Failure to settle)

១- ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធរបស់ខ្លួន ក្នុងសភាផាត់ទាត់ ក្នុងរយៈពេលអនុញ្ញាត២ម៉ោងនោះទេ អ្នកដឹកនាំផាត់ទាត់នឹងជូនដំណឹងចំពោះប្រធានសភាផាត់ទាត់ដែលនឹងកំណត់នូវវិធានការកែលំអ។ ប្រសិនបើ ធនាគារជាតិនៃកម្ពុជា បានប្រកាសថា សមាជិកនោះ " មានកំហុស (In Default)" ប្រធានសភាផាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត។ គ្រាផាត់ទាត់មិនត្រូវបានប្រកាសបិទទេ លើកលែងតែគណនីទាំងអស់ត្រូវបានចុះឥណពន្ធជាស្ថាពរនៅថ្ងៃផាត់ទាត់នោះ។

២- ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺចុះបញ្ច្រាសនូវឥណទានដែលបានផ្តល់ឱ្យធនាគារទទួលចំពោះមូលប្បទានប័ត្ររបស់ខ្លួនដែលយកទៅឱ្យសភាផាត់ទាត់ និងចុះបញ្ច្រាសនូវឥណពន្ធចំពោះមូលប្បទានប័ត្រដែលបានយកដោយធនាគារដទៃ ហើយគណនាជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាមនោះ។ អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំគំរូជាថ្មី ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់។ ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការផាត់ទាត់ទៀតឡើយ។

**ប្រការ ១៩.- ព្រំដែននៃការទទួលខុសត្រូវ** (Limit of liability)

ធនាគារជាតិនៃកម្ពុជា មិនទទួលខុសត្រូវ និងមិនទទួលសងឡើយ ក្នុងករណីដែលសមាជិកមានការខាតបង់ក្នុងទំនាក់ទំនងជាមួយសមាជិកសភាផាត់ទាត់ លើកលែងក្នុងករណីនៃការធ្វេសប្រហែសនិងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់។ ការតវ៉ាទាំងអស់អំពីការបែងចែកមិនត្រឹមត្រូវការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានប័ត្រ កំហុសរបស់សមាជិក ។ល។ ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់

លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ជីរបស់ធនាគារជាតិនៃកម្ពុជាដើម្បីកត់ត្រាប្រតិបត្តិការ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារ និងលក្ខខណ្ឌនៃបទបញ្ញាសម្រាប់មូលប្បទានប័ត្ររបស់ខ្លួនផ្ទាល់ ដែលបានបញ្ចូលដើម្បីជាត់ទាត់ និងទូទាត់តាមរបៀបដូចគ្នានឹងសមាជិកដទៃទៀត។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ២០.- ច្បាប់សម្រាប់គ្រប់គ្រង (Governing Law)**

ប្រតិបត្តិការដែលឋិតនៅក្រោមបទបញ្ញានេះ ត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញាផ្សេងៗទៀតរបស់ធនាគារជាតិនៃកម្ពុជា ដែលបានផ្សព្វផ្សាយឱ្យអនុវត្តនូវគ្រប់ករណី។

**ប្រការ ២១.- លក្ខខណ្ឌភាពអាសន្ន (Emergency Conditions)**

ការដឹកនាំប្រតិបត្តិការជាត់ទាត់ប្រចាំថ្ងៃអាចត្រូវពន្យារពេលពេញមួយថ្ងៃធ្វើការ ឬ អាចត្រូវលើកទៅថ្ងៃបន្ទាប់ ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបាន ដោយសារតែមានភាពអាសន្ន ដូចជា អាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ ការចលាចលធំៗក្នុងទីក្រុង ឬក្នុងប្រទេស។ ក្នុងកាលៈទេសៈនេះ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការណែនាំជាក់លាក់ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសម្រាប់អនុវត្តក្នុងការជាត់ទាត់ ឬត្រូវបង្វិលវិញ។ ទោះយ៉ាងណាក្តី សមាជិកនីមួយៗ គួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួន ចំពោះការរំខាននោះ និងត្រូវទទួលខុសត្រូវក្នុងការរក្សាគំរោងការ និងទីកន្លែងដំណើរការដោយមានសំភារៈបរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសម្រាប់រយៈពេលបន្ទាប់ៗ។

**ប្រការ ២២.- អំពីស្ថិតិ (Statistics)**

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រង និងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានជាត់ទាត់ប្រចាំថ្ងៃពេញមួយខែ ដោយបញ្ចូលព័ត៌មាន ស្តីពីមូលប្បទានប័ត្របង្វិលវិញ (មូលប្បទានប័ត្រមិនទូទាត់)។ លំដាប់លំដោយនៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសម្រាប់ឆ្នាំនេះ និងឆ្នាំមុន។ ព័ត៌មានស្តីពីការជាត់ទាត់របស់ធនាគារសមាជិកនីមួយៗ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ លើកលែងតែចំពោះធនាគារសាមី។

**ប្រការ ២៣.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងធនាគារជាសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជារៀល ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ២៥**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ ១-ក**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

---------------------------

**ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់**

----------------------

ឈ្មោះអ្នកសុំ: .......................................................................................................................

ឋានៈ : .......................................................................................................................

អាសយដ្ឋានៈ .......................................................................................................................

អាសយដ្ឋានប្រៃសណីយ៍: ...........................................................................................

ទូរស័ព្ទ: .......................................................................................................................

**ជូនចំពោះ លោកប្រធានសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល**

ក្រោយពីបានស្វែងយល់ ប្រកាសស្តីពី សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល លេខ........ ចុះថ្ងៃទី........ខែ..........ឆ្នាំ...........និងដើម្បីសំរួលដល់ការប្រើប្រាស់មូលប្បទានប័ត្ររវាងធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ

យើងខ្ញុំសុំស្នើលោកប្រធានសភាផាត់ទាត់ មេត្តាពិនិត្យនិងសំរេចឱ្យធនាគារយើងខ្ញុំបានចូលជា សមាជិកនៃសភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល ដោយអនុគ្រោះ។

សូមជូនភ្ជាប់ជាមួយនូវៈ

- ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណធ្វើអាជីវកម្មធនាគារ ១ច្បាប់
- លិខិតឧទ្ទេសនាម និងគំរូហត្ថលេខា ៣ច្បាប់

យើងខ្ញុំសន្យាថា នឹងគោរព អនុវត្តនូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ភ្នំពេញ, ថ្ងៃទី .......... ខែ ......... ឆ្នាំ ២០០

ហត្ថលេខា

**ឧបសម្ព័ន្ធ ២**

## សមាជិកទាក់ទាញមូលប្បទានប័ត្រចារឹកជាប្រាក់រៀល

| លេខរៀង | ឈ្មោះធនាគារ | អក្សរសម្គាល់ | លេខអត្តសញ្ញាណ |
|---|---|---|---|
| ១ | ធនាគារជាតិនៃកម្ពុជា | NBC | |
| ២ | រតនាគារជាតិ | NTG | T001 |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | FTB | B001 |
| ៤ | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | CCB | B003 |
| ៥ | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | CPB | B004 |
| ៦ | ធនាគារ កាណាឌីយ៉ា | CNB | B005 |
| ៧ | ធនាគារ ក្រុងថៃ | KTB | B009 |
| ៨ | ធនាគារ កសិករថៃ | TFB | B012 |
| ៩ | ធនាគារ ក្រេឌីតអាហ្រ្គីកូលឥណ្ឌូស៊ុយអេស៍ | CAI | B013 |
| ១០ | ធនាគារ កម្ពុជាអាស៊ី | CAB | B016 |
| ១១ | សាជីវកម្មធនាគារសឹង្ហបូរី | SBC | B018 |
| ១២ | ធនាគារ មេយប៊ែង | MBB | B020 |
| ១៣ | ធនាគារ សឹង្ហបូរីពាណិជ្ជ | SCB | B021 |
| ១៤ | ធនាគារ ស្តាន់ដារឆាទើរ៉ែត | SCB1 | B025 |
| ១៥ | ធនាគារ សហពាណិជ្ជ | UCB | B026 |
| ១៦ | ធនាគារ ក្រៅប្រទេសទី១ | FOB | B031 |

**<u>ឧបសម្ព័ន្ធ ៣</u>**

## មូលហេតុដែលបានព្រមព្រៀងសម្រាប់ការបង្វិលវិញនូវមូលប្បទានប័ត្រ

១- សំវិធានវត្ថុគ្មាន ឬមិនគ្រប់គ្រាន់

២- សំវិធានវត្ថុមិនទាន់បានជម្រះ

៣- បញ្ឈប់ការទូទាត់

៤- បុរេបរិច្ឆេទ និងកាលបរិច្ឆេទមិនត្រឹមត្រូវ

៥- ហួសកាលបរិច្ឆេទ (លើសពី ៦ខែ)

៦- ចំនួនទឹកប្រាក់ជាអក្សរ និងជាលេខខុសគ្នា

៧- ខ្វះចំនួនទឹកប្រាក់ជាអក្សរ

៨- ហត្ថលេខារបស់បរហារកខុសពីគំរូហត្ថលេខា

៩- ខ្វះហត្ថលេខារបស់បហារក

១០- ខ្វះហត្ថលេខារបស់បហារកចំពោះការផ្លាស់ប្តូរ

១១- មិនចេញផ្សាយតាមគំរូធនាគារ

១២- មូលប្បទានប័ត្រខ្វេចខ្ទី

១៣- គណនីត្រូវបានបិទ

១៤- គ្មានគណនី

១៥- បហារកទទួលមរណភាព

១៦- បហារកធនក្ស័យ ត្រូវជម្រះបញ្ជី

<u>ឧបសម្ព័ន្ធ ៤</u>

**គំរូ PPC001 : កត់ត្រាមូលប្បទានប័ត្ររបស់ធនាគារនីមួយៗប្រគល់ឱ្យសភាផាត់ទាត់**

**សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល**

មូលប្បទានប័ត្រប្រគល់ដោយធនាគារ.................................ចំពោះធនាគារ...........................................

ថ្ងៃទី ..............................................

| | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|---|---|---|
| 1 | | | 35 | | |
| 2 | | | 36 | | |
| 3 | | | 37 | | |
| 4 | | | 38 | | |
| 5 | | | 39 | | |
| 6 | | | 40 | | |
| 7 | | | 41 | | |
| 8 | | | 42 | | |
| 9 | | | 43 | | |
| 10 | | | 44 | | |
| 11 | | | 45 | | |
| 12 | | | 46 | | |
| 13 | | | 47 | | |
| 14 | | | 48 | | |
| 15 | | | 49 | | |
| 16 | | | 50 | | |
| 17 | | | 51 | | |
| 18 | | | 52 | | |
| 19 | | | 53 | | |
| 20 | | | 54 | | |
| 21 | | | បូកសរុបមូលប្បទានប័ត្រថ្មី | | |
| 22 | | | | | |
| 23 | | | មូលប្បទានប័ត្របង្វិលវិញ | | |
| 24 | | | | | |
| 25 | | | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
| 26 | | | | | |
| 27 | | | 1 | | |
| 28 | | | 2 | | |
| 29 | | | 3 | | |
| 30 | | | 4 | | |
| 31 | | | 5 | | |
| 32 | | | 6 | | |
| 33 | | | 7 | | |
| 34 | | | 8 | | |
| | សរុប: | | សរុបមូលប្បទានប័ត្របង្វិលវិញ | | |
| | | សរុបមូលប្បទានប័ត្រថ្មីនិងមូលប្បទានប័ត្របង្វិលវិញ | | | |

សម្រាប់ប្រើប្រាស់ក្នុងសភាផាត់ទាត់

ហត្ថលេខា...................

**គំរូPPC002 : កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានប័ត្របានប្រគល់ឱ្យសភាផាត់ទាត់**

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

មូលប្បទានប័ត្រប្រគល់ដោយ ................................... ″ ឈ្មោះធនាគារ ″ ឥណពន្ធគណនី: .........

នៅ ..................″ ម៉ោង ″ នាគ្រាផាត់ទាត់ .............................. ″ កាលបរិច្ឆេទ″ ឥណទានគណនី: .........

| ល.រ | លេខសម្គាល់ ធនាគារ | ធនាគារ | មូលប្បទានប័ត្រប្រគល់ "សំវិធានវត្ថុត្រូវទទួល" | ចំនួន | មូលប្បទានប័ត្រទទួល "សំវិធានវត្ថុត្រូវសងធនាគារដទៃ" | ចំនួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុបៈ | | | | | | | |

ហត្ថលេខា .....................″ធនាគារប្រគល់ ឬទទួល″

ហត្ថលេខា .....................″ធនាគារជាតិនៃកម្ពុជា″

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

### សំរង់មូលប្បទានប័ត្រចារឹកជារៀលមិនអាចទូទាត់បាន

មូលប្បទានប័ត្រនៃគ្រាផាត់ទាត់ ថ្ងៃទី ................................................

ពីធនាគារ ........................................................................................

ចំពោះធនាគារ .................................................................................

សម្រាប់គ្រាផាត់ទាត់ថ្ងៃទី ..........................................................................

| លេខរៀង | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|
| | | |
| **សរុបៈ** | | |

មូលប្បទានប័ត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPC001 នៃគ្រាផាត់ទាត់ថ្ងៃទី ....................

សម្រាប់មូលប្បទានប័ត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ ។

ហត្ថលេខា "ធនាគារប្រគល់" ....................

ហត្ថលេខា "ធនាគារទទួល" .....................

គំរូPPC003 : កត់ត្រានូវលទ្ធផលផាត់ទាត់សរុបតាមធនាគារនីមួយៗ

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

នៅ ...................." ម៉ោង " នាគ្រាផាត់ទាត់ .............................. " កាលបរិច្ឆេទ"

| ល.រ | លេខសម្គាល់ធនាគារ | ធនាគារ | "សំវិធានវត្ថុត្រូវសងធនាគារដទៃ" | ចំនួន | "សំវិធានវត្ថុត្រូវទទួលពីធនាគារដទៃ" | ចំនួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុប: | | | | | | | |

ហត្ថលេខា ......................"ធនាគារជាតិនៃកម្ពុជា"

ធ៥-០៣-០១៦ ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្ទេរទៅ-មក ខេត្ត-ក្រុង និងការកំណត់កំរៃសេវា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជំរាបជូនដំណឹងដល់អតិថិជនដែលមានបើកគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា និងតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងជ្រាបថា ធនាគារជាតិនៃកម្ពុជាផ្តល់សេវាផ្ទេរប្រាក់ទៅ-មកខេត្តក្រុង តាមរយៈនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងចាប់ពីពេលជូនដំណឹងនេះតទៅ។

## I. អតិថិជនដែលទទួលបាននូវការផ្តល់សេវា

១- <u>ផ្ទេរប្រាក់ពីធនាគារជាតិនៃកម្ពុជាទៅសាខាធនាគារជាតិខេត្ត-ក្រុង:</u>

- ក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបើកគណនីនៅនាយកដ្ឋាន ប្រតិបត្តិការ

២- <u>ផ្ទេរប្រាក់ពីសាខាធនាគារខេត្ត-ក្រុងមកធនាគារជាតិនៃកម្ពុជា</u>

- រតនាគារខេត្ត-ក្រុង
- មន្ទីរស្ថាប័នខេត្ត-ក្រុងកំពង់ផែ អគ្គិសនី រដ្ឋាករទឹក
- សាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គម
- អាជីវករប្តូរប្រាក់ និង លោហធាតុមានតម្លៃដែលមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

## II. បែបបទផ្ទេរប្រាក់

អតិថិជនត្រូវបំពេញនូវបញ្ជាផ្ទេរប្រាក់តាមគំរូលេខ ១១ ចំពោះអតិថិជនជានីតិបុគ្គល ឬតាមគំរូលេខ ១២ ចំពោះ អតិថិជនជាឯកត្តជន ដោយភ្ជាប់ជាមួយនូវមូលប្បទានប័ត្រដកប្រាក់ពីគណនីរបស់ខ្លួន។ (សូមភ្ជាប់ជាមួយនេះនូវគំរូលេខ ១១ និងគំរូលេខ ១២)

## III. កំរៃសេវា

- កំរៃសេវាត្រូវគិតលើចំនួនប្រាក់ផ្ទេរ ០.១០% (ជាប្រាក់រៀល ឬប្រាក់ដុល្លាររអាមេរិក)
- កំរិតអប្បបរមា ១២.០០០រៀល ឬ ៣ ដុល្លារ ក្នុងប្រតិបត្តិការផ្ទេរប្រាក់១លើក ការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនគិតកំរៃសេវាទេ។

កំរៃសេវាត្រូវបានគិតយកពីអតិថិជននៅធនាគារផ្តើមប្រតិបត្តិការ ហើយអតិថិជនមិនមានការចំណាយកំរៃសេវានៅពេលទទួលប្រាក់ទៀតឡើយ។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៣

**អគ្គនាយក**

ហត្ថលេខានិងត្រា: **គាល់ ណៃអ៊ីម**

គំរូលេខ១១

ថ្ងៃទី ខែ ឆ្នាំ

....... ............Date.................

**បញ្ជាផ្ទេរប្រាក់**

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO: Manager of the National Bank of Cambodia

**ខេត្ត-ក្រុង**

Branch..................................

- អង្គភាព/ ស្ថាប័ន/ គ្រឹះស្ថាន:

  Equity/ Institution

:.........................................................................................................

- អ្នកដែលទទួលសិទ្ធិ:

  Authorized Person:....................................................................................................

- យោងលិខិតផ្ទេរសិទ្ធិលេខ ចុះថ្ងៃទី

  Reference the Proxy No............................Date.......................................................

- ចំនួនប្រាក់:

  Amount ...................................................................................................................

- អ្នកទទួលប្រាក់:

  Beneficiary Name....................................................................................................

- លេខគណនី:

  Account Number.......................................................................................................

- ធនាគារអ្នកទទួលប្រាក់ :

  Beneficiary Bank.....................................................................................................

- អាសយដ្ឋាន

  Address of Beneficiary Bank....................................................................................

- បញ្ជាពិសេស : សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ

  ដែលបានបើកនៅធនាគារលោក/ លោកស្រី

  Special Instruction : please debit our account n.....................................................

  opened with your bank.

**ហត្ថលេខា**

Signature

គំរូលេខ១២

ថ្ងៃទី ខែ ឆ្នាំ

...... ............Date.................

# បញ្ជាផ្ទេរប្រាក់

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO: Manager of the National Bank of Cambodia

**ខេត្ត-ក្រុង**

Branch.................................

- អ្នកផ្ទេរប្រាក់ :
  Name of transferor ...........................................................................................
- អាសយដ្ឋាន :
  Address.......................................................................................................
- អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន :
  ID Card or Passport No.......................................................................................
- ចំនួនប្រាក់:
  Amount.......................................................................................................
- អ្នកទទួលប្រាក់ :
  Beneficiary Name............................................................................................
- លេខគណនី :
  Account Number..............................................................................................
- ធនាគារអ្នកទទួលប្រាក់ :
  Beneficiary Bank.............................................................................................
- បញ្ជាពិសេស : សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក / លោកស្រី
  Special Instruction: please debit our account n........................................................
opened with your bank

**ហត្ថលេខា**

Signature

ធ៩-០៦-២៣៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់

**ប្រការ ១**.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា២ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួនដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេងពីនេះ៖

**១.ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង** សំដៅដល់ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនៅក្រោមប្រកាសនេះ។

**២. សេចក្តីណែនាំ** សំដៅដល់ខ្លឹមសារនៃបញ្ជាទូទាត់។

**៣.អ្នកចាត់ការ** រួមមានសមាជិកនៃក្រុមប្រឹក្សាភិបាល និងសំដៅដល់បុគ្គលមួយចំនួនដែលធនាគារជាតិនៃកម្ពុជាយល់ថាស្ថិតក្នុងឋានៈជាអ្នកត្រួតពិនិត្យហើយដែលទទួលខុសត្រូវលើការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់អ្នកផ្តល់សេវា។ សេចក្តីជូនដំណឹងនៅក្រោមប្រការនេះត្រូវបានផ្តល់ឱ្យអ្នកចាត់ការ ដូចដែលអ្នកផ្តល់សេវាបានជូនដំណឹងចំពោះធនាគារជាតិនៃកម្ពុជា លើកលែងតែធនាគារជាតិនៃកម្ពុជាបានចាត់តាំងជាក់លាក់នូវបុគ្គលមួយផ្សេងទៀតថាជាអ្នកចាត់ការ។

**៤.តម្លៃរូបិយវត្ថុ** សំដៅដល់មធ្យោបាយដោះដូរ ទោះបីជាអាចប្តូរជាប្រាក់ឬមិនអាចក្តី រួមទាំងក្រោមរូបភាពជាតម្លៃសន្សំ ជាឧបករណ៍ទូទាត់សងប្រាក់ ឬជាការចុះឥណទានចូលក្នុងគណនីផងដែរ។

**៥. រូបិយវត្ថុ** សំដៅដល់ឯកតារូបិយវត្ថុ ឬមធ្យោបាយដោះដូរដែលត្រូវបានចេញផ្សាយ បង្កើតឡើង អនុញ្ញាត ឬអនុម័តដោយប្រទេសកម្ពុជា ឬរដ្ឋាភិបាលបរទេស។ ពាក្យនេះរួមបញ្ចូលទាំងឯកតារូបិយវត្ថុ ឬមធ្យោបាយដោះដូរដែលបានចេញផ្សាយ បង្កើតឡើង អនុញ្ញាត ឬអនុម័ត ដោយអង្គការអន្តររដ្ឋាភិបាល ឬដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលពីរ ឬច្រើនផងដែរ។

**៦.ការបញ្ជូនប្រាក់** សំដៅដល់ការលក់ ឬចេញផ្សាយតម្លៃរូបិយវត្ថុ ឬការទទួលប្រាក់ ឬតម្លៃរូបិយវត្ថុពាក់ព័ន្ធនឹងការបញ្ចូលប្រាក់ ឬតម្លៃរូបិយវត្ថុ ទោះបីពីអ្នកបញ្ជូន ឬសម្រាប់អត្ថគាហកក្តី ហើយរួមទាំងការផ្តល់សេវាកម្មសម្រាប់ការដកប្រាក់ ការផ្ទេរតម្លៃរូបិយវត្ថុរវាងគណនី ឬសម្រាប់ការទូទាត់សងតម្លៃរូបិយវត្ថុភាគីទីបីផងដែរ។ ពាក្យនេះរួមបញ្ចូលទាំងការចូលរួមក្នុងប្រតិបត្តិការ ឬកិច្ចសម្របសម្រួលពាក់ពន្ធ័នឹងការអនុវត្ត ការបញ្ជូនប្រាក់ពីអ្នកបញ្ជូនទៅអត្ថគាហក ទោះបីជាអ្នកបញ្ជូន ឬអត្ថគាហកនោះពុំមែនជាភាគី ឬអ្នកចូលរួមផ្ទាល់ នៅក្នុងប្រតិបត្តិការនោះក្តី។ ការបញ្ជូន

ប្រាក់អាចធ្វើឡើងពីកន្លែងមួយទៅកន្លែងមួយនៅក្នុង ទៅកាន់ឬចេញពីប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត។

**៧.អ្នកចូលរួម** សំដៅដល់ភាគីមួយនៃកិច្ចសម្របសម្រួលពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់។ បុគ្គលនោះអាចជាធនាគារ ជាអ្នកផ្តល់សេវាបញ្ញូលប្រាក់ឬបុគ្គលដទៃផ្សេងទៀត តែមិនរួមបញ្ចូលអ្នកប្រើប្រាស់ ឬអតិថិជនរបស់អ្នកចូលរួម ដែលជាអ្នកចេញបញ្ជា ឬទទួលការទូទាត់សងប្រាក់តាមរយៈប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ឡើយ។

**៨. ប័ណ្ណទូទាត់សងប្រាក់** សំដៅដល់ប័ណ្ណ សន្លឹកប័ណ្ណ សៀវភៅគូប៉ុង ឬឧបករណ៍ផ្សេងទៀត ដែលរួមមានទាំងលេខកូដ ឬមធ្យោបាយផ្សេងទៀតសម្រាប់ចូលរួមទៅប្រើប្រាស់គណនី ឬតម្លៃសន្សំដែលអាចត្រូវបានប្រើប្រាស់ពីពេលមួយទៅពេលមួយ ដើម្បីទទួលបានប្រាក់ ឬធ្វើការទូទាត់សងប្រាក់ហើយរួមបញ្ចូលទាំងប័ណ្ណឥណពន្ធ កំរៃ ប័ណ្ណឥណទាន និងប័ណ្ណនៃតម្លៃផងដែរ។

**៩. ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់** សំដៅដល់ប្រព័ន្ធ ឬកិច្ចសម្របសម្រួលសម្រាប់ទំនាក់ទំនងដំណើរការ ការប្តូរ ការផាត់ទាត់ឬទូទាត់ នូវបញ្ជាទូទាត់និងសារផ្សេងៗដែលជះឥទ្ធិពលបញ្ជា បង្កលក្ខណៈ ឬសំរួលដល់ការទូទាត់សងប្រាក់ ការបញ្ចូនប្រាក់ ការដកប្រាក់ ឬការផ្ទេរតម្លៃរូបិយវត្ថុ។

**១០. វិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់** សំដៅដល់វិធាន ដែលទោះជាមានឈ្មោះដូចម្តេចក្តីក្រៅពីវិធានចេញដោយធនាគារជាតិនៃកម្ពុជា គឺជាវិធានដែលគ្រប់គ្រងលើប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ រួមទាំងប្រតិបត្តិការ ការផាត់ទាត់ និងការទូទាត់នៃប្រព័ន្ធនោះផងដែរ។ វិធាននោះរួមបញ្ចូលទាំងវិសោធនកម្ម ឬការលុបចោលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ផងដែរ។

**១១.ឧបករណ៍ទូទាត់សងប្រាក់** សំដៅដល់មូលប្បទានប័ត្រ រូបិយាណត្តិ អាណត្តិផ្ទេរប្រាក់ មូលប្បទានប័ត្រទេសចរណ៍ ប័ណ្ណទូទាត់សងប្រាក់ ឬឧបករណ៍ផ្សេងទៀត សម្រាប់ការបញ្ចូន ឬការទូទាត់សងប្រាក់ ឬតម្លៃរូបិយវត្ថុ ដែលអាចជួញដូរបាន ឬមិនបានក្តី។ ពាក្យនេះមិនរួមបញ្ចូលវិក័យប័ត្រ ប័ណ្ណឥណទាន លិខិតឥណទាន ឬឧបករណ៍ដែលអាចសងវិញ ដោយអ្នកចេញផ្សាយជាទំនិញ ឬសេវាទេ។

**១២.បុគ្គល** សំដៅដល់ឯកត្តជន សាជីវកម្ម ឯកាធិកម្មអាជីវកម្ម ក្រុមហ៊ុនអចលនទ្រព្យ មូលនិធិរួមភាពជាដៃគូ ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត សមាគម សម្ព័ន្ធសាជីវកម្ម រដ្ឋាភិបាល អង្គភាពណាមួយនៃរដ្ឋាភិបាល ទីភ្នាក់ងារ ឬអង្គភាពសាជីវកម្មសាធារណៈ ឬស្ថាប័នសាធារណៈណាមួយក្រុមហ៊ុនឯកជន ឬអង្គភាពពាណិជ្ជកម្ម ការិយាល័យ ឬអង្គភាពដែលមាន ឬគ្មានភាពជានីតិបុគ្គលដោយឡែក។

**១៣.កំណត់ត្រា** សំដៅដល់ព័ត៌មាន ដែលបានកត់ត្រាលើមធ្យោបាយរូបិយ ឬដែលត្រូវបានរក្សាទុកក្នុងមធ្យោបាយអេឡិកត្រូនិក ឬមធ្យោបាយផ្សេងទៀត ហើយដែលអាចយកមកប្រើបានក្នុងទម្រង់ជាក់ស្តែង។

**១៤.អ្នកផ្តល់សេវា** សំដៅដល់បុគ្គលដែលដំណើរការ ឬចូលរួមនៅក្នុងប្រតិបត្តិការប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់។

**១៥. តម្លៃសន្សំ** សំដៅដល់តម្លៃរូបិយវត្ថុដែលបង្ហាញភស្តុតាងតាមកំណត់ត្រាអេឡិកត្រូនិក។

**ប្រការ ២.-**

១. ធនាគារជាតិនៃកម្ពុជាអាចចេញវិធានដើម្បីៈ

ក. កំណត់លក្ខខណ្ឌ កាតព្វកិច្ច និងស្តង់ដារដែលនៅក្រោមនោះប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់អាចនឹងត្រូវបានដំណើរការ និងបានចាត់តាំង

**ប្រការ ៣.-**

១.ប្រសិនបើមានការយល់ថាជាផលប្រយោជន៍សាធារណៈក្នុងការធ្វើដូច្នេះ ធនាគារជាតិនៃកម្ពុជាអាចចាត់តាំងឱ្យមានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់មួយឱ្យនៅក្រោមបទប្បញ្ញត្តិ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តនៅក្រោមប្រកាសនេះ។

២.ដើម្បីកំណត់ថា តើការចាត់តាំងឱ្យមានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ជាផលប្រយោជន៍សាធារណៈ ឬយ៉ាងណា គប្បីត្រូវពិចារណាលើកត្តាមួយចំនួនដូចខាងក្រោម

ក. កំរិតសុវត្ថិភាពហិរញ្ញវត្ថុដែលប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ផ្តល់ចំពោះអ្នកចូលរួម និងអ្នកប្រើប្រាស់

ខ.ប្រសិទ្ធភាពនិងការប្រកួតប្រជែងនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ក្នុងប្រទេសកម្ពុជា និង

គ. ផលប្រយោជន៍ខ្ពស់បំផុតរបស់អ្នកចូលរួមនិងអតិថិជននៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ឬនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។

៣.មុននឹងធ្វើការចាត់តាំងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាត្រូវពិភាក្សាជាមួយអ្នកចាត់ការ និងអ្នកចូលរួមក្នុងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ក៏ដូចជាអាចពិភាក្សាជាមួយភាគី មានចំណាប់អារម្មណ៍ដទៃទៀតអំពីផលប៉ះពាល់នៃការចាត់តាំងនោះ។

៤.ធនាគារជាតិនៃកម្ពុជាត្រូវផ្តល់ដំណឹងដល់អ្នកចាត់ការ និងអ្នកចូលរួមអំពីប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ដែលបានចាត់តាំងតាមវិធីណាក្តីដែលខ្លួនគិតថាសមស្រប។

៥. ការចាត់តាំងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

**ប្រការ៤.-**

១.ច្បាប់ចម្លងនៃរាល់វិធានប្រព័ន្ធផាត់ទាត់នៃការសងប្រាក់ ដែលគ្រប់គ្រងលើប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង នឹងត្រូវបានផ្តល់ដោយអ្នកចាត់ការប្រព័ន្ធផាត់ទាត់នៃការទូទាត់

សងប្រាក់នោះឬបើគ្មានអ្នកចាត់ការទេ ច្បាប់ចម្លងនេះនឹងត្រូវបានផ្តល់ដោយអ្នកចូលរួមទៅឱ្យធនាគារជាតិនៃកម្ពុជា។

ក.ក្នុងករណីដែលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវបានធ្វើឡើងមុនការចាត់តាំងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ វិធាននេះត្រូវផ្តល់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការចាត់តាំង និង

ខ.ក្នុងករណីដែលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ត្រូវបានធ្វើឡើងក្រោយការចាត់តាំងប្រព័ន្ធផាត់ទាត់ នៃការទូទាត់សងប្រាក់ ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយការបង្កើតវិធាននោះ។

២.វិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ក្រៅពីវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលមានចែងក្នុងកថាខណ្ឌទី១ក មិនចូលជាធរមានមុនរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានផ្តល់ច្បាប់ចម្លងវិធាននេះជូនធនាគារជាតិនៃកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ទេ ប៉ុន្តែធនាគារជាតិនៃកម្ពុជាអាចប្រកាសឱ្យប្រធាននោះចូលជាធរមាននៅពេលណាក៏បានមុនពេលផុតរយៈពេលកំណត់។

៣.បើធនាគារជាតិនៃកម្ពុជាយល់ថាការពន្យាររយៈពេលកំណត់ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី២ជាការចាំបាច់ដើម្បីអាចពិនិត្យឡើងវិញឱ្យបានសមស្របនូវវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ក្នុងរវាង ១០ថ្ងៃ បន្ទាប់ពីបានទទួលវិធាននោះ តាមការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកផ្ញើវិធាននោះ ធនាគារជាតិនៃកម្ពុជាអាចពន្យារពេលកំណត់រហូតដល់ ៣០ថ្ងៃ។

៤.ធនាគារជាតិនៃកម្ពុជា អាចមិនអនុញ្ញាតទាំងស្រុង ឬលើផ្នែកណាមួយនៃវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលគ្រប់គ្រងលើប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនៅមុន ឬនៅពេលណាមួយ ក្រោយវិធាននេះចូលជាធរមាន ឬកំពុងនៅជាធរមាន។ វិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលកំពុងមានសុពលភាព តែមិនត្រូវបានអនុញ្ញាតវិញ និងត្រូវបាត់បង់សុពលភាពចាប់ពីពេលដែលសេចក្តីសំរេចពីការមិនអនុញ្ញាតនោះត្រូវបានជូនដំណឹងទៅអ្នកចាត់ការប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ដែលបានចាត់តាំងនោះ ឬនៅពេលណាមួយក្រោយមកទៀត ដូចដែលធនាគារជាតិនៃកម្ពុជាបានណែនាំនៅក្នុងសេចក្តីសំរេចរបស់ខ្លួនអំពីការមិនអនុញ្ញាតនូវវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់នោះ។

៥.ពេលណាដែលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលកំពុងមានសុពលភាព មិនត្រូវបានអនុញ្ញាតឱ្យអនុវត្តទាំងស្រុង ឬមួយផ្នែកពីធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌទី៤ ដែលនាំឱ្យមានការចាំបាច់ត្រូវធ្វើវិសោធនកម្ម ឬធ្វើការជំនួសឡើងវិញនូវប្រធានផាត់ទាត់នៃ ការទូទាត់សងប្រាក់ ដើម្បីសម្រួលដល់ប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងឱ្យមានភាពរលូនបន្តទៀត សេចក្តីសំរេចរបស់ធនាគារជាតិនៃកម្ពុជាអំពីការមិនអនុញ្ញាតឱ្យអនុវត្តវិធាននេះ ចាំបាច់ត្រូវដាក់បញ្ចូលក្នុងសេចក្តីណែនាំដែលចេញផ្សាយអនុលោមតាមប្រការ៥ ដែលណែនាំចំពោះអ្នកចាត់ការនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ដែលបាន

ចាត់តាំងនោះ និងថែមទាំងផ្តល់នូវអត្ថបទវិធានសម្រាប់ប្រព័ន្ធនៃការទូទាត់សងប្រាក់បណ្តោះអាសន្ន ដែលត្រូវអនុវត្តរហូតដល់វិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវធ្វើវិសោធនកម្ម ឬ ជំនួសត្រូវបានអនុម័តដោយប្រព័ន្ធនោះ។ វិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់បណ្តោះអាសន្ន ត្រូវចូលជាធរមានភ្លាមនៅពេលដែលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវ ធ្វើវិសោធនកម្ម ឬត្រូវបានជំនួសអស់សុពលភាព។

៦.ធនាគារជាតិនៃកម្ពុជា អាចធ្វើការលើកលែងប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់ តាំងនោះអនុលោមតាមកថាខណ្ឌទី ២។

**ប្រការ ៥**.-

១.ធនាគារជាតិនៃកម្ពុជាអាចចេញផ្សាយសេចក្តីណែនាំទៅកាន់អ្នកចាត់ការ ឬអ្នកចូលរួមនៃប្រព័ន្ធ ផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងដូចខាងក្រោម៖

ក. លក្ខខណ្ឌទាំងឡាយដែលបុគ្គលម្នាក់ចាំបាច់ត្រូវបំពេញដើម្បីប្រើប្រាស់ឬក្លាយជាអ្នកចូលរួមក្នុង ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង។

ខ.ប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់រួមមានការផាត់ទាត់ និងការទូទាត់នៃប្រព័ន្ធ នោះ។

គ. អន្តរកម្មនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់នោះជាមួយប្រព័ន្ធផាត់ទាត់នៃការទូទាត់សង ប្រាក់ផ្សេងទៀត។

ឃ. ទំនាក់ទំនងនៃប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ជាមួយអ្នកចូលរួមរបស់ខ្លួន។

២. មុននឹងផ្តល់សេចក្តីណែនាំ ធនាគារជាតិនៃកម្ពុជាត្រូវពិគ្រោះជាមួយបុគ្គលដែលត្រូវទទួលសេចក្តី ណែនាំនោះ ហើយក៏អាចពិគ្រោះជាមួយភាគីមានចំណាប់អារម្មណ៍ផ្សេងទៀតដែរ អំពីខ្លឹមសារ និងផលប៉ះពាល់នៃសេចក្តីណែនាំនោះ។

៣. ធនាគារជាតិនៃកម្ពុជាអាចបញ្ជាក់ក្នុងសេចក្តីណែនាំថា ក្នុងអំឡុងពេលដែលធនាគារជាតិនៃកម្ពុជា យល់ថាចាំបាច់ អ្នកចាត់ការ និងអ្នកចូលរួមប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់នោះត្រូវ

ក. បញ្ឈប់ ឬផ្អាកសកម្មភាព ឬការប្រព្រឹត្ត

ខ.ធ្វើសកម្មភាពទាំងនោះដែលធនាគារជាតិនៃកម្ពុជាយល់ថាជាការចាំបាច់សម្រាប់បម្រើឱ្យផល ប្រ-យោជន៍សាធារណៈ ឬ

គ. បង្កើត ធ្វើវិសោធនកម្ម ឬលុបចោលវិធានប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់។

៤. ក្នុងពេលយ៉ាងឆាប់តាមតែអាចទៅបាន ក្រោយពីការអនុវត្តសេចក្តីណែនាំ និងបំពេញរាល់សកម្ម ភាពដែលបានតម្រូវក្នុងទំនាក់ទំនងជាមួយសេចក្តីណែនាំនោះ បុគ្គលដែលបានទទួលការណែនាំ ត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជាថា បញ្ជាណែនាំត្រូវបានអនុវត្តនិងបានបំពេញសកម្មភាព រួចរាល់ហើយ។

៥. សេចក្តីណែនាំត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

៦. សេចក្តីណែនាំ គឺជាចំណងកាតព្វកិច្ចចំពោះបុគ្គលដែលស្ថិតនៅក្រោមសេចក្តីណែនាំនោះ។

**ប្រការ ៦**.-

១.ធនាគារជាតិនៃកម្ពុជាអាចធ្វើសវនកម្ម អធិការកិច្ច និងតម្រូវឱ្យបង្ហាញនូវគណនី កំណត់ត្រា បញ្ជី និងឯកសារនានា ធ្វើការពិនិត្យតាមការិយាល័យ និងស្នើសុំព័ត៌មានពីបុគ្គលណាដែលធនាគារជាតិនៃកម្ពុជាមានបំណងកំណត់ ទោះជាបុគ្គលនោះធ្វើប្រតិបត្តិការប្រព័ន្ធជាត់ទាត់សងប្រាក់ដែលត្រូវលើកយកមកពិចារណាសម្រាប់ការចាត់តាំងដែលមានចែងក្នុងប្រការនេះ។

២.បុគ្គល និងនិយោជិត ភ្នាក់ងារ ឬអ្នកចាត់ការរបស់បុគ្គលដែលទទួលសំណើសុំនៅក្រោមកថាខណ្ឌទី១ ត្រូវតែគោរពតាមសំណើនោះ។

៣.ធនាគារជាតិនៃកម្ពុជាអាចប្រគល់ឱ្យសវនករឯករាជ្យខាងក្រៅធ្វើសវនកម្ម និងអធិការកិច្ចទាំងស្រុង ឬមួយផ្នែក ក្នុងនាមរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ ហើយត្រូវរាយការណ៍ជូនធនាគារជាតិនៃកម្ពុជា។

៤.ក្នុងគោលបំណងទទួលបានភស្តុតាងត្រឹមត្រូវក្រោមការសច្ចាប្រណិធានពាក់ព័ន្ធនឹងការធ្វើសវនកម្ម ឬ អធិការកិច្ចក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ធនាគារជាតិនៃកម្ពុជា។

៥.អ្នកចូលរួមត្រូវគោរពតាមរាល់កាតព្វកិច្ចដែលបានតម្រូវចំពោះអ្នកចាត់ការនៃប្រព្រឹត្តជាត់ទាត់នៃការទូទាត់សងប្រាក់នៅក្រោមប្រការ៦ នេះ។

៦.បើអ្នកចាត់ការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមប្រការនេះ អ្នកចូលរួមទាំងអស់ត្រូវរួមគ្នាអនុវត្តកាតព្វកិច្ចទាំងនោះ និងត្រូវទទួលខុសត្រូវចំពោះការបំពានលើកាតព្វកិច្ចទាំងនោះក្នុងលក្ខណៈ និងកំរិតដូចគ្នាដូចអ្នកចាត់ការដែរ។

**ប្រការ ៧**.-

ការស្នើសុំការពិនិត្យដោយហ្មត់ចត់លើការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ណាមួយ ឬសេចក្តីណែនាំដែលចេញផ្សាយក្រោមប្រការនេះ មិនត្រូវមានការពន្យារពេលចាត់តាំង ឬផ្តល់ការណែនាំ ដើម្បីរង់ចាំសេចក្តីសំរេចចុងក្រោយលើការស្នើសុំនោះឡើយ។

**ប្រការ ៨**.-

១. ព័ត៌មាន និងឯកសារដែលទទួលបាននៅក្រោមប្រកាសនេះ ត្រូវរក្សាជាការសម្ងាត់ និងត្រូវទុកដាក់ឱ្យបានត្រឹមត្រូវ។

២.គ្មានចំណុចណានៅក្នុងកថាខណ្ឌទី១ ហាមឃាត់ធនាគារជាតិនៃកម្ពុជាមិនឱ្យផ្សព្វផ្សាយព័ត៌មាន ឬឯកសារណាមួយទៅអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នបញ្ញត្តិកម្មដែលទទួលបន្ទុកគ្រប់គ្រងលើគ្រឹះស្ថានហិរញ្ញវត្ថុឡើយ នៅក្នុងលក្ខខណ្ឌដែលថាធនាគារជាតិនៃកម្ពុជាមានទំនុកចិត្តថាព័ត៌មាន ឬឯកសារទាំងនោះត្រូវបានរក្សាទុកជាការសម្ងាត់ដោយស្ថាប័ន អង្គភាព ឬបុគ្គលទាំងនោះ។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានអង្គភាពនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់

**ប្រការ១**.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួន ដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេងពីនេះ៖

១- **ភាគីបដិភាគចម្បង** សំដៅដល់សាជីវកម្ម សមាគម ភាពជាដៃគូ ភ្នាក់ងារ ឬអ្នកផ្តល់សេវាកម្មដទៃទៀត ឬបុគ្គលក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលជាមួយភាគីទាំងឡាយនោះ សិទ្ធិ និងកាតព្វកិច្ចទូទាត់សងប្រាក់របស់អ្នកចូលរួមក្នុងប្រព័ន្ធ ត្រូវបានជាត់ទាត់សុទ្ធ ដើម្បីគណនាប្រាក់ជំពាក់សុទ្ធតែមួយ រវាងអ្នកចូលរួមនីមួយៗនិងភាគីបដិភាគចម្បង។

២- **ប្រព័ន្ធជាត់ទាត់និងទូទាត់** សំដៅដល់ប្រព័ន្ធមួយ ឬកិច្ចសម្របសម្រួលសម្រាប់ការជាត់ទាត់ ឬទូទាត់បំណុលក្នុងប្រព័ន្ធហិរញ្ញវត្ថុជារូបិយប័ណ្ណណាមួយ និងដែលក្នុងនោះយ៉ាងហោចណាស់ក៏មានអ្នកចូលរួមចំនួនបី ហើយយ៉ាងតិចបំផុតមួយគឺគ្រឹះស្ថានហិរញ្ញវត្ថុ។ ដើម្បីឱ្យមានការប្រាកដជាងនេះ ប្រព័ន្ធនេះមានរាប់បញ្ចូលផងដែរនូវប្រព័ន្ធ ឬកិច្ចសម្របសម្រួលសម្រាប់ការជាត់ទាត់និងទូទាត់ជារូបិយវត្ថុជាតិរបស់ប្រទេសកម្ពុជា ឬកិច្ចសម្របសម្រួលសម្រាប់ប្រតិបត្តិការមូលបត្រ ប្រតិបត្តិការរូបិយប័ណ្ណបរទេស ឬប្រតិបត្តិការដទៃទៀត ឬកិច្ចសន្យាហិរញ្ញវត្ថុ នៅពេលណាដែលប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះធ្វើការជាត់ទាត់ ឬទូទាត់កាតព្វកិច្ចសងប្រាក់ដែលកើតចេញពីប្រតិបត្តិការនិងកិច្ចសន្យាទាំងនោះ។

៣- **សភាជាត់ទាត់** សំដៅដល់សាជីវកម្ម សមាគម ភាពជាដៃគូ ភ្នាក់ងារ ឬអង្គភាពដទៃទៀត អង្គការ ឬ បុគ្គលដែលផ្តល់សេវាជាត់ទាត់ ឬទូទាត់សម្រាប់ប្រព័ន្ធជាត់ទាត់និងទូទាត់ ប៉ុន្តែមិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជាឡើយ។

៤- **ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង** សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ក្រោមប្រការ២ កថាខណ្ឌទី១។

៥- **គ្រឹះស្ថានហិរញ្ញវត្ថុ** សំដៅដល់៖

ក-ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាប័ណ្ណ

ខ-បុគ្គលដទៃទៀត អង្គភាព ឬបុគ្គល ឬអង្គភាពក្នុងក្រុមបុគ្គល ឬអ្នកផ្តល់សេវាកម្ម ដែលប្រកបរបរជាចម្បងក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលអាចត្រូវបានចាត់តាំងដោយ

ធនាគារជាតិនៃកម្ពុជា ថាជាគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីបម្រើឱ្យគោលបំណងក្នុងប្រកាសនេះ។

៦- **ប្រព័ន្ធហិរញ្ញវត្ថុ** សំដៅដល់ប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

៧- **សេចក្តីណែនាំ** សំដៅដល់ខ្លឹមសារនៃបញ្ជាទូទាត់។

៨- **អ្នកចូលរួម** សំដៅដល់សមាជិកនៃសភាជាត់ទាត់ ឬភាគីនៃកិច្ចសម្របសម្រួលដែលបង្កើតប្រព័ន្ធជាត់ទាត់និងទូទាត់។

៩- **ហានិភ័យជាប្រព័ន្ធ** សំដៅដល់ហានិភ័យដែលអសមត្ថភាពរបស់អ្នកចូលរួមម្នាក់ក្នុងការបំពេញកាតព្វកិច្ចបំណុលក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ នៅពេលដែលបំណុលនោះដល់កាលកំណត់ ឬរាំងស្ទះណាមួយក្នុងប្រព័ន្ធជាត់ទាត់ និងទូទាត់តាមរយៈការបញ្ជូនបញ្ជាហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធដែលអាចបណ្តាលឱ្យៈ

ក- អ្នកចូលរួមដទៃទៀតក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅពេលដល់កាលកំណត់

ខ- គ្រឹះស្ថានហិរញ្ញវត្ថុក្នុងផ្នែកដទៃទៀតនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួនបាននៅពេលដល់កាលកំណត់ ឬ

១០- សភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ ឬសភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ផ្សេងទៀតក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅពេលដល់កាលកំណត់។

**ប្រការ ២**.-

១- នៅពេលដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា ប្រព័ន្ធជាត់ទាត់និងទូទាត់មួយធ្វើសកម្មភាពក្នុងលក្ខណៈ ដែលអាចបង្កឱ្យមានហានិភ័យជាប្រព័ន្ធនោះ ធនាគារជាតិនៃកម្ពុជាអាចចាត់ថ្នាក់ប្រព័ន្ធជាត់ទាត់និងទូទាត់នេះជាប្រព័ន្ធជាត់ទាត់ និងទូទាត់មានសារៈសំខាន់ជាប្រព័ន្ធដែលត្រូវស្ថិតនៅក្រោមប្រកាសនេះ។

២- ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងដល់សភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងអំពីការចាត់ថ្នាក់នេះ ហើយត្រូវផ្សព្វផ្សាយព័ត៌មាននេះក្នុងរាជកិច្ច។

៣- ការចាត់តាំងប្រព័ន្ធជាត់ទាត់និងទូទាត់មួយថា មានសារៈសំខាន់ជាប្រព័ន្ធនៅក្រោមប្រកាសនេះអាចនឹងត្រូវបានផ្តល់ជាបន្ថែមទៅលើការចាត់តាំងនៃប្រព័ន្ធដូចគ្នានេះក្រោមប្រកាសស្តីពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់។ បុគ្គលដែលស្ថិតក្រោមប្រកាសស្តីពីការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ និងប្រកាសស្តីពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ត្រូវតែអនុវត្តតាមរាល់កាតព្វកិច្ចដែលត្រូវបានតម្រូវក្រោមប្រកាសទាំងពីរនេះ។

**ប្រការ ៣.-**

ធនាគារជាតិនៃកម្ពុជាអាចធ្វើកិច្ចព្រមព្រៀងជាមួយ ឬចេញសេចក្តីណែនាំដល់សភាផាត់ទាត់ ឬអ្នកចូលរួមក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងឬប្រព័ន្ធទាំងពីរចំពោះ៖

ក- កិច្ចសម្របសម្រួលផាត់ទាត់និងទូទាត់សុទ្ធ

ខ- យន្តការបែងចែកហានិភ័យនិងគ្រប់គ្រងហានិភ័យ

គ- ភាពប្រាកដប្រជានៃការទូទាត់ និងការបញ្ចប់ជាស្ថាពរនៃការទូទាត់សងប្រាក់

ឃ- លក្ខណៈនៃកិច្ចសម្របសម្រួលហិរញ្ញវត្ថុក្នុងចំណោមអ្នកចូលរួម

ង- ប្រព័ន្ធប្រតិបត្តិការនិងភាពរឹងមាំខាងហិរញ្ញវត្ថុនៃសភាផាត់ទាត់

ច- ការងារផ្សេងទៀតដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា អាចពាក់ព័ន្ធនឹងហានិភ័យជាប្រព័ន្ធ។

**ប្រការ ៤.-**

១- នៅពេលណាដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា៖

ក-សភាផាត់ទាត់សម្រាប់ប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងកំពុងធ្វើ ឬរៀបនឹងធ្វើសកម្មភាព ធ្វើការភ្លេចភ្លាំង ឬការប្រព្រឹត្តណាមួយ

ខ-អ្នកចូលរួមកំពុងធ្វើ ឬរៀបនឹងធ្វើសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តណាមួយពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួនក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

គ-ប្រព័ន្ធផាត់ទាត់ និងទូទាត់ដែលចាត់តាំង កំពុងអនុវត្ត ឬរៀបនឹងអនុវត្តតាមរបៀបមួយដែលបណ្តាលឱ្យ ឬទំនងជាបណ្តាលឱ្យមានហានិភ័យជាប្រព័ន្ធ ដោយសារមិនត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ ធនាគារជាតិនៃកម្ពុជា អាចចេញសេចក្តីណែនាំដល់សភាផាត់ទាត់ដោយតម្រូវឱ្យភាគីទាំងឡាយនោះ ក្នុងរយៈពេលមួយដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់:

- បញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្ត ឬឱ្យអ្នកចូលរួមបញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្ត និង
- ធ្វើសកម្មភាព ឬឱ្យអ្នកចូលរួមធ្វើសកម្មភាព ដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់ ដើម្បីដោះស្រាយបញ្ហា។

២- នៅពេលណាដែលធនាគារជាតិនៃកម្ពុជាមានការយល់ឃើញនៅក្រោមកថាខណ្ឌទី១ ថាហានិភ័យជាប្រព័ន្ធមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវទេនោះ ហើយ៖

ក-សភាផាត់ទាត់មិនបានអនុវត្តតាមសេចក្តីណែនាំដែលត្រូវបានដាក់ចេញចំពោះខ្លួននៅក្រោមកថាខណ្ឌទី១

ខ- ប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងពុំមានសភាផាត់ទាត់ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាឬ

គ- តាមយោបល់របស់ធនាគារជាតិនៃកម្ពុជា

- ហានិភ័យជាប្រព័ន្ធនោះមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវដោយសារតែសកម្មភាពណាមួយ ការភ្លេចភ្លាំង ឬការប្រព្រឹត្តរបស់អ្នកចូលរួមពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកទាំងនោះនៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង និង
- សកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តនោះមិនស្ថិតនៅក្រោមច្បាប់ កិច្ចសម្របសម្រួល វិធាន នីតិវិធី សេចក្តីណែនាំ ឬបទបញ្ជាដទៃទៀតដែលគ្រប់គ្រងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង។

ធនាគារជាតិនៃកម្ពុជា អាចចេញសេចក្តីណែនាំដល់អ្នកចូលរួម ក្នុងរយៈពេលមួយដែលធនាគារជាតិនៃកម្ពុជា យល់ឃើញថាចាំបាច់ ហើយអាចបញ្ជាក់នៅក្នុងសេចក្តីណែនាំនោះថាអ្នកចូលរួមៈ

- បញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តជាក់លាក់ណាមួយពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួននៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង និង
- ធ្វើសកម្មភាពពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួន ដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់ ដើម្បីដោះស្រាយបញ្ហា។

៣- សេចក្តីណែនាំស្ថិតក្រោមប្រការនេះ អាចត្រូវបានធ្វើឡើងចំពោះបញ្ហាណាមួយដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការចូលរួមក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង។ ដើម្បីឱ្យមានការប្រាកដជាងនេះ សេចក្តីណែនាំក្រោមប្រការនេះអាចមិនត្រូវបានធ្វើឡើងចំពោះបញ្ហាដូចខាងក្រោមទេៈ

ក- ភាពគ្រប់គ្រាន់នៃដើមទុនរបស់អ្នកចូលរួម

ខ- ការគ្រប់គ្រងលើវិនិយោគរបស់អ្នកចូលរួម

គ- អភិបាលកិច្ចសាជីវកម្មរបស់អ្នកចូលរួម

ឃ- ទំនាក់ទំនងរបស់អ្នកចូលរួមជាមួយអតិថិជនដែលមិនមែនជាអ្នកចូលរួមដោយផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

ង- រចនាសម្ព័ន្ធកម្មសិទ្ធិរបស់អ្នកចូលរួម។

៤- សេចក្តីណែនាំអាចតម្រូវថា កាតព្វកិច្ចទូទាត់សងប្រាក់ដែលកើតចេញពីការផាត់ទាត់នៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវតែបានទូទាត់តាមរយៈការកែតម្រូវចំពោះគណនីមួយ ឬច្រើនរបស់អ្នកចូលរួមមួយ ឬច្រើននៅធនាគារជាតិនៃកម្ពុជា។

៥- សេចក្តីណែនាំ ប្រសិនបើមានចែងដូច្នេះ នឹងអនុវត្តចំពោះប្រព័ន្ធផាត់ទាត់ និងទូទាត់ដែលបានចាត់តាំងដែលត្រូវបានបង្កើតឡើងដោយ ឬក្រោមច្បាប់ណាមួយ។

៦- សេចក្តីណែនាំត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

៧- សេចក្តីណែនាំគឺជាចំណងកាតព្វកិច្ចចំពោះបុគ្គលដែលស្ថិតក្រោមសេចក្តីណែនាំនោះ។

**ប្រការ ៥**.-

១- ធនាគារជាតិនៃកម្ពុជាអាចធ្វើអ្វីៗទាំងអស់ ឬអ្វីមួយដូចខាងក្រោម ក្នុងទំនាក់ទំនងជាមួយប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង និងសភាជាត់ទាត់នៃប្រព័ន្ធនោះ៖

ក- ផ្តល់ការធានាដោយមាន ឬគ្មានវត្ថុបញ្ចាំចំពោះការទូទាត់សងប្រាក់ពីអ្នកចូលរួម

ខ- ផ្តល់ឥណទានសាច់ប្រាក់ងាយស្រួលដល់សភាផាត់ទាត់ និងភាគីបដិភាគចម្បង និង

គ- ដើរតួជាភាគីបដិភាគចម្បងចំពោះអ្នកចូលរួម។

២- ប្រសិនបើធនាគារជាតិនៃកម្ពុជាយល់ឃើញថា ការចូលរួមនៅក្នុងប្រព័ន្ធផាត់ទាត់ និងទូទាត់ដែលបានចាត់តាំងដោយអ្នកចូលរួមធ្វើឱ្យ ឬទំនងជាធ្វើឱ្យមានហានិភ័យជាប្រព័ន្ធដែលមិនអាចទទួលយកបាន ឬហានិភ័យដែលមិនអាចទទួលយកបានចំពោះធនាគារជាតិនៃកម្ពុជាក្នុងការធានាការទូទាត់សងបំណុលរបស់អ្នកចូលរួមនោះ ធនាគារជាតិនៃកម្ពុជាអាចពន្យារការចូលរួមរបស់អ្នកចូលរួមនោះ ហាមឃាត់មិនឱ្យចូលរួម ឬអាចទាមទារឱ្យអ្នកចូលរួមបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួនតាមដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាជាការចាំបាច់។

**ប្រការ ៦**.-

១- ក្នុងប្រការ៦ និងប្រការ៧ បណ្តឹងអំពីអសាធនភាព សំដៅដល់វិធានការរួមដែលកំណត់ដោយច្បាប់ ដើម្បីបញ្ចប់សកម្មភាពរបស់អ្នកចូលរួម ឬដើម្បីរៀបចំអ្នកចូលរួមនោះឡើងវិញ ទោះដោយស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្តក្តី ដែលវិធានការទាំងនោះ រួមមានការព្យួរ ឬការដាក់កំហិតលើបញ្ជាទូទាត់ និងការទូទាត់សងប្រាក់។

២- បញ្ជាទូទាត់ដែលចូលទៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង និងក្នុងការទូទាត់សុទ្ធនៃប្រព័ន្ធនោះ ត្រូវតែអនុវត្តបានដោយស្របច្បាប់ ទោះបីជាក្នុងករណីមានបណ្តឹងអំពីអសាធនភាពទល់នឹងអ្នកចូលរួមក្តី និងត្រូវតែជាចំណងនីត្យានុកូលលើភាគីទីបីនៅក្នុងលក្ខខណ្ឌថាបញ្ជាទូទាត់ត្រូវបានចូលទៅក្នុងប្រព័ន្ធមុនពេលមានបើកបណ្តឹងអំពីអសាធនភាពនោះ។

៣- នៅពេលណាដែលបញ្ជាទូទាត់ត្រូវបានចូលទៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងក្រោយពេលបើកបណ្តឹងអំពីអសាធនភាព និងត្រូវបានអនុវត្តនៅថ្ងៃបើកបណ្តឹងបែបនេះ បញ្ជាទូទាត់ទាំងនោះត្រូវតែអាចអនុវត្តដោយស្របច្បាប់ និងត្រូវតែជាចំណងនីត្យានុ-កូលលើភាគីទីបីតែប៉ុណ្ណោះ ប្រសិនបើក្រោយពេលទូទាត់ ភាគីបដិភាគចម្បង ឬសភាផាត់ទាត់អាចបញ្ជាក់អះអាងថា ពួកគេមិនបានដឹង ឬមិនត្រូវបានឱ្យដឹងអំពីការបើកបណ្តឹងបែបនេះ។

៤- ពេលវេលាដែលបញ្ជាទូទាត់ចូលមកក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវតែបានកំណត់ដោយវិធាននៃប្រព័ន្ធនេះ។

៥- ចំពោះគោលបំណងនៃប្រការនេះ ពេលវេលានៃការបើកបណ្តឹងអំពីអសាធនភាពត្រូវតែជាពេលវេលា ដែលអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការបានធ្វើសេចក្តីសម្រេច។

៦- នៅពេលណាដែលសេចក្តីសម្រេចត្រូវបានធ្វើឡើងអនុលោមតាមកថាខណ្ឌទី៥ អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះជាបន្ទាន់ដល់ធនាគារជាតិនៃកម្ពុជា។

៧- បណ្តឹងអំពីអសាធនភាព មិនត្រូវមានឥទ្ធិពលប្រតិសកម្មទៅលើសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកចូលរួមដែលកើតឡើងពីការជាត់ទាត់និងទូទាត់បំណុលតាមប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងនៅគ្រាមុនពេលបើកបណ្តឹងនេះឡើយ។

**ប្រការ ៧**.-

១- ក្នុងប្រការនេះ វិធានទូទាត់ សំដៅដល់វិធានដែលត្រូវបានបង្កើតឡើងតាមវិធីណាមួយដែលផ្តល់ជាមូលដ្ឋានសម្រាប់គណនាកាតព្វកិច្ចទូទាត់សងប្រាក់ចំនួនសុទ្ធ ឬត្រូវបានទូទាត់ និងដែលរួមបញ្ចូលផងដែរនូវវិធានច្បាប់ដើម្បីចាត់វិធានការក្នុងព្រឹត្តិការណ៍ដែលអ្នកចូលរួមគ្មានលទ្ធភាព ឬទំនងជាគ្មានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សងរបស់ខ្លួនចំពោះសភាជាត់ទាត់ ភាគីបដិភាគចម្បង ឬអ្នកចូលរួមដទៃទៀត។

២- ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតចែងផ្ទុយពីនេះ៖

ក- វិធានទូទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងមានសុពលភាព និងជាចំណងកាតព្វកិច្ចចំពោះសភាជាត់ទាត់ អ្នកចូលរួម ភាគីបដិភាគចម្បង និងធនាគារជាតិនៃកម្ពុជា។ សកម្មភាពណាមួយ ឬការទូទាត់សងប្រាក់ណាមួយអាចនឹងត្រូវបានធ្វើឡើងដោយអនុលោមតាមវិធានទូទាត់នេះ។

ខ- កាតព្វកិច្ចរបស់អ្នកចូលរួម សភាជាត់ទាត់ ឬភាគីបដិភាគចម្បងក្នុងការទូទាត់សងប្រាក់ឱ្យអ្នកចូលរួមម្នាក់ និងសិទ្ធិរបស់អ្នកចូលរួមសភាជាត់ទាត់ ឬភាគីបដិភាគចម្បង ត្រូវតែបានគណនាជាចំនួនសុទ្ធ ហើយចំនួនប្រាក់ទូទាត់សុទ្ធ ឬចំនួនប្រាក់បិទបញ្ជី ត្រូវតែបានកំណត់ស្របតាមវិធានទូទាត់នៃប្រព័ន្ធជាត់ទាត់ និងទូទាត់ដែលបានចាត់តាំងប្រសិនបើមានចែងបែបនេះ និង

គ- នៅពេលដែលវិធានទូទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងបានចែងថាការទូទាត់កាតព្វកិច្ចទូទាត់សងប្រាក់តាមរយៈការទូទាត់ចូល ឬការទូទាត់ចេញពីគណនីរបស់អ្នកចូលរួមសភាជាត់ទាត់ ឬភាគីបដិភាគចម្បងនៅធនាគារជាតិនៃកម្ពុជាត្រូវបានបញ្ចប់ជាស្ថាពរ និងមិនអាចបដិសេធបាន ការទូទាត់សងប្រាក់ចូល ឬចេញនោះនឹងមិនត្រូវបានចុះបញ្ច្រាសទូទាត់សងត្រលប់វិញ ឬទុកដោយឡែកសិនបានឡើយ។

៣- ការទូទាត់សងប្រាក់ចូល ឬចេញពីគណនីរបស់អ្នកចូលរួម សភាផាត់ទាត់ ឬភាគីបដិភាគចម្បងនៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចបំណុលក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងមិនត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ ឬបញ្ហាណាមួយដែលមានលក្ខណៈជាការពន្យារពេលនៃសកម្មភាពនោះទេ។

៤- សិទ្ធិនិងដំណោះស្រាយរបស់អ្នកចូលរួម សភាផាត់ទាត់ ភាគីបដិភាគចម្បង ឬធនាគារជាតិនៃកម្ពុជា ចំពោះប្រាតិភោគដែលផ្តល់ការធានាចំពោះការទូទាត់សងប្រាក់ ឬការអនុវត្តកាតព្វកិច្ចដែលកើតមាននៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង អាចមិនត្រូវបានទទួលរងឥទ្ធិពលពីបណ្តឹងអសាធនភាពឡើយ។ ជាពិសេស សិទ្ធិនិងដំណោះស្រាយទាំងនេះ អាចមិនត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិពន្យារពេល ឬ បញ្ហាណាមួយ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់ឥណទាយកក្នុងការអនុវត្តសិទ្ធិនិងដំណោះស្រាយរបស់ខ្លួនពាក់ព័ន្ធដល់ប្រាតិភោគនោះឡើយ។

៥- ទោះបីជាការគ្រប់គ្រង ឬប្រតិបត្តិការទាំងអស់ ឬមួយផ្នែកនៃប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវបានធ្វើឡើងនៅក្រៅប្រទេសកម្ពុជា ឬវិធានទូទាត់នៃប្រព័ន្ធនោះត្រូវបានគ្រប់គ្រងដោយច្បាប់នៃយុត្តាធិការបរទេសក្តី នៅពេលដែលក្នុងបណ្តឹងណាមួយក្នុងប្រទេសកម្ពុជា តុលាការកំណត់ថា សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលណាមួយដែលកើតចេញ ឬមានពាក់ព័ន្ធជាមួយប្រតិបត្តិការរបស់ប្រព័ន្ធផាត់ទាត់ និងទូទាត់ដែលបានចាត់តាំងត្រូវបានគ្រប់គ្រងទាំងមូល ឬមួយផ្នែកដោយច្បាប់របស់កម្ពុជា បទប្បញ្ញត្តិនៃប្រការនេះត្រូវតែអនុវត្តក្នុងកម្រិតមួយដែលច្បាប់កម្ពុជាបានអនុវត្តក្នុងការកំណត់សិទ្ធិ និងកាតព្វកិច្ចទាំងនោះ។

**ប្រការ ៨.-**

១- ពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង សភាផាត់ទាត់នីមួយៗត្រូវផ្តល់ដំណឹងជាមុនដល់ធនាគារជាតិនៃកម្ពុជា អំពីការកែប្រែទាំងឡាយណាដែលធ្វើឡើងដោយសភាផាត់ទាត់ដែលមានលក្ខណៈសំខាន់ចំពោះប្រព័ន្ធផាត់ទាត់ និងទូទាត់ដែលបានចាត់តាំងនោះ និងដោយពុំមានកំណត់តែចំពោះការកែប្រែជាទូទៅទេ សេចក្តីជូនដំណឹងត្រូវតែបានធ្វើឡើង ចំពោះរាល់ការកែប្រែទាំងឡាយណាដែលមានផលប៉ះពាល់ទៅលើ៖

ក- ឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងការកសាង បង្កើត រៀបចំ អភិបាលកិច្ច និងប្រតិបត្តិការរបស់សភាផាត់ទាត់ រួមទាំងផ្នែកទាំងឡាយនៃឯកសារនោះ ឬអនុស្សារណៈសមាគម ប្រកាស និងសេចក្តីសំរេចសំខាន់ៗ និងកិច្ចសម្របសម្រួល វិធាន និងនីតិវិធីផងដែរ

ខ- ប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

គ- ប្រកាស កិច្ចសម្របសម្រួល វិធាន នីតិវិធី សេចក្ដីណែនាំ ឬឯកសារផ្សេងៗទៀតដែលគ្រប់គ្រងលើប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង។

២- បន្ទាប់ពីបានធ្វើការកែប្រែពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងនោះ សភាផាត់ទាត់នីមួយៗត្រូវតែផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃកម្ពុជាអំពីការកែប្រែនេះ និងដោយពុំមានកំណត់តែចំពោះការកែប្រែជាទូទៅទេ សេចក្ដីជូនដំណឹងត្រូវតែបានធ្វើឡើងចំពោះរាល់ការកែប្រែទាំងឡាយណាដែលមានផលប៉ះពាល់ទៅលើ៖

ក- សមាសភាពរបស់សមាជិកក្រុមប្រឹក្សាភិបាលសភាផាត់ទាត់ ដោយសារការលាឈប់ពីដំណែង ឬពីមូលហេតុផ្សេងទៀត ឬ

ខ- សវនករសភាផាត់ទាត់ដែលត្រូវបានតែងតាំង។

៣- ពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង សភាផាត់ទាត់នីមួយៗត្រូវផ្ដល់ដំណឹងដល់ធនាគារជាតិនៃកម្ពុជានូវព័ត៌មានទាំងនោះ តាមពេលវេលានិងទម្រង់បែបបទដែលធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ។

**ប្រការ ៩**.-

១- ក្នុងគោលបំណងអនុវត្តភារកិច្ចដូចដែលមានចែងក្នុងប្រការនេះ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិធ្វើសវនកម្ម និងអធិការកិច្ចលើសភាផាត់ទាត់ ហើយសភាផាត់ទាត់នីមួយៗប្រសិនបើមានការស្នើសុំ ត្រូវតែជួយដល់ធនាគារជាតិនៃកម្ពុជាតាមការចាំបាច់ដើម្បីបង្កលក្ខណៈឱ្យធនាគារជាតិនៃកម្ពុជាអាចធ្វើសវនកម្ម និងអធិការកិច្ចបាន។

២- ធនាគារជាតិនៃកម្ពុជា អាចប្រគល់ឱ្យសវនករឯករាជ្យខាងក្រៅធ្វើសវនកម្មនិងអធិការកិច្ចទាំងស្រុង ឬមួយផ្នែកក្នុងនាមរបស់ខ្លួន ដូចដែលមានចែងក្នុងកថាខណ្ឌទី១ ហើយត្រូវរាយ-ការណ៍ជូនធនាគារជាតិនៃកម្ពុជា។

៣- ក្នុងគោលបំណងទទួលបានភស្តុតាងត្រឹមត្រូវពាក់ព័ន្ធនឹងការធ្វើសនវកម្ម ឬអធិការកិច្ចក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

៤- ធនាគារជាតិនៃកម្ពុជាអាចអនុវត្តនូវមុខងារទាំងអស់ ឬមុខងារមួយដែលពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់ និងសភាផាត់ទាត់ដូចខាងក្រោម៖

ក- ជាអ្នកចូលរួម ចូលរួមនិងធ្វើសកម្មភាពជាភាគីបដិភាគចម្បង រួមទាំងនៅក្នុងយន្តការបែងចែកការខាតបង់

ខ- ធ្វើសកម្មភាពជាអ្នករក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុ ឬជាភ្នាក់ងារទូទាត់ ឬធ្វើទាំងពីរនិង

គ-ទទួលប្រាក់បញ្ញើពីសភាផាត់ទាត់ អ្នកចូលរួម ឬភាគីបដិភាគចម្បង ឬទូទាត់សងការប្រាក់។

៥- នៅពេលណាដែលធនាគារជាតិនៃកម្ពុជា មានមូលហេតុសមស្របនឹងជឿជាក់ថាប្រព័ន្ធមួយ ឬកិច្ចសម្របសម្រួលមួយត្រូវបានបង្កើតឡើងសម្រាប់ការជាត់ទាត់ និងទូទាត់កាតព្វកិច្ច ឬសារសម្រាប់ទូទាត់សងប្រាក់ ប៉ុន្តែធនាគារជាតិនៃកម្ពុជាត្រូវការព័ត៌មានបន្ថែមទៀតដើម្បីកំណត់ថាប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះជាប្រព័ន្ធជាត់ទាត់និងទូទាត់ ធនាគារជាតិនៃកម្ពុជាអាចស្នើទៅបុគ្គលណាម្នាក់ដែលជាភាគីនៃប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះឱ្យផ្តល់ព័ត៌មាន និងឯកសារផ្សេងៗដែលទាក់ទងនឹងប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះ តាមដែលធនាគារជាតិនៃកម្ពុជាត្រូវការដើម្បីធ្វើការកំណត់។ រាល់បុគ្គលទាំងឡាយណាដែលទទួលបានសំណើក្រោមកថាខណ្ឌនេះត្រូវតែគោរពតាមសំណើនោះ។

៦- ពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់របស់ខ្លួន សភាជាត់ទាត់នីមួយៗ ត្រូវផ្តល់ព័ត៌មាននិងឯកសារទាំងឡាយដល់ធនាគារជាតិនៃកម្ពុជា តាមដែលធនាគារជាតិនៃកម្ពុជាអាចតម្រូវជាក់ស្តែង ដើម្បីផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាឱ្យអាចកំណត់បានថា តើប្រព័ន្ធជាត់ទាត់និងទូទាត់នោះបង្កឱ្យមានហានិភ័យជាប្រព័ន្ធដែរឬទេ ដោយពុំមានការកំណត់ចំពោះតែព័ត៌មានជាទូទៅពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ សភាជាត់ទាត់ចាំបាច់ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវព័ត៌មានដូចខាងក្រោមៈ

ក- ឈ្មោះអ្នកចូលរួមរបស់ខ្លួន

ខ- ច្បាប់ចម្លងនៃឯកសារទាំងឡាយណាពាក់ព័ន្ធនឹងការកសាង បង្កើត រៀបចំ អភិបាលកិច្ច និងប្រតិបត្តិការរបស់សភាជាត់ទាត់រួមទាំងផ្នែកទាំងឡាយនៃឯកសារនោះឬអនុស្សារណៈសមាគម ប្រកាស និងសេចក្តីសម្រេចសំខាន់ៗរបស់សភាជាត់ទាត់ កិច្ចសម្របសម្រួល វិធាន និងនីតិវិធីផងដែរ

គ- ឈ្មោះរបស់នាយកចាត់ចែង សមាជិកគណៈកម្មការ និងសវនករ

ឃ- ច្បាប់ចម្លងនៃរបាយការណ៍ សេចក្តីថ្លែងការណ៍ ឬឯកសារដទៃទៀតរបស់ខ្លួនដែលត្រូវបានទាមទារឱ្យរក្សាទុកនៅនឹងស្ថាប័នរដ្ឋាភិបាលឬអង្គភាពបញ្ញត្តិកម្មនិង

ង- ច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុ។

៧- នៅក្នុងប្រការនេះ ធនាគារជាតិនៃកម្ពុជាមិនតម្រូវឱ្យអ្នកចូលរួមណាមួយផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអ្នកចូលរួមដទៃមួយទៀតនៃប្រព័ន្ធជាត់ទាត់ណាមួយទេ ប្រសិនបើព័ត៌មាននោះមិនមានសម្រាប់ការប្រើប្រាស់របស់អ្នកចូលរួមទាំងអស់គ្នា។

**ប្រការ ១០**.-

១- នៅក្នុងប្រការនេះ៖

ក- តម្លៃបញ្ចប់សុទ្ធ សំដៅដល់ចំនួនប្រាក់សុទ្ធដែលទទួលបានពីការកាត់កង ឬការផាត់ទាត់កាតព្វកិច្ចសុទ្ធរវាងភាគីនានានៃកិច្ចព្រមព្រៀងផាត់ទាត់សុទ្ធ អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនោះ។

ខ- កិច្ចព្រមព្រៀងផាត់ទាត់សុទ្ធ សំដៅដល់កិច្ចព្រមព្រៀងរវាងគ្រឹះស្ថានហិរញ្ញវត្ថុពីរ ឬច្រើន ឬរវាងធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើនដែលផ្តល់នូវការផាត់ទាត់ ឬកាត់កងកាតព្វកិច្ចទូទាត់សងប្រាក់បច្ចុប្បន្ន ឬអនាគតទល់នឹងសិទ្ធិបច្ចុប្បន្ន ឬអនាគតក្នុងការទទួលការទូទាត់សងប្រាក់។

២- ទោះបីជាមានបទប្បញ្ញត្តិក្នុងច្បាប់ណាមួយដែលពាក់ព័ន្ធ ឬមិនពាក់ព័ន្ធក្តីទៅនឹងច្បាប់ក្ស័យធន ឬក៏ដីការរបស់តុលាការដែលធ្វើឡើងដោយអនុលោមទៅតាមការគ្រប់គ្រងនៃការរៀបចំឡើងវិញ កិច្ចព្រមព្រៀង ឬភាពជាអ្នកទទួលសំណងពាក់ព័ន្ធនឹងអសាធនភាព ដែលនៅក្នុងនោះគ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារជាតិនៃកម្ពុជាជាភាគីមួយនៃកិច្ចព្រមព្រៀងផាត់ទាត់សុទ្ធ គ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារជាតិនៃកម្ពុជាអាចបញ្ចប់កិច្ចព្រមព្រៀង ឬ កំណត់តម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធ អនុលោមតាមបទប្បញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀង។ ភាគីដែលមានសិទ្ធិទទួលបានតម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធ ត្រូវតែជាឥណទាយកនៃភាគីដែលជំពាក់តម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធក្នុងតម្លៃ ឬចំនួនប្រាក់នោះ។

**ប្រការ ១១**.-

១- នៅពេលណាសភាផាត់ទាត់ខកខានមិនបានអនុវត្តកាតព្វកិច្ចដែលតម្រូវដោយប្រកាសនេះពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់របស់ខ្លួន ឬមិនគោរពតាមប្រកាសនេះ អ្នកចូលរួមទាំងអស់ត្រូវរួមគ្នាអនុវត្តកាតព្វកិច្ចទាំងនោះ ហើយអ្នកចូលរួមទាំងនោះត្រូវទទួលខុសត្រូវចំពោះការមិនគោរពកាតព្វកិច្ចទាំងនោះក្នុងលក្ខណៈនិងកម្រិតដូចជាសភាផាត់ទាត់ដែរ។

២- នៅពេលណាប្រព័ន្ធផាត់ទាត់និងទូទាត់មួយមិនមានសភាផាត់ទាត់ ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាទេនោះ អ្នកចូលរួមដែលមានទីតាំងនៅប្រទេសកម្ពុជា

ក- ត្រូវគោរពតាមកាតព្វកិច្ចទាំងឡាយដែលបានដាក់ចេញនៅក្រោមប្រការនេះអំពីសភាផាត់ទាត់ចំពោះការងារពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់ និង

ខ- មានសិទ្ធិគ្រប់យ៉ាងដែលត្រូវបានផ្តល់ឱ្យនៅក្នុងប្រការនេះស្តីពីសភាផាត់ទាត់ ចំពោះការងារពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់និងទូទាត់

ក្នុងលក្ខណៈនិងកម្រិតដូចគ្នា ដូចជាអ្នកចូលរួមដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាជាសភាផាត់ទាត់ដែលក្នុងនេះកាតព្វកិច្ច និងសិទ្ធិទាំងនោះត្រូវបានតម្រូវ និងក្នុងគោលបំណងនេះ វិធានការនានាដែលធនាគារជាតិនៃកម្ពុជាអាចដាក់ចុះពាក់ព័ន្ធនឹងសភាផាត់ទាត់អាចនឹងត្រូវបានអនុវត្តតែចំពោះអ្នកចូលរួមដែលមានទីតាំងនៅក្នុងប្រទេស

កម្ពុជាប៉ុណ្ណោះ។ ដើម្បីគោលបំណងនៃកថាខណ្ឌនេះ អ្នកចូលរួមត្រូវបានចាត់ទុកថាមានទីតាំងនៅកម្ពុជានៅពេលណា ពួកគេត្រូវបានបង្កើតឡើងនៅក្រោមច្បាប់នៃប្រទេសកម្ពុជា។

៣- ធនាគារបរទេសដែលជាអ្នកចូលរួម ឬមានបំណងធ្វើជាអ្នកចូលរួមនៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវព័ត៌មានដែលទាក់ទងទៅនឹងការអនុវត្តច្បាប់បរទេសចំពោះធនាគារបរទេសដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់។

**ប្រការ ១២**.-

១- ការគោរពតាមបទប្បញ្ញត្តិនៃប្រកាសនេះ ឬសេចក្តីណែនាំចេញដោយធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងបញ្ហាណាមួយនៅក្រោមបទប្បញ្ញត្តិខាងលើ ឬការស្នើសុំព័ត៌មានដោយស្របច្បាប់នៅក្រោមប្រកាសនេះ អាចនឹងត្រូវបានអនុវត្តតាមរយៈការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជាទៅកាន់តុលាការមានសមត្ថកិច្ចឱ្យចេញដីកាបង្គាប់ឱ្យគោរពតាមបទប្បញ្ញត្តិ វិធានសេចក្តីណែនាំ ឬសំណើនោះ។ ដោយផ្អែកលើការស្នើសុំនេះ តុលាការអាចចេញដីកាតាមនោះ ឬដីកាបន្ថែមទៀត ប្រសិនបើយល់ថាចាំបាច់។

២- ចំពោះការស្នើសុំការត្រួតពិនិត្យដោយតុលាការ លើការចាត់តាំងណាមួយក្រោមប្រកាសនេះ ឬសេចក្តីណែនាំពាក់ព័ន្ធដែលត្រូវបានចេញផ្សាយ មិនត្រូវមានការផ្តល់ឱ្យនូវការពន្យារពេលការចាត់តាំង ឬសេចក្តីណែនាំដើម្បីរង់ចាំសេចក្តីសំរេចចុងក្រោយលើការស្នើសុំសេចក្តីណែនាំឡើយ។

**ប្រការ ១៣**.-

១- ព័ត៌មាននិងឯកសារដែលទទួលបាននៅក្រោមប្រកាសនេះត្រូវរក្សាជាការសម្ងាត់ និងត្រូវចាត់ចែងជាការសម្ងាត់ដូចគ្នា។

២- ខ្លឹមសារក្នុងកថាខណ្ឌទី១ មិនហាមឃាត់ធនាគារជាតិនៃកម្ពុជាក្នុងការផ្សព្វផ្សាយព័ត៌មាន ឬឯកសារណាមួយទៅអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នបញ្ញត្តិកម្មដែលទទួលបន្ទុកគ្រប់គ្រងលើគ្រឹះស្ថានហិរញ្ញវត្ថុឡើយ នៅក្នុងល័ក្ខខណ្ឌដែលធនាគារជាតិនៃកម្ពុជាមានទំនុកចិត្តថាព័ត៌មាន ឬឯកសារ ទាំងនោះត្រូវបានរក្សាទុកជាការសម្ងាត់ដោយ ស្ថាប័ន អង្គភាពនិងបុគ្គលទាំងនោះ។

**ប្រការ ១៤**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពនិងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៥**.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-០៦-២៤០ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការនៃគណនីទូទាត់

**ប្រកាស ១**.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សង់ប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួនដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេង៖

១ . **ធនាគារ** សំដៅដល់ធនាគារ ដូចមានចែងក្នុងមាត្រា ២ ច្បាប់ស្តីពីឧបករណ៍អាចជួយដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា។

២. **ការទូទាត់សងប្រាក់ធនាគារទ្វេភាគី** សំដៅដល់ការទូទាត់ពីធនាគារមួយផ្សេងទៀត។

៣. **ការទូទាត់** សំដៅដល់ការទូទាត់ចេញពី ឬចូលក្នុងគណនីទូទាត់។

៤. **ការទូទាត់សងប្រាក់ធនាគារតែមួយ** សំដៅការទូទាត់ប្រាក់រវាងធនាគារ និងធនាគារជាតិនៃកម្ពុជា

៥. **អ្នកដំណើរការតតិយភាគី** សំដៅដល់អ្នកផ្តល់មធ្យោបាយសម្រាប់ដំណើរការបញ្ជាទូទាត់ក្នុងនាមធនាគារ។

**ប្រកាស ២**.-

**១.** ការជាត់ទាត់និងការទូទាត់នឹងធ្វើរាល់ថ្ងៃធ្វើការ របស់ធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះដូរបញ្ជាទូទាត់ដែលពាក់ព័ន្ធនឹងការទូទាត់សងប្រាក់ធនាគារតែមួយ និងទ្វេភាគី។

**២.** ដើម្បីចូលរួមក្នុងការជាត់ទាត់និងការទូទាត់ បញ្ជាទូទាត់អន្តរធនាគារមួយនឹងឆ្លុះបញ្ចាំងពីប្រតិបត្តិការទូទាត់ក្នុងនាមអតិថិជនម្នាក់ ឬធនាគារចូលរួមមួយ។ បញ្ជាទូទាត់ដែលបានប្រគល់ដោយផ្ទាល់ពីអតិថិជនទៅអ្នកដំណើរការតតិយភាគីតាមការបញ្ជារបស់ធនាគារខ្លួន ត្រូវបានចាត់ទុកជាបញ្ជាទូទាត់ផ្ទាល់របស់ធនាគារដែលអនុវត្តតាមបញ្ជារបស់អតិថិជន។

**៣.** អ្នកចូលរួមក្នុងការជាត់ទាត់ និងការទូទាត់គឺជាធនាគារ។ ការទូទាត់អន្តរធនាគារនៃការជាត់ទាត់ធ្វើឡើងនៅលើគណនីទូទាត់របស់ធនាគារដែលអនុវត្តតាមបញ្ជាដែលរក្សានៅធនាគារជាតិនៃកម្ពុជា។

**៤.** ធនាគារត្រូវគោរពតាមប្រកាសនេះ និងនីតិវិធីប្រតិបត្តិការនានាក៏ដូចជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងប្រការជាបន្តបន្ទាប់ទៅនេះ។

**៥.** ប្រកាសនេះអនុវត្តតែចំពោះការផ្ទេរឥណទាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងគណនីទូទាត់ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ។

**ប្រការ ៣**.-

**១.** ដើម្បីអាចបញ្ចូលទៅក្នុងការទូទាត់បាន បញ្ជាទូទាត់នីមួយៗត្រូវតែសម្រាប់ការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគី និង/ឬ ចូលក្នុងគណនីទូទាត់។ បញ្ជាទូទាត់ត្រូវមានចែងសេចក្តីណែនាំដោយគ្មានលក្ខខណ្ឌនិងមិនអាចបដិសេធបានចំពោះការទូទាត់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ហើយមិនត្រូវស្ថិតនៅក្រោមការរឹតត្បិត ឬការដាក់កម្រិតណាឡើយ លើកលែងតែបញ្ជាទូទាត់នេះមានកំណត់ថ្ងៃប្រសិទ្ធភាព ដូចបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ។ បញ្ជាទូទាត់ត្រូវគោរពតាមលក្ខណៈជាក់លាក់ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ និងត្រូវបញ្ជូនទៅធនាគារណាមួយ ឬធនាគារជាតិនៃកម្ពុជា។

**២.** ក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ បញ្ជាទូទាត់ដែលគោរពតាមកថាខណ្ឌទី១ នៃប្រកាសនេះ នឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជា តាមការចុះឥណពន្ធនិង/ឬឥណទានក្នុងគណនីទូទាត់។ បញ្ជាទូទាត់ដែលមិនគោរពតាមថាខណ្ឌទី១ នៃប្រការនេះឬមិនអាចបញ្ជូនបានដោយសារទិន្នន័យមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ មិនអាចបញ្ជាក់យថាភូតបាន ឬហេតុផលផ្សេងទៀត ព្រមទាំងបញ្ជាទូទាត់នីមួយៗ ដែលបានផ្ញើខុសអាសយដ្ឋាន ត្រូវបញ្ជូនត្រឡប់ទៅធនាគារផ្ញើដោយអនុលោមតាមលេខកូដតែមួយដែលបានជ្រើសយកសម្រាប់ផ្ញើរត្រឡប់វិញនេះ ដែលផ្តល់ដោយធនាគារចូលរួមនីមួយៗ។

**ប្រការ ៤**.-

រាល់ធនាគារកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា ដែលមានបំណងចូលរួមការទូទាត់បញ្ជាទូទាត់ក្នុងស្រុក ត្រូវបើកនិងរក្សាគណនីទូទាត់ក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជា ហើយត្រូវបើកនិងដាក់ឱ្យដំណើរការនូវគណនីនោះតាមលក្ខខណ្ឌ និងការកំណត់ដូចដែលបានសម្រេចដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

**១-** ចំពោះរាល់ធនាគារ ការទូទាត់សងប្រាក់នីមួយៗដូចខាងក្រោមដែលផ្តើមឡើងដោយបញ្ជាទូទាត់អាចត្រូវបានធ្វើឡើងដោយបញ្ជូនទៅក្នុង និងដកចេញពីគណនីទូទាត់៖

**ក.** ការទូទាត់សងប្រាក់ធនាគារតែមួយ

**ខ.** ការទូទាត់សងប្រាក់ធនាគារទ្វេភាគី

២-ធនាគារជាតិនៃកម្ពុជានឹងមិនចុះឥណទានទូទាត់ ឬអនុញ្ញាតឱ្យដកសាច់ប្រាក់ចេញពីគណនីនេះទេ លុះត្រាតែមានសមតុល្យគ្រប់គ្រាន់ដើម្បីធានាចំនួនឥណទាន ឬការដកប្រាក់។

៣. ការទូទាត់សាច់ប្រាក់ធនាគារតែមួយ ដូចជាការដកសាច់ប្រាក់ ឬការដាក់ប្រាក់បញ្ញើនឹងត្រូវបានចុះកិច្ចបញ្ជិកាដោយធនាគារជាតិនៃកម្ពុជាទៅក្នុងគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ចេញពីគណនីទូទាត់របស់នៅធនាគារជាតិនៃកម្ពុជា ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធចំពោះគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ដោយធនាគារជាតិនៃកម្ពុជាចូលក្នុងគណនីទូទាត់ត្រូវធ្វើឡើងតាមរយៈការចុះឥណទានចំពោះគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ក្នុងធនាគារតែមួយនឹងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងអាចបដិសេធបាននៅពេលណាបានចុះកិច្ចបញ្ជិកាខ្ទង់ឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៤. ការទូទាត់សងប្រាក់ធនាគារទ្វេភាគីអាចផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់ទៅកាន់ធនាគារជាតិនៃកម្ពុជា ដើម្បីចុះឥណពន្ធគណនីទូទាត់សងប្រាក់ និងចុះឥណទានគណនីទូទាត់របស់ធនាគារមួយទៀត។ ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ និងចុះឥណទានព្រមគ្នាលើគណនីទូទាត់របស់ធនាគារមួយផ្សេងទៀត។ ការទូទាត់សងប្រាក់ធនាគារទ្វេភាគីនិងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និង មិនអាចបដិសេធបាន នៅពេលណាបានចុះបញ្ជិកាខ្ទង់ឥណពន្ធ និងឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៥. លិខិតបញ្ជាក់តាមរយៈការជូនដំណឹងការចុះកិច្ចបញ្ជិកាខ្ទង់ឥណពន្ធ ឬឥណទានទៅក្នុងគណនីទូទាត់នៅក្រោមកថាខណ្ឌនេះ ត្រូវធ្វើដោយធនាគារជាតិនៃកម្ពុជាទៅកាន់ធនាគារដែលចូលរួមនៅក្នុងការទូទាត់សង់ប្រាក់ធនាគារតែមួយ ឬទ្វេភាគីនោះ។ ការជូនដំណឹងត្រូវធ្វើឡើងភ្លាមបន្ទាប់ពីការបញ្ចប់ការផាត់ទាត់ប្រចាំថ្ងៃដូចដែលបានកំណត់ក្នុងនីតិវិធីប្រតិបត្តិការ។

៦. ខ្ទង់ឥណពន្ធចំពោះការដកសាច់ប្រាក់ដោយធនាគារ ត្រូវតែបានចុះកិច្ចបញ្ជិកាជាបន្ទាន់ដោយធនាគារជាតិនៃកម្ពុជា ទៅក្នុងគណនីទូទាត់របស់ធនាគារនោះភ្លាមបន្ទាប់ពីការដកសាច់ប្រាក់។

៧. ចំពោះរាល់ប្រតិបត្តិការទូទាត់សងប្រាក់ ការទូទាត់ត្រូវបានបញ្ចប់នៅពេលណាដែលលទ្ធផលនៃខ្ទង់ឥណពន្ធ ឬខ្ទង់ឥណទាននៃការទូទាត់នោះត្រូវបានចុះកិច្ចបញ្ជិកាគណនីទូទាត់របស់ធនាគារជាភាគីនៃការទូទាត់សងប្រាក់បានក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនបដិសេធបាន។

**ប្រការ ៦.-**

**១.** បញ្ជាទូទាត់ដែលបញ្ជាឱ្យធនាគារជាតិនៃកម្ពុជាអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគី អាចត្រូវបានប្រគល់ដោយធនាគារទៅឱ្យធនាគារជាតិនៃកម្ពុជា ជាបញ្ជាទូទាត់មួយៗដោយឡែក ឬជាផ្នែកនៃសំណុំមួយ។

**២.** ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តការទូទាត់ចំពោះបញ្ជាទូទាត់នីមួយៗ ដែលបានបញ្ជូនមក៖

- តែនៅពេលណាដែលគណនីទូទាត់ របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់ប៉ុណ្ណោះ និង
- នៅពេលណាមួយមុនពេលបញ្ចប់ការផាត់ទាត់ប្រចាំថ្ងៃ ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ។

ចំពោះបញ្ជាទូទាត់មានថ្ងៃប្រសិទ្ធភាពដូចដែលបានចែងក្នុងនីតិវិធីប្រតិបត្តិការ ពេលវេលានៃការអនុវត្តបញ្ជាទូទាត់នោះត្រូវតែនៅថ្ងៃប្រសិទ្ធភាព។

**៣.** នៅពេលណាដែលមូលនិធិនៃគណនីធនាគារទូទាត់សងប្រាក់ពុំមានគ្រប់គ្រាន់សម្រាប់ទូទាត់ ធនាគារជាតិនៃកម្ពុជាអាចបដិសេធ ឬដាក់បញ្ជាទូទាត់ឱ្យស្ថិតក្នុងការរង់ចាំ ហើយផ្តល់ដំណឹងដល់ធនាគារបញ្ជានោះ។ បញ្ជាទូទាត់ដែលបានដាក់ឱ្យស្ថិតក្នុងការរង់ចាំនឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជាទៅតាមលំដាប់នៃការរង់ចាំ និងដោយគ្មានការជូនដំណឹងជាមុន លុះត្រាតែគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់។ ធនាគារជាតិនៃកម្ពុជា អាចបដិសេធបញ្ជាទូទាត់នេះត្រូវបានអនុវត្តនៅពេលណាក៏បាន មុនពេលបញ្ជាទូទាត់នេះត្រូវបានអនុវត្ត ហើយនឹងផ្តល់ធនាគារបញ្ជានោះ។ បញ្ជាទូទាត់របស់ធនាគារដែលមិនត្រូវបានអនុវត្ត និងបដិសេធក្នុងអំឡុងពេលផាត់ទាត់ប្រចាំថ្ងៃនឹងត្រូវបានលុបចោលតាមការកំណត់ដោយច្បាប់នៅចុងបញ្ចប់នៃការផាត់ទាត់ប្រចាំថ្ងៃដូចមានចែងក្នុងនីតិវិធីប្រតិបត្តិការ។

**៤.** ចំពោះគោលបំណងនៃកថាខណ្ឌខាងលើនៅពេលណាមានមូលនិធិគ្រប់គ្រាន់សម្រាប់សំណុំបញ្ជាទូទាត់ ធនាគារជាតិនៃកម្ពុជាអាចចាត់ទុកបញ្ជាទូទាត់នីមួយៗក្នុងសំណុំនោះជាបញ្ជាទូទាត់ដែលបញ្ជូនមកដាច់ដោយឡែកៗពីគ្នា។ ធនាគារជាតិនៃកម្ពុជាត្រូវចាត់ចែងបញ្ជាទូទាត់នីមួយៗ នោះសម្រាប់អនុវត្តទៅតាមមូលនិធិដែលមានដោយការដាក់បន្តគ្នា ឬបដិសេធទៅតាមលំដាប់សមស្រប។

**៥.** លើកលែងតែមានការបដិសេធ ឬការដាក់ឱ្យស្ថិតក្នុងការរង់ចាំបន្តគ្នាដោយធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើ បញ្ជាទូទាត់របស់ធនាគារដែលបានប្រគល់ឱ្យធនាគារជាតិនៃកម្ពុជានឹងមិនអាចបដិសេធបាន និងលុបចោលបានដោយធនាគារនោះឡើយ។ ចំពោះបញ្ជាទូទាត់ដែល

ស្ថិតក្នុងការរង់ចាំ ការលុបចោលដោយធនាគារបញ្ជានឹងមានប្រសិទ្ធភាព លុះត្រាតែបានជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជាតាមរបៀប ពេលវេលា និងអនុលោមតាមវិធីដែលបានចែង និងអនុម័តដោយធនាគារជាតិនៃកម្ពុជាតែប៉ុណ្ណោះ ដែលបង្កលក្ខណៈឱ្យធនាគារជាតិនៃកម្ពុជាអាចចាត់វិធានការមុនការចុះឥណពន្ធគណនីទូទាត់របស់ធនាគារ។

**៦.** ធនាគារជាតិនៃកម្ពុជា ត្រូវបដិសេធចំពោះបញ្ជាទូទាត់ណាដែលគ្មានយថាភាពត្រឹមត្រូវ មិនមានព័ត៌មានលំអិតអំពីធនាគារឬអត្ថគាហកគ្រប់គ្រាន់ ឬល្មើសនឹងប្រកាសនេះ ឬប្រកាសស្តីពីនីតិវិធីប្រតិបត្តិ ឬបញ្ហាណាផ្សេងៗទៀត។

**៧.** បញ្ជាទូទាត់របស់ធនាគារដែលត្រូវបានលុបចោលឬបដិសេធមិនអាចយកមកអនុវត្តបានឡើយលើកលែងតែមានការបញ្ជាទូទាត់ថ្មីពីសំណាក់ធនាគារបញ្ជា។

**ប្រកាស ៧**.-

នីតិវិធីប្រតិបត្តិការអាចអនុញ្ញាតឱ្យធនាគារផ្ញើ ចាត់ថ្នាក់បញ្ជាទូទាត់មួយនៅក្រោមវិធាននេះជាការទូទាត់សងប្រាក់អាទិភាព។ ជាកម្មវត្ថុនៃការមានមូលនិធិក្នុងគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ធនគារជាតិនៃកម្ពុជានឹងព្យាយាមដំណើរការ ការទូទាត់សងប្រាក់អាទិភាពនេះនៅពេលបានទទួលបញ្ជាទូទាត់ដែលត្រូវបានចាត់ថ្នាក់នេះ។

**ប្រការ ៨**.-

**១.** ចំពោះការទូទាត់ប្រាក់ជំពាក់រវាងធនាគារនៅទីបញ្ចប់នៃវដ្តផាត់ទាត់ពហុភាគីអន្តរធនាគារ បញ្ជីអំពីស្ថានភាពឥណពន្ធនិងឥណទានរបស់ធនាគារនីមួយៗ ត្រូវប្រគល់ទៅឱ្យធនាគារជាតិនៃកម្ពុជាក្នុងនាមធនាគារចូលរួមទាំងអស់។ ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តការទូទាត់ដោយៈ

- ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយ ពីធនាគារដែលមានស្ថានភាពឥណទាននូវចំនួនប្រាក់ឥណពន្ធរបស់ធនាគារ និងបន្ទាប់មក
- ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយទៅឱ្យធនាគារដែលមានស្ថានភាពឥណទាន នូវចំនួនទឹកប្រាក់ឥណទានរបស់ធនាគារ។

គ្មានខ្ទង់ឥណពន្ធ ឬ ឥណទានចំពោះគណនីទូទាត់នៅក្រោមប្រការនេះនឹងក្លាយជាស្ថាពរមិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាននៅមុនពេលដែលរាល់ខ្ទង់ឥណពន្ធសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់ របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថានភាពឥណពន្ធ និងរាល់ខ្ទង់ឥណទានសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថានភាពឥណទានឡើយ។ ការទូទាត់សងប្រាក់ធនាគារតែមួយនៅក្រោមកថាខណ្ឌនោះអាច

ត្រូវបានធ្វើឡើង ដើម្បីបញ្ចូលឬទូទាត់ចេញពីគណនីហាមឃាត់ដែលបានរក្សានៅធនាគារជាតិនៃកម្ពុជា។

**២.** ធនាគារជាតិនៃកម្ពុជា មិនត្រូវអនុវត្តការទូទាត់ក្រោមកថាខណ្ឌទី១ទេ និងត្រូវស្វះស្វែងរកការបញ្ជាក់បន្ថែមដើម្បីបញ្ចប់ការទូទាត់ក្រោមកថាខណ្ឌទី១ លើកលែងតែ៖

**ក.** ធនាគារជាតិនៃកម្ពុជាបានធ្វើការបញ្ជាក់ដំបូងថា ចំនួនប្រាក់សរុបជំពាក់ដោយធនាគារទាំងអស់ក្នុងស្ថានភាពឥណពន្ធ ស្មើនឹងចំនួនប្រាក់សរុបជំពាក់ចំពោះធនាគារទាំងអស់ក្នុងស្ថានភាពឥណទាន និង

**ខ.** ចំពោះធនាគារដែលស្ថិតក្នុងស្ថានភាពឥណពន្ធ មូលនិធិមានចំនួនគ្រប់គ្រាន់សម្រាប់ទូទាត់ចេញពីគណនីទូទាត់ដើម្បីអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយក្នុងចំនួនប្រាក់ឥណពន្ធ។

**៣.** វិធានគ្រប់គ្រងការជាត់ទាត់ពហុភាគីអន្តរធនាគារដែលត្រូវបានទូទាត់នៅក្រោមប្រការនេះ រួមទាំងនីតិវិធីសម្រាប់ប្រើនៅពេលដែលមានការមិនគោរពតាមលក្ខខណ្ឌនានាក្រោមកថាខណ្ឌទី២ ខ ត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយការសម្របសម្រួលរវាងធនាគារចូលរួមដែលមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៩**.-

**១.** ធនាគារជាតិនៃកម្ពុជាអាចអនុម័តនីតិវិធីប្រតិបត្តិការ រួមទាំងការកំណត់លក្ខណៈជាក់លាក់សម្រាប់បញ្ហាទូទាត់តារាងពេលវេលា និងនីតិវិធីសម្រាប់គ្រប់គ្រងលើការជាត់ទាត់ និងការទូទាត់។

**២.** ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយជាបន្តបន្ទាប់ នូវតារាងកំរៃនិងសោហ៊ុយសេវានៅក្រោមប្រកាសនេះ។

**ប្រការ ១០**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានអង្គភាព និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១១**.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-០៨-១៨៦ ប្រ.ក

# ប្រកាស
# ស្តីពី
# មូលប្បទានប័ត្រស្តង់ដារ

## សម្រេច

**ប្រការ ១.-**

កំណត់ឱ្យមានការឯកភាពជាលក្ខណៈស្តង់ដារនូវមូលប្បទានប័ត្រដែលប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ ដើម្បីឱ្យការទូទាត់និងផាត់ទាត់អន្តរធនាគារប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។

**ប្រការ ២.-**

គ្រឹះស្ថានធនាគារត្រូវរៀបចំ និងបោះពុម្ពមូលប្បទានប័ត្រសម្រាប់ប្រើប្រាស់ ឬផ្តល់ជូនអតិថិជនរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារមាត្រា៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងឱ្យមានលក្ខណៈស្តង់ដារ ទាំងលេខកូដ ទំហំ និទ្ទេស ព្រមទាំងមានចារឹកតួលេខ និងសញ្ញាពិសេសដែលអាចអានបានដោយម៉ាស៊ីន ដូចមានចែងក្នុងសេចក្តីណែនាំស្តីពីលក្ខណៈស្តង់ដារនៃមូល-ប្បទានប័ត្រដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣.-**

ការប្រើប្រាស់មូលប្បទានប័ត្រស្តង់ដារនឹងចាប់ផ្តើមអនុវត្តក្រោយពីប្រកាសនេះចុះហត្ថលេខា ហើយបានប្រាំមួយខែ (៦ខែ)។ ក្នុងរយៈពេល៦ខែបន្ទាប់ពីថ្ងៃចុះហត្ថលេខានៃប្រកាសនេះ គ្រឹះស្ថានធនាគារត្រូវរៀបចំបោះពុម្ពមូលប្បទានប័ត្រស្តង់ដារដូចមានចែងក្នុងប្រការ២ ដើម្បីជំនួសមូលប្បទានប័ត្រដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

**ប្រការ ៤.-**

ប្រកាសលេខ ធ៥-០១-៦៥ ប្រក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០១ ស្តីពី ការដាក់ឱ្យប្រើប្រាស់មូល-ប្បទានប័ត្រថ្មី នឹងត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីថ្ងៃដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រស្តង់ដារតទៅ។

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ ដែលនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ**

ប្រកាសលេខ ធ៩-០៨-១៨៦ ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

# សេចក្តីណែនាំ
# ស្តីពី
# លក្ខណៈស្តង់ដារនៃមូលប្បទានប័ត្រ

ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារ អំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងព័ត៌មាននៅលើមូលប្បទានប័ត្រឱ្យមានលក្ខណៈស្តង់ដារដូចខាងក្រោមៈ

## ១- លក្ខណៈស្តង់ដារ

### ១.១. តម្រូវការខាងផ្នែកគតិយុត្ត

យោងតាមមាត្រាទី៤នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ មូលប្បទានប័ត្រ ដែលចេញផ្សាយអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬជាអក្សរបរទេស និងត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- ពាក្យថា **មូលប្បទានប័ត្រ** ដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ
- បញ្ជាដោយឥតលក្ខខណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ
- ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់
- កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់
- កាលបរិច្ឆេទ និងកន្លែងដែលមូលប្បទានប័ត្រត្រូវបានចេញ
- ហត្ថលេខារបស់បហារក ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានប័ត្រ

### ១.២. ទំហំមូលប្បទានប័ត្រ និងផ្ទៃសម្រាប់បន្ទាត់លេខកូដ

#### ១.២.១. ទំហំមូលប្បទានប័ត្រ

ការតម្រូវឱ្យទំហំមូលប្បទានប័ត្រមានលក្ខណៈស្តង់ដារ គឺដើម្បីសម្រួលដល់ការចេញផ្សាយ ការប្រើប្រាស់ ការទទួល ដំណើរការទូទាត់ និងការរក្សាទុកមូលប្បទានប័ត្រជាលក្ខណៈរូបវន្ត។ ទំហំមូលប្បទានប័ត្រស្តង់ដារ (ដោយមិនគិតបញ្ចូលគល់សន្លឹក) ត្រូវបានកំណត់ឱ្យមានបណ្តោយប្រវែង១៨០មម និងទទឹងប្រវែង៩០មម។

#### ១.២.២. សណ្ឋាននៃមូលប្បទានប័ត្រ

ផ្ទៃលាតសម្រាប់ធនាគារត្រូវស្ថិតនៅផ្នែកខាងក្រោមនៃមូលប្បទានប័ត្រ ដែលមានប្រវែង១៦មមពីគែម ខាងក្រោម និងមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានប័ត្រ។ ផ្នែកខាងមុខនិងខាងក្រោយនៃផ្ទៃលាត ដែលត្រូវបានរក្សាទុកសម្រាប់ដាក់លេខកូដត្រូវមានសណ្ឋានដូចគ្នាបេះបិទ។ ផ្នែកខាងមុខនៃផ្ទៃលាតនេះត្រូវបានប្រើសម្រាប់ចុះព័ត៌មានលំអិតរបស់មូលប្បទានប័ត្រដែលមានលក្ខណៈជាតួលេខ និងសញ្ញាពិសេសដោយប្រើពុម្ពអក្សរ E13B ដែលតម្រូវឱ្យចុះនៅលើបន្ទាត់លេខកូដ។ នៅលើផ្នែកខាងមុខ និងខាងក្រោយនៃផ្ទៃលាតមិនត្រូវមានសារធាតុគីមី ឬសញ្ញាអ្វីមួយដែលអាចធ្វើឱ្យរំខានដល់ការអានរបស់ម៉ាស៊ីនអានលេខកូដឡើយ។

**រូបភាព១: ទីតាំងផ្ទៃលាតនៅលើផ្នែកខាងមុខនិងខាងក្រោយនៃមូលប្បទានប័ត្រ**




## ១.៣. បន្ទាត់លេខកូដសម្រាប់ដំណើរការស្វ័យប្រវត្តិកម្ម

### ១.៣.១. ទីតាំងបោះពុម្ពបន្ទាត់លេខកូដ

បន្ទាត់លេខកូដត្រូវតែបោះពុម្ពតាមបណ្តោយផ្ទៃលាតលើផ្នែកខាងមុខនៃមូលប្បទានប័ត្រ។ ក្នុងករណីដែលផ្នែកខាងមុខនេះមិនអាចប្រើដើម្បីបោះពុម្ពលេខកូដនេះបាន ដោយសារតែខូច ឬមានការសរសេរជាន់គ្នា ឬការជំនួសតួលេខ នោះបន្ទាត់លេខកូដត្រូវតែបោះពុម្ពនៅលើផ្ទៃលាតនៃផ្នែកខាងក្រោយរបស់មូលប្បទានប័ត្រ។

### ១.៣.២. ពុម្ពអក្សរលើបន្ទាត់លេខកូដ

បន្ទាត់លេខកូដនេះត្រូវតែបោះពុម្ពដោយប្រើពុម្ពអក្សរ E13B ដើម្បីសម្រួលឱ្យម៉ាស៊ីនអានលេខកូដអាចអានតួលេខនិងសញ្ញាពិសេសបានលឿន និងត្រឹមត្រូវ។

### ១.៣.៣. ការការពារផ្ទៃលាតសម្រាប់ធនាគារ

នៅលើផ្នែកទាំងសងខាងនៃមូលប្បទានប្រ័តក្នុងផ្ទៃលាតសម្រាប់ធនាគារ មិនត្រូវមានការបោះពុម្ពដោយទឹកខ្មៅផ្សេងៗ ឬការរំលេចពណ៌ណាមួយ ដែលអាចប៉ះពាល់ដល់ការអានដោយស្វ័យប្រវត្តិទៅលើតួលេខ និង សញ្ញាពិសេស ដូចជា ការបោះពុម្ពរូបបណ្តុះ ការបោះពុម្ពផុស ឬសញ្ញាណាផ្សេងៗទៀត ក្រៅពីពុម្ពអក្សរ E13B ឡើយ។

### ១.៣.៤. ទីតាំងសម្រាប់បន្ទាត់លេខកូដ

បន្ទាត់លេខកូដត្រូវមានកម្ពស់ ៣,១៧៥មម ហើយត្រូវស្ថិតនៅខាងក្នុងនិងចំកណ្តាលនៃផ្ទៃលាតសម្រាប់ធនាគារ ព្រមទាំងត្រូវបានខណ្ឌផ្នែកខាងលើ និងខាងក្រោមដោយចន្លោះលាតពីរ ដែលមានទទឹងស្មើនឹង ១,៥៨៧៥មម។ ផ្ទៃបន្ទាត់លេខកូដបូកនឹងចន្លោះលាតទាំងពីរដែលស្ថិតនៅខាងលើនិងខាងក្រោម គឺជាផ្ទៃសម្រាប់ម៉ាស៊ីនអាន (Read Band) ។

ពុម្ពអក្សរ E13B ត្រូវតែបោះពុម្ពនៅក្នុងផ្ទៃបន្ទាត់លេខកូដតែប៉ុណ្ណោះ។

**រូបភាពទី ២: ផ្ទៃលាតសម្រាប់ធនាគារៈ ផ្ទៃសម្រាប់ម៉ាស៊ីនអាន និងបន្ទាត់លេខកូដ**




## ១.៤. ការកំណត់ទ្រង់ទ្រាយបន្ទាត់លេខកូដ

### ១.៤.១. ស្តង់ដារទូទៅ

បន្ទាត់លេខកូដស្តង់ដារនៃមូលប្បទានប័ត្ររបស់កម្ពុជា មានលក្ខណៈស្របតាមបន្ទាត់លេខកូដស្តង់ដារអន្តរជាតិ ដូចបានកំណត់ច្បាស់នៅក្នុងស្តង់ដារ ANSI X9[5] និង ISO[6]។

យោងតាមសេចក្តីកំណត់នៃស្តង់ដារ ទាំងនេះ

ទីតាំងដាក់លាក់នៃតួលេខនិងសញ្ញាពិសេសនៅក្នុងបន្ទាត់លេខកូដត្រូវបានដាក់លេខរៀងពីខាងស្តាំបំផុតនៃបន្ទាត់លេខកូដដោយផ្តើមពីលេខ១។ បន្ទាត់លេខកូដមិនត្រូវមានកន្លែងចុះទិន្នន័យលើសពីប្រាំ(៥) ហើយកន្លែងនីមួយៗមិនត្រូវមានតួលេខនិងសញ្ញាពិសេសលើសពី១៥តួឡើយ ។

**រូបភាពទី ៣: រចនាសម្ព័ន្ធបន្ទាត់លេខកូដនៃមូលប្បទានប័ត្រ**




### ១.៤.២. ការបោះពុម្ពបន្ទាត់លេខកូដនិងការកំណត់លេខកូដ

ទិន្នន័យទាំងឡាយ ដូចជាលេខមូលប្បទានប័ត្រ លេខកូដធនាគារនិងសាខា និងលេខគណនី ត្រូវតែបញ្ចូលដោយធនាគារដែលចេញផ្សាយមូលប្បទានប័ត្រ ដោយប្រើ Software សមស្រប និងត្រូវតែបោះពុម្ពជាស្រេចមុននឹងធ្វើការបែងចែកសៀវភៅមូលប្បទានប័ត្រទៅឱ្យអតិថិជន។

សញ្ញាពិសេសនៃទិន្នន័យនៅក្នុងក្រុមនីមួយៗ ត្រូវតែបោះពុម្ពក្នុងពេលជាមួយគ្នានឹងទិន្នន័យដែលនៅក្នុងក្រុមនោះ។ ឧទាហរណ៍ សញ្ញាពិសេសនៃចំនួនប្រាក់ត្រូវតែបោះពុម្ពក្នុងពេលជាមួយគ្នានឹងចំនួនប្រាក់។

---

[5] ANSI X9: American National Standard ស្តង់ដារលេខកូដសម្រាប់ប្រើក្នុងវិស័យហិរញ្ញវត្ថុដូចជា មូលប្បទានប័ត្រ ការផ្ទេរតាមអេឡិកត្រូនិក និងលេខសម្គាល់អត្តសញ្ញាណ (PIN).។

[6] ISO: Internatioanl Standard Organization ស្តង់ដារទទួលស្គាល់អន្តរជាតិ។

ពីខាងលើនិងខាងក្រោមនៃបន្ទាត់លេខកូដ ត្រូវមានបម្រុងទុកផ្ទៃទំនេរ ដើម្បីសម្រួលដល់ការពង្រីកដំណើរការនៃការផាត់ទាត់ក្នុងពេលអនាគត ដូចជាលេខកូដរបស់សភាផាត់ទាត់ជាដើម។ ប្រសិនបើមានការតម្រូវឱ្យបញ្ចូលលេខកូដ លេខកូដនោះត្រូវតែបោះពុម្ពនៅក្នុងកន្លែងដែលបានបម្រុងទុកនេះ។

ចំពោះកន្លែងចុះទិន្នន័យដែលនៅជាប់គ្នាហើយគ្មានចន្លោះទំនេររវាងកន្លែងទាំងនោះ លេខកូដត្រូវតែបញ្ចូលក្នុងពេលជាមួយគ្នា ដើម្បីជៀសវាងកំហុសឆ្គងនានាដោយសារតែលំអៀងនៃតួលេខ និងចន្លោះបន្ទាត់ដែលធ្វើឱ្យម៉ាស៊ីនអានលេខកូដមិនអាចអានពុម្ពអក្សរ E13B បានត្រឹមត្រូវ។

### ១.៤.៣. ទីតាំង និងកន្លែងចុះទិន្នន័យនៅក្នុងបន្ទាត់លេខកូដ

ទិន្នន័យនៅក្នុងបន្ទាត់លេខកូដត្រូវបានចែកចេញជាប្រាំផ្នែក ដោយរាប់ពីស្តាំទៅឆ្វេង។

#### ក. កន្លែងចុះចំនួនប្រាក់

កន្លែងចុះចំនួនប្រាក់មានតួលេខចំនួន១៥ខ្ទង់ និងមានសញ្ញាពិសេសចំនួន២ដែលប្រាប់ពីចំណុចផ្តើមនិង ចំណុចបញ្ចប់នៃកន្លែងចុះចំនួនប្រាក់។

- **ទីតាំងទី១:** មានសញ្ញាពិសេសចំនួន១ខ្ទង់ ដែលតាងដោយនិមិត្តសញ្ញា(⑇)សម្គាល់ឃ្នៀបបើកនៃចំនួនប្រាក់។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានប័ត្រទៅគែមខាងស្តាំនៃសញ្ញាពិសេសមានប្រវែង៨មម។
- **ទីតាំងទី២ ដល់១៦:** ចំនួនប្រាក់នៃមូលប្បទានប័ត្រជាដុល្លារ ឬជារៀល(ចំពោះមូលប្បទានប័ត្រជាដុល្លារ ខ្ទង់សេនមាន២ខ្ទង់ដែលស្ថិតនៅផ្នែកខាងស្តាំបំផុត ទោះបីជាមិនត្រូវចំណាយជាសេនក៏ដោយ)។
- **ទីតាំងទី១៧:** សញ្ញាពិសេសតំណាងដោយនិមិត្តសញ្ញា (⑇ ) សម្គាល់ឃ្នៀបបិទនៃចំនួនប្រាក់។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានប័ត្រ ទៅគែមខាងឆ្វេងនៃកន្លែងចុះចំនួនប្រាក់ ត្រូវមានប្រវែង ៦២មម។

ឧទាហរណ៍: ចំនួនប្រាក់ ៩៩.៩៨៨.៨០០,០០ រៀល
នៅលើបន្ទាត់លេខកូដមានទម្រង់ដូចខាងក្រោម:

⑇000000099988800⑇

<u>សម្គាល់</u> : ការកែតួលេខត្រូវធ្វើឡើងដោយក្រដាសកែតម្រូវដែលមានកម្រាស់មិនលើសពី ០,២៣មម ដាក់បិទភ្ជាប់នៅខាងខ្នងមូលប្បទានប័ត្រ ហើយតួលេខត្រូវតែចុះនៅលើក្រដាសបិទភ្ជាប់នេះតាមចំនួនប្រាក់ដែលត្រូវទូទាត់សង។

#### ខ. កន្លែងចុះលេខកូដប្រតិបត្តិការ

កន្លែងចុះលេខកូដប្រតិបត្តិការមានលេខ២ខ្ទង់ ដែលស្ថិតនៅខ្ទង់ទី១៩ និងខ្ទង់ទី២០ សម្រាប់សម្គាល់ប្រភេទរូបិយប័ណ្ណ:

- ០០: សម្រាប់មូលប្បទានប័ត្រជាប្រាក់រៀល
- ០១: សម្រាប់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក

<u>សម្គាល់:</u> គណៈកម្មាធិការទូទាត់នៃសមាគមធនាគារ អាចពិភាក្សាជាមួយសមាជិករបស់ខ្លួនលើការប្រើប្រាស់លេខកូដប្រតិបត្តិការទាំង២ខ្ទង់នេះសម្រាប់សម្គាល់ប្រភេទប្រតិបត្តិការទូទាត់ផ្សេងៗទៀតដូចជាប្រភេទ ប្រតិបត្តិការឥណពន្ធ ឬឥណទានជាដើម។

- **ទីតាំងទី១៨**: ជាចន្លោះទំនេរសម្រាប់ខណ្ឌកន្លែងចុះចំនួនប្រាក់ និងកន្លែងចុះលេខកូដប្រតិបត្តិការ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអានទិន្នន័យដោយស្វ័យប្រវត្តិឱ្យបានសុក្រិត។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានប័ត្រ ទៅគែមខាងស្តាំនៃកន្លែងចុះលេខកូដនេះ ត្រូវមានប្រវែង ៧១,៥មម។

ឧទាហរណ៍: ចំនួនប្រាក់ ៩៩.៩៨៨.៨០០,០០រៀល និងលេខកូដសម្គាល់ប្រភេទរូបិយប័ណ្ណដែលមូលប្បទានប័ត្រត្រូវទូទាត់សងមានបង្ហាញនៅលើបន្ទាត់លេខកូដដូចខាងក្រោម:

00 ⑇000000099988800⑇

### គ. កន្លែងចុះលេខគណនី

កន្លែងចុះលេខគណនីមានលេខ១២ខ្ទង់ ដែលស្ថិតនៅខ្ទង់ទី២២ ដល់ខ្ទង់ទី៣៣។ កន្លែងចុះលេខគណនីនេះមានសញ្ញាពិសេស(⑈) ដែលស្ថិតនៅខ្ទង់ទី២១ សម្រាប់សម្គាល់លេខគណនី។

ឧទាហរណ៍: លេខគណនី ១១១២២២៣៣៣៤៤៤ ក្នុងបន្ទាត់លេខកូដមានបង្ហាញដូចខាងក្រោម:

111222333444⑈00 ⑇000000099988800⑇

### ឃ. កន្លែងចុះលេខកូដធនាគារ និងសាខាធនាគារ

លេខកូដធនាគារនិងលេខកូដសាខាធនាគារ ត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណធនាគារឬសាខាធនាគារ ដែលផ្តើមប្រតិបត្តិការ និងធនាគារឬសាខាធនាគារគោលដៅ ។

កន្លែងចុះលេខនេះរួមមាន លេខកូដសម្គាល់ធនាគារចំនួន៣ខ្ទង់ លេខកូដសម្គាល់សាខាធនាគារចំនួន៣ខ្ទង់ ចន្លោះទំនេរចំនួន១ខ្ទង់ និងលេខកូដសម្រាប់ផ្ទៀងផ្ទាត់ចំនួន១ខ្ទង់ ព្រមទាំងមានសញ្ញាពិសេស (⑆)។

- ទីតាំងទី៣៤: ជាសញ្ញាពិសេស (⑆) ដែលជាឃ្នៀបបើកកន្លែងចុះលេខធនាគារ ឬសាខាធនាគារ
- ទីតាំងទី៣៥: ជាលេខកូដផ្ទៀងផ្ទាត់
- ទីតាំងទី៣៦: ជាចន្លោះទំនេរ
- ទីតាំងទី៣៧ ដល់៣៩: ជាលេខកូដសាខាធនាគារ
- ទីតាំងទី៤០: ជាសញ្ញាពិសេស (⑉)
- ទីតាំងទី ៤១ ដល់ ៤៣: ជាលេខកូដធនាគារ

ឧទាហរណ៍: លេខកូដធនាគារនិងលេខកូដសាខាធនាគារ និងលេខកូដផ្ទៀងផ្ទាត់ដែលត្រូវបានបញ្ចូលនៅក្នុងបន្ទាត់លេខកូដគឺ (១) លេខកូដធនាគារ = ១០០ (២) លេខកូដសាខាធនាគារ = ០០១ និង (៣) លេខកូដផ្ទៀងផ្ទាត់ = ៧

⑈100⑉001 7⑆111222333444⑈00 ⑇0000000999888800⑇

### ង. កន្លែងចុះលេខរៀងមូលប្បទានប័ត្រ

លេខមូលប្បទានប័ត្រមានចំនួន៦ខ្ទង់ ព្រមទាំងសញ្ញាឃ្នៀបបើកនិងបិទ(⑈)នៅអមសងខាង។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានប័ត្រទៅចុងខាងឆ្វេងនៃកន្លែងចុះលេខរៀងមូលប្បទានប័ត្រមានប្រវែង ១៧០មម។

ឧទាហរណ៍: លេខមូលប្បទានប័ត្រដែលដាក់នៅក្នុងបន្ទាត់លេខកូដគឺលេខ១។

⑈000001⑈100⑉001 7⑆111222333444⑈00 ⑇0000000999888800⑇

## ១.៤.៤. ទីតាំងជារូបវន្តនៃតួលេខនិងសញ្ញាពិសេស

ដើម្បីជាឯកសារយោងនិងដើម្បីសម្រួលដល់ការរៀបចំទីកន្លែង និងទីតាំងជារូបវន្តនៃតួលេខ និង សញ្ញាពិសេសរបស់លេខកូដដែលបោះពុម្ព និងកន្លែងចុះទិន្នន័យនានាត្រូវបានសង្ខេបក្នុងរូបភាព៤។

**រូបភាព៤: ទីតាំងសម្រាប់ចុះទិន្នន័យនីមួយៗនៅក្នុងបន្ទាត់លេខកូដ**




## ១.៤.៥. សេចក្តីលំអិតអំពីលក្ខណៈស្តង់ដារនៃប្រភេទតួលេខនិងសញ្ញាពិសេស E13B

លក្ខណៈស្តង់ដារនៃរូបរាង ទំហំ និងចរិតលក្ខណៈរបស់ពុម្ពអក្សរ E13B (តួលេខនិងសញ្ញាពិសេស) រួមទាំងលក្ខណៈមើលស្គាល់ដោយស្វ័យប្រវត្តិនៃពុម្ពអក្សរ E13B ផង ត្រូវតែបោះពុម្ពដើម្បីឱ្យអាចមើលឃើញច្បាស់។

### ក. គោលបំណងនិងការប្រើប្រាស់

ពុម្ពអក្សរនេះត្រូវបានប្រើជាអន្តរជាតិ ហើយត្រូវបានរៀបចំឡើងដើម្បីជៀសវាងនូវកំហុសឆ្គងក្នុងការបោះពុម្ព និងការអាន ព្រមទាំងដើម្បីសម្រួលដល់ដំណើរការស្វ័យប្រវត្តិកម្មនៃមូលប្បទានប័ត្រ ឬធ្វើជាឯកសារស្តង់ដារដទៃទៀត ជាពិសេសក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។

### ខ. រូបរាងនៃតួលេខ និងសញ្ញាពិសេស

ពុម្ពអក្សរ E13B ដែលប្រើសម្រាប់បោះពុម្ពក្នុងបន្ទាត់លេខកូដនៅលើមូលប្បទានប័ត្រមានចំនួន ១០តួជាលេខ និង ៤តួ ជាសញ្ញាពិសេស ដូចមានបង្ហាញដូចខាងក្រោម:

តួលេខ

| | | | |
|---|---|---|---|
| 1 | មួយ | 6 | ប្រាំមួយ |
| 2 | ពីរ | 7 | ប្រាំពីរ |
| 3 | បី | 8 | ប្រាំបី |
| 4 | បួន | 9 | ប្រាំបួន |
| 5 | ប្រាំ | 0 | សូន្យ |

សញ្ញាពិសេស

| | |
|---|---|
| ⑆ | ធនាគារ / សាខា |
| ⑇ | ចំនួនប្រាក់ |
| ⑈ | លេខគណនី |
| ⑉ | វញ្ញសញ្ញា (Dash) ឬ សហសញ្ញា (Hyphen) |

## ២- អនុសាសន៍អំពីមូលប្បទានប័ត្រស្តង់ដារ

### ២.១ ផ្ទៃខាងមុខនៃមូលប្បទានប័ត្រ

ផ្ទៃខាងមុខនៃមូលប្បទានប័ត្រត្រូវបានបែងចែកជាពីរផ្នែកៈ (១) ផ្ទៃលាតសម្រាប់ធនាគារ (២) សម្រាប់ធុរកិច្ច។ ព័ត៌មានដែលមាននៅក្នុងផ្នែកសម្រាប់ធុរកិច្ចត្រូវបានកំណត់ដោយតម្រូវការនៃផ្នែកគតិយុត្ត ដូចមានចែងដោយសង្ខេបក្នុងចំណុច១.១ ខាងលើ។

ការបញ្ជាក់លំអិតបន្ថែមចំពោះផ្ទៃដែលត្រូវប្រើប្រាស់ និងទីតាំងនៃព័ត៌មានផ្សេងៗមានជាអនុសាសន៍ដូចតទៅៈ

#### ២.១.១ ពណ៌ផ្ទៃខាងក្រោយ

ពណ៌ផ្ទៃខាងក្រោយនៅត្រង់កន្លែងសម្រាប់ធុរកិច្ច ត្រូវមានពណ៌សឬពណ៌ស្រាលដើម្បីឱ្យអាចមើលឃើញទិន្នន័យច្បាស់។ ពណ៌នៃផ្ទៃខាងក្រោយនិងការរំលេចពណ៌ត្រូវគោរពតាមលក្ខណៈ វិនិច្ឆ័យដូចខាងក្រោមៈ

(១) សម្រាប់ការបោះពុម្ព អុបសិត (offset) ដែលដាក់ពណ៌ដោយការបោះពុម្ពអុបសិត

សមាមាត្រជាភាគរយនៃការដាក់ពណ៌ក្នុងការបោះពុម្ពអុបសិតមិនត្រូវលើសពីចំនួនដូចខាងក្រោមនេះៈ

| ពណ៌ | | ការដាក់ពណ៌ក្នុងការបោះពុម្ពអុបសិត |
|---|---|---|
| លឿង | ( Yellow-Y ) | 100% |
| កំបោរ | ( Magenta-M ) | 20% |
| ខៀវទឹកសមុទ្រ | ( Cyan-C ) | 20% |
| ខ្មៅ | ( Black-B ) | 0 % |

(២) សម្រាប់ការបោះពុម្ពអុបសិត ឬការបោះពុម្ពផ្សេងទៀតដែលមិនមានការដាក់ពណ៌ដោយការបោះពុម្ព

ពណ៌នៃផ្ទៃខាងក្រោយនិងការរំលេចពណ៌ មិនត្រូវជិតជាងពណ៌លាយដែលអនុវត្តតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះពុម្ពដូចមានចែងក្នុងតារាងខាងលើចំណុច២.២.១ (១)។

**២.១.២ ទីតាំងចុះកាលបរិច្ឆេទ**

កន្លែងចុះកាលបរិច្ឆេទត្រូវស្ថិតនៅខាងលើផ្នែកខាងស្តាំ សម្គាល់ដោយបន្ទាត់ចុចៗដែលមានប្រវែង ៤៤មម ហើយចុងខាងស្តាំនៃបន្ទាត់ចុចៗនេះមានចម្ងាយ៦មម ពីគែមខាងស្តាំនៃមូលប្បទានប័ត្រ និងចម្ងាយ ៧៧មម ពីគែមខាងក្រោមនៃមូលប្បទានប័ត្រ។ ពាក្យថា "កាលបរិច្ឆេទ" ត្រូវស្ថិតនៅខាងឆ្វេង និងនៅស្មើនឹងបន្ទាត់ចុចៗដែលបញ្ជាក់ថាជាទីតាំងសម្រាប់ចុះកាលបរិច្ឆេទ។

**២.១.៣ ទីតាំងសម្រាប់ចុះចំនួនប្រាក់**

ទីតាំងសម្រាប់ចុះចំនួនប្រាក់ត្រូវស្ថិតនៅខាងក្រោមកន្លែងចុះកាលបរិច្ឆេទ។ ទីតាំងសម្រាប់ចុះចំនួនប្រាក់នេះជាប្រអប់រាងចតុកោណកែងដែលមានទទឹងប្រវែង១០មម និងបណ្តោយប្រវែង៦៧មម។ ចុងខាងស្តាំនៃ ប្រអប់នេះមានចម្ងាយ ៦មម ពីគែមខាងស្តាំ និងចម្ងាយ ៤៧មម ពីគែមខាងក្រោមនៃមូលប្បទានប័ត្រ។ នៅក្នុងប្រអប់នេះ ត្រូវមានអក្សរកូដសម្គាល់រូបិយប័ណ្ណជា "KHR" សម្រាប់មូលប្បទានប័ត្រដែលទូទាត់សងជាប្រាក់រៀល ឬជា "USD" សម្រាប់មូលប្បទានប័ត្រដែលទូទាត់សងជាប្រាក់ដុល្លារអាមេរិក ហើយអក្សរកូដសម្គាល់រូបិយប័ណ្ណនេះ ត្រូវស្ថិតនៅចម្ងាយ ៦មម ពីគែមខាងឆ្វេងនៃប្រអប់។

**២.១.៤ ទីតាំងសម្រាប់ចុះហត្ថលេខា**

ទីតាំងសម្រាប់ចុះហត្ថលេខាត្រូវស្ថិតនៅខាងក្រោមផ្នែកខាងស្តាំនៃមូលប្បទានប័ត្រ ដែលមានចម្ងាយ ៦មម ពីគែមខាងស្តាំនៃមូលប្បទានប័ត្រ និងចម្ងាយ ១០មម ពីខាងលើផ្ទៃលាតសម្រាប់ធនាគារ។ ការកំណត់ទីតាំងនេះគឺដើម្បីសម្រួលដល់ប្រព័ន្ធផ្ទៀងផ្ទាត់ហត្ថលេខាដោយស្វ័យប្រវត្តិ និងម៉ាស៊ីនអានលេខកូដ E13B ផងដែរ។

**២.១.៥ ឈ្មោះនិងអាសយដ្ឋានរបស់ធនាគារចេញផ្សាយមូលប្បទានប័ត្រ**

កន្លែងសម្រាប់ឈ្មោះនិងអាសយដ្ឋានរបស់ធនាគារចេញផ្សាយមូលប្បទានប័ត្រ (ឡូហ្គោរបស់ធនាគារនិងសាខា) ត្រូវស្ថិតនៅផ្នែកខាងលើជ្រុងខាងឆ្វេង ដែលមានបណ្តោយប្រវែង៤៨មម និងកម្ពស់ប្រវែង១៨មម ហើយមានចម្ងាយ ៦មម ពីគែមខាងឆ្វេង និងចម្ងាយ ៧២មម ពីគែមខាងក្រោមនៃមូលប្បទានប័ត្រ។

**២.១.៦ ឈ្មោះ (និងអាសយដ្ឋាន) របស់បហារីក**

កន្លែងសម្រាប់ឈ្មោះ (និងអាសយដ្ឋាន) របស់បហារីក ត្រូវស្ថិតនៅពីក្រោមផ្នែកខាងឆ្វេងនៃពាក្យ " ចំនួនប្រាក់ " នៃមូលប្បទានប័ត្រ។

គ្រឹះស្ថានធនាគារអាចដាក់ ឬមិនដាក់បញ្ចូលនូវអាសយដ្ឋានរបស់បហារីកនៅលើមូលប្បទានប័ត្រ។

## រូបភាព៥: លក្ខណៈលំអិតនៃមូលប្បទានប័ត្រគំរូ




## ២.២ ផ្នែកខាងខ្នងនៃមូលប្បទានប័ត្រ

ផ្នែកខាងខ្នងនៃមូលប្បទានប័ត្រត្រូវបានចែកចេញជាបីផ្នែកសំខាន់ៗ:

## រូបភាព៦: ផ្នែកខាងខ្នងនៃមូលប្បទានប័ត្រ




### ២.២.១ ផ្នែកទី១: ផ្ទៃលាតសម្រាប់ធនាគារ (Clear Band)

ផ្ទៃលាតនេះស្ថិតនៅផ្នែកខាងក្រោមបំផុតនៃមូលប្បទានប័ត្រ ដែលមានទទឹងប្រវែង១៦មមពីគែមខាងក្រោម និងមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានប័ត្រ។ ផ្ទៃលាតនេះមានទីតាំង និងទំហំស្មើនឹងផ្ទៃលាតសម្រាប់ធនាគារ ដែលស្ថិតនៅផ្ទៃខាងមុខមូលប្បទានប័ត្រដែរ។

### ២.២.២ ផ្នែកទី២: សម្រាប់ធនាគារនិងអតិថិជន

ផ្ទៃនៃផ្នែកនេះមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានប័ត្រ និងមានទទឹងប្រវែង ៧៤មម ចាប់ពីខាងលើនៃផ្ទៃលាតសម្រាប់ធនាគារដល់គែមខាងលើនៃមូលប្បទានប័ត្រ ដោយដកចេញនូវផ្ទៃសម្រាប់សភាផាត់ទាត់ដូចមានចែងក្នុងចំណុច ២.២.៣ ខាងក្រោម។

### ២.២.៣ ផ្នែកទី៣: សម្រាប់សភាផាត់ទាត់

ផ្ទៃនៃផ្នែកនេះស្ថិតនៅខាងលើជ្រុងខាងស្តាំដែលមានទទឹងប្រវែង ៤២មម និងបណ្តោយប្រវែង ៨៥មម។

ផ្នែកខាងក្រោយនៃមូលប្បទានប័ត្រអាចមានបន្ទាត់ខណ្ឌចែកផ្នែកនីមួយៗដែលមានដាក់អក្សរសម្គាល់ដោយពណ៌ស្រាលៗថា "សម្រាប់ធនាគារនិងអតិថិជន" និង "សម្រាប់សភាផាត់ទាត់"។

ការបោះពុម្ពត្រូវតែគោរពតាមការកំណត់ក្នុងចំណុច ២.២ នេះ ឬក៏អាចដាក់កំណត់សម្គាល់សម្រាប់បែងចែកផ្នែកនីមួយៗនៅលើក្របផ្នែកខាងក្នុងនៃសៀវភៅមូលប្បទានប័ត្រ។

## ៣- អនុសាសន៍លើការការពារការក្លែងបន្លំ

មូលប្បទានប័ត្រត្រូវមានលក្ខណៈពិសេសដែលអាចទប់ស្កាត់ការក្លែងបន្លំ និងការកែប្រែព័ត៌មានដូចខាងក្រោម:

### ៣.១ ក្រដាសបោះពុម្ពមូលប្បទានប័ត្រ

ក្រដាសប្រើសម្រាប់បោះពុម្ពមូលប្បទានប័ត្រត្រូវមានលក្ខណៈពិសេស និងប្រកបដោយគុណភាព។

### ៣.២ ការការពារការកែប្រែព័ត៌មាន

កន្លែងសម្រាប់ចុះព័ត៌មានសំខាន់ៗក្នុងមូលប្បទានប័ត្រដែលអាចជាកម្មវត្ថុនៃការកែប្រែ ដូចជាឈ្មោះបហារិត ចំនួនប្រាក់ត្រូវទូទាត់សង (ជាលេខនិងជាអក្សរ) ត្រូវតែបោះពុម្ពនៅពីលើពណ៌នៃផ្ទៃខាងក្រោយ ឬនៅពីលើពណ៌រំលេចដោយទឹកខ្មៅដែលមិនងាយរលុបដើម្បីការពារការកែប្រែ ដូចជាការប្រើទឹកខ្មៅពិសេសដែលនឹងអាចមើលឃើញដោយកាំរស្មីពណ៌ស្វាយ (អ៊ុលត្រាវីយូឡេ) ឬទឹកខ្មៅដែលមិនងាយរលុបបាត់បន្ទាប់ពីត្រូវបានលុប ឬ កែដោយទឹកលុប។ល។

### ៣.៣ ការការពារការថតចម្លងពណ៌ធម្មជាតិ

មូលប្បទានប័ត្រត្រូវបោះពុម្ពដោយប្រើបច្ចេកទេសពិសេស ដើម្បីការពារការក្លែងបន្លំដោយប្រើម៉ាស៊ីនថតចម្លងពណ៌ធម្មជាតិ។

គ្រឹះស្ថានធនាគារ ត្រូវកំណត់គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនចំពោះប្រតិបត្តិការមូលប្បទានប័ត្រ ។

## ៤- ការប្រើមូលប្បទានប័ត្រ

សេចក្តីណែនាំក្នុងការប្រើប្រាស់មូលប្បទានប័ត្រ ត្រូវតែបោះពុម្ពនៅលើក្របផ្នែកខាងក្នុងនៃសៀវភៅមូលប្បទានប័ត្រ និងត្រូវមានគោលការណ៍ណែនាំដូចខាងក្រោម ៖

ក- ទាំងផ្ទៃខាងមុខនិងផ្ទៃខាងក្រោយនៃផ្ទៃលាតសម្រាប់ធនាគារ មិនត្រូវមានសរសេរ ស្នាមកាត់ ឬរហែក ស្នាមបិទឬកិប ឬប្រឡាក់ជាតិគីមីផ្សេងៗ ដែលនាំឱ្យរំខានដល់ការអានរបស់ម៉ាស៊ីនអានលេខកូដឡើយ។

ខ- ការឆូតបន្ទាត់ ហត្ថលេខារបស់បហារីក ឬការបោះត្រាណាមួយ ឬចំណារ មិនត្រូវធ្វើឡើងនៅលើផ្នែកខាងក្រោមដែលជាផ្ទៃលាតសម្រាប់ធនាគារ ដែលប្រើសម្រាប់ចារឹកលេខកូដឡើយ។

គ- មិនត្រូវកោស ឬលុបតួលេខនិងសញ្ញាពិសេសនៅលើបន្ទាត់លេខកូដនៅក្នុងផ្ទៃលាតឡើយ។

ឃ- ដើម្បីកែប្រែព័ត៌មានណាមួយលើមូលប្បទានប័ត្រ អ្នកប្រើមូលប្បទានប័ត្រត្រូវគូសឆូតចោលព័ត៌មានទាំងមូល ហើយចុះហត្ថលេខារបស់ខ្លួននៅពីលើផ្នែកដែលត្រូវបានកែប្រែនោះ ជៀសវាងការប្រើទឹកលុប។

ង- ការប្រើប្រាស់ផ្នែកខាងខ្នងនៃមូលប្បទានប័ត្រ ត្រូវបានអនុញ្ញាតតែចំពោះផ្នែកសម្រាប់ធនាគារនិងអតិថិជនតែប៉ុណ្ណោះ។

ច- មិនត្រូវបត់ និងធ្វើឱ្យរហែកមូលប្បទានប័ត្រ ជាពិសេសនៅផ្នែកសម្រាប់បន្ទាត់លេខកូដ។

- ធនាគារត្រូវតែប្រាកដថាស្នាមចោះៗសម្រាប់ហែកសន្លឹកមូលប្បទានប័ត្រ ត្រូវបានធ្វើឡើងប្រកបដោយគុណភាពនិងគួរឱ្យទុកចិត្ត ដើម្បីសម្រួលឱ្យការហែកសន្លឹកមូលប្បទានប័ត្រចេញពីសៀវភៅមូលប្បទានប្រ័តធ្វើបានត្រឹមត្រូវ។
- ព័ត៌មានដែលសរសេរដោយដៃត្រូវតែច្បាស់និងអាចអានបានតាមដែលអាចធ្វើទៅបាន ព្រមទាំងត្រូវសរសេរដោយប្រើទឹកខ្មៅពណ៌ខ្មៅ ឬទឹកខ្មៅពណ៌ខៀវចាស់ដែលមិនរលុប។ ជៀសវាងការប្រើទឹកខ្មៅដែលមានលក្ខណៈចាំងពន្លឺ និងឧបករណ៍សរសេរដែលអាចលុបបានដូចជាខ្មៅដៃជាដើម។
- ព័ត៌មានដែលសរសេរដោយដៃត្រូវសរសេរបញ្ចូលឱ្យចំទីតាំងដែលបានកំណត់ដោយមិនទុកឱ្យមានសល់ចន្លោះទំនេរដែលធ្វើឱ្យអាចកែប្រែចំនួនប្រាក់ឡើយ ជាពិសេសចន្លោះពីសញ្ញាសម្គាល់រូបិយវត្ថុ និងចំនួនប្រាក់ជាតួលេខ។

---

ធ៩-០៨-១៨៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់លេខអត្តសញ្ញាណធនាគារ

## សម្រេច

**ប្រការ ១**.-

កំណត់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ ដើម្បីចារឹកលេខកូដធនាគារនៅលើមូលប្បទានប័ត្រ ដែលអាចអានបានដោយម៉ាស៊ីន ស្របតាមមូលប្បទានប័ត្រស្តង់ដារ។

គ្រប់មូលប្បទានប័ត្រទាំងអស់ ត្រូវតែចារឹកនូវលេខអត្តសញ្ញាណសម្រាប់សម្គាល់ដូចតទៅ:

ក- លេខកូដធនាគារដែលបោះផ្សាយមូលប្បទានប័ត្រ

ខ- លេខកូដសាខារបស់ធនាគារដែលចេញផ្សាយមូលប្បទានប័ត្រ និង

គ- លេខកូដផ្ទៀងផ្ទាត់ Check digit។




**ប្រការ ២**.-

លេខកូដសម្រាប់សម្គាល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដូចតទៅ៖

| ឈ្មោះគ្រឹះស្ថានធនាគារ | លេខកូដ |
|---|---|
| ធនាគារជាតិនៃកម្ពុជា | ១០០ |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ០០១ |
| ធនាគារកម្ពុជាពាណិជ្ជចំកាត់ | ០០៣ |
| ធនាគារកម្ពុជាសាធារណៈ ចំកាត់ | ០០៤ |
| ធនាគារកាណាឌីយ៉ា ក្រុមហ៊ុនអនាមិក | ០០៥ |
| ធនាគារក្រុងថៃ មហាជន សាខាភ្នំពេញ | ០០៩ |
| ធនាគារកម្ពុជាអាស៊ីចំកាត់ | ០១៦ |
| សាជីវកម្មធនាគារសឹង្ហបុរី ចំកាត់ | ០១៨ |
| ធនាគារមេយប៊ែង សាខាភ្នំពេញ | ០២០ |
| ធនាគារសហពាណិជ្ជ ក្រុមហ៊ុនអនាមិក | ០២៦ |
| ធនាគារ មេគង្គកម្ពុជា មហាជនទទួលខុសត្រូវមានកម្រិត | ០៣២ |
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | ០៣៦ |
| ធនាគារអភិវឌ្ឍជនបទ | ០៣៨ |

| | |
|---|---|
| ធនាគារពាណិជ្ជទី១ សាខាភ្នំពេញ | ០៤០ |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | ០៤១ |
| ធនាគារឯកទេស ប៉េង ហេង អេស អឹម អ៊ី | ០៤២ |
| ធនាគារវឌ្ឍនៈ | ០៤៣ |
| ធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់កម្ពុជា | ០៤៤ |
| ធនាគារឯកទេស វិនិយោគទី១ | ០៤៧ |
| ធនាគារ ខេមខូលីមីធីត | ០៥២ |
| ធនាគារ ស៊ិនហានខ្មែរ | ០៥៣ |
| ធនាគារ វី. អាយ . ភី | ០៥៤ |
| ធនាគារ វិនិយោគរុងរឿង | ០៥៥ |
| ធនាគារជប៉ុន ម៉ារូហាន់ | ០៥៦ |
| ធនាគារ ប៊ូយ៉ុង ខ្មែរ | ០៦១ |
| ធនាគារ ភ្នំពេញពាណិជ្ជ | ០៥៨ |
| ធនាគារ អូ. អេស. ខេ អិនដូឆាយណាលីមីធីត | ០៥៧ |
| ធនាគារ ខ្មែរយូញៀន | ០៥៩ |
| ធនាគារឯកទេស ប៊េស | ០៦០ |
| ធនាគារ អង្គរកាពីតាល់ | ០៦៣ |

**ប្រការ ៣.-**

ក- លេខកូដសម្រាប់សម្គាល់ទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជានៅតាមបណ្តាខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម ៖

| ឈ្មោះធនាគារ | លេខកូដ |
|---|---|
| ធនាគារជាតិនៃកម្ពុជា | ០០១ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកណ្តាល | ០០២ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម | ០០៣ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបាត់ដំបង | ០០៤ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រៃវែង | ០០៥ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តសៀមរាប | ០០៦ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ធំ | ០០៧ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តតាកែវ | ០០៨ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្វាយរៀង | ០០៩ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តពោធិ៍សាត់ | ០១០ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ឆ្នាំង | ០១១ |

| | |
|---|---|
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ស្ពឺ | ០១២ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពត | ០១៣ |
| សាខា ធនាគារជាតិនៃកម្ពុជា ក្រុងព្រះសីហនុ | ០១៤ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកោះកុង | ០១៥ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រះវិហារ | ០១៦ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តក្រចេះ | ០១៧ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តរតនគីរី | ០១៨ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តមណ្ឌលគីរី | ០១៩ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្ទឹងត្រែង | ០២០ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបន្ទាយមានជ័យ | ០២១ |
| សាខា ធនាគារជាតិនៃកម្ពុជា ក្រុងភ្នំពេញ | ០២៣ |

ខ- ចំពោះលេខកូដសម្គាល់សាខាគ្រឹះស្ថានធនាគារ នឹងត្រូវបានកំណត់ដោយសាមីគ្រឹះស្ថាននីមួយៗ ហើយសាមីគ្រឹះស្ថានត្រូវផ្ញើបញ្ជីលេខកូដសម្គាល់សាខារបស់ខ្លួនដែលបានកំណត់ហើយនោះមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

ចំពោះលេខកូដសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ និងសម្គាល់សាខាធនាគារជាតិនៃកម្ពុជា ដែលត្រូវបង្កើតថ្មី នឹងត្រូវបានកំណត់ដោយសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

លេខកូដផ្ទៀងផ្ទាត់ (Check digit) ត្រូវបានប្រើសម្រាប់ផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃលេខកូដអត្តសញ្ញាណធនាគារដែលចែងក្នុងប្រការ១។ វិធីសាស្ត្រដាក់លេខកូដផ្ទៀងផ្ទាត់នេះ នឹងត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

ក្នុងករណីមានការផ្លាស់ប្តូរទីតាំងសាខាគ្រឹះស្ថានធនាគារ ឬបង្កើតសាខាគ្រឹះស្ថានធនាគារបន្ថែមទៀត សាមីគ្រឹះស្ថានធនាគារត្រូវផ្តល់ដំណឹងជាមុនមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១០ ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីដែលសាខាគ្រឹះស្ថានធនាគារណាមួយបិទទ្វារបញ្ឈប់សកម្មភាពអាជីវកម្ម លេខកូដសាខាគ្រឹះស្ថានធនាគារនោះ មិនអនុញ្ញាតឱ្យយកទៅប្រើសម្រាប់សម្គាល់សាខាគ្រឹះស្ថានធនាគារដែលបើកថ្មីឡើយ។ សាខាគ្រឹះស្ថានធនាគារថ្មីត្រូវកំណត់លេខកូដថ្មី។

**ប្រការ ៧**.-

ការប្រើប្រាស់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារដូចមានចែងខាងលើ នឹងចាប់ផ្តើមអនុវត្តនៅពេលដែលមូលប្បទានប័ត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់។

**ប្រការ ៨**.-

លិខិតបទដ្ឋានទាំងឡាយណាដែលពាក់ព័ន្ធនឹងការដាក់លេខអត្តសញ្ញាណធនាគារ ត្រូវចាត់ទុកជា

និរាករណ៍ចាប់ពីថ្ងៃដែលមូលប្បទានប័ត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់មូលប័ត្រស្តង់ដារ
# របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ ១**.-

ដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រស្តង់ដារថ្មី ចំនួន០២ (ពីរ) ប្រភេទ គឺមូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងចារឹកជាប្រាក់ដុល្លាររអាមេរិក ជំនួសមូលប្បទានប័ត្រដែលកំពុងប្រើបច្ចុប្បន្ននេះ។

**ប្រការ ២**.-

មូលប្បទានប័ត្រស្តង់ដារថ្មីនេះ មានលក្ខណៈសម្គាល់ដូចតទៅ:

**១. លក្ខណៈទូទៅ**

ក. ទំហំមូលប្បទានប័ត្រមាន: បណ្តោយ ១៨០មម ទទឹង ៩០មម

ខ. ពណ៌នៃមូលប្បទានប័ត្រ:

- មូលប្បទានប័ត្រចារឹកជាប្រាក់រៀល មានពណ៌មាសស្រាល
- មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារ មានពណ៌មរកតស្រាល

គ. មូលប្បទានប័ត្រស្តង់ដាររបស់ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្តាល និងសាខាមានលក្ខណៈដូចគ្នាទាំងស្រុង លើកលែងតែអាសយដ្ឋានប៉ុណ្ណោះ។

**២. លក្ខណៈពិសេស**

សន្លឹកមូលប្បទានប័ត្រ ត្រូវបានបោះពុម្ពដោយក្រដាសពិសេស និងមានលក្ខណៈពិសេសដូចខាងក្រោម:

- មានរូបបណ្តុះ (Watermark) ជារូបផ្កាច័ន្ទគ្របកមូល ពង្រាយពាសពេញផ្ទៃក្រដាស
- លើផ្ទៃក្រដាសទាំងសងខាង មានរាយបង្កប់កំណាត់សសៃអំបោះពិសេស (Tissue) ចំនួនពីរប្រភេទ ក្នុងនោះមួយប្រភេទមើលឃើញមានពណ៌ទឹកក្រូច និងពណ៌បៃតង គ្មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយទេ និងមួយប្រភេទទៀតមើលមិនឃើញមានចំណាំងពន្លឺ ក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ទឹកក្រូច និងពណ៌បៃតង
- ផ្ទៃខាងឆ្វេងនៃមូលប្បទានប័ត្រ រួមទាំងសញ្ញាធនាគារផង (រូបធំព្រាលៗ) ត្រូវបានបោះពុម្ពដោយទឹកខ្មៅទិស្សមាន មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌មាស ចំពោះ

មូលប្បទានប័ត្រចារឹកជាប្រាក់រៀល មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌មរកត ចំពោះមូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

- ផ្នែកកណ្ដាលនៃផ្ទៃខាងស្ដាំរបស់សន្លឹកមូលប្បទានប័ត្រ ត្រង់ប្រអប់រាងបួនជ្រុងទ្រវែងទាំងពីរត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេស មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ស៊ីជម្ពូ

- គំនូសបន្ទាត់ទាំង ៦ កំណាត់លើមូលប្បទានប័ត្រ សុទ្ធតែត្រូវបានផ្គុំឡើងដោយអក្សរតូចល្អិត " NATIONAL BANK OF CAMBODIA" និង

- លេខមូលប្បទានប័ត្រ នៅជ្រុងលើខាងស្ដាំ ត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេសពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ។

**ប្រការ ៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងគ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤**.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៩-០១០-១៥០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន

## សម្រេច

**ប្រការ ១**.-

ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់ សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរ ឬអេឡិកត្រូនិក ដែលមានទម្រង់ជាការផ្ទេរឥណទាន។

បញ្ជាទូទាត់នេះនឹងត្រូវបានប្រើ ដើម្បីផ្ទេរប្រាក់ពីគណនីរបស់អ្នកសងប្រាក់ទៅគណនីរបស់អ្នកទទួលប្រាក់ដែលគណនីទាំងនេះអាចមាន ឬមិនមាននៅក្នុងធនាគារ ឬសាខាធនាគារជាមួយគ្នា។

**ប្រការ ២**.-

បញ្ជាទូទាត់ត្រូវបានប្រើជាឧបករណ៍ស្របច្បាប់ អនុលោមតាមមាត្រា ១៩៩, ២០០, ២០១ និង ២០២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។ បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានត្រូវបានរៀបចំឱ្យមានលក្ខណៈស្តង់ដារច្បាស់លាស់ និងគ្រប់គ្រាន់ អំពីទម្រង់ ទិន្នន័យ និងព័ត៌មានដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០១០-១៥០ ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

## លក្ខណៈស្តង់ដារនៃបញ្ជាទូទាត់

ទម្រង់ ទិន្នន័យ និងព័ត៌មានដែលត្រូវបំពេញនៅក្នុងបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាលាយលក្ខណ៍អក្សរ និងអេឡិកត្រូនិក ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានបី ដូចខាងក្រោមៈ

- SWIFT
- សារប័ណ្ណ (Card Message)
- មូលប្បទានប័ត្រស្តង់ដារ ដូចមានចែងនៅក្នុងប្រកាសលេខ ធ៩-០៨-១៨៦ និងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ១- តារាង ទិន្នន័យ និងព័ត៌មាននៃការផ្ទេរឥណទាន

| ឈ្មោះខ្លឹមសារ | ទម្រង់ខ្លឹមសារ | ការពន្យល់ |
|---|---|---|
| លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់ | ៦ ខ្ទង់ | លេខកូដតំណាងឱ្យ " ការផ្ទេរឥណទាន " (ជាកាតព្វកិច្ច) |
| កាលបរិច្ឆេទ | ៨ ខ្ទង់ | ថ្ងៃ-ខែ-ឆ្នាំ (00-00-0000) (ជាកាតព្វកិច្ច) |
| លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីអ្នកសងប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកសងប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកសងប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |
| ចំនួនប្រាក់ | ១៥ ខ្ទង់ | ១៥ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជា |

| | | |
|---|---|---|
| | | បន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| លេខកូដរូបិយប័ណ្ណ | ៣ ខ្ទង់ | ៣ខ្ទង់តំណាងឱ្យរូបិយប័ណ្ណ ឧទាហរណ៍ KHR ឬ USD (ជាកាតព្វកិច្ច) |
| លេខកូដសុវត្ថិភាព | ១៨ ខ្ទង់ | តំណាងឱ្យលេខកូដសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ (ម៉ាស៊ីនគណនាដោយស្វ័យប្រវត្តិ) |
| លេខសម្គាល់អត្តសញ្ញាណធនាគារទទួលការប្រាក់ | ៦ ខ្ទង់ | ៣ ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីរបស់អ្នកទទួលប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកទទួលប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកទទួលប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |

ធ៥-០៩-៦៣៨ ស.ជ.ណ

# សេចក្តីជូនដំណឹង
# អំពី
# ការកំណត់កំរៃសេវាផ្ទេរប្រាក់ទៅ-មកក្នុងប្រទេស
# តាមរយៈធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយស សូមជូនដំណឹងដល់អតិថិជនដែលបើកគណនីនៅធនាគារជាតិនៃកម្ពុជា ដែលមានតម្រូវការផ្ទេរប្រាក់តាមគណនីទៅ-មក រវាងនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិនៃកម្ពុជា ជ្រាបដូចខាងក្រោម៖

-អតិថិជនត្រូវធ្វើបញ្ជាផ្ទេរប្រាក់ (ដូចគំរូជូនភ្ជាប់) ដោយភ្ជាប់ជាមួយនូវមូលប្បទានប័ត្រដកប្រាក់ពីគណនីរបស់ខ្លួន។

-កំរៃសេវាត្រូវបានគិត ០.១០ % លើទឹកប្រាក់ផ្ទេរ ( មិនត្រូវបានគិតចំពោះការផ្ទេរថវិការដ្ឋ)

-កំរិតអប្បបរមា ១២.០០០ រៀល ឬ ៣ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ

-កំរិតអតិបរមា ៤.០០០.០០០ រៀល ឬ ១.០០០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ

កំរៃសេវាត្រូវបានគិតដោយធនាគារផ្តើមធ្វើប្រតិបត្តិការ អតិថិជនមិនមានការចំណាយកំរៃសេវានៅពេលទទួលប្រាក់ទៀតឡើយ។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩

**ទេសាភិបាល**

**ជា ចាន់តូ**

ធ៥-០៩-៨៦០ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ជម្រាបមក**

**លោក លោកស្រី អគ្គនាយកគ្រប់ធនាគារ**

**ជាសមាជិកសភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា**

**កម្មវត្ថុ** : **ការបង់កម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ**

**យោង** : វិធាន និងនីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោក-លោកស្រី អគ្គនាយកគ្រប់ធនាគារជាសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកឱ្យបានជ្រាបថា ដើម្បីឱ្យស្របតាមវិធាន និងនីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា ឧបសម្ព័ន្ធ៧ ស្តីពីការយកកម្រៃសេវាសភាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំណត់កម្រៃសេវាការងារផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ៣.២០០.០០០រៀល ក្នុង១ឆ្នាំ។

កម្រៃសេវាថ្មីនេះ នឹងត្រូវបានអនុវត្តពីឆ្នាំ២០១០ តទៅ រហូតដល់មានការជូនដំណឹងជាថ្មី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីអគ្គនាយក មេត្តាជ្រាប និងអនុវត្តតាមការគួរ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**អគ្គនាយក**

**គាល់ ណែអ៊ីម**

ធ៥-០១០-៤៨៦ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០

**ជម្រាបមក**

**លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាផាត់ទាត់**

**កម្មវត្ថុ:** ការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត

**យោង:** វិធាន និង នីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយលសូមជម្រាបជូន លោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាផាត់ទាត់ឱ្យបានជ្រាបថា ដើម្បីឱ្យស្របតាមវិធាន និងនីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា ឧបសម្ព័ន្ធ៧ ស្តីពីការយកកម្រៃសេវាសភាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំណត់យកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ៖

១- កម្រៃសេវាសភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ចំនួន ៣.២០០.០០០ រៀល ក្នុងមួយឆ្នាំ ដូចគ្នា។

២- ការផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ៨.០០០ រៀល ក្នុងមួយសន្លឹក ដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់នេះ នឹងចាប់អនុវត្តពីឆ្នាំ ២០១១ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាផាត់ទាត់ដើម្បីសហការអនុវត្ត។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

**តាល់ ណៃអ៊ីម**

ធ៥-០១១-១៣៦ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

**ជម្រាបមក**

**លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត**

**កម្មវត្ថុ** : ការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត

**យោង** : ចំណារឯកភាពរបស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោកនាយកសាខា ធនាគារជាតិនៃកម្ពុជាខេត្ត ឱ្យបានជ្រាបថា ដើម្បីជម្រុញ និងលើកទឹកចិត្តក្នុងការប្រើប្រាស់មូលប្បទានប័ត្រនៅតាមបណ្តាខេត្តឱ្យកាន់តែច្រើនថែមទៀតនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែសម្រួលការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ លើមូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ២.០០០.០០០ រៀល ក្នុងមួយឆ្នាំដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំនេះ នឹងចាប់អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាផាត់ទាត់ដើម្បីសហការអនុវត្ត។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយកបច្ចេកទេស**

**ឡូន សុខា**

ធ៥-០១១-០២៨៩ ស.ជ.ណ

# សេចក្តីជូនដំណឹងបន្ថែម
# លើការស្នើសុំផ្ទេរប្រាក់ទៅក្រៅប្រទេស
# តាមរយៈធនាគារជាតិនៃកម្ពុជា

យោងសេចក្តីជូនដំណឹងលេខ ធ៥-០៨-៥៦១ សជណ ចុះថ្ងៃទី១១ ខែ០៦ ឆ្នាំ២០០៨ ស្តីពី កម្រៃសេវាផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក លោកស្រី អគ្គនាយកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងអស់ដែលមានគណនីនៅធនាគារជាតិនៃកម្ពុជា ជ្រាបអំពីការកំណត់បន្ថែមសម្រាប់ប្រតិបត្តិការផ្ទេររូបិយប័ណ្ណដុល្លារអាមេរិកទៅក្រៅប្រទេស ដូចខាងក្រោម៖

**១-អំពីពេលវេលាទទួលឯកសារស្នើសុំផ្ទេរប្រាក់៖**

- ឯកសារស្នើសុំផ្ទេរប្រាក់មានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវ ច្បាស់លាស់ ដែលបានយកមកប្រគល់ដល់មន្ត្រីធនាគារជាតិនៃកម្ពុជាមុនម៉ោង ១១ ព្រឹក នឹងត្រូវបានចាត់ចែងធ្វើប្រតិបត្តិការក្នុងថ្ងៃ។
- ឯកសារស្នើសុំផ្ទេរប្រាក់មានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវ ច្បាស់លាស់ ដែលបានយកមកប្រគល់ដល់មន្ត្រីធនាគារជាតិនៃកម្ពុជាក្រោយម៉ោង១១ព្រឹក ត្រូវបានរក្សាទុកសម្រាប់ធ្វើប្រតិបត្តិការនាថ្ងៃធ្វើការបន្ទាប់។

**២-អំពីទំហំទឹកប្រាក់ស្នើសុំផ្ទេរ៖**

ករណីផ្ទេរប្រាក់ទៅគោលដៅតែមួយ លោក លោកស្រី អាចស្នើសុំផ្ទេរតាមទំហំទឹកប្រាក់នៃប្រតិបត្តិការជាក់ស្តែង។

**៣-អំពីថ្ងៃប្រសិទ្ធភាព (Value Date):**

- ករណីផ្ទេរប្រាក់ក្រោម ២០ លាន ដុល្លារអាមេរិក ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺមួយថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+1)។
- ករណីផ្ទេរប្រាក់ចាប់ពី ២០ លាន ដុល្លារអាមេរិក ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺពីរថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+2)។

ខ្លឹមសារដូចបានជម្រាបជូនខាងលើ ជាការបំពេញបន្ថែមសម្រាប់ការអនុវត្តប្រតិបត្តិការផ្ទេរប្រាក់។

សេចក្តីជូនដំណឹងបន្ថែមនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១

**អគ្គនាយកបច្ចេកទេស**

**ខួន សុខា**

ធ៧-០១១-២៤១ ប្រ.ក

# ប្រកាស
# ស្តីពី
# អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុសំដៅផ្តល់គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារ អាចធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ធនាគារដូចមានចែងក្នុងមាត្រា ២ ចំណុចទី១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមាត្រា៣៤ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគាររួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

គ្រឹះស្ថានផ្សេងទៀតដែលមានបំណងផ្តល់ឬកំពុងផ្តល់ផលិតផលភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌសម្រាប់ស្នើសុំអាជ្ញាប័ណ្ណត្រូវបានកំណត់ដោយប្រកាសដោយឡែក។

**ប្រការ ៣**.-

ភតិសន្យាហិរញ្ញវត្ថុ សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ៖

១. ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ។

២. ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដើម្បីជួលឲ្យភតិកៈ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់៖

១. ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបានឬមិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូលឬការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

២. ភតិកៈមានឬពុំមានជម្រើសឬក្រោយមកទទួលយកជម្រើសថាទិញឬបន្តជួលចលនវត្ថុមួយរយៈពេលបន្ថែមទៀត។

**ប្រការ ៤**.-

ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានបំណងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុត្រូវ៖

១. មានស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការរឹងមាំ អនុបាតសាធនភាព និងអនុបាតផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។
២. មានធនធានមនុស្ស និងសម្ភារៈគ្រប់គ្រាន់សម្រាប់ដំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។
៣. មានផែនការអាជីវកម្មច្បាស់លាស់ជាលាយលក្ខណ៍អក្សរសម្រាប់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាននោះ។

ផែនការនេះរួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

ក. គោលនយោបាយ និងនីតិវិធីសម្រាប់ប្រតិបត្តិការអាជីវកម្ម
ខ. សេចក្ដីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរាយការណ៍សមស្រប។

សេចក្ដីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងហោចណាស់ត្រូវមាន៖

- ការវាយតម្លៃពីលំហូរសាច់ប្រាក់
- ប្រព័ន្ធវិភាគឥណទាន នីតិវិធីកំណត់កម្រិតឥណទានអតិថិជន និងនីតិវិធីកំណត់ប្រាក់កក់ និងកម្រៃផ្សេងៗ
- នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជា ការទិញចលនវត្ថុ អ្នកផ្គត់ផ្គង់ ការគ្រប់គ្រងចលនវត្ថុដែលរឹបអូស ការតាមដាន និងត្រួតពិនិត្យចលនវត្ថុ ការវាយតម្លៃនៃតម្លៃសេសសល់របស់ចលនវត្ថុ និង
- ឯកទេសកម្ម និងការប្រមូលផ្ដុំសមស្រប។

**ប្រការ ៥**.-

ចលនវត្ថុសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុសំដៅដល់ទ្រព្យសម្បត្តិគ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែ ដី និងអគារ។

លុះត្រាតែមានច្បាប់ ឬកិច្ចព្រមព្រៀងចែងផ្សេងពីនេះ ចលនវត្ថុដែលត្រូវបានភ្ជាប់ ឬត្រូវបានតម្លើងនៅក្នុងអគារ ឬលើដី ឬចលនវត្ថុដទៃទៀត ត្រូវរក្សាអត្តសញ្ញាណដាច់ដោយឡែករបស់ខ្លួន និងមិនក្លាយទៅជាចំណែកនៃដី ឬអគារ ឬចលនវត្ថុដទៃទៀតដែលត្រូវបានភ្ជាប់ជាមួយនោះទេ។

**ប្រការ ៦**.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡាគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

ធ៧-០១១-២៤២ ប្រ.ក

# ប្រកាស
# ស្ដីពី
# ការផ្ដល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដោយកំណត់លក្ខខណ្ឌក្នុងការផ្ដល់អាជ្ញាបណ្ណនិងដាក់បទប្បញ្ញត្តិចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះ គ្របដណ្ដប់លើប្រតិបត្តិការរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាគ្រឹះស្ថានដែលធ្វើតែអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប៉ុណ្ណោះ។

### ប្រការ ៣.- ដើមទុនចុះបញ្ជី

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយដើមទុនចុះបញ្ជីនេះត្រូវតែជាដើមទុនបង់ជម្រះ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

### ប្រការ ៤.- ការដាក់ពាក្យសុំអាជ្ញាបណ្ណ

១. គ្មានបុគ្គលណាម្នាក់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

២. ពាក្យសុំអាជ្ញាបណ្ណត្រូវធ្វើឡើងដោយបុគ្គល ដែលមានសិទ្ធិអំណាចនៅក្នុងក្រុមហ៊ុន (នាយកគ្រប់គ្រង ឬបុគ្គលដែលត្រូវបានផ្ដល់សិទ្ធិអំណាច) និងបង្ហាញព័ត៌មានដូចខាងក្រោម៖

- ក. កិច្ចព្រមព្រៀងចូលភាគហ៊ុន ឬកិច្ចព្រមព្រៀងរបស់ភាគទុនិក
- ខ. នាម ឬនាមករណ៍របស់ក្រុមហ៊ុន
- គ. អាសយដ្ឋាននៃទីស្នាក់ការកណ្ដាល ឬសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស
- ឃ. រូបភាពគតិយុត្ត និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬឯកសារផ្សេងទៀត
- ង. ប្រភេទមូលបត្រតំណាងឲ្យដើមទុន និងទំនាក់ទំនងរវាងការកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិបោះឆ្នោត

ច. ចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបោះផ្សាយ និងដើមទុនបង់ជម្រះ

ឆ. ការបែងចែងភាគហ៊ុន សិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀង ដែលអាចមានរវាងភាគទុនិកដែលធ្វើសកម្មភាពក្នុងការដឹកនាំគោលនយោបាយរបស់ក្រុមហ៊ុន

ជ. ភាគទុនិកដែលកាន់កាប់៥% (ប្រាំភាគរយ) នៃសិទ្ធិបោះឆ្នោត ឬលើស ត្រូវផ្តល់ព័ត៌មានដូចមាន រៀបរាប់នៅក្នុងប្រការ ១៣ នៃប្រកាសនេះ។

ឈ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច១រូប (មួយរូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានតាមឧបសម្ព័ន្ធ២ ព្រមទាំងមានបញ្ជាក់លិខិតថ្កោលទោសមួយច្បាប់ផង

ញ. អត្តសញ្ញាណរបស់បុគ្គលទទួលខុសត្រូវក្នុងការចេញសេចក្តីសម្រេច។ បុគ្គលនោះត្រូវបំពេញប្រវត្តិរូប និងបញ្ជាក់ថាខ្លួនមិនត្រូវបានហាមឃាត់នៅក្នុងប្រការ១៤នៃប្រកាសនេះទេ។ បុគ្គលនោះត្រូវមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មភតិសន្យានិងឥណទានយ៉ាងតិច៣ឆ្នាំ (បីឆ្នាំ)

ដ. ប្រសិនបើនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនេះ ជាក្រុមហ៊ុនដែលបានបង្កើតរួចហើយ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីអាជីវកម្ម ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុបញ្ជាក់ដោយស្នងការគណនី សម្រាប់ប្រតិបត្តិការរយៈពេល៣ឆ្នាំ (បីឆ្នាំ)

ឌ. ភស្តុតាងសមស្របផ្សេងទៀត ដូចជា៖

- ដំណើរការគ្រប់គ្រងហានិភ័យ ដូចជា ការកំណត់អត្តសញ្ញាណ ការវាស់វែង ការតាមដាន និងត្រួតពិនិត្យហានិភ័យ
- ផែនការគ្រប់គ្រង៖
  - ហានិភ័យសន្ទនីយភាព អត្រាការប្រាក់ និងកាលវសាន្ត (ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម)
  - ហានិភ័យឥណទាន
  - ហានិភ័យប្រតិបត្តិការ
  - ហានិភ័យទីផ្សារ
  - ហានិភ័យទ្រព្យសកម្ម
  - ហានិភ័យឯកសារ (Documentation Risk)
  - ហានិភ័យប្រមូលផ្តុំ (Concentration Risk)
  - ហានិភ័យដទៃទៀត ដែលអាចកើតមានចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅពេលធ្វើប្រតិបត្តិការភតិសន្យាតាមផែនការអាជីវកម្ម។

**ប្រការ ៥.- សំណើសុំផ្លាស់ប្តូរព័ត៌មាន**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា ដូចជា៖

ក . ការផ្លាស់ប្តូរនាមករណ៍

ខ. ការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុន

គ. ការកែប្រែវិសាលភាពអាជីវកម្ម

ឃ .ការផ្លាស់ប្តូរដើមទុនចុះបញ្ជី

ង. ការកែប្រែលក្ខន្តិកៈ

ច. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

ឆ. ការផ្លាស់ប្តូរអភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់

ជ. ការរួមបញ្ចូល ឬការបែងចែកឬ

ឈ.បញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៣
## អនុមតិផ្តល់អាជ្ញាបណ្ណ និង ការយកកំរៃ

### ប្រការ ៦.- ការផ្តល់លិខិតអនុញ្ញាតជាគោលការណ៍

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេល ៣ខែ(បីខែ) ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។ ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់លក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើពុំបានអនុវត្តតាមពេលវេលាកំណត់ ឬពុំបានសុំពន្យារពេល លិខិតអនុញ្ញាតនោះត្រូវចាត់ទុកជាមោឃៈ។

### ប្រការ៧.- អនុមតិផ្តល់អាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ជាមុនសិន មុននឹងទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

### ប្រការ៨.- សុពលភាពនៃអាជ្ញាបណ្ណ

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានសុពលភាពរយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) ហើយអាចសុំបន្តជាថ្មីទៀតបាន។

### ប្រការ៩.- សោហ៊ុយសិក្សាឯកសារ និងសោហ៊ុយអាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់សោហ៊ុយសិក្សាឯកសារចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំដូចខាងក្រោម៖

- ៤.០០០.០០០រៀល (បួនលានរៀល) សម្រាប់ស្នាក់ការកណ្តាល
- ២.០០០.០០០រៀល (ពីរលានរៀល) ក្នុងមួយសាខា។

សម្រាប់ក្រុមហ៊ុនដែលបង្កើតនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបង់តាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

## ជំពូកទី ៤
## វិធានប្រុងប្រយ័ត្ន

### ប្រការ១០.- ការបង់ដើមទុន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់ជម្រះ ១០០% (មួយរយភាគរយ) នៃដើមទុនចុះបញ្ជីទៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមប្រតិបត្តិការ។

ក្រុមហ៊ុនត្រូវតម្កល់ប្រាក់ចំនួន៥% (ប្រាំភាគរយ) នៃដើមទុនចុះបញ្ជី ដោយគ្មានការប្រាក់នៅក្នុងគណនីអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជានឹងប្រគល់ប្រាក់តម្កល់ឲ្យក្រុមហ៊ុនវិញ តែក្នុងករណីជម្រះបញ្ជី និងគ្មានបំណុល។

**ប្រការ ១១.- ភាតព្វកិច្ចរាយការណ៍**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមកាតព្វកិច្ចរាយការណ៍ ដូចខាងក្រោម :

១. ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ស្របតាមស្តង់ដារគណនេយ្យសម្រាប់អាជីវកម្មសហគ្រាស និងបញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍តុល្យការ របាយការណ៍ចំណូលនិងចំណាយ និងរបាយការណ៍ដទៃទៀតតាមតម្រូវការរបស់អាជ្ញាធរត្រួតពិនិត្យ។ តំណាងស្របច្បាប់ និងអ្នកទទួលខុសត្រូវដទៃទៀតនៃក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

៣. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) ដំបូងនៃខែបន្ទាប់។

៤. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍សវនកម្មប្រចាំឆ្នាំ បញ្ជាក់ដោយសវនករដែលបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល៤ខែ (បួនខែ) ដំបូងនៃឆ្នាំបន្ទាប់។

**ប្រការ ១២.- បទប្បញ្ញត្តិប្រុងប្រយ័ត្ន**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៥
## រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

**ប្រការ ១៣.- ភាគទុនិក**

ភាគទុនិកត្រូវផ្តល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក :

ក. ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាននៃស្នាក់ការកណ្តាល របាយការណ៍សវនកម្មហិរញ្ញវត្ថុ លក្ខន្តិកៈ និងព័ត៌មានផ្សេងទៀតដែលតម្រូវដោយអាជ្ញាធរត្រួតពិនិត្យ

ខ. ក្នុងករណីជារូបវន្តបុគ្គល ត្រូវរៀបរាប់ គោត្តនាម នាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត ដោយរៀបរាប់លំអិតអំពីនីតិវិធីនៃការទិញភាគហ៊ុន។ ប្រសិនបើភាគទុនិកជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមនៃទុនវិនិយោគ។

៣. ការបញ្ជាក់ពីចំនួនភាគរយនៃភាគហ៊ុនដែលកាន់កាប់ដោយភាគទុនិកម្នាក់ៗ ក្នុងករណីចាំបាច់ភាគទុនិកត្រូវ :

ក. រៀបរាប់អំពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនហូលឌីង (Intermediate Holding Companies) ដោយផ្តល់ជាភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត

ខ. ធ្វើបញ្ជីអ្នកគ្រប់គ្រងសំខាន់ៗដែលជាភាគទុនិក។

៤. ប្រសិនបើភាគទុនិកនោះជាផ្នែកនៃសម្ព័ន្ធមួយ ភាគទុនិកត្រូវ :

ក. រៀបរាប់អំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ រួមជាមួយអង្គការលេខផង

ខ. បញ្ជាក់អំពីចំនួនភាគហ៊ុននៅក្នុងគ្រឹះស្ថានឥណទានផ្សេងទៀត ទាំងនៅក្នុងប្រទេស និងនៅបរទេស។

៥. ចំណងទាក់ទងរវាងភាគទុនិក និងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៦. នីតិវិធីសវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅរបស់ភាគទុនិក។

៧. សាវតារនៃអំពើល្មើសរបស់ភាគទុនិកក្នុងរយៈពេល១០ឆ្នាំ (ដប់ឆ្នាំ)កន្លងមក ប្រសិនបើមាន។

៨. គោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងក្រុមហ៊ុន ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ។

៩. ទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិក និងអ្នកដាក់ពាក្យស្នើសុំ។

១០.ទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងភតិសន្យាហិរញ្ញវត្ថុរបស់ភាគទុនិកនៅព្រះរាជាណាចក្រកម្ពុជា។

១១.គណនីរបស់ភាគទុនិក ឬក្រុមហ៊ុនមេរបស់ខ្លួន សំរាប់រយៈពេល៣ឆ្នាំ (បីឆ្នាំ) ចុងក្រោយព្រមទាំងព្យាករណ៍សំរាប់ឆ្នាំនេះ (រួមមានព័ត៌មានគួបសរុបផង ប្រសិនបើមាន)។ ក្នុងករណីភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

១២.អភិបាលកិច្ចក្រុមហ៊ុន (រចនាសម្ព័ន្ធចាត់តាំង សន្និបាតប្រចាំឆ្នាំរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាត្រួតពិនិត្យ និងនាយកជាន់ខ្ពស់) ដោយបែងចែកភារកិច្ចឲ្យបានច្បាស់លាស់ ធានាប្រតិបត្តិការដោយឯករាជ្យ និងប្រព័ន្ធត្រួតពិនិត្យមានតម្លាភាព ព្រមទាំងបង្កើតយន្តការគោលនយោបាយប្រកបដោយប្រសិទ្ធភាព យន្តការលើកទឹកចិត្ត និងរក្សាបុគ្គលិក។

១៣.គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

## ប្រការ ១៤.- សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល និងនាយក

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាត្រួតពិនិត្យ ឬនាយករបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬដឹកនាំ គ្រប់គ្រង ឬដំណើរការក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទៈ

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- គ្រប់គ្រងមិនបានត្រឹមត្រូវក្នុងតួនាទីខ្លួនជាអ្នករក្សាប្រាក់បញ្ញើ
- គៃបន្លំមូលនិធិ ឬមូលបត្រ ឬទ្រព្យធន
- ធ្វើព្រឹទ្ធិកម្ម

- ការសម្អាតប្រាក់

- ក្លែងឬ/និងប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់។

៣. ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលមានចែងនៅក្នុងចំណុច១ និង២ ខាងលើ។

៤. ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្ស័យធន ឬការជម្រះបំណុលតាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ។

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ។

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាបណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល និងនាយកដែលត្រូវបានតែងតាំង ត្រូវផ្តល់ព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

## ជំពូកទី ៦
## វិធានការ និង ការពិន័យ

### ប្រការ ១៥.- សិទ្ធិអំណាចរបស់អាជ្ញាធរត្រួតពិនិត្យ

១. ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការផ្តល់ ព្យួរ ដកហូតអាជ្ញាបណ្ណ ដាក់បទប្បញ្ញត្តិ បទបញ្ជា និងការណែនាំសម្រាប់ត្រួតពិនិត្យ អាជីវកម្មរបស់ក្រុមហ៊ុន តាមការចាំបាច់។

២. ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាបណ្ណ ដោយផ្អែកលើមូលហេតុមួយ ឬច្រើន ដូចខាងក្រោម:

ក. ក្រុមហ៊ុនមិនបានចាប់ផ្តើមអាជីវកម្មក្នុងកំឡុងពេលបីខែ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណ

ខ. ក្រុមហ៊ុនបំពានច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្រប់គ្រងលើប្រតិបត្តិការក្រុមហ៊ុន

គ. ក្រុមហ៊ុនមិនអាចប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ឃ. ក្រុមហ៊ុនផ្អាកអាជីវកម្មភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា

ង.ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីអាជ្ញាធរត្រួតពិនិត្យ

ច. ក្រុមហ៊ុនអសាធនភាព ឬក្ស័យធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬក្នុងដំណាក់កាលតែងតាំងអភិបាលបណ្តោះអាសន្នតាមផ្លូវតុលាការ។

## ប្រការ ១៦.- វិធានការចំពោះក្រុមហ៊ុន

១. ក្នុងករណីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានប្រព្រឹត្តល្មើសនឹងច្បាប់ភតិសន្យាហិរញ្ញវត្ថុ ឬបទប្បញ្ញត្តិជាធរមាន ធនាគារជាតិនៃកម្ពុជានឹងដាក់ទណ្ឌកម្មខាងវិន័យចំពោះក្រុមហ៊ុននោះយោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។

២. ប្រសិនបើក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជា អាចចាត់វិធានការកែតម្រូវក្នុងរយៈពេលកំណត់មួយ។ ក្នុងករណីក្រុមហ៊ុនមិនអាចអនុវត្តបានតាមពេលកំណត់ ឬសកម្មភាពរបស់ក្រុមហ៊ុនអាចប៉ះពាល់ដល់ស្ថិរភាពប្រតិបត្តិការ ឬប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់អតិថិជន ធនាគារជាតិនៃកម្ពុជានឹងចាត់វិធានការ ដូចជា ផ្អាកដំណើរការអាជីវកម្ម និងកំណត់សិទ្ធិរបស់ភាគទុនិក ជាដើម ផ្អែកទៅលើស្ថានភាពជាក់ស្តែង និងស្របតាមបទប្បញ្ញត្តិជាធរមាន។

## ប្រការ ១៧.- ពិន័យអន្តរការណ៍

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលមិនបានគោរពតាមកាលកំណត់នៃការបញ្ជូនរបាយការណ៍នឹងត្រូវពិន័យដូចខាងក្រោម៖

ក. ចំពោះរបាយការណ៍៖

| <u>ចំនួនថ្ងៃដែលយឺតយ៉ាវ</u> | <u>ចំនួនទឹកប្រាក់</u> |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ១១ទៅ ១៥ ថ្ងៃ | ៧០០.០០០ រៀល (ប្រាំពីររយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១៦ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

ខ.ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ ៖

| <u>ចំនួនថ្ងៃដែលយឺតយ៉ាវ</u> | <u>ចំនួនទឹកប្រាក់</u> |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១១ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

២. ការល្មើសនឹងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យទឹកប្រាក់ ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

# ជំពូកទី ៧
# អវសានប្បញ្ញត្តិ

**ប្រការ ១៨**.-

បុគ្គល ឬក្រុមហ៊ុនដែលបាន និងកំពុងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុដោយមិនមានអាជ្ញាបណ្ណ ត្រូវស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៦ខែ (ប្រាំមួយខែ) គិតចាប់ពីថ្ងៃដែលប្រកាសនេះ ចូលជាធរមាន។

**ប្រការ ១៩**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២០**.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធទី ១**

**គំរូលិខិត**

**សូមគោរពជូន ឯកឧត្តមទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

ឯកឧត្តមជាទីគោរព

យោងតាមការតែងតាំងនាយកក្រុមហ៊ុន (ឈ្មោះក្រុមហ៊ុន) ដែលខ្ញុំនឹងចូលកាន់តំណែងជា............ ខ្ញុំសូមជូនភ្ជាប់មកជាមួយនូវព័ត៌មាន (រួមមានប្រវត្តិសង្ខេប និងសំនួរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២) តាមប្រការ ១៣ នៃប្រកាសនេះ។

ខ្ញុំសូមធានាថាព័ត៌មាននេះពិតជាត្រឹមត្រូវ និងពេញលេញ ឆ្លើយតបទៅនឹងតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេស ខ្ញុំសូមធានាអះអាងថា ខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងប្រការ១៤ នៃប្រកាសនេះទេ។

ខ្ញុំសូមសន្យាថានឹងផ្តល់ព័ត៌មានស្តីពីការផ្លាស់ប្តូរណាមួយ ដែលទាក់ទងទៅនឹងព័ត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកក្រុមហ៊ុន ខ្ញុំសូមធានាថា នឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មានដែលទាក់ទងនឹងការចាត់តាំងរដ្ឋបាលនិងគណនេយ្យ ស្ថានភាពហិរញ្ញវត្ថុ ជាពិសេសចំពោះគុណភាពនៃទ្រព្យសម្បត្តិភតិសន្យា និងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់។

សូម ឯកឧត្តម ទេសាភិបាល មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីខ្ញុំ៕

ហត្ថលេខា

**ឧបសម្ព័ន្ធទី ២**

# ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពីឯកត្តជន ឬ ជនដែលចំរុងក្លាយទៅជា គណៈនាយក ភាគទុនិក នាយកចាត់ការ របស់អាជីវកម្មគតិសន្យាហិរញ្ញវត្ថុ

១. គោត្តនាម

............................................................................................................................................

២. នាមខ្លួន

............................................................................................................................................

៣. ឈ្មោះហៅក្រៅ

............................................................................................................................................

៤.១ សូមរៀបរាប់បំពេញលើគំរូនេះនូវនីតិសម្បទារបស់លោក ឧទាហរណ៍ដូចជាៈ គណៈនាយកបច្ចុប្បន្ន ឬ ជាអនាគតគណៈនាយក ភាគទុនិក ឬ នាយកចាត់ការ ឬ បុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

៤.២ សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈ តួនាទីទាំងនេះ

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

៤.៣ ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាត់បង្ហាញរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

៤.៤ សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឲ្យអ្នកដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណង ចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនសុំនោះ។

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

៥. អាសយដ្ឋានផ្ទាល់ខ្លួន

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

៦. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុនៈ

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

៧. កាលបរិច្ឆេទ (ថ្ងៃ/ ខែ/ ឆ្នាំ) និងទីកន្លែងកំណើត (គិតទាំងស្រុកនិងក្រុង)

...................................................................................................................................................

...................................................................................................................................................

៨. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ  សញ្ជាតូបនីយកម្ម  ការរៀបអាពាហ៍ពិពាហ៍)

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

៩. ឈ្មោះ និង អាសយដ្ឋាននៃធនាគារិករបស់លោក- លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

១០. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និង គុណវុឌ្ឍិវិជ្ជាជីវៈព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១១.១ ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពី ឈ្មោះ អាសយដ្ឋាន របស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១១.២ សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១១.៣ សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នក ចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយឬជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១២. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយកជាភាគទុនិក ឬជាអ្នកចាត់ការ ធ្លាប់ទទួលឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុង

ប្រទេសណាមួយដែរឬទេ បើមាន សូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

១៣. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធររាជរដ្ឋាភិបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

១៤. តើខ្លួនលោក-លោកស្រី ធ្លាប់ត្រូវគេហាមមិនឲ្យចូលប្រកបវិជ្ជាជីវៈជំនាញ
ឬបំរើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

១៥. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឲ្យបានច្បាស់លាស់។

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

១៦. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស នៅប្រទេសណា, តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ, តើធ្លាប់ត្រូវបានគេចោទប្រកាន់ ឬរកឃើញនូវកំហុសនៃការសម្អាតប្រាក់ដែរឬទេ, បើសិនជាមាន សូមបញ្ជាក់ករណីនីមួយៗឲ្យបានច្បាស់លាស់។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៧. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយទេ បើមានសូមបញ្ជាក់ឲ្យច្បាស់លាស់។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៨. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្មនិងទ្រព្យអកម្ម។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៩. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទី ឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២០. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួន ដូចមានបញ្ជាក់ក្នុងសំណួរ ៤.១ សាមីជនគួរតែបញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សំរាប់ការពិនិត្យពិចារណាឲ្យត្រឹមត្រូវតាមទម្រង់គតិយុត្ត។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗ ដែលពាក់ព័ន្ធដោយបង្វែរព័ត៌មានពិត ឬផ្តល់ឲ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

**ចូរកត់សំគាល់ឲ្យបានច្បាស់ថា:** រាល់ព័ត៌មានដែលបានផ្តល់ឲ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើក លែងតែករណីដែលផ្តល់ឲ្យស្របតាមទម្រង់គតិយុត្ត។

## សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយ ឬខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណប្រកបអាជីវកម្ម។

ខ្ញុំសូមបញ្ជាក់ជូនជាឧឡារិកថា ព័ត៌មានដែលបានឲ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេងឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពីរឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាន នៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណា លើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

ឈ្មោះ

....................................................................................................................................................

មុខងារ និងឋានៈដែលទទួលបន្ទុក

....................................................................................................................................................

ហត្ថលេខា...................................................................ថ្ងៃទី..........ខែ................ ឆ្នាំ...................

# តារាង
# នៃបទប្បញ្ញត្តិត្រូវបាននិរាករណ៍

១. ធ៧-០០-៥២ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៦-២២៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

២. ធ៩-៩៨-៣៨៦ ប្រ.ក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី ការយកកំរសេវាសំរាប់ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយ ធ៩-៩៨-៤១១ ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ។

៣. ធ៧-៩៨-៣៦៦ ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពី កំរិតកំណត់នៃការយកកំរៃសេវាផ្ទេរប្រាក់សំរាប់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយ ធ៩-៩៨-៤១១ ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ ។

៤. ធ៧-៩៦-១៥៣ ប្រ.ក ចុះថ្ងៃទី២៥ ខែ១០ ឆ្នាំ១៩៩៦ ស្តីពី អាជ្ញាប័ណ្ណរបស់ធនាគារដែលបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ត្រូវបានជំនួសដោយ ប្រកាស ធ៧-០០-០៤ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ ។

៥. ធ៧-៩៥-៧៣ ប្រ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អត្រាជាគោលសំរាប់បុនហិរញ្ញប្បទានត្រូវបានជំនួសដោយ ប្រកាស ធ៥-០១-២០១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១ ស្តីពី ការកំណត់អត្រាការប្រាក់ជាគោលសំរាប់បុនហិរញ្ញប្បទាន។

៦. ធ៧-៩៥-០៣ ស.រ.ណ.ន ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អនុបាតបង្កាហានិភ័យ (ភាពគ្រប់គ្រាន់នៃដើមទុន) ត្រូវបានជំនួសដោយ ប្រកាស ធ៧-០០-៤៦ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

៧. ធ៧-៩៥-០៣ ប.ប ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពីអនុបាតបង្កាហានិភ័យ ត្រូវបាន ជំនួសដោយ ប្រកាស ធ៧-០០-៤៦ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

៨. ធ៧-៩៥-០២ ស.រ.ណ.ន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី ការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជមកធនាគារជាតិនៃកម្ពុជា ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៦-២១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជនិងធនាគារឯកទេស។

៩. ធ៧-៩៥-០០១ ស.រ.ណ.ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហររបស់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៧-១៣៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

១០. ធ៧-៩៥-០១ ប.ប.ជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហររបស់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៧-១៣៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១១. ធ៧-៩៤-៧៨ ប្រ.ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ចំណាត់ថ្នាក់ និងនយោបាយក្នុងការធ្វើសំវិធានវត្ថុនៃបំណុលរបស់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយ ប្រកាស ធ៧-០០-៥១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់រួមទាំងការប្រាក់ដែលបានព្យួរ។

១២. ធ៧-៩៤-០០២ ស.រ.ណ.ន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ចំណាត់ថ្នាក់និងនយោបាយក្នុងការធ្វើសំវិធានវត្ថុនៃបំណុលនៃធនាគារពាណិជ្ជ ត្រូវបានជំនួសដោយប្រកាស ធ៧-០០-៥១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់រួមទាំងការប្រាក់ដែលបានព្យួរ។

១៣. ធ៧-៩៤-០០១ ស.រ.ណ.ន ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី រយៈពេលមូលដ្ឋានដែលត្រូវតំកល់ និងថ្ងៃត្រូវរាយការណ៍ ត្រូវបានជំនួសដោយសារាចរណែនាំថ្មីនៅរៀងរាល់ចុងឆ្នាំ។

១៤. ធ៧-៩៤-០០១ ប.ប៣ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពី លក្ខខណ្ឌសំរាប់ធនាគារពាណិជ្ជ ត្រូវបានជំនួសដោយបញ្ញត្តិដូចខាងក្រោម ៖

- ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩
- ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ធ៧-០១-១៣៦ ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តំកល់ធានាលើដើមទុន
- ធ៧-០១-១៨៧ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ
- ធ៧-០៦-២១០ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាសស្តីពីសោហ៊ុយបង្កើនដើមទុនសំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

១៥. ធ៥-៩៣-២០៨ ប្រ.ក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការប្រើប្រាស់ភាសា និងឯកត្តារូបិយវត្ថុសំរាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ត្រូវបានជំនួសដោយ ប្រកាស ធ៧-០៧-១៦៤ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សំរាប់ចុះកិច្ចបញ្ជីកាគណនេយ្យនិងរាយការណ៍។

១៦. ធ៥-៩៣-០១ ប.ប១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៣ ស្តីពី ការតំកល់ប្រាក់បញ្ញើដើមទុនសំរាប់ធានានៅធនាគារជាតិនៃកម្ពុជា របស់ធនាគារពាណិជ្ជដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវបានជំនួសដោយប្រកាស ៖

- ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តំកល់ធានាលើដើមទុន
- ធ៧-០៧-១៣៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៧. ធ៧-០០-៥១ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់ និង បំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ និង ធ៧-០២-១៤៥ ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់ និង បំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ត្រូវបានជំនួសដោយប្រកាស ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ចំណាត់ថ្នាក់ និង សំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៨. ធ៧-០៤-០១ ស.រ.ណ.ន ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ សារាចរណែនាំស្តីពី ឥណទានមិនដំណើរការសំវិធានធន និងកិច្ចបញ្ជិកាគណនេយ្យការប្រាក់ ត្រូវបានជំនួសដោយប្រកាស ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៩. ធ៧-០៥-០១ ស.រ.ណ.ន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ សារាចរណែនាំស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនចំពោះឥណទានសងរំលោះ ត្រូវបានជំនួសដោយប្រកាស ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២០. ធ៧-០០-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ជំនួសដោយប្រកាស ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

២១. ធ៧-០០-៣៩ ប្រ.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ ជំនួសដោយប្រកាស ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

២២. ធ៧-០៥-០១ ស.រ.ណ.ន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ សារាចរណែនាំស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់ធ្វើសវនកម្ម ប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានជំនួសដោយសារាចរណែនាំស្តីពី ធ៧-០១០-០០២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់ធ្វើសវនកម្ម ប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២៣. ធ៧-៩៣-២៨២ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពី ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងប្រាក់សុំខ្ចីចងការផ្សេងៗដោយស្ថាប័នរូបិយវត្ថុ ជំនួសដោយប្រកាស ធ៧-០៩-០៧៥ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២៤. ធ៧-៩៣-២៨៧ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពី របៀបតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងប្រាក់សុំខ្ចីចងការផ្សេងៗ ព្រមទាំងការរាយការណ៍ស្តីពីប្រាក់បំរុងនេះ ជំនួសដោយប្រកាស ធ៧-០៩-០៧៥ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២៥. ធ៧-០៧-០២ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ស្តីពី រយៈពេលមូលដ្ឋាន និងរយៈពេលដែលត្រូវតម្កល់និងថ្ងៃរាយការណ៍ ជំនួសដោយប្រកាស ធ៧-០៩-០៧៥ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២៦. ធ៥-៩៥-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ១៩៩៥ ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ជំនួសដោយប្រកាស ធ៧-០៩-២១៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ។

២៧. ធ៧-០៦-០៧៣ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការប្រើប្រាស់និងការការពារព័ត៌មានឥណទាន ជំនួសដោយប្រកាស ធ៧-០១១-១៤៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ។

២៨. ធ៧-០៦-១០១ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការដាក់ឲ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជំនួសដោយប្រកាស ធ៧-០១១-១៤៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ។

២៩. ធ៧-០៦-១០២ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជំនួសដោយប្រកាស ធ៧-០១១-១៤៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ។

៣០. ធ៧-០៦-១០៣ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជំនួសដោយប្រកាស ធ៧-០១១-១៤៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ។

៣១. ធ៧-០៦-១០៤ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតក្រុមប្រតិបត្តិនិងលេខាធិការដ្ឋាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជំនួសដោយប្រកាស ធ៧-០១១-១៤៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ។

៣២. ធ៧-០២-២០៦ ប្រ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ ស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណនៃការសំអាតប្រាក់នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជំនួសដោយប្រកាស ធ៧-០៨-០៨៩ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

៣៣. ធ៧-០៣-០២ ស.រ.ណ.ន ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៣ ស្តីពី ប្រតិបត្តិការសង្ស័យ និង គោលនយោបាយស្គាល់អតិថិជន ជំនួសដោយប្រកាស ធ៧-០៨-០៨៩ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ស្តីពី ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

៣៤ ធ៩-៩៩-១០០ ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងអាជីវកម្មត្បូងថ្ម និងលោហធាតុមានតម្លៃ ជំនួសដោយប្រកាស ធ៩-០៩-២៦២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ ។

៣៥. ធ៥-០១-៦៥ ប្រ.ក ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០១ ស្តីពី ការដាក់ឲ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មី ជំនួសដោយប្រកាស ធ៩-០៨-១៨៦ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី មូលប្បទានបត្រស្តង់ដារ។

៣៦. ធ៩-៩៨-៣៩៣ ប្រ.ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវករប្តូរប្រាក់ ជំនួសដោយប្រកាស ធ៩-០៩-២៣០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់។

៣៧. ធ៥-០២-៥៩៣ ប្រ.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពី សេចក្តីជូនដំណឹងស្តីពី ការផ្លាស់ប្តូរអត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក ជំនួសដោយប្រកាស ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ប្រាក់បញ្ញើទុនបំរុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុន ជារូបិយប័ណ្ណដុល្លារអាមេរិក។

# តារាង
# នៃបទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្មលើបទប្បញ្ញត្តិផ្សេងៗ

១. ធ៧-០៧-១៣៥ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ប្រកាសស្តីពីវិសោធនកម្មលើប្រកាស ស្តីពីអនុបាតសាធនភាពរបស់ធនាគារ។

២. ធ៧-០៦-២១០ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ប្រកាសស្តីពី ការកែសំរួលប្រកាសស្តីពីសោហ៊ុយបង្កើនដើមទុនសំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

៣. ធ៧-០៦-២០៨ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ប្រកាសស្តីពី ការកែសំរួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស។

៤. ធ៧-០៦-២០៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ប្រកាសស្តីពី ការកែសំរួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ។

៥. ធ៧-០៥-២១២ ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ ប្រកាសស្តីពី វិសោធនកម្មលើប្រកាសស្តីពីនិតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតំរូវបន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៦. ធ៧-០៤-២០៧ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ប្រកាសស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៧. ធ៧-០៤-២០៦ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ប្រកាសស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាព។

៨. ធ៧-០២-១៨៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសស្តីពី វិសោធនកម្មលើសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៩. ធ៧-០២-១៤៦ ប្រ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ប្រកាសស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០១-១៣៧ ប្រ.ក ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។

១០. ធ៧-០២-១៤៥ ប្រ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ប្រកាសស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១ ប្រ.ក ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ។

១១. ធ៧-៩៧-០២ ប.ប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី វិសោធនកម្មលើលក្ខខណ្ឌនៃការតំកល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗដោយស្ថាប័នរូបិយវត្ថុ។



រៀបចំបោះពុម្ពដោយ ធនាគារជាតិនៃកម្ពុជា